# ការព្យាបាលរបួសមិនអាចមើលឃើញ

## ផ្លូវទៅកាន់ក្ដីសង្ឃឹមនិងការងើបឡើងវិញនៅក្នុងពិភពលោកហិង្សា

## Healing Invisible Wounds




by Richard F. Mollica, M.D.

*translated into Khmer by Chan Hopson and colleagues*


*photograph by Marcus Halevi*

ការព្យាបាលរបួសគ្មានស្នាមៈជំហានទៅកាន់សេចក្តីសង្ឃឹមនិងភាពសះស្បើយឡើងវិញក្នុងពិភពលោកដ៏ឃោរឃៅ។

វេជ្ជបណ្ឌិត រិចឆឺដ អេហ្វ ម៉ល្លិកា

កម្មវិធីហាវើដផ្នែកភាពតក់ស្លុតរបស់ជនភៀសខ្លួន

សូមអរគុណដល់លោកស្រីសំបូរ-លី លោកស្រីច័ន្ទ-ហាប់សុន លោកវេជ្ជបណ្ឌិតចំរើន-ហេងនិង
លោកវឌ្ឍនា-ពឹង
ដែលបានចំណាយពេលវេលាដ៏ច្រើននឹងបានយកចិត្តទុកដាក់យ៉ាងខ្លាំងដើម្បីក្នុងការបកប្រែ
ពិនិត្យកែសម្រួលអត្ថបទនៃសៀវភៅ "ការព្យាបាលរបួសគ្មានស្នាមៈ
ជំហានទៅកាន់សេចក្ដីសង្ឃឹមនិងភាពសះស្បើយឡើងវិញក្នុងពិភពលោកដ៏ឃោរឃៅ"
ពីភាសាអង់គ្លេសទៅភាសាខ្មែរ។
យើងមិនអាចថ្លែងអំណរគុណឱ្យបានគ្រប់គ្រាន់ចំពោះការខិតខំរបស់លោកអ្នកដែលអាចអនុញ្ញាត

ឱ្យសហគមន៍ខ្មែរទូទាំងពិភពលោកអាចរកសៀវភៅនេះបានជាភាសាកំណើតរបស់ខ្លួន។
យើងសូមជូនពរដ៏ល្អបំផុតដល់លោកអ្នក
ហើយសូមកោតសរសើរនូវភាពសប្បុរសដ៏អស្ចារ្យរបស់លោកអ្នក។

និពន្ធដោយៈ **វេជ្ជបណ្ឌិតរីចឆឺដ អេហ្វ ម៉ល្លីកា**

*(Richard F. Mollica, M.D)*

**បកប្រែដោយៈ** លោកស្រី លី សំបូរ

**ពិនិត្យកែសម្រួលដោយៈ** លោកស្រី ហប់សុន ឥន្ទ ច័ន្ទ

វេជ្ជបណ្ឌិត ហេង ចំរើន

បន្ទាប់ពីព្យុះសង្ឃរា ទឹកជំនន់ និងរញ្ជួយផែនដី បន្ទាប់ពីជួបប្រទះអំពើទារុណកម្ម និងអំពើពិឃាតរង្គាល បន្ទាប់ពីយើងបានឃើញភាពអន្តរាយដ៏អស្ចារ្យ អាចធ្វើឡើងដល់មនុស្សផ្សេងៗទៀត ជាបុគ្គលម្នាក់ៗ ឬជាក្រុម តើយើងធ្វើយ៉ាងណាទៅ ដើម្បីអាចព្យាបាលរបួសនោះ?

លោករីចឆឺដ អេហ្វ ម៉ល្លីកា Richard F. Mollica បានចំណាយពេលជាង៣ ឆ្នាំ ជួយជនរងគ្រោះ នៃភាពវន្ទត់គ្រប់បែបយ៉ាង។ ពេលនេះគាត់បានដកស្រង់បទសម្ភាសន៍រាប់រយ និងការស្រាវជ្រាវរាប់សិបឆ្នាំ និងបទពិសោធន៍ផ្តល់ឱវាទរបស់គាត់ ដើម្បីបង្ហាញពីវិធីថ្មីក្នុងការជួយមនុស្សបំភ្លេចការឈឺចាប់របស់ខ្លួន ។ គន្លឹះ? មនុស្សមានសមត្ថភាពព្យាបាលខ្លួនឯងពីធម្មជាតិ។ មេរៀនដែលយើងអាចរៀនសូត្រ ពីជនដែលរួចផុតពីសេចក្តីស្លាប់ ពីបទពិសោធន៍ និងស្ថានភាពអស្ចារ្យនោះអាចបង្រៀនដល់យើងគ្រប់រូប អំពីរបៀបលៃលកដោះស្រាយប្រសើរនៅក្នុងដំណើរជីវិតប្រចាំថ្ងៃ។

នេះជាសម្រែកសង្វេគ មនុស្សធម៌ប្រកបដោយសេចក្តីសង្ឃឹម នៅក្នុងពិភពលោកពោរពេញទៅដោយភាពសាហាវ និងឃោរឃៅ ស្រែកប្រាប់យើងថាយើងអាចធ្វើលើសពីភាពរួចពីសេចក្តីស្លាប់ យើងអាចជួយរកកម្លាំង និងភាពជាសះស្បើយ ទោះបីជាយើងបានទទួលបទពិសោធន៍បែបណាក៏ដោយ។

រូបភាពគូរដោយលោក Raffaellp Sazio ផ្តល់ឡើងដោយសារមន្ទីរ Vatican លោកវេជ្ជបណ្ឌិត រីច ឆឺដ អេហ្វ ម៉ល្លីកា Richard F. Mollica, MDHarcourt, Inc.Orlando Austin New York San Diego Toronto London រក្សាសិទ្ធិ@2006 ដោយ រីចឆឺដ អេហ្វ ម៉ល្លីកា Richard F. Mollica រក្សាសិទ្ធិគ្រប់យ៉ាង។

ហាមថតចម្លងចំណុចណាមួយ នៃសៀវភៅបោះពុម្ពនេះ ឬផ្ញើរជាប្រព័ន្ធអេឡិចត្រូនិច ឬដោយបច្ចេកទេស មានរួមទាំងការថតចម្លង ការថតទុក ឬការរក្សាព័ត៌មាន និងការយកព័ត៌មាន ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខអក្សរពីអ្នកបោះពុម្ពផ្សាយ។

ការស្នើសុំសេចក្តីអនុញ្ញាត ថតចម្លងចំណុចណាមួយនៃរឿងនេះ ត្រូវតែបញ្ជូនតាមប្រព័ន្ធអ៊ីនធឺណេត Website: www.harcourt.com

សូមទំនង់ទំនង ឬផ្ញើរលិខិតទៅអាស័យដ្ឋានដូចខាងក្រោមនេះ ៖ Permission Department, Harcourt,Inc. 677 Sea Harbor Drive, Orlando, Florida 32887-677, Website: www.HarcourtBooks.com

បណ្ណាល័យរដ្ឋសភា Library of Congress Cataloging-in-Publication Data Mollica, Richard F.

Healing invisible wounds: Paths to hope and recovery in a violent world/Richard F. Mollica-1st ed. p. cm.Includes bibliographical references and index.

1. Political refugees-Mental Health. 2. Political Refugees-Counseling of.
2. Posttraumatic stress disorder-Treatment. 4. Psychic Trauma-Treatment.
3. Title

RC.451.4. P57M65 2006

616.8521-dc22 2006004785

ISBN: -13:978-0-15-101036-3 ISBN-10:0-15-101036-6

Text ser in Minion Cyrillic

រចនាដោយ : ឡរ៉ិន រ៉ាលី Designed by Lauren Rille

បោះពុម្ពនៅសហរដ្ឋអាមេរិក: Printed in the United States of America

បោះពុម្ពផ្សាយលើកទីមួយ( First Edition )

*ជូនចំពោះមាតាបិតា របស់ខ្ញុំ*

*ហ្វ្រែង និងអាយរីន ម៉ល្លីកា( Frank and Irene Mollica )*

# មាតិការឿង

**បុរេកថា**……………………………………………………………………………………………7

**ជំពូកទី ១ . ចំណាប់អារម្មណ៍ទៅលើមាគ៌ាថ្មី**………………………………………………………………11

ផ្នែក ១. នៅលើមាគ៌ាថ្មី……………………………………………………………………………11

១.១. មន្ទីរសុខភាព……………………………………………………………………………12

១.២. ការបង្កើតមធ្យោបាយព្យាបាលថ្មី…………………………………………………………16

១.៣. វិធីសាស្ត្រព្យាបាលចម្លែកអស្ចារ្យ………………………………………………………17

១.៤. ការបកស្រាយជម្រៅអត្ថបទ អត្ថន័យពាក្យ…………………………………………………18

ផ្នែក ២. ខណៈបើកបង្ហាញការពិត……………………………………………………………………20

២.១. ការរាវរកគន្លឹះ បើកបង្ហាញអាថ៌កំបាំងនៃភាពតក់ស្លុត……………………………………21

២.២. ការរកឃើញឥទ្ធិពលព្យាបាលដោយការថែទាំខ្លួនឯង…………………………………………23

២.៣. បក្សីតូចមួយចូលក្នុងដួងព្រលឹងរបស់ខ្ញុំ……………………………………………………27

២.៤. សេចក្ដីឈឺចាប់របស់ព្យាបាល………………………………………………………………29

**ជំពូកទី ២ . រឿងនិទានតក់ស្លុត**…………………………………………………………………………33

ផ្នែក ១. ប្រវត្តិគោលដៅនៃរឿងតក់ស្លុត…………………………………………………………………34

១.២. ចំណុចសំខាន់បួន(៤) នៃរឿងតក់ស្លុត…………………………………………………………36

១.៣. សេចក្ដីអធិប្បាយពិតនៃបុព្វហេតុ……………………………………………………………37

១.៤. អត្ថន័យ នៃវប្បធម៌ភាពតក់ស្លុត……………………………………………………………38

កថាខណ្ឌ ១. មើលហួសពីឆាកជីវិត ហួសរាំងនន……………………………………………………39

១.១. ទំនាក់ទំនងរវាងអ្នកស្ដាប់ និងអ្នកនិទានរឿង………………………………………………43

១.២. រឿងតក់ស្លុតរបស់ជនជាតិបូស្ន៊ា Bosnia……………………………………………………44

១.៣. កក្ដាពិត…………………………………………………………………………………46

១.៤. អត្ថន័យនៃភាពតក់ស្លុតតាមបែបវប្បធម៌……………………………………………………49

១.៥. មើលឆាកជីវិត នៅពីក្រោយរាំងនន……………………………………………………...50

១.៦. ទំនាក់ទំនង់-រវាងអ្នកស្តាប់-អ្នកនិទានរឿង………………………………………….52

**ជំពូកទី ៣ . ភាពអាប់យស( អាម៉ាស់មុខ )**…………………………………………………55

១. ការរំលាយវប្បធម៌អោយសាបសូន្យ……………………………………………………….56

២. អំពើព្រៃផ្សៃរំលោភផ្លូវភេទ…………………………………………………………...58

៣. ការបមផ្លាញភាពពិតសាមញ្ញ………………………………………………………...59

ផ្នែក ១. ចរិយាល្ងង់ខ្លៅ…………………………………………………………………………60

១.២. ភាពអាម៉ាស់មុខអារម្មណ៍សោកសង្វេគ នៃអំពើឃោរឃៅ…………………………63

១.៣. ការវិនាសនៃសេចក្តីចងចាំ………………………………………………………………65

១.៤. ភាពផ្ទុយគ្នាពីបែប នៃការអាម៉ាស់មុខ……………………………………………………68

១.៥. ហេតុផលជម្រុញអំពើយង់ឃ្នងការស្រមើលស្រម៉ៃចង់បង្កើតពិភពឥតខ្មោះ…………………70

**ជំពូកទី ៤ . ឥទ្ធិពលព្យាបាលដោយខ្លួនឯង**………………………………………………76

ផ្នែក ១. ភាពព្យាបាលដោយខ្លួនឯង……………………………………………………………..80

១.១. ជំនួយទៅលើការព្យាបាលដោយធម្មជាតិ………………………………………………..87

១.២. មជ្ឈដ្ឋានសម្រាប់ភាពជាសះស្បើយ…………………………………………………….90

**ជំពូកទី ៥ . ការនិទានរឿងជាវិធិសាស្រ្តព្យាបាល**……………………………………………93

ផ្នែក ១. ការនិទានរឿង មិនក្បោះក្បាយ……………………………………………………..94

១.១. អព្ភូតហេតុធម្មជាតិ………………………………………………………………...96

១.២. ទំនាក់ទំនងផ្នែកវប្បធម៌……………………………………………………………...99

១.៣. រឿងតក់ស្លុតកម្មបទសិល្បះ……………………………………………………..101

១.៤. ការនិទានរឿង………………………………………………………………………105

កថាខណ្ឌ ១. ការធ្វើអោយមានស្នាដៃនៅក្នុងពិភពលោក……………………………………108

**ជំពូកទី ៦ . សុបិន្តល្អ និងសុបិន្តអាក្រក់**………………………………………………..112

ផ្នែក ១. តួនាទីវិជ្ជមាន(ល្អ) របស់សុបិន្ត……………………………………………………..113

១.១. តួនាទីអវិជ្ជមាន(មិនល្អ) របស់សុបិន្ត……………………………………………………..116

១.២. ការចងចាំដែលបរាជ័យ……………………………………………………………….118

១.៣. ការប្រមូលផ្តុំយកសុបិន្តមកបរិយាយចែកចាយ………………………………………..122

កថាខណ្ឌ ១. ការតភ្ជាប់ពិតពខាងក្នុង និងខាងក្រៅ………………………………………………129

**ជំពូកទី ៧ . មធ្យោបាយសង្គម នៃការព្យាបាល**………………………………………………131

ផ្នែក ១. សហការ និងការរស់នៅជាមួយគ្នា……………………………………………………134

១.១. ទស្សនះសង្គម នៃការព្យាបាល……………………………………………………..137

១.២. ការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង……………………………………………….137

១.៣. ជំនឿ…………………………………………………………………………………146

១.៤. ការព្យាបាលនៅក្នុងដំណើរជីវិតប្រចាំថ្ងៃ………………………………………………154

**ជំពូកទី ៨ . ចលនាទាមទារដើម្បីថែរក្សាសុខភាព**………………………………………..157

ផ្នែក ១. ការប៉ាន់ស្មានល្អលើលក្ខណះជម្ងឺ ទៅថ្ងៃមុខ………………………………………..158

១.១. ជំហានសម្រាប់ព្យាបាលខ្លួនឯង……………………………………………………..161

១.២. ចំណីអាហារ និងការហាត់ប្រាណ……………………………………………………..162

១.៣. ភាពកាត់បន្ថយកមហឹង……………………………………………………………..164

១.៤. ការក្បត់ និងរួបរួមក្នុងក្រុមគ្រួសារ……………………………………………………166

១.៥. សេចក្ដីចងចាំ ដែលមិនអាចគ្រប់គ្រងបាន……………………………………………..169

ផ្នែក ២. ឥទ្ធិពលព្យាបាលដោយភាពសើចសប្បាយ…………………………………………..170

២.១. ឧបករណ៍របស់សង្គម សម្រាប់ការព្យាបាល……………………………………………172

២.២. ដំណើរការពីស្ថានភាពដ៏ហួសកម្រិតទៅតាមស្ថានភាពសាមញ្ញ……………………..173

២.៣. យុត្តិធម៌សង្គម……………………………………………………………………..176

**ជំពូកទី ៩ . សង្គមអ្នកព្យាយាម**………………………………………………………..178

ផ្នែក ១. ភាពព្ទកិច្ច ភាពប្រឈមមុខ និងភាពផ្ដេកផ្ដួល(ពឹងផ្អែក)……………………………..181

១.១. អំនួតក្រអឺតក្រទមផ្នែកពេទ្យ…………………………………………………………184

១.២. បំណងល្អបណ្ដាលអោយមានលទ្ធផលអាក្រក់…………………………………………………...186
១.៣. សិទ្ធិមនុស្ស ប្រយម និងការព្យាបាល…………………………………………………………189
១.៤. ថ្ងៃទាំសង្គមដែលមានជម្ងឺ……………………………………………………………………191
១.៥. ការព្យាបាលក្នុងសតវត្សទី ២១……………………………………………………………..193
**អវសានបទ(ទីបញ្ចប់):** …………………………………………………………………………..201

# បុរេកថា

មានក្មេងប្រុស ជនជាតិអ៊ីតាលី តូចម្នាក់ អាយុ ប្រហែលជា ១៥ឆ្នាំ សក់រួញ និងរញ៉េរញ៉ៃ បានដើរយ៉ាងលឿនតាមដងផ្លូវ តេណឹមីន(Tenement) ទីក្រុងហារលឹម(Harlem)ដើម្បីទៅជួប នឹងឪពុរបស់វានៅហាងលក់បន្លែ ផ្លែឈើ។ ក្មេងប្រុសតូចនេះ កោតសរសើរឪពុករបស់វា កាមឺឡូ (Carmelo) ជាមនុស្ស ពិសេសមួយសម្រាប់រូបវាគាត់មានពុកមាត់ពណ៌ក្រហមសង្ហា និងភ្នែកពណ៌ខៀវភ្លឺថ្លា។ គ្មានមិត្តភក្តិជនជាតិអ៊ីតាលីណាមួយរបស់វា មានឪពុកសង្ហា ដូចជាឪពុករបស់វាទេ វាសង្ឃឹមថានៅពេលដែលវាធំឡើង វានឹងមានពុកមាត់ដូច ការមីឡូដែរ។

នៅពេលដែលក្មេងប្រុសតូចនេះ ដើរមកដល់កាច់ជ្រុងជិតហាងនោះ វាឃើញមនុស្សមួយហ្វូងធំ កំពុងចោមរោមជុំជិតកេះដាក់ទំពាំងបាយជូរ និងក្រូចពោធិ៍សាត់។ គេទាំងនោះពុំមានទិញអ្វីទេ តែគេនាំគ្នាស្រែកដោយភ័យខ្លាច ជាភាសារអ៊ីតាលី វាក៏ត្បុលហើយវែកចូលទៅក្នុងហ្វូងមនុស្សមីរដេដាស់នោះ។ នៅពីមុនកេះដាកើបន្លែវាឃើញឪពុកវាដេកដួលនៅលើដី ឈាមពណ៌ក្រហម មានពណ៌ដូចជាពុកមាត់របស់គាត់ ហូរពាសពេញផ្ទៃមុខរបសើគាត់។ គាត់ត្រូវគេសម្លាប់ ក្មេងប្រុសពិតជាពុំដឹងថាអ្នកណាជាអ្នកសម្លាប់ឪពុករបស់វាឡើយ។

ពីរទៅបីឆ្នាំក្រោយមក ណៅពេលដែលក្មេងប្រុសនេះ មានវ័យ១៣ឆ្នាំ វាមានរោគរលាកខួរក្បាល រោគនោះពុំធ្វើអោយវាស្លាប់ទេ តែរោគនោះបានធ្វើអោយវាមើលលែងឃើញខ្លាំង រហូតដល់ចាត់ខ្វាក់ភ្នែក។ ក្រោយមកទៀយម្តាយរបស់វាក៏ស្លាប់ទៅទៀត នេះជាការបាត់បង់ដ៏រន្ធត់ តែអ្វីដែលគួរអោយអស្ចារ្យនោះ គឺនៅពេលដែលក្មេងនេះធំឡើងក្មេងប្រុសនេះពុំបណ្តាលអោយបុព្វហេតុទាំងនេះ បំផ្លាញសេចក្តីរីករាយនៅក្នុងជីវិតរបស់វាឡើយ។ គាត់មានហាងលក់កង់ នៅទីក្រុងហារលឹម ហើយគាត់ធ្វើអ្វីៗ បានដូចជាមនុស្សភ្នែកភ្លឺដែរ។ គាត់បានរៀបការមានភរិយា និងចិញ្ចឹមកូន៤នាក់ គាត់សង់ទូកកតោង ហើយបើកទូកនោះដើរកំសាន្តជុំវិញទីក្រុង។ គាត់ជួសជុល និងបើកបរថយន្ត ហើយរស់នៅពោរពេញទៅដោយសេចក្តីរីករាយ និងរស់រវើកដែលកូនរបស់គាត់ពុំដឹងពីសេចក្តីឈឺចាប់ពីអតីតកាលរបស់គាត់ឡើយ។ ផ្ទុយទៅវិញ កូនទាំងនោះដឹងក្តីឡើង ហើយបានដឹងឮថាជីតារបស់វា មានពុកមាត់ច្រើន ថែមទាំងមានពណ៌ក្រហមទៀត ក្មេងទាំងនោះចាប់ផ្តើមរីករាយ នឹងពិភពស្រម៉ៃដែលផ្តល់ឡើងដោយបុរសម្នាក់ដែលមើលស្ទើរតែលែងឃើញទៅហើយនោះ។ បុរសដ៏អស្ចារ្យម្នាក់នេះ គឺជាឪពុករបស់ខ្ញុំហ្វ្រែង ម៉ល្លីកា(Frank Mollica)ជាកូនប្រុសរបស់ជនអន្តោប្រវេសន៍អ៊ីតាលី ហើយខ្លឹមសារនៃដំណើរជីវិតរស់នៅរបស់គាត់បានបង្រៀនខ្ញុំនូវមេរៀនដ៏មានតម្លៃទៅលើភាពពិតនៃដំណើរជីវិត។

ខ្ញុំបានរៀនសូត្រពីឪពុករបស់ខ្ញុំ ថាយើងបង្កើតភាពពិតនៃជីវិតរបស់ពួកយើង ហើយជាញឹកញាប់ភាពពិតនោះមានលើសពីមួយបែបដែលយើងអាចជ្រើសយក ឪពុករបស់ខ្ញុំបានធ្វើអោយក្រុមគ្រួសាររបស់ខ្ញុំ មិត្តភក្តិនិងញាតិសន្តានរបស់យើងទាំងអស់ ភ្លេចខ្លួនថារូបគាត់ងងឹតភ្នែកស្ទើរតែទាំងស្រុងទៅហើយ។ នៅពេលដែលគាត់បដិសេធពុំបើកឡានទៅពេលយប់ ឬនៅពេលដែលគាត់សួររកស្នេតូស្កូបរបស់ខ្ញុំមក យកមកស្តាប់ម៉ាស៊ីន

ឡានហើយគាត់ ស្ទើរតែអារកាត់ជាក់ច្បាស់ថាជាឡាននោះខូចអ្វីជារឿយៗនៅពេលនោះហើយដែលខ្ញុំនឹកឃើញថា គាត់មើលស្ទើរតែលែងឃើញទៅហើយ។ គាត់ចូលចិត្តគូរគំនូរ និងគូររូបភាព ហើយគាត់បានជួយបងប្អូនរបស់ខ្ញុំ និងរូបខ្ញុំ គូរប្លង់ដ៏ល្អប្រណិត និងពណ៌ស្រស់រវើកដែលជាកិច្ចការសម្រាប់សាលារៀន។ រោងជាងឡានរបស់គាត់ រៀបចំដូចជាបន្ទប់រចនារបស់វិចិត្រករ ពុំមានភាពជារោងជួសជុលឡានទេ ។ គ្រឿងឧបករណ៍របស់គាត់រៀបតាមបន្ទះក្តារពណ៌តាមលំដាប់ បំពង់ស៊ីម៉ាំងឡានការរៀបតាមម៉ាក និងធុនធំ តូច។ ឪពុករបស់ខ្ញុំប្រាថ្នាជានិច្ចទៅលើ ” ការមើលឃើញ” ហើយសេចក្តីប៉ងប្រាថ្នានោះមានភាពលើសពីពិភពលោក មើលឃើញទៅទៀត។ គាត់តែងតែនិយាយប្រាប់ថា "មើលភាពពិតអោយច្បាស់ តែកុំបោះបង់សេចក្តីស្រម៉ៃរបស់អ្នក” ទោះបីជាជីវិតរបស់យើងជួបភាពលំបាកកំរិតណាក៏ដោយ យើងតែងតែអាចធ្វើអោយភាពលំបាកនោះ ក្លាយទៅជាភាពមានតម្លៃដោយប្រការអ្វីមួយ។

ច្រើនឆ្នាំក្រោយមក នៅពេលដែលគាត់កំពុងប្រឈម នឹងជម្ងឺមហារីកសួត ដែលបានរាលដល់ខួរក្បាលរបស់គាត់នៅក្នុងឱកាសដែលគាត់មានអារម្មណ៍ល្អ ដែលកម្រមានគាត់បាននិយាយ "កូនប្រុស ពុកចង់អោយឯងដឹងពីព្រឹត្តការណ៍ដ៏ក្រៀមក្រំ ដែលបានកើតឡើងដល់រូបពុក គឺមរណៈភាពឪពុករបស់ពុក ពុកនឹកគាត់ពេញមួយជីវិតរបស់ពុក” គាត់យំខ្សិបខ្សួល ពីរទៅបីម៉ោងក្រោយគាត់ក៏បានដាច់ខ្យល់ស្លាប់ទៅ។

ទោះបីជាជីវិតរបស់ឪពុកខ្ញុំ កាលពីដំបូងពោរពេញទៅដោយ ភាពតក់ស្លុត យ៉ាងណាក៏ដោយ គាត់តែងតែប្រឈមមុខ នឹងវិបត្តិនោះ ដោយនិយាយលេងសើចទៅវិញ។ ឃ្លាដែលគាត់ចូលចិត្តនិយាយសម្តែងពីទឹកចិត្តរបស់គាត់គឺ "កុំបារម្ភ វានឹងពិបាកជាងនេះទៅទៀត” ខ្ញុំពុំដែលគិតអំពីអត្ថន័យឃ្លាចំអកលេងដ៏ប្លែកនេះ រហូតទាល់តែនៅគ្រាមួយដែល ខ្ញុំបាននិយាយឃ្លានេះប្រាប់អ្នកធ្វើការជាមួយខ្ញុំនៅតំបន់អាស៊ីអាគ្នេយ៍អ្នកទាំងនោះបានទទួលបទពិសោធន៍អំពើសាហាវយង់ឃ្នង់ក្រៃលែង។ ប្រតិកម្មទូទៅ ទៅលើគតិបណ្ឌិតពាក្យរបស់ឪពុកខ្ញុំគឺជាសំណើចរីករាយ ក្រោយមកគេបានចារពាក្យរបស់ឪពុកខ្ញុំជាភាសារខ្មែរ នៅលើជញ្ជាំងមន្ទីរពិនិត្យសុខភាពក្នុងជំរុំជនភៀសខ្លួនខ្មែរ។ ឪពុករបស់ខ្ញុំបង្កើតភាពពិតនៃសេចក្តីសង្ឃឹម ដែលជនជួបប្រទះ នឹងតក់ស្លុតភាគច្រើនអាចយល់។ អ្នកទាំងនោះអាចជ្រើសយកពិភពបែបណា ហើយរៀបចមជីវិតរបស់ខ្លួន ចេញពីសេចក្តីតក់ស្លុត និងសេចក្តីឈឺចាប់របស់ខ្លួន ហើយសម្រេចថាការឈឺចាប់កំរិតណាដែលគេ នឹងបញ្ចេញអោយអ្នកផ្សេងទៀតដឹង។

ការរៀបចំរឿងតក់ស្លុតរបស់ប្រជាជនសាមញ្ញ ប្រមូលផ្តុំអោយទៅជាសម្លេងរបស់ជនរងគ្រោះកាន់តែមានច្រើនឡើង។ សម្រែកទ្រូតចេញពីប្រភពផ្សព្វផ្សាយ បុគ្គលិកសង្គ្រោះ និងអ្នកនយោបាយឮកាន់តែខ្លាំងឡើងៗ ។ ក្រោយពីព្យុះមហន្តរាយស៊ូណាមុី (Tsunami)នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៤ នៅលើទំព័រទីមួយក្នុងកាសែតអាមេរិកកាំង ល្បីល្បាញ បានបង្ហាញនូវរូបភាពមហន្តរាយដល់អ្នកអាន ដោយបង្ហាញស្ត្រីម្នាក់ដែលទ្រូតបាត់បង់វិញ្ញាណ។ ស្ត្រីនោះអង្គុយនៅលើកំរាលឥដ្ឋមន្ទីរពេទ្យណាហ្គាផាទីណាម(Nagapattinam) ប្រទេសឥណ្ឌា (India)ដ៏ល្វឹងល្វើយតែជុំជិតទៅដោយសពជនរងគ្រោះដោយព្យុះស៊ូណាមុី សពមួយចំនួនធំនៅក្នុងចំណោមសពទាំងនោះជាកូនរបស់គាត់។ ក្មេងនៅខាងមុខស្លាប់ដោយខ្លួនស្រាតននលគក នៅម្ខាងទៀតជើង

មនុស្សធ្លាក់ចេញពីក្រណាត់សគ្របសាកសព។ ទិដ្ឋភាពដ៏រន្ធត់នេះគ្មានផ្តល់អ្វីក្រៅពីសេចក្តីតក់ស្លុត និងសេចក្តីអស់សង្ឃឹមព្រមទាំងអារម្មណ៍ យើងបានជ្រៀតជ្រែកចូលទៅក្នុងបទពិសោធន៍ផ្ទាល់ខ្លួនដោយគ្មានគិត។ អ្នកកាសែតធ្វើការថ្លឹងថ្លែង នៅក្នុងចំណោមខ្លួនឯងថា តើគេគួរតែចាក់ផ្សាយជាសាធារណៈ នូវសម្រែកមនុស្សដែលគេបំរុង នឹងកាត់ក្បាល ឬមួយម៉ោងយ៉ាងណាដែរ។ ចំពោះយើងគ្រប់រូបដែលឃើញទិដ្ឋភាពរន្ធត់ទាំងនេះជារៀងរាល់ថ្ងៃ សំណួរដែលសំខាន់ជាងគេគឺ តើយើងសម្រួលទិដ្ឋភាពនេះដោយវិធីណាដោយពុំដើរចេញពីសេចក្តីអស់សង្ឃឹមខ្លាំង។

រឿងតក់ស្លុតរបស់ឪពុកខ្ញុំ និងរឿងរន្ធត់ចិត្តរាប់ពាន់រឿងដែលខ្ញុំបានស្តាប់ជាង ២៥ ឆ្នាំ ក្នុងនាមជា វេជ្ជបណ្ឌិត ព្យាបាលជនរួចផុតពីសេចក្តីស្លាប់ដោយអំពើសាហាវយង់ឃ្នង ហាក់ដូចជាពិបាកស្តាប់ និងពុំអាចកាត់ស្មានបានឡើយ។ តែរឿងនេះជារឿងពោរពេញដោយភាពស្រទន់ និងពិរោះរន្ថម នៅក្នុងចិត្តរបស់ជនម្នាក់ៗ សេចក្តីរន្ធត់នោះប្រែក្លាយទៅជាអ្វី ដែលកែប្រែខុសប្លែកទាំងស្រុង គ្មាននរណាអាចប៉ាន់ស្មានបានឡើយ។ រូបថតអ្នករួចផុតពីសេចក្តីស្លាប់ ពីព្យុះមហន្តរាយស៊ូណាមិដែលបានផ្សព្វផ្សាយជាពាណិជ្ជកម្មនៅក្នុងការសែត នឹងធ្វើអោយសេចក្តីឈឺចាប់ដែលពុំអាចបកស្រាយបានរបស់ខ្លួន ក្លាយទៅជាឥទ្ធិពលសម្រាប់ ការតស៊ូដោយស្ងៀមស្ងាត់ និងថ្លៃថ្នូរ។ ឥទ្ធិពលនេះគ្មានអ្វីជាអាថ៌កំបាំងទេ ឥទ្ធពល គឺមាននៅក្នុងស្ត្រីនេះ និងនៅក្នុងខ្លួនយើងគ្រប់ៗគ្នាដែលមានពីធម្មជាតិជាសតិអារម្មណ៍ និងឥទ្ធិពលសង្គមសំរាប់ព្យាបាលខ្លួនឯង នឹងជាសមត្ថភាពមានពីកំណើតដែលមនុស្សលោកគ្រប់រូបមាន ដើម្បីកសាងឡើងវិញនីវរាងកាយ និងសតិអារម្មណ៍របស់ខ្លួនប្រកបទៅដោយកម្លាំងពេញលេញ និងសុខភាពជីវិត ដោយពុំគិតពីកំរិតខូចខាតដេលកើតមានឡើងពីមុនមក។

រឿងតក់ស្លុតនៅក្នុងសៀវភៅនេះ នឹងបង្ហាញនូវការវិវឌ្ឍន៍ឥទ្ធិពលព្យាបាល ដែលចាប់ផ្តើមដំណើរការឡើងនៅពេលដែលភាពសាហាវយង់ឃ្នងព្យាបាទជីវិត។ រឿងនេះអាចធ្វើអោយមានអារម្មណ៍ថា ជារឿងរបស់ពិភពផ្សេងៗ និងជារឿងធម្មតា តែស្ថានភាពអស្ចារ្យអាចជាភាពទាក់ទងនៅក្នុងដំណើរជីវិតប្រចាំថ្ងៃ។ ជីវិតរបស់យើងអាចពោរពេញទៅដោយសេចក្តីរីករាយ ដោយយើងអបអរសាទរជីវិតអង់អាចរបស់មនុស្សដែលឆ្លងកាត់វិបត្តិតក់ស្លុតក្នុងជីវិត។ តែយើងក៏អាចភ្លេចនូវទិដ្ឋភាពតក់ស្លុតដែលកើតមាននៅក្នុងដំណើរជីវិតរបស់យើង ជាពិសេសនៅពេលដែលការឈឺចាប់នោះបណ្តាលកើតឡើងដោយមនុស្សលោកផ្សេងទៀត។ យើងគ្រប់រូប នឹងឆ្លងកាត់ភាពរន្ធត់ណាមួយទាំងនេះ ដោយរបួសរាងកាយ ជម្ងឺអំពើហឹង្សានៅក្នុងក្រុមគ្រួសារ ឬមរណៈភាពមនុស្សម្នាក់ជាទីស្រលាញ់របស់យើង។ សៀវភៅនេះ នឹងបើកបង្ហាញអំពើឥទ្ធពលព្យាបាលដែលមាននៅក្នុងរូបយើងគ្រប់ៗគ្នា ដែលអាចជួយយើងអោយធូរស្បើយពីបទពិសោធន៍រន្ធត់នៅក្នុងជីវិត។ អ្នកដែលឆ្លងកាត់ភាពឃោរឃៅនៅក្នុងជិវិត ដូចជាសង្គ្រាម និងទារុណកម្មដែលអាចជាផ្លូវណែនាំដោយបង្រៀនយើងនូវវិធីលៃលកដោះស្រាយ និងការសម្រេចជោគជ័យធម្មតា អោយកាន់តែមានច្រើនឡើងនៅក្នុងពិភពទូទៅ ។ "បើសិនជាគេអាចធ្វើបាន យើងក៏អាចធ្វើបានដែរ" យើងក៏អាចរៀនលៃលកដោះស្រាយអំពើឃោរឃៅ នៅក្នុងសង្គមទាំងមូលរបស់យើង។

ខណៈដែលការពិភាក្សាជាសាធារណៈអំពីសតិអារម្មណ៍ ដែលប៉ះទង្គិចដោយអំពើសាហាវយង់ឃ្នង មានរួមទាំងភាពមហន្តរាយដោយធម្មជាតិ បានផ្សព្វផ្សាយជាទូទៅ ទៅហើយនោះ ដែលស្ទើរតែគ្មានសោះកាលពី២៥ឆ្នាំមុន។ ជាការពិតវាជាណាស់ជារឿងដែលគេហាមឃាត់មិនអោយនិយាយ នៅពាក់កណ្តាលឆ្នាំ ១៩៨០ ខ្ញុំបានទទួលការបដិសេធរួមប្រជុំពីគណៈអភិបាលជាន់ខ្ពស់អង្គការសហប្រជាជាតិជនភៀសខ្លួន ដោយគាត់មានជំនឿយ៉ាងជាក់ច្បាស់ថាជនភៀសខ្លួនពុំមានបញ្ហាអារម្មណ៍ ឬបញ្ហាសតិអារម្មណ៍ ដែលកើតឡើងដោយការចាត់តាំងអោយរស់នៅកន្លែងផ្សេង ឬភាពគ្មានទីជម្រកច្បាស់លាស់។ នៅគ្រានោះអ្នកបង្កើតច្បាប់អន្តរជាតិ និងច្បាប់អាមេរិកកាំង នឹងអង្គការមនុស្សធម៌ ពុំព្រមទទួលស្គាល់របួសសតិអារម្មណ៍គ្មានស្នាម ដែលប៉ះពាល់ដល់មនុស្សគ្រប់រូបដែលបានឆ្លងកាត់ភាពរន្ធត់ទូទាំងពិភពលោក បច្ចុប្បន្ននេះ មានការទាមទារអោយយកវិធីវិសាស្រ្តថ្មី និងការអនុវត្តន៍ជារឿយៗ មកជួយរបួសទាំងនោះ។

អំពើឃោរឃៅបង្កើតកំណត់ពេលប្រវត្តិសាស្រ្តថ្មី ដែលកើតឡើងទៅលើមនុស្ស ហើយចាប់មានរូបរាងឡើងនៅពេលដែលមានការប្រេះស្រាំនៅក្នុង"ពិភពលោកទាំងមូល" នៃដំណើរការជីវិតទូទៅ។ អ្វីៗទាំងអស់ដែលជាទម្លាប់ប្រចាំ និងជាភាពដែលអាចប៉ាន់ស្មានបានមួយរំពេចនោះស្រាប់តែប្រែប្រួលថ្មីទាំងអស់ ហើយក្លាយជាទីកន្លែងប្លែកផ្សេង។ ការប្រែប្រួលនេះជាព្រឹត្តិការណ៍ប្រវត្តិសាស្រ្ត ដែលលាតត្រដាងភាពចរាចរណ៍នៅក្នុងសង្គម និងទំនាក់ទំនងនយោបាយដែលជាលទ្ធផលសំខាន់ៗ ពុំមែនសម្រាប់តែបុគ្គលតែម្នាក់ៗនោះទេ តែវាជាលទ្ធផលសំខាន់ៗ សម្រាប់ពិភពលោក។ កំណត់ពេលទាំងនេះញឹកញាប់កើតឡើងដោយហេតុការណ៍ឃោរឃៅ ទៅតាមល្បមដាប់របស់មនុស្សម្នាក់ៗ តែភាគច្រើនវាកើតមានឡើងតាមលំដាប់របស់សហគមន៍។ នៅក្នុងស្ថានភាពទាំងនេះ ព័ត៌មានភ្ញាក់ផ្អើលអាច ឬកើតមានឡើងនៅពេលដេលភាពពិតថ្មី ផុសចេញឡើង។ អ្នកដែលប្រព្រឹត្តឧក្រិដ្ឋកម្ម និងអ្នកដែលផ្សព្វផ្សាយដំណឹងកេងប្រវ័ញ្ចទៅលើភាពរន្ធត់អំពើឃោរឃៅ ដោយផ្តោតអារម្មណ៍ទៅលើតែភាពពិត នៃចំណុចណាដែលគេចង់បើកចំហ ។ គួរអោយស្តាយណាស់ ដោយអ្នកទាំងនោះ ពុំរង់ចាំមើលថាតើមានអ្វីកើតឡើង នៅពេលដែលរឿងរ៉ាវទាំងនោះចប់សព្វគ្រប់ ។ ភាពប្រែប្រួលព័ត៌មានភ្ញាក់ផ្អើលទាំងនោះ គឺបានយកមកបកស្រាយតាមរយៈ ការរៀបរាប់អំពីដំណើរជីវិតរបស់អ្នកដែល រៀបរាប់ពីរឿងរបស់ខ្លួននៅក្នុងសៀវភៅនេះ ដំណើរជិវិតជាទូទៅរបស់យើងពុំអាចជៀសផុតពីភាពសោកនាដកម្ម និងសេចក្តីឈឺចាប់បានឡើយ តែគេអាចរកអត្តន័យថ្មី នៅពេលដែលគេបញ្ចូលវាទៅក្នុងគម្រោងព្យាបាលទូលំលាយ។

# ជំពូកទី១ ចំណាប់អារម្មណ៍

## ផ្នែក ១. ទៅលើមាត៌ាថ្មី

ទោះបីជាយើងគ្រប់រូបដឹងថា ទុក្ខសោកជាបទពិសោធន៍ជាសាកលសំរាប់មនុស្សលោក តែពិភពលោកដ៏ទំនើបនៅតែពុំដឹងថា ត្រូវនិយាយ និងយល់ដឹងអំពីបទពិលោធន៍ដ៏ជូរចត់ដែលមនុស្សធ្វើអោយមនុស្សឈឺចាប់ជារៀងរាល់ថ្ងៃដោយរបៀបណានៅឡើយ។ សោកនាកម្ម និងភាពហួសពីការស្មាននៃអំពើឃោរឃៅ ដែលមនុស្សលោកធ្វើឡើង ទៅលើមនុស្សលោកធ្វើអោយមនុស្សមើលឃើញតែភាពអាក្រក់ដោយងាយស្រួល ហើយគិតថាគ្មានអ្វីអាចទប់ស្កាត់អំពើឃោរឃៅនេះ ឬអាចជាសះស្បើយបានឡើយ។ មូលហេតុមួយ ដែលធ្វើអោយមានអារម្មណ៍បែបនេះកើតមានឡើង គឺរបួសធ្ងន់ធ្ងរដែលបង្កើតឡើងដោយអំពើហឹង្សារបស់មនុស្សលោក ជារបួសដែលគ្មានស្នាម ។ ស្នាមរបួសរាង្គកាយអាចមើលឃើញ និងព្យាបាលដោយវិជ្ជាសាស្ត្រពេទ្យ ប៉ុន្តែ របួសសតិអារម្មណ៍ និងរបួសផ្លូវវិញ្ញាណជារបួសដែលមើលមិនឃើញ ឫជាភាពអាថ៌កំបាំង។

ខ្ញុំបាទចំណាយពេល ចំនួនជាង ម្ភៃប្រាំឆ្នាំ ព្យាបាលមនុស្សដែលធ្លាប់បានឆ្លងកាត់នូវអំពើហឹង្សា លើមនុស្សសាមញ្ញដែលជាជនភៀសខ្លួន ជាជនរងគ្រោះដោយអំពើទារុណកម្ម ឬភេរវកម្ម និងជាជនរួចផុតពីសេចក្តីស្លាប់ដោយសង្គ្រាម ។ បទពិសោធន៍របស់ខ្ញុំបង្ហាញនូវរបៀបគិតថ្មី ទៅលើអំពើហឹង្សារបស់មនុស្សលោក និងភាពជាសះស្បើយកាយសម្បទា និងសតិអារម្មណ៍ដែលបានខូចខាតដោយអំពើទាំងនោះ។ ចំណុចយល់ដឹងច្បាស់ដែលខ្ញុំហៅថា ការរកឃើញដោយវិទ្យសាស្ត្រ ឬការបញ្ចេញអោយដឹង កើតមានឡើងនៅពេលដែលខ្ញុំធ្វើការទាក់ទងផ្ទាល់ជាមួយអ្នកជម្ងឺរបស់ខ្ញុំ ។ ខ្ញុំហ្នឹងបន្តការតាមដានការសន្និដ្ឋាន ជារបៀបវិទ្យាសាស្ត្រដោយវិជ្ជាសាស្ត្រពេទ្យ នៅពេលដែលមានការបញ្ជាក់ថាត្រឹមត្រូវ ហើយបញ្ចូលវាទៅក្នុងការព្យាបាល ការរកឃើញនេះបង្កើតជាមូលដ្ឋាន សំរាប់របៀបព្យាបាលដែល នឹងពិពណ៌នានៅក្នុងសៀវភៅនេះ។

វិធីរបស់ខ្ញុំ នៅក្នុងកិច្ចការងារនេះ គឺជាវិធីបទបែនមួយដោយ ខ្ញុំបានទទួលការសិក្សា នៅវិទ្យាល័យបច្ចេកទេស ព្រមទាំងបានសិក្សាកម្មវិធីវិស្វករ ផ្នែករូបវិទ្យា គីមីវិទ្យា និងគណិតវិទ្យា ខ្ញុំបានដឹងតាំងពីដំបូងថាវិទ្យាសាស្ត្រ ពុំអាចដោះស្រាយបញ្ហាសីលធម៌ និងបញ្ហាមនុស្សលោកនៅក្នុងសង្គមបានឡើយ ។ បញ្ហាទាំងនេះអាចដោះស្រាយបានយ៉ាងល្អប្រសើរតាម ផ្នែកមនុស្សធម៌ និងសិល្បះ ។ នៅមហាវិទ្យាល័យខ្ញុំបានរៀនយកមុខវិជ្ជាគីមី និងសាសនា ទោះបីជារូបខ្ញុំ ពុំដែលបានជួបវេជ្ជបណ្ឌិតក្រៅពីពេលពិនិត្យសុខភាពរាង្គកាយ ជាទូទៅក៏ដោយ ខ្ញុំនឹកស្រម៉ៃថាក្នុង ផ្នែកវិជ្ជាពេទ្យ ខ្ញុំអាចយកចំណូលចិត្តរបស់រូបខ្ញុំក្នុង ផ្នែកវិទ្យាសាស្ត្រ សាសនា ទស្សនះវិជ្ជា និងសិល្បះ ជួយធ្វើអោយស្ថានភាពរបស់មនុស្សលោក អោយមានភាពប្រសើរឡើង ។ នៅពេលដែលខ្ញុំកំពុងតែសិក្សានៅសាលាវិជ្ជាពេទ្យ នៃរដ្ឋនីវម៉ិចស៊ីកូ New Mexico ខ្ញុំធ្វើការនៅភូមិស្ពេនីសដែលដាច់ស្រយាលនៅតាមតំបន់ខាងត្បូងរដ្ឋនីវម៉ិចស៊ីកូ និងកុលសម្ព័ន្ធជនជាតិអ៊ិនឌៀន Indian ហ្សូនី Zuni និង ជីម៉េ ភុយប្លូ Jemez Pueblo ដោយផ្តល់សេវាដល់អ្នកជម្ងឺក្រីក្រ ដែលរស់នៅក្នុងមជ្ឈដ្ឋានពោរពេញទៅដោយវប្បធម៌ និងសម្បត្តិធម្ម

ជាតិ ។ ក្រោយមកខ្ញុំបានសិក្សាការហ្វឹកហ្វឺនយកជំនាញផ្នែក សតិអារម្មណ៍ ហើយសិក្សាយកមុខវិជ្ជា សាសនា និងទស្សនៈវិជ្ជាជាន់ខ្ពស់ នៅពេលជាមួយគ្នានោះដែរ ។ សាលាសាសនាបានផ្តល់នូវទម្រង់ សីលធម៌ដល់ការសិក្សាជំនាញរបស់ខ្ញុំ ផ្នែកវិជ្ជាសាស្ត្រពេទ្យ និងវិទ្យាសាស្ត្រ ព្រមទាំងផ្នែកប្រកបការងាររបស់ខ្ញុំនៅពេលអនាគតកាលជាមួយ និងជនរួចផុតពីសេចក្តីស្លាប់ដោយអំពើហឹង្សាសាហាវយង់ឃ្នង។ ចំណូលចិត្តរបស់ខ្ញុំ ក្នុងផ្នែកសិល្បៈ និងអក្សរសាស្ត្រក៏ជួយដល់ការងាររបស់ខ្ញុំ ដោយផ្តល់នូវវិធីប្រៀបធៀបដ៏ជ្រៅជ្រះទៅលើភាពអាថ៌កំបាំងដែល ផ្នែកវិទ្យាសាស្ត្រ និងផ្នែកវិជ្ជាពេទ្យពុំអាចបកស្រាយបាន ។

## ១.១ មន្ទីរសុខាភាពថ្មី

នៅពេលដែលខ្ញុំបានមកដល់ ហាវើដ Harvard លោក វេជ្ជបណ្ឌិតវ័យក្មេង នៅក្នុងឆ្នាំ១៩៨០ ខ្ញុំដឹងថាខ្ញុំចង់ផ្តល់សេវាសុខភាព និងសេវាព្យាបាល ផ្នែកសតិអារម្មណ៍ប្រកបដោយគុណភាពដ៏ខ្ពស់បំផុត ដល់ប្រជាជនក្រីក្រដែលរស់នៅក្នុងសហគមន៍របស់ខ្ញុំ ទោះបីជាមានឧបសគ្គ ខាងផ្នែកថវិការ ឬនយោបាយបែបណាក៏ដោយ។ នៅពេលរកមើលឃើញប្រជាជនដែលត្រូវការជំនួយនៅក្នុងទីក្រុង បូស្តុន Boston ខ្ញុំបានរកឃើញជនភៀសខ្លួនដែលមកពីអាស៊ីអាគ្នេយ៍ ជាប្រជាជនក្រីក្រហើយ ស្ទើរតែត្រូវគេពុំរាប់បញ្ចូលក្នុងសេវាផ្នែកសាធារណៈ ផ្នែកឯកជន និងផ្នែកសុខភាពថែមទៀតផង ។ ដោយមានការជួយពីលោក ជេម ឡាវែល (James Lavelle) បុគ្គលិកសង្គមកិច្ចវ័យក្មេង ពោរពេញទៅដោយគំនិតខ្ពង់ខ្ពស់ ហើយកំពុងតែធ្វើការនៅក្នុងសហគមន៍ជនភៀសខ្លួន យើងក៏សំរេចបើកមន្ទីរសុខភាពតូចមួយនៅតំបន់ប្រាយតុន (Brighton) នៅក្នុងទីក្រុង បូស្តុន (Boston) ដែលពីដំបូងមានឈ្មោះថាមន្ទីរសតិអារម្មណ៍ឥណ្ឌូចិន (Indochinese Psychiatry Clinic) ហើយក្រោយមកត្រូវបានហៅថា កម្មវិធីជម្ងឺតក់ស្លុត របស់ជនភៀសខ្លួន នៃសាកលវិទ្យាល័យ ហាវើដ (Harvard Program in Refugee Trauma) ។ ក្រុមការងារមួយចំនួនតូចរបស់យើងមួយក្រុមនេះ បានទទួលស្គាល់ថាជាមន្ទីរសុខភាពពិនិត្យ ផ្នែកសតិអារម្មណ៍ជាដំបូងគេនៅក្នុងសហរដ្ឋអាមេរិក ដោយគ្មានភាពចាប់អារម្មណ៍ទុកជាមុន។

នៅក្នុងពេលនោះ ផ្នែកសុខភាព និងផ្នែកសតិអារម្មណ៍ គឺលំអៀងទៅតាមពណ៌សម្បុរ និងភេទ ទោះបីជាមានការជួយជ្រោមជ្រែងពីលោក ហ្វ្រីច រេកឡិច (Fritz Redlich) សាស្ត្រាចារ្យ ផ្នែកសតិអារម្មណ៍សាកលវិទ្យាល័យយេល (Yale) ដែលជាអ្នកបង្ហាត់ដល់រូបខ្ញុំ។ លោក រេកឡិច (Redlich) បានបង្ហាញនៅក្នុងការសិក្សាស្រាវជ្រាវរបស់គាត់ នៅដើមឆ្នាំ១៩៥០ ទោះបីជា រោគសតិអារម្មណ៍រាតត្បាតច្រើននៅក្នុងចំណោមជនដែលមានជីវភាពក្រីក្រក៏ដោយ ក៏អ្នកទាំងនោះបានទទួលការព្យាបាលសតិអារម្មណ៍ខុសគ្នា ពីជនដែលមានជីវភាពមធ្យម និងជនមានជីវភាពខ្ពស់។ អ្នកជម្ងឺក្រីក្រជាញឹកញាប់គេអោយថ្នាំព្យាបាល ហើយពុំសូវបានទទួលការព្យាបាល ផ្នែកសតិអារម្មណ៍ឡើយ ដោយគេចាត់ទុកថា អ្នកទាំងនោះគ្មានសមត្ថភាពប្រើប្រាជ្ញាភ្លឺថ្លារបស់ខ្លួន ទៅលើបញ្ហាសតិអារម្មណ៍ទេ។ គ្រូពេទ្យផ្នែកសតិអារម្មណ៍កម្រព្យាបាលអ្នកទាំងនេះណាស់ ផ្ទុយទៅវិញ ជនក្រីក្រទាំងនេះទទួលបានការព្យាបាលពីបុគ្គលិក ផ្នែកសតិអារម្មណ៍ដែលទទួលបានការហ្វឹកហ្វឺនបន្ទាប់បន្សំ។

ចំនួន ម្ភៃប្រាំឆ្នាំ ក្រោយមកទើបខ្ញុំអាចរកឃើញតាមរយៈ ការសិក្សាស្រាវជ្រាវ តាមដានពីការព្យាបាលដោយលំអៀងទៅលើជនក្រីក្រ និងជនស្បែកខ្មៅនៅតែមានសភាពដដែល ទោះបីជា មានការខំប្រឹងប្រែងដ៏លើសលប់ពី រដ្ឋកិបាលសហព័ន្ធក្នុងការកែសម្រួលស្ថានភាពនោះ តាមរយៈ ការជួយសម្រួលដល់ការទទួលសេវាព្យាបាល នៅមណ្ឌលសតិអារម្មណ៍សហគមន៍ ។ ជនភៀសខ្លួនអាស៊ីអាគ្នេយ៍ដែលទើបតែមកដល់ថ្មីៗ នៅតែត្រូវបញ្ជូនទៅក្នុងចំណោមអ្នកជម្ងឺជីវភាពក្រីក្រ ដែលទទួលការថែទាំសុខភាព និងការថែទាំសតិអារម្មណ៍បន្ទាប់បន្សំ ពីព្រោះពួកគាត់មានបញ្ហាសង្គមជាច្រើន ហើយពុំមែន ជាជនជាតិស្បែកស និងមិនយល់ដឹងអំពីរបៀបព្យាបាលផ្នែកសុខភាព ផ្លូវចិត្តបែបអាមេរិកកាំង ជាពិសេសការព្យាបាលសតិអារម្មណ៍។

ជនភៀលខ្លួនទាំងអស់ដែលចូលមកសហរដ្ឋអាមេរិក បានទទួលការពិនិត្យសុខភាពជម្មតា នៅតាមមណ្ឌលសុខភាព ជាទូទៅដែលមានការឧបត្ថម្ភដោយរដ្ឋាភិបាលសហព័ន្ធ ។ ជនភៀសខ្លួនមកពីអាស៊ីអាគ្នេយ៍រាប់ពាន់នាក់ ជនរងគ្រោះដោយសង្គ្រាមមកពីប្រទេសវៀតណាម ចូលមកពពាក់ពពូនតាមមណ្ឌលទាំងនេះ ដើម្បីកសាងជីវិតជាថ្មីនៅលើទឹកដីសហរដ្ឋអាមេរិក។ ក្រុមអ្នកជំនាញរបស់យើងរងចាំជួយព្យាបាល បញ្ហាសតិអារម្មណ៍របស់អ្នកជម្ងឺទាំងនោះ។ នៅមន្ទីរសុខភាព ប្រាយតុន (Brighton) ដែលជាញឹកញាប់អ្នកជម្ងឺត្រូវបានបញ្ជូនដោយគ្រូពេទ្យប្រចាំខ្លួនរបស់គេ មកមន្ទីរសុខភាពនេះ។ បុគ្គលិករបស់យើងមានរួមទៅដោយលោក ជីម ឡាវ៉ែល (Jim Lavelle ទា យ៉ាង Ter Yang) មេកន្ទ្រាញជនជាតិម៉ុង ជាកុលសម្ព័ន្ធវិញ្ញាណនិយមប្រទេសឡាវ លោកបិន ទូ ដែលជាអតីតនាយទាហ៊ានវៀតណាម ដែលគេស្គាល់ថាជា "ហ្វ្រែង ស៊ីណាត្រា (Frank Sinatra ) របស់ទ័ពវៀតណាម " និង រូស្សា លេក (Rosa Lek) ជាស្ត្រីខ្មែរវ័យក្មេងដែលមានមុខងារ ជាអ្នកបូមឈាមនៅមន្ទីរពិសោធន៍។

មន្ទីរសតិអារម្មណ៍បើកទ្វារធ្វើការជាដំបូង ចំនួនកន្លះថ្ងៃក្នុងមួយអាទិត្យ សេវាយើងឥតគិតថ្លៃ ហើយបុគ្គលិកយើងក៏គ្មានប្រាក់ខែដែរ អ្នកជម្ងឺបញ្ជូនទៅសន្និកសន្ទាប់ ដោយគ្រូពេទ្យដែលជាសហការីរបស់យើង។ ពេលល្ងាចខ្លះយើងមានអ្នកជម្ងឺជាជនភៀសខ្លួនរហូតដល់ទៅ២០នាក់ ជនភៀសខ្លួនទាំងនេះពុំចាំបាច់ទទួលការបញ្ចុះបញ្ចូលទៅលើសារៈសំខាន់ប្រយោជន៍ នៃមន្ទីរសុខភាពនេះទេ គេមានអារម្មណ៍ទុកចិត្តមួយរំពេច នៅពេលដែលគេបានទទួលការស្វាគមន៍ដោយវេជ្ជបណ្ឌិត បុគ្គលិកសង្គមកិច្ច និងសមាជិកដែលបានទទួលសេចក្តីគោរពនៅក្នុងសហគមន៍របស់ខ្លួន។ សហការីឥណ្ឌូចិនរបស់យើង ពុំដែលបំពេញមុខងារជាអ្នកបកប្រែភាសាឡើយ អ្នកទាំងនោះជាសមាជិកក្រុមព្យាបាលដែលជាសហការដ៏សំខាន់ ក្នុងផ្នែកវប្បធម៌ចម្រុះ គេជាគន្លឹះធ្វើអោយមន្ទីរសុខភាពបានទទួលជោគជ័យ។

នៅពេលដែលខ្ញុំបានស្គាល់រឿងរបស់ លក្ខិណា ស្ត្រីខ្មែរចំណាស់ម្នាក់ ដែលជាអ្នកជម្ងឺដំបូងគេ របស់ខ្ញុំនៅក្នុងមន្ទីរពេទ្យពិនិត្យសុខភាព ខ្ញុំដឹងថាចំណេះដឹងជាទូទៅ ផ្នែកសតិអារម្មណ៍ដែលខ្ញុំបានទទួលពីការរៀនសូត្រនោះ ពុំអាចជួយគាត់បានឡើយៈ

នៅក្នុងឆ្នាំម្សាញ់ ព្រះអាទិត្យបានចូលមករស់នៅក្នុងរាង្គកាយរបស់ខ្ញុំ វាធ្វើអោយខ្លួនខ្ញុំញាប់ញ័រសព្វរាង្គកាយរហូតដល់ខ្ញុំបានដួលសន្លប់ ។ នៅពេលដែលខ្ញុំដឹងខ្លួនហើយបើកភ្នែកឡើង ខ្ញុំបានឃើញតែភាពងងឹតស្លុប ។ ហើយខ្ញុំក៏ដើរទៅវាលស្រែ ដើម្បីសួរគេថា តើម៉ោងប៉ុន្មានហើយ មានសម្លេងស្រែកឡើងថា "ម៉ោងដប់"។ មួយរំពេចនោះសត្វទីទុយក៏ចាប់ផ្តើមយំ ហើយសត្វផ្សេងៗទៀត ជាតំណាងអោយសេចក្តីស្លាប់ស្រែកថ្ងូរជុំវិញខ្លួនខ្ញុំ។ ខ្ញុំមើលឃើញស្នុងៗ មានមនុស្សមួយក្រុមតូចដែលកំពុងតែខ្សឹបខ្សៀវគ្នានៅក្នុងព្រៃ ស្រាប់តែខ្ញុំទៅធ្វើអោយភ័យខ្លាចខ្លាំង ហើយក៏ព្យាយាមរម្ងាប់អារម្មណ៍ខ្លួនឯង ដោយការបន់ស្រន់ដល់ព្រះ និងទេវតានៅឋានសួគ៌ អោយជួយថែរក្សាការពាររូបខ្ញុំរួចផុតពីគ្រោះថ្នាក់នេះ។ ខ្លួនខ្ញុំទៅជាស្ពឹកដោយសេចក្តីភ័យខ្លាច ហើយវាធ្វើអោយខ្ញុំដើរលែងរួចទៅមុខមិនរួចថយក្រោយក៏មិនរួច។

ខ្ញុំបានរស់នៅក្នុងទីក្រុង បូស្តុន (Boston) ផ្នែកខាងកើតនៅជិតសមុទ្រ បច្ចុប្បន្ននេះ នៅពេលដែលខ្ញុំយល់សុបន្តិ ខ្ញុំតែងតែឃើញជនជាតិអាមេរិកកាំងស្លៀកពាក់ខ្មៅដើរតាមសមុទ្រ។ នៅថ្ងៃមួយដែលខ្ញុំនៅផ្ទះអ្នកជានា (ស្ពន់ស័រ) របស់ខ្ញុំ ខ្ញុំបានស្រម៉ៃថា ឆ្នាំនេះជា ឆ្នាំឆ្លូវខ្ញុំចង់អោយជនជាតិអាមេរិកកាំងជួយកសាងវត្តមួយអោយខ្ញុំនៅតាមឆ្នេរសមុទ្រ។ ចាប់តាំងពីទាហ៊ានប៉ុលពតវាយសម្លាប់កូនរបស់ខ្ញុំបាត់ទៅ ខ្ញុំព្រួយណាស់ហើយខ្ញុំគ្មានគិតឃើញពីអ្វីក្រៅតែពីការកសាងវត្ត។ ព្រះបានមកបង្ហាញរូបអោយខ្ញុំឃើញម្តងទៀតកាលពីថ្ងៃមុន ហើយបានប្រាប់ខ្ញុំថាអោយកសាងវត្ត។ សូមជួយអោយសេចក្តីស្រម៉ៃរបស់ខ្ញុំអោយក្លាយទៅជាភាពពិតផង ពុំដូច្នោះទេខ្ញុំពុំអាចរស់នៅបានទៀតឡើយ។

លក្ខិណាបានរួចផុតពីសេចក្តីស្លាប់ចេញពីជុំរុំពលកម្មខ្មែរក្រហម ដែលសម្លាប់កូនស្រីរបស់គាត់ ប្រាំនាក់និងចៅ៤នាក់ ក្នុងចំណោមចៅទាំងដប់នាក់របស់គាត់។ ក្រោយពីរត់ភៀសខ្លួនទៅនៅជុំរុំជនភៀសខ្លួននៅស្រុកថៃ គាត់សល់តែកូនប្រុសម្នាក់ និងកូនស្រីម្នាក់ដែលមករស់នៅសហរដ្ឋអាមេរិក។ តាមផ្នែកសតិអារម្មណ៍គាត់មានតែសេចក្តីភ័យខ្លាច និងអស់សង្ឃឹម បញ្ហាសុខភាពដែលគាត់មាន គឺគាត់វិលមុខ ហើយជាប្រចាំគាត់តែងតែងងឹតមុខដួលជានិច្ច។

នៅក្នុងពេលនោះខ្ញុំពុំសូវដឹងច្បាស់អំពីទំនៀមទម្លាប់ ភាសារបស់ លក្ខិណា និងអំពើកំណាចឃោរឃៅដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមនោះទេ ។ នៅពេលនោះជនជាតិអាមេរិកកាំងភាគតិចណាស់ ដែលដឹងអំពីអំពើប្រល័យពូជសាសន៍ ដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ដែលប្រជាជន ចំនួនជាងពីរលាននាក់ នៅក្នុងចំណោមប្រជាជនប្រហែលជាង ប្រាំបីលាននាក់ បានស្លាប់ដោយសេចក្តីអត់ឃ្លាន ការកាប់សម្លាប់រង្គាល នៅមណ្ឌលពលកម្មលុតដំ ។

ដើម្បី នឹងជួយដល់ លក្ខិណា ខ្ញុំបានរួមសហការ យ៉ាងជិតស្និតជាមួយ និងក្រុមសមាជិកឥណ្ឌូចិនរបស់ខ្ញុំ ទោះបីជាគេពុំបានទទួលការហ្វឹកហ្វឺន ផ្នែកពេទ្យក៏ដោយ គេអាចរៀបរាប់ពីដំណើរប្រវត្តិសាស្រ្ត និងទុក្ខសោករបស់អ្នកជម្ងឺទាំងនោះ ។ គេក៏បានបំភ្លឺនូវដំណើរទុក្ខសោកយ៉ាងច្បាស់លាស់ នៅក្នុងសង្គមជនជាតិអាស៊ីអាគ្នេយ៍ផ្សេងៗទៀត អ្នកជម្ងឺខ្មែរវ័យជរារបស់ខ្ញុំ ជាស្ត្រីមេម៉ាយកាន់ព្រះពុទ្ធសាសនា គាត់ជឿថាព្រលឹងរបស់គាត់ គឺ

ទទួលយកសណ្ឋិតដោយព្រះអគ្គី ដែលធ្វើអោយគាត់សន្លប់ហើយនាំរូបគាត់ទៅកាន់ទីកន្លែងដែលមានសត្វ និងមនុស្សដែលជាតំណាងសេចក្តីស្លាប់។ ការសណ្ឋិតដោយប្រភពផ្សេងៗ នៅក្នុងព្រលឹងរបស់មនុស្ស កើតមានឡើងជាសាមញ្ញ ហើយជាអបិយជំនឿនៅក្នុងទំនៀមទម្លាប់ខ្មែរ នៅក្នុងករណី របស់អ្នកជម្ងឺនេះអាចធ្វើអោយមានគ្រោះថ្នាក់។ នៅពេលដែលព្រលឹងអាក្រក់ចូលទៅសណ្ឋិតនៅក្នុងខ្លួន និងក្នុងចិត្តរបស់មនុស្ស អាចធ្វើអោយមានពេគាខ្លាំង ហើយអាចធ្វើអោយស្លាប់ បើមិនកំចាត់ភ្លាមៗនោះទេ ។ អ្នកជម្ងឺម្នាក់នេះសោកសង្រេងខ្លាំងណាស់ ដោយខ្មែរក្រហមបានសម្លាប់កូន និងចៅរបស់គាត់អស់មួយចំនួនធំ ។ តាមរយៈការស្នើសុំអោយជួយកសាងវត្ត គាត់បានប្រាប់យើងថា ដំណោះស្រាយទៅលើទុក្ខសោក និងសេចក្តីអស់សង្ឃឹមចម្លែករបស់គាត់ពុំអាចរកឃើញដោយការព្យាបាលទឹកចិត្ត ឬថ្នាំពេទ្យដែលយើងផ្តល់អោយគាត់ឡើយ។ សេចក្តីឈឺចាប់របស់គាត់មានកំរិតខ្លាំងណាស់ ហើយអាចសំរាលបានដោយការកសាងវត្តព្រះពុទ្ធតែម៉្យាងប៉ុណ្ណោះ។

ការព្យាបាលសតិអារម្មណ៍ទូទៅ លក្ខិណា នឹងទទួលការវិនិច្ឆ័យរោគថាមានរោគវិកលចរិត ព្រោះគាត់ហាក់បីដូចជានៅឋានមួយទៀត ដោយគាត់អះអាងថាព្រះអគ្គីបានចូលមកសណ្ឋិតនៅក្នុងខ្លួនរបស់គាត់ ហើយគាត់ ឮសម្លេងនិយាយ និងរវើរវាយ។ ពេទ្យ បានអោយថ្នាំគាត់លេប ហើយគេ នឹងបដិសេធការព្យាបាលដោយចិត្តវិទ្យា ។ ការស្នើសុំជំនួយកសាងវត្ត នៅមាត់សមុទ្ររបស់គាត់ នឹងទទួលបកស្រាយថា ជាភាពមហោឡារិក និងជាភាពក័ន្តវិញ្ញាណ។ តែការប្រមាណមើលនេះពុំត្រឹមត្រូវសោះ គាត់យល់ដឹងអំពីតួនាទីរបស់ខ្ញុំដែលជាវេជ្ជបណ្ឌិតដែលជួយព្យាបាលគាត់អោយមានសុខភាពល្អ ហើយជាការសមហេតុផលដែលគាត់បានស្នើសុំអោយខ្ញុំជួយគាត់កសាងវត្ត ដោយគាត់មានអារម្មណ៍ថាគាត់ នឹងស្លាប់។

ខ្ញុំយល់ព្រមតាមសេចក្តីស្នើសុំរបស់គាត់ ហើយពុំដឹងថាធ្វើយ៉ាងណា ដើម្បីបំពេញតាមសេចក្តីសន្យានេះបានឡើយ ។ ដំណោះស្រាយដែលយើងគិតឃើញ គឺយើងត្រូវពិភាក្សាជាមួយ និងអ្នកដឹកនាំខ្មែរប្រចាំតំបន់ ដើម្បីអនុញ្ញាតអោយលក្ខិណា ចូលវត្តបួសជាដូនជីបំរើព្រះពុទ្ធសាសនា។ ទោះជាគាត់ពុំអាចកសាងវត្តដោយខ្លួនគាត់ តែគាត់អាចបរិច្ចាគជីវិតរបស់គាត់ ប្រគេនព្រះពុទ្ធសាសនា លក្ខិណាបានមកជួបខ្ញុំជារៀងរាល់ខែរយះ ពេលចំនួន១៥ឆ្នាំ រហូតទាល់តែគាត់ស្លាប់បាត់បង់ជីវិតទៅ តែគាត់ពុំដែលបង្ហាញថាគាត់ខកចិត្ត ដោយគាត់ពុំបានបំពេញតាមសេចក្តីប្រាថ្នារបស់គាត់ឡើយ។ នៅដើមឆ្នាំ១៩៨០ ពេទ្យវិកលចរិត និងអ្នកចិត្តវិទ្យាជនជាតិអាមេរិកកាំង មានលទ្ធភាពតិចតួចណាស់ នៅក្នុងការរកមើលនិង ព្យាបាលបញ្ហាចិត្តវិទ្យា នៅក្នុងចំណោមប្រជាជនដែលពុំអាចចេះ និយាយភាសាអង់គ្លេសបាន ដូចជា រូបលក្ខិណា។ ជាបន្ថែមទៀត ផ្នែកពេទ្យ និងផ្នែកចិត្តវិទ្យាមានជំនឿខ្លាំងថា គេពុំអាចជួយព្យាបាលអ្នកជម្ងឺដែលធ្លាប់ឆ្លងកាត់បទពិសោធន៍ នឹងអំពើកាចសាហាវ រួមទាំងអំពើរំលោភផ្លូវភេទ និងបទឧក្រិដ្ឋកម្មដែលបណ្តាលអោយភាពតក់ស្លុតទាំងនោះអោយមានសភាពដូចដើមវិញបាននូវឡើយ។ ជាទូទៅគេគិតថា អ្នកដែលរួចរស់រានមានជីវិតពីការកាប់សម្លាប់រង្គាល បញ្ចេញអំពើហឹង្សារបស់ខ្លួនដោយការត្អូញត្អែរជាសេចក្តីឈឺចាប់ទៅលើរាង្គកាយ និងរោគា។ ផ្នែកពេទ្យជឿថាអ្នកជម្ងឺដោយភាពតក់ស្លុតទាំងនេះ "ប្រុងប្រយ័ត្នទៅលើឥទ្ធិពលចិត្តគំនិត" ដូច្នេះ លទ្ធភាពរបស់គេក្នុងការដោះស្រាយបញ្ហាតក់ស្លុតមាន

តិចតួចណាស់។ ជំនឿទាំងនោះ គឺពិតជាខុសទាំងស្រុង មន្ទីរសុខភាពរបស់យើងបានទទួលជោគជ័យក្នុងការព្យាបាលអ្នករួចផុតពីសេចក្តីស្លាប់ ពីអំពើសាហាវយង់ឃ្នង និងទារុណកម្មឃោឃៅក្រៃលែងនៅក្នុងរយៈពេលពីរទសវត្សមកហើយ។

## ១.២ ការបង្កើតមធ្យោបាយព្យាបាលថ្មី

ចាប់តាំងពីការពិសោធន៍លើកដំបូង ខ្ញុំបារម្ភទៅលើការកែតម្រូវនិន្នាការ ថាអ្នកជម្ងឺឥណ្ឌូចិនទទួលការបណ្តែតបណ្តោយ ឬអោយតែថ្នាំពេទ្យ ដើម្បីប្រើប្រាស់ តែដោយសារមកពីគេមានឋានៈទាបនៅក្នុង ផ្នែកសុខាភិបាល ។ យើងត្រូវរិះរកមធ្យោបាយផ្សេងៗ ដែលមានប្រសិទ្ធិភាពជាងនេះ លោកវេជ្ជបណ្ឌិតចិត្តសាស្រ្តជនជាតិអង់គ្លេស ដឹកគ្លាស់ ប៊េណិត (Douglas Bennett) ផ្តល់អោយយើងនូវវិធីព្យាបាលផ្សេងៗ សម្រាប់អ្នកជម្ងឺទាំងនេះ។ បន្ទាប់ពីបំពេញបេសកម្មជានាវិក (អ្នកបើកយន្តហោះ) នៅក្នុងសង្គ្រាមលោកលើកទី២ លោកវេជ្ជបណ្ឌិត ប៊េណិត ចាប់ផ្តើមធ្វើការនៅមន្ទីរពេទ្យ បេតលឹម (Bedlam) ដែលជាមន្ទីរពេទ្យតូចតាចមួយនៅទីក្រុង ឡុង ដុន (London) ជាទីកន្លែងដែលលោកបានតស៊ូព្យាបាលអ្នកដែលមានជម្ងឺខួរក្បាលធ្ងន់ធ្ងរ អោយមានសភាពដូចដើមវិញ។ អ្នកជម្ងឺទាំងនេះបានទទួលការបំបោះបង់ចោលដោយ ផ្នែកវិជ្ជាពេទ្យ និងផ្នែកវេជ្ជវិទ្យាវិកលចរិត ហើយបានដាក់ទៅក្នុងឃ្លាំងមន្ទីរពេទ្យឆ្កួត។ គេអោយឈ្មោះថាជាអ្នកជម្ងឺសង្គមអង់គ្លេស "បដិសេធ" និង "ប្រមាថមើលងាយ" ដោយអ្នកជម្ងឺទាំងនោះរឹងទទឹងយ៉ាងសាហាវ និងការព្យាបាលវិកលចរិត ហើយជាញឹកញាប់មានរូបរាង្គកាយគួរអោយខ្ពើមរអើម ដោយមកពីស្ថានភាពរស់នៅដ៏ក្រីក្រ និងគ្មានអនាម័យ។[3] លោក វេជ្ជបណ្ឌិត ប៊េណិត ពារកេ "មាសនៅក្នុងធុងសំរាមរបស់មនុស្សឯទៀត" មធ្យោបាយរបស់គាត់ គឺទស្សនៈវិទ្យាសាមញ្ញក្នុងការព្យាបាលល្អិតល្អន់។ គាត់បដិសេធ និងផ្លាស់ប្តូរទម្លាប់ព្យាបាល ផ្នែកវិកលចរិតដែលគេបង្ខំអ្នកជម្ងឺអោយលេបតែថ្នាំ ហើយបញ្ជាអោយអ្នកជម្ងឺទាំងនោះពឹងផ្អែកលើខ្លួនឯង នៅក្នុងប្រព័ន្ធវិកលចរិត ដែលធ្វើអោយមានការលំបាកក្នុងការគេចូលរួម ទៅក្នុងសង្គមជាទូទៅដោយជោគជ័យ ។ គាត់បានហៅថាជាមធ្យោបាយរបស់គាត់ថា "វេជ្ជវិទ្យាវិកលចរិតក្រឡាប់ចាក់"[4] ហើយលោកបានជឿជាក់ថា គ្មានអ្នកជម្ងឺណាម្នាក់ជាជនអស់សង្ឃឹមឡើយ ។ ជនទាំងអស់អាចមានការងារ នៅក្នុងសង្គម ហើយមានប្រាក់ខែ ទោះបីជាសតិអារម្មណ៍របស់គេមានការខ្វះខាតធ្ងន់ធ្ងរប៉ុណ្ណាក៏ដោយ។ ដោយផ្តោតទៅលើមូលដ្ឋានភាពពិត នៃដំណើរជីវិតប្រចាំថ្ងៃ លោក ប៊េណិត ជាអ្នកជំនាញមួយរូប ដែលយកមនុស្សមានរោគខួរក្បាល ដែលពីមុនត្រូវគេបោះបង់ចោល អត់ការងារធ្វើ នៅមន្ទីរពេទ្យឆ្កួតកខ្វក់ ទៅរស់នៅក្នុងសហគមន៍ ហើយអោយធ្វើការនៅក្នុងរោងចក្រ ដើម្បីចិញ្ចឹមជីវិត អ្នកខ្លះក៏បានសំរេចជោគជ័យដោយមានមុខរបរផ្ទាល់ខ្លួន។

អ្នកជម្ងឺជនភៀសខ្លួននៅមន្ទីរសុខភាព ហារើត ក៏ដូចជា អ្នកជម្ងឺរបស់លោក ប៊េណិត ដែល គេជាប្រជាជនក្រីក្រជាងគេនៅក្នុងសហគមន៍ដែលគេរស់នៅ។ បើសិនជាអ្នកទាំងនោះទៅបន្ទប់សង្គ្រោះបន្ទាន់ ដើម្បីរកជំនួយសំរាលបញ្ហាទុក្ខសោកកើតភាពតក់ស្លុតធ្ងន់ធ្ងររបស់ខ្លួន អ្នកនោះ នឹងត្រូវគេបញ្ជូនទៅមន្ទីរពេទ្យឆ្កួត ផ្ទុយ

ពីសេចក្តីប្រាថ្នារបស់ខ្លួន ហើយត្រូវគេបញ្ជាដោយម៉ឺងម៉ាត់ថាត្រូវលេបថ្នាំវិកលចរិត ដោយគ្មានការព្យាបាលផ្នែកចិត្តសាស្ត្រ ឬការព្យាបាលដោយសង្គមវិជ្ជាឡើយ។ នៅក្នុងរយៈពេលពីរទៅបីឆ្នាំដំបូង យើងបានសង្គ្រោះជនភៀសខ្លួនរាប់រយនាក់ ពីមន្ទីរពេទ្យឆ្កួត។ នៅមន្ទីរសុខភាពរបស់យើង យើងផ្តល់សម្ភារៈគ្រប់យ៉ាង (ឧទាហរណ៍ ទីលំនៅ) និងជំនួយចិត្តសាស្ត្រ (ដូចជាផ្តល់ឱវាទជាភាសារបស់គេ) គេត្រូវការរកការងារធ្វើ រស់នៅដោយឯករាជ្យ និងចិញ្ចឹមបីបាច់ក្រុមគ្រួសាររបស់គេ។ ដូចគ្នា និងការពិសោធន៍របស់លោក បេណិត (Bennett) នៅទីក្រុងឡុងដុន(London) ដែរ ភាគច្រើនបានសំរេចជោគជ័យដោយខ្លួនទីពឹងពាក់ខ្លួន មានតែពីរទៅបីនាក់ទេដែលត្រូវទៅព្យាបាលនៅមន្ទីរពេទ្យឆ្កួត។

## ១.៣ វិធីសាស្ត្រព្យាបាលចម្លែកអស្ចារ្យ

បន្ទាប់ពីមន្ទីរសុខភាពចាប់ផ្តើមដំណើរការឡើង ហើយចាប់ផ្តើមទាក់ទាញអ្នកជម្ងឺឥណ្ឌូចិន យើងត្រូវរិះរកមូលហេតុពិតប្រាកដ នៃបញ្ហារបស់អ្នកទាំងនោះហើយ រកវិធីដ៏ប្រសើរបំផុត ដើម្បីជួយអ្នកទាំងនោះដោះស្រាយអារម្មណ៍ហឹង្សារបស់ខ្លួន។ ចម្លើយបានមកពីវិធីសាស្ត្រចម្លែកអស្ចារ្យ ដែលបានបង្កើតឡើងត្រូវបានអនុវត្តន៍ យ៉ាងទូលំទូលាយ នឹងត្រូវទទួលស្គាល់ពាសពេញទ្វីបអ៊ឺរ៉ុប (Europe) របស់អ្នកចិត្តវិទ្យាជនជាតិអាមេរិកកាំងដ៏ល្បីល្បាញបំផុត ឈ្មោះលោក វិលយឹម ជេម (William James)។ គោលការណ៍ជាមូលដ្ឋាន នៃវិធីនេះ គឺជាមធ្យោបាលថ្មីស្រឡាង ដែលទាក់ទងទៅលើអាកប្បកិរិយារបស់មនុស្ស និងទំនាក់ទំនងដែលអាចរកឃើញដោយអ្នកចិត្តវិទ្យា ឬវេជ្ជបណ្ឌិត តាមរយៈការបោះបង់ចោលនូវទ្រឹស្តីអនុវត្តន៍នាពេលបច្ចុប្បន្ននេះ និងយោបល់ការវិនិច្ឆ័យខុស និងភាពលំអៀង។ ដើម្បីជួយអ្នកជម្ងឺអោយបានល្អបំផុត អ្នកប្រកបដោយវិជ្ជាជីវៈជាអ្នកព្យាបាលត្រូវលះបង់ការសន្និដ្ឋានរបស់ខ្លួន ហើយ "ឃើញ" អ្វីដែលជាការពិតនៅចំពោះមុខ។ ជាការលំបាកក្រៃលែងដែលអ្នកព្យាបាលបដិសេធនូវអ្វីៗ ទាំងអស់ដែលគេបានសិក្សា ដោយគេបានពឹងផ្អែកទៅលើសញ្ញាសន្មតថា និងវិនិច្ឆ័យប្រភេទរោគ។ ប៉ុន្តែ នៅពេលដែលខ្ញុំចាប់ផ្តើមព្យាបាលអ្នកជម្ងឺឥណ្ឌូចិន ខ្ញុំចង់រកឃើញដោយខ្លួនឯងនូវរបៀបដ៏ប្រសើរបំផុត ដើម្បីជួយអ្នកទាំងនោះ ដោយមិនធ្វើតាមយ៉ាងងងឹតងងល់ នៃការព្យាបាលរបស់គ្រូពេទ្យពីមុន។

ហេតុដូច្នេះ យើងសរសេរកត់ត្រានូវចំណេះដឹងទូទៅ ផ្នែកចិត្តវិទ្យា ចំណេះដឹងទាំងនេះអាចត្រូវបានបដិសេធចោល ក្រោយពីត្រូវបានបញ្ជាក់ថា ពុំត្រឹមត្រូវ។ ជំនឿដែលយើងបោះបង់ចោល រួមទាំងមានទស្សនៈដែលផ្តើមប្រឌិតដោយអ្នកចិត្តវិទ្យាទូទៅថា ជនរួចផុតពីសេចក្តីស្លាប់ដោយធ្វើទារុណកម្ម និងអ្នកជម្ងឺផ្សេងៗទៀតដែលឆ្លងកាត់ភាពតក់ស្លុតដោយឧក្រិដ្ឋកម្មឃោរឃៅ ពុំអាចព្យាបាលជាបានឡើយ។ ជនដែលមានការតក់ស្លុតខ្លាំងក្លាដែលពុំអាចរៀបរាប់បាន អំពីបទពិសោធន៍តក់ស្លុតនៅក្នុងជីវិតរបស់គេបាន ហើយអ្នកជម្ងឺផ្សេងៗ ក្រៅពីបច្ចឹមប្រទេស តែងតែបញ្ចេញទុក្ខសោកសង្រេងរបស់គេដោយតាមរយៈការឈឺចាប់រាងកាយ។ មានចំនួន ជាង២០ឆ្នាំ តាមការសន្និដ្ឋាននេះជាការជាក់ស្តែង គឺខុសទាំងស្រុង លទ្ធភាពរបស់ជនរងគ្រោះដែល

ភាពជាសះស្បើយពីភាពសាហាវ និងការចូលរួមក្នុងការព្យាបាលដោយខ្លួនឯង គឺជាការរកឃើញដែលជាកត្តាពិត ហើយបានត្រូវទទួលការអបអរសាទរនៅក្នុងសៀវភៅនេះ។

## ១.៨ ការបកស្រាយជម្រៅអត្ថបទ: អត្ថន័យពាក្យ

ការរកឃើញដ៏សំខាន់មួយទៀតនៅក្នុងមធ្យោបាយរបស់យើង គឺការផ្តោតអារម្មណ៍ទៅលើវប្បធម៌ និងប្រវត្តិសាស្ត្រ ដែលអ្នកជម្ងឺរបស់យើងបានបកស្រាយ ជាពាក្យសម្តីដែលរៀបរាប់អំពីបទពិសោធន៍តក់ស្លុតក្នុងដំណើរជីវិតរបស់ខ្លួនគេ។ យើងពុំអាចគ្រាន់តែស្តាប់ពាក្យពេចន៍របស់ជនរងគ្រោះទាំងនេះ ហើយចាត់ថាជាការគ្រប់គ្រាន់បានឡើយ ដោយភាសាអាចលាក់បាំងនូវអារម្មណ៍ពិតៗ របស់ជនទាំងនេះ។ នៅពេលដែលជនភៀសខ្លួននិយាយថា "គេគ្មានទីលំនៅ" វាអាចមានន័យទៅលើការភៀសខ្លួនគេចេញពីភូមិរបស់គេ មុនក្រុមប្រដាប់អាវុធចូលមកដល់ ឬក៏អាចមានន័យថា គេមើលឃើញជនឈ្លានពានដែលកំពុងតែចាប់កូនស្រីរបស់ខ្លួនរំលោភផ្លូវភេទនៅ នឹងមុខហើយសម្លាប់កូនស្រីនៅក្នុងផ្ទះនោះមុន នឹងពួកវាដុតផ្ទះរបស់ខ្លួនចោលអោយទៅជាផេះ ហើយខ្លួនក៏ត្រូវបង្ខំអោយរត់ចេញពីភូមិស្រុករបស់ខ្លួនទៀត។ ឃ្លា"ការចាប់រំលោភ" អាចមានខ្លឹមសារខុសគ្នានៅសង្គមផ្សេងៗ វាអាចជាអំពើរំលោភផ្លូវភេទ ឬគ្រាន់តែជាការឈរស្រោតនៅចំពោះមុខមនុស្សម្នា ឬក៏ជាភាពអាម៉ាស់មុខកំរិតផ្សេងៗគ្នាក្នុងសង្គម ដូចជាការលែងលះប្តីប្រពន្ធ ឬជាអំពើសម្លាប់ដែលត្រូវបានគេរំលោភ។

សិស្សផ្នែកសាសនា សិក្សារៀនសូត្រពីមធ្យោបាយសំខាន់ក្នុងការបកស្រាយអត្ថបទ ស៊ីជម្រៅនេះជាការពន្យល់ផ្តោតទៅលើភាពច្បាស់លាស់ នៃអត្ថន័យពិតប្រាកដនៃការដកស្រង់ខ្លីៗ ជាទូទៅមាននៅក្នុងព្រះគម្ពីរ។ ការអធិប្បាយពាក្យ និងគំនិតដកស្រង់ខ្លីៗ ចេញពីអត្ថបទ យកទៅធ្វើការស្រាវជ្រាវរួចដាក់ទៅក្នុងបរិបទប្រវត្តិរបស់អ្នកនិពន្ធវិញ។ ការប្រើវិធីនេះអ្នកប្រាជ្ញ ផ្នែកគម្ពីរព្យាយាមរក្សាខ្លឹមសារដើម នៃពាក្យ និងឃ្លាដែលប្រើដោយព្រះ និងព្រះយេស៊ូ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មី។

ឧទាហរណ៍: នៅក្នុងអត្ថបទខាងក្រោមនេះរបស់លោក ម៉ាកុស St. Mark (7:24-30) ស្ត្រី (សាសន៍ក្រេកកូនកាត់ស៊ីរ៉ូ-ភេនីស) syro-phoenician អង្វរព្រះយេស៊ូ អោយជួយព្យាបាលកូនស្រីរបស់គាត់ម្នាក់ ដែលអារក្សមកចូលសណ្ឋិតនៅក្នុងខ្លួនរបស់វា ហើយព្រះយេស៊ូ ក៏បាននិយាយថា "ទុកឲ្យកូនក្មេងស៊ីឆ្អែតជាមុនសិន ព្រោះមិនគួរនឹងយកនំបុ័ងរបស់កូនក្មេងបោះទៅឲ្យឆ្កែស៊ីទេ"។ តែគាត់ទូលឆ្លើយថា "មែនហើយព្រះអង្គម្ចាស់ ប៉ុន្តែ ឆ្កែនៅក្រោមតុវាស៊ីកំទេចពីកូនក្មេងដែរ"។ នោះព្រះយេស៊ូ ព្រះបន្ទូលថា "ដោយព្រោះពាក្យនោះ ចូលនាងទៅចុះ អារក្សបានចេញពីកូននាងហើយ"។ រួចកាលនាងបានទៅដល់ផ្ទះវិញ ក៏ឃើញកូនដេកនៅលើគ្រែ អារក្សបានចេញស្រេចហើយ។[6] ពាក្យបកស្រាយនៅក្នុងអត្ថបទនេះ គឺសរសេរឡើងដោយលោក ម៉ាកុស St. Mark នៅប្រទេសក្រេក។ នៅពេលដែលព្រះយេស៊ូនិយាយទៅកាន់ស្ត្រីនោះថា "ទុកឲ្យកូនក្មេងស៊ីឆ្អែតជាមុនសិន ព្រោះមិនគួរនឹងយកនំបុ័ងរបស់កូនក្មេងបោះទៅឲ្យឆ្កែស៊ីទេ" ព្រះយេស៊ូប្រើពាក្យថា TeKnow (tekvwv) សំរាប់ពាក្យក្មេង ដោយមានក្មេងឈរនៅពីមុខ "ជាទំនាក់ទំនងរវាងព្រះ "នៅក្នុងអត្ថបទនេះ ព្រះគ្រីស្ទ គឺប្រើសំដៅទៅលើរូបស្ត្រី សាសន៍

ក្រិចកូនកាត់ស៊ីរ៉ូ-ភេនីស syro-phoenician ជាអ្នកកាន់សាសនា ក្រៅពីសាសនាយូដា Jewish ជាព្រះគ្រីស្ទ ដែលបានមកកាន់ប្រទេសអ៊ីស្រាអែល Israel មុនគេ។ តែការជ្រើសយកពាក្យរបស់ព្រះយេស៊ូ ពាក្យថាឆ្កែ Kyon (Kvwv) ដែលគាត់ឆ្លើយតបទៅស្ត្រីនោះ ពាក្យនោះមានន័យថា តូចជាភាសាក្រិច Kuvapiov ឆ្កែតូច។ នៅចំណុចផ្សេងៗ នៅក្នុងព្រះគម្ពីរពាក្យឆ្កែសំដៅទៅលើមនុស្សដែលដើរតាមផ្លូវកាយធុងសំរាមនៅក្នុងក្រុង ហើយជនជាតិយូដា Jew បានចាត់ទុកអ្នកទាំងនោះថាជាមនុស្សកខ្វក់ និងសាហាវ។ នៅក្នុងអត្ថបទនេះព្រះយេស៊ូពុំប្រើពាក្យនេះដោយសំដៅថា ជាឆ្កែកាយធុងសំរាមនោះទេ តែព្រះយេស៊ូប្រើពាក្យឆ្កែនេះ ដោយសំដៅទៅលើឆ្កែតូចដែលគេអាចទទួលរាប់រកមកវិញបាន។ អ្នកកាន់សាសនា ដែលពុំមែនជាសាសនាយូដា Jewish ដូចជា "ឆ្កែតូច" មានគំនិតថា យូរៗទៅគេគង់តែអនុញ្ញាតអោយចូលព្រះវិហារវិញ។

បទពិលោធន៍របស់ខ្ញុំនៅក្នុងវិធីបកស្រាយស៊ីជម្រៅ លើការសិក្សា ផ្នែកសាសនា មានឥទ្ធិពលទៅលើមធ្យោបាយប្រកបការងាររបស់ខ្ញុំជាអ្នកព្យាបាលជម្ងឺវិកលចរិត។ ដំណើរការគ្មានព្រំដែននេះ មានរួមនូវការរាវរកមូលហេតុដើម និងអត្ថន័យពាក្យ និងឃ្លាដែលអាចធ្វើអោយអ្នកអាន ឬនៅក្នុងករណីរបស់ខ្ញុំជាវេជ្ជបណ្ឌិតកាន់តែខិតជិតទៅពិភពពិត នៃការនិទានរឿងដែលជាវិធីមួយមានប្រសិទ្ធិភាពខ្លាំងក្លាក្នុងការបកស្រាយ។ យើងចាប់ផ្តើមដោយបកស្រាយពាក្យពេចន៍សាមញ្ញ និងពាក្យដែលជនភៀសខ្លួន យកមកប្រើរៀបរាប់ពីហេតុការណ៍តក់ស្លុតនៅក្នុងជីវិតរបស់គេ ។ មានការខុសគ្នាខ្លាំង ឧទាហរណ៍ ទាំងការប្រើប្រាស់ពាក្យទារុណកម្មនៅក្នុងសង្គមបច្ចឹមប្រទេស និងសង្គមអាស៊ី។ នៅក្នុងសង្គមបច្ចឹមប្រទេសពាក្យទារុណកម្ម Torture ចេញមកពីពាក្យឡាតាំង Torquere ដែលមានន័យថា "បណ្តាលអោយមានការកែប្រែក្រឡាប់ចាក់" ដើម្បីដកស្រង់សេចក្តីពិត និង/ឬភស្តុតាង ដើម្បីបង្រ្កាបទស្សនៈប្រឆាំងផ្នែកនយោបាយ ឬផ្នែកសាសនា។ បច្ចុប្បន្ននេះពាក្យថា ទារុណកម្មបង្ហាញនូវការធ្វើអោយការឈឺចាប់ទៅលើ កាយសម្បទា និងសតិអារម្មណ៍ ដើម្បីរកសេចក្តីសារភាពស្របច្បាប់ និងបំបិទសិទ្ធិមនុស្សរបស់បុគ្គល។ នៅក្នុងប្រទេសកម្ពុជា ទោះបីជាយ៉ាងណាក៏ដោយ ពាក្យខ្មែរសំរាប់ទារុណកម្ម *Tieru Na Kam* ចេញពីពាក្យបាលី ថាកម្មផលដែលមានន័យថា ជាអំពើ និងគំនិតរបស់បុគ្គល ជារឿយៗច្រើនតែសំដៅទៅលើភាពបាបកម្ម ដែលកើតមានពីជាតិមុនហើយកំពុងតែត្រូវទទួលនៅក្នុងជាតិនេះ។ ជនជាតិខ្មែរដែលរួចផុតពីសេចក្តីស្លាប់ ច្រើនជឿថាបទពិសោធន៍ទារុណកម្ម ជាការផ្តន្ទាទោសទៅលើអំពើបាបកម្ម ដែលខ្លួនបានប្រព្រឹត្តឡើងពីជាតិមុន។

វេជ្ជបណ្ឌិតដែលធ្វើការជាមួយ នឹងអ្នកជម្ងឺដែលបានទទួលទារុណកម្ម ត្រូវចងចាំនូវជំនឿនេះ ហើយជួយអ្នកជម្ងឺ រកវិធីដោះស្រាយភាពដាក់ទោសទៅលើខ្លួនឯង និងជំនឿថាខ្លួនជា អ្នកទទួលខុសត្រូវលើទារុណកម្ម និងរោគារបស់ខ្លួន។

ឧទាហរណ៍: រាប់រយមាននៅក្នុងការយល់ដឹងជ្រៅជ្រះ ដែលកើនឡើងដោយការប្រើមធ្យោបាយបកស្រាយសាសនា ក្នុងការបកស្រាយហេតុការណ៍តក់ស្លុងនៅក្នុងវប្បធម៌ផ្សេងៗគ្នា។[7] ឧទាហរណ៍: ពាក្យថា ពង្វក់ខួរក្បាល មានប្រជាប្រិយភាព នៅក្នុងកំឡុងសង្គ្រាមកូរ៉េ និងសង្គ្រាមវៀតណាម ដែលជាការព្យាបាលរបស់ទ័ព

កុម្មុយនិស្ត បង្វែរជំនឿ ផ្នែកនយោបាយឈ្លើយសង្គ្រាមរបស់ខ្លួន។ ក្រោយពីសង្គ្រាមវៀតណាម ទ័ពកុម្មុយនិស្ត ដែលបានទទួលជ័យជំនះ ដាក់ទ័ពវៀតណាម ខាងត្បូងទៅក្នុង "គុកអប់រំ" ដែលគេពង្វក់ស្មារតីដោយធ្វើទារុណកម្មកាយសម្បទា និងសតិអារម្មណ៍។ ពាក្យវៀតណាមហៅថា Cai fu tal tu tuong មានន័យថាអប់រំចិត្ត និងគំនិតរបស់មនុស្សឡើងវិញ ដូចគ្នា និងពាក្យខ្មែរចំតាមន័យពាក្យពង្វក់ស្មារតី ***អប់រំណែនាំអោយផ្លាស់ប្តូរចិត្ត គំនិត*** ដែលបកស្រាយតាមពាក្យ និងពាក្យថា "ណែនាំតាមរយៈអប់រំ" ដើម្បី នឹងផ្លាស់ប្តូរចិត្ត និងគំនិតរបស់មនុស្ស ការបកស្រាយចំតាមន័យរបស់ពាក្យ មានន័យថា "លានខួរក្បាល"។ នៅក្នុងជំនឿសាសនាអ៊ីស្លាម ការលាងខួរក្បាលជាករណីមួយពុំដែលនឹកឃើញ។ ជនជាតិអ៊ីស្លាម Islam ដែលកាន់សាសនាពិតប្រាកដ មានការប្តេជ្ញានៅក្នុងចិត្ត ហើយពុំមែនជាជនដែលងាយចាញ់សម្លុតដោយការពង្វក់ ឬការបង្អត់នោះទេ។ ជនជាតិអ៊ីស្លាមដែលបូជាចិត្ត ពុំអាចពង្វក់ស្មារតីបានឡើយដោយការប្រឆាំង និងភាពពង្វក់ស្មារតីជាជំរើសសីលធម៌ គឺជាសេចក្តីប្តេជ្ញាទៅលើអំពើល្អ និងយុត្តិធម៌ដែលមានលើសលប់ទៅលើអំពើអាក្រក់ និងអំណាចផ្តាច់ការ។ នៅក្នុងសង្គមអ៊ីរ៉ាក់ Iraq សព្វថ្ងៃ ពាក្យពេចន៍ ***ពង្វក់ខួរក្បាល*** ការបកប្រែអោយចំពីភាសាអង់គ្លេស គឺគ្មានន័យអ្វីទាំងអស់ ការបកស្រាយដោយម៉ាត់ចត់ ទៅលើភាសាដែលជនរួចផុតពីសេចក្តីស្លាប់យកមកប្រើ ធ្វើអោយវេជ្ជបណ្ឌិតយល់ដឹងអត្ថន័យ ដែលអ្នកជម្ងឺរៀបរាប់អំពីបទពិសោធន៍តក់ស្លុតរបស់ខ្លួន។[8] ពាក្យជាពិសេសពាក្យ ដែលបង្ហាញពីហេតុការណ៍តក់ស្លុតត្រូវបកស្រាយដោយប្រុងប្រយ័ត្នទៅលើដំណើរជីវិតរបស់អ្នកជម្ងឺ ក្រុមគ្រួសារ និងសហគមន៍។ នៅគ្រាដែលបទពិសោធន៍ទារុណកម្ម ដែលជាហេតុការណ៍រន្ធត់គ្រប់ទីកន្លែង វប្បធម៌ផ្សេងៗ ចាត់ទុកហេតុផល និងលទ្ធផលជាបែបផ្សេងៗគ្នា។ នៅក្នុងសង្គមខ្លះ ជនដែលរស់រានមានជីវិតរួចផុតពីការធ្វើទារុណកម្មទទួលសេចក្តី មេត្តា ករុណា ចំណែកអ្នកផ្សេងៗទៀតទទួលការស្តីបន្ទោស និងទណ្ឌកម្ម។ ការយល់ដឹងនេះអាចជួយនៅក្នុងការព្យាបាលអ្នករួចផុតពីសេចក្តីស្លាប់ និងពេលខ្លះអាចជួយដល់សង្គមទៀតផង។

## ផ្នែក ២. ខណៈបើកបង្ហាញការពិត

វិធីវិទ្យាសាស្ត្ររបស់យើង បានជួយរៀបចំបុគ្គលិករបស់យើង និងរូបខ្ញុំនូវចំណេះដឹងជ្រៅជ្រះផ្នែកវិទ្យាសាស្ត្រសំខាន់។ ការផ្ទុះចេញដ៏ច្បាស់លាស់ ឬការបំភ្លឺ ផ្នែកវិទ្យាសាស្ត្រ ទោះបីជាកម្រ កើតមានឡើងក៏ដោយ វាធ្វើអោយមានខ្លឹមសារ និងមានផលប្រយោជន៍ជាច្រើន។ ទស្សនៈវិជ្ជា ជនអ៊ីតាលី អត្ថន័យសំដៅថា I momenti ខណៈបើកបង្ហាញការពិត។ នៅគ្រាដែលអ្នកបោះបង់គំនិតចាស់ចេញ អ្នកបើកចំហអោយមានការយល់ច្បាស់ដោយពុំបាច់ពិចារណា និងការស្រមើលស្រម៉ៃនាំអ្នកទៅកាន់អ្វីៗដែលថ្មីស្រឡាង។ ការមានចំណេះដឹងជ្រៅជ្រះមួយរំពេចរបស់ខ្ញុំ ខ្ញុំដឹងថាខ្ញុំត្រូវលះបង់ការវិនិច្ឆ័យរោគសតិអារម្មណ៍ជាធម្មតាចំពោះលក្ខិណាLeakeana ស្ត្រីខ្មែរចំណាស់ម្នាក់នេះ ដើម្បីអោយខ្ញុំដឹងពីភាពតក់ស្លុតដ៏សង្វេគរបស់គាត់ ដោយហេតុនេះខ្ញុំត្រូវតែបំពេញតាមបំណងរបស់គាត់ ដោយរកឃើញភាពជាសះស្បើយតាមរយៈជំនឿព្រះពុទ្ធសាសនា។

នៅក្នុងកំឡុងពេល ដែលខ្ញុំថែទាំជនទទួលរងគ្រោះដោយអំពើឃោរឃៅ ខ្ញុំជួបប្រទះ និងខណៈបើកបង្ហាញការពិតមួយចំនួន ដែលបានបង្វែរគំនិតរបស់ខ្ញុំ និងការប្រកបការងាររបស់ខ្ញុំទៅជា វេជ្ជបណ្ឌិតព្យាបាលរោគ ជាការសំខាន់ដែលយើងស្តាប់អ្នកជម្ងឺ ហើយវិនិច្ឆ័យកំរិតចេះដឹងនៅក្នុងគំនិតរបស់ខ្លួន យើងត្រូវតែប្រុងប្រយ័ត្ន ទៅលើភាពលំអៀងរបស់យើង ហើយរៀបចំជាស្រេច ដើម្បីទទួលចំណេះដឹងថ្មី។

## ២.១ ការរាវរកគន្លឹះ បើកបង្ហាញអាថ៌កំបាំងនៃទាពតក់ស្លុត

ចំនួន ប្រាំឆ្នាំក្រោយមក មន្ទីរសុខភាពជនភៀសខ្លួន បានបើកបន្ថែមពីកន្លះថ្ងៃទៅពេញមួយថ្ងៃ មកទល់ពេលនេះ អ្នកជម្ងឺពុំទាន់បកស្រាយអោយចំច្បាស់ទៅលើបទពិសោធន៍តក់ស្លុតក្នុងជីវិតរបស់ខ្លួនគេទេ តែគេបានផ្តល់ភាពសាហាវយង់ឃ្នងត្រួសៗ ដែលគេបានទទួល ឬបានឃើញ។ ក្រោយមកអ្នកដឹកនាំទូរទស្សន៍សាធារណៈបានមកសុំសម្ភាសន៍ ជាមួយអ្នកជម្ងឺរបស់យើងដែលបានទទួលទារុណកម្ម។ នាងបានរៀបចំថតរឿងឯកសារផ្សេងៗមួយចំនួនសំរាប់កម្មវិធីណូវ៉ា Nova អំពីមធ្យោបាយព្យាបាលផ្សេងៗ ដែលធ្វើឡើងនៅតាមមណ្ឌលព្យាបាលធំៗ នៅទ្វីបអឺរ៉ុប Europe សហរដ្ឋអាមេរិកកណ្តាល Central សហរដ្ឋអាមេរិកឡាតាំង Latin និងសហរដ្ឋអាមេរិក។ ក្រោយពីការពិភាក្សាមួយចំនួន ចម្លើយរបស់ក្រុមយើង គឺដោយច្បាស់។ ដោយខ្វះការពិចារណា យើងជឿថានៅក្នុងមន្ទីរពេទ្យព្យាបាលរបស់យើង គ្មានជនរួចផុតពីសេចក្តីស្លាប់ដោយទារុណកម្មឡើយ ហើយបើសិនជាមាន គេពិតជាពុំចង់និយាយរឿងរបស់គេប្រាប់អ្នកថតកុនជាឯកសារឡើយ។ នៅគ្រាដែលអ្នកជម្ងឺ មួយចំនួនរៀបរាប់ អោយដឹងអំពីអំពើឃោរឃៅដែលគេបានទទួល យើងជឿថាយើងថែទាំជនភៀសខ្លួនដែលដំបូងត្រូវគេបង្ខំអោយរត់ចេញពីភូមិ ស្រុក និងផ្ទះសម្បែងរបស់គេ ហើយត្រូវបានសង្គ្រោះយកដាក់នៅជុំរុំតាមរយៈអង្គការសហប្រជាជាតិ រួចចាប់ផ្តើមតាំងទីលំនៅឡើងវិញនៅពេញពិភពលោក។ គ្មាននរណាម្នាក់អាចប្រមូលយកហេតុការណ៍ពិត ដែលសំអាងទៅលើបទពិសោធន៍តាមកំរិត និងបែបបទហេតុការណ៍តក់ស្លុត ដែលជនភៀសខ្លួនទាំងនេះបានទទួលបទពិសោធន៍ឡើយ នៅក្នុងមន្ទីរពេទ្យព្យាបាលរបស់យើង ខ្ញុំបានឮអំពីករណីទារុណកម្មពីរទៅបីករណីហើយ។

យើងចាត់ទុកថាជាភាពឥតសីលធម៌ ក្នុងការសួរជនភៀសខ្លួនអោយរៀបរាប់ពីបទពិសោធន៍របស់គេទៅអ្នកថតកុន។ អ្នកថតកុនចេះតែនិយាយទទូចថាយើងគិតខុសហើយ ដោយនៅតែជឿជាក់ថាយើងត្រូវ យើងក៏សម្របសម្រួលដោយអញ្ជើញអ្នកជម្ងឺពីរនាក់ មកធ្វើសម្ភាសន៍នៅចំពោះមុខម៉ាស៊ីនថត (កាម៉េរ៉ា)។ យើងមានការភ្ញាក់ផ្អើលដោយអ្នកជម្ងឺទាំងពីរនាក់ យល់ព្រមនិយាយប្រាប់រឿងតក់ស្លុតរបស់គេ អ្នកទាំងពីរនាក់ធ្លាប់បានទទួលទារុណកម្ម ហើយចង់តែនិយាយរឿងរបស់គេ ប្រាប់ពិភពលោក អំពីអ្វីៗដែលបានកើតឡើងដល់រូបគេ។

យើងរង់ចាំដោយរំភើបចិត្ត និងបារម្ភទៅលើភាពបង្ហាញអ្នកជម្ងឺអោយទទួលការសម្ភាសន៍ឈឺចាប់ តែគេបានមកចូលរួម ដោយការរៀបចំខ្លួនជាស្រេច អ្នកទាំងពីរស្លៀកសំលៀកបំពាក់តាមប្រពៃណីដ៏ស្រស់សោភា គេបង្ខំចិត្តនិយាយរឿងរ៉ាវផ្ទាល់ខ្លួនរបស់គេពោរពេញទៅដោយភាពសមរម្យ និងថ្លៃថ្នូរជាភាសារបស់ខ្លួន។ អ្នកទាំង

នោះភ្លាហ៊ានដោយពេលនេះជាលើកដំបូងដែលគេនិយាយបញ្ចេញពីទារុណកម្មរបស់ខ្លួនគេដោយក្បោះក្បាយ។ អ្នកជម្ងឺម្នាក់បាននិយាយពីក្រុមគ្រួសារទាំងអស់របស់គាត់ ដែលខ្មែរក្រហមបានសម្លាប់ បន្ទាប់ពីគេវាយដំរូបគាត់ ហូតដល់សន្លប់បាត់ស្មារតី តែគាត់ពុំទាន់ស្លាប់ហើយគេក៏លើករូបគាត់បោះទៅលើគំនរខ្មោចក្រុមគ្រួសារ និង ញាតិសន្តានរបស់គាត់។

បុគ្គលិករបស់ ខ្ញុំនិងរូបខ្ញុំ រន្ធត់ស្មារតីនៅពេលដែល ឮរឿងដ៏តក់ស្លុតទាំងនេះ តើនរណាម្នាក់ដែលអាច និយាយហេតុការណ៍ព្រៃផ្សៃនេះ ជាសាធារណៈ ហើយគ្មានអារម្មណ៍ភ័យរន្ធត់នោះ? អ្នកថតកុនពុំមានការភ្ញាក់ ផ្អើលអ្វីទេ ដោយគេបានថតរឿង ទារុណកម្ម ពីអ្នករួចពីសេចក្តីស្លាប់ នៅប្រទេស អែលស្សាវ៉ាឌ័រ El Salvador ឆីលី Chile អាចិនធីណា Argentina និងកន្លែងសាហាវយង់ឃ្នងផ្សេងៗ ពេញពិភពលោក។ ហេតុការណ៍នេះ គឺ ជាចំណុចដែលបង្ហាញផ្លូវដល់មន្ទីរសុខភាពរបស់យើង ដោយបានបង្ខំអោយយើងប្រឈមមុខ នឹងភាពញញើត ញញើមរបស់យើងក្នុងការទទួលស្គាល់ថា អ្នកជម្ងឺជនភៀសខ្លួនរបស់យើងភាគច្រើនបានទទួលទារុណកម្ម និង ការប៉ាន់ស្មានដោយសំអាងរបស់ជនបច្ចឹមប្រទេសថា ជនរងគ្រោះពុំចង់និយាយអំពីបទពិសោធន៍របស់គេទេ។ បើអ្នករួចពីសេចក្តីស្លាប់ទាំងពីរនាក់នេះ អាចនិយាយពីបទពិសោធន៍ទារុណកម្មរបស់ខ្លួន ជាសាធារណៈបាន ហេតុដូចម្តេចបាន ជាយើងមិនសួរគេអោយនិយាយនៅក្នុងមន្ទីរសុខភាពរបស់យើង? យើងក៏ចាប់ផ្តើមសួរ ហើយអ្នកជម្ងឺក៏ចាប់ផ្តើមនិយាយរឿងរបស់គេដោយធូរស្រាលក្នុងចិត្ត ។ ដោយការថតកុនទុកជាឯកសារ រឿង តក់ស្លុតរបស់អ្នកជម្ងឺក្លាយទៅជាចំណុចសំខាន់ៗ នៃដំណើរការព្យាបាល។[9]

រឿងតក់ស្លុតជាពាក្យបរិយាយរឿងផ្ទាល់ខ្លួន របស់បុគ្គលម្នាក់ៗអំពីបទពិសោធន៍ និងហេតុការណ៍ តក់ស្លុត ដែលគេបានទទួលនៅក្នុងដំណើរជីវិតរបស់គេ និងការប៉ះពាល់ទៅលើការរស់នៅក្នុងសង្គម កាយ សម្បទា និងសតិអារម្មណ៍ ដែលបណ្តាលអោយកើតឡើង ដោយហេតុការណ៍ទាំងនេះ។ នេះពុំមែនជាការបក ស្រាយរបស់នរណាម្នាក់ទៅលើហេតុការណ៍នេះឡើយ តែវាអាចមានការតាមសង្កេតមើលទៅលើប្រត្តិកម្មរបស់ សមាជិកគ្រួសារ និងសហគមន៍ប្រចាំតំបន់។ ការនិយាយរឿង អាចជាការរៀបរាប់រឿងប្រាប់អ្នកឯទៀត ដោយ មូលហេតុផ្សេងៗ មានរួមទាំងការចង់បានជំនួយ និងការថែរទាំសុខភាព។ ព្រមគ្នានេះដែរ អ្នករួចផុតពីសេចក្តី ស្លាប់ខ្លះ អាចចង់លាក់ទុកហេតុការណ៍ និងប្រវត្តិរឿងរបស់ខ្លួន ទុកជាអាថ៌កំបាំងដោយមូលហេតុផ្ទាល់ខ្លួន ឬសង្គម (ឧទាហរណ៍ក្នុងករណីរំលោភផ្លូវភេទ)។

ការធ្វើសម្ភាសន៍ ដើម្បីជួយអ្នកជម្ងឺអោយ និយាយរឿងតក់ស្លុតរបស់ខ្លួន ជាការលំបាក ហើយត្រូវការហ្វឹក ហាត់ ហេតុដូច្នេះបានជាយើងអាចព្យាបាលអ្នកជម្ងឺជនភៀសខ្លួនជាច្រើនឆ្នាំ តែយើងពុំបានដឹងថាអ្នកជម្ងឺទាំង នោះបានទទួលទារុណកម្មឡើយ។ នៅគ្រានោះ វេជ្ជបណ្ឌិតពុំដឹងអំពីវិធីព្យាបាលទៅលើឥទ្ធិពលសតិអារម្មណ៍ ដែលបណ្តាលឡើងដោយទារុណកម្មទេ។ ជាមួយគ្នានោះដែរ អ្នកព្យាបាលទាំងអស់ដឹងថា ប្រវត្តិជីវិត តក់ស្លុត អាចជាភាពនឹកពុំឃើញ ។ ជាញឹកញាប់ នៅពេលដែលអ្នកព្យាបាលមានពេលស្តាប់អ្នកជម្ងឺ ពេលនោះអ្នកជម្ងឺពុំ ទាន់អាចនិយាយបាន ។ ហើយនៅពេលដែលអ្នកព្យាបាលពុំបានរៀបចំខ្លួនស្តាប់ អ្នកជម្ងឺទៅជាអាចនិយាយបាន

យ៉ាងហូរហែរ ។ ការខ្វះខាតរៀបចំពេលវេលាអោយត្រូវគ្នា រវាងអ្នកព្យាបាល និងអ្នកជម្ងឺជាឧបសគ្គអាចំកំបាំងនៅក្នុងដំណើរការព្យាបាល ។ ដោយរឿងតក់ស្លុតពោរពេញទៅដោយអត្ថន័យ ហើយទាក់ទងយ៉ាងសំខាន់ ទៅលើការយល់ឃើញចាំបាច់ ក្នុងពិភពលោករបស់ជនដែលទទួលទារុណកម្ម វាអាចចញ្ចេញឡើងដោយជនម្នាក់ទៅលើជនម្នាក់ទៀតដោយប្រើវិធីបញ្ជិតបញ្ចៀង ។ ជាភាពលំបាកក្នុងការនិយាយចំៗ អំពីអារម្មណ៍ និងហេតុការណ៍សំខាន់ៗបំផុតរបស់ខ្លួនផ្ទាល់ទៅអ្នកផ្សេងៗទៀត រឿងតក់ស្លុតជារឿងដែលលាក់ទុក លុះត្រាតែអ្នកជម្ងឺរកឱកាសឃើញហើយបញ្ចេញវាម្តងបន្តិចៗ។

ដោយការញញើតញញើមមិននិយាយនេះ កើយមានឡើងដោយអ្នករួចផុតពីសេចក្តីស្លាប់ ភ័យខ្លាចការបដិសេធ ឬជាងនេះទៅទៀត នាង និងគាត់ខ្លាចអ្នកដែលស្តាប់រឿងនោះគ្មានចំណូលចិត្ត ឬចង់ដឹងពីរឿងនោះ។ ការយល់ដឹងពីរឿងតក់ស្លុត តម្រូវអោយអ្នកស្តាប់មានជំនាញខាងស្តាប់ ពុំមែនគ្រាន់តែប្តូរអារម្មណ៍ទៅវិញទៅមកនោះទេ តែត្រូវដាក់ខ្លួនទៅក្នុងហេតុការណ៍នោះហើយយកមកពិនិត្យ និងអបអរកោតសរសើរប្រវត្តិសាស្ត្រ និងវប្បធម៌ និងអត្ថន័យផ្ទាល់ខ្លួននៅក្នុងហេតុការណ៍នោះផង។ មធ្យោបាយរៀបចំល្អ គឺការផ្តល់ឱកាសអោយនិយាយបញ្ចេញ ទោះជាហេតុការណ៍នោះមានសភាពធ្ងន់ធ្ងរបែបណាក៏ដោយ។

## ២.២ ការរកឃើញឥទ្ធិពលព្យាបាលដោយការថែទាំខ្លួនឯង

នៅគ្រប់ឱកាសការរកឃើញទាំងអស់ដែលបានទទួលអបអរសាទរនៅក្នុងមន្ទីរសុភាពរបស់យើង នេះជាឱកាសដ៏អស្ចារ្យ និងការរកឃើញថ្មី៖ អ្នកជម្ងឺមានលទ្ធភាពព្យាបាលខ្លួនឯង។ វេជ្ជបណ្ឌិតព្យាបាលរោគទទួលការហ្វឹកហ្វឺនរកជម្ងឺ ហើយប្រើមធ្យោបាយសាមញ្ញ ដែលបញ្ជាក់ទៅលើតែការប្រើថ្នាំពេទ្យ។ អ្នកព្យាបាលចិត្តសាស្ត្រសិក្សាមធ្យោបាយព្យាបាលជីវិត្តសាស្ត្រ ដែលព្យាយាមពិនិត្យរាង្គកាយ ចិត្តសាស្ត្រ និងសង្គមសាស្ត្រ ដែលបណ្តាលអោយមានរោគនេះកើតមានឡើង។ សាលាសិក្សាអាទិទេពសាសនា បង្ហាត់បង្រៀនសិស្សអោយពិចារណាពីឥទ្ធិពលប្រវត្តិសាស្ត្រ និងវប្បធម៌ដែលបញ្ចេញឡើងដោយភាសា។ ប៉ុន្តែ ជនដែលទទួលការផ្លាស់ប្តូរនៅក្នុងជីវិតរបស់គេដោយបទពិសោធន៍តក់ស្លុត ពុំមានទទួលការសួរនាំដោយអ្នកប្រកបអាជីវកម្មទាំងនេះអោយចូលរួមដោយសកម្មនៅក្នុងដំណើរការព្យាបាលឡើយ ។ ក្នុងនាមជាវេជ្ជបណ្ឌិត ថែទាំស្ត្រីមេម៉ាយខ្មែរអាយុជិតសែសិបឆ្នាំ ដែលមានកូនពីរនាក់រៀននៅសាលាមត្តេយ្យដ្ឋាន និងកូនពីរនាក់រៀននៅសាលាមធ្យមសិក្សា ខ្ញុំរកឃើញថាខ្ញុំខ្វះ ឥទ្ធិពលព្យាបាលខ្លួនឯង។

សុវណ្ណារី Sovannary គ្រាំគ្រាដោយសេចក្តីព្រួយចិត្ត អស់រយៈពេល ១៨ ខែនាងបានទទួលការព្យាបាលដោយថ្នាំ និងការព្យាបាលភាពច្របូកច្របល់ចិត្ត។ ជារៀងរាល់សប្តាហ៍ខ្ញុំអង្គុយដោយស្ងៀមស្ងាត់នៅក្នុងបន្ទប់ចំនួន មួយម៉ោងជាមួយរូបនាង និងអ្នករួមការងារជនជាតិខ្មែរហើយសួរអោយនាងនិយាយពីការតស៊ូរបស់នាងនៅក្នុងការរៀបចំជីវិតថ្មីនៅក្នុងសហរដ្ឋអាមេរិក។ រួមគ្នាយើងខិតខំជួយសម្រាលបញ្ហារបស់នាង ថ្ងៃមួយនោះនាងឈប់លេបថ្នាំពេទ្យ ដោយនិយាយថាថ្នាំនោះមិនអាចជួយនាងបានទេ។ នាងនិយាយប្រាប់ខ្ញុំថានាងត្រូវការ

និយាយជាមួយខ្ញុំតែម្នាក់ឯង។ ខ្ញុំភ័ន្តភាំងដោយនាងបានធ្វើការស្នើសុំជាភាសាអង់គ្លេសឥតខ្ចោះ មកទល់ពេលនេះការព្យាបាលរបស់នាងបានធ្វើឡើងជាភាសាខ្មែរទាំងអស់ ដែលជាជំនួយរបស់អ្នករួមការងាររបស់ខ្ញុំ។ ខ្ញុំពុំដែលឮនាងនិយាយភាសាអង់គ្លេសសោះ សុវណ្ណារី Sovannary និយាយថានាងខំរៀនភាសាអង់គ្លេស គឺនាងចង់និយាយរឿងរបស់នាងប្រាប់ខ្ញុំដោយផ្ទាល់តែម្តង។ ជាលើកដំបូង ដែលនាងរៀបរាប់រឿងអាថ៌កំបាំងរបស់នាងដោយច្បាស់លាស់ពិតៗ។

កាលពីយុវវ័យនាងស្រលាញ់គ្នា និងបុរសក្មេងម្នាក់ តែឪពុកម្តាយរបស់នាងបដិសេធមិនអនុញ្ញាតអោយនាងបានរៀបការ ហើយបានបង្ខំអោយនាងរៀបការ និងស្វាមីដែលឪពុកម្តាយរបស់នាងរើសអោយ។ ការបដិសេធពុំទទួលសង្សារបស់នាង ធ្វើអោយអ្នកទាំងពីរខូចចិត្ត។ ភាពរកាំរកូសបានកន្លងផុតទៅ ជាច្រើនឆ្នាំរហូតទាល់តែខ្មែរក្រហមចូលមកកាន់កាប់។ ប្តីរបស់នាងត្រូវទាហ៊ានប៉ុលពតសម្លាប់ ហើយរូបនាងត្រូវគេបញ្ជូនទៅជុំរុំអប់រំជាមួយ និងកូនរបស់នាង។ នៅពេលដែលនាងរស់នៅក្នុងជុំរុំសុវណ្ណារី Sovannay បានជួប នឹងសង្សារពីកុមារភាពរបស់នាង ជាលើកដំបូង តាំងតែពីពេលដែលគេបែកគ្នា ពីក្មេងៗមក។ ផ្ទុយទៅវិញ នឹងជួយនាងគេបានគេបានចាប់រំលោភនាង ហើយនៅពេលដែលបុរសនោះកំពុងតែរំលោភនាង ទាហ៊ានខ្មែរក្រហម មកទាន់វាក៏ចាប់ទាញកាំភ្លើងបាញ់ចំក្បាលគាត់ស្លាប់ទៅ។

នៅគ្រាដែល សុវណ្ណារី Sovannay កំពុងតែនិយាយរឿងនាងប្រាប់ខ្ញុំ ខ្ញុំមានអារម្មណ៍ថានាងបានបន្ទោសខ្លួនឯង ទៅលើការស្លាប់សង្សារបស់នាងកាលពីកុមារភាព ។ នាងនៅមានអារម្មណ៍ស្រលាញ់បុរសនោះខ្លាំងណាស់ ទោះបីជាបុរសនោះចាប់នាងរំលោភក៏ដោយ ។ បុរសនោះប្រហែលជាប្រព្រឹត្តិអំពើយង់ឃ្នង ដោយបុរសនោះមានអារម្មណ៍ថា នាងបានក្បត់ចិត្តស្រលាញ់របស់គាត់ ជាច្រើនឆ្នាំមកហើយ ។ សុវណ្ណារី Sovannary មានអារម្មណ៍រីករាយ យ៉ាងក្រៃលែង ដោយនាងបានខិតខំរៀនភាសាអង់គ្លេស ដើម្បីនិយាយរឿង អនុស្សាវរីយ ដែលដក់ជាប់នៅក្នុងចិត្តរបស់នាងជាយូរមកហើយនោះប្រាប់ខ្ញុំ ។ ជារឿងអាថ៌កំបាំងរបស់នាង ពេលនេះបាននិយាយបើកចំហនៅក្នុងទំនាក់ទំនងរវាងយើងទាំងពីរនាក់ ។ ក្រោយមកទៀតនាងបានប្រាប់ខ្ញុំថា ចាប់តាំងពីពេលដែលនាងបាននិយាយពីបទពិសោធន៍របស់នាងមក នាងពុំមានអារម្មណ៍ថាអស់សង្ឃឹមក្នុងការរិះរកមធ្យោបាយដោះស្រាយឥទ្ធិពលព្រឹត្តិការណ៍នៅក្នុងជីវិតរបស់នាងទៀតឡើយ ។ ខ្ញុំបានប្រាប់នាងថា ខ្ញុំមានកិត្តិយសដោយបានធ្វើជា វេជ្ជបណ្ឌិតរបស់នាង ហើយរីករាយដោយមានអ្នកជម្ងឺម្នាក់សកម្ម និងខ្លាំងក្លាដែលអាចរៀនភាសាដ៏ពិបាក ដើម្បី នឹងអាចនិយាយប្រាប់រឿងរបងស់នាង។

សេចក្តីគោរពទៅវិញគ្នាទៅមក ដែលកើតមានឡើងរវាងយើងទាំងពីរនាក់ នៅក្នុងការផ្តល់ឱកាសធ្វើអោយអ្នកជម្ងឺរូបនេះបានអោយតម្លៃខ្លួន ក្នុងនាមជាមនុស្សម្នាក់ឡើងវិញ។ អនុស្សាវរីយនៃហេតុការណ៍តក់ស្លុតរបស់នាងរលាយបាត់ទៅបន្តិចម្តងៗ។ អារម្មណ៍របស់គាត់បានរួចផុតពីទុក្ខសោក ហើយគិតពីរឿងហេតុល្អ សំរាប់រូបនាង និងកូនរបស់នាង ។ ទុក្ខសោករបស់ សុវណ្ណារី Sovannay ក៏បានរសាយបាត់ទៅ នាងធ្វើអោយជីវិតរបស់នាងមានខ្លឹមសារឡើង ដោយនាងចូលរួមជួយសហគមន៍ និងជួយកូនរបស់នាងសម្របសម្រួលខ្លួនគេទៅក្នុង

បរិយាកាសនៃសាលារៀន ។ ដប់ពីរខែក្រោយមកនាង បាននាំក្រុមគ្រួសាររបស់នាងប្តូរទីលំនៅពី បូស្តុន Boston ទៅរដ្ឋ កាលីហ្វ័រនីញ៉ា California ដើម្បីរស់នៅជុំគ្នាជាមួយប្អូនស្រីរបស់នាង។ ខ្ញុំពុំបានទទួលដំណឹង អ្វីពីនាង ហេតុ ទាល់តែរយៈពេលថ្ងៃមួយនោះ ខ្ញុំបានទទួលទូរស័ព្ទ ដល់អាថ៌កំបាំង។ បុគ្គលិករបស់ខ្ញុំ ប្រាប់ខ្ញុំថាមានស្ត្រីម្នាក់បានទូរស័ព្ទមកពីរដ្ឋ កាលីហ្វ័រញ៉ា California ស្នើសុំអោយខ្ញុំចូលរួមនៅក្នុងពិធីមង្គលការរបស់នាង។ ស្ត្រីនោះគឺ សុវណ្ណារី Sovannary មិនត្រឹមតែរៀបការប៉ុណ្ណោះទេ សុវណ្ណារី Sovannary បានបង្កើតមន្ទីរពេទ្យព្យាបាលសតិអារម្មណ៍នៅក្នុងសហគមន៍របស់នាងសំរាប់ជនជាតិខ្មែរ ដែលរួចផុតពីសេចក្តីស្លាប់ក្នុងរបបសម្លាប់រង្គាលប្រល័យពូជសាសន៍ប៉ុលពត។

សុវណ្ណារី Sovannary បានបង្ហាញខ្ញុំ នូវឥទ្ធិពលដែលអ្នកជម្ងឺមានទៅលើការព្យាបាលខ្លួនរបស់គេចំពោះជនដែលទទួលសេចក្តីតក់ស្លុត ខ្លាំងបំផុតការជួសជុលដំណើរជីវិតប្រចាំថ្ងៃដែលរងគ្រោះដោយការវិនាសជាការពិបាកទ្រាំជាងពេលដែលគេកំពុងតែទទួលការឈឺចាប់ដល់រាង្គកាយ និងការឈឺចិត្តដោយអំពើយង់ឃ្នងទៅទៀត។ យើងត្រូវតែយកចិត្តទុកដាក់ ដោយប្រុងប្រយ័ត្នទៅលើការ ព្យាយាមព្យាបាលដោយខ្លួនឯង ហើយជួយគាំទ្រ និងជួយបីបាច់ថែរក្សា អ្នកទាំងអស់ដែលរួចពីសេចក្តីស្លាប់ដោយអំពើសាហាវយង់ឃ្នងបំផុត។

ការព្យាបាលខ្លួនឯង អាចបង្ហាញជាភស្តុតាងតាមការយល់ដឹងរួមគ្នា តែឥទ្ធិពលនៃការព្យាបាល ពុំ ងាយស្រួល នឹងសម្គាល់រកឡើយ ។ ឥទ្ធិពលការព្យាបាលរបស់ជនទាំងអស់ នៅក្នុងសង្គមកម្រ នឹងមានទិសដៅស្របគ្នាណាស់។ ប៉ុន្តែ នៅប្រទេស បូស្សនា Bosnia ការព្យាយាមព្យាបាលខ្លួនឯងកើតមានឡើងនៅក្នុងចំណោមប្រជាជន ស្សារ៉ាយ៉េវ៉ូ Sarajevo ទាំងមូល ។ ស្សារ៉ាយ៉េវ៉ូ Sarajevo ជាទីក្រុងដ៏ស្រស់បំព្រងនៃជំនឿសាសនា គ្រីស្ទាន Christian ម៉ូស្លីម Muslim និងរ៉ូម៉ាំងកាតូលិក Roman Catholic ដែលបានទទួលបទពិសោធន៍ព្រៃផ្សៃចំនួន មួយពាន់ថ្ងៃ ជាអំពើសាហាវយង់ឃ្នងដែលគេពុំជួបប្រទះនៅទ្វីបអឺរ៉ុប Europe តាំងពីសង្គ្រាមលោកលើកទី២មកម្លេះ។ មនុស្សប្រុសស្រី ដែលគ្មានទោស និងគ្មានអាវុធ និងកូនក្មេងរាប់ពាន់នាក់រងគ្រាប់កាំភ្លើង និងសំបកគ្រាប់ស្រោចដូចគ្រាប់ភ្លៀងពីលើទួលជិតខាងជារៀងរាល់ថ្ងៃ។ ដោយគ្មានស្បៀងអាហារ និងភ្លើងអគ្គីសនី និងម៉ាស៊ីនកំដៅ ជាភាពដ៏សែនអស្ចារ្យដែលប្រជាជន ស្សារ៉ាយ៉េវ៉ូ Sarajevo រស់រានមានជីវិត នៅពេលដែលពិភពលោកទាំងមូលមើលឃើញការកាប់សម្លាប់រង្គាលទាំងនេះតាមកញ្ចក់ទូរទស្សន៍យ៉ាងតក់ស្លុត។

ទោះបីជាគេព្យាយាមសម្លាប់មនុស្សមួយទីក្រុងនេះមែនពិត តែប្រជាជន ស្សារ៉ាយ៉េវ៉ូ Sarajevo ពុំបោះបង់ការតស៊ូរបស់គេ ដើម្បីរស់ឡើយ។ នៅថ្ងៃមួយរដូវផ្ការីក ក្រោយពីសង្គ្រាមបានចប់សព្វគ្រប់ទៅ នៅពេលដែលខ្ញុំកំពុងតែដើរតាមមាត់ទន្លេ ដែលពោរពេញទៅដោយភាពមហន្តរាយ ខ្ញុំនឹកគិតឆ្ងល់ថាតើអ្នកទាំងនេះរស់រានមានជីវិតដោយវិធីណាដែរ ។ ពេលនោះខ្ញុំបានប្រទះឃើញផ្ទាំងពិពណ៌សិល្បៈមួយ នៅក្នុងជុំវិញជនភៀសខ្លួន ឬទីផ្សេងៗ ដែលជួបប្រទះ និងអំពើសាហាវយង់ឃ្នងខ្ញុំតែងតែដើររកផ្ទាំងគំនូរ ឬជាគំនូរ និងថ្មីដែដ៏ប្រណិតរបស់គេដែលផ្ទុកនូវសេចក្តីសង្ឃឹមផ្ទៃក្នុង ដែលជាញឹកញយច្រើនតែបាត់បង់នៅក្នុងគំនរបរិស្ថានកខ្វក់។ នៅស្សារ៉ាយ៉េវ៉ូ Sarajevo ខ្ញុំបានអានសេចក្តីថ្លែងដូចខាងក្រោមនេះ ដែលសរសេរជាភាសាអង់គ្លេសនៅលើផ្ទាំងគំនូរ។ វិចិត្រ

ករឈ្មោះ ស៊ី បុតាំងស៊ី បង្ហាញយ៉ាងច្បាស់លាស់នូវឥទ្ធិពលព្យាបាលខ្លួនឯង។ ជាញឹកញាប់យើងសួរខ្លួនឯងថាៈ បើសិនជាមានភាពមហន្តរាយ ហើយជីវិតរបស់យើងពោរពេញទៅដោយសង្គ្រាម និងសេចក្តីស្អប់ខ្ពើម ហើយបើសិនជាយើងជាប់ិតនៅក្នុងស្ថានភាពនោះ តើយើងមានប្រតិកម្មយ៉ាងដូចម្តេចទៅ? ប្រជាជន ស្សារ៉ាយ៉េវ៉ូ Sarajevo ពុំបានត្រៀមខ្លួនទទួលហេតុការណ៍នោះទេ ដូចជាមនុស្សគ្រប់រូបធ្លាប់លាន់មាត់ថា ជាប្រជាជនរស់រាយរស់នៅក្នុងទីក្រុងដ៏ល្អប្រណិត និងស្ងាត់ជ្រងុំ។ គ្មានភាពទាល់ក្រ ប្រជាជនមានទំនាក់ទំនងជិតស្និទ្ធល្អ និងគ្នាទៅវិញទៅមកម្នាក់ៗ គិតពីរឿងកូនចៅរបស់ខ្លួន មង្គលការ និងពិធីបុណ្យបញ្ចុះសពជាសកម្មភាពដែលមានជាប្រចាំ។ អ្វីៗមានភាពជាធម្មតាស្រាប់តែមួយពព្រិចភ្នែកអំពើសាហាវយង់ឃ្នងកើតមានឡើង វាមានភាព ដូចជា អ្នកមានអារម្មណ៍ថាខ្លួននៅក្នុងពិភពពោគា និងប្រឈមមុខ និងសេចក្តីស្លាប់។ អ្វីៗដែលខ្ញុំបានឃើញនៅទីនេះហើយអ្វីៗ ដែលគេបានបង្រៀនខ្ញុំ ថាជីវិតសេចក្តីប្តេជ្ញា ដើម្បីរស់តែងតែមានឥទ្ធិពល ជាងអំពើសាហាវយង់ឃ្នង ហើយមនុស្សអាចរស់បាន ថ្វីបើមានគ្រាប់កាំភ្លើង និងគ្មានអ្វីៗទាំងអស់មានតែសេចក្តីសង្ឃឹម សេចក្តីឆ្មៃប្រឌិត និងសេចក្តីស្រលាញ់ក៏ដោយ។ ប្រជាជន ស្សារ៉ាយ៉េវ៉ូ Sarajevo យល់ច្បាស់ថា បើគេនៅតែតស៊ូហើយបើសិនជាគេនៅមានកាហ្វេ នៅក្នុងប៉ាន់កាហ្វេ នៅពេលដែលគេឈប់បាញ់គ្នា ហើយបើសិនជាគេ និយាយគ្នាអំពីសិល្បៈតាំងពីព្រលឹមទល់ព្រលប់ ហើយគេសួរគ្នាទៅវិញទៅមក អំពីរឿងកុនមួយណាដែលល្អមើល ឬក៏ថាតើក្រុមភ្លេងរ៉ក Rock ថ្មីនៅ សហរដ្ឋអាមេរិក U.S.A. មានអ្វីខ្លះនៅក្នុងកាលៈទេសៈនោះ គេពិតជាអាចផ្តល់ភាពតស៊ូយ៉ាងស្វិតស្វាញទៅលើសិទ្ធិប្រល័យជីវិតដោយឥតត្រាប្រណីនោះបាន។ ខ្ញុំបានរកឃើញការបញ្ជាក់បន្ថែម មួយចំនួនទៅលើការព្យាបាលខ្លួនឯងនៅពេលដែលខ្ញុំធ្វើការនៅទីក្រុង នីវយក New York ក្រោយពីការវាយប្រហារបំផ្លាញមណ្ឌលពាណិជ្ជកម្មពិភពលោកភ្លាម ។ ក្រុមព្យាបាលមានរួមទាំងបុគ្គលិករបស់ខ្ញុំ បុព្វជិត(អាចារ្យ) ប្រចាំសកលវិទ្យាល័យ យេល Yale និងភ្ញៀវជាសាស្ត្រាចារ្យប្រទេសជប៉ុន បានជួយអ្នករួមការងាររបស់យើងនៅ បែលឡឺវ៉ Bellevue ថែទាំអ្នកជម្ងឺរងគ្រោះដោយភាពតក់ស្លុតនេះ។ សាមគ្គីភាពរបស់ប្រជាពលរដ្ឋទីក្រុង នីវយក New York ពីគ្រប់ជាតិសាសន៍ សញ្ជាតិ និងឋានៈសង្គម មានសភាពដ៏អស្ចារ្យ។ ដូចគ្នា និងស្សារ៉ាយ៉េវ៉ូ Sarajevo ជនគ្រប់រូបដឹងពីកាតព្វកិច្ចរបស់ខ្លួន ហើយម្នាក់ៗ ជួយផ្តល់សន្តិសុខ និងការពារគ្នាទៅវិញទៅមក។

ការសិក្សាស្រាវជ្រាវ ក្រោយមកបានបញ្ជាក់យល់ព្រមទៅតាម ការចាប់អារម្មណ៍របស់ខ្ញុំ អំពីទីក្រុង នីវយក ថាបុគ្គលដែលទទួលរងគ្រោះដោយព្រឹត្តិការណ៍ថ្ងៃទី១១ ខែ កញ្ញា ពុំត្រឹមតែរកជំនួយពី ក្រុមគ្រួសារ មិត្តភក្តិ អាចារ្យ និងគ្រឹះស្ថានសាសនាទេ។ គេបានរកជំនួយពី វេជ្ជបណ្ឌិត និងគិឡានុបដ្ឋាយិកាដោយសកម្មដែរ កំរិតដោះស្រាយដ៏អស្ចារ្យបាន បង្កើតឡើងជាកត្តាពិត វេជ្ជបណ្ឌិតប្រចាំខ្លួននៅ បែលឡឺវ៉ូ Bellevue បានធ្វើការសំរេចថា អ្នកជម្ងឺបានស្នើសុំ កុំអោយនិយាយពី បញ្ហាសង្គម និងបញ្ហាគ្រួសារតែសុំអោយគ្រាន់តែជួយខ្លួនគេលៃលកដោះស្រាយភាពភ័យខ្លាច និងភាពបារម្ភ ដើម្បីប្រឈម និងការវាយប្រហារភេរវកម្មនៅអនាគតតកាលជាពិសេសរបៀបជួយកូន និងក្រុមគ្រួសារនៅពេលមានវិបត្តិអាសន្ន។

ជនរងគ្រោះដោយភាពនទ្ធត់តក់ស្លុតទូទាំងពិភពលោក ធ្វើការស្នើសុំជំនួយ ផ្នែកព្យាបាលខ្លួនឯង ដូចគ្នា អ្នកប្រកបវិជ្ជាជីវៈ ផ្នែកព្យាបាល ជាពិសេសវេជ្ជបណ្ឌិតពុំអើពើ និងសេចក្តីស្នើសុំនេះទេ ហើយច្រើនតែអនុវត្តន៍ ដោយគ្មានការយល់ដឹងច្បាស់លាស់ ពីសេចក្តីត្រូវការរបស់ជនរួចផុតពីសេចក្តីស្លាប់។ ហេតុនេះកើតឡើងមួយ ចំនួន ទៅលើកត្តាពិតថា វេជ្ជបណ្ឌិត និងអ្នកព្យាបាលពុំដឹងជាគិតធ្វើយ៉ាងណាចំពោះមនុស្សដែលចង់ព្យាបាល ខ្លួនឯង។ ជាការងាយស្រួលក្នុងការគេ ពុំរវល់ជាមួយមនុស្សដែលមាន បញ្ហាច្រើនហួស និងដែលពុំអាចជួយបាន ដោយប្រើវិធីព្យាបាលទូទៅ។ ជនដែលរួចផុតពិសេចក្តីស្លាប់ ជាការពិត គឺគេហុចដៃមកអោយយើង ហើយ និយាយថាៈ "សូមកុំបដិសេធរូបខ្ញុំ ខ្ញុំនឹងបំពេញកិច្ចការមួយចំនួនធំ ហើយខ្ញុំគ្រាន់តែត្រូវការអោយអ្នកទទួលយក ការព្យាបាលរបស់ខ្ញុំ និងជួយខ្ញុំនៅពេលដែខ្ញុំដើរផ្លូវខុស"។

## ២.៣ បក្សីតូចមួយចូលក្នុងដួងព្រលឹងរបស់ខ្ញុំ

ខណៈបើកបង្ហាញការពិតមួយដែល ខ្ញុំមានភ័ព្វសំណាងបានទទួលបទពិសោធន៍ ដែលបង្ហាញពីកត្តាសំខាន់ៗ នៃភាពជិតស្និទដែលត្រូវតែ មានជាមួយ និងជនរួចផុតពីសេចក្តីស្លាប់ ដើម្បីផ្សព្វផ្សាយការព្យាបាល។ នៅក្នុងឆ្នាំ១៩៨៦ ខ្ញុំបានសួរអ្នករួមការងាររបស់ខ្ញុំ ស្វាង តោ Swang Tor ជាជនរួចផុតពីសេចក្តីស្លាប់ពីរបបប៉ុល ពត អោយជួយខ្ញុំនៅក្នុងកម្មវិធីប្រវត្តិសាស្ត្រ និយាយផ្ទាល់មាត់នៅបណ្ណាល័យ ឆ្លេតស៊ីងហ្គ័រ Schelesinger អំពីប្រវត្តិសាស្ត្រ ស្ត្រីនៅសហរដ្ឋអាមេរិក។ ខ្ញុំបានសុំអោយគាត់ជួយរកស្ត្រីខ្មែរចំនួនដប់នាក់ ដែលមានឋានៈ សង្គមផ្សេងៗ គ្នាដែលមករស់នៅក្នុងតំបន់នេះ។ ខ្ញុំរកអ្នកស្ម័គ្រចិត្តចូលរួមនៅក្នុងការនិយាយផ្ទាល់អំពីប្រវត្តិជីវិតរបស់គេ ។ ស្ត្រីដែលយើងរកបាននៅក្នុង ដប់ប្រាំ ឆ្នាំខាងមុខ គឺមានប្រវត្តិគ្រប់បែបយ៉ាង អ្នកខ្លះជាអ្នកធ្វើស្រែ ម្នាក់ជាអ្នករបាំព្រះរាជ្យទ្រព្យ ម្នាក់ទៀតជាម្ចាស់ក្សត្រី អ្នកទាំងនេះ ពុំដែលនិយាយពី ប្រវត្តិជីវិតរបស់គេ ប្រាប់នរណាម្នាក់ឡើយ។ ស្ត្រីទាំងនេះបានទទួលសម្ភាសន៍ម្នាក់ៗ លើសពីចំនួន១២ម៉ោង គេពុំមែនជាអ្នកជម្ងឺរបស់យើងតែគេជាសមាជិកនៅក្នុងសហគមន៍។ អ្វីដែលបានទទួលពីកម្មវិធីនេះ គឺទស្សនវិស័យប្រវត្តិសាស្ត្ររបស់ស្ត្រី ចំនួនដប់នាក់ ដែលទទួលការបាត់បង់ និងបំភ្លេចចោលដោយសារតែភាពសាហាវយង់ឃ្នងដែលស្ត្រីទាំងនោះបានទទួលបទពិសោធន៍ ហើយស្ត្រីទាំងនេះបានផ្តល់ដល់យើងនូវការយល់ដឹងដ៏ធំធេងអំពីសេចក្តីតក់ស្លុត និងឥទ្ធិពលដែលកើតឡើងក្រោយមក។

ការរៀបចំប្រមូលប្រវត្តិបរិយាយផ្ទាល់មាត់ទាំងនេះ ស្វាមី និងរូបខ្ញុំពុំមានគំរូប្រៀបធៀបអ្វីមួយដែលយើងអាចចម្លងបាន ដើម្បីចាប់ផ្តើមយើងត្រូវសំរេច ពីកំរិតទំនាក់ទនង រវាងអ្នកផ្តល់ប្រវត្តិសាស្ត្រ និងរូបយើង។ យើងពុំមែនជាអ្នកព្យាបាលរបស់គេ ហើយគេក៏ពុំមែនជាអ្នកជម្ងឺរបស់យើង យើងពុំសង្ឃឹមថាគេ នឹងបញ្ចេញរឿងជីវិតផ្ទាល់ខ្លួនរបស់គេដោយក្បោះក្បាយឡើយ។ យើងក៏ពុំមែនជាអ្នកកាសែតដែលសរសេរអំពីដំណើររឿងជីវិតរបស់ស្ត្រីខ្មែរ ឬជាអ្នកប្រាជ្ញ បោះពុម្ពសៀវភៅប្រវត្តិសាស្ត្រ សង្គមរបស់ស្ត្រីខ្មែរដែរ។ ដូច្នេះ ដើម្បីបង្កើតកំរិតភាពស្និទ្ធស្នាលដែលធ្វើអោយមានទិដ្ឋភាពប្រវត្តិសាស្ត្រ នៅក្នុងការសម្ភាសន៍យើងបានប្រាប់អ្នកទាំងនោះថាៈ "អ្នក

បរិយាយអំពីប្រវត្តិសាស្ត្រតាមរយៈរូបយើង"។ រឿងទាំងនេះ ជារឿងប្រវត្តិសាស្ត្រដោយអ្នកនិយាយរឿង ទោះបីជាខ្លួនគេក្រីក្របែបយ៉ាងណា ឬជាជនសាមញ្ញ គេជឿថារឿងនេះពុំមែនគ្រាន់តែជារឿងរបស់ខ្លួនគេទេ តែវាជារឿងវប្បធម៌ និងសង្គមរបស់គេ។ វាបង្រៀនអំពីបែបបទដែលពិភពលោកមានដំណើរការនៅក្នុងជីវិតរបស់គេ ស្ត្រីទាំងនេះ បានយល់ព្រមថារឿងរបស់គេ ជាការពិពណ៌នាពិត នៃរបបខ្មែរក្រហម ។

ប៉ុន្តែ តើយើងអាចកោតសរសើរអបអរដោយពេញទំហឹងទៅលើបទពិសោធន៍ និងអារម្មណ៍ដែលស្ត្រីទាំងនេះបញ្ចេញអំពីជីវិតរបស់គេទេ? ទោះជាស្វាមី និងរូបខ្ញុំជាមួយអ្នករួមកិច្ចការដែលមានភាពទីទៃពីគ្នា ចំណងមិត្តភាពរបស់យើង ផ្តល់នូវបរិយាកាសល្អដល់ស្ត្រីទាំងនេះ។ ស្វាមីជាជនរងគ្រោះនៃវាលពិឃាត តែគាត់ក៏ធ្វើការជិតស្និតជាមួយខ្ញុំនៅមន្ទីរសុខភាពជាបុគ្គលិក ផ្នែកសតិអារម្មណ៍។ គាត់សម្ភាសន៍ស្ត្រីទាំងនេះជាភាសាខ្មែរ ខ្ញុំចាំស្តាប់ដោយស្ងៀមស្ងាត់យូរៗម្តង ស្វាមីឈប់ហើយនិយាយកាត់ចំណុចសំខាន់ៗជាភាសាអង់គ្លេស។ ខ្ញុំសរសេរកត់ត្រាទុកហើយចងចាំចំណុចទាំងនេះ នៅពេលដែលយើងស្តាប់ ខ្ញុំកោតសរសើរការនិយាយទាក់ទងដោយកាយវិការរបស់អ្នកបរិយាយរឿង។ ការស្តាប់រាប់រយម៉ោង ជាភាសាបរទេសដែលខ្ញុំស្តាប់ពុំយល់ បានបង្រៀនខ្ញុំអោយយល់ដឹងពីបទពិសោធន៍របស់អ្នក ទាំងនោះដោយគ្មានការនិយាយស្តី។ ខ្ញុំអាចមើលដឹងការបញ្ចេញគំនិតយល់ពីអារម្មណ៍របស់គេ ហើយអាចមើលឃើញទិដ្ឋភាពដែលគេបរិយាយជាភាសាខ្មែរ។ ស្ទើរតែគ្រប់ពេលសម្ភាសន៍ទំនាក់ទំនងផ្ទាល់ខ្លួនបានកើតមានឡើងរវាងស្វាមី ស្ត្រីទាំងនោះ និងរូបខ្ញុំ ទំនាក់ទំនងរវាងយើងទាំងបីនាក់គ្មានអាក់រអួល ហើយគ្មានកំណត់ពេល ។

ទោះបីជា រូបខ្ញុំពុំមែនជាខ្មែរ ឬជាស្ត្រីភេទអារម្មណ៍របស់ខ្ញុំពោរពេញទៅដោយរឿងប្រវត្តិសាស្ត្រដែលបរិយាយផ្ទាល់មាត់ដោយសម្លេងរបស់ស្ត្រីទាំងនេះ ខ្ញុំពុំដែលមានស្តាប់អ្វីមួយដែលឮខ្លាំង ឬច្បាស់នោះទេ ។ នៅពេលដែលអ្នកនិយាយរឿងប្រវត្តិសាស្ត្រ ខ្ញុំក៏យំ នៅពេលគេសើច ខ្ញុំក៏សើច នេះជារឿងធម្មជាតិ។ ការខុសប្លែកជាតិសាសន៍ និងវប្បធម៌រវាងយើងពុំកាត់បន្ថយនូវសេចក្តីអរគុណរបស់ខ្ញុំ ទៅលើប្រវត្តិដំណើរជីវិតរបស់គេ ដូចគ្នា និងអ្នកស្តាប់សម័យឥឡូវដែលចាប់អារម្មណ៍ទៅលើទឹកដមកំណាព្យបុរាណ រាប់ពាន់ឆ្នាំក្រោយមក។ កម្មវិធីនេះផ្តល់អោយយើង នូវសេចក្តីត្រេកអរទៅលើការយល់ដឹងទូលំទូលាយដែលអាចបង្កើតឡើង រវាងមនុស្សដែលមានវប្បធម៌ បទពិសោធន៍ និងភេទទីទៃពីគ្នា ។

សេចក្តីបញ្ចប់ ប្រវត្តិសាស្ត្រផ្ទាល់មាត់ មានរួមទាំងការរៀបចំបកប្រែភាសាពីខ្សែអាត់សម្លេង ក្លាយទៅជារឿងស្មុគស្មាញដល់ស្វាមី និងរូបខ្ញុំ។ ស្ត្រីទាំងនោះពេញចិត្ត និងដំណើរការទាំងនោះ គេបានបរិយាយអំពីប្រវត្តិសាស្ត្រ តាមរយៈរូបយើងហើយភារកិច្ចរបស់គេបានបញ្ចប់សព្វគ្រប់ ។ ផ្ទុយទៅវិញស្វាមី និងខ្ញុំពុំជាក់ច្បាស់ថាតើត្រូវចាត់ចែងយ៉ាងណាទៅលើរឿងទាំងនេះ ។ វាជាការពុំសមរម្យដែលយើងយករឿងនេះ ផ្តល់ទៅអោយជនដែលចូលចិត្តរឿងនេះដូចជា ផ្នែកកម្មវិធីសិក្សា និងផ្នែកប្រកបអាជីវកម្ម។ រឿងនៅពុំមែនជារឿងរបស់យើង យើងពុំមានសិទ្ធិ ទទួលការកោតសរសើរពីរឿងទាំងនោះឡើយ ម្យ៉ាងវិញទៀត ការដាក់រឿងនោះចោលនៅបណ្ណាល័យរង់ចាំទស្សនិកជនអនាមិកហាក់បីដូចជាពុំត្រឹមត្រូវ។

រឿងនោះ ជារឿងដែលពិបាកអាន គ្រប់វគ្គវាផ្ទុកនូវសេចក្តីឈឺចាប់ និងទុក្ខសោក យើងមានមតិផ្ទុយគ្នាទៅលើការចែកចាយរឿងនេះ ជាមួយអ្នកឯទៀត ម៉្យាងវិញទៀតយើងក៏ពុំចង់បោះបង់កិច្ចការទាំងនោះយល់ដែរ។ យើងឆ្ងល់ថា តើយើងបានចំណាយពេលជិតដប់ប្រាំឆ្នាំ ទៅលើការងារដោយឥតគិតនោះ ដោយមកពីយើងពុំបានចំណាយពេលគ្រប់គ្រាន់ គិតអោយច្បាស់លាស់ អំពីវិធីដែលយើងត្រូវចែកចាយលទ្ធផលចុងក្រោយ។ តែកម្មវិធីនោះបានធ្វើអោយយើងផ្លាស់ប្តូរ ក្រោយពីយើងបានបញ្ចប់កិច្ចការដ៏ឈឺចាប់នេះ យើងបានក្លាយទៅជាបុគ្គលនិងអ្នកព្យាបាលប្រសើរឡើង។ យើងដឹងថា ប្រវត្តិសាស្ត្របរិយាយផ្ទាល់មាត់ មានផ្ទុកនូវលទ្ធភាព ផ្លាស់ប្តូរភាពស្ងប់ស្ងាត់របស់អ្នកឯទៀត ។ តើដោយរបៀបណា?

ខ្ញុំបានរកឃើញដំណោះស្រាយមួយ នៅក្នុងផ្ទាំងគំនូរថ្មី នៅពេលតាំងពិពណ៌នៅក្នុងសារមន្ទីរសិល្បៈទីក្រុងនីវយក។ នៅក្នុងផ្ទាំងគំនូរតូចមួយរបស់វិចិត្រករ ស្សាសែតា Sassetta ប្រទេសសាយអ៊ីនីស Sienese សន្តបុគ្គល (អ្នកកាន់សីលធម៌) អាហ្គីណូ Saint Thomas Aquinas កំពុងបន់ស្រន់ដល់ព្រះយេស៊ូ ដែលបូជាជីវិតនៅលើឈើឆ្កាង។ ហើយនៅក្នុងមាត់ព្រះយ៉េស៊ូ ឃើញមានបក្សីដ៏ល្អប្រណិតហើរចេញពីមាត់ទ្រង់ ចូលទៅក្នុងមាត់សន្តបុគ្គលនោះ។ នៅពេលដែលខ្ញុំ កំពុងតែមើលគំនូរនេះ ខ្ញុំបានសួរខ្លួនឯងថា តើទស្សនិកជនអាចមើលឃើញសត្វបក្សីតូចនេះ ឬមានកោតសរសើរនូវអត្ថន័យដ៏សំខាន់ៗ ដែលមានសំរាប់សន្តបុគ្គលនោះដែរឬទេ។ កាលពីជំនាន់សិល្បៈ អក្សរសាស្ត្រ ទំនើប និងកើតឡើងនៅក្នុងសតវត្សទី១៤ សន្តបុគ្គលទទួលការគោរពថាជាបុព្វបុរសខុសពីជំនាន់បុព្វបុរសហ្វ្ល័រ៉ង់ Florence ក្រិច និងរ៉ូម៉ាំង Roman សន្តបុគ្គលទទួលការគោរព និងយកធ្វើជាគំរូ។ ផ្ទាំងគំនូរដ៏ប្រណិតនេះបានគូរឡើងជាផ្ទាំងគំនូរសំរាប់អាសនៈ (សក្ការបូជា) សំរាប់អោយតែបុព្វជិត (អ្នកបួស) មើលឃើញនៅពេលដែលបុព្វជិតនោះកំពុងតែប្រារព្ធមហាសន្និបាតសាសនា ដើម្បីជួយរំឭកបុព្វជិតនោះអោយដើរតាមគន្លងធម៌របស់សន្តបុគ្គលដែលគេបានធ្វើឡើងដល់សហគមន៍។ ព្រលឹងបក្សីនៃព្រះយ៉េស៊ូជាការពិតពុំមែនគ្រាន់តែចូលទៅក្នុងសន្តបុគ្គលថូម៉ាស់ ប៉ុណ្ណោះទេ វាចូលទៅក្នុងព្រលឹងបុព្វជិតមានជីវិតដែលបានឃើញគំនូរនេះជាសាក្សី។ នៅក្នុងឱកាសបញ្ចេញអោយដឹងនេះ គឺជាពេលដែលខ្ញុំ ទើបតែយល់ដឹងពីគោលដៅប្រវត្តិសាស្ត្រផ្ទាល់មាត់។ រឿង "ព្រលឹងសត្វបក្សី" របស់ស្ត្រីខ្មែរដែលហើរចូលដួងព្រលឹងរបស់យើង និងដួងព្រលឹងរបស់អ្នកឯទៀតដែលសុខចិត្តខិតចូលជិត ដើម្បីស្តាប់រឿងរបស់ ជនរួចផុតពីសេចក្តីស្លាប់។ នេះជាឧទាហរណ៍ បទពិសោធន៍ការព្យាបាល ដែលអ្នកព្យាបាលត្រូវដាក់ខ្លួនអោយជិត និងភាពឈឺចាប់ និងទុក្ខសោករបស់ជនទទួលភាពតក់ស្លុត ដើម្បី និងយករឿងនោះមកបកស្រាយ វិធីនេះក្លាយទៅជាមូលដ្ឋាន សំរាប់អនុវត្តន៍រាល់ការព្យាបាលទាំងអស់។

## ២.៤ សេចក្តីឈឺចាប់របស់អ្នកព្យាបាល

ពេលខ្លះអ្នកព្យាបាល និងអ្នកជម្ងឺរបស់គេ អាចឈានទៅភាពខ្មាស់អៀនដែលមានរួមទៅដោយអ្វីៗ ដែលប៉ះពាល់ឡើងដោយអំពើឃោរឃៅខ្លាំង។ ភាពអាម៉ាស់មុខក្នុងសង្គម និងភាពអៀនខ្មាស់អាចកើតឡើងទៅលើ

អ្នកជម្ងឺដែលមានរោគមហារីក រោគអេចអាយវី/រោគអេដ ឬរោគវង្វេងស្មារតី ដ៏ដូចជាអ្នកជម្ងឺដែលកំពុងតែលែលកដោះស្រាយ និងអំពើហឹង្សាក្នុងគ្រួសារ និងអំពើបំពារបំពានផ្លូវភេទ។ វេជ្ជបណ្ឌិតក៏អាចទទួលការប៉ះពាល់ដោយបាតុភូតអាក្រក់នេះដែរ។ ខ្ញុំពុំដឹងខ្លួនរហូតទាល់តែកូនប្រុសរបស់ខ្ញុំធំដឹងក្តីឡើង ហើយវាបានសួរខ្ញុំថា តើខ្ញុំប្រកបរបរអ្វីដើម្បីចិញ្ចឹមជីវិត។ មនុស្សជាច្រើនចាត់ទុកថាការងាររបស់ខ្ញុំជាអ្នកថែទាំជនរួចផុតពីសេចក្តីស្លាប់ដោយភាពសាហាវយង់ឃ្នង និងអំពើទារុណកម្មជាអំពើវីរៈបុរស។ ខ្ញុំតែងតែទទួលកិត្តិយសជាពិសេស នៅក្នុងចំណោមអ្នករួមការងារពេទ្យ នៅពេលដែល ខិតខំប្រឹងប្រែងបំពេញកិច្ចការ ផ្នែកពេទ្យដោយមាន សីលធម៌ច្បាស់លាស់ និងសភាគតិការងារ។ តែនៅពេលដែលកូនរបស់ខ្ញុំចាប់ផ្តើមសួរខ្ញុំ ខ្ញុំត្រូវទទួលស្គាល់ថាខ្ញុំពុំសូវចង់និយាយប្រាប់គេច្រើនទេ ដោយខ្ញុំមានការខ្មាស់អៀន នឹងការងាររបស់ខ្ញុំ។ ក្នុងនាមជាអ្នកព្យាបាល ខ្ញុំបានរកឃើញថាពុំអាចលាងបំបាត់ស្នាមសាហាវយង់ឃ្នងរបស់មនុស្សលោក ដែលគេបានទទួលនោះ តាមរយៈ វិធីព្យាបាលឡើយ ។ ការប្តេជ្ញា ការចូលរួម និងការទទួលយករបស់វេជ្ជបណ្ឌិតដោយគ្មានស្ទាក់ស្ទើរ ទៅលើភាពខ្មាស់អៀនដែលលាក់ទុកដោយស្ងាត់ពុំអាចពិចារណាបាន វាជារឿងមួយដែល នឹងពិបាកពន្យល់ដល់កូនក្មេង។

ទស្សនិកជនមានភាពអៀនខ្មាស់ នៅពេលដែលគេចូលទៅក្នុងសារមន្ទីរវិនាសកម្ម ឬឈរនៅមុខផ្ទាំងសិលា រំឭកវិញ្ញាណក្ខ័ន្ធ ជនសង្គ្រាមវៀតណាម នៅរដ្ឋវ៉ាស៊ីងតោនឌីស៊ី Washington DC ។ ប្រត្តិកម្មដំបូងគេ គឺការព្យាយាមទប់អារម្មណ៍ដែលបណ្តាលអោយទឹកភ្នែកហូរ ដោយពុំអាចទប់បាន ក្លាយទៅជាសេចក្តីខឹងរួមទៅដោយអារម្មណ៍ខ្មាស់អៀន។ បុព្វហេតុនេះអាចពុំមែនកើតឡើងជាទូទៅ តែវាជាបុព្វហេតុដែលមនុស្សជាច្រើនបានបរិយាយឡើង ហើយដែលរូបខ្ញុំមានបទពិសោធន៍។ ពិភពខ្មាស់អៀនតែងតែកើតមានឡើង ដោយជនរងគ្រោះទទួលអំពើរំលោភផ្លូវភេទគ្មានឈប់ឈរ អំពើហឹង្សាលើកុមារ និងជនគ្មានទោសឯទៀត ដែលក្លាយទៅជាជនភៀសខ្លួន ដោយសារអំពើយង់ឃ្នងរបស់មនុស្សលោក។ អ្នកព្យាបាល និងអ្នករួចផុតពីសេចក្តីស្លាប់ ពុំមានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មទេ ស្ទើរតែ គ្រប់រូបទាំងអស់គេមានអារម្មណ៍ទទួលខុសត្រូវទៅលើអ្វីមួយ។ ថាង Thang ឈ្លើយសង្គ្រាមវៀតណាម ពុំអាចប្រឈមមុខ និងអ្នកឯទៀតដែលមានវ័យប្រហែលគាត់ដោយការធ្វើអោយអាម៉ាស់មុខរបស់គាត់ តែគាត់ពុំបានអភ័យទោសអោយខ្លួនគាត់ឡើយ។

សេចក្តីឈឺចាប់របស់អ្នកជម្ងឺអាចជ្រាបចូលទៅក្នុងសតិគំនិត និងអារម្មណ៍របស់វេជ្ជបណ្ឌិតដ៏ជ្រៅ ហើយនៅតែវិលវល់គ្មានទីបញ្ចប់។ ពាក្យពេចន៍របស់កវីកំណាព្យបុព្វបុរសក្រិច ស្សាហ្វូ Sappho បរិយាយអំពីដំណើរការនេះ៖

⇨ សេចក្តីឈឺចាប់ជ្រាបចូល

☞ ខ្ញុំធ្លាក់

☞ ម្តងបន្តិចៗ[10]

ការធ្វើជាសាក្សីទៅលើអំពើឃោរឃៅអាចធ្វើអោយសាក្សីទទួលរងគ្រោះដូចគ្នា នឹងអ្នកដែលទទួលបទពិសោធន៍ដោយអំពើឃោរឃៅដែរ។ បានន័យថា វេជ្ជបណ្ឌិតក៏ទទួលភាពប៉ះពាល់អារម្មណ៍ដែរ នៅពេលដែលគេ

ជួយព្យាបាលព្រឹត្តិការណ៍ ហេតុកើតឡើងដោយបទពិសោធន៍។ អ្វីៗទាំងនេះពុំអាចជៀសបានឡើយ ដោយបុគ្គលិក មន្ទីរពេទ្យព្យាបាលបានសហការរួមគ្នាយ៉ាងរឹងមាំជាមួយ និងអ្នកជម្ងឺដោយព្យាយាម ដើម្បីសំរេចគោលដៅដែលនាំមកនូវលទ្ធផលព្យាបាលល្អ។ តើវេជ្ជបណ្ឌិត និងអ្នកជម្ងឺខំព្យាយាមតស៊ូដោយវិធីណា?

បន្ទាប់ពីគ្រាមួយដែលខ្ញុំបានធ្វើការនៅបាល់កាន Balkans ខ្ញុំបានធ្វើដំណើរទៅប្រទេសអ៊ីតាលី Italy ដើម្បីលំហែរអារម្មណ៍ និងពង្រឹងស្មារតីឡើងវិញ។ រូបខ្ញុំហ្វិតល្វែក្រៃលែង អស់ទាំងកម្លាំងកាយទាំងកម្លាំងចិត្ត ក្រោយពីខ្ញុំបានជួបប្រទះ និងវិនាសកម្មទាំងនោះ ដោយខ្ញុំមានអារម្មណ៍ថាមនុស្សលោកពុំអាចលះបង់អំពើកំណាចឃោរឃៅ និងជាសភាពជាមនុស្សព្រៃខ្វះអរិយធម៌នៅបានឡើយ។ ការប្រណាំងប្រជែងរបស់មនុស្សហាក់បីដូចជា លឿនទៅមុខ ដែលបង្កើតអោយមានជនរងគ្រោះ និងអ្នកជម្ងឺថ្មីៗ គ្មានឈប់ឈរ។ ហើយក្រោយមននៅពេលដែលខ្ញុំដើរទៅសារមន្ទីរវិឡាប័ហ្គិស Villa Borghese នៅទីក្រុងរ៉ូម Rome នៅឱកាសនោះខ្ញុំបានទទួលបទពិសោធន៍ភ្លឺស្វាងមួយ។ ខ្ញុំឈរនៅចំពីមុខផ្ទាំងគំនូរដ៏ធំអស្ចារ្យមួយ ដែលគូរដោយវិចិត្រករការ៉ាវ៉ាហ្គូ Caravaggio ដែលខ្ញុំពុំធ្លាប់បានឃើញពីមុនមក។ ផ្ទាំងគំនូរពណ៌នាអំពីនាងម៉ារា Mary ព្រះយេស៊ូ វ័យក្មេង ដែលកំពុងតែយកជើងជាន់ក្បាលពស់។

ជាដំបូងអ្នកពិតជាពុំចាប់អារម្មណ៍ឡើយដោយឃើញជើងធំៗ លេចចេញពីរ៉ូបរបស់ដូនជីក្រមុំ ជើងធំម្រាមជើងធំៗ ត្រលុកត្រលន់ពុំមែនដូចយើងគិតក្នុងចិត្តថាជើងម៉ារា Mary មានរាងតូចស្រលូននោះទេ។ ហើយនៅលើខ្នងជើងរបស់មាតានេះ គឺមានជើងតូចរបស់ព្រះយេស៊ូ សង្កត់សន្សឹមៗ ទៅលើជើងរបស់ម៉ារា ហើយធ្វើអោយជើងម៉ារាជាន់បំបែកក្បាលពស់នោះ។ ដូនជីអាន Ann ជាមាតារបស់ម៉ារាមើលឃើញអាកប្បកិរិយានេះ គាត់បានបញ្ចេញទឹកមុខពោរពេញដោយភាពស្តីបន្ទោស ទឹកមុខរបស់គាត់បង្ហាញថាគាត់ពុំពេញចិត្ត និងអាកប្បកិរិយារបស់ព្រះយេស៊ូឡើយ ។ មាតារបស់ព្រះយេស៊ូ បញ្ចេញអារម្មណ៍ហាក់បីដូចជាស្រឡាំងកាំង ពុំរីករាយហើយក៏ពុំខឹងដែរ នាងហាក់បីដូចជាចេញវាចារថា "បុត្រធ្វើអ្វីហ្នឹង"? នៅក្នុងកែវភ្នែករបស់ព្រះយេស៊ូ បង្ហាញនូវភាពប្តេជ្ញា។ ព្រះអង្គបានដឹងជាស្រេចអំពីការបូជាជីវិតនៅលើឈើឆ្កាងរបស់ព្រះអង្គ ព្រះអង្គជាក្មេងប្រុសមានរូបរាងសង្ហា ក្មេងខ្ជីដែលដាក់ខ្លួនប្រឈមមុខ និងវត្តមានអំពើសាហាវគ្មានសីលធម៌។ ព្រះអង្គដឹងថាព្រះអង្គត្រូវតែធ្វើដូច្នេះទៅលើសត្វពស់នោះ ទោះបីជាវាពុំអាចកែប្រែអ្វីៗ ដែលឡើងដល់រូបព្រះអង្គនៅពេលអនាគតក៏ដោយ ព្រះអង្គដ៏ដូចជាក្មេងឯទៀតដែរ ជាក្មេងមានប្រាជ្ញាឈ្លាសវៃ ដូចជាបុរសឆ្លាតម្នាក់តែមានរាង្គកាយជាកូនក្មេង។

ព្រះយេស៊ូ វ័យក្មេង កូនប្រុសរបស់ខ្ញុំ និងកូនរបស់យើងទាំងអស់គ្នា ដឹងច្បាស់ណាស់ថាព្រះត្រូវធ្វើអ្វីខ្លះៗ នោះ។ កូនរបស់ខ្ញុំដឹងច្បាស់អំពីការងាររបស់ខ្ញុំ ហើយគេកោតសរសើរការងារដែលជាដួងជីវិតរបស់ខ្ញុំដោយស្ងៀមស្ងាត់។ គេពុំខ្លាច នឹងនិយាយទេ។ ដោយស្ងៀមស្ងាត់គេដាក់ជើងរបស់គេនៅលើជើងរបស់ខ្ញុំ ហើយខ្សឹបដាក់ត្រចៀកខ្ញុំយ៉ាងពិរោះថា "ខំជម្រុញទៀតទៅប៉ា។ ប៉ាអាចហត់នឿយ និងខកចិត្តបន្ទាប់ពីខិតខំធ្វើការនេះរស់រយៈពេលជាង ម្ភៃឆ្នាំ តែយើងនៅតែគាំទ្រប៉ាជានិច្ច"។ ក្មេងមើលឃើញការពិតដោយច្បាស់លាស់ណាស់ វាពុំមានអារម្មណ៍ផ្ទុយគ្នា ឬគិតពីភាពសមហេតុផលស្មុគស្មាញឡើយ អ្នកនយោបាយធ្វើអោយប្រជាជនរាប់លាននាក់នៅ

បាល់កាន់ Balkans វេងទុក្ខ ហើយនៅក្នុងកាសែតឃើញមានសុទ្ធតែសេចក្ដីដោះសារ ឯកសារយោងប្រវត្តិសាស្ត្រ សេចក្ដីស្វែងរកអភ័យទោសពីវិញ្ញាណក្ខ័ន្ធ សេចក្ដីភូតកុហក សេចក្ដីបដិសេធ សេចក្ដីផ្លែងសក្ខីភាព សេចក្ដីបរិហារកេរ្ដិ៍ សេចក្ដីអត់អោន...និងសេចក្ដីបកស្រាយភាពពិតខុសស្រឡះគ្មានទីបញ្ចប់។

នៅមុខផ្ទាំងគំនូរមួយនេះ ខ្ញុំបានបិទភ្នែកហើយ នឹកគិតទៅដល់សេចក្ដីចងចាំដ៏អស្ចារ្យ នៃការលះបង់ នឹងសេចក្ដីថ្លៃថ្នូរ របស់មនុស្សជាតិ ដែលខ្ញុំបានឆ្លងកាត់ជាមួយអ្នកដ៏ទៃទៀត ដែលបានផ្ដល់អោយខ្ញុំនូវសោភ័ណភាព និងសេចក្ដីស្រលាញ់ នៅពេលខ្ញុំដឹងខ្លួនថា ខ្ញុំអាចព្យាយាមបាន ដោយខ្ជាប់ខ្ជួន តទៅមុខទៀត។

## ជំពូកទី ២ រឿងនិទានតក់ស្លុត

បុព្វបុរសប្រទេសក្រិច Philoctetes ជាឧទាហរណ៍ដែលបរិយាយភាពចាំបាច់នៃហេតុការណ៍តក់ស្លុតពិត និងរឿងរបស់ជនរួចផុតពីសេចក្តីស្លាប់។ វាជាទេពកោសល្យរបស់បុព្វបុរសប្រទេសក្រិច Sophocles នៅកំណត់ពេលជាង ពីរពាន់ឆ្នាំមុនគាត់បានសរសេររឿងមនោសញ្ចេតនា ដែលនៅតែបរិយាយចំច្បាស់ទៅលើបទពិសោធន៍ពិបាកដែលជា ប្រស្នាផ្ទាល់ខ្លួនរបស់យើង ឬអំពើសាហាវយង់ឃ្នង ដែលយើងចងចាំ។ រឿងនេះជាសេចក្តីពិចារណាទៅលើវាសនារបស់ជនដែលបានជួប នឹងរឿងតក់ស្លុត៖ តើយើងអាចរួចផុតពីសេចក្តីស្លាប់ដោយបែបណាហើយអាចក្លាយទៅជាមនុស្សពេញលេញវិញយ៉ាងណាទៅ នៅពេលដែលយើងបានជួបប្រទះនឹងព្រឹត្តិការណ៍តក់ស្លុតដែលធ្វើអោយយើងឈឺចាប់ និងធ្លាក់ទៅក្នុងកាលៈទេសៈ ដែលពុំអាចស្មានទុកជាមុន ហើយសង្គមរបស់យើងគេពុំធ្វើដឹងឮ ឬបានបោះបង់យើងចោលនោះ? ហ្វីឡុក់តេតេស Philoctetes ជាមិត្តដ៏ល្អរបស់ហឺហ្គូលី Hercules គាត់បានទទួលអានិច្ចកម្មទៅ ដោយហេរ៉ា Hera បានបញ្ជាអោយសត្វពស់វែក ពិសិដ្ឋទៅចឹក Hercules បណ្តាលអោយមានរបួសមើលពុំជា និងឈឺចុកចាប់ក្រៃលែងដែលពុំអាចទ្រាំទ្របាន។ គោលបំណងរបស់ហេរ៉ា Hera គឺធ្វើយ៉ាងណារារាំង ពួកក្រិចមិនអោយឈ្នះសង្គ្រាមត្រូវជាន Trojan ដោយប្រើធ្នូវេទមន្តរបស់ហឺហ្គូលី Hercules ដែលគាត់បានអោយទៅ Philoctetes នៅពេលដែលគាត់ជិតដាច់ខ្យល់ស្លាប់។ ផ្ទុយពីទទួលការសង្គ្រោះរបួស និងសម្រាលសេចក្តីឈឺចាប់ដោយអ្នករួមអាវុធក្រិច Philoctetes ត្រូវគេបោះបង់ចោលអោយនៅកណ្តាលកណ្តោងតែម្នាក់ឯងនៅលើកោះឡឹមណូស Lemnos ។

គ្មាននរណាម្នាក់ ឮការស្រែកទ្រហោរយំ សោកស្តាយរបស់គាត់ ដែលលាក់ការពិតថា មានតែធ្នូរបស់ Hercules ដែល Hercules បានអោយ Philoctetes នោះទេ អាចជួយស្រោចស្រង់ប្រទេសក្រិចហើយអាចបញ្ចប់សង្គ្រាម Trojan បាន។ បន្ទាប់ពីភាពបរាជ័យនៃសង្គ្រាមនេះចំនួន ប្រាំបួនឆ្នាំមក ពួកក្រិចបានដើររកបុព្វបុរសដែលគេបានបោះបង់ចោលនៅឡឹមណូស ដើម្បី នឹងរកវិធីសង្គ្រោះខ្លួនគេ។ ដូចអូឌីស្សឺស Odysseus បាននិយាយថា "មានតែធ្នូរបស់គាត់ទេដែលអាចចាប់ត្រយ Troy បាន"។ អូឌីស្សឺសព្យាយាមបញ្ចុះបញ្ចូលបុត្ររបស់អាធីលេ Achilles ឈ្មោះ នី អូបតូលីមីស Neoptolemus អោយទៅនិយាយកុហក Philoctetes ដើម្បី នឹងលួចធ្នូ របស់គាត់។ តែជាអកុសល សេចក្តីអាណិតអាសូររបស់ Neoptolemus ធ្វើអោយខូចគម្រោងការរបស់ Odysseus អស់ដោយបុរសវ័យក្មេងនេះពុំអាចក្បត់មិត្តរបស់ឪពុកខ្លួន នៅខណៈដែលវាឃើញគាត់កំពុងតែឈឺចាប់។ ដោយសុច្ចរិតភាពរបស់ក្មេងប្រុសនេះ សេចក្តីពិតនៃផែនការណ៍បោកប្រាស់នេះបានលាតត្រដាងយ៉ាងច្បាស់ឡើងថា៖

ធ្នូគ្មានតម្លៃបើគ្មានអ្នករស់រានមានជីវិតប្រើវាមានតែ Philoctetes ទេដែលអាចបាញ់ធ្នូនេះបាន ជាញឹកញាប់អ្នកស្តាប់ជំនាន់ថ្មីព្យាយាម " លួច - (បំបាត់) " " ធ្នូ (រឿង) " សេចក្តីតក់ស្លុតដោយពុំបានគិតថា អត្ថន័យពិតពុំអាចលាតត្រដាងបានឡើយ បើគ្មានការចូលរួមពីអ្នករួចផុតពីសេចក្តីស្លាប់។ រឿងរបស់ Philoctetes ពុំមែន

គ្រាន់តែជារឿងមានធ្នូជាកម្មសិទ្ធិនោះទេ តែវាជារឿងទាក់ទង នឹងវិធីប្រើប្រាស់ នៅក្នុងករណីរឿងរបស់ជនរួចផុតជីវិតពីភាពកត់ស្លុត ធ្នូរប្រៀបដូចជារឿងដែលគេបាននិយាយចប់សព្វគ្រប់។ មានតែការយកចិត្តទុកដាក់ស្តាប់សេចក្តីរៀបរាប់រឿងរបស់អ្នករួចផុតពីសេចក្តីស្លាប់អោយចប់សព្វគ្រប់ ពេលនោះហើយជាកំណត់ពេលព្រួញអាចបាញ់លែងចេញពីធ្នូបាន នៅក្នុងដំណាក់ការនេះ ជាកំណត់ពេលដែលជនរងគ្រោះព្រមទាំងសង្គមអាចទទួលភាពសះស្បើយបាន។

ទោះជាយ៉ាងណាក៏ដោយ ការរៀបរាប់រឿងតក់ស្លុត ប្រកបដោយចំនេះដឹង និងគតិបណ្ឌិតច្រើនស្រទាប់ អាចចែកចាយដល់អ្នកព្យាបាល និងអ្នកទ្រឹស្តី ដែលច្រើនតែយកចិត្តទុកដាក់ទៅលើការបែងចែករឿងតក់ស្លុតពីអ្នកនិយាយរឿងដោយយកមូលដ្ឋាននិយាយថា "យើងមានរឿង យើងពុំត្រូវការភាពពិតផ្ទាល់ខ្លួនរបស់អ្នកនិយាយរឿងឡើយ"។

## ផ្នែក ១. ប្រវត្តិគោលដៅ នៃរឿងតក់ស្លុត

រឿងតក់ស្លុតមានគ្រប់ទីកន្លែង នៅក្នុងថ្ងៃណាមួយសូមសាកល្បងយកចិត្តទុកដាក់ទៅលើអ្វីៗ ដែលបានចែកចាយរវាងប្តីប្រពន្ធ ញាតិសន្តាន មិត្តភក្តិ អ្នករួមកិច្ចការ ផ្នែកផ្សាយព័ត៌មាន និងបុព្វជិត (អាចារ្យ) ផ្នែកគ្រឹះស្ថានសាសនារបស់យើង។ ជាទូទៅរឿងទាំងនេះជារឿងខ្លីៗបំផុតដែលបង្ហាញឡើងជាច់ៗ ហើយពេលខ្លះប្រតិកម្មកើតមានឡើងដោយការអង្វរករ ហើយជាញឹកញាប់គ្មានការឆ្លើយតប ទាំងនោះជាសេចក្តីសន្មតទូទៅ។ នៅក្នុងកម្មវិធីជួបជុំគ្នាតូចតាច អ្នកអាចឃើញថាមានមនុស្សដែលបានជួបប្រទះ និងភាពលែងលះគ្នាជូរចត់ អំពើរំលោភបំពានផ្លូវភេទ និងជម្ងឺរាតត្បាតអាយុជីវិត ឬការបាត់បង់មនុស្សជាទីស្រលាញ់ ដោយសារគ្រោះថ្នាក់ ឬឧក្រិដ្ឋកម្ម។ គ្មាននរណាម្នាក់អាចសម្របសម្រួលខ្លួនអោយបានឡើយ ព្រឹត្តិការណ៍ប៉ះពាល់ ដល់សតិអារម្មណ៍កើតឡើងពុំមែនតែក្នុងសង្គ្រាមភេវកម្ម និងទំនាស់ជាតិសាសន៍នោះឡើយ។

ក្រៅពីសេចក្តីត្រូវការរបស់យើង សម្រាប់ភាពជាសះស្បើយ និងភាពរួចផុតពីសេចក្តីស្លាប់ មនុស្សលោកបង្កើតសណ្តាប់ធ្នាប់ស្មុគស្មាញ ដែលឆ្លើយតបដោយរាង្គកាយ និងសតិអារម្មណ៍ ដែលមានរួមទៅដោយភាសា និងការនិយាយទាក់ទង។ នៅចុងបញ្ចប់ វាប្រាប់យើងអោយដឹងថាមានគ្រោះថ្នាក់កើតឡើងហើយមានវិធីផ្សេងៗ ដែលយើងអាចលៃលក ដោះស្រាយប្រតិកម្មដែលកើតមានឡើងទៅលើសេចក្តីគំរាមកំហែងនោះ។ រឿងតក់ស្លុតឃើញមានកើតឡើង នៅក្នុងប្រវត្តិសាស្រ្តតាំងពីជំនាន់ Paleotithic ដែលគេគូរគំនូរ នៅតាមរូងភ្នំនៅប្រទេសបារាំង។ នៅក្នុង Les Trois Freres ផ្ទាំងគំនូរធ្មប់រាំបង្ហាញមានស្នែងត្រចៀកជា សត្វប្រើស ភ្នែក និងមុខជាសត្វទីទុយ ពុកមាត់រាង្គកាយជាមនុស្សប្រុស និងមានកន្ទុយជាកន្ទុយសេះ។ គេអាចស្មានថាមនុស្សពិសេសមួយរូបនេះជាមនុស្សមានឥទ្ធិពល ផ្នែកបាតុភូត(ព្រលឹងបីសាច) អាចការពារមនុស្សដែលគូររូបនេះ ពីធាតុអាកាសផ្លាស់ប្តូរ ភាពខ្វះខាតអាហារ និងសត្វសាហាវផ្សេងៗ។ នៅក្នុងជំនាន់ សតវត្សទី៩ នៅប្រទេសអេហ្សីប Egypt (ឆ្នាំ ១៣២៤-១៦៥០ មុនគ្រឹស្តសតវត្ស) បីសាចកើតឡើងនៅ Amduat (ឬសៀវភៅដែលនៅក្នុងពិភពមានកម្រិត

ហួសពីផ្នូរខ្មោច- The book of That Which Is in the World Beyond the Grave)។ បីសាចទាំងនេះជាតំណាងភាពព្រៃផ្សៃ និងឥទ្ធិពលអាក្រក់ ដែលអាចចូលរូបបំផ្លាញមនុស្ស និងសហគមន៍របស់គេ។ គំនូរសិល្បៈជំនាន់ដើមរៀបរាប់អំពីសេចក្ដីបារម្ភរបស់មនុស្សជាតិ ដើម្បីការពារខ្លួនគេពីឥទ្ធិពលមហន្តរាយដែលមាននៅក្នុងពិភពលោក។

រឿងតក់ស្លុតនៅក្នុងថ្ងៃនេះ បានប្រែភាពពីរឿងនិទានអំពីបាតុភូតទៅជារឿងតក់ស្លុត និងសេចក្ដីឈឺចាប់ផ្ទាល់របស់បុគ្គល និងសង្គម។ ភាពរួចផុតពីសេចក្ដីស្លាប់ និងភាពជាសះស្បើយពីអំពីសាហាវយង់ឃ្នង ពុំមែនផ្អែកតែទៅលើសិល្បវេទមន្តនោះទេ តែវាក៏ពឹងផ្អែកទៅលើមធ្យោបាយលៃលកដោះស្រាយ ដ៏ទំនើបរបស់បុគ្គល និងវិជ្ជាជីវៈ ។ ការដាក់ភ្ជាប់ពាក្យតក់ស្លុតទៅ នឹង **រឿងជាគំនិតទំនើបមធ្យមមួយ ពាក្យតក់ស្លុត** ជាពាក្យដែលចេញពីដើមកំណើតរបស់ប្រទេសក្រិច *Traumatikos* តែពេលថ្មីៗ នេះគេនិយាយសំដៅថា ជារបួសរាង្គកាយ និងការព្យាបាល។ បច្ចុប្បន្ននេះ ពាក្យថា ***"តក់ស្លុត"*** ក៏និយាយសំដៅទៅលើរបួសគ្មានរូបរាង និងរបួសសតិអារម្មណ៍ដែលប៉ះពាល់ដល់ខួរក្បាល និងព្រលឹង។ របួសទាំងនេះពុំបង្កប់ផុត ពីភាពមើលឃើញឡើយដោយ ឧបករណ៍វិទ្យាសាស្ត្រ នៅបច្ចុប្បន្នកាលនេះអាចមើលឃើញ សេចក្ដីឈឺចាប់សតិអារម្មណ៍ និងភាពពិការដែលបណ្ដាលឡើងដោយភាពសាហាវយង់ឃ្នងនេះ។

ប្រភេទមនុស្ស យើងត្រូវការអោយយើងយល់ដឹង អំពីវិធីដែលយើងគេចផុត ពីភាពឃោឃៅអាយុជីវិតគ្រប់យ៉ាងរបស់មនុស្ស ជាពិសេសអ្វីៗ ដែលបានបង្កើតឡើងដោយដៃរបស់យើងផ្ទាល់។ នៅពេលដែលអំពើឃោរឃៅបណ្ដាលអោយមានរបួសដល់រាង្គកាយ និងសតិអារម្មណ៍ វាជាមូលហេតុដែល ប៉ះពាល់ទៅដល់ប្រតិកម្មនៃការព្យាបាល។ គំនិតមួយនៅក្នុងចំណោមគំនិតទាំងឡាយនៅក្នុងរឿងតក់ស្លុតនេះ មុខងាររបស់វាពុំមែនតែព្យាបាលអ្នកជម្ងឺតែប៉ុណ្ណោះទេ តែវាក៏ជួយបង្រៀន និងណែនាំអ្នកស្ដាប់ ហើយបង្ហាញដល់សង្គមអំពីភាពព្យាបាល និងភាពរួចផុតពីសេចក្ដីស្លាប់។

Sophocles's Philoctetes ហាមយើងទុកជាមុនថា ទោះបីជាយ៉ាងណាក៏ដោយ គតិបណ្ឌិតរឿងតក់ស្លុត ដែលបាននិយាយឡើងជាញឹកញាប់ច្រើនតែគ្មាននរណាយកចិត្តទុកដាក់។ អ្នកមានទុក្ខតក់ស្លុតក៏បានដឹងថា ទោះជាគេ និយាយរៀបរាប់ សេចក្ដីតក់ស្លុត អំពីការលែងលះគ្នា ដ៏ជូរចត់របស់ខ្លួនគេ ឬមរណភាព កូនរបស់អ្នក ស្ដាប់ភាពច្រើនបានរៀបចំខ្លួនជាស្រេចថា តើគេ នឹងស្ដាប់រឿងនោះដោយរបៀបណា ហើយតើគេ នឹងអោយខ្លួនគេស្ដាប់រឿងនោះដល់កម្រិតណា។ អ្នកខ្លះជៀសពុំស្ដាប់រឿងដោយគេមានអារម្មណ៍ថា រឿងនោះពុំទាក់ទង នឹងជីវិតរបស់គេ អ្នកខ្លះពុំចង់មានអារម្មណ៍ក្ដុកក្ដួល បើសិនជាគេយកចិត្តទុកដាក់ស្ដាប់រឿងនោះ។ សម័យទំនើបគេច្រើនតែជ្រើសយកកត្តា សាហាវយង់ឃ្នង ហើយយកចិត្តទុកដាក់តែលើចំណុចសំខាន់ នៅក្នុងសាច់រឿង ភាពសាហាវយង់ឃ្នងអាចធ្វើអោយយើងរិតតែចង់ដឹងឡើង ដោយមកពីភាពចម្លែកអស្ចារ្យ ភាពរំជើបរំជួលអារម្មណ៍ដែលផ្ដល់ឱកាសអោយយើង ទទួលបទពិសោធន៍ហួសពីអ្វីៗ ដែលគួរអោយជឿ ហើយគ្មានគិតពីរបួស ដែលអាចកើតមានឡើងដល់ខ្លួន។ ក្រៅតែពីធ្វើអោយមាន ភាពរំជើបរំជួលអារម្មណ៍ ពុំមានអ្វីដែលធ្វើអោយ

ចំរើនដល់គតិបណ្ឌិត និងភាពយល់ដឹងជ្រៅជ្រះ ទោះបីជាយ៉ាងណាយើងពិតជាយកចិត្តទុកដាក់ស្តាប់ក៏ដោយ។ គតិបណ្ឌិតរបស់ Philoctetes មានប្រភពចេញពីព្រឹត្តិការណ៍តក់ស្លុត ដែលមានតែអ្នករួចផុតពីសេចក្តីស្លាប់ទេ ដែលដឹងរឿងទាំងនោះទោះជារឿងសោកសង្រេង នោះកើតឡើងដោយសោកនាដកម្ម នៅក្នុងដំណើរជីវិតធម្មតា ឬនៅក្នុងសង្គ្រាម ឬនៅក្នុងភាពមហន្តរាយធម្មជាតិ។

## ១.២ ចំណុចសំខាន់បួន(៤)នៃរឿងតក់ស្លុត

ការប្រមូលប្រវត្តិរឿងផ្ទាល់មាត់ដែលកើតឡើងនៅពេលជួនគ្នា និងពេលបង្កើតមន្ទីរ របស់ជនភៀសខ្លួនរបស់យើង បានផ្តល់នូវសេចក្តីយល់ដឹងជ្រៅជ្រះទៅលើគម្រោង និងមាតិការឿងតក់ស្លុត។ យើងដឹងតាំងពីគ្រាដំបូងថា វាជាភាពងាយស្រួលហើយមានប្រយោជន៍បើយើងសម្ភាសន៍មនុស្សដែលមានប្រវត្តិដំណើរជីវិតប្រហាក់ប្រហែលគ្នា នឹងអ្នកជម្ងឺរបស់យើង តែអ្នកទាំងនោះពុំមែនជាអ្នកជម្ងឺ។ ដោយយើងពុំត្រូវការព្យាបាល អ្នកផ្តល់រឿងផ្ទាល់មាត់ ហើយគេក៏ពុំសង្ឃឹមថា អាចទទួលអ្វីពីយើងដែលជាអ្នកព្យាបាលផងនោះ ដូច្នេះ ដំណើរការព្យាបាលនៅមន្ទីរសុខភាពពុំមានការប៉ះពាល់ទៅដល់ការនិយាយរឿងរបស់គេឡើយ។

ការសម្ភាសន៍រឿងផ្ទាល់មាត់របស់ស្ត្រីខ្មែរ មួយផ្នែកៗ មានរយៈពេល ប្រហែលជាពីរ-ម៉ោង-កន្លះ ហើយសម្រាកមួយខណៈៗ ចំនួន ៦សប្តាហ៍ សរុបមានចំនួន លើសពី ១២ម៉ោង។ ការសម្ភាសន៍ធ្វើឡើងនៅផ្ទះរបស់អ្នកនិយាយរឿង កន្លែងធ្វើការ ឬគ្រឹះស្ថានសាសនា ដូចជា វត្តព្រះពុទ្ធសាសនា។ ភាពក្សេមក្សាន្តនៅក្នុងផ្ទះរបស់គេ ជាទូទៅបញ្ចេញកស្តុតាងដ៏តិចតួចទៅលើភាពតក់ស្លុតអតីតកាល និងរបួសគ្មានស្នាមរបស់គេ លើកលែងតែគេមានរូបថតញាតិមិត្តចាស់ៗ ដែលភាគច្រើនបានទទួលអនិច្ចកម្មមុនកំណត់ពេល។

នៅពេលយើងចាប់ផ្តើមការសម្ភាសន៍ ការយល់ដឹងជាដំបូងរបស់យើងគឺ ភាពបង្វែរអារម្មណ៍ដ៏ងាយទៅលើព្រឹត្តិការណ៍រឿងតក់ស្លុត ហាក់បីដូចជា ការសម្លឹងចំព្រះអាទិត្យដែលកំពុងតែចែងចាំងរស្មី ធ្វើអោយយើងងងឹតស្លុងដោយគ្មានឃើញអ្វីទាំងអស់ ហាក់បីដូចជា ព្រឹត្តិការណ៍ទាំងនោះលាតត្រដាងពាសពេញផ្ទៃមេឃ ទៅលើដំណើរជីវិតរបស់ជននោះ។ តែហេតុការណ៍ឃោរឃៅ ជាញឹកញាប់ពុំមែនជា ហេតុការណ៍ដែលធ្វើអោយប៉ះពាល់ដល់ជីវិតរបស់ជននោះឡើយ។ ស្ត្រីខ្មែរម្នាក់ដែលមានប្រវត្តិក្នុងឋានៈមធ្យម ឈ្មោះ ផល លេត Phal Let បានពន្យល់ថាហេតុការណ៍ តក់ស្លុតជាងគេរបស់គាត់ពុំមែននៅក្នុងរបបប៉ុលពតទេហេតុការពិត គឺឪពុកម្តាយរបស់គាត់ពុំអនុញ្ញាតអោយគាត់រៀនអាន និងរៀនសរសេរអក្សរខ្មែរ ដោយមានការបារម្ភ ជាទូទៅនៅក្នុងចំណោមឪពុកម្តាយនៅជំនាន់គាត់ គិតថាបើកូនស្រី ចេះអាន ចេះសរសេរអក្សរ អ្នកទាំងនោះ នឹងសរសេរលិខិតទៅសង្សាររបស់គេ។ ស្ត្រីរូបនេះមានអារម្មណ៍ថា ឪពុក ម្តាយរបស់គាត់ បានបដិសេធភាពប៉ិនប្រសប់របស់ខ្លួនគាត់ ដែលត្រូវការសម្រាប់តស៊ូពុះពារ ដើម្បីរស់រានមានជីវិតនៅក្នុងរបបប៉ុលពត។ សំខាន់ជាងនេះទៅទៀត គឺភាពប៉ិនប្រសប់ដែលគាត់ត្រូវការដើម្បី ដោះស្រាយជីវិតនៅសហរដ្ឋអាមេរិក។

របៀបសួរប្រវត្តិផ្ទាល់មាត់ដែលយើងសួរ គឺអោយស្ត្រីចាប់ផ្ដើម និយាយអំពីដំណើរជីវិតរបស់គេ តាំងពីកំណើតមក ដែលបង្រៀនអោយយើងមើលឃើញក្រៅពី "កម្ដៅព្រះអាទិត្យងងឹតស្លុង" ទៅលើព្រឹត្តិការណ៍តក់ស្លុតជាសាធារណៈ ហើយយកចិត្តទុកដាក់ទៅលើព្រឹត្តិការណ៍ ដ៏គួរអោយចាប់អារម្មណ៍ផ្សេងៗ នៅក្នុងជីវិតរបស់គេ។ ប្រវត្តិផ្ទាល់មាត់ អាចមានរួមទៅដោយរឿងរ៉ាវផ្ទាល់ខ្លួនណាមួយនៅក្នុងជីវិត មានអ្វីៗ ទាំងអស់រួមទាំងការចំអិនអាហារ ការចូលមករស់នៅប្រទេសថ្មី បទពិសោធន៍ក្នុងសង្គ្រាម។ ការស្ដាប់ស្ត្រីពណ៌នា ដោយរំលឹកយ៉ាងលម្អិត ទៅលើដំណើរជីវិតរបស់គេ បានបង្ហាញឡើងថា អ្នករងការឈឺចាប់ពុំមែន ឈឺចាប់គ្រប់ពេលនោះឡើយ។ ចំពោះស្ត្រីខ្មែរគ្រប់រូប ដែលបានប្រាប់យើងអំពីពិធីអាពាហ៍ពិពាហ៍របស់គេ គឺជារឿងដ៏រីករាយមួយផ្នែកនៅក្នុង ការរំលឹកដំណើរជីវិតរបស់គេ ។ ជនគ្រប់រូបបាន រៀបអាពាហ៍ពិពាហ៍ ឡើងដោយ ឪពុក ម្ដាយជាអ្នកផ្សំផ្គុំអោយ អ្នកខ្លះពុំដែលឃើញមុខ អនាគតស្វាមីរបស់ខ្លួន រហូតទាល់តែពីរទៅបីថ្ងៃមុនថ្ងៃមង្គលការ។ គេបានរៀបរាប់ពីភាពល្អវិសេសនៅក្នុងថ្ងៃមង្គលការ ក្នុងករណីខ្លះពិធីមង្គលការមានកំឡុងពេលបីថ្ងៃ និងមានក្បួនដង្ហែរហើយនៅក្នុងករណី រាត្រីមង្គលការខ្លះៗ គេបានលាក់ខ្លួន ជាច្រើនថ្ងៃនៅពេលដែលគេបានឃើញអាក្រាតកាយរបស់មនុស្សប្រុសជាលើកដំបូង។ រឿងអាពាហ៍ពិពាហ៍ ក៏ដូចជាទិដ្ឋភាពផ្សេងៗ នៃប្រវត្តិដំណើរជីវិតរបស់គេ ពុំមានប្រលាក់ទៅដោយអំពើរំលោភផ្លូវភេទសាហាវឃោរឃៅ អំពើសម្លាប់ និងទារុណកម្ម ដែលក្រោយមកគេបានជួបប្រទះ នៅក្នុងរបបប៉ុលពតនោះឡើយ។ ពុំមានជីវិតណាមួយ ជាជីវិតអាក្រក់គ្រប់បែប ហើយគ្មានអ្នកកើតរោគមហារីកណាម្នាក់ តែងតែឈឺគ្រប់ពេល ហើយក៏គ្មាននរណាម្នាក់ រស់នៅក្នុងជីវិតអាពាហ៍ពិពាហ៍ជូរចត់តែងតែទទួលរងអំពើហឹង្សា ឬអំពើពុំគប្បីគ្រប់ពេលឡើយ។ ប្រវត្តិផ្ទាល់មាត់របស់ស្ត្រីទាំងនោះជួយ រំលឹកអោយយើងយល់អំពីតម្លៃ បទពិសោធន៍របស់មនុស្សគ្រប់យ៉ាង ដែលកើតមានឡើងនៅក្នុង ព្រឹត្តិការណ៍តក់ស្លុត។

លទ្ធផល នៃការសិក្សាទាំងនេះ និងប្រវត្តិផ្ទាល់មាត់ផ្សេងៗ របស់ជនដែលបានទទួលភាពតក់ស្លុតនៅក្នុងប្រពៃណី និងទីកន្លែងផ្សេងៗ ភាពពិតនៃសេចក្ដី រន្ធត់អស្ចារ្យកើតមានឡើង។ អ្នកនិយាយរឿងបង្ហាញនូវទស្សនៈត្រិះរិះផ្ទៃក្នុង និងទ្រង់ទ្រាយសំខាន់ៗនៅក្នុងរឿងតក់ស្លុតរបស់គេ នៅពេលដែលគេបានយទទួលឱកាសនិយាយដោយមានការបញ្ឈប់ និងការរំខានតិចតួច។

## ១.៣ សេចក្ដីអធិប្បាយពិតនៃបុព្វហេតុ

ចំណុចសំខាន់ៗនៃរឿងគឺ ការអធិប្បាយ*ភាពពិត* នៃបុព្វហេតុ ឬអ្វីៗដែលកើតឡើងពិតទៅលើអ្នកនិយាយរឿង។ ជាទូទៅទាំងនេះ ជាការលាតត្រដាង ដោយគ្មានបញ្ចេញបញ្ចូល អំពីដំណើរ ជីវិតតក់ស្លុត របស់បុគ្គល។ នៅពេលដែលភាពពិតបែបនេះ ប្រមូលយកមក ទោះបីជាមាន តែពីរទៅបីនាក់ ក៏ដោយវាផ្ដល់ទុកជា ឯកសារប្រវត្តិសាស្ត្រ និងអត្តចរិតដ៏ច្បាស់លាស់របស់ឧក្រិដ្ឋជន ប្រឆាំង នឹងអំពើមនុស្សធម៌ ដែលបង្ហាញអំពីគោលបំណង និងការរៀបចំយ៉ាងច្បាស់លាស់របស់ឧក្រិដ្ឋជន។ ដោយមានតែឧក្រិដ្ឋជន មួយចំនួនតូចបាននិយាយអំពីរឿងរបស់គេ ដូច្នេះ គោលដៅឧក្រិដ្ឋកម្មរបស់អ្នកទាំងនេះនៅតែមានភាពទូលំទូលាយ និងពិបាកយល់។ តែអ្នករស់

បានមានជីវិតពីភាពតក់ស្លុតអាចបញ្ចេញ ដ៏ច្បាស់លាស់ពីបទពិសោធន៍ផ្ទាល់ខ្លួន និងហេតុផលរបស់ឧក្រិដ្ឋកជន។ ដោយហេតុនេះ អ្នកនិយាយរឿងមួយចំនួនតូចអាច ពណ៌នាដោយលម្អិតក្រៃលែងអំពីការប្រតិបត្តិការទូទៅរបស់ប៉ុល ពត រដ្ឋាភិបាលបំបែកពូជសាសន៍ នៅប្រទេសអាហ្វ្រិកខាងត្បូង South Africa ឬរាជ្យភីណូជេ Pinochet ប្រទេស ឆីលេ Chile ។

ស្ទើរតែគ្រប់រឿងតក់ស្លុតទាំងអស់ អ្នកនិយាយរឿងដឹងកំណត់ថ្ងៃច្បាស់លាស់ ហើយពេលខ្លះថែមទាំង ដឹងកំណត់ម៉ោងដែលអំពើឃោរឃៅនោះចាប់ផ្តើមកើតឡើង ជាមូលដ្ឋាន បណ្តាលអោយមានការបង្អាក់នៅក្នុង ដំណើរជីវិតរបស់គេ។ នៅក្នុងប្រវត្តិរឿងផ្ទាល់មាត់នីមួយៗ របស់ស្ត្រីខ្មែរ ឧទាហរណ៍ បទពិសោធន៍យង់ឃ្នងនៅ ក្នុងរបបប៉ុលពត បានបកស្រាយយ៉ាងច្បាស់លាស់។ ការដកស្រង់ខ្លីៗ ខាងក្រោមនេះ ជាការដកស្រង់ចេញពីជន ដែលយើងធ្វើសម្ភាសន៍ សូម៉ាលី Somaly ជាគ្រួសារបឋានៈ មធ្យម ជាអ្នករបាំព្រះរាជ្យទ្រព្យ បានបញ្ចេញអោយ ដឹងនូវអំពើសាហាវយង់ឃ្នងដែលជនជាតិខ្មែរទាំងអស់ បានជួបប្រទះនៅក្នុងរបបប៉ុលពត។

ចាប់តាំងពីពេលនោះមក ក្នុងរយៈពេលបី ឬបួនខែ នៅក្នុងជុំរុំការងារខ្មែរក្រហម កូនស្រីរបស់ខ្ញុំ តូចជាង គេបង្អស់ចាប់ផ្តើមឈឺខ្លាំង។ នាងរាគរូស ខ្ញុំមានភ័ព្វសំណាង ដោយមានទាហ៊ានម្នាក់លួចស្រលាញ់ខ្ញុំ មកជួបខ្ញុំ ជាញឹកញាប់។ ខ្ញុំបានអង្វរវាថា ខ្ញុំព្រមធ្វើអ្វីៗ ទាំងអស់អោយតែខ្ញុំបានថ្នាំពេទ្យសម្រាប់ព្យាបាលកូនខ្ញុំ នៅពេល នោះវាអោយថ្នាំ ប៉េនីស៊ីលីន Penicillin មកខ្ញុំ ហើយខ្ញុំគិតថាវាពុំអាចព្យាបាលកូនខ្ញុំអោយបានជាសះស្បើយ ឡើយ តែវានៅតែគ្រាន់បើជាងគ្មានអ្វីទាំងអស់។ ដូច្នេះ ខ្ញុំក៏អោយថ្នាំនោះទៅកូនស្រីខ្ញុំលេប តែវារិតតែខ្សោយ ទៅៗ ស្ថានភាពស្បៀងអាហារក៏រិតតែអស់ទៅៗ ខ្ញុំក៏ចេះតែខ្សោយទៅៗ ខ្ញុំមើលឃើញកូនរបស់ខ្ញុំ...ចាប់ផ្តើម...វា នឹកផ្ទះ វានឹកឃើញប្រដាប់ប្រដារលេង វានឹកចំណីអាហារ ហើយវាចាប់ផ្តើមរអ៊ូរទាំ និងនិយាយគ្មានឈប់ឈរដូច ជាគ្រាប់ទឹកភ្លៀង ដែលគ្មានអ្វីអាចទប់ស្កាត់បាន។ ចំពោះរូបសូម៉ាលី សេចក្តីស្លាប់របស់កូននាងធ្វើអោយមានការ ប្រែប្រួលនៅក្នុងក្រុមគ្រួសាររបស់នាងទាំងមូល។ នាងបានស្លាប់ទៅហើយ យប់នោះខ្ញុំអោប ខ្លួនកូនស្រីរបស់ខ្ញុំ គ្រួសារយើងទាំងអស់គ្នាស្ងៀមស្ងាត់ អត់មាននរណាម្នាក់ចង់និយាយស្តីអ្វីទេ នាងជាអ្នកស្លាប់មុនគេបង្អស់នៅ ក្នុងគ្រួសាររបស់យើង។ ខ្ញុំចាប់ផ្តើមឃើញឪពុករបស់ខ្ញុំ ប្តូរអាកប្បកិរិយារបស់គាត់ ផ្ទុយ នឹងទម្លាប់និយាយលេង សើច គាត់លែងនិយាយកំប្លែងលេងសើចអ្វីទៀត។

គ្រប់ព្រឹត្តិការណ៍ឃោរឃៅទាំងអស់ រមែងមានជនរងគ្រោះ ហើយប្រតិកម្មទាំងនោះបង្កប់នៅក្នុងសេចក្តី រាយការណ៍ពិត។ ទាំងនេះជាការឆ្លើយតប ដ៏ខ្លាំងក្លាដោយផ្ទាល់ខ្លួន និងដោយអារម្មណ៍ជាទ្រង់ទ្រាយរបួសគ្មាន ស្នាមដែលបណ្តាលឡើងដោយភាពឃោរឃៅ។

## ១.៤ អត្ថន័យ នៃវប្បធម៌នាពេលតក់ស្លុត

បន្ថែមទៅលើការ រំលឹកអំពីសេចក្តីពិតឡើងវិញ ភាពតក់ស្លុតនីមួយៗ បានបង្ហាញនូវ ប្រវត្តិវប្បធម៌ សង្គម របស់អ្នករួចផុតពីសេចក្តីស្លាប់ ជាភាពតូចតាចដែលបរិយាយអំពីវប្បធម៌ ទំនៀមទម្លាប់ និងតម្លៃដែលបង្កប់ទុកនៅ

ក្នុងរឿងរបស់គេ។ ទោះជាបុរស និងស្ត្រីនៅគ្រប់សង្គមយល់ថាអំពើឃោរឃៅជារបួសពិបាកយល់ និងសេចក្តីអប្បយស ដល់សង្គមការឆ្លើយតបមានភាពខុសៗគ្នា យោងទៅតាមវប្បធម៌ ។ សង្គមអាចធ្វើអោយជនរងគ្រោះមានភាពអាម៉ាស់មុខតាមកម្រិតច្រើន ឬតិច ។ ប្រវត្តិរឿងតក់ស្លុត ផ្តល់នូវប្រាជ្ញាភ្លឺថ្លា ទាំងល្អទាំងអាក្រក់ នៅក្នុងទម្រង់វប្បធម៌របស់អ្នកនិទានរឿង។

សូម៉ាលី និយាយរឿងដែលបរិយាយអំពីខ្មែរក្រហមរៀបចំប្រព័ន្ធ ប៉ងធ្វើអោយវប្បធម៌ខ្មែរអប្បយស និងសាបសូន្យ៖ វាជាភាពរន្ធត់ក្រៃលែង ខ្ញុំកប់សពម្តាយ ឪពុករបស់ខ្ញុំ ដោយផ្ទាល់ដៃ ដូចខ្ញុំបាននិយាយរួចមក ហើយថាធ្លាប់រៀបចំសព ដោយស្លៀកសំលៀកបំពាក់ល្អស្អាត គឺសំលៀងដែលបុគ្គលិកនោះធ្លាប់ស្រលាញ់ជាងគេមុនពេលគេស្លាប់។ យើងលាងសំអាតសព ពិតណាស់? ហើយយើងស្លៀកសំលៀកបំពាក់ស្អាតអោយគេ ព្រមទាំងលាបប្រេងម្សៅបន្តិចបន្តួចថែមទៀត។ ហើយបើសិនជាសពនោះជាម្តាយ បើសិនជាម្តាយស្លាប់ តែកូននៅរស់រានមានជីវិត ពេលខ្លះ.......គេដាក់ ផ្លែឪឡឹកទៅជាមួយម្តាយ ដោយចាត់ថា ផ្លែឪឡឹកនោះជា កូនង៉ែតរបស់ម្តាយដែលបានស្លាប់ទៅ។ ជាភ័ព្វសំណាង នៅពេលម្តាយខ្ញុំគាត់ស្លាប់ ខ្ញុំអាចរុំសពរបស់គាត់ និងសំលៀកបំពាក់ស្អាត។ ភាពអាក្រក់បានកើតឡើងលើរូបគាត់ ពីរទៅបីថ្ងៃក្រោយពីខ្ញុំបានបញ្ចុះសពរបស់គាត់ នេះគឺជាសុបិន្តអាក្រក់ដែលខ្ញុំនៅតែមានមកទាល់សព្វថ្ងៃ ពេលនោះមានគេបានប្រាប់ខ្ញុំថា ឆ្កែចចកបានកាយផ្នូររបស់ម្តាយខ្ញុំ ដោយគេបញ្ចុះសពគាត់រាក់ពេក។ តើអ្នកមានអារម្មណ៍បែបណា បើសិនអ្នកជារូបខ្ញុំវិញ? គាត់ជាជនដ៏ជាទីស្រលាញ់របស់ខ្ញុំ គាត់ស្លាប់បាត់ទៅ ហើយយើងគិតថាគាត់បានសុខហើយ សូម្បីតែសពក៏ពុំអាចនៅជួប នឹងសេចក្តីសុខបានដែរ។

នៅក្នុងរឿងរបស់ សូ ម៉ាលី ករណីកិច្ចដ៏ពិសិដ្ឋទៅលើសេចក្តីស្លាប់ និងវិធីបុណ្យសពត្រឹមត្រូវតាមទំនៀមទម្លាប់ព្រះពុទ្ធសាសនា ត្រូវបានហាមឃាត់ដល់រូបនាង និងក្រុមគ្រួសាររបស់នាង។ ជនល្មើសដឹងច្បាប់ពីវប្បធម៌ទំនៀមទម្លាប់ និងជំនឿសាសនារបស់ជនរងគ្រោះ គេបានរិះរកភាពធ្វើអោយអាម៉ាស់មុខកម្រិតបំផុត ដោយដកហូត ពិធីបញ្ចុះសពជាសក្ការបូជាដែលនឹងនាំដួងព្រលឹងរបស់ជនដែលស្លាប់ទៅហើយនោះអោយទៅកាន់សុគតិភព ហើយអោយវិញ្ញាណក្ខ័ន្ធនោះទៅចាប់ជាតិនៅក្នុងជីវិតថ្មី។ ការធ្វើអោយអប្បយសទៅលើវិធីបុណ្យសពដោយខ្មែរក្រហមជាទម្លាប់ និងជាការដឹកនាំទូទៅដែលអនុវត្តន៍ឡើងក្រោយពីអ្នកទាំងនោះបានស្លាប់ទៅ។ ជនជាតិខ្មែរជាច្រើនរូបទទួលភាពរាតត្បាតនៅពេលយប់ ដោយព្រលឹងអ្នកស្លាប់ទាំងនោះ នៅតែវិលវល់ ដើម្បីរកសេចក្តីសុខតាមរយៈ ពិធីបុណ្យបញ្ចុះសពត្រឹមត្រូវ។ បើសិនជាអាចធ្វើបានអ្នករួចផុតពីសេចក្តីស្លាប់ ភាគច្រើនក្រោយមកបានធ្វើវិធីបុណ្យសពទាំងនោះ។

## កថាខណ្ឌ ១. មើលហួសពីឆាកជីវិត ហួសរាំងនន

អ្នកប្រាជ្ញ និពន្ធសាសនា ក្វេចហ្គ័រ Quaker និងអ្នកណែនាំឪក្លាស់ ស្ទៀរ Douglas V. Steeve ធ្វើការប្រៀបធៀបគំនិតបន់ស្រន់របស់ព្រះសង្ឃត្រាប់ពិស Trappist គំនិតរបស់ ថមម៉ាស់ ម័រតុនThomas Merton ទៅ

លើបទពិសោធន៍ "ការមើលហួសពីវាំងនន" នៅលើឆាកសម្តែង។ ដែលមានន័យម៉្យាងទៀត ថាការបន់ស្រន់ធ្វើអោយមនុស្សឃើញហេតុពិតនៃដំណើរជីវិតរបស់មនុស្សតាមបែបសាសនា។ តែដូច Merton បានផ្តល់យោបល់ថាការលួចមើលពីក្រោយវាំងនន ពុំមែនគ្រាន់តែជាភាពសន្តោសប្រណីនោះទេ តែវាជាការយល់ដឹងច្បាស់នៃភាពចម្រើនភាវនា ដែលអាចជាការឈឺចាប់ និងសេចក្តីអាក់អន់ចិត្តៈ សេចក្តីភ័យញញើត និងភាពធ្វេសប្រហែសរបស់ជនកាន់សាសនា ហាក់បីដូចជា ទារុណកម្ម តែវាជាការពិតនៅក្នុងពាក្យរបស់ អាយស្សាក់ ស្ទែឡា Issac Stella (អ្នកភាវនាសតវត្សទី១២) " ភាពមេត្តាធម៌នៃអំពើយង់ឃ្នង ពុំមែនជាសេចក្តីខឹងក្រេវក្រោធ " ៖ "*In Inferno Sumus sed misericodiae, non irae; in caelo erimus*" ដើម្បីនៅក្នុងភាព " ភាពមេត្តាធម៌នៃអំពើយង់ឃ្នង" គឺត្រូវមានបទពិសោធន៍ទៅលើភាពគ្មានអ្វីទាំងអស់ មានតែចិត្តស្តាយក្រោយ និងសេចក្តីលះបង់ប្រគេនចំពោះព្រះ ដោយប្រាថ្នាទទួល និងប្រតិបត្តិតាមបំណងរបស់ព្រះ ដោយគ្មានយកចិត្តស្អប់ខ្ពើមរអើម និងប្រឆាំងមកលាយលំ ទោះបីជាអាចទទួលបាន ***អារម្មណ៍*** ថាពេលខ្លះអារម្មណ៍ទោរទន់នេះមានកម្រិតស្ទើរតិចៗ ក៏ដោយ។

ការពណ៌នារបស់ ម៉ូរតុន Merton រវាង "ភាពមេត្តាធម៌នៃអំពើយង់ឃ្នង" និងសមត្ថភាពរបស់ជនទទួលភាពតក់ស្លុតមានភាពប្រហាក់ប្រហែលគ្នា ដែលកើតមានឡើងតាមរយៈភាពយង់ឃ្នងផ្ទាល់ខ្លួនរបស់គេ ដើម្បីនឹងសម្រេចភាពច្បាស់លាស់នៃទស្សនៈពិភពលោក គឺត្រូវបំបាត់ភាពអាក្រក់ និងទុក្ខព្រួយចេញអោយអស់។ ការមើលហួសពីឆាកជីវិត អ្នករួចផុតពីសេចក្តីស្លាប់បាន បើកបង្ហាញភាពពិតច្បាស់លាស់ដ៏ជ្រៅរបស់ខ្លួននៅពេលដែលគេនឹកគិតអំពីស្ថានភាពរបស់ខ្លួនឯង។ អ្នករួចផុតពីសេចក្តីស្លាប់ពីមុនមកធ្លាប់គាំទ្រជំនឿសង្គម និងឥរិយាបទថាខ្លួនជាមនុស្ស "អាក្រក់" ដោយខ្លួនបានចូលរួមនៅក្នុងព្រឹត្តិការណ៍អាក្រក់។ តែបច្ចុប្បន្ននេះ បទពិសោធន៍អំពើយង់ឃ្នងធ្វើអោយប្រពៃណីនិយមនេះ ហាក់បីដូចជាមានភាពខុស នឹងមានទុក្ខទោស ដោយសេចក្តីឈឺចាប់ទាំងនេះគេបដិសេធគំនិតតាមទំនៀមទម្លាប់ចាស់ទាំងនេះ ហើយគេមើលហួសឆាកដំណើរជីវិតធម្មតារបស់គេដើម្បីរកអ្វីថ្មីផ្សេងទៀត។

ស្ត្រីដែលទទួលភាពតក់ស្លុត ទូទាំងពិភពលោក ជាពិសេសស្ត្រីខ្លះ ដែលបានជួបឧបសគ្គដោយអំពើយង់ឃ្នងសង្គមជាពិសេស នៅពេលដែលគេប្រឈម នឹងអំពើបំពានផ្លូវភេទ។ ស្ត្រីដែលទទួលទារុណកម្មភេទ ជាញឹកញាប់ទទួលការប្រព្រឹត្តិតបដោយក្រុមគ្រួសារ និងសង្គមថាខ្លួនជាអ្នកប្រព្រឹត្តអំពើឧក្រិដ្ឋទាំងនោះ។ ទោះបីជាខ្លួនគ្មានកំហុស និងជាជនរងគ្រោះដែលទទួលការឈឺចាប់ គេអាចទទួលការវាយដំ កេរ្តិ៍ឈ្មោះអាក្រក់ ភាពកាត់កាល ហើយនៅក្នុងករណីខ្លះអាចត្រូវគេសម្លាប់ចោលទៀតផង។ រឿងនិទានរបស់ខ្មែរ "ពស់កេងកង" លាតត្រដាងនូវភាពពុំស្មើគ្នា និងភាពរើសអើងចំពោះស្ត្រីភេទ ដែលទទួលអំពើរំលោភបំពានផ្លូវភេទ៖

នៅថ្ងៃមួយនោះឈ្មួញកំសត់ទុគតម្នាក់ ឈ្មោះ មាណព បានចាកចេញពីប្រពន្ធនាងនី ហើយបានប្រាប់នាងថាគាត់ចេញដំណើរទៅយូរថ្ងៃ ដើម្បីលក់ដូរ។ គាត់ នឹងឃ្លាត់ទៅយូរ ដូច្នេះ នាងជាប្រពន្ធត្រូវតែផ្តល់ម្ហូបអាហារ និងការពារខ្លួននាង និងកូនស្រីជំទង់ ឈ្មោះនាងអេត រហូតទាល់តែពេលគាត់ត្រឡប់មកវិញ មាណព

បានហាមនាងនី កុំអោយចេញពីផ្ទះទៅលេងផ្ទះអ្នកជិតខាង។ ជាច្រើនខែកន្លងផុតទៅ នាងនី និងនាងអេតអស់ម្ហូបអាហារ ដូច្នេះ គេទាំងពីរនាក់បង្ខំចិត្តបំពានពាក្យបណ្តាំរបស់មាណព ហើយបាននាំគ្នាចូលព្រៃទៅរកដំឡូងព្រៃ និងត្រពាំង។ នៅខណៈដែលគេកំពុងតែស្វះស្វែងរកម្ហូបអាហារ គេបានរកឃើញគុម្ពឫស្សីធំមួយដែលមានត្រពាំងដុសស្កេះស្កាល។ នៅពេលដែលគេកំពុងតែជីកត្រពាំងស្រាប់តែជ្រុះបាត់ផ្លែចបជីក។ គេបានដើររកសព្វទីកន្លែងតែរកពុំឃើញសោះ។ ដោយភ័យខ្លាចបាត់គ្រឿងប្រដាប់ប្រើប្រាស់របស់ប្តី នាងនីបានស្រែកយំខ្លាំងៗ ថា "បើលោកណារកឃើញផ្លែចបជីករបស់ខ្ញុំ ខ្ញុំនឹងបំពេញបំណងប្រាថ្នារបស់អ្នកគ្រប់យ៉ាង"។

នៅពេល ឮសូរសេចក្តីប្រកាសនេះ ពស់កេងកងបានលូនចេញពីរន្ធរបស់វា ហើយបានសួរនាងនី តើសម្តីនាងជាសម្តីពិត។ នាងនីឆ្លើយថា "សម្តីខ្ញុំជាសម្តីពិត" ពេលនោះពស់កេងកងនិយាយថា "បើអ្នកព្រមយកខ្ញុំធ្វើប្តី ខ្ញុំនឹងរកផ្លែចបជីកអោយនាង" ដោយហេតុតែនាងភ័យខ្លាច និងត្រូវរចង់រស់រានមានជីវិតនាងនីបានយល់ព្រម។ ជាច្រើនខែកន្លងផុតទៅ នាងនី និងនាងអេតស្ទើរតែមិនរស់ និងម្ហូបអាហារដែលផ្តល់ឡើងដោយពស់កេងកង ទោះបីជាយ៉ាងណាក៏ដោយ នេះជាពាក្យសន្យារបស់នាង នាងនីយកពស់កេងកងទៅដេកជាមួយរៀងរាល់យប់ ដោយចាត់ទុកខ្លួននាងជាប្រពន្ធរបស់ពស់កេងកង ក្រោយមកនាងក៏មានផ្ទៃពោះ។

ទីបំផុត មាណព បានត្រឡប់មកផ្ទះវិញ ហើយបានទទួលដំណឹងពីកូន អំពីភាពជិតក្បត់របស់ប្រពន្ធខ្លួន នាយក៏រៀបចំផែនការសម្លាប់ធ្វើបាបនាងនី និងពស់កេងកង។ នៅថ្ងៃមួយនោះ នាយបានអោយកូនស្រីលេងល្បិចទៅហៅពស់កេងកងចូលផ្ទះ។ នាយពួននៅពីក្រោយទ្វារ រួចហក់ចេញមកនៅពេលដែលពស់កេងកងលូនមកដល់ នាយទាញកំបិតកាប់ពស់ជាបីកំណាត់។ រួចនាយយកក្បាលពស់កេងកងដាក់នៅលើដើមឈើនៅក្នុងចំការ ហើយយកកន្ទុយពស់ដាក់នៅលើពិដានផ្ទះបាយ។ នាយលាងសំអាតឈាមយ៉ាងស្អាត ហើយយកសាច់ដងខ្លួនពស់កេងកងទៅ ខ ។ នៅពេលនាងនី ត្រឡប់មកផ្ទះនៅក្នុងថ្ងៃនោះ មាណព បានជួសម្ហូបឆ្ងុញឆ្ងាញ់អោយនាងស្រស់ស្រូបទទួលអាហារពេលល្ងាច ក្រុមគ្រួសារបានអង្គុយស្រស់ស្រូបអាហារពេលល្ងាចជុំគ្នា។ មួយរំពេចនោះ ស្រាប់តែសត្វក្អែកមួយបានបូលឡើងថា "ក្រលូវ! ក្រលូវ! កន្ទុយនៅលើពិដាន" នៅពេលឮសត្វក្អែកបូល នាងនីងើបមើលឡើងលើ នាងឃើញកន្ទុយពស់កេងកងនៅលើពិដាន ស្រាប់តែនាងយំភ្លាម។ មាណពដឹងច្បាស់ថាប្រពន្ធរបស់ខ្លួនលួចសហាយស្មន់ជាមួយ នឹងពស់កេងកង នៅពេលដែលខ្លួនមិននៅ មាណពសួរថា "ហេតុអ្វីបានជាអូនយំ"? នាងនីបានឆ្លើយតបថា "បាយក្តៅសម្លក្តៅ រលឹកកូនចៅរលីរលោងទឹកភ្នែក"។

បន្ទាប់ពីស្រស់ស្រូបអាហារល្ងាចហើយ មាណពបានហៅនាងនី ទៅមុជទឹកទន្លេជាមួយនាយ មាណពឃើញថានាងនីសប្បាយរីករាយនៅពេលមុជទឹកទន្លេ ហើយឃើញនាងលែងយំនឹកនាពស់កេងកងទៀត។ ពេលនោះនាយក៏ហៅនាងនីមកជិតខ្លួន ដើម្បីដុសក្អែលអោយនាង នាងនីក៏មកជិត ពេលនោះមាណពបានយកកាំបិតធំកាប់វះពោះនាងនី នៅពេលដែលនាងកំពុងតែត្រូវរខ្យល់ស្លាប់ កូនសត្វពស់រាប់ពាន់លូនចេញពីពោះនាង។

រឿងនិទាននេះ បាននិទានឡើងនៅប្រទេសកម្ពុជា ដើម្បីពន្យល់ប្រាប់អំពីដំណើរហេតុកំណើតសត្វពស់ច្រើនបែប ដែលកើតមានឡើងនៅក្នុងពិភពលោក។ នៅក្នុងសង្គមនានា ជាច្រើនក្នុងបច្ចុប្បន្នកាល រឿងនិទាននេះពណ៌នាដ៏ច្បាស់លាស់ អំពីការរំលោភបំពាន វាសនារបស់ស្ត្រី ជាពិសេសស្ត្រី ដែលទទួល អំពើរំលោភបំពាន ផ្លូវភេទ។

នាង រ៉ូស្សា Rosa ជាស្ត្រីវៀតណាម បានធ្វើដំណើរតាមទូក ដែលខ្ញុំបាន ជួបនៅមន្ទីរពិនិត្យសុខភាព ត្រូវជម្រត់ និងរំលោភផ្លូវភេទដោយចោរសមុទ្រសៀម។ តែនាងបានលួចរត់គេចខ្លួន បន្ទាប់ពីពួកចោរចាប់ឃុំខ្លួននាងមួយរយៈខ្លីទុកជាស្រីស្នំបំរើផ្លូវភេទ។ នៅពេលនាងបានមកដល់ជុំរុំជនភៀសខ្លួន នាងបានទទួលដំណឹងថា ប្តីនាង និងកូនក៏រស់នៅទីនោះដែរ តែដោយសេចក្តីអាម៉ាស់មុខរបស់នាង និងសេចក្តីអាម៉ាស់មុខដែលនាងគិតថាប៉ះពាល់ដល់កិត្តិយសគ្រួសាររបស់នាង នាងបានបដិសេធពុំមកជួបជុំជាមួយ នឹងពួកគេឡើយ។ នៅពេលដែលក្រុមគ្រួសារបានទទួលការអនុញ្ញាត អោយស្នាក់នៅប្រទេសកាណាដា រូបនាងបានសម្រេចមកនៅសហរដ្ឋអាមេរិក គ្រួសារនាងពុំដឹងថានាងនៅរស់មានជីវិតឡើយ។

ផ្ទុយទៅវិញស្ត្រីខ្មែរម្នាក់ ជាសិល្បៈការីនីរបាំព្រះរាជ្យទ្រព្យ ឈ្មោះ សូ ម៉ាលី បានប្រឆាំងពុះពារ នឹងប្រពៃណីរបស់ខ្ញុំ។ ទោះបីជាក្រុមគ្រួសាររបស់នាង បានបាត់បង់ជីវិតជាច្រើននាក់ មានរួមទាំងប្តី ម្តាយឪពុក និងកូន នាងខិតខំតស៊ូជំនះ និងប្រពៃណីខ្មែរដែលថ្កោលទោសនាងថា នាងពុំរក្សាភាពជាស្ត្រីមេម៉ាយអោយបានខ្ជាប់ខ្ជួន។ ខ្ញុំគិតថាក្នុងនាមជាមនុស្សលោក យើងត្រូវតែមានសេចក្តីស្រលាញ់នៅក្នុងបេះដូងរបស់យើង បើសិនជាអ្នកពុំមានសេចក្តីស្រលាញ់ទេ អ្នកពុំមែនជាមនុស្សលោកទេ។ ជីវិត គឺកើតឡើយដោយសេចក្តីរីករាយ សេចក្តីក្រៀមក្រំ សេចក្តីរំភើប សេចក្តីគ្មានភាពរំភើប សេចក្តីធុញទ្រាន់ ទាំងនេះហើយដែលបង្កើតជីវិត។ ពេលខ្លះនៅពេលដែលជីវិតក្លាយទៅជាមានភាពជូរចត់ ខ្ញុំគិតថានេះជាជីវិតរបស់ខ្ញុំ ខ្ញុំត្រូវទទួលយក ទោះជាខ្ញុំពុំបានជ្រើសយកជីវិតនេះ ដើម្បីរស់រានមានជីវិតជាថ្មីម្តងទៀត ហើយរស់នៅក្នុងស្ថានភាពបច្ចុប្បន្ននេះ។ ខ្ញុំពុំដែលចង់នៅម្នាក់ឯងឡើយ ពិតជាពុំចង់ទាល់តែសោះ វាជាស្ថានភាពដ៏ភ័យខ្លាចមួយដែលរស់នៅដោយគ្មាននរណាម្នាក់នៅជាមួយនោះ។ ហើយខ្ញុំក៏ពុំចង់រៀបការ ដោយគ្មានស្នេហភាពដែរ ព្រោះខ្ញុំបានឆ្លងកាត់ជាច្រើនរួចមកហើយ... តែខ្ញុំរកនរណាម្នាក់ដើម្បីស្រលាញ់ជាថ្មីទៀត ជនម្នាក់សម្រាប់ជនម្នាក់ទៀត។ នៅក្នុងសង្គមខ្មែរស្ត្រីមានឱកាសតែម្តងគត់ក្នុងការរៀបមង្គលការ។ បើសិនជាប្តីស្លាប់ នាងត្រូវតែនៅលីវរហូតហើយ ពុំអាចរៀបការម្តងទៀតឡើយ ទោះជានាងនៅវ័យក្មេងក៏ដោយ។ សូ ម៉ាលី បាត់បង់ប្តីរបស់នាង និងកូនទាំងអស់របស់នាងនៅពេលដែលមានអាយុ៣០ឆ្នាំ ហើយនាងមានបំណងរកស្នេហាថ្មីយ៉ាងខ្លាំង។ សូ ម៉ាលី មើល "ហួសឆាកជីវិត" របស់នាងដោយនាងបានបដិសេធជីវិត ស្ត្រីមេម៉ាយ ហើយរកឃើញស្នេហាថ្មី។ អស្ចារ្យណាស់ដែល សូ ម៉ាលី បានរៀបការជាថ្មី ព្រមទាំងមានកូនទៀត នាងបានបំពានការហាមឃាត់ធម្មជាតិប្រឆាំង នឹងការរៀបការជាថ្មីនេះ មានស្ត្រីជាច្រើនក្នុងសង្គមផ្សេងៗ មានស្ថានភាពដូចគ្នានេះសុខចិត្តទទួលភាពកណ្តោចកណ្តែងនៃជីវិត តែស្ត្រីខ្លះពុំព្រមទទួលយកឡើយ។ សេចក្តីសម្រេចចិត្ត និងការសម្របសម្រួលជីវិតប្រកបដោយជោគជ័យនៅសហរដ្ឋអាមេរិករបស់សូ

ម៉ាលី អាចជាភាពមួយដែលជួយអោយនាងឃើញឧបសគ្គប្រពៃណីជាភាពសង្កត់សង្កិន ទស្សនៈថ្មីរបស់នាងជាទស្សនៈសេរី។

## ១.១ ទំនាក់ទំនងរវាងអ្នកស្តាប់-អ្នកនិទានរឿង

ពុំមានមនុស្សទូទៅ មនុស្សសាមញ្ញម្នាក់ ពិតជាចង់ទទួលបទពិសោធន៍ ឃើញផ្ទាល់ភ្នែក ឬ ឮអំពីភាពឃោរឃៅសាហាវយង់ឃ្នង ដោយគេព្យាយាមគេចវេសពុំចង់និយាយអំពីរឿងនេះ។ អ្នកច្រៀងបន្ទនៅក្នុងការសម្តែងរបស់ សូល ហ្វូហ្គល់ Sophocles ដែលសម្តែង ជាផីលុកតេតេស Philoctetes បានដឹងអំពីកត្តាពិតនេះ ពេលដែលគេទៅជួប នឹង Philoctetes ដោយភ្លាមនោះ គេបានច្រៀងថា " ខ្ញុំជាមនុស្សចម្លែកម្នាក់នៅក្នុងទឹកដីប្លែកមួយ"។ កោះដែល Philoctetes រស់នៅចាត់ថាជាទីប្លែក ព្រោះគ្មានមនុស្សមានជីវិតរស់នៅទីនោះឡើយ គឺវាមានតែសម្រែកស្រែកទ្រហោយំដោយការឈឺចាប់របស់វីរៈបុរស និងជនរួមជាតិ។ សេចក្តីចម្លែកនេះ គឺពុំមែនតែកោះនោះទេ តែវាជាទីកន្លែងដែលគ្មានមនុស្សរស់នៅ។

គំនិតរបស់ Philoctetes ក៏ប្លែកហើយទីកន្លែងជាទីច្របូកច្របល់ពោរពេញទៅដោយហឹង្សា ភាពស្អប់ និងសេចក្តីអស់សង្ឃឹម ខ្វះសេចក្តីរីករាយ និងភាពពេញចិត្តរបស់មនុស្សលោក។ អារម្មណ៍ឈឺចាប់របស់ Philoctetes ជាភាពមួយគួរអោយភ័យខ្លាច ដោយពុំដឹងថាខ្លួនត្រូវប្រកាន់អាកប្បកិរិយាដូចម្តេច អ្នកច្រៀងបន្តសួរ អូឌីស៊ីស Odysseusថា "តើខ្ញុំត្រូវលាក់បាំងអ្វីទៅលោក ឬតើខ្ញុំត្រូវនិយាយបែបណានៅពេលដែលខ្ញុំប្រឈម នឹងជនសង្ស័យ"? អ្នកច្រៀងបន្តប្រើរបៀប "អៀនខ្មាស់ចំពោះជនចម្លែក"។ ដែលធ្វើឡើងដោយសេចក្តីភ័យខ្លាច-ទាក់ទង នឹងភាពពុំទុកចិត្តលើមនុស្សចម្លែក សេចក្តី "អៀនខ្មាស់ចំពោះជនចម្លែក" ជាភាពទន់ខ្សោយ និងចំណាប់អារម្មណ៍ដែលមាននៅក្នុងមនុស្សទាំងអស់ដែលធ្លាប់ឆ្លងកាត់ភាពតក់ស្លុត។ ជនជួប នឹងភាពតក់ស្លុត ជាទូទៅអារម្មណ៍របស់គេពុំជក់ជាប់ដោយភាពយង់ឃ្នងទេ តែផ្ទុយទៅវិញអារម្មណ៍របស់គេសម្របសម្រួលទោរទន់ទៅតាម កលល្បិចទំនាក់ទំនងរបស់មនុស្សលោក។

អ្នកនិទានរឿងក៏អាចទទួលការឈឺចាប់ទៅលើអារម្មណ៍ និងរាង្គកាយ នៅពេលដែលគេ និយាយរឿងរបស់គេឡើងវិញ។ គេអាចរារែកក្នុងការរៀបរាប់អំពីព្រឹត្តិការណ៍ណាមួយ ដោយគេខ្លាចសេចក្តីឈឺចាប់នោះអាចផុសឡើងមកវិញ។ ជនដែលបានជួប នឹងភាពតក់ស្លុតទោរទន់អារម្មណ៍ជាទីបំផុត មិនចំពោះតែទៅលើភាពដែលគេអាចទទួលការឈឺចាប់ម្តងទៀតនោះទេ តែខ្លួនគេអាចទទួលប្រាជ្ញា ដឹងទុកជាមុន ដោយគេដឹងថាវាស្ទើរតែជួយខ្លួនគេសឹងតែពុំបានទៀតផង។ កាលពីជំនាន់ដើម ជនដែលកាន់សាសនាខ្ជាប់ខ្ជួន ហើយធ្វើការបន់ស្រន់តែឯកឯងជារៀងរាល់ថ្ងៃ គេឃើញថាអារម្មណ៍របស់គេបានសុខសាន្ត គេពុំអាចនិយាយរៀបរាប់បើកចំហរឿងរបស់គេបានឡើយ ។ គេពុំនិយាយ អំពីវិធីដែលគេលៃលកដោះស្រាយ និងកំពុងធ្វើដោយគេ គិតថាការរៀបរាប់អោយគេដឹងនេះ អាចធ្វើអោយមធ្យោបាយរបស់គេ បរាជ័យហាក់បីដូចជា អបីយជំនឿឡើយ។ ការចូលរួមជាមួយ នឹងជនផ្សេងៗ អាចបើកចំហភាពគ្មានទិសដៅ ៖

ការនិយាយទាក់ទងអាចជាទំនាក់ទំនងសម្រាប់គ្រាអនាគត វាពុំមែនត្រឹមតែជាការរាប់អានជាមិត្ត និងមេត្រីភាពនោះទេ តែវាក៏ទៅជាភាពសោកស្តាយ។ ការចូលរួមនៅក្នុងរឿងតក់ស្លុតដូច្នេះ អ្នកស្តាប់ត្រូវតែទទួលភាពខ្មាស់អៀនរបស់អ្នកនិទានរឿង។ សេចក្តីអត់ធ្មត់ និងចំណាប់អារម្មណ៍ជាចំណុចដ៏សំខាន់បំផុត នៃរឿងតក់ស្លុត៖ ទំនាក់ទំនងរវាងអ្នកស្តាប់ និងអ្នកនិយាយរឿង ជាកត្តាពិតរឿងតក់ស្លុត ពុំអាចក្លាយទៅជារឿងបានប្រសិនបើគ្មាន និយាយប្រាប់នរណាម្នាក់នោះទេ អ្នកស្តាប់ត្រូវតែជ្រើសចូលរួមចំណែកនៅក្នុងរឿងនោះដែរ។ តែយើងត្រូវតែដឹងថា យើងត្រូវចំណាយពេលយកចិត្តទុកដាក់ និងទទួលសេចក្តីឈឺចាប់ នៅពេលដែលអ្នក និយាយរឿងបញ្ជូន សេចក្តីឈឺចាប់ទាំងនោះទៅអ្នកស្តាប់។

អ្នកស្តាប់នៅជិតអ្នកនិយាយហើយទទួលព័ត៌មានពីមាត់អ្នកនិយាយដោយផ្ទាល់ អ្នកនាំសារនេះ គឺជាសត្វចាបតូចមួយនៅក្នុងរូបគំនូរ ក៏ត្រូវការសេចក្តីទទួលស្គាល់ថា រឿងតក់ស្លុតទាំងអស់ជារឿងផ្ទាល់ខ្លួន ហើយវាក៏ជាព្រឹត្តិការណ៍សំខាន់ៗនៅក្នុងប្រវត្តិសាស្ត្រ ដែលជនសាមញ្ញបានជួបប្រទះ ហើយគេចង់ធ្វើអោយខ្លួនគេជាសះស្បើយដោយជួយបង្រៀនអ្នកឯទៀតអំពីភាពរស់រានមានជីវិត និងការព្យាបាលខ្លួនគេ។

នៅក្នុងលោកយើងសព្វថ្ងៃនេះ គេច្រើនតែផ្តោតអារម្មណ៍ ទៅលើកត្តាដឹងឮអំពីរឿងតក់ស្លុត អ្នកនិទានរឿង និងសង្គមគ្មានទាក់ទងគ្នាឡើយ។ មេរៀនដ៏សំខាន់ៗដែលយើងត្រូវរៀនសូត្រពីចំណុចសំខាន់ផ្សេងៗ នៅក្នុងរឿងតក់ស្លុត ត្រូវបានបំបាត់ចោលដោយគេកម្រយករឿងទាំងនោះមកពិភាក្សាជាសាធារណៈណាស់។ នៅក្នុងករណីទូទៅ អ្នកនិទានរឿងជាគ្រូបង្រៀនហើយអ្នកស្តាប់ជាកូនសិស្ស។ កាតព្វកិច្ចរបស់អ្នកស្តាប់ គឺយកមេរៀនរស់រានមានជីវិត និងភាពជាសះស្បើយទៅប្រើក្នុងដំណើរជីវិតផ្ទាល់ខ្លួន ឬជាវិជ្ជាជីវៈរបស់គេ។ ដោយយល់ថាខ្លួនគេចូលរួមចំណែកនៅក្នុងដំណើរប្រវត្តិសាស្ត្រ ចូលរួមនៅក្នុងការចែកចាយប្រវត្តិសាស្ត្រផ្ទាល់មាត់ ហើយធ្វើអោយខ្លួនកាន់តែមានជំហរឹងមាំឡើង និងពុំអាចបំបាក់បាន។

## ១.២ រឿងតក់ស្លុតរបស់ជនជាតិបូស្សនា Bosnia

ប្រទេសយូកូស្លាវ៉ា Yugoslava ពីដើមមានតំបន់របបសាធារណៈរដ្ឋចំនួន៦ និងមានតំបន់ឯករាជ្យពីរកន្លែង។ បច្ចុប្បន្ននេះ ក្រោយពីសង្គ្រាមស៊ីវិលនៅឆ្នាំ១៩៩០ យូកូស្លាវ៉ា Yugoslava នៃប្រទេសស៊ែប៉ើ Serbia និងប្រទេសម៉ុនតេណីហ្គ្រូ Montenegro នៅតែមានភាពដដែល ប្រទេសបូស្សនា Bosnia ហឺស្សូហ្គូវ៉ា Herzogovina ក្រូអេទ្យា Croatia ស្លូវ៉េណា Slovenia និងម៉ាសេដូនីញ៉ា Macedonia ក្លាយទៅជាប្រទេឯករាជ្យ។

ក្រុមការងាររបស់យើងបានចូលទៅប្រទេសបូស្សនា Bosnia ហឺស្សូហ្គូវ៉ា Herzogovina ភ្លាមៗបន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាព ដេតុន Dayton Peace Accords នៅក្នុងឆ្នាំ១៩៩៥។ សង្គ្រាមបានចាប់ផ្តើមឡើងនៅខែ មេសា ថ្ងៃទី ៦ ឆ្នាំ១៩៩២ នៅពេលដែលជនស៊ើប Serb ចាប់ផ្តើមរឹបអូស ស្សារ៉ាយ៉េវូ Sarajevo ក្រោយពីការបោះឆ្នោតសិទ្ធិឯករាជ្យនៅប្រទេសបូស្សនា បក្សសាធារណៈរដ្ឋ ដែលមានប្រជាជន

ច្រើនជាងគេ គឺជនជាតិឥស្លាម Islam។ សង្គ្រាមប្រទេសបូស្សនាបានសម្លាប់ប្រជាជនជាង ២០០,០០០(២០ម៉ឺន) នាក់ និងប្រជាជនចំនួនជាង២លាននាក់ខ្ចាត់ខ្ចាយគ្មានទីជម្រក សរុបទាំងអស់ គឺប្រជាជនជាងពាក់កណ្ដាលប្រទេសបានទទួលរងទុក្ខ។

ទ័ពសៀបឈ្លានពាន ប្រទេសស្សារ៉ាយ៉េវូ និងតំបន់ជិតខាងជាងបីឆ្នាំ នៅរដូវត្រជាក់នៅក្នុងប្រទេស ស្សារ៉ាយ៉េវូ ប្រជាជនគ្មានស្បៀងអាហារ ភ្លើងអគ្គិសនី និងទឹក គេបានរស់រានមានជីវិតផុតពីគ្រាប់ផ្លោង និងគ្រាប់កាំភ្លើងបាញ់ចេញពីលំដ្ឋានគ្មានស្រាកស្រាន្ត។ ប្រជាជនស្រកទម្ងន់កម្រិតមធ្យម ក្នុងចំណោមមនុស្សចាស់ គឺចំនួន ៣០ផោន ប្រជាជនចំនួនជាង ១២,០០០នាក់ ស្លាប់ហើយក្នុងចំណោមអ្នកស្លាប់នេះចំនួន១,៥០០នាក់ជាកូនក្មេង។ យើងបានទទួលការអញ្ជើញអោយទៅប្រទេសបូស្សនា នៅពេលចុងបញ្ចប់សង្គ្រាម ដើម្បីផ្ដល់សេវាសុខភាពផ្នែកសតិអារម្មណ៍ទូទាំងប្រទេស តាមរយៈប្រព័ន្ធសុខភាពទូទៅ ដែលនៅសេសសល់ក្រោយពីសង្គ្រាម។ ប្រទេសយ៉ូកូស្លាវ៉ា ជាប្រទេសគំរូដ៏ល្អអស្ចារ្យ ផ្នែកសុខភាពនៅទ្វីបអឺរ៉ុបដែលធ្វើអោយប្រទេសនានាច្រណែន នឹងភាពអស្ចារ្យនេះ។ ផ្ទុយនឹងការបំផ្លាញ ផ្នែកទំនាក់ទំនងសុខភាព និងការបាត់បង់ វេជ្ជបណ្ឌិត និងគិលានុប្បដ្ឋាយិកាដែលភៀសខ្លួនចេញ ឬត្រូវគេសម្លាប់ចោល គ្រឹះស្ថាន និងគ្រូពេទ្យ ផ្ដល់សេវាជម្ងឺទូទៅនៅតែមានជាបន្តទៀត។

យើងបានផ្ដល់ការហ្វឹកហ្វឺនសុខភាពសតិអារម្មណ៍ ដល់អ្នករួមអាជីព ផ្នែកសុខភាពនៅប្រទេស បូស្សនាដើម្បីជួយអ្នកទាំងនោះរកជម្ងឺ និងព្យាបាលរោគដោយជោគជ័យ ដល់អ្នកជម្ងឺរាប់ពាន់នាក់ ដែលរងគ្រោះសតិអារម្មណ៍ដោយសង្គ្រាម។ វិធីថ្មីជឿនលឿន គឺប្រមូលរឿងតក់ស្លុត ហើយផ្សព្វផ្សាយរឿងនោះ មានរួមទៅដោយចំណុចសំខាន់ៗបួនយ៉ាង ទៅក្នុងការប្រតិបត្តិសុខភាពគំរូ។

ដូចជា មាននៅក្នុងភាពពុំចុះសម្រុងគ្រប់យ៉ាង ការចែកដាច់គ្នារវាងអ្នកជម្ងឺ និងអ្នកប្រតិបត្តិគ្មានភាពច្បាស់លាស់។ អ្នកប្រកបវិជ្ជាជីវៈ ផ្នែកសុខភាពជាច្រើនរូបបានទទួលភាពតក់ស្លុតដោយសង្គ្រាម ហើយពេលខ្លះរូបគេកើតទុក្ខជាងអ្នកជម្ងឺរបស់ខ្លួនគេទៅទៀត។ ប្រជាជន បូស្សនា និងក្រូអេឡាជាប្រទេសដំបូងបំផុត ដែលខ្ញុំមានឱកាសកត់ត្រាប្រវត្តិសាស្ត្រផ្ទាល់មាត់របស់អ្នកប្រកបវិជ្ជាជីវៈ ផ្នែកសុខភាព។ វេជ្ជបណ្ឌិត បាឃា ណាកាស Bakir Nakas ជាវេជ្ជបណ្ឌិតសុខភាពនៅ បូស្សនាដែលបានឈរនាំមុខ។ រួមទៅដោយការចាត់ចែងយ៉ាងមុះមុត និងជាវីរៈបុរសម្នាក់ប្រកបទៅដោយបេសកម្មច្បាស់លាស់ លោក វេជ្ជបណ្ឌិតណាកាសបានដឹកនាំមន្ទីរពេទ្យរដ្ឋសម្រាប់ប្រជាជនស្សារ៉ាយ៉េវ៉ូ នៅក្នុងពេលដែលទ័ពសៀបកំពុងតែឡោមព័ទ្ធ។ វេជ្ជបណ្ឌិតណាកាសុបិន្តរស់នៅក្នុងស្សារ៉ាយ៉េវូនៅក្នុងកំឡុងពេលបះបោរ ការចូលរួមរបស់គាត់ក្នុងការព្យាបាល និងវះកាត់ប្រជាជនរបួសរាប់ពាន់នាក់ ធ្វើអោយរូបគាត់ និងក្រុមគ្រួសាររបស់គាត់ស្ថិតនៅក្នុងភាពមានគ្រោះថ្នាក់។

រូបគាត់ និងបុគ្គលិកបំពេញកិច្ចការក្នុងស្ថានភាពអស្ចារ្យ ភាគច្រើនគ្មានភ្លើងអគ្គិសនី ឬម៉ាស៊ីនកម្ដៅ រួមទៅដោយការខ្វះខាតសម្ភារៈសុខភាព។ បច្ចុប្បន្ននេះជញ្ជាំងមន្ទីរពេទ្យបន្សល់ទុកនៅដោយស្នាមគ្រាប់កាំភ្លើងធ្លុះនៅលើជញ្ជាំង ដែលជាសញ្ញារំលឹកអំពីរយៈកាលដែលសត្រូវព្យាយាមបំផ្លាញគ្រឹះស្ថានព្យាបាលជម្ងឺរបស់បុគ្គលិក

និងអ្នកជម្ងឺ។ ប្រវត្តិផ្ទាល់មាត់របស់វេជ្ជបណ្ឌិតណាកាសបានលាតត្រដាងអំពីបុគ្គលភាព ទីកន្លែង និងទិដ្ឋភាពវប្បធម៌ ដែលខុសស្រឡះពីប្រវត្តិផ្ទាល់មាត់របស់ជនជាតិខ្មែរ តែទ្រង់ទ្រាយសំខាន់ៗ មានមូលដ្ឋាន ដូចគ្នា។

## ១.៣ កត្តាពិត

នៅគ្រាដំបូង នៃការប្រយុទ្ធឃោជា នៅក្នុង ស្សារ៉ាយ៉េវូ វេជ្ជបណ្ឌិតណាកាសចូលមន្ទីរពេទ្យ ហើយកម្រឃើញគាត់ចេញមកវិញណាស់ សូម្បីតែ ទៅមើលក្រុមគ្រួសាររបស់គាត់ ក៏គាត់កម្រទៅដែរ រហូតទាល់តែ៣ឆ្នាំក្រោយមក។ ប្រពន្ធ និងកូនទាំងពីររបស់គាត់ដែលរស់នៅក្នុង ស្សារ៉ាយ៉េវូគាំទ្រគាត់ហូតដល់ទីបញ្ចប់ គាត់បានក្លាយទៅជាអគ្គនាយកមន្ទីរពេទ្យរដ្ឋ ដែលហាក់បីដូចជា កើតឡើងដោយកាលៈទេសៈ។ នៅពេលសង្គ្រាមចាប់ផ្តើមឡើងជាលើកដំបូង លោកមានឋានៈជាវរៈសេនីយទោ ផ្នែកឃោជា យ៉ូហ្គូស្លាវ Yogoslav ហើយលោកធ្វើការនៅក្នុងមន្ទីរពេទ្យ។ នៅក្នុង ខែ មីនា ឆ្នាំ១៩៩២ កងទ័ពពិសេសបានចូលមន្ទីរពេទ្យដើម្បី "ការពារសន្តិសុខ" ហើយបានបង្កើតទីកន្លែងហាមឃាត់នៅជាន់ខាងលើ។ បន្ទាប់ពីការប្រយុទ្ធអាវុធចាប់ផ្តើមឡើងនៅក្នុង ខែ មេសា វេជ្ជបណ្ឌិតណាកាសបានតាមដានដឹងថា ទ័ពសន្តិសុខ ស៊ើបយកមន្ទីរពេទ្យប្រើជាមូលដ្ឋានសម្រាប់បាញ់ប្រជាជនដែលដើរនៅតាមផ្លូវ៖

ក្រោយមកខ្ញុំបានទទួលដំណឹងថា គេបាញ់ប្រជាជនតាមបង្អួចមន្ទីរពេទ្យ ដោយឮពាក្យចាមអារាមនេះ ខ្ញុំបានឡើងទៅជាន់ទីដប់។ ខ្ញុំឃើញគ្រាប់ហើរសំដៅទៅលើដីទួល ដែលជាទីកន្លែងម្តាយខ្ញុំរស់នៅ នៅពេលនោះខ្ញុំបានសម្រេចចិត្តចាកចេញពីឃោជាជាតិ យ៉ូហ្គូស្លាវ។ ពីរទៅបីសប្តាហ៍មុន នៅថ្ងៃទី២ ខែ មេសា នៅពេលដែលអំពើកាប់សម្លាប់ចាប់ផ្តើមឡើង នៅស្សារ៉ាយ៉េវូ ឪពុករបស់លោកណាកាស បានចាកចេញពីផ្ទះហើយពុំមានត្រឡប់មកវិញ ដោយគាត់បានស្លាប់ដោយជម្ងឺគាំងបេះដូង។ ប្រពន្ធរបស់វេជ្ជបណ្ឌិតណាកាស ក្រោយមករកឃើញឪពុករបស់នាងនៅសាលតម្កល់សពនៅមន្ទីរពេទស្សារ៉ាយ៉េវូ។ លោកណាកាស ជឿជាក់ថាព្រឹត្តិការណ៍សាហាវនៅក្នុងថ្ងៃនោះបានសម្លាប់ឪពុករបស់លោក ដោយការយល់ដឹងទុកជាមុនទៅលើអំពើប្រឆាំងគ្នារវាងម៉ូស្លីម ក្រូត និងស៊ើប ដែលឪពុកគាត់ឃើញថាជាការឈឺចាប់ ដែលគាត់ពុំអាចទ្រាំទ្របាន ក្នុងនាមជាជនជាតិយ៉េកូស្លាវ។ ករណីនេះ មានភាពដូចគ្នា នឹងជនជាច្រើនរូបដែលរួចផុតពីសេចក្តីស្លាប់ រឿងតក់ស្លុតរបស់វេជ្ជបណ្ឌិតណាកាសចាប់ផ្តើមឡើងនៅថ្ងៃដែលពុំអាចបំភ្លេចបាន៖ ថ្ងៃទី២ ខែមីនា ជាថ្ងៃដែលឪពុករបស់លោកស្លាប់។

ចំពោះរូបវេជ្ជបណ្ឌិតណាកាស ការបាញ់ចេញពីមន្ទីរពេទ្យជាអំពើក្បត់អ្នកជម្ងឺ និងបូរណភាពរបស់លោកផ្នែកព្យាបាលជម្ងឺ។ លោកបានអធិប្បាយស្តីអំពីពេលដែលលោកទៅជួប នឹងមេបញ្ជាការរបស់លោក ហើយលោកបានប្រាប់គេថាលោកឈប់ធ្វើទាហ៊ាននៅក្នុងពេលនេះតែម្តង៖

✍ អាជីពរបស់ខ្ញុំផ្នែកឃោជាចប់ត្រឹមនេះ ខ្ញុំចង់ចេញពីមន្ទីរពេទ្យ ខ្ញុំចង់ចេញពីកំណែនកងពលទាហ៊ាន អ្វីៗដែលលោកត្រូវការ ខ្ញុំនឹង"ចុះហត្ថលេខា"ទាំងអស់។ លោកឧត្តមសេនីយ បានស្នើសុំ អោយខ្ញុំនៅដោយនិយាយថាយើងទាំងពីររូបបានធ្វើឃោជា ជាមួយគ្នាជាច្រើនឆ្នាំ។ "សូមអនុញ្ញាតអោយខ្ញុំចេញទៅ ខ្ញុំឆ្អែត នឹងអ្វីៗ គ្រប់

បែបដែលខ្ញុំបានឃើញ។ គេបាញ់ចេញពីមន្ទីរពេទ្យ សំដៅទៅទីក្រុងដែលម្តាយខ្ញុំរស់នៅ។ ខ្ញុំត្រូវការនៅជួបជុំក្រុមគ្រួសាររបស់ខ្ញុំ -ខ្ញុំពុំត្រូវនៅជាមួយ នឹងយោធាដែល "យាមការពារ" មន្ទីរពេទ្យពីប្រជាជនសាមញ្ញដោយប្រើអាវុធបែបនេះឡើយ" រួចគាត់ក៏អោយខ្ញុំចេញនៅពេលល្ងាច នៅវេលាម៉ោងជាង៥កន្លះ។

✎ ក្នុងនាមជាគ្រូពេទ្យ គាត់ពុំអាចទ្រាំទ្របានដោយឃើញមន្ទីរពេទ្យក្លាយទៅជាទីកន្លែងធ្វើអោយប្រជាជនស្ប៉ា៉យេ៉វូភ័យខ្លាច ហើយអ្នកជម្ងឺពុំអាចទៅរកជំនួយបាន។ លោកបានដាក់ជីវិតរបស់លោកក្នុងភាពមានគ្រោះថ្នាក់ដោយលោកឈប់ធ្វើទាហ៊ាន។

✎ ខ្ញុំបានបោះបង់ចោលអ្វីៗទាំងអស់ ខ្ញុំត្រឡប់ទៅផ្ទះវិញ-ទៅទីដើមកំណើតរបស់ខ្ញុំ ខ្ញុំជួបជុំ នឹងប្រពន្ធរបស់ខ្ញុំ។ នាងមានសេចក្តីភ័យខ្លាច ដោយនាង ឮពាក្យចចាមអារាមថា ជនដែលនៅសេសសល់ពីផ្នែកទាហ៊ានគេ នឹងចុះឈ្មោះ ដាក់ទៅក្នុងបញ្ជីបំរុងយកទៅសម្លាប់ចោល មិត្តភក្តិរបស់ខ្ញុំជាច្រើននាក់ បានបបួលខ្ញុំអោយរត់ចេញពីប្រទេស តែខ្ញុំពុំទទួលយក។

នៅពេលដែលពណ៌នាអំពីការពិត វិបត្តិជាច្រើន បែបបានបញ្ចេញឡើងដោយអ្នកនិយាយរឿង នៅពេលនេះវេជ្ជបណ្ឌិតណាកាស ពុំដឹងខ្លួនថារូបគាត់មាន ឱកាសដ៏ល្អបំផុត ក្នុងការផ្តល់សេវា ដល់ជនរួមជាតិរបស់គាត់-ជាឱកាសដែលគាត់ពុំអាចអាក់ខាន បើសិនជាគាត់គៀសខ្លួនចេញពីប្រទេស។

ក្រោយពីចាកចេញពីយោធា វេជ្ជបណ្ឌិតណាកាសអត់ការធ្វើចំនួនតែ ១ខែ ពីរថ្ងៃ ស្រាប់តែហេតុការណ៍ដែលស្មានពុំដល់កើតមានឡើង៖

🕮 កងទ័ពស៊ើបបានដកចេញពីមន្ទីរពេទ្យ នៅថ្ងៃទី១០ ខែឧសភា គាត់បានចូលមកមន្ទីរពេទ្យដោយចង់ជួយ។

🕮 ខ្ញុំដើរចូលតាមមាត់ទ្វារមន្ទីរពេទ្យ ខ្ញុំឃើញមនុស្សស្លៀកឯកសណ្ឋានប្លែក គេជាផ្នែកការពារបូស្សនា និងប៉ូលីសស្ប៉ា៉យេ៉វូ។ គេសួរខ្ញុំថាលោកជានរណា៖ ខ្ញុំពន្យល់ប្រាប់គេថាខ្ញុំជាអតីតបុគ្គិលយោធា ហើយជាវេជ្ជបណ្ឌិត។ បុគ្គលិកពេទ្យបានទៅជួបខ្ញុំ ហើយប្រាប់ខ្ញុំថាបុគ្គលិកពេទ្យចំនួន៦៦០ នៅសល់តែ៥០នាក់ទេ។ គេក៏អនុញ្ញាតអោយខ្ញុំចូលមន្ទីរពេទ្យចំនួន១៩២ថ្ងៃ។ ខ្ញុំចំណាយពេលទាំងនោះ នៅក្នុងមន្ទីរពេទ្យព្យាយាមរៀបចំសកម្មភាពនៅក្នុងមន្ទីរពេទ្យ ដោយគេបានសន្យាថា នឹងចាត់តាំងខ្ញុំជា អគ្គនាយកមន្ទីរពេទ្យ។

🕮 អស្ចារ្យណាស់ នេះគឺជាព្រហ្មលិខិត របស់វេជ្ជបណ្ឌិតណាកាស ដោយសារតែទឹកចិត្តមុះមុតដែលគាត់បានសម្រេចថារស់នៅស្ប៉ា៉យេ៉វូ ហើយគាត់ នឹងវិលត្រឡប់មកមន្ទីរពេទ្យវិញ។ ក្រោយពីសេចក្តីសម្រេចចិត្តដែលបាន ផ្លាស់ប្តូរដំណើរជីវិតរបស់គាត់ គាត់បានទទួលការជ្រើសយក ជានាយកមន្ទីរពេទ្យ ដែលបានសម្រេចជោគជ័យដ៏អស្ចារ្យក្នុងរយៈពេល៣ឆ្នាំ។ ព្រឹត្តិការណ៍តក់ស្លុត ដែលគាត់បានទទួល ដោយផ្ទាល់កើតឡើងដោយសារការរងទុក្ខរបស់មន្ទីរពេទ្យអ្នកជម្ងឺ និងបុគ្គលិក។ ក្រោមការចាត់ចែងរបស់គាត់ មន្ទីរពេទ្យនេះបានក្លាយទៅជាទីកន្លែងរស់រវើក ដែលមានដង្ហើមចេញចូល ដែលគាត់មានអារម្មណ៍ថា វានឹងត្រូវតែមានជីវិតឈ្នះគ្រប់ឧបសគ្គនានា។

ចំនួនបីថ្ងៃ ក្រោយពីខ្ញុំចូលមកមន្ទីរពេទ្យ ធ្វើការគេបានចាប់ផ្តើមបាញ់មន្ទីរពេទ្យ ជាដំបូងគេបោះគ្រាប់បែកចូល រួចមកបាញ់ចូល។ មុនដំបូងគេបាញ់អគារទូទៅ រួចមកគេបាញ់បន្ទប់សង្គ្រោះភាពអាសន្ន ធ្វើអោយមន្ទីរពេទ្យគ្មានទឹក ភ្លើងអគ្គិសនី និងគ្រឿងអាហារ។ លើសពីនេះទៅទៀត ប្រជាជន ស្យារ៉ាយ៉េវូពុំទទួលស្គាល់មន្ទីរពេទ្យថា ជាទីសន្តិសុខ ដោយពីមុនទ័ពស៊ើប ធ្លាប់រស់នៅក្នុងនោះ។ ប្រជាជនជៀសវាងពុំមកកាន់មន្ទីរពេទ្យ រហូតទាល់តែការសម្លាប់ខ្លាំងកើតមានឡើងនៅផ្សារម៉ាហ្គេល Markale។

វេជ្ជបណ្ឌិតណាកាស និងបុគ្គលិកពេទ្យ បានលៃលកដោះស្រាយ នឹងស្ថានភាពទាំងនោះ ហើយបន្តបំពេញការងារពេទ្យយ៉ាងប្រសិទ្ធិភាព ដោយប្រើកម្លាំងបាយអូសទាញ អ្នកជម្ងឺចេញពីមន្ទីរពេទ្យដែលមានអ្នកជម្ងឺកកកុញ ហើយយកអ្នកជម្ងឺទាំងនោះទៅព្យាបាល នៅមន្ទីរពេទ្យរដ្ឋ ដើម្បីធ្វើអោយអ្នកជម្ងឺ មានទំនុកចិត្តទៅលើមន្ទីរពេទ្យនេះឡើងវិញ។ ដើម្បីជៀសពីការបាញ់ធ្មក់ និងអំបែងគ្រាប់ផ្លោង អ្នកជម្ងឺ និងបន្ទប់វះកាត់ គឺត្រូវប្តូរទីកន្លែងជាប់រហូត។ គេត្រង់ទឹកភ្លៀងយកមកប្រើប្រាស់ ហើយកែច្នៃអាងផលិតប៊ីយ៉ែរ ទៅជាប្រព័ន្ធត្រង់ទឹកនៅលើដំបូលមន្ទីរពេទ្យ។ នៅពេលនោះគេបានសម្រេចថាគេពុំត្រូវការប្រើភ្លើង ២៤ម៉ោង ក្នុងមួយថ្ងៃទេ តែគេត្រូវការប្រើម៉ាស៊ីនខ្លះៗ ជាចាំបាច់ ជាពិសេសនៅក្នុងពេលវះកាត់។ គេបានប្រើម៉ាស៊ីនភ្លើងតូចមួយ យ៉ាងសន្សំសំចៃដោយប្រើសម្រាប់តែពេលត្រូវការចាំបាច់បំផុត។ ការច្នៃប្រឌិតផ្សេងៗ បានជួយដល់ផ្នែកថ្នាំព្យាបាល ឈាម និងខ្យល់អុកស៊ីសែន ដើម្បីស្រោចស្រង់ជីវិតអ្នកជម្ងឺជាច្រើននាក់ក្នុងមន្ទីរពេទ្យ។

ភាពជួបប្រទះរបស់វេជ្ជបណ្ឌិតនៅក្នុងបទពិសោធន៍របស់គាត់ គឺមានរួមទៅដោយរឿងរបស់អ្នកជម្ងឺ ការជួបប្រទះដោយផ្ទាល់នូវរឿងតក់ស្លុតជាញឹកញាប់ច្រើនតែផ្តោតទៅលើសមាជិកគ្រួសារ និងអ្នករួមការងារដែលរួចផុតពីសេចក្តីស្លាប់។ សេចក្តីស្រលាញ់ និងភក្តីភាពរបស់វេជ្ជបណ្ឌិតណាកាសចំពោះអ្នកជម្ងឺរបស់គាត់ ជាចំណែកមួយផ្នែកនៃប្រវត្តិតក់ស្លុតរបស់គាត់។

ខ្ញុំដើរមើលមន្ទីរពេទ្យជារៀងរាល់ថ្ងៃ ចំនួនពីរទៅបីដង ក្នុងមួយថ្ងៃ ហើយខ្ញុំសួរសុខទុក្ខអ្នកជម្ងឺ ហើយខ្ញុំមើលឃើញ...អ្នកទាំងនោះហើយវានៅដក់ជាប់ក្នុងអារម្មណ៍របស់ខ្ញុំជានិច្ច ប៉ុន្តែ ខ្ញុំពុំចាំឈ្មោះ របស់គេឡើង ខ្ញុំនៅតែចាំមុខមាត់របស់គេ សេចក្តីឈឺចាប់ និងសេចក្តីរីករាយរបស់គេ។ ខ្ញុំអាចចាំគេបានច្បាស់ ដូចជាខ្ញុំចាំរឿងដែលបានបញ្ចាំងអោយមើល។

ជាពិសេសគាត់បានចងចាំអ្នកជម្ងឺពីរនាក់ដែលជាពលរដ្ឋ ស្យារ៉ាយ៉េវូសំខាន់ គេដាច់ជើងដោយសារគ្រាប់ផ្លោង។ ជនម្នាក់ជាប្រធានគណនេយ្យមានឆន្ទៈធំធេងក្នុងដំណើរជីវិត ហើយថ្ងៃនេះគាត់អាចបន្តដំណើរជីវិតរបស់គាត់ដោយអត់ជើង។ ម្នាក់ទៀតជាតួកុនដ៏ល្បីល្បាញដាច់ជើងដោយការផ្ទុះគ្រាប់នៅហាងកាហ្វេ ក្រោយពីរងរបួសគាត់ចង់ស្លាប់។ តួកុនរូបនេះមានអារម្មណ៍ថា រូបខ្លួនគ្មានប្រយោជន៍ដោយគ្មានជើង គាត់ជឿថាគ្មាននរណាយកគាត់ទៅដើរតួរទៀតឡើយ។ ក្រោយមកតួកុនរូបនេះបានប្រាប់វេជ្ជបណ្ឌិតណាកាសអំពីបទពិសោធន៍ដែលគាត់បានទទួលនៅមន្ទីរពេទ្យ ធ្វើអោយរូបគាត់ចង់រស់ម្តងទៀត វេជ្ជបណ្ឌិតណាកាសបានរំលឹកឡើងថា៖

✂ ខ្ញុំព្យាយាមរៀបចំកម្មវិធីសាធារណៈនៅក្នុងមន្ទីរពេទ្យ ខ្ញុំបានអញ្ជើញផ្នែកលេងភ្លេងជាតិ នៅក្នុងខួបកំណើតឆ្នាំទីមួយ ដែលមន្ទីរពេទ្យរួបផុតពីគ្រោះថ្នាក់ ខ្ញុំបានរៀបចំពិធីអបអរសាទរ។ ខ្ញុំបានអញ្ជើញតួរកុនអោយចូលរួមដោយប្រាសចាកពីបំណងរបស់គាត់។ នៅចុងបញ្ចប់ នៃពិធីខ្ញុំបានស្នើសុំអោយតួកុនថ្លែងសុន្ទរកថាទៅកាន់អ្នកចូលរួម។ ខ្ញុំមានការភ្ញាក់ផ្អើលដោយឃើញគាត់ភ័យ ហើយនិយាយមកកាន់ខ្ញុំថា "ហេតុអ្វីបានជាអ្នកធ្វើដូចនេះមកលើរូបខ្ញុំ?" ខ្ញុំបានប្រាប់គាត់ថា "ខ្ញុំគ្រាន់តែជាវេជ្ជបណ្ឌិត-អ្នកជាតួកុន ហើយនេះជាឆាករបស់អ្នក"។ គាត់ចាប់ផ្តើមនិយាយតាមលំដាប់ពីរឿងបុរាណរបស់បូស្សនា ម្នាក់ៗចាប់ផ្តើមយំ។ ក្រោយមកគាត់បានប្រាប់ខ្ញុំថា បើគ្មានកម្មវិធីនេះទេ គាត់ពិតជាគ្មានឱកាសបានដើរតួនៅលើឆាកជាថ្មីម្តងទៀតឡើយ។

នៅក្នុងគ្រាមានភាពឃោរឃៅ វេជ្ជបណ្ឌិតត្រូវគេហៅអោយបំពេញតួនាទីជាច្រើនបែប ដែលគេពុំដែលបានទទួលការហ្វឹកហ្វឺន ហើយវាក៏មានដូចគ្នា នឹងអ្នកផងទាំងឡាយ ដែលបានទទួលបទពិសោធន៍ នឹងអំពើឃោរឃៅដែរ។

រឿងតក់ស្លុតរបស់វេជ្ជបណ្ឌិតណាកាស មានពោរពេញទៅដោយ ឧទាហរណ៍ នៃភាពអយុត្តិធម៌ ភាពយង់ឃ្នង និងភាពក្បត់របស់មនុស្សលោក។ ការឡោមព័ទ្ធនៅ ស្សារ៉ាយ៉េវូ ដាក់កំណត់ជាថ្មីទៅលើភាពព្រៃផ្សៃតែកត្តាពិត នៃរឿងតក់ស្លុតបង្ហាញមិនត្រឹមតែភាពសាហាវយង់ឃ្នងនោះទេ វាបានបង្ហាញនូវភាព ផ្លាស់ប្តូរអស្ចារ្យរបស់ជនទទួលភាពតក់ស្លុត ទៅតួនាទីថ្មី និងឥរិយាបទពិសេស។ ព្រឹត្តិការណ៍តក់ស្លុតអាចមានរួមទៅដោយការផ្លាស់ប្តូរល្អទៅលើចរិត និងអាកប្បកិរិយារបស់បុគ្គល រឿងរបស់វេជ្ជបណ្ឌិតណាកាសជាតំណាងប្រវត្តិសាស្ត្រដំបូងបង្អស់ដែលបរិយាយអំពីមន្ទីរពេទ្យដែលរួចផុតពីគ្រោះភ័យនៅក្នុងសង្រ្គាមឈ្លានពាននៅស្សារ៉ាយ៉េវូ វាជាកាអរិយកិច្ចដ៏មានតម្លៃ ជាពិសេសនៅពេលដែលភាពពុំចុះសម្រុងគ្នានៅក្នុងសម័យថ្មី នៅតែមានជាបន្តដោយតម្រង់បំផ្លាញគ្រឹះស្ថានព្យាបាល បុគ្គលិក និងអ្នកជម្ងឺ។ ឧក្រិដ្ឋជនជឿថាបើសិនជាគេបំផ្លាញសមត្ថភាពព្យាបាលជនរងគ្រោះ គឺគេបានបំផ្លាញសមត្ថភាពរស់រានមានជីវិត និងភាពគ្រាន់បើឡើងវិញរបស់អ្នកទាំងនោះ។

## ១.៨ អត្ថន័យ នៃភាពតក់ស្លុតតាមបែបវប្បធម៌

ព្រឹត្តិការណ៍តក់ស្លុតក្នុងជីវិតពុំមែនតែជា រឿងផ្ទាល់ខ្លួននោះទេ វាជាវប្បធម៌ និងប្រវត្តិសាស្ត្រ វេជ្ជបណ្ឌិតណាកាសបានពន្យល់ថា គោលដៅផ្នែកវប្បធម៌ ទាក់ទងទៅ នឹងទារុណកម្មអតីត យ៉ូកូស្លាវ៉ា Yugoslavia៖

☞ នៅពេលដែល ក្រុមតីតូ Tito សម្រេចចិត្តចែកផ្លូវគ្នាពី ស្តាលីន Stalin ជនគ្រប់រូបដែលចូលចិត្តស្តាលីន បានទទួលការចោទប្រកាន់ហើយបានទទួលទារុណកម្ម។ ផងដែរជនជាតិ យ៉ូកូស្លាវ Yugoslav ក៏បានទទួលទារុណកម្មនៅក្នុងគុក ប្រទេសអាល្លឺម៉ង់ ឬចំណាយពេលនៅក្នុងគុក នៅក្នុងសង្គ្រាមលោកលើកទៅII។

☞ អ្នកទាំងនោះទោះបីជាយ៉ាងណាក៏ដោយ គេលាក់ការអំពីស្ថានភាពដែលគេបានជួបប្រទះ គេពុំចង់ទាក់ទាញភាពយកចិត្តទុកដាក់ពុំល្អមកលើខ្លួនគេ ឬក្រុមគ្រួសាររបស់គេឡើយ។

☞ វេជ្ជបណ្ឌិតណាកាសបានពន្យល់ថា នេះជាមូលហេតុដែលខ្លួនគាត់ពុំបានដឹងឮ អំពីទារុណកម្មពីអ្នកជម្ងឺរបស់គាត់ នៅក្នុងពេលសង្គ្រាម ទោះជាគាត់បានឃើញនៅក្នុងទូរទស្សន៍នូវអំពើសាហាវយង់ឃ្នងដែលប្រជាជនបានទទួលរងគ្រោះក៏ដោយ។

☞ ខ្ញុំបាន ឮពាក្យខ្លះៗ អំពីរឿងទាំងនេះ តែប្រជាជនខ្លាចពុំហ៊ាន និយាយអំពីទារុណកម្ម និងអំពើព្រៃផ្សៃទាំងនោះទេ។ គេមានអារម្មណ៍ខ្មាស់អៀនក្នុងការនិយាយរឿងទាំងនោះ គេខ្មាសគេចង់ចូលរួមច្រើនក្នុងរឿងនេះ ឬផ្តល់ព័ត៌មានបន្ថែម។ បានន័យថា នៅក្នុងវប្បធម៌របស់យើង មនុស្សពុំចង់និយាយអំពីឃោរឃៅ ដោយវាអាចធ្វើអោយអ្នកស្តាប់មានការមន្ទិលសង្ស័យ។ អ្នកស្តាប់ នឹងសន្មតថាអ្នកនោះសមនឹងទទួលភាពទាំងនោះ។ អ្វីៗដែលអ្នកបានស្នើសុំ គឺអ្នកនឹងទទួល ហើយអ្នកត្រូវបម្រុងខ្លួនជាស្រេចក្នុងការពន្យល់ពីមូលហេតុ ដែលអ្នកខ្លះទទួលទារុណកម្មដោយហេតុថាអ្នកទាំងនោះសម នឹងទទួល បើអ្នកនោះនៅខាងស្នេលីន គេពិតជាសម នឹងទទួលទារុណកម្មនោះ។

នៅក្នុងពេលប្រឆាំងគ្នាទ័ពស៊ែប៊ៀន ចាប់រំលោភផ្លូវភេទ និងប្រព្រឹត្តិអំពើយង់ឃ្នងផ្លូវភេទទៅលើស្ត្រីម៉ូស្លីមជា ឧបករណ៍ បង្កើតចរាចលរហូតដល់កម្រិតដែលគេពុំដែលជួបប្រទះក្រោយពីគុកទារុណកម្មជំនាន់នាស៊ី Nazi ។ នៅពេលសួរអំពីមូលហេតុនៃកម្រិតអំពើរំលោភផ្លូវភេទនេះ វេជ្ជបណ្ឌិតណាកាសបានថ្លែងថា៖ ខ្ញុំពិតជាពុំអាចប៉ាន់ស្មានបានថានៅក្នុងអារម្មណ៍របស់ខ្ញុំទៅលើករណីរំលោភទាំងនោះ ដូចជាស្ត្រីម្នាក់ ដែលបានទទួលអំពើរំលោភផ្លូវភេទចំនួន ១៥ដងនៅក្នុងមួយយប់ដោយមនុស្ស១៥នាក់។

វេជ្ជបណ្ឌិតណាកាសបានធ្វើការស្មានថា អំពើរំលោភផ្លូវភេទយកមកប្រើជាមធ្យោបាយបង្កចរាចលទៅលើជនស៊ីវិល ដែលគ្មានអ្វី ការពារ នៅតាមតំបន់ដោយធ្វើអោយ អ្នកទាំងនោះរស់នៅ ទាំងភ័យខ្លាចថា ស្ត្រី និងក្មេងៗ នឹងទទួលការចាប់រំលោភផ្លូវភេទ បើសិនជាទ័ពទាហ៊ាន ប៉ារ៉ាស៊ែប Serb ចាប់អ្នកទាំងនោះបាន។ វេជ្ជបណ្ឌិតណាកាស ក៏បានប៉ាន់ស្មានថា ប្រវត្តិសាស្ត្រ ល្បីរបស់ទ័ពនេះ បណ្តាលអោយសកម្មភាពនេះកើតមានឡើង៖ ទ័ពស៊ែបសងសឹកទៅលើ ស្ត្រីម៉ូស្លីម ដោយសារតែទំនៀមទម្លាប់ រាត្រីដំបូងនៅជំនាន់ចក្រភព អូតូមែន Ottoman ដែលត្រួតត្រាលើទឹកដីស៊ែបៀ Serbia ជាច្រើនសតវត្ស។ នៅក្រោមការចាត់ចែងរបស់ Just Primae Noctis ( សិទ្ធិរាត្រីដំបូង ) អ្នកចាត់ចែងការអូតូមែន Ottoman ដែលគ្រប់គ្រងភូមិស៊ែបមានសិទ្ធិក្រេបព្រហ្មចារីយរបស់កូនក្រមុំស៊ែប និងខ្ញុំបញ្ចៀសទាំងអស់នៅរាត្រីដំបូងមុនមង្គលការ។ ប្រវត្តិនេះ ល្បីសព្វទីកន្លែងហើយបច្ចុប្បន្ននេះ គេបានយកមកពិភាក្សានៅបាល់កាន Balkans។ ការសងសឹកដោយអំពើចាប់រំលោភផ្លូវភេទរបស់ទ័ពស៊ែបទៅលើស្ត្រីភេទដែលគ្មានទោសនេះ ជាច្រើនសតវត្សក្រោយមក គេបានប៉ាន់ស្មានថាមានស្ត្រីចំនួនពីម្ភៃទៅហាសិបម៉ឺននាក់បានទទួលការចាប់រំលោភផ្លូវភេទនៅបូស្សានាដែលគេរាប់បញ្ចូលក្នុងរឿងនិទានរាត្រីដំបូង។

## ១.៩ មើលឆាកជីវិតនៅពីក្រោយរាំងនន

នៅគ្រាដែលអធិប្បាយអំពីរឿងឈឺចាប់របស់ខ្លួន វេជ្ជបណ្ឌិតណាកាស បានបញ្ចេញនូវជម្រៅរឿងផ្ទាល់ខ្លួនរបស់លោក និងពន្លឺចិត្តនិយម ដែលកែប្រែជីវិតរបស់លោកអោយល្អ។ នៅក្នុងនិទានកថាផ្ទាល់របស់លោក លោកបានផ្តល់ដល់យើងគ្រួសៗ នៃនាំងឆាកជីវិតដែលលោកបានហូតវាំងនននោះមកដាក់នៅកៀនមួយកន្លែង ដើម្បីអោយឃើញនូវទស្សនៈ ឬវិធីថ្មី ៖

✍ ប្រហែលជានៅពេលដែលខ្ញុំគិតអំពីរឿងនេះ ខ្ញុំពុំនឹកស្មានថាមេរៀន ចំនួន ប៉ុន្មានដែលខ្ញុំបានរៀន ដោយមេរៀនទាំងនេះក្លាយជាមរតកមួយចំណែកក្នុងចរិយារបស់ខ្ញុំ។ ខ្ញុំពុំនឹងស្មានថាខ្ញុំបានរៀនសូត្ររឿងទាំងនោះឡើយ តែខ្ញុំមានអារម្មណ៍ថាខ្ញុំដឹងរឿងនេះជារៀងរហូត។ ខ្ញុំបានរៀនសូត្រអំពីភាពក្លាយជាវេជ្ជបណ្ឌិត ដែលបានចូលប្រឡូកជាមួយ នឹងប្រជាជន និងសមាជិកគ្រួសារ។

✍ វិធីឈានរកភាពពិតថ្មីជាក្បួនមួយដ៏សំខាន់ ក្នុងការយល់ដឹងអំពីជនទាំងអស់ដែលទទួលការឈឺចាប់ដោយរឿងតក់ស្លុត។ គំនិតចាស់ទទួលការបដិសេធ អ្វីៗចាំបាច់ជាងគេ(អាទិភាព)បានចាត់ឡើង ធម្មនិយមវប្បធម៌ទៅលើអាកប្បកិរិយាសមស្រប នឹងការឆ្លើយតបទៅ នឹងអំពើសាហាវយង់ឃ្នងត្រូវប្រានទុកមួយអន្លើ ដូចជាភាពអាម៉ាស់មុខ ភាពអាស្រូវកិត្តិយស ភាពនិរទេសដែលទាក់ទងទៅ នឹងទារុណកម្ម និងការចាប់រំលោភផ្លូវភេទសំខាន់ជាងនេះទៅទៀត ដូចជាវេជ្ជបណ្ឌិតណាកាសបានបង្ហាញឡើងថា សេចក្តីពិតខ្លះៗ ទាំងនេះអាចចែកចាយគ្នាទៅវិញទៅមក។

តែអ្វីៗ ដែលខ្ញុំពិតជាបានរៀនសូត្រ គឺវិធីរក្សា ***សុខភាពអោយល្អ*** គ្មានអ្វីសំខាន់ជាងសុខភាពទេ គ្មានទ្រព្យសម្បត្តិបើគ្មានសុខភាព។ អ្នកត្រូវតែរក្សាសុខភាពអោយល្អ-ហើយបើសិនជាអ្នកមានសុខភាពល្អ អ្នកអាចទទួលរបស់ទាំងឡាយនោះមកវិញ។

✍ ក្នុងនាមគាត់ជាអ្នកព្យាបាលនៅក្នុងសង្គ្រាម វេជ្ជបណ្ឌិតណាកាសបានឃើញភស្តុតាងសំខាន់នៃសុខភាពរបស់មនុស្សលោក។ ប្រជាជនស្សាវ៉ាយ៉េវូតស៊ូប្រឆាំង ដើម្បីជាសះស្បើយពីរបួស និងជម្ងឺ ទោះជាគេត្រូវសម្លាប់នៅពេលបន្តិចក្រោយមកក៏ដោយ។ វេជ្ជបណ្ឌិតណាកាសបានពោលអះអាងទៅលើតម្លៃសុខភាពជាជាងវត្ថុផ្សេងៗ។ ខ្ញុំក៏ដឹងដែរថា អ្វីៗជាវត្ថុពុំមានន័យ (សុពលភាព)សម្រាប់រូបខ្ញុំទេ-ទូរទស្សន៍ រថយន្ត ឬអ្វីៗ ផ្សេងទៀតលើកលែងតែការកាយសម្បទារបស់ខ្ញុំ ម្រាមដៃ ដៃនិងអ្វីៗ ទាំងអស់បើសិនជាខួរក្បាល និងរាង្គកាយរបស់ខ្ញុំគ្មានខូចខាត ខ្ញុំអាចធ្វើអ្វីទាំងនោះឡើងវិញ។

ដោយបានព្យាបាលអ្នកជម្ងឺរាប់រយនាក់ដែលបាក់ដៃបាក់ជើង និងខូចខាតភ្នែក វេជ្ជបណ្ឌិតណាកាសបានដឹងពិតប្រាកដនូវសារៈសំខាន់ នៃភាពមានអាវៈយវៈសព្វគ្រប់។ ហេតុដូចនេះហើយបានជាអ្នកជម្ងឺពីររូបដែលដាច់ជើងដក់ជាប់នៅក្នុងអារម្មណ៍របស់គាត់។ បើសិនជាគាត់ត្រូវបាត់បង់អ្វីៗ គ្រប់យ៉ាងតែគាត់នៅមានសុខភាពល្អ គាត់មានអារម្មណ៍ថាគាត់អាចកសាងជីវិតសង្គមថ្មី។ វេជ្ជបណ្ឌិតណាកាសពុំត្រូវការទ្រព្យសម្បត្តិ និងឋានៈសង្គម

ដែលផ្តល់ឡើងដោយសង្គមដល់វេជ្ជបណ្ឌិតទៀតឡើយ គាត់មានទស្សនវិជ្ជាប្តេជ្ញាទៅលើសុខភាពលើសពីអ្វីៗគ្រប់យ៉ាងទាំងអស់។ ខ្ញុំយល់ដឹងថាភាពសុខស្រួលដែលយើងរស់នៅ គឺជាអ្វីៗដែលយើងបានបង្កើតឡើងសម្រាប់រូបយើង។ យើងកម្រិតជីវភាពសម្ភារៈហើយកម្រិតនោះចេះតែកើនច្រើនឡើងៗនៅជំនាន់នីមួយៗ តែនៅក្នុងសង្គ្រាមយើងរស់រួចផុតពីសេចក្តីស្លាប់នៅក្នុងភាពលំបាកជាទីបំផុត។ បានន័យថាយើងរស់ដោយមានតែទឹកមួយលីត្រក្នុងមួយថ្ងៃ គ្មានភ្លើងអគ្គិសនី បីឆ្នាំ គ្មានទូរទស្សន៍ គ្មានម៉ាស៊ីនសំអាតផ្ទះ គ្មានទូរទឹកកក គ្មានម៉ាស៊ីនបូមព្រុំ។ ខ្ញុំយល់ដឹងថាដោយគ្មានវត្ថុទាំងនេះ យើងអាចរស់រួចផុតពីសេចក្តីស្លាប់-ហើយអាចមានភាពរិតតែប្រសើរឡើង។

វេជ្ជបណ្ឌិតណាកាស បានបញ្ចប់មេរៀនភាពរួចផុតពីសេចក្តីស្លាប់ ហើយសេចក្តីពិត គឺតែងតែដក់នៅជាមួយរូបគាត់ជានិច្ច ជាសារៈសំខាន់ដែលដក់ជាប់នៅក្នុងខ្លួនយើងច្រើនរូបៈ

នៅចំណុចមួយនៃ ផ្នែកការចងចាំរបស់ខ្ញុំ ថាអ្វីៗបានសរសេរទុករួចអស់ទៅហើយ។ មួយភ្លេតនោះខ្ញុំយល់ដឹងថាអ្វីៗ បាត់បង់ទាំងអស់ហើយវាអាចស្តារឡើងវិញម្តងទៀត។ បានន័យថាបើមានមនុស្សលោក បើមានសេចក្តីប្រាថ្នា បើមានចំណងមិត្តភាព បើមានបងប្អូន ពិតជាមានឱកាសរស់រួចផុតពីសេចក្តីស្លាប់។

នៅគឺជាវេជ្ជបញ្ញារបស់វេជ្ជបណ្ឌិត សម្រាប់ភាពជាសះស្បើយ ដែលពុំមានបង្រៀននៅសាលាវិជ្ជាជីវៈពេទ្យទេ តែមាននៅជួរសមរភូមិមុខ។

## ១.៦ ទំនាក់ទំនង-រវាងអ្នកស្តាប់-អ្នកនិទានរឿង

វេជ្ជបណ្ឌិតណាកាសមានអ្វីៗ ជាច្រើនបានបង្រៀនដល់យើង ក្នុងនាម គាត់ជាវេជ្ជបណ្ឌិត និងជាមនុស្សលោក។ នៅពេលស្តាប់រឿងរបស់គាត់ គាត់អាចប្តូរភាពផ្តោតអារម្មណ៍តានតឹង ដោយរួមបញ្ចូលកត្តាពិត ជាពិសេសសេចក្តីស្លាប់របស់ឪពុកគាត់ និងទុក្ខសោករបស់តារាសម្តែងដែលបានរងរបួស មេរៀនដែលគាត់ចង់បង្រៀនអំពីភាពរស់រួចផុតពីសេចក្តីស្លាប់ និងភាពជាសះស្បើយ។ វេជ្ជបណ្ឌិតណាកាសពុំចង់អោយអ្នកស្តាប់ជាប់ចិត្តទៅលើភាពតក់ស្លុត និងសេចក្តីឈឺចាប់របស់គាត់ឡើយ ក៏ដូចជាជនរស់រួចផុតពីសេចក្តីស្លាប់ជាច្រើនរូបទៀត គាត់បានជ្រើសយកដោយប្រុងប្រយ័ត្នតែចំណែកមួយផ្នែកតូច នៃសេចក្តីឈឺចាប់គាត់។

វេជ្ជបណ្ឌិតណាកាសបានដឹងថាគាត់និយាយអំពីប្រវត្តិសាស្រ្ត "គ្មាននរណាម្នាក់អាចស្មានទុកជាមុនអំពីតម្លៃ នៃការរួមចំណែកនៅក្នុងប្រវត្តិសាស្រ្ត" គាត់មានមោទនភាពទៅលើការដឹកនាំរបស់គាត់នៅក្នុងសង្គ្រាមៈ

🗎 គ្មាននរណាម្នាក់អាចពណ៌នាអំពីមន្ទីរពេទ្យនេះ ដោយពុំមាននឹងឃើញរូបគាត់បានឡើយ អ្នកខ្លះកើតហើយស្លាប់ទៅវិញដោយគ្មានចូលរួមចំណែកនៅក្នុងសង្គម។ អ្នកខ្លះជាអ្នកបង្កើតគ្រឿងផ្ទះ អ្នកខ្លះជាអ្នកបង្កើតទូរទស្សន៍ អ្នកខ្លះជាអ្នកបង្កើតទូរស័ព្ទ ហើយអ្នកទាំងនោះបានទទួលស្គាល់ដោយអ្វីៗ ដែលគេរកឃើញ និងបង្កើតឡើង។ ខ្ញុំពុំមានរកឃើញអ្វីទេ តែខ្ញុំចូលរួមចំណែកនៅក្នុងប្រវត្តិសាស្រ្តក្នុងទីក្រុងនេះ រូបខ្ញុំជាចំណែកមួយនៅក្នុងប្រវត្តិសាស្រ្តបូស្សនា និងតំបន់នេះ។

🗎 យើងអាចយល់អំពីអារម្មណ៍ពេញចិត្ត នៃពាក្យពេចន៍របស់វេជ្ជបណ្ឌិតណាកាស តែគួរអោយស្តាយដោយអ្នករួចផុតពីសេចក្តីស្លាប់ជាច្រើនរូប ពុំផ្តល់កិត្តិយសដល់ខ្លួនគេទៅលើសេចក្តីបរិច្ចាគដែលគេបានធ្វើឡើងដល់ក្រុមគ្រួសារ និងសហគមន៍របស់ខ្លួន។ វេជ្ជបណ្ឌិតនៅបូស្សនាមួយចំនួនមានអារម្មណ៍ថា គេបានបង់ខាតដំណើរជីវិតជាវេជ្ជបណ្ឌិតជាច្រើនឆ្នាំនៅក្នុងសង្គ្រាម ដោយគេគ្មានអ្វីជាក់ច្បាស់ នឹងបង្ហាញគេឯង។ វេជ្ជបណ្ឌិតណាកាសរៀននូវ ឧទាហរណ៍ល្អមួយ តាមរយៈការយល់ដឹងរបស់គាត់នៃភាពរួចផុតពីសេចក្តីស្លាប់។

🗎 អ្វីៗទាំងនេះធ្វើអោយខ្ញុំមានអារម្មណ៍ពេញចិត្តដោយខ្ញុំមានអារម្មណ៍ថា បើសិនជាខ្ញុំពុំនៅទីនេះទេ អ្វីៗអាចមានភាពកាន់តែខ្លាំងជាងនេះទៅទៀត។ ខ្ញុំពិងជាពុំដឹងច្បាស់ទេ អ្វីៗ អាចក្លាយទៅជាបែបផ្សេងទៅវិញ បើសិនជាខ្ញុំពុំមានវត្តមាននៅក្នុងពេលនោះ។ ដោយហេតុនេះហើយវាធ្វើអោយខ្ញុំសប្បាយចិត្ត បើពុំដូច្នេះទេ ខ្ញុំពិតជាមានអារម្មណ៍អស់សង្ឃឹម។

លោក វេជ្ជបណ្ឌិតណាកាស ក៏បានលើកយកប្រធានបទទំនាក់ទំនង រវាងអ្នកស្តាប់-អ្នកនិទានរឿង ចេញពីទស្សនៈរបស់អ្នកនិទានរឿង។ គាត់ជឿជាក់ថាអ្នករួចផុតពីសេចក្តីស្លាប់មួយចំនួនធំយល់ថាការនិទានរឿងអាចជួយរំសាយទុក្ខកង្វល់។ នៅគ្រាដែល អ្នកបាននិទានរឿងមានអារម្មណ៍ថាធូរស្រាល ខ្ញុំផ្តល់ឧទាហរណ៍មួយរបស់ប្រជជនបូស្សានានៅតំបន់ម៉ូស្លីម។ គេពុំយំសោកច្រើនទេ។ ស្ត្រីចូលរួមនៅក្នុងបុណ្យសពគេនាំគ្នានិយាយច្រើន គេនិយាយរឿងម្តងហើយម្តងទៀត។ ខ្ញុំមានឱកាសបានស្តាប់រឿងនោះពីរទៅបីដងនៅក្នុងរឿងសោកនាដកម្មខ្លះៗ នៅក្នុងពិធីដ៏ច្រើនទាំងនោះ។ រឿងនោះដូចជាកាសែតអត់សម្លេងរួមដោយពាក្យពេចន៍ និងឃ្លាដដែលៗ ហើយរៀងរាល់ពេលមុន នឹងបញ្ចប់ អ្នកនិទានរឿងមានអារម្មណ៍រីករាយជាងមុន ហើយអ្នកស្តាប់ក៏យល់ដឹងកាន់តែច្រើនឡើង ដោយបានទទួលចំណេះដឹងថ្មី។

ដូចវេជ្ជបណ្ឌិតណាកាស បានពន្យល់ថាការនិទានរឿងសារឡើងវិញ ធ្វើអោយអ្នកនិទានរឿងមានអារម្មណ៍ទុកចិត្តទៅលើខ្លួន។ ផលល្អគឺមានអ្នកស្តាប់ដែលជាចំណែកមួយនៅក្នុងដំណើរការព្យាបាល វេជ្ជបណ្ឌិតណាកាសរកឃើញផលប្រយោជន៍សំខាន់នៃរឿងតក់ស្លុត៖ ការស្តាប់ធ្វើអោយយើងមានចំណេះហៀរហូរដោយយើងទទួលបាននូវចំណេះដឹងថ្មី។ តើចំណេះដឹងថ្មីនេះមានអ្វីខ្លះ? ដែលសេចក្តីឈឺចាប់ដែលអ្នករងគ្រោះបញ្ជូនមកអោយយើង ព្រមទាំងភាពពិត នៃបទពិសោធន៍ដែលកើតឡើងដោយពិត។ អ្នកស្តាប់រឹតតែឈ្លាសវៃឡើងដោយគេដឹងអំពីជោគជ័យ របស់អ្នកនិទានរឿង។ ជាពិសេសរឿងតក់ស្លុត នៅក្នុងចំណុចសំខាន់នីមួយៗ នៃចំណុចសំខាន់ៗទាំងបួន និងសាច់រឿងទាំងស្រុង ផ្តល់នូវព័ត៌មានថ្មីដ៏អស្ចារ្យអំពីភាពរួចផុតពីសេចក្តីស្លាប់ និងភាពជាសះស្បើយ។ ប្រវត្តិរឿងផ្ទាល់មាត់របស់វេជ្ជបណ្ឌិតណាកាស និងស្ត្រីខ្មែរបានចែកចាយគតិបណ្ឌិតរបស់គេដោយគេសង្ឃឹមថា នឹងជួយជម្រុញទឹកចិត្ត និងកម្លាំងដល់អ្នកស្តាប់អោយពុះពារធ្វើអោយខ្លួនគេរួចផុតពីភាពតក់ស្លុតដែលគេពុំអាចគេចផុត ហើយដែលបានដក់ជាប់នៅក្នុងដំណើរជីវិតរបស់គេ។

អ្នកស្តាប់ត្រូវតែចាំថាគោលដៅ នៃមរតករឿងតក់ស្លុតគឺ ភាពជាសះស្បើយ និងភាពរួចផុតពីសេចក្តីស្លាប់ត្រូវអោយអ្នករួចផុតពីសេចក្តីស្លាប់ រៀបរាប់រឿងតក់ស្លុតតាមបែបបទរបស់គេ។ យើងពុំត្រូវដាក់បន្ទុកបន្ថែម

ដោយលើកយកទ្រឹស្តីបកស្រាយ ឬទស្សនៈផ្ទាល់ខ្លួន ជាពិសេសបើសិនជាយើងយល់ដឹងស្តួចស្តើងអំពីទំនៀមទម្លាប់ និងប្រវត្តិនយោបាយរបស់គេ។ យើងពុំត្រូវជ្រៀតជ្រែក តែត្រូវរក្សាខ្លួនជាអ្នកស្តាប់ដែលចង់ដឹង និងទោរទន់អារម្មណ៍ ដូច្នេះ រឿងតក់ស្លុត និងដំណើរការទៅតាមសម្រួលដោយគ្មានភាពបញ្ចុះបញ្ចូលពីក្រៅ។ បើសិនជាអ្នកនិទានរឿងមានអារម្មណ៍ថាយើងដឹងអំពីអ្វីៗ ដែលគេបំរុង នឹងនិយាយគេអាចបដិសេធពុំនិយាយ ឬនិយាយតែអំពីអ្វីៗ ដែលយើងចង់ដឹងឮ។ ត្រូវយកចិត្តទុកដាក់ទៅលើចំណុចសំខាន់ៗបួននៃរឿងតក់ស្លុត ដោយអោយអ្នកនិទានរឿងចែកចាយចំណេះដឹងអាថ៌កំបាំង តាមលំដាប់ដែលអាចធ្វើអោយយើងជាសះស្បើយ និងរួចផុតពីសេចក្តីស្លាប់នៃភាពតក់ស្លុតរបស់មនុស្សលោក។

រឿងតក់ស្លុតអាចនិយាយរៀបរាប់ជាក្រុម រួមនឹងមនុស្សឯទៀត ដែលមានបញ្ហាដូចគ្នា ពិនិត្យអត្ថន័យទំនៀមទម្លាប់ ភាពតក់ស្លុត ជាពិសេសវាមានប្រយោជន៍បើសិនជាព្រឹត្តិការណ៍ដំណើរជីវិតនោះមានរួមទៅដោយភាពអាម៉ាស់មុខ និងភាពអាប់អោនកិត្តិយសនៅក្នុងសង្គម។ ឧទាហរណ៍លីន ហ្វ្រែងគ្លិន Lynn Franklin ជាអ្នកបង្កើត និងជាអ្នកនិពន្ធ សូមអោយរង្វង់មូលកុំដាច់៖ ***ដំណើរយាត្រាពិតៗសំដៅទៅលើកត្តាសំខាន់នៃការសំបុត្រចិញ្ចឹម*** បានយកមកប្រើជាមធ្យោបាយប្រកបដោយជោគជ័យនៅក្នុងកម្មសិក្សាជាមួយ នឹងស្ត្រីដែលបោះបង់កូនអោយគេចិញ្ចឹម។ ម្តាយដែលបង្កើតបុត្រភាគច្រើនមានវ័យក្មេងនៅពេលដែលគេមានផ្ទៃពោះ ហើយបានទទួលការបង្ខិតបង្ខំដោយក្រុមគ្រួសារអោយដាក់កូនទៅអោយគេចិញ្ចឹម ដើម្បីជៀសវាងពីភាពស្តីបន្ទោស និងភាពខ្មាស់អៀននៅក្នុងសង្គម។ ជាច្រើនឆ្នាំកន្លងផុតទៅគេនៅតែមានទុក្ខសោក ជាញឹកញាប់ដោយលួចលាក់យ៉ាងស្ងាត់ស្ងៀម ដោយគេគ្មានដឹងអ្វីទាំងអស់អំពីសុខទុក្ខកូនរបស់ខ្លួន។ នៅពេលដែលម្តាយបង្កើតនឹកឡើងវិញនូវរឿងតក់ស្លុតរបស់ខ្លួន គេអាច "មើលហួសទាំងពីរឆាកជីវិត" ហើយដឹងខ្លួនថាការសម្រេចចិត្តដាក់កូនអោយគេចិញ្ចឹមគឺយោងទៅតាមប្រពៃណីនិយមក្នុងសង្គម ហើយពេលនោះការយល់ដឹងរបស់ខ្លួន ឬការយកចិត្តទុកដាក់ទៅលើភាពប៉ះទង្គិចយូរលង់ នៃភាពបែកបាក់គ្នា និងអាថ៌កំបាំងរវាងអ្នកដែលទទួលចិញ្ចឹមកូន និងឪពុកម្តាយបង្កើតមានតិចតួចពេក។ កម្មសិក្សាចាប់ផ្តើមដំណើរការភាពជាសះស្បើយដោយអនុញ្ញាតអោយជនទាំងនោះបញ្ចេញសេចក្តីឈឺចាប់ដោយទទួលយកសេចក្តីសម្រេចចិត្តរបស់ខ្លួន និង/ឬរកកូនខ្លួនដែលបានវង្វេងបាត់។

មធ្យោបាយថ្មីនៃការយល់ដឹងរឿងតក់ស្លុតផ្តល់ដល់ជនគ្រប់រូបនូវវិធីនិយាយ និងវិធីបកស្រាយរឿងផ្ទាល់ខ្លួនក្រៅពីរឿងរបស់អ្នកផ្សេងៗទៀត។ យើងអាចមើលក្នុងព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងដំណើរជីវិតរបស់យើង ដោយរំលឹកឡើងវិញតាមលំដាប់ចំណុចសំខាន់ ទាំងបួន ម្តងមួយៗ។ ភាពគ្រាន់តែនិយាយអំពីសេចក្តីឈឺចាប់របស់យើងប្រាប់អ្នកឯទៀត អាចជួយបន្ថយសេចក្តីឈឺចាប់។ អ្នកជម្ងឺរោគហឺត និងរោគឈឺសន្លាក់ដៃជើងរ៉ាំរ៉ៃ ដកដង្ហើមបានធូរស្រាល និងបានរំសាយពីការឈឺចាប់សន្លាក់ឆ្អឹងក្រោយពីគេកត់ទុករឿងរ៉ាវប្រចាំថ្ងៃអំពីស្ថានភាពដែលធ្វើអោយគេខឹងចិត្តនៅក្នុងដំណើរជីវិតរបស់គេ។ កូនសៀវភៅកំណត់ហេតុប្រចាំថ្ងៃកត់ត្រារឿងសោកសង្រេងដែលរួមទៅដោយជម្ងឺសុខភាព ត្រូវប្រមាណមើលក្នុងន័យជាភាពសម្រាលសេចក្តីឈឺចាប់។ ការ

ពេញចិត្តទៅលើវិស័យ និងជម្រៅរឿងសោកសង្រេង ជាតួនាទីដ៏សំខាន់ផ្ទាល់ខ្លួន និងសង្គមក្នុងការជាសះស្បើយពីភាពអាម៉ាស់មុខឃោរឃៅ និងភាពបង្អាក់គោលដៅ។

**ជំពូកទី៣** **ភាពអាប់យស**

**(អាម៉ាស់មុខ)**

នៅថ្ងៃទី៦ ខែ មេសា ឆ្នាំ១៩៩៤ ពួកឧទ្ទាមបាន ព័ទ្ធបាញ់អាកាសយានដែលជូនដំណើរ លោក ប្រធានាធិបតី រ៉្វាន់ដា Rowanda និង ប៊ូ រុនឌី Burundi ហើយវាបានសម្លាប់អ្នកទាំងពីរនោះចោល នៅថ្ងៃទី៧ ខែ មេសា អំពើសម្លាប់រង្គាលដែលពុំមានពីមុនមកក៏ចាប់ផ្ដើមកើតឡើង។ មកទល់ខែ កក្កដា ប្រជាជន ទុតស៊ីTutsi និង ប្រជាជន ហ៊ូទូ Hutu កម្រិតថ្នាក់មធ្យមនិយមចំនួន ៨០០,០០០នាក់ បានស្លាប់ដោយសារស្នាដៃទ័ពដែលបានរៀបចំឡើងដោយពួកទាហ៊ាន ហ៊ូទូ Hutu ប្រជាជន បីលានគ្មានទីជម្រក ប្រទេសក្លាយទៅជា កលិយុគ (ច្របូកច្របល់)។

នៅក្នុងឆ្នាំ១៩៩៦ មន្ទីរសុខភាពរបស់យើងបានធ្វើការស្រង់ស្ថិតិទៅលើភាពប៉ះទង្គិចសតិអារម្មណ៍ ដែលកើតឡើងដោយអំពើសម្លាប់រង្គាលនៅ រ៉ូ វ៉ាន់ដា។ សេចក្ដីស្រង់ស្ថិតិបញ្ជាក់អំពីស្នាមផ្ចិតដៃ ដែលជនល្មើសព្យាយាមធ្វើអោយសង្គមទាំងមូលសាបសូន្យ។ ទោះជាការសម្លាប់ផ្ដោតតែទៅលើជនជាតិទូតស៊ីក៏ដោយ គ្មាននរណាម្នាក់អាចគេចផុតឡើយ។ ប្រជាជនរ៉្វាន់ដាគ្រប់រូបទទួលបានបទពិសោធន៍តក់ស្លុតប្លែកៗគ្នា ព្រមទាំងស្ថានភាពដ៏សាហាវយង់ឃ្នងដែលកើតឡើងទៅលើក្រុមគ្រួសារ និងសហគមន៍របស់គេ។ បទពិសោធន៍របស់គេមានរួមទាំងការខូចខាតសម្ភារៈ សម្បត្តិទ្រព្យ ដូចជាផ្ទះសម្បែង ដីស្រែ ភូមិឋាន របួសរាងកាយ ពិការ និងស្លាប់ ថែមទាំងខូចខាតដល់ ផ្នែកវប្បធម៌ ដូចជា ការបំផ្លាញវិហារព្រះយ៉េស៊ូ និងសាលារៀន ភាពខូចខាតសតិអារម្មណ៍ ដូចជាមានការភ័យខ្លាចអត់ស្រាកស្រាន្ត ថាខ្លួននឹងត្រូវគេសម្លាប់ ឬភាពមើលឃើញមិត្តភក្តិ និងញាតិមិត្ត ដែលត្រូវគេសម្លាប់ និងភាពបាត់បង់សេចក្ដីទុកចិត្តទៅលើអ្នកជិតខាង។

នៅក្នុងឆ្នាំ ១៩៩៩ កោះប៉ាស៊ីហ្វិកតូចមួយនៅទីម័រខាងកើតTimor បានបោះឆ្នោតសុំឯករាជ្យភាពពីប្រទេសឥណ្ឌូណេស៊ី បានបណ្ដាលអោយកើតឧក្រិដ្ឋកម្មជាមួយ នឹងទ័ពឥណ្ឌូណេស៊ី។ មួយឆ្នាំក្រោយមក ខ្ញុំបានទទួលការអញ្ជើញអោយទៅរៀបចំមន្ទីរសុខភាពសតិអារម្មណ៍នៅទីម័រខាងកើត។ ទោះជាគេសម្លាប់ប្រជាជនទីម័រតែមួយចំនួននៅក្នុងពេលវាយប្រទាំងគ្នាក៏ដោយ ក៏ទ្រព្យសម្បត្តិមួយចំនួនធំ ត្រូវគេបំផ្លាញចោល សូម្បីតែទូកនេសាទតូចមួយក៏គ្មានសល់ដែរ។ ទោះជាការរស់នៅរបស់ប្រជាជនស្ថិតនៅជិតសមុទ្រដ៏សម្បូរបែប តែជនជាតិទីម័រខាងកើតទៅជាជួបភាពអត់ឃ្លានដាច់ពោះ។ ជនល្មើសមិនត្រឹមតែបំផ្លាញផ្ទះសម្បែង និងភូមិឋាននោះទេ តែជនល្មើសបានបំផ្លាញជីវិតដោយប៉ងបំបាត់ពូជពង្ស គោលដៅរបស់ជនល្មើស គឺបង្ហាញដោយច្បាស់ថាគេប៉ងបំបាត់ វប្បធម៌នោះអោយសាបសូន្យ។

ក្នុងការសិក្សាដំណើររឿងនេះ និងរឿងតក់ស្លុតជាច្រើនដែលរាប់មិនអស់ ខ្ញុំបានយល់ដឹងថាភាពអាម៉ាស់មុខជាស្ថានភាពសតិអារម្មណ៍ដែលបណ្ដាលឡើងដោយអំពើយង់ឃ្នង ហើយដែលអ្នកព្យាបាលសតិអារម្មណ៍

និងថ្នាំពេទ្យពុំបានចាប់អារម្មណ៍ជាង១០០ឆ្នាំមកហើយ។ ភាពអាម៉ាស់មុខទាក់ទងយ៉ាងខ្លាំងទៅ នឹងអារម្មណ៍ខ្មាស់អៀន ភាពអាប់កិត្តិយស និងភាពនិយាយបន្ថោក ដែលជាប្រតិកម្ម ធម្មតាទៅលើសកម្មភាពយង់ឃ្នង។ ដោយភាពទាំងនេះកើតមានឡើងរួមទៅដោយអំពើហឹង្សា ភាពអស់សង្ឃឹម និងភាពអាម៉ាស់មុខ ជាញឹកញាប់ច្រើនតែបិទបាំងដោយអារម្មណ៍តានតឹងទាំងនេះ។ ចំណុចដែលធ្វើអោយខូចខាតដល់សតិអារម្មណ៍ ជាញឹកញាប់ពិបាកមើលឃើញនៅក្នុងស្ថានភាពដូចជាអំពើបំពាន និងអំពើហឹង្សារវាងប្តីប្រពន្ធ និងអំពើរំលោភផ្លូវភេទ។ តែនៅក្នុងករណីអំពើសាហាវបំផុត ភាពពិត និងភាពខូចខាតជាធម្មជាតិ ដែលប៉ះពាល់ដោយភាពអាម៉ាស់មុខអាចមើលឃើញបាន។

ភាពអាម៉ាស់មុខដែលបានកើតមានឡើងក្រោយពីអំពើយង់ឃ្នង ជួយយើងអោយយល់ថាអំពើសាហាវយង់ឃ្នងទារុណកម្ម និងភេវកម្មហាក់ដូចជាពុំមែនកើតឡើងដោយអំពើយង់ឃ្នងព្រាវនោះទេ។ អំពើទាំងនោះបានរៀបចំឡើងជាព្រឹត្តិការណ៍ដែលប៉ងធ្វើឡើងដើម្បីបំបាត់អោយសាបសូន្យ មិនត្រឹមតែបំបាត់បុគ្គលម្នាក់ អោយសាបសូន្យនោះទេ គឺបំបាត់សង្គម និងប្រទេសជាតិអោយសាបសូន្យទៀតផង។ ផែនការទាំងនេះបានរៀបចំឡើងដោយជនល្មើសប៉ង ឬយ៉ាងហោចណាស់ធ្វើអោយផ្លាស់ប្តូរមូលដ្ឋាន និងវប្បធម៌ទាំងមូល។

## ១. ការរំលាយវប្បធម៌អោយសាបសូន្យ

ការរំលាយវប្បធម៌មនុស្សអោយសាបសូន្យកើតឡើង ដោយមានរួមទាំងការបំផ្លាញសម្ភារៈ រាង្គកាយសង្គម និងខូចខាតសតិអារម្មណ៍។ ការរំលាយវប្បធម៌អោយសាបសូន្យមានកម្រិតលើសពីការបំផ្លាញរោងចក្រ និងស្ពាន រហូតដល់ទៅមានការវាយសម្លាប់ និងធ្វើអោយពិការរាងកាយដល់ទាហ៊ាន និងប្រជាជនសាមញ្ញ។

សព្វថ្ងៃនេះ ពុំមានធនធានគ្រប់គ្រាន់ នៅក្នុងពិភពលោក ដែលអាចជួយ ដល់ការខូចខាត ដែលបណ្តាលឡើងដោយសង្គ្រាម និងការវាយប្រឆាំង និងជាតិសាសន៍ឡើយ។ ពុំមានវិធីណាមួយដែលអាចរកកសិករ គ្រូបង្រៀន វិស្វករ និងអ្នកចាត់ការសាធារណៈដែលបានបាត់បង់ជីវិតទៅនោះមកជំនួសវិញឡើយ។ នៅប្រទេសកម្ពុជា ក្រោយពីរបបភេវកម្មខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ ក្នុងចំណោមវេជ្ជបណ្ឌិត ២០០០នាក់ នៅសល់តែវេជ្ជបណ្ឌិតតិចជាង១០០នាក់។

វត្តអារាមស្ទើរតែទាំងអស់បានបំផ្លាញចោល រូបព្រះពុទ្ធបដិមាករ ត្រូវប្រមាថមើលងាយដោយបំភ្លេចចោល គ្រវែងចោលទៅក្នុងបឹង និងវាលស្រែ។ ការវាយប្រហារ រវាងបាល់កាន Balkans និងអាប់ហ្គានីស្ថាន Afghanistan ជនល្មើសបានផ្តោតអារម្មណ៍សំដៅលើប្រជាជនសាមញ្ញ ដោយមានរួមដោយអំពើសម្លាប់រង្គាលលើស្ត្រីភេទ និងកូនក្មេង ការបំផ្លាញគ្រឹះស្ថានសាសនា និងមន្ទីរពេទ្យ។ នៅក្នុងសង្គ្រាមបាល់កាន Balkans នៅក្នុងឆ្នាំ១៩៩០ សកលវិទ្យាល័យ និងមន្ទីរពេទ្យនៅស្សារ៉ាយ៉េវូ បានទទួលការប៉ងបំផ្លាញអោយសាបសូន្យ ដោយទំពស្សើប។

លោក រ៉ា ដូវ៉ាន់ ការ៉ាតហ្សិច Radovan Kardzic អតីតសាស្ត្រាចារ្យ សកលវិទ្យាល័យចិត្តវិទ្យាបានបញ្ជាអោយ គេផ្លោងគ្រាប់កាំភ្លើងធំចំអតីតមន្ទីរសុខភាពដែលគាត់ធ្វើការដើម្បីបំផ្លាញអ្នករួមការងារ និងអ្នកជម្ងឺរបស់គាត់អោយសាបសូន្យ។ នៅប្រទេសអាប់ហ្គានីស្ថាន Afghanistan ពួកថាលីបាន Taliban យកស្ត្រី និងកូនក្មេងធ្វើជាទាសករយ៉ាងព្រៃផ្សៃនៅក្នុងមជ្ឈឹមសម័យ(គ.ស ១១០០-១៤០០)។ នៅក្នុងឆ្នាំ២០០១ ពួកថាលីបាន Taliban បានវាយបំផ្លាញព្រះពុទ្ធបដិមាករធំអស្ចារ្យ ពីរព្រះអង្គដែលឆ្លាក់ជាប់ នឹងចំណោតភ្នំបាមីយាន Bamiyan ព្រះពុទ្ធមួយអង្គ គឺឆ្លាក់ឡើងតាំងពីសតវត្សទី៣ មកម្លេះ។ ពួកថាលីបានចាត់ទុកថាការដាក់តាំងរូបអាទិទេព គឺប្រមាថដល់ពិសិដ្ឋវត្ថុ ទោះជាអាទិទេពនោះ មកពីប្រភពជំនឿសាសនាផ្សេង ក៏ដោយ។ ការពិតគេប្រើគ្រឿងផ្ទុះពីរទៅបីសរសៃបំផ្លាញទីតាំងកេរ្តិ៍មរតកពិភពលោក ដើម្បីបញ្ចេញភាពមើលងាយទៅលើសាសនាផ្សេងទៀត ការបញ្ចេញភាពពុំអត់អោនក្នុងផ្នែកសាសនាជាបែបហួសហេតុអស្ចារ្យណាស់។

ជាងមួយត្រីមាស នៃសតវត្សភាពកែប្រែបានកើតមានឡើងទៅលើអំពើសាហាវយង់ឃ្នង ដូច្នេះ ភាពខូចខាតទាំងវប្បធម៌ ទាំងសតិអារម្មណ៍ក្លាយទៅជាភាពខូចខាតសំខាន់ទាំងសម្ភារៈ ទាំងរាងកាយ។ ការវាយប្រហារប្រឆាំងគ្នាសម័យថ្មីគ្រប់ជ្រុង ទូទាំងពិភពលោក គឺលែងយកចិត្តទុកដាក់ទៅលើការចាប់អ្នកជណ្តើមជ័យជំនះយកមកដាក់គុក ដើម្បីបញ្ចប់ដានដំណើរជីវិតរបស់គេ។ ក្បួនសម្លាប់វេជ្ជបណ្ឌិត និងអ្នកជម្ងឺ អំពើឃោរឃៅបំពានក្រិតក្រម កាកបាទក្រហមអន្តរជាតិ ការចាប់ខ្លួន និងការសម្លាប់អ្នកកាសែត និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធ័រណេតដែលបង្ហាញអំពើសម្លាប់ព្រៃផ្សៃទៅលើប្រជាជនសាមញ្ញដែលត្រូវគេចាប់ខ្លួន ជាក្បួនខ្លះៗ ដែលបានប្រកាសផ្សាយនូវយុគសម័យថ្មីអំពីភេរវកម្មចិត្តសាស្ត្រ និងវប្បធម៌ ។ មនោគមវិជ្ជារបស់ណាស៊ី Nazi នៃការបំបាត់អោយសាបសូន្យ "ជីវិតគ្មានតម្លៃ នឹងជីវិត "បានផ្សព្វផ្សាយទូទាំងពិភពលោក ជាការបំបាត់ភាព "គ្មានប្រយោជន៍" របស់សង្គម វប្បធម៌មនុស្សអោយសាបសូន្យ។ ជនល្មើសប៉ងបំផ្លាញសង្គមរបស់សត្រូវដោយសម្លាប់ប្រជាជនក្នុងប្រទេសជំនួសទៅវិញ។

ការបំបាត់វប្បធម៌អោយសាបសូន្យចាប់ផ្តើមឡើងដោយការបញ្ចុះតម្លៃ ឬការបំបាត់ដានសកម្មភាពប្រចាំថ្ងៃ និងទំនាក់ទំនងផ្ទាល់ខ្លួន ដូចជា វិជ្ជាអប់រំ កាតព្វកិច្ចពលរដ្ឋ ឬសាសនា។ កសិករជនជាតិបូស្សនាមួយរូបដែលបានចូលរួមនៅក្នុងកម្មវិធីរបស់យើងបានរៀបរាប់ការវាយប្រហាររបស់ជនជាតិស៊ែប៊ទៅលើភូមិរបស់គាត់ នៅក្នុងសង្គ្រាមពេលថ្មីៗ នេះ ៖

ពួកយើងភាគច្រើនរត់ទៅរកទីជ្រកកោនដើម្បីការពារខ្លួនយើងពីជនជាតិ ឆិតនិច Chenik [ស៊ែប៊] ដែលជាអ្នកបំផ្លាញសត្វគោ និងដីស្រែរបស់យើង។ ខ្ញុំនាំក្រុមគ្រួសាររបស់ខ្ញុំទៅជ្រកទីសុវត្ថិភាព ស្រាប់តែមួយរំពេចមានអ្វីមកប្រាប់ខ្ញុំ។ ខ្ញុំក៏ប្រាប់ប្រពន្ធខ្ញុំថា ខ្ញុំត្រឡប់ទៅវិញដើម្បីរកមើលតើមានអ្វីនៅសល់ ឬទេ...ពួកឆិតនិចកំពុងតែដុតកំទេចអ្វីៗ ទាំងអស់ ហើយសត្វគោក៏ត្រូវពួកវាដុតទាំងរស់នៅក្នុងក្រោល។

កសិករ ជនជាតិបូស្សនា ស្រលាញ់ដីស្រែ ស្រុកភូមិជាអារម្មណ៍រីករាយដោយគេបានទទួលតំណែងប្រវត្តិសាស្ត្រ តគ្នាពីជីដូន ជីតារបស់គេនៅក្នុងទីតាំងតូចមួយនេះ។ ការបំផ្លាញដីស្រែ និងសត្វគោបានរំលាយ

ចោលដំណើរជីវិតរបស់គាត់ និងចាប់ពីពេលនោះមកគាត់បានបាត់បង់អត្តសញ្ញាណរបស់គាត់ ។ ច្រើនឆ្នាំក្រោយមកគាត់នៅតែភ្ញាក់ពីដំណេកបែកញើសជោគខ្លួន ដោយគាត់យល់សុបិន្តឃើញសម្រែកសត្វគោស្រែកទ្រហោរ ដោយគេដុតទាំងរស់នៅក្នុងភ្លើងកំពុងតែឆេះសន្ធោសន្ធៅ។

## ២. អំពើព្រៃផ្សៃនាពវរំលោភផ្លូវភេទ

នៅក្នុងចុងឆ្នាំ១៩៨០ អ្នកប្រកបការងាររបស់ខ្ញុំ និងរូបខ្ញុំបានធ្វើការស្រង់មតិទូទៅពិភពលោកទៅលើមន្ទីរពេទ្យចំនួនជាង៩០នាក់ ដែលពិនិត្យអ្នកជម្ងឺរួចផុតពីសេចក្តីស្លាប់ដោយទារុណកម្មឃោរឃៅ បានបង្ហាញថា អំពើរំលោភផ្លូវភេទ និងអំពើបំពានផ្លូវភេទផ្សេងៗ ជាវិធីចំបងគេក្នុងការធ្វើទារុណកម្មដល់ស្ត្រីភេទ ស្ទើរតែគ្រប់ភូមិសាស្ត្រនយោបាយទាំងអស់។ ការរកឃើញនេះ និងការរកឃើញដ៏តក់ស្លុតឯទៀត របស់អ្នកចិត្តសាស្ត្រក្នុងតំបន់ បាល់កាន ឃើញថា ទ័ពទាហ៊ាន និងទ័ពជំនួយទាហ៊ាននៅតំបន់ក្រអូឡា Croatia និងបូស្សនា Bosnia បានចាប់រំលោភអ្នកភូមិច្រើននាក់ជារឿយៗ រួមទាំងកូនក្មេងទៀតផង ដែលទីបញ្ចប់ធ្វើអោយអង្គការសហប្រជាជាតិប្រកាសថាអំពើរំលោភផ្លូវភេទ ពុំមែនគ្រាន់តែជាសកម្មភាពព្រៃផ្សៃនោះទេ តែវាជាឧបករណ៍ទាក់ទាញនយោបាយបំបាត់ពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ដំណើរការបំបាត់វប្បធម៌ដែលមានប្រសិទ្ធភាពជាងគេបំផុត ពុំមែនតាមរយៈអំពើបំផ្លាញរាង្គកាយទេ តែតាមរយៈបំពានផ្លូវភេទ។ អំពើព្រៃផ្សៃនេះជាមូលដ្ឋានកែប្រែទំនាក់ទំនងសង្គមគ្រប់ជាន់ថ្នាក់នៅក្នុងសហគមន៍គ្រប់វង្សត្រកូលទាំងអស់។ នៅក្នុងសង្គ្រាមប្រជារាស្ត្រនៅប្រទេស រ៉្វាន់ដា Rowanda ស្ត្រីជនជាតិ រ៉ូស៊ីជាច្រើននាក់ត្រូវគេចាប់រំលោភផ្លូវភេទ ឬបំពានផ្លូវភេទដោយជនល្មើស ហ៊ូទូ Hutu។ ក្នុងស្ថានភាពដែលមានអំពើរំលោភផ្លូវភេទច្រើនលើសលប់-ដូចជាពួកចោរសមុទ្រថៃចាប់រំលោភផ្លូវភេទស្ត្រីវៀតណាមនៅសមុទ្រថៃ ស្ត្រីខ្មែរនៅជុំរុំជនភៀសខ្លួន ស្ត្រីអាហ្វ្រិកនៅតំបន់ទន្លេធំ Great Lake នៅប្រទេសស៊ូដាន Sudan ឆីលី Chile និងក្វ៉ាតេម៉ាឡា Guatemela និងការឃោសនាបំបាត់ពូជសាសន៍បូស្សនា Bosnia លទ្ធផល គឺមានរួមទៅដោយពុំត្រឹមតែការឆ្លងរាលដាលរោគអេចអាយវី HIV/AIDS អេដស៍ និងទារកដែលគេពុំចង់បាននោះទេ តែការបដិសេធពុំទទួលស្គាល់ដ៏ខ្លាំងក្លាដោយក្រុមគ្រួសារ និងសហគមន៍ទៅលើស្ត្រីទាំងនោះ។

សុភាសិតវៀតណាមបានសង្ខេបដោយខ្លី ពីភាពពិតក្នុងសង្គមថ្មី ទៅលើស្ត្រីដែលទទួលអំពើរំលោភផ្លូវភេទទូទាំងពិភពលោក៖ "ចានស្អាតហើយបើមានគេទទួលទានពីចាននោះ វាបន្សល់ទុកនូវភាពកខ្វក់"។ ជនល្មើស សម័យបច្ចុប្បន្ន ដឹងថាជនរងគ្រោះប្រើពេលពេញមួយជីវិត ដើម្បីបំភ្លេចលាងសំអាតសេចក្តីបំផ្លាញភាពបរិសុទ្ធដោយអំពើរំលោភផ្លូវភេទដែលកើតមានឡើងតែមួយដង ហើយគូរស្រករ និងសហគមន៍ នឹងពុំទទួលស្គាល់នាងដូចដើមវិញឡើង ទាំងនេះបានបន្សល់ទុក្ខសោក ដែលពុំអាចបំភ្លេចបានដល់ជនគ្រប់រូបដែលទទួលរងគ្រោះ និងជនដែលចូលរួមដឹងឮ នូវទង្វើទាំងនេះ។

នៅតំបន់ដាហ្វ៉រ Darfur នៅប្រទេស ស៊ូដាន Sudan អំពើរំលោភផ្លូវភេទបានធ្វើឡើងយ៉ាងលើសលប់ជាទង្វើទារុណកម្មលើទារកដ៏ច្រើននាក់ ដែលបានកើតឡើងដោយអំពើចាប់រំលោភផ្លូវភេទរបស់ទ័ពទាហ៊ានអារ៉ាប់ Arab ទៅលើស្ត្រី និងក្មេងស្រីជាច្រើននាក់ ទ័ពនោះត្រូវគេអោយឈ្មោះថា *ជេនចាវីត Janjaweed* មានន័យថា "បិសាចលើខ្នងសេះ" សេចក្តីសង្ឃឹមទៅលើអនាគតរបស់ក្មេងទាំងនេះ និងម្តាយរបស់គេ នៅក្នុងទំនៀមទម្លាប់សង្គម គឺមានតែភាពក្រៀមក្រំ ។ មេភូមិជនជាតិអារ៉ាប់ម្នាក់ថ្លែងអំពីទារកម្នាក់ដែលមានអាយុទើបតែពីរទៅបីថ្ងៃថា៖ "យើងនឹងថែទាំនាងចាត់ទុក ដូចជាកូនរបស់យើង តែយើង នឹងតាមមើលនាងដោយប្រុងប្រយ័ត្ននៅពេលដែលនាងធំដឹងក្តីឡើង ដើម្បីមើលថាតើនាងប្រកាន់អាកប្បកិរិយា ដូចជា *ជេនចាវីត* ឬមួយយ៉ាងណា។ បើសិនជានាងប្រកាន់អាកប្បកិរិយាដូចជា *ជេនចាវីត* នាងពុំអាចរស់នៅក្នុងចំណោមពួកយើងបានឡើយ"។

## ៣. ការបំផ្លាញភាពពិតសាមញ្ញ

បំណងមួយទៀតរបស់ជនល្មើស ក្នុងការធ្វើអោយរបួសដល់ចិត្តសាស្ត្រ គឺបង្កើតអោយមានការបាត់បង់ជំនឿទូទៅ នៃភាពពិតក្នុងដំណើរជីវិត។ នៅក្នុងពេលវាយឈ្លានពាន ប្រទេសស្សា រ៉ាយ៉េវ៉ូ គ្រូបង្រៀនថ្នាក់ មត្តេយ្យដ្ឋាន ស្សឺបៀន ត្រូវគេនាំទៅលើភ្នំអោយធ្វើទៅជាខ្មាំងបាញ់ផ្តក់ បាញ់សម្លាប់អតីតសិស្សម៉ូស្លីម និងសិស្សបូស្សនារបស់ខ្លួន ។ ស្ត្រីមានផ្ទៃពោះ និងកូនក្មេងតូចៗ និងជនចាស់ជរា ក្លាយទៅជាសត្រូវចំបងរបស់ខ្មាំងបាញ់ផ្តក់។ នេះជាអំពើអស្ចារ្យមិនគួរជឿ សកម្មភាពសង្គមបែបនេះក្លាយទៅជាព្រឹត្តិការណ៍ធម្មតា សូម្បីតែប្រជាពលរដ្ឋ នៅស្សារ៉ាយ៉េវ៉ូក៏មិនជឿដែរថា សោកនាដកម្មនេះពិតជាកំពុងតែកើតមានឡើងមែននោះ។

ក្មេងកំព្រាប្រុសម្នាក់អាយុ១០ឆ្នាំ ដែលរស់មានជីវិតរួចផុតពីអំពើសម្លាប់រង្គាលដោយពួក ហ៊ូទូ នៅរ៉ូវ៉ាន់ដាបានពណ៌នាអំពីភាពពិតនៅក្នុងសង្គមថ្មី ដែលខ្លួនវាបានទទួលបទពិសោធន៍ទាំងបង្ខំ៖

☞ ក្រោយពីវាដុតកំទេចផ្ទះខ្ញុំ ខ្ញុំរត់លួចពួន ខ្ញុំឃើញវា ខ្ញុំមើលឃើញអ្វីៗ គ្រប់យ៉ាងទាំងអស់ វាបាញ់ម្តាយខ្ញុំ ហើយវាអារកាត់ដៃគាត់ និងកណ្តៀវ វាសម្លាប់គាត់ និងអ្នកឯទៀត វាប្រាប់អោយកូនក្មេងហុតឈាមទាំងនោះ ហើយវាសម្លាប់កូនក្មេងនោះចោលទៀតផង។

ក្មេងនេះបាត់បង់ផ្ទះ និងម្តាយរបស់ខ្លួន ហើយត្រូវបង្ខំអោយបោះបង់វិញ្ញាណ សុភាវធម៌ជាមនុស្សលោកដោយឃើញហេតុការណ៍អំពើដ៏ព្រៃផ្សៃនេះ។ អំពើសាហាវយង់ឃ្នងបង្កើតពិភពប្លែកខុសពីធម្មតាដល់អ្នកដែលរស់រួចផុតពីសេចក្តីស្លាប់ ហើយអ្នកទាំងនោះពុំអាចបកស្រាយភាពពិតបានឡើយ។ ជនល្មើសប៉ង់រុញច្រានជនរងគ្រោះទៅទីកន្លែងដែលតម្លៃ និងលក្ខណៈសម្បត្តិនៃ "ភាពធម្មតា" ត្រូវបំផ្លាញខ្ទេចខ្ទី។ យើងទទួលស្គាល់ជំនឿដែលផ្តល់អត្ថន័យ អំពីបណ្តាញដ៏ស្មុគស្មាញនៃជីវិត បានត្រូវរំលាយចោលហើយយកច្បាប់ថ្មី ភាសាថ្មីមកដាក់ជំនួសវិញ។ ជនរងគ្រោះដោយភាពតក់ស្លុតខ្លះបានប្រឆាំងវាយតបដោយកម្លាំងផ្ទាល់ខ្លួន និង /ឬជំនឿសាសនា ហើយក៏ពុំចុះចាញ់ ទៅតាមប្រព័ន្ធជំនឿរបស់ជនល្មើសដែរ ។ អ្នកទាំងនោះមានលទ្ធភាព រក្សាទស្សនៈរបស់ខ្លួនអោយនៅដដែល ហើយថែមទាំងអាច តតាំងជាមួយ នឹងពិភពដ៏អាក្រក់របស់ជនល្មើសបានទៀតផង។ អ្នកដែល

រស់រួចផុតពីសេចក្តីស្លាប់ជាច្រើននាក់ បានផ្តោតអារម្មណ៍ទៅលើការជួយអ្នកឯទៀតដែលអភ័ព្វជាងខ្លួន។ ជាភ័ព្វសំណាងអាក្រក់ដែលជនរងគ្រោះផ្សេងទៀតឃើញពិភពរបស់ខ្លួនដួលរលំ ហើយគេក៏ជឿថាជំនឿនៅក្នុងអតីតជីវិតរបស់គេ គឺជាការបង្កើតភាពក្លែងក្លាយដោយគ្មានតម្លៃ ពុំមាននរណាម្នាក់បានរៀបចំខ្លួនដើម្បីទទួលអត្ថន័យខ្វេចខ្វីនេះឡើយ។

## ផ្នែក ១. ចរិយាល្ងង់ខ្លៅ

អ្នកដែលរស់រួចផុតពីសេចក្តីស្លាប់ជាច្រើននាក់ បានរងគ្រោះដោយអារម្មណ៍បែងចែករបស់ខ្លួន-អ្នកចិត្តសាស្ត្រហ្វ្រូឌៀន Freudians ចាត់អ្នកទាំងនេះជា "ចរឹកបែងចែក"។ សតិគំនិតប្រឹងរក្សាសុភាវធម៌ដោយចែកចេញជាពីរចំណែក មួយចំណែកគាំទ្រជំនឿដែលខ្លួនបានជឿពីមុនមក ហើយមួយចំណែកទៀតបែរទៅតាមភាពកលិយុគ និងភាពអវិជ្ជា នៃអំពើរលោយអោយសាបសូន្យ។ ជនរងគ្រោះឈឺចាប់ក្រៃលែងក្នុងការតស៊ូប្រឹងរស់រួចផុតពីសេចក្តីស្លាប់ ដោយរក្សាជាប់នូវគំនិតទាំងពីរនេះ គំនិត "សង្ឃឹម" ព្យាយាមជៀសកុំអោយវាលប់បំបាត់ដោយគំនិត "អស់សង្ឃឹម" សេចក្តីតស៊ូនេះនៅតែមានបន្តជាច្រើនឆ្នាំបន្ទាប់ពីភាពតក់ស្លុតបានស្ងប់បាត់ទៅ។

ផាង Phang ជាបុរសខ្មែរម្នាក់ គេហៅគាត់ថាខ្មែរក្រហម ដោយគាត់កើតនៅប្រទេសវៀតណាម គាត់បានតស៊ូជំនះ និងគំនិតបែងចែក ចំនួន១០ឆ្នាំ បន្ទាប់ពីគាត់ចាកចេញពី ប្រទេស វៀតណាម មកកាន់សហរដ្ឋអាមេរិក។ ក្នុងនាមជាប្រជារាស្ត្រវៀតណាម ផាងត្រូវគេបង្ខំអោយជីករណ្តៅ ដែលពោរពេញទៅដោយចម្លឹងដែកស្រួច នៅតាមព្រំដែនវៀតណាម -ខ្មែរ ។ ជនជាតិខ្មែរដែលធ្វើដំណើរទៅមកភាគច្រើននៅភូមិរបស់គាត់ ត្រូវអាជ្ញាធរវៀតណាម ចាត់ទុកថាជាអ្នកស៊ើបការសម្ងាត់ អោយរដ្ឋាភិបាលខ្មែរ ដែលជាសត្រូវ។ ពីមួយឆ្នាំទៅមួយឆ្នាំគាត់ឃើញមិត្តភក្តិរបស់គាត់ ធ្លាក់ទៅក្នុងរណ្តៅដោយគ្មានទោស ហើយជង់ និងចម្លឹងដែកស្រួចនោះ។

ទោះជាស្អប់ចៅហ្វាយនាយវៀតណាមរបស់គាត់ យ៉ាងណាក៏ដោយ តែគាត់ត្រូវតែទោរទន់ទៅតាមសុឆន្ទៈរបស់វា ពុំដូច្នេះទេវា នឹងធ្វើទារុណកម្មដល់រូបគាត់។ ក្នុងនាមជាប្រជារាស្ត្រប្រទេសវៀតណាមគេតម្រូវអោយគាត់ការពារប្រទេសរបស់គាត់ ក្នុងនាមជាជនជាតិខ្មែរគាត់បំផ្លាញជនជាតិខ្លួនឯង។ ផាងផ្ទុកសេចក្តីប្រឆាំងរវាងអត្តសញ្ញាណរហូតមកដល់សហរដ្ឋអាមេរិក ជាទីកន្លែងដែលគាត់អាចរស់នៅដោយពុំជ្រកកោននៅក្នុងសង្គមជនភៀសខ្លួនវៀតណាម ឬខ្មែរឡើយ។ គាត់បានឃ្លាតចេញពីកូនរបស់គាត់ដែលមានមិត្តភក្តិសុទ្ធតែជនជាតិវៀតណាម ភាពលំបាកនៃជំនឿរបស់គាត់ឈានដល់កម្រិតទីបំផុត នៅពេលដែលគាត់អោយកូនគាត់អាយុប្រាំឆ្នាំទៅលេងបងប្អូននៅប្រទេសវៀតណាមតែម្នាក់ឯង។

កូនប្រុសតូចយំអង្វរសុំអត់ទៅ តែឪពុករបស់វានៅតែបង្ខំអោយវាធ្វើដំណើរទៅទៀត។ បន្ទាប់ពីទៅដល់វៀតណាមបាន ចំនួនពីរអាទិត្យ ក្មេងប្រុសនោះស្លាប់យ៉ាងខ្លោចផ្សារដោយគ្រុនឈាម ហើយសពវាក៏បញ្ចុះនៅទីនោះទៅ។ ឪពុកស្លុតដួលទៅដោយទុក្ខសោក។ ប្រទេសវៀតណាមបានឆក់យកសេចក្តីស្រលាញ់បំផុតរបស់គាត់យ៉ាងព្រៃផ្សៃ ដោយមកពីសតិអារម្មណ៍របស់គាត់ជាប់វិលវល់ទៅដោយគំនិតបែងចែកនេះ។ គាត់មានអារម្មណ៍

ថាទារុណកម្មបានតាមកំចាត់រូបគាត់រហូតដល់សហរដ្ឋអាមេរិកទៀត។ ជនល្មើសរង់ចាំឱកាសបង្កើតភាពទន់ខ្សោយទៅលើជនរងគ្រោះ ដើម្បីបញ្ចូលពិភពទស្សនៈរបស់វាទៅក្នុងខួរក្បាលអ្នកដែលគ្មានជំនឿ។ ដំណើរការនេះបន្សល់ទុកនូវស្នាមប្រឡាក់អារម្មណ៍ថា ជនរងគ្រោះគួរតែទទួលទារុណកម្ម ដោយគេបានចូលរួមចំណែក និងភាពពុំស្អាតស្អំ ដូច្នេះ គេត្រូវតែលាងជម្រះអោយស្អាត ហើយខ្លួនគេអាចជាឧបសគ្គនៅក្នុងការបង្កើតពិភពលោកអោយប្រសើរឡើង។

វាហាក់បីដូចជាមានភាពធម្មតានៅក្នុងមជ្ឈដ្ឋានទាំងនេះ ដោយប្រើទំនាក់ទំនង ដើម្បីបង្កើតអត្ថិភាព និងអត្ថន័យភាសាថ្មី ដោយបំផ្លាញកលល្បិច និងភាពប្រហាក់ប្រហែលគ្នា នៃទំនាក់ទំនងទូទៅ ។ ភាសាក្លាយទៅជាផ្ទាំងសិលាដាក់ផ្តួបគ្នា និងបែបបទសាសនា ដែលកើតឡើងម្តងហើយម្តងទៀត នៅគ្រប់កម្រិតអំពើយង់ឃ្នងដោយបញ្ចេញសារបណ្តាំថា៖ "ឯងគ្មានអ្វីសោះ ឯងគ្មានប្រយោជន៍"។

អ្នកជម្ងឺជនជាតិខ្មែររបស់យើង និងអ្នករួមការងារបានទទួលបទពិសោធន៍ថា ភាសាបាត់បង់អត្ថន័យជាទូទៅ។ មនុស្សជាច្រើនបានបង្កើតអាកប្បកិរិយា "ល្ងង់ខ្លៅ" ឬ "ទីងមោង"។ នៅក្នុងរបបខ្មែរក្រហម គេបានដកខ្លួនដើម្បីធ្វើជា "មិនឃើញអ្វីទាំងអស់ ឬឮអ្វី និងនិយាយអ្វីទាំងអស់។ គេប្រកាន់អាកប្បកិរិយា ដូចជារូបសំណាក់ឈើ គ្មានប្រតិកម្មទៅលើអ្វីៗ ដែលបានកើតឡើងនៅជុំវិញខ្លួនរបស់គេ"។

ថាងThang ជាឈ្លើសសង្គ្រាមវៀតណាម ត្រូវគេឃុំទុក នៅក្នុងគុកអប់រំខ្មែរក្រហម ចំនួន១០ឆ្នាំ នៅក្នុងកំឡុងពេលដ៏លំបាកមួយគាត់ត្រូវគេដាក់ខ្នោះជើងទាំងសងខាង ក្នុងបន្ទប់ងងឹតតូចមួយ ចំនួន៣ខែ តែគាត់ពុំដែលបញ្ចេញអារម្មណ៍អ្វីទេ។ គាត់បាននិយាយថា "ខ្ញុំទុកមាត់ខ្ញុំអោយស្ងៀមជានិច្ច" "ខ្ញុំធ្វើពើថាខ្ញុំរស់នៅពោរពេញទៅដោយជីវិតដ៏ស្រស់បំព្រង" គាត់ពុំដែលមានប្រតិកម្មទៅលើអំពើឃោរឃៅ និងទារុណកម្មព្រៃផ្សៃដែលគេបានធ្វើមកលើរូបគាត់ទេ ដោយគាត់ដឹងថា បើសិនជាគាត់បញ្ចេញសញ្ញាខឹងសម្បារណាមួយគេ នឹងការប្រហារជីវិតគាត់។ ថាងពុំបណ្តោយអោយខ្លួនគាត់អោយអស់សង្ឃឹមឡើយ នៅក្នុងអារម្មណ៍របស់គាត់ គាត់បានបកស្រាយបទពិសោធន៍របស់គាត់ អោយទៅជាអ្វីដែលគាត់ដឹង អ្វីដែលគាត់អាចបង្ក្រាបបាន។
ឧទាហរណ៍ នៅពេលដែលសត្វមូសរោមខាំ និងសត្វជន្លេនវារពេញខ្លួនគាត់នៅក្នុងបន្ទប់ងងឹត គាត់ស្រម៉ៃទុកថាសកម្មភាពទាំងនេះ ជាការវាយប្រហាររបស់ សត្រូវដោយកប៉ាល់ហោះកន្ទុមរុយ និងរថក្រោះ តែដោយគាត់មានកងទ័ពអ្នកជាប់គុក គាត់អាចទប់ទល់ នឹងការវាយប្រហារនោះបាន។

គាត់បានរស់រួចផុតពីសេចក្តីស្លាប់ដោយគាត់ធ្វើជា "អ្នកធ្វើពើ" ។ គាត់ថែមទាំងស្រមើលស្រម៉ៃថា ស្មៅដែលព័ទ្ធជុំវិញគុក គឺជាវល្លិផ្កាកុឡាបដ៏ស្រស់បំព្រង។

នៅពេលដែលមជ្ឈដ្ឋានសង្គមមានអំពើសង្កត់សង្កិន មនុស្សលោកផ្តាច់អារម្មណ៍របស់គេចេញពីកាយហើយធ្វើខ្លួនទៅជា "អ្នកធ្វើពើ" ។ អំពើឃោរឃៅបង្អាក់ទស្សនៈរបស់ជនមានទុក្ខសោកសង្រេងធ្វើអោយវាក្រឡាប់ចាក់។ ដោយហេតុនេះការនិទានពីរឿងតក់ស្លុតមានភាពលំបាកខ្លាំណាស់ ដោយមូលដ្ឋានភាពពិតពោរពេញទៅដោយឧបសគ្គ។

ជនទទួលភាពតក់ស្លុតមានអារម្មណ៍ថា តាមរយៈអំពើឃោរឃៅខ្លួនគេ គឺជាអ្នកទទួលការបង្ក្រាបដោយភាពពិតដោយមនុស្សម្នាក់ទៀត ហើយគ្មានផ្លូវត្រឡប់ទៅពិភពដែលគេស្គាល់នោះវិញឡើយ។ នៅពេលដែលគេសុំចាកចេញពីភាពយល់សុបិន្តនេះ ជនល្មើសបាននិយាយថា "អ្នកពុំអាចទៅបានឡើយ ខ្ញុំធ្វើបាបអ្នកបែបនេះដើម្បីជាផលល្អសម្រាប់រូបអ្នក" ក៏ដូចគ្នានៅក្នុងកម្រិតសង្គម រដ្ឋាភិបាល នឹងបដិសេធថាពុំមានអំពើឃោរឃៅកើតមានឡើង។ ជនល្មើសប៉ងព្យាយាមអោយអ្នកនិទានរឿងតក់ស្លុតមានសេចក្តីសង្ស័យ ទៅលើសុខដុមរម្យនារបស់ខ្លួន ដោយហេតុនេះ អ្នករស់រួចផុតពីសេចក្តីស្លាប់ទៅជាសង្ស័យទៅលើសមត្ថភាពរបស់អ្នកស្តាប់ក្នុងការជឿទៅលើបទពិសោធន៍ពិតរបស់ខ្លួនជាជនរងគ្រោះ។

ការបំបាត់វប្បធម៌ អោយសាបសូន្យកើតឡើងជាទូទៅ នៅក្នុងជីវិតដែលបានជួបប្រទះ នឹងអំពើឃោរឃៅធម្មតា។ ឧទាហរណ៍អំពើហឹង្សានៅក្នុងក្រុមគ្រួសារ និងប្តីប្រពន្ធ ជនល្មើសធ្វើអោយរបួសដោយចេតនា តែច្រើនតែបដិសេធ។ អាចមានរួមទៅដោយការបំផ្លាញផ្ទះសម្បែង មជ្ឈដ្ឋាន ការខាតបង់ប្រាក់កាក់ និងសុខុមាលភាពរបស់សមាជិកគ្រួសារ និងភាពបន្ថោកតម្លៃផ្លូវភេទ និងជាតិសាសន៍។ អាកប្បកិរិយារបស់ជនប្រព្រឹត្តិអំពើហឹង្សាក្លាយទៅជាអាក្រក់ ឬខុស។ ជាទូទៅនៅក្នុងស្ថានភាពហឹង្សា ជនរងគ្រោះបានសួរខ្លួនឯងពីភាពពិត ដូចជាជនជាតិខ្មែររស់រួចផុតពីសេចក្តីស្លាប់ គេបានធ្វើខ្លួនគេអោយទៅជារូបសំណាក់ ឬរបាំងរឹងដើម្បីធ្វើអោយអារម្មណ៍គេប្រឈមមុខ នឹងអ្វីៗ ដែលកើតឡើងដល់រូបគេ។ ជនជាតិអាហ្វ្រិកប្រើកលល្បិចនៅក្នុងករណីទាសភាព នៅជំនាន់ជីម ក្រូ Jim Crow ស្ត្រីជាច្រើនរូប និងកូនក្មេងបានតស៊ូ នឹងអំពើហឹង្សានៅក្នុងក្រុមគ្រួសារដោយវិធីដូចគ្នាដែរ។ ជនរងគ្រោះពុំហ៊ាននិយាយប្រាប់ឪពុកម្តាយ មិត្តភក្តិ ឬអ្នកជិតខាងរបស់ខ្លួនគេបានទទួលអំពើហឹង្សា។ ដោយភាពពុំរ៉ែ និងកម្រិតអំពើហឹង្សាប្រចាំថ្ងៃទាំងនេះ វាជាការលំបាកសម្រាប់សង្គមក្នុងការដឹងឮអំពីគោលដៅពិតរបស់ជនល្មើស។

អ្នកជម្ងឺម្នាក់ បានមកដល់បន្ទប់ស្នាក់នៅបណ្តោះអាសន្នដែលជាទីកន្លែងខ្ញុំធ្វើការ នាងត្រូវប្តីធ្វើបាបបង្ខំអោយប្រព្រឹត្តអំពើសេពកាមអាក្រក់ហួសនិស្ស័យ។ ក្រោយពីបានស្តាប់រឿងទុក្ខសោករបស់នាង ខ្ញុំបានប្រាប់នាងថាត្រូវរាយការណ៍អោយប៉ូលីសចាប់ប្តីនាង នាងបានបដិសេធ នាងមានអារម្មណ៍អាណិតអាសូរប្តី ហើយនិយាយថានាងស្រលាញ់ប្តី។

នៅក្នុងបន្ទប់បណ្តោះអាសន្ន នាងបិតនៅស្ថានភាពរត់ចាកចេញពីអំពើឃោរឃៅរបស់ប្តីមួយរយៈពេលខ្លី ហើយនាងកំពុងតែរន្ធត់ និងភ័យខ្លាចទៅលើស្ថានភាពរបស់នាង។ តែនាងចាប់ផ្តើមបន្តិចម្តងៗ មិនទុកចិត្តទៅលើការប្រមាណមើលនេះ ហើយនៅចុងបញ្ចប់ នៃការប្រជុំនៅមន្ទីរពេទ្យនាងបានបដិសេធថានាងពុំត្រូវការជំនួយទេ។ នាងចាប់ផ្តើមទទួលស្គាល់ភាពពិតរបស់ប្តីនាង មានន័យថាអំពើហឹង្សាលើផ្លូវភេទជាទិដ្ឋភាពធម្មតានៃសេចក្តីស្រលាញ់របស់ប្តីនាងចំពោះរូបនាង នាងបានទទួលស្គាល់ទស្សនៈរបស់ប្តីនាងទៅលើភាពជាប្តីប្រពន្ធ៖ "ខ្ញុំធ្វើបាបតែអ្នក ព្រោះខ្ញុំស្រលាញ់អ្នក"។

## ១.២ ភាពអាម៉ាស់មុខ អារម្មណ៍សោកសង្វេគនៃអំពើឃោរឃៅ

គោលបំណងនៃអំពើឃោរឃៅដោយពុំគិតពីកម្រិតសកម្មភាព វាមានកម្រិតដូចគ្នា គឺបង្កើតនូវសភាពអារម្មណ៍សោកសង្វេគ នៃអំពើឃោរឃៅ។ នៅក្នុងហេតុការណ៍កើតឡើងជារៀងរាល់ថ្ងៃ ភាពអាម៉ាស់មុខបន្តិចបន្តួចជាភាពធម្មតា។ ឧទាហរណ៍ ប្ដីនិយាយថា "អ្នកធ្វើអោយខ្ញុំអាម៉ាស់មុខនៅចំពោះមុខភ្ញៀវរបស់យើង" បានន័យថាប្រពន្ធបានធ្វើអ្វីដែលធ្វើអោយអាម៉ាស់មុខ ឬមិនចេះធ្វើអ្វី ឬនាងព្យាយាមធ្វើអោយប្ដីអន់ ឬល្ងង់ខ្លៅ។ ភាពអាម៉ាស់មុខស្ដួចស្ដើងនេះបង្ហាញថាមានខ្វះខាតអ្វីមួយ ជាទូទៅសេចក្ដីស្រលាញ់ គោរព ឬស្នេហារវាងមនុស្សពីរនាក់។ នៅពេលដែលមនុស្សនិយាយថា "ខ្ញុំធ្វើខ្លួនឯងអោយអាម៉ាស់មុខ" គឺគេនិយាយសំដៅទៅលើការខ្វះសេចក្ដីស្រលាញ់ និងសេចក្ដីគោរពទៅលើខ្លួនគេ។

តែភាពអាម៉ាស់មុខដែលរួមដោយអំពើឃោរឃៅជាសម្ព័ន្ធខុសគ្នា ជនល្មើសព្យាយាមបង្ខក់ស្មារតីជនរងគ្រោះដោយប្រើមូលដ្ឋានគ្មានតម្លៃ។ នៅក្នុងពេលប្រព្រឹត្តអំពើឃោរឃៅ គឺគ្មានភាពស្នេហា ស្រលាញ់ និងអាណិតអាសូរឡើយ។ នៅក្នុងរឿងតក់ស្លុតដោយអំពើឃោរឃៅក្រៃលែង អារម្មណ៍អាម៉ាស់មុខ គឺបង្ហាញឡើងដោយពេញលេញដែលអនុញ្ញាតអោយយើងឃើញ និងចាប់ផ្ដើមយល់ដឹងពីភាពនេះគ្រប់ជ្រុងទាំងអស់។ ភាពអាម៉ាស់មុខជាអារម្មណ៍ដ៏ស្មុគស្មាញរបស់មនុស្សលោកដោយវាទាក់ទងទៅ នឹងអ្វីៗ ដែលមនុស្សជឿជាក់ថាសង្គមជាអ្នកវាយតម្លៃអោយខ្លួនគេ ។ វាពុំច្បាស់លាស់ដូចជា សេចក្ដីភ័យខ្លាចឡើយ តែវាជាសភាពរបស់សត្វលោកដែលរួមដោយលក្ខណៈអារម្មណ៍ និងការបង្ខក់ស្មារតីនៃភាពពុំបរិសុទ្ធ និងភាពអៀនខ្មាស់ វិញ្ញាណគ្មានតម្លៃ កំហុស និងសីលធម៌ស្អប់ខ្ពើមចំពោះអ្នកឯទៀត មានរួមទៅដោយព្រះ និងសត្វលោកឋានៈខ្ពស់។

នៅក្នុងពេលបង្រៀនដែលខ្ញុំផ្ដល់ឡើងដល់ក្រុមជនភៀសខ្លួននៅ រដ្ឋកាលីហ្វ័រនីញ៉ា ខ្ញុំបានជួប នឹងអ្នកដឹកនាំឡាវ ឈ្មោះ ស៊ូវណ្ណា Souvanna។ លោកជាជនដែលបញ្ចេញវោហារ ហើយមានទំនុកចិត្តលើខ្លួនឯងដែលបានមករស់នៅសហរដ្ឋអាមេរិកនៅក្នុងឆ្នាំ១៩៨០។ ស៊ូវណ្ណាអាចបញ្ជាក់នូវ លក្ខណៈធម្មជាតិខ្លី នៃភាពអាម៉ាស់មុខ នៅពេលដែលគាត់និយាយថា៖ "ភាពអាម៉ាស់មុខជាអារម្មណ៍ពុះពារ ដើម្បីរកអត្តសញ្ញាណ តែភាពអាម៉ាស់មុខជាពាក្យល្អ ចំពោះរូបខ្ញុំ ខ្ញុំគិតថាបន្ទាប់ពីជាប់គុក ចំនួនជាង២៧ឆ្នាំ ខ្ញុំនៅតែគិតថាវាជារឿងធំ"។ លោក ស៊ូ វណ្ណា បានបរិយាយដោយលម្អិតនូវព្រឹត្តិការណ៍ដែលជាលក្ខណៈអាម៉ាស់មុខរបស់ខ្លួនគាត់ដោយពួកកុម្មុយនីស្ដជាតិឡាវ។

រហូតទាល់តែពេលខ្ញុំជាប់គុក ខ្ញុំពុំដែលឈរតម្រង់ជួរសុំម្ហូបអាហារឡើយ ខ្ញុំពុំដែលលត់ជង្គង់លន់តួរនរណាម្នាក់ឡើយ ជាពិសេសជនដែលមានវ័យក្មេងជាងខ្ញុំ។ ខ្ញុំពុំដែលសុំទានអ្វីទាំងអស់ នៅពេលដែលគេចាប់ខ្ញុំដាក់គុក ខ្ញុំត្រូវធ្វើអ្វីៗ ទាំងនេះ។ ធ្វើដូច្នេះ ដើម្បីអោយខ្ញុំក្លាយទៅជា ជនសាមញ្ញ ឧបមាថាខ្ញុំជាឧត្ដមសេនីយ វរៈសេនីយត្រី ឬជាស្ដេច។ តើអ្នកអាចគិតប្រដូចអំពីឥទ្ធិពលដែលកើតឡើងដោយសកម្មភាពនេះ ដែលអាចប៉ះពាល់ដល់កិត្តិយសមនុស្សយ៉ាងដូចម្ដេចទេ? ខ្លាំងក្លាណាស់ ពិតជាខ្លាំណាស់។

ទស្សនៈនេះបានបង្ហាញនូវធម្មជាតិ នៃភាពអាម៉ាស់មុខទូទាំងសកលលោក ដោយគ្មានគិតពីឋានៈសង្គម ឬមុខងារនៅក្នុងពិភពលោក ក៏វាមានទូទៅគ្រប់សង្គម ភេទ ពូជពង្ស និងជនជាតិ។ ពេលខ្លះ ភាពអាម៉ាស់មុខធ្វើអោយឈឺចាប់ដោយអំពើអសីលធម៌ និងទម្លាប់ទូទៅ ។ នៅជុំរុំឃុំឃាំងខ្មែរក្រហម ស្ត្រីមានអារម្មណ៍អៀនខ្មាស់ និងពុំបរិសុទ្ធ នៅពេលដែលគេបង្ខំអោយនាងលាងសំអាតកាយនៅទីសាធារណៈ។ អ្នករស់រួចផុតពីសេចក្ដីស្លាប់ទទួលបទពិសោធន៍នេះដោយផ្ទាល់។ ណូរ៉ា Nora អ្នករស់រួចផុតពីសេចក្ដីស្លាប់ជនជាតិឆីលី រៀបរាប់អំពីទារុណកម្មដែលទ័ពពីនូឆេ Pinochet បានធ្វើមកលើរូបនាង វាយកសត្វកណ្ដុររស់រុញចូលជ្រៅទៅក្នុងយោនី (ប្រដាប់ភេទ)របស់នាង។ គ្មានពាក្យអ្វីដែលនាងអាចបកស្រាយអោយសមទៅតាមអារម្មណ៍គ្មានតម្លៃ ដែលកើតឡើងដោយអំពើព្រៃផ្សៃនេះឡើយ។ នៅក្នុងករណីខ្លះ ភាពអាម៉ាស់មុខកើតឡើងដោយអំពើអាប់យស អាប់កេរ្តិ៍ខ្មាស់ ដែលបានធ្វើឡើងដោយប្រជាពលរដ្ឋមួយទៅលើប្រជាពលរដ្ឋមួយទៀត វិទ្យុ ទូរទស្សន៍រ៉ាវ៉ាន់ដាបានឃោសនាបញ្ចុះបញ្ចូលអោយអ្នកស្ដាប់ជនជាតិហ៊ូទូ Hutu "បំពេញរណ្ដៅផ្នូរដែលពុំទាន់ពេញដោយដាក់ខ្មោចសត្វកន្លាតជនជាតិទុតស៊ី Tutsi ធ្វើការប្រៀបធៀបប្រជាពលរដ្ឋជិតខាងទៅ នឹងសត្វល្អិតកខ្វក់"។

ការដឹងថាអារម្មណ៍សាបសូន្យ អាប់យស និងអាម៉ាស់មុខអាចបង្កើតជាបរិស្ថានដែលគ្មានភាពស្រលាញ់ មេត្តា និងមូលដ្ឋាន ទោរទន់អារម្មណ៍ អាចជួយអោយយើងដឹងនៅពេលដែលភាពអាម៉ាស់មុខកំពុងកើតមានឡើង។ នៅពេលដែលអំពើឃោរឃៅ ខ្លាំងកើតមានឡើង ដូចជាទារុណកម្ម អំពើអាម៉ាស់មុខអាចឃើញយ៉ាងច្បាស់ ។ នៅក្នុងស្ថានភាពភេរវកម្មអារម្មណ៍ អាម៉ាស់មុខអាចបិទបាំងដោយអារម្មណ៍សោកសង្វេគខ្លាំង ដូចជាសេចក្ដីភ័យខ្លាច និងរំជួលអារម្មណ៍ ។ អំពើវាយប្រហារឃោរឃៅដោយពួកអាល់ កេដា al-Qaeda ទៅលើសហរដ្ឋអាមេរិក នៅថ្ងៃទី១១ ខែ កញ្ញា ឆ្នាំ២០០១ បានបញ្ចេញដោយច្បាស់នូវភាពអាម៉ាស់មុខដល់សហរដ្ឋអាមេរិកដែលជាគោលបំណងមួយរបស់វា។ ចំពោះក្រុមគ្រួសារជាច្រើនដែលសមាជិកគ្រួសារ បានបាត់បង់ជីវិត នៅក្នុងថ្ងៃនោះ ទីលានលេខសូន្យនៅទីក្រុង នីវយ៉ូក New York ជាតំណាងភាពបំបាត់អោយសាបសូន្យនៃសេចក្ដីស្រលាញ់ និងមេត្តាធម៌របស់មនុស្សលោក។ វាជាទីកន្លែងដែលពោរពេញទៅដោយអារម្មណ៍អាម៉ាស់មុខ ដូចគ្នានឹងអំពើឃោរឃៅទាំងអស់ដែលកើតឡើងដោយ មូលដ្ឋានគោរព និងភាពពេញចិត្តត្រូវបំបាត់ដោយអំពើព្រៃផ្សៃ ហើយអារម្មណ៍អាម៉ាស់មុខអាចដក់ជាប់នៅក្នុងអារម្មណ៍ និងរិតតែមានឥទ្ធិពលឡើង។

ដោយអាចកំបាំងភាពអាម៉ាស់មុខហាក់បីដូចជាងាយស្រួល នឹងបង្កើតឡើង ទោះជាជនរងគ្រោះស្អប់ខ្ពើម ឬបដិសេធគោលបំណង និងតម្លៃរបស់ជនល្មើសក៏ដោយ។ ហេតុអ្វីបានជាមនុស្សលោក ឆាប់ទោរទន់អារម្មណ៍ និងភាពអាម៉ាស់មុខជាករណីពុំច្បាស់លាស់ ទោះបីជាដោយមូលហេតុអ្វីក៏ដោយ ការទោរទន់ទៅលើភាពទន់ជ្រាយ និងអារម្មណ៍ងាយឈឺចាប់ធ្វើអោយកិច្ចការរបស់ជនល្មើសរិតតែមានភាពងាយស្រួលឡើង។

សមត្ថភាពធ្វើអោយអាម៉ាស់មុខមានភាពផ្សេងៗ គ្នានៅក្នុងព្រឹត្តិការណ៍តក់ស្លុត ស្ថានភាពខ្លះ ដូចជាការបង្ខំអោយស្រាត ឬអំពើឃោរឃៅលើប្រដាប់ភេទ អាចធ្វើអោយមានភាពអាម៉ាស់មុខច្រើនជាងបែបផ្សេងៗ ដូចជាការស្រែកជេរដៀលដោយប្រើពាក្យអាសអាភាស។ ភាពអាម៉ាស់មុខច្រើនតែចាប់ផ្ដើមឡើងដោយការអៀនខ្មាស់

ដែលធ្វើឡើងនៅទីសាធារណៈ នៅចំពោះមុខហ្វូងមនុស្ស ឬក្រុមអ្នកស្តាប់មួយ ចំនួនតូច ហើយច្រើនមានប្រសិទ្ធភាពខ្លាំងនៅចំពោះមុខប្តីប្រពន្ធ កូនចៅ ញាតិមិត្ត និងអ្នកជិតខាង។ គ្មាននរណាម្នាក់ចង់ឃើញទិដ្ឋភាពបែបនេះកើតមានឡើងដល់ ជនដែលយើងស្រឡាញ់ និងញាតិមិត្ត ដែលមានចិត្តមេត្តាធម៌ ករុណា ដល់យើងទេ ។ គួរអោយស្តាយណាស់ ទោះបីជាយ៉ាងណាក៏ដោយ យើងច្រើនតែធាប់ទទួលភាពអាម៉ាស់មុខ បើរឿងនោះកើតមានឡើងនៅចំពោះមុខមនុស្សដែលស្គាល់គ្នា។ យើងជឿថាជាទូទៅវាពុំត្រឹមត្រូវ ដែលសមាជិកគ្រួសារ និងមិត្តភក្តិជិតដិតរបស់យើងឃើញភាពធាប់ទោរទន់ ភាពទន់ខ្សោយ និងអារម្មណ៍អាម៉ាស់មុខរបស់យើងជាបែបពុំល្អដែលនឹងបណ្តាលអោយមានការបដិសេធ។

នៅក្នុងស្ថានភាពដ៏អស្ចារ្យមួយ ស្ត្រីជនជាតិអាហ្វ្រិកម្នាក់ ដែលបំរុងទៅជ្រកកោននៅសហរដ្ឋអាមេរិកបានពណ៌នា ពីបទពិសោធន៍របស់នាង នៅពេលដែលមន្ត្រី ប៉ូលីសចូលលុកលុយផ្ទះ និងដកហូតទ្រព្យសម្បត្តិរបស់នាង។ នៅចំពោះមុខប្អូនស្រី និងកូនរបស់នាង គេច្រាននាងដួល ទាញសម្រាតខោអាវហើយចាប់នាងរំលោភផ្លូវភេទ មន្ត្រីប៉ូលីសពីរនាក់ទាញជើងនាងហែក អោយមន្ត្រីប៉ូលីសទីបីរំលោភផ្លូវភេទនាង។ ក្នុងពេលដែលនាងខំរើបំរះនេះវាទាញដៃនាងកាច់ ធ្វើអោយបួសដៃជាអចិន្ត្រៃយ៍។ នៅពេលដែលនិយាយរំលឹករឿងនេះស្ត្រីនេះបារម្ភអំពីកូនរបស់នាង ដែលបានឃើញម្តាយគេចាប់រំលោភផ្លូវភេទដោយផ្ទាល់ភ្នែក ហើយគិតថាតើកូនរបស់នាងអាចនៅតែគោរពម្តាយ ដែលបណ្តោយអោយរឿងនេះកើតឡើងបានដែរនោះទេ? ទំនាក់ទំនងជិតស្និទរវាងជនឈ្លានពាន និងជនរងគ្រោះរិតតែធ្វើអោយជនរងគ្រោះទទួលភាពអាម៉ាស់មុខដោយងាយស្រួល។ ជនល្មើសអាចប្រើជំនាញដាច់អហង្ការ ដើម្បីធ្វើបាបអ្នកឯទៀត ។ គ្រប់ជាតិសាសន៍ ការប្រឆាំងដោយភាពស្និទស្នាលនិងទំនុកចិត្ត ដោយឆ្កឹះឆ្កៀលអ្នកជិតខាងអោយប្រឆាំងគ្នា ធ្វើអោយមានការអោម៉ាស់មុខ ដ៏ខ្លាំងរហូតដល់ទៅពុំអាចសម្រុះសម្រួលគ្នាបានដោយសន្តិវិធី។

## ១.៣ ការវិនាសនៃសេចក្តីចងចាំ

ភាអាម៉ាស់មុខ កើតឡើងជាមាត្រដ្ឋានដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រ នៅជំនាន់រ៉ូម៉ាំង Roman ដំណើរការលប់បំបាត់សេចក្តីចងចាំរបស់មនុស្សគ្រប់ក្នុងសង្គមទាំងអស់មាន ឈ្មោះថា *ការធ្វើអោយវិនាសសេចក្តីចងចាំ* ឬការផ្តន្ទាទោសទៅលើសេចក្តីចងចាំ។ ស្នាដៃសាធារណៈរបស់មនុស្សបានរំលាយអោយសាបសូន្យ ដោយការបំផ្លាញរូបសំណាក់ លាយល័ក្ខអក្សរ និងឯកសារស្រមច្បាប់ ។ ជាលទ្ធផលដែលបញ្ជាក់ថាជននោះពុំមានអត្តិភាព។ ចំពោះញាតិមិត្ត ដែលនៅរស់រានមានជីវិតរបស់ជន ដែលគេលុបបំបាត់ចោលនោះ ទង្វើរទាំងនេះជាទង្វើរអាម៉ាស់មុខ។

*ការធ្វើអោយវិនាសសេចក្តីចងចាំ* បានធ្វើឡើងដល់អធិរាជ ប្រទេសរ៉ូម Rome មន្ត្រីជាន់ខ្ពស់ និងប្រជាពលរដ្ឋ។ នៅសម័យបច្ចុប្បន្ននេះ ដំណើរការដូចគ្នាបានធ្វើឡើងដើម្បី "លុបបំបាត់" ប្រជាជនសាមញ្ញនៅក្នុងពេលប្រឆាំងគ្នា ដោយអំពើឃោរឃៅ ។ ជនរងគ្រោះ រួមមានទាំងកូនក្មេង ត្រូវប៉ូលីស ទ័ពព្រៃ និងក្រុមភេរវកម្ម និងអង្គ

ការឃោរឃៅចាប់ខ្លួនហើយពុំដែលឃើញត្រឡប់មកវិញទេ-សពរបស់គេត្រូវបំផ្លាញចោល ដោយគ្មានទាំងទុកភស្តុតាង ថាអ្នកទាំងនោះត្រូវបានចាប់ឃុំទុក។

ស្រាប់តែអ្នកទាំងនោះពុំឃើញមានវត្តមានទៀត ហើយគ្មាននរណាម្នាក់ ដឹងព័ត៌មានអ្វីអំពីហេតុការណ៍ដែលកើតឡើងដល់អ្នកទាំងនោះឡើយ។ ពាសពេញពិភពលោកផ្នូរខ្មោចរាប់ម៉ឺន ផ្ទុកសពគ្មាន ឈ្មោះរបស់ជនដែលទទួលទារុណកម្មដោយអំពើសម្លាប់ចោល។ ពាក្យបំបាត់ចោលកើតមានឡើងនៅក្នុងអក្ខរាវិរុទ្ធរបស់ប្រជាជនអាចឹនទីណា Argentine និងឈីលី Chilean ដែលបានក្លាយទៅនាមផ្ទាល់ខ្លួន។

ការពង្រាត់ក្រុមគ្រួសារទាសករជនជាតិអាហ្វ្រិក អាមេរិកកាំង និងការបញ្ជូនជនក្រីក្រនៅប្រទេសអូស្ត្រាលី និងសហរដ្ឋអាមេរិកដោយដាក់ចូលទៅក្នុងចំណោមប្រជាជន និងសាលារៀនទូទៅ ហើយ សមជិកគ្រួសារដែលដឹងរឿងអតីតកាលច្រើនតែលាក់ការសម្ងាត់ ទាំងនេះជាវិធីធ្វើអោយសេចក្តីចងចាំវិនាស។ ជនល្មើសយល់ដឹងថាមនុស្សពិតជាពិបាកដោះស្រាយផ្លូវចិត្តទៅលើការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួន។

ការស្តាប់ស្ត្រីមេម៉ាយ នៅប្រទេសស្រេប្រីនីកា Sebrinica ដែលបាត់បង់បុរស ចំនួន ៨ពាន់នាក់ តែក្នុងរយៈពេល២ថ្ងៃ ក្រុមគ្រួសារដែលបាត់បង់ជីវិតនៅក្នុងសោកនាដកម្មថ្ងៃទី១១ ខែ កញ្ញា ឬមួយចំនួនដែលរាប់ពុំអស់របស់ប្រទេសឈីលី Chile ផឺរ៉ូ Peru អាចឹនទីណា Argentina កម្ពុជា បូស្សនា Bosnia និងទីផ្សេងៗទៀត ការប្រៀបប្រដូចសេចក្តីឈឺចាប់ដោយសារការបាត់បង់មនុស្សជាទីស្រលាញ់ពុំអាចទ្រាំបានឡើយ។ រៀងរាល់ថ្ងៃម្តាយនៅទីក្រុងនីវយក ជួបប្រទះ នឹងសេចក្តីឈឺចាប់ ដោយនឹកឃើញជីវិតចុងក្រោយរបស់កូនប្រុសគាត់ដែលឆេះសន្ធោសន្ធៅ នៅក្នុងមហាអគ្គិភ័យក្នុងអគារភ្លោះ។ ម្តាយម្នាក់នៅ ប្រទេសយូហ្គាន់ដា Uganda ខាងជើងខ្លោចផ្សារដោយកូនស្រីទើបតែពេញវ័យរបស់គាត់ត្រូវទ័ពទាហ៊ានចាប់យក។ ការគិតឃើញទាំងនេះក្លាយទៅជាការស្រមើលស្រម៉ៃ និងភ័យខ្លាចគ្មានព្រំដែនពិតប្រាកដ បើសិនជាពុំទប់ស្កាត់ទេ វានឹងលប់បំបាត់អ្វីៗ ផ្សេងទៀតដែលមាននៅក្នុងស្មារតី។

រឿងបាត់បង់ដោយគ្មានគិតពីបរិបទវប្បធម៌ បង្ខំអោយអ្នកស្តាប់ និងអ្នកនិទានរឿងនិយាយទាក់ទងជាមួយ នឹងអ្នកដែលបាត់ខ្លួន។ "អ្នកបាត់ខ្លួន" ត្រូវគេនិយាយស្តីជាមួយហាក់បីដូចជា អ្នកនោះនៅតែមានវត្តមានជារូបរាង ហើយអាចឆ្លើយតបទៅ នឹងអ្វីៗ ដែលគេបាននិយាយ។ ធ្វើអោយកិច្ចការផ្ទាល់ខ្លួនត្រូវទុកចោល ការពិភាក្សាត្រូវទុកចោលដោយគ្មានទីបញ្ចប់ ខុសពីជនដែលស្លាប់បាត់បង់ជីវិតដែលបានទទួលការកាន់ទុក្ខ អ្នកបាត់ខ្លួនហាក់បីដូចជានៅតែមានជីវិតរស់នៅរហូត។

សូមស្រម៉ៃថា ថ្ងៃមួយនៅពេលដែលអ្នកត្រឡប់មកផ្ទះ ហើយដឹងថាកូនប្រុសស្រី ប្តីប្រពន្ធ ឬឪពុកម្តាយរបស់អ្នកបាត់ខ្លួនសូន្យឈឹង ដោយគ្មានថ្ងៃជួបវិញឡើយ។ ខ្ញុំបានឆ្លងកាត់សេចក្តីឈឺចាប់ពន់ពេក នឹងកម្រងរឿងនេះជាមួយ នឹងអ្នកជម្ងឺរបស់ខ្ញុំ ជាច្រើនឆ្នាំមក សារមន្ទីរ នៅប្រទេស រ៉ូម មានតាំងរូបចម្លាក់ ពីរទៅបីរបស់ ហ្គេតា Geta ដែលបានឆ្លងកាត់ការធ្វើអោយសេចក្តីចងចាំវិនាស បន្ទាប់ពីមរណៈភាពរបស់ លោក ហ្គេត ដែលឃុបឃិតឡើងដោយប្អូនប្រុសរបស់ លោក ម៉ា កូស អូរីលីស អន់តូនីស ការ៉ាកាយ៉ា Marcus Aurelius Antonius

Caracalla (សតវត្ស ១៨៨-២១៧) ជាជនដែលចង់ធ្វើអធិរាជតែមួយគត់ក្រោយពីបិតារបស់ លោក សុគតទៅ។ នៅពេលទស្សនារូបចម្លាក់នោះ ខ្ញុំបានគិតរវើរវាយមួយស្របក់ស្រម៉ៃឃើញខ្មោចហ្គេតា មើលឃើញការបំបាត់រូបគាត់អោយសាបសូន្យចេញពីសង្គមរ៉ូម។ តើសេចក្តីឈឺចាប់ នៃការបំបាត់ខ្លួនប្រាណអាចលាតត្រដាងបន្លាយរហូតដល់ទៅពិភពស្លាប់ដែរឬទេ?

ការបាត់បង់ត្រូវរួមបញ្ចូលដោយត្រឹមត្រូវទៅក្នុងដំណើរការភាពជាសះស្បើយ វាពុំអាចធ្វើពុំដឹងឮ ឬបំភ្លេចចោលបានឡើយ។ ទស្សនៈនេះទទួលបញ្ជាក់ដោយរូបថតគួរអោយព្រឺក្បាលនៅក្នុងសៀវភៅ ស្រេប្រីនីកា Srebrenica នៅក្នុងថ្ងៃទី១០ ទៅទី១៩ ខែ កក្កដា ឆ្នាំ១៩៩៥ ទ័ពសើ្បបានសម្លាប់បុរស និងកុមាររាប់ពាន់នាក់ ហើយលាក់សពនៅក្នុងគំនរផ្នូរ។ នៅក្នុងរូបភាពស្បែកជើងម្ខាងប្រឡាក់ដោយភក់ និងឈាមដាក់នៅលើតុកាកបាទក្រហម នៅក្នុងបញ្ជីចំទ្បែកនេះ វាជាសំណល់តែមួយគត់ ដែលសល់ពីសពដែលគេគាស់ចេញពីផ្នូរ។ នៅខាងក្រោមស្បែកជើងមានដាក់ចំណងជើងថា៖

- អ្នកម្តាយ បងប្អូនស្រី អ្នកអាចស្គាល់ស្បែកជើងខ្ញុំទេ៖ តើអ្នកអាចស្គាល់ថាស្បែកជើងនេះជាស្បែកជើងដែលគ្របដណ្តប់ជើងរបស់ប្តី និងឪពុករបស់អ្នកដែលបាត់ខ្លួនឬទេ? ខ្ញុំនៅជាមួយជីតា និងកូនប្រុសទាំងបីរបស់យើង។ យើងគ្មានឈ្មោះទេ អត្តសញ្ញាណរបស់ខ្ញុំផ្ចិតយ៉ាងប្រណិតជាប់ នឹងស្បែកជើងនេះ។ នេះជារូបរាងរបស់ខ្ញុំនៅពេលនេះ អ្នកចាំទេមួយខែមុនសត្រូវបានឈ្លានពានចូលទីក្រុងរបស់យើង យើងជឿជាក់ថាយើងមានសន្តិភាព។ ក្រុមគ្រួសារយើងបានធ្វើដំណើរដោយរីករាយនៅតាមដងផ្លូវធំ នៅក្នុងទីក្រុងរបស់យើង យើងកោតសរសើរឥទ្ធិពល អ្នកធ្វើឧបការគុណអន្តរជាតិរបស់យើង។ នៅក្នុងឱកាសរីករាយនេះ យើងបានឈប់នៅហាងធ្វើស្បែកជើងដែលជាមិត្តរបស់យើង។ គាត់បានទុកស្បែកជើងថ្មីរបស់ខ្ញុំ ចំនួនមួយឆ្នាំ នៅខណៈដែលសង្គ្រាមចាប់ផ្តើមឡើង។ ពេលនោះយើងរីករាយមែនទេ ដោយកូនប្រុសទាំងបីនាក់របស់យើងសាកពាក់ស្បែកជើងថ្មីរបស់ឪពុកវា? គេចង់បានស្បែកជើងនោះ ដោយស្បែកជើងរបស់គេរហែកជិតអស់ទៅហើយ ទ្រនាប់ស្បែកជើងពណ៌ទឹកប្រាក់ និងម្រាមជើងខ្លះៗ បានលេចចេញមក។
- វាជាសេចក្តីរីករាយណាស់នៅពេលដែលគេសាកពាក់ស្បែកជើងនោះពិតមែនទេ? សូមចាំថាខ្ញុំចង់អោយអ្នក និងបងប្អូនស្រីរបស់ខ្ញុំមើលស្បែកជើងនេះដោយយកចិត្តទុកដាក់ ហើយនិយាយថាស្បែកជើងនេះជាស្បែកជើងរបស់គាត់។ ជីតា និងកូនប្រុសទាំងអស់កំពុងរង់ចាំ អ្នកអាចមក ហើយទាមទារ យកសំណល់សេសសល់របស់យើង។ យើងស្រលាញ់អ្នក សូមកុំទុកអោយយើងសាបសូន្យនៅក្នុងផ្នូរគ្មាន ឈ្មោះជាមួយ នឹងអ្នកឯទៀត ដែលពុំមានអ្វីសេសសល់ជាតំណាងរូប ដូចអ្នកឯទៀតដែលមានភ័ព្វសំណាង។

ខ្លឹមសារពាក្យពេចន៍នេះពណ៌នា នូវសេចក្តីត្រូវការរបស់អ្នករស់រានមានជីវិត ដែលចង់អោយអ្នកបាត់ខ្លួននៅតែបន្តវត្តមាននៅក្នុងវិញ្ញាណរបស់ក្រុមគ្រួសារ និងសហគមន៍ជានិច្ច។ នៅក្នុងវប្បធម៌ជាច្រើនការបាត់ខ្លួន

ចាត់ទុកជាព្រលឹង ដែលវិលវល់នៅក្នុងស្រមោលពិភពលោក រវាងអ្នករស់ និងអ្នកស្លាប់ដែលព្យាយាមរកសេចក្ដីស្លាប់ដោយសន្តិវិធីគ្មានទីបញ្ចប់។ ហេតុទាល់តែគេរកឃើញ គេពុំអាចគេចពីទុក្ខកង្វល់ និងសេចក្ដីឈឺចាប់បានឡើយ។ គេក៏ពុំអាចចូលរួមជាមួយ នឹងញាតិមិត្តឯទៀត ដែលបានស្លាប់ ដូចគ្នាក្នុងមូលដ្ឋានសម្រាប់ជីវិតសត្វលោកបានដែរ ។ "សូមកុំទុកអោយយើងនៅក្នុងផ្នូរគ្មានឈ្មោះ" បានបញ្ជាក់នូវសារៈសំខាន់ នៃបុព្វបុរសរបស់អ្នករស់រួចផុតពីសេចក្ដីស្លាប់ និងពាំនាំនូវភាពសុខសាន្តជាអាថ៌កំបាំទៅដល់ជនដែលស្លាប់ ការធ្វើអោយសេចក្ដីចងចាំវិនាស ពុំមែនគ្រាន់តែជាបាតុភូតប្រវត្តិសាស្ត្រទេ ចំពោះមនុស្សជាច្រើននាក់ នេះជាភាពពិតប្រាកដផ្ទាល់ខ្លួន។ ចំពោះអ្នកមានសមាជិកគ្រួសារបាត់ខ្លួន អំពើឃោរឃៅបានបង្កើតនូវភាពបាត់បង់ខ្លាំង ដែលដក់នៅក្នុងសតិអារម្មណ៍របស់អ្នកទាំងនោះ ហេតុដូច្នេះ ជាប្រឆាំង នឹងសមត្ថភាពរបស់មនុស្សក្នុងការតស៊ូដើម្បីរស់។

## ១.៨ ភាពផ្ទុយគ្នាពីរបែបនៃការអាម៉ាស់មុខ

ថ្វីបើហេតុការណ៍អាម៉ាស់មុខបានកើតឡើង ជាទូទៅរបស់ជនតក់ស្លុត ការសិក្សាអំពីឥទ្ធិពលបំផ្លាញស្ទើរតែត្រូវ ផ្នែកចិត្តសាស្ត្រសម័យបំភ្លេចចោលទាំងស្រុង។ មូលហេតុ មួយដែលបាត់បង់សេចក្ដីយកចិត្តទុកដាក់អាចបណ្ដាលមកពីការចាប់ផ្ដើមកើតឡើងដំបូងបានប្ដូរដោយរហ័សទៅជាអារម្មណ៍ខឹង សោកសង្វេគ និងអស់សង្ឃឹម ស៊ូ វណ្ណា ជាអ្នកដឹកនាំឡាវ បានពណ៌នាអំពីអារម្មណ៍របស់ខ្លួននៅក្នុងគុក ៖

> ➢ នៅពេលដែលអ្នក មានអារម្មណ៍អាម៉ាស់មុខ អ្នកអោយតម្លៃខ្លួនទាប ដោយអ្នកមានfaអារម្មណ៍ខ្មាស់គេអ្នកមានអារម្មណ៍ថាកិត្តិយសរបស់អ្នកត្រូវគេដកហូតពីខ្លួនអ្នក ។ ភាពអាម៉ាស់មុខ អាចប្ដូរទៅជាភាពសងសឹក និងភាពសៅហ្មងចិត្ត។ ខ្ញុំនិយាយថាវាទាំងពីរបែបហ្នឹង ហាក់បីដូចជា មាននរណាម្នាក់បានដកយកសេចក្ដីក្លាហ៊ានចេញពីខ្លួនរបស់អ្នក ហើយដាក់អ្វីជំនួសវិញដែលធ្វើអោយខ្លួនអ្នកទៅជាមនុស្សទាប ភ័យខ្លាច និងគ្មានតម្លៃសោះ។
>
> ➢ កាលពីក្មេងខ្ញុំបានទទួលការអប់រំថាមនុស្សលោកមានភាពស្មើគ្នា ហើយខ្ញុំរីករាយ នឹងភាពស្មើគ្នានោះ។ នៅពេលដែលគេនាំខ្លួនអ្នកទៅគេធ្វើអោយអ្នកមានអារម្មណ៍អត់តម្លៃ អ្នកមានអារម្មណ៍ភ័យ គ្មានតម្លៃហើយអ្នកខ្លាច។

ចំនួន ម្ភៃប្រាំពីរ ឆ្នាំ ក្រោយមកភាពអាម៉ាស់មុខរបស់ ស៊ូ វណ្ណា នៅតែមានឥទ្ធិពលជាដដែល នៅពេលដែលស្ថានភាពអាម៉ាស់មុខកើតមានឡើង វាមានឥទ្ធិពល និងវិវឌ្ឍន៍ដោយពុំទាក់ទង នឹងមូលហេតុដើមដែលបង្កើតរឿងនេះឡើង។ ដូចជា ស៊ូ វណ្ណា បានបកស្រាយថាសេចក្ដីទុក្ខព្រួយបង្កើតឡើងដោយភាពអាម៉ាស់មុខដែលកើតមានឡើងតាមភាពខុសគ្នា នៃដំណើររបស់អារម្មណ៍។

អ្នកដែលទទួលភាពអាម៉ាស់មុខ នឹងចង់សងសឹក បើសិនជាអ្នកអាចធ្វើបានហើយមាននរណាម្នាក់ធ្វើអោយអ្នកអាម៉ាស់មុខ អ្នកនោះពុំអាចគេចរួចទេ អ្នក នឹងវាយប្រហារតបវិញ សត្វនឹងខាំហើយនៅក្នុងពេលជាមួយគ្នានោះ ស៊ូ វណ្ណា ក៏បានបកស្រាយអារម្មណ៍តានតឹងរបស់ខ្លួន ៖

អ្នកមានអារម្មណ៍ព្រួយដោយអ្នកជាជនរងគ្រោះ ដោយរូបអ្នកលែងមានភាពដូចអ្នកឯទៀតហើយ អ្នកពុំមែនជាមនុស្សធម្មតាទៀតឡើយ អ្នកជាប្រជាពលរដ្ឋវណ្ណៈតូចតាច ហើយជាការពិតមនុស្សលោកគ្មាននរណាចង់នៅក្នុងសភាពនេះទៀតទេ។

ពេលខ្លះជនតក់ស្លុតយោលចុះឡើងនៅចន្លោះភាពខុសគ្នាទាំងពីរបែបនេះ ជនជាប់គុកដោយសង្គ្រាមប្រទេសវៀតណាម ឈ្មោះ ថាង បានបកស្រាយនូវអារម្មណ៍ដ៏រន្ធត់ ដែលពុះកញ្ជ្រោលក្នុងខ្លួនរបស់គាត់ខ្លោចផ្សារចំនួនជាង ១០ ឆ្នាំ ទៅលើភាពអាប់យសនៅក្នុងគុកអប់រំខ្មែរក្រហម ៖

- នៅពេលដែលយើងប្រឈម នឹងភាពអាម៉ាស់មុខ ហើយមិនសប្បាយចិត្តខ្លាំងណាស់ ហើយយើងក៏ខឹងខ្លាំណាស់ដែរ ពេលខ្លះយើងចង់សម្លាប់ខ្លួនយើង ឬចង់សម្លាប់អ្នកដែលធ្វើអោយយើងអាម៉ាស់មុខ។ មានម្នាក់ត្រូវតែស្លាប់ បើសិនជាអ្នកជាប់គុកពុំអាចរម្ងាប់អារម្មណ៍របស់គេបានទេ គេអាចធ្វើអ្វីភ្លាមៗ ហើយជាលទ្ធផលអ្នកនោះត្រូវល្បាតយាមគុកប្រហារជីវិតចោល។
- តែវាពុំមានជម្រើសទេ នៅពេលដែលយើងចង់សម្លាប់ខ្លួនយើង ឬនៅពេលដែលយើងចង់សម្លាប់អ្នកដែលធ្វើអោយយើងអាម៉ាស់មុខសេចក្តីស្លាប់ជាវិធីតែមួយគត់ដែលជួយរម្ងាប់កំហឹងរបស់យើង។

អ្នកជាប់គុកជាមួយគាត់ជាច្រើននាក់ពុំអាចរម្ងាប់អារម្មណ៍របស់គេបាន ទីបញ្ចប់ត្រូវគេប្រហារជីវិត ថាងក៏រៀបរាប់អំពីជំនឿទៅលើការស្លាប់ នៃអារម្មណ៍របស់មនុស្ស។ គាត់និយាយរឿងទាក់ទងទៅ នឹងអ្នកជាប់គុកជាមួយគ្នាដែលគាត់ និងអ្នកទាំងនោះបន់ស្រន់ព្រះពុទ្ធ ព្រះយេស៊ូ អោយយកជីវិតរបស់គេនៅពេលដែលគេដេកលក់ ដើម្បីកុំអោយគេភ្ញាក់ឡើង ហើយប្រឈម នឹងការឈឺចាប់មួយថ្ងៃតទៅទៀត។

គាត់និយាយខ្សឹបៗ ជាភាសាបារាំងឃ្លាចុងក្រោយ នៃកំណាព្យរបស់កវីបារាំង ឈ្មោះ អាល់ហ្វ្រីត ឌឺ វិតញ៉ី Alfred de Vigny (១៧៩៧-១៨៦៣) *Lamort du Loup* (សេចក្តីស្លាប់របស់ចចក) ដែលគាត់បានរៀនសូត្រជាសិស្សនៅប្រទេសវៀតណាម។

- *ការត្អូញត្អែរ យំ ឬទទូចអង្វរសុំ ស្មើនឹងភាពកំសាក*
- *សម្រេចជោគជ័យដោយស្វាហាប់ ទៅលើការប្រឹងប្រែងដ៏យូរអង្វែងរបស់អ្នក*
- *នៅលើវិថីដែលព្រហ្មលិខិតបានចារអោយអ្នកដើរ*
- *ហើយបន្ទាប់មក ដូចជារូបខ្ញុំឈឺចាប់ និងស្លាប់ដោយពុំបាននិយាយស្តី។*

ថាងសូត្រកំណាព្យជាពាក្យបន់ស្រន់នៅកំឡុងពេលដែលគាត់ជាប់គុក ដើម្បីបង្កើនកម្លាំងកាយ និងទឹកចិត្តអោយគាត់បំភ្លេចទុក្ខវេទនា ក្នុងជីវិត។ នៅក្នុងកំណាព្យ សត្វចចកព្រៃជាគ្រូព្រលឹងរបស់ជនជាប់គុកដោយសង្គ្រាម។ ទោះជាសត្វចចកត្រូវព្រានបាញ់សម្លាប់ ដោយព្រៃផ្សៃយ៉ាងណាក៏ដោយ វាបង្ហាញអ្នកសម្លាប់វានូវវិធីស្លាប់ដោយថ្លៃថ្នូរ។ ថាងសម្រេចជ្រើសយកវាសនា នៅក្នុងគុកអប់រំ ហើយស្លាប់នៅទីនោះ បើសិនជាគាត់ត្រូវស្លាប់ដោយគ្មានតក់ស្លុត។ នេះជាវិធីដែលជួយអោយសម្រេចជោគជ័យក្នុងការរម្ងាប់កំហឹងរបស់គាត់ នៅក្នុងដំណើរជីវិតរបស់ជនរួចផុតពីសេចក្តីស្លាប់ សេចក្តីគរថ្លង់ជាវិធីប្រសើរបំផុត។ ចំពោះរូបគាត់ការបញ្ចេញប្រតិកម្ម

ទៅលើកំហឹងពិតជាបរាជ័យ និងជាសកម្មភាពកំសាកគាត់បានផ្តល់ ឈ្មោះ ភាពពិតដែលគាត់បង្កើតឡើងសម្រាប់ខ្លួនគាត់ថាជា " ភាពថ្លៃថ្នូរនៃសេចក្តីពុំរីករាយ " ។

អារម្មណ៍ឆ្លើយតប នឹងភាពខុសគ្នានៃការអោម៉ាស់មុខដែលទទួលរក្សាទុក ហើយថែមទាំងជួយពង្រឹងដោយការទទួលយល់ព្រមពីសង្គម ក្រុមគ្រួសារ និងសហគមន៍។ នាពេលបច្ចុប្បន្ននេះ នៅក្នុងសង្គមប្រឆាំង-កំចាត់ ភាគច្រើនបានជម្រុញអោយមានភាពសងសឹក ស្អប់ ជាជាងសម្រុះសម្រួលគ្នា។ ភាពវាទដោយគ្មានសេចក្តីទុកចិត្ត និងភាពក្បត់ រវាងអ្នកជិតខាងនៅមជ្ឈឹមប្រទេស Middle East បាល់កាន រ៉ូ វ៉ាន់ដា បានបង្កើតនូវមជ្ឈដ្ឋាន ពុំអាចសម្រុះសម្រួលគ្នាបានឡើយ។ ការសងសឹកជាចម្លើយតែមួយគត់ នៅក្នុងសង្គមតក់ស្លុតឯទៀងសេចក្តីគ្មានផ្លូវដោះស្រាយ និងសេចក្តីឥតសង្ឃឹមមានជ័យជំនះ ទៅលើអាកប្បកិរិយាជនតក់ស្លុត។ នៅសហគមន៍ខ្មែរសហរដ្ឋអាមេរិក សេចក្តីកើតទុក្ខបានបំផ្លាញទម្រង់ ដំណើរជីវិតប្រចាំថ្ងៃរបស់គេ បន្តិចម្តងៗ មណ្ឌលសហគមន៍ខ្មែរមួយ រកឃើញថាអ្នកជម្ងឺជាច្រើនកើតទុក្ខ។ តែនាយកបានដឹកនាំពន្យល់ថាសេចក្តីទុក្ខព្រួយដ៏ច្រើននេះជា "ភាពធម្មតា" នៅក្នុងសហគមន៍របស់គាត់ ហើយគ្មានអ្វីដែលអង្គការនេះអាចជួយបានក្រៅពីភាពធ្វើជាមិនដឹងមិនឮ។

ទូទាំងពិភពលោកសភាពទាំងនេះ ហាក់បីដូចជា ពុំអាចទទួលយកបានឡើយ ដែលយកមូលដ្ឋានមធ្យមនៃសង្គមយកមកប្រើជាវិធីព្យាបាលផ្សេងទៀតសម្រាប់ភាពកើតទុក្ខ ឬភាពសងសឹក។ វាអាចកើតមានឡើងនៅក្នុងស្ថានភាពបច្ចុប្បន្ន បើសិនជាមានផលប្រយោជន៍ដល់សង្គមដោយចង់បង្វិលគំនិតអស់សង្ឃឹម ឬកំហឹងរបស់ប្រជាពលរដ្ឋ អោយទៅជាគោលដៅនយោបាយ ឬលិទ្ធិជាតិនិយម។ វាក៏អាចកើតមានឡើងដែរដោយប្រជាពលរដ្ឋទូទៅគេចពីអ្នករស់រួចផុតពីសេចក្តីស្លាប់ ដោយខ្លាចថាអ្នកទាំងនោះបញ្ចេញអារម្មណ៍មកដោយបំផ្លាញខ្លួនឯង ឬប្រព្រឹត្តអំពើសាហាវនៅក្នុងសង្គម។ ដំណើរការដ៏ត្រឹមត្រូវដែលប្រមូលផ្តុំអោយរួចពីភាពអាម៉ាស់មុខ ទាមទារមធ្យោបាយសង្គមថ្មី ដោយផ្តោតទៅលើឥទ្ធិពលព្យាបាលដោយខ្លួនឯង។

## ១.៨ ហេតុផលជម្រុញអំពើយង់ឃ្នង ការស្រមើលស្រម៉ៃចង់បង្កើតពិភពឥតខ្ចោះ

រឿងតក់ស្លុតអាចបញ្ចេញមិនត្រឹមត្រូវសកម្មភាពសាហាវដែលបានប្រព្រឹត្តិឡើងទេ តែវាក៏មានដំណោះសារទៅលើសកម្មភាពទាំងនោះដែរ។ ការព្យាយាមយល់ដឹងទៅលើជនល្មើសអាចមានគ្រោះថ្នាក់ ដោយការព្យាយាមនេះអាចធ្វើអោយមានភាពសមហេតុផល ឬភាពទទួលស្គាល់អំពើយង់ឃ្នងរបស់ជនព្រៃផ្សៃ។ តែការព្យាយាមយល់ដឹងជាកិច្ចចាំបាច់ក្នុងដំណើរការជាសះស្បើយ ដោយកាយសម្បទា និងស្មារតីរបស់ជនតក់ស្លុតត្រូវបានជនល្មើសផ្តិតជាប់ទៅដោយជំនឿរបស់គេ។ ក្រោយពីជនល្មើសបានសាបសូន្យទៅជាយូរក៏ដោយ មនោគមវិជ្ជារបស់ជនល្មើសនៅតែតាមព្យាបាទស្មារតីរបស់ជនរស់រួចផុតពីសេចក្តីស្លាប់ជានិច្ច។

ជនល្មើសជឿថាគេអាចសម្លាប់ និងធ្វើអោយសត្រូវរបួសដោយគ្មានមូលហេតុ ហើយជាញឹកញាប់ដោះសារភាពឃោរឃៅរបស់ខ្លួន វាដោយប្រាប់ភាពពិតតែមួយផ្នែក ដែលជាសេចក្តីស្រម៉ៃរបស់ជនប្រកបការងារផ្នែក

មនុស្សធម៌ ក្នុងការបង្កើតស្ថានភាពដែលល្អឥតខ្ចោះ ឬឋានសួគ៌នៅលើផែនដី។ គោលដៅនេះជាញឹកញាប់បង្ហាញកត្តាពិតដែលផ្តល់ឡើងនៅក្នុងរឿងតក់ស្លុត សេចក្តីស្រម៉ៃរកភាពសុខក្សេមក្សាន្តនេះក៏អាចរកឃើញនៅក្នុងឯកសារដែលចុះរាយពីបេសកម្មរបស់ជនល្មើស។

នៅក្នុងករណីខ្លះ សេចក្តីថ្លែង នៃបេសកម្មទាំងនេះបានយកមកប្រើ និងបកស្រាយខុសសិក្ខាបទ ទស្សនៈវិជ្ជា បំភ្លឺសតវត្សទី ដប់ប្រាំបី។ ទស្សនៈវិទូ ជីន-ជេគហ រ៉ូស្សូ Jean-Jacques Rousseau (១៧១២-១៧៧៨) ជាជនម្នាក់ដែលរកឃើញ វប្បធម៌លិទ្ធិប្រជាធិបតេយ្យសម័យ ដែលកត់ត្រានៅក្នុងកិច្ចសន្យាសង្គមឆ្នាំ១៧៦២ ថា "L'homme est né libre et partous il est dans les fers. (បុរសកើតមកដោយសេរី តែជាប់ចំណងគ្រប់ទិសទី)" យោងតាម លោក រ៉ូ ស្សូ អរិយធម៌របស់មនុស្សលោក គឺថោកទាបដោយ "សេចក្តីសង្គ្រោះថ្លៃថ្នូរ" ឬមនុស្សលោកជំនាន់មុន ដែលដាក់ខ្លួនអោយនៅឯកោដោយបង្កើតភាពខ្លួនទីពឹងខ្លួន និងគ្រប់គ្រងខ្លួនតាមស្ថានភាពដើម។ ផ្ទៃរឿងដែលនិយាយថាអរិយធម៌មនុស្សលោក ពុករលួយហើយត្រូវតែដាក់ជំនួសនេះ មានឥទ្ធិពលទៅលើការវិវឌ្ឍន៍លិទ្ធិប្រជាធិបតេយ្យ តែទស្សនៈរបស់លោករ៉ូស្សូ Rousseau ក៏បានផ្តល់ព័ត៌មានអំពីចលនាសាហាវយង់ឃ្នង ដូចជា របបខ្មែរក្រហម។

ប៉ុលពត និងអនុប្រធានដែលបានទទួលការហ្វឹកហ្វឺននៅទីក្រុងប៉ារីស Paris នៅក្នុងឆ្នាំ១៩៥០ បានសំដែងសេចក្តី កោតសរសើរគោរពដ៏ក្រៃលែង ទៅលើទស្សនៈបដិវត្តន៍របស់ លោក រ៉ូស្សូ Rousseau ថាជាឧត្តមគតិដឹកនាំប្រជាជន អាចបង្កើតឡើងតាមរយៈ "ឆន្ទៈទូទៅ"របស់មនុស្ស ដោយធ្វើការបញ្ជាក់នូវភាពល្អឥតខ្ចោះដែលអាចកើតមានឡើងនៅក្នុងសង្គម។ នៅក្នុងសុន្ទរកថាជាសាធារណៈមួយ នៃសុន្ទរកថាមួយចំនួនតូច ក្រោយពីឡើងកាន់កាប់អំណាច ប៉ុលពតបានថ្លែងថា "យើងរាល់គ្នាដឹងអំពីប្រវត្តិប្រាសាទអង្គរ"។ ប្រាសាទអង្គរបានស្ថាបនាឡើងនៅក្នុងរបបទាសករ (កញ្ជះ)ទាសកររបស់យើងទាំងនោះហើយជាអ្នកសង់ប្រាសាទអង្គរ នៅក្រោម នឹមត្រួតត្រារបស់អ្នកគាំទ្រជំនាន់នោះសម្រាប់បំពេញសេចក្តីរីករាយរបស់ស្តេច។ បើប្រជាពលរដ្ឋ យើងអាចសង់ប្រាសាទអង្គរបាន គេក៏អាចធ្វើអ្វីបានគ្រប់យ៉ាងដែរ តែគួរអោយស្តាយណាស់ ដែលប៉ុលពតបានជឿជាក់ទៅលើកេរកម្មក្នុងរាជ្យកាលចាកូប៊ិន Jacobin ដែលបានកើតមានឡើងបន្ទាប់ពីបដិវត្តន៍បារាំង ដែលបានអនុវត្តទ្រឹស្តីបង្ខំអោយចាកចេញ ឬបំបាត់ចោលជនណាដែលប្រឆាំង នឹងបទបញ្ជាសង្គមថ្មី។ គាត់បានជឿថា សង្គមថ្មី ត្រូវតែស្អាតស្អំ ដោយគ្មានបុគ្គល និងស្ថាប័នណាជ្រៀតជ្រែកនៅក្នុងការបង្កើតពិភពថ្មីដែលល្អឥតខ្ចោះនោះឡើយ។

នៅគ្រាដែល មូលដ្ឋានសង្គមបានផ្លាស់ប្តូរឡើងនៅក្រោមរបបខ្មែរក្រហម ដែលបានដឹងឮគ្រប់ទិសទីមានរួមទាំងការផ្លាស់ប្តូរទាំងស្រុងទៅលើប្រជាពលរដ្ឋទូទាំងប្រទេស អោយទៅជាសង្គមលិទ្ធិផ្តាច់ការ មុនដំបូងគេបង្អស់ ទិដ្ឋភាពនៃសេចក្តីស្រមើលស្រម៉ៃ ទៅលើភាពសុខក្សេមក្សាន្តផ្សេងៗ នៃអំពើដ៏សាហាវយង់ឃ្នងពុំមានដឹងឮឡើយ។ ឧទាហរណ៍ បេសកម្មដ៏ងុបងល់របស់ពួកអាលកេដា Al-Qaeda ដើម្បីស្តារជាថ្មីនូវមូលដ្ឋានពិភពលោកដោយយកតាមលំនាំច្បាប់អ៊ីស្លាម ជាគំនិតដែលទើប នឹងផុសចេញថ្មី ពីការថ្លែងសុន្ទរកថាជាសាធារណៈរបស់អូ

សាមា បិន ឡេដិន Osama Bin Laden និង វីឌីអូដែលបានរកឃើញ។ សេចក្ដីសម្រេចធ្វើការបះបោរ ការសងសឹក របស់គាត់ និងរបស់ពួកម៉ូស្លីម ដែលជាអាយ៉ងរបស់គាត់ អាចមើលឃើញនៅក្នុងកំណាព្យដែលគាត់សូត្រឡើងនៅក្នុងពិធីមង្គលការកូនប្រុសរបស់គាត់ ក្នុងខែ មករា ឆ្នាំ ២០០១ គឺ៩ខែមុន ហេតុការណ៍១១ ខែ កញ្ញា កើតមានឡើង។

នៅក្នុងកំណាព្យនេះគាត់អបអរសាទរភាពអត្តឃាតប្រយុទ្ធបំផ្លាញសហរដ្ឋអាមេរិក អត្តឃាតទម្លាក់គ្រាប់បែក ទៅលើនាវាចំបាំងតូចអាមេរិក នៅក្នុងឆ្នាំ ២០០០ នៅលើផ្ទៃ សមុទ្រ យ៉េមែន Yemen, USS Cole. *នាងសោត់អណ្ដែត តាមរលកបញ្ចេញភាពក្រអឺតក្រទម, ពោរពេញទៅដោយអំនួត និងអំណាចក្លែងក្លាយទៅកាន់មរណភាព នាងធ្វើចលនាមួយៗ ពោងមួយកំពុងវង់ចាំរូបនាង នាងកំពុងជិះនៅលើទឹករលក បងប្រុសរបស់អ្នកនៅតំបន់ខាងកើត រៀបចំអ្នកយាមទុកជាស្រេច ហើយសត្វអូដ្ឋប្រយុទ្ធ ក៏បានរៀបបំរុងជាស្រេចនាវាចំបាំងតូចធ្វើចលនាសំដៅទៅទីបូជាមរណៈ ពោរពេញទៅដោយវិញ្ញាណក្លែងក្លាយថាគ្មាននរណាអាចផ្ដាញ់ផ្ដាល់បានឡើយ!* កំណាព្យនេះពុំអាចបរិយាយប្រាប់យើងអំពីមូលហេតុដែល Bin Laden ស្អប់អាមេរិកដ៏លើសលប់នោះឡើយ តែនៅក្នុងវីឌីអូដែលគេរកឃើញនៅកាន់ដាហាអាប់ហ្គានីស្ថាន Kandahar Afghanistan ឃើញគាត់អានកំណាព្យរបស់គាត់ទៅកាន់បក្សដែលគាំទ្រគាត់៖

- *ខ្ញុំឃើញហេតុពិតថា ការប្រឈមនឹងមុខកាំបិតស្រួច*
- *ដែលតែងតែជួបប្រទះនឹងភាពលំបាក ហើយរួមសាមគ្គីគ្នា*
- *នៅពេលដែលភាពងងឹតគ្របដណ្ដប់លើយើង ខ្លួនយើងមុតដោយរណាមុខស្រួច ខ្ញុំនិយាយថា... "ស្រុកទេសយើងពោរពេញទៅដោយឈាមហូរពាសពេញ និងអ្នកគ្រប់គ្រងផ្ដាច់ការដែលចេញចូលដោយសេរីនៅក្នុងស្រុកទេសយើង" ហើយទីលានប្រយុទ្ធ*
- *ពន្លឺផ្លេកៗនៃផ្លែដាវ និងសត្វសេះ...និងសម្រែកខ្សឹកខ្សួល ពេលនេះក៏បានសាបសូន្យទៅ យើងឮសម្លេងវាយស្គរ និងចង្វាក់ភ្លេង...គេវាយសម្រុកចូលបន្ទាយហើយស្រែកថា "យើងនឹងមិនដកការវាយឆ្មក់លុះត្រាតែយើងសង្គ្រោះដែនដីរបស់យើង"។*

នៅចំណុចនេះគាត់ថ្លែងដោយច្បាស់អំពីទ្វីបខាងលិច ជាពិសេស សហរដ្ឋអាមេរិក ដែលកំចាត់បំផ្លាញជនជាតិម៉ូស្លីម។ គាត់ចាត់ខ្លួនគាត់ ជាអ្នករំដោះជនជាតិម៉ូស្លីម និងជនជាតិមជ្ឈឹមប្រទេសពីការលុបបំបាត់ដោយបច្ចឹមប្រទេស និងសហរដ្ឋអាមេរិក។

នៅក្នុងឆ្នាំ២០០២ Bin Laden បានប្រកាសជាសាធារណៈ "លិខិតជូនដល់អាមេរិក" ដែលបញ្ចេញច្បាស់នូវទស្សនៈសុខក្សេមក្សាន្តរបស់គាត់ក្នុងការបង្កើតសាសនាអ៊ីស្លាមដែលជាសាសនាពិតប្រាកដ និងខុសប្លែកពីទំនៀមទម្លាប់បច្ចឹមប្រទេសដោយសាសនានេះជឿទៅលើ "ភាពស្មើគ្នារវាងមនុស្សគ្រប់រូបដោយពុំប្រកាន់ពណ៌សម្បុរ ភេទ ឬភាសារ"។ នៅក្នុងលិខិតមានរាយឡើងជាទ្រង់ទ្រាយដូចគ្នា នឹងលោក Rousseau ថាអំពើអសីលធម៌ដែលមាននៅក្នុងអរិយធម៌បច្ចឹមប្រទេស និងសង្គមអាមេរិក ("ជាអរិយធម៌ដ៏អាក្រក់ជាងគេដែលមនុស្ស

លោកបានជួបប្រទះ") មានរួមទាំងអសីលធម៌ផ្នែកផ្លូវភេទ បែបបទចងការប្រាក់អាករ (យកចំណេញពេកក្រៃ) ការប្រើគ្រឿងញៀន និងស្រាដ៏លើសលប់ ការបែកចែករវាងសាសនា និងនយោបាយ ល្បែងពាលាពាណិជ្ជកម្ម ស្ត្រីភេទ នៅក្នុងផ្នែកកំដរអារម្មណ៍ ឧស្សាហកម្ម និងទេសចរណ៍ ផ្លូវភេទ ភាពរាលដាល រោគ អេច អាយ វ៉ី និង អេដស៍ HIV /AIDS ទូទាំងសកលលោក ភាពបំពុលបរិស្ថាន គាំទ្រផ្លូវច្បាប់ផ្តល់សិទ្ធិ ដក់អ្នកមានសម្បូរធនធាន ពុំចុះហត្ថលេខាលើសិទ្ធិសញ្ញា Kyoto និងច្បាប់សិទ្ធិមនុស្សធម៌អន្តរជាតិ ហើយការពារសេរីភាព និងប្រជាធិប តេយ្យសម្រាប់តែជនជាតិស្បែកស។

ដំណោះស្រាយរបស់ Bin Laden គឺប្រជាជនអ៊ីស្លាម នៅក្នុងលិខិតដែលគាត់សរសេរទៅអាមេរិក គាត់បានបញ្ចប់លិខិតនោះដោយនិយាយថា៖ "អ្នកដឹងច្បាស់នូវខ្លឹមសារដួងវិញ្ញាណរបស់ប្រជាជាតិអ៊ីស្លាម ដែលផ្ទុយនឹងភាពអំនួត និងភាពក្រអឺតក្រទមរបស់អ្នក"។ នៅទីបញ្ចប់យោងទៅតាមដួងព្រលឹងរបស់អ្នកស្រមើលស្រម៉ៃ ភាពសុខក្សេមក្សាន្តទាំងអស់បន្ទាប់ពី លោក Rousseau ដែលបានថ្លែងថា ជាអំពើដែលអនុញ្ញាតអោយធ្វើគ្មានប្រាស់ចាកសីលធម៌ ដោយសម្លាប់សត្រូវទាំងអស់ ដើម្បី នឹងសម្រេចការរៀបចំពិភពលោកដ៏ល្អឥតខ្ចោះ។ នៅក្នុងខែ កុម្ភៈ ឆ្នាំ២០០៣ តាមរយៈការផ្សាយរបស់ Aljaseera- Bin Laden បានថ្លែងថា "ជាការធម្មតា [និយាយទៅកាន់សហរដ្ឋអាមេរិក និងអ៊ីស្រាអ៊ែល] ក្នុងការបង្ហូរឈាម និងរឹបអូសទ្រព្យសម្បត្តិ"។ ហើយប្រយុទ្ធតតាំង នឹងអ្នកគាំទ្ររបបអាមេរិកកាំងនៅមជ្ឈឹមប្រទេស បង្កើតឥទ្ធិពលព្រះ គ្រប់គ្រងព្រះធរណី ទីបញ្ចប់ភាពប្រតិកម្ម (ចំអក)-មានន័យថាភាពល្អឥតខ្ចោះរបស់បុរស គឺសម្លាប់មនុស្សផ្សេងទៀត។

ភេរវកម្ម និងទារុណកម្ម កើតឡើងដោយការប៉ងបំផ្លាញស្ថាប័ន សង្គម វប្បធម៌ និងមនុស្សដែលគេប្រមាថមើលងាយ។ ការយល់ដឹងទំនាក់ទំនងរវាងបំណង នៃអំពើឃោរឃៅ និងជំនឿ នយោបាយត្រូវការសេចក្តីបំភ្លឺពីអ្នកប្រាជ្ញ និងអ្នកបង្កើតច្បាប់ ដើម្បី នឹងបង្កើតកម្មវិធីទប់ស្កាត់ និងរៀបចំឡើងវិញ។ លោក ដេវិត ទ្រឹមបល់ David Trimble អ្នកដឹកនាំសាសនា ប្រូតេស្តង់ នៅប្រទេស អាយឡិន Ireland ខាងជើងមានឥទ្ធិពលក្នុងការក្លែងបន្លំប្រវត្តិសាស្ត្រកិច្ចសន្យាសន្តិភាព បានថ្លែងយ៉ាងច្បាស់ នៅក្នុងសុន្ទរកថារបស់លោក នៅក្នុងពេលដែលលោកទទួលរង្វាន់សន្តិភាពអន្តរជាតិ លោកបានបកស្រាយកម្មវត្ថុអំពើឃោរឃៅ នៃភាពស្រមើលស្រម៉ៃសេចក្តីសុខក្សេមក្សាន្ត ដោយយកពាក្យល្បីល្បាញរបស់អ្នកនិពន្ធអ៊ីស្រាអ៊ែល Amos Oz.

អ្នកនិយម លិទ្ធិនយោបាយ ពុំមែនជាបុគ្គល ដែលចង់ធ្វើអោយខ្លួនឯង ល្អឥតខ្ចោះ នោះឡើយ គេចង់ធ្វើអោយរូបអ្នកល្អឥតខ្ចោះ។ គេចង់ធ្វើអោយអាកប្បកិរិយា នយោបាយ សាសនា ជាតិសាសន៍ និងភូមិសាស្ត្ររបស់អ្នកល្អឥតខ្ចោះ។ គេចង់អោយអ្នកដូរគំនិត ដូររដ្ឋាភិបាល និងដូរព្រំដែនរបស់អ្នក គេអាចប្តូរជាតិសាសន៍របស់អ្នក ដើម្បីបំបាត់រូបអ្នកចេញពីភាពជាសមីការ(ស្មើគ្នា)ល្អឥតខ្ចោះ ហើយក្នុងគំនិតរបស់គេ គឺបំបាត់ចោលរូបអ្នកចេញពីផែនដី។

ការបំបាត់ចោលវប្បធម៌បុរាណ និងតម្លៃអតីតរបស់ សត្រូវបានបកស្រាយនូវអត្ថន័យពិសេសទៅលើការកំចាត់បំផ្លាញវប្បធម៌របស់បុគ្គល គ្រួសារ និងសហគមន៍។ ការប្រើភាពអាម៉ាស់មុខ ជាឧបករណ៍ ក្នុងអំពើ

យង់ឃ្នង ជាភាពចាំបាច់ក្នុងការប្រមាថ និងសងសឹកពិតប្រាកដទៅលើជនដែលគេជឿជាក់ថាជាពួកក្បត់ ជនផ្លៀតឱកាស និង "ព្រៃផ្សៃ" នៅក្នុងរបៀបរបបនយោបាយអតីតកាល ក្នុងការចង់បានអំណាចល្អឥតខ្ចោះបែបថ្មីស្ទើរតែគ្រប់ករណី ជនសាមញ្ញពុំត្រូវបានចាត់ទុកជាជនស្លូតត្រង់ឡើយ។ ជាការពិតអ្នកទាំងនេះ ជាមូលដ្ឋានរបស់សង្គមពុករលួយ។ ជាលទ្ធផលសង្គមថ្មី អាចកសាងឡើងដោយដាក់ទារុណកម្ម ទៅលើមនុស្សស្លូតត្រង់។ ការសម្លាប់រង្គាលទៅលើប្រជាជនស្លូតត្រង់ត្រូវតែ "សំអាត"អោយអស់ពីសង្គម ដើម្បីធ្វើអោយ "បរិសុទ្ធ"។ ប៉ុលពត បានថ្លែងថា គាត់ នឹងសម្លាប់ជនជាតិខ្មែរសង្គមចាស់ ទៅតាមសេចក្តីត្រូវការ ដើម្បី នឹងបង្កើតសង្គមខ្មែរបរិសុទ្ធថ្មី ហើយបានបន្តការសម្លាប់មនុស្សរាប់លាននាក់ទៅ។

នៅប្រទេសកម្ពុជា និងការវាយប្រហារភេរវកម្មនៅថ្ងៃទី១១ ខែ កញ្ញា អ្នករួចផុតពីសេចក្តីស្លាប់បានទទួលរងពីការ វាយប្រហារដ៏ពេញទំហឹងរបស់សុបិន្តអ្នក ចង់បានពិភពល្អឥតខ្ចោះ ។ ការចង់ដឹងអំពីការកើតឡើងនៃទស្សនៈ ល្អឥតខ្ចោះជាករណីសំខាន់ ពុំត្រឹមតែដើម្បីយល់ដឹងនូវរង្វាន់ដ៏មានឥទ្ធិពល ដែលផ្តល់ឡើងទៅលើការប្រព្រឹត្តសកម្មភាពឧក្រិដ្ឋដ៏សាហាវយង់ឃ្នងដែលពុំអាចបរិយាយបាននេះ តែគេថែមទាំងយល់ដឹងពីឥទ្ធិពលដែលប៉ះទង្គិចនៅលើដំណើរការជាសះស្បើយ។ អ្នកសុបិន្តដែលចង់បានពិភពល្អឥតខ្ចោះព្យាយាមធ្វើអោយមានការភ័ន្តច្រឡំ និងទប់ស្កាត់ដំណើរការជាសះស្បើយ ដោយពោលអះអាងថា គេធ្វើល្អដោយធ្វើបាបអ្នកឯទៀត ហើយការខូតខាត ដែលគេបានធ្វើឡើងពុំត្រូវជួសជុលឡើងវិញឡើយ ហើយអ្នករងរបួស ត្រូវទុកអោយស្លាប់ ឬរស់ពោរពេញដោយជីវិតទន់ខ្សោយដោយរបួសរបស់ខ្លួន។

ពេលនេះអាចថ្លែងឡើងដោយច្បាស់ថា ភាពអាម៉ាស់មុខ រួមមានទៅដោយអំពើយង់ឃ្នងគ្រប់ប្រភេទហើយ ការព្យាបាលជនតក់ស្លុត ពុំអាចទុកដោយធ្វើមិនដឹង មិនឮ ឬមិនចាប់អារម្មណ៍ ទៅទៀតបានឡើយ។ ឥទ្ធិពលខ្លាំង និងភាពស្មុគ្រស្មាញសមហេតុផលក្នុងការធ្វើអោយអ្នកឯទៀតរងរបួស អាចទប់ស្កាត់បានដោយប្រើវិធីព្យាបាលត្រឹមត្រូវ។ ទោះបីជាយ៉ាងណាក៏ដោយ វាហាក់ដូចជា ជាក់ស្តែងថា សកម្មភាពព្រៃផ្សៃដូចជាហេតុការណ៍ ដែលបានកើតឡើងនៅថ្ងៃទី១១ ខែ កញ្ញា ឬនៅស្រេប្រីនីកា Sebrenica បានទទួលការកាត់ទោសជាស្រេច ពីពិភពផ្សេងៗ តែករណីនេះពុំពិតទេ។ ចំពោះមនុស្សជាច្រើនរូប រួមទាំងជនរងគ្រោះ ទស្សនៈដែលចង់បានពិភពល្អឥតខ្ចោះរបស់ឧក្រិដ្ឋជន មានភាពសមហេតុផល។ នៅកម្រិតមូលដ្ឋានខ្លះៗ គំនិតរបស់ Rousseau ធ្វើអោយសង្គមមនុស្សលោកល្អឥតខ្ចោះ នៅតែមានឥទ្ធិពលជាក់លាក់ទៅលើលិទ្ធិប្រជាធិបតេយ្យដែលព្យាយាមបំបាត់ភាពអយុត្តិធម៌ កៀបសង្កត់ និងភាពពុំស្មើគ្នាក្នុងសង្គម។ គោលដៅដែលចង់បានពិភពល្អឥតខ្ចោះ គឺត្រូវឧក្រិដ្ឋជនដណ្តើមយក ហើយផ្តល់ហេតុផលទៅលើសកម្មភាពអសីលធម៌ ដោយភាពច្នៃប្រឌិតស្ថានភាពពិតបង្កើតភាពភ័ន្តច្រឡំ និងមន្ទិលសង្ស័យទៅលើមូលហេតុឃោរឃៅ ហើយនិយាយថាមូលហេតុនេះ បំរើគោលបំណងយ៉ាងត្រឹមត្រូវ។ វិធីព្យាបាល និងភាពជាសះស្បើយត្រូវតែព្យាយាមដោយសតិសម្បជញ្ញៈ ដើម្បីលុបបំបាត់ភាពក្លែងបន្លំទាំងនេះ។ ការព្យាបាលដែលធ្វើឡើង ត្រូវបញ្ជាក់ដោយច្បាស់ថាអំពើយង់ឃ្នងជាអំពើខុស ទោះជាមានមូលហេតុ សមហេតុផលក៏ដោយ ហើយការធ្វើអោយអ្នកឯទៀតរងរបួស និងបណ្តាលអោយទៅជាការសង

សឹកដោយអំពើឃោរឃៅកើតមានឡើងដដែលៗ ជាថ្មីទៀត។ ចាប់ផ្តើមផ្តល់ឱវាទដោយធ្វើការបញ្ជាក់ច្បាស់លាស់ ជាវិធីប្រកបដោយប្រសិទ្ធភាពខ្លាំង៖ "អ្នកពុំត្រូវទទួលខុសត្រូវទៅលើអំពើយង់ឃ្នងអ្វីណាមួយដែលកើតមានឡើងដល់រូបអ្នកឡើយ។ ហើយគ្មានហេតុផល ឬការអត់ឱនអ្វី ដែលអាចបង្ហាញភាពយុត្តិធម៌ទៅលើសកម្មភាពទាំងនេះបានឡើយ"។

ដើម្បីអោយការព្យាបាលបន្តទៅទៀត វាជាការសំខាន់ក្នុងការបញ្ជាក់អារម្មណ៍អាម៉ាស់មុខ ដែលពោរពេញទៅដោយភាពរំជួលចិត្ត។ ដូច លោក ថាង បានថ្លែងដោយខ្លោចផ្សារថា "ភាពអាម៉ាស់មុខ ដកហូតអនុភាពរបស់មនុស្ស គោលដៅរបស់វា គឺធ្វើអោយរូបអ្នកក្លាយទៅជាមនុស្សគ្មានអានុភាព ដែលពុំអាចបំពេញកិច្ចការ ជាមនុស្សធ្វើការពុំកើត ឬថៃទាំក្រុមគ្រួសារ និងមិត្តភក្តិ"។ នៅចំណុចនេះគាត់ពុំមែននិយាយអំពីលទ្ធផលដែលប៉ះពាល់ដល់ទារុណកម្មរាង្គកាយឡើយ តែគាត់និយាយអំពីអារម្មណ៍របស់គាត់ ទៅលើភាពអាម៉ាស់មុខដែលគាត់ជួបប្រទះជារៀងរាល់ថ្ងៃ ដោយសារការធែកធេរដល់រូបគាត់ដោយអ្នកយាមគុក។ អ្នកតក់ស្លុត គ្រប់រូបរួមទៅដោយជំនួយពីមិត្តភក្តិ និងអ្នកព្យាបាលត្រូវរកមូលដ្ឋានដើម នៃវិចារណញ្ញាណ-ដោយគ្មានជាប់ស្លាកស្នាមភូតកុហករបស់អ្នកឈ្លានពាន-ហើយនៅតែមានអនុភាពផ្ទាល់ខ្លួនដែលធ្វើអោយភាពព្យាបាលចំរើនឡើង។

# ជំពូកទី៤ ឥទ្ធិពលព្យាបាលដោយខ្លួនឯង

ភាពបរាជ័យរបបខ្មែរក្រហម នៅក្នុងឆ្នាំ ១៩៧៩ និងឆ្នាំ១៩៨០ បានធ្វើអោយជនជាតិខ្មែរខ្វះអាហាររាប់រយ រាប់ពាន់នាក់ ព្យាយាមរត់ចូលទៅក្នុងប្រទេសថៃ។ នៅគ្រាដំបូង រដ្ឋាភិបាលថៃបានបដិសេធមិនអោយជនជាតិខ្មែរចូលប្រទេសគេឡើយ បានធ្វើអោយប្រជាជនខ្មែរ រាប់ពាន់នាក់ស្លាប់នៅតាមព្រំដែន។ ក្រោយពីមានបាតុកម្មពីសហគមន៍អន្តរជាតិ រដ្ឋាភិបាលថៃ ក៏បានអនុញ្ញាតអោយអង្គការសហប្រជាជាតិ ទទួលតួនាទីនេះជំនួសវិញ។ អ្នករត់គៀសខ្លួនជំនាន់ទីមួយ បានទទួលចាត់តាំងជាជនភៀសខ្លួនត្រឹមត្រូវស្របតាមច្បាប់អន្តរជាតិ ហេតុទាល់តែគេបានទៅរស់នៅសហរដ្ឋអាមេរិក អ៊ឺរ៉ុប កាណាដា និងអូស្ត្រាលី។

ក្រោយមកពួកថៃបានបដិសេធការចាត់តាំងជាបែបបទជនភៀសខ្លួននេះ ដល់ជនភៀសខ្លួនខ្មែររាប់ពាន់នាក់ ដែលបានចូលមកដល់ ធ្វើអោយជនជាតិខ្មែររាប់ពាន់នាក់ ក្លាយជាជន "គ្មានទីពឹង"។ ដោយមូលហេតុនេះ អ្នកទាំងនោះពុំបានទទួលការអនុញ្ញាតអោយនៅក្រោមច្បាប់ការពារអន្តរជាតិ ហើយគេក៏គ្មានសិទ្ធិទៅជ្រកកោននៅប្រទេសទីបីបានឡើយ។ ជនជាតិខ្មែរជាង៣៥០,០០០នាក់ រស់នៅជាជនគ្មានទីពឹងនៅតាមជុំរុំព្រំដែនថៃ-ខ្មែរក្រោយពី ឆ្នាំ១៩៨២។

គេបានទទួលការថែទាំដោយអង្គការសហប្រជាជាតិពិសេស គឺអង្គការបេសកម្ម សង្គ្រោះព្រំដែន United Nations Border Relief Operation (UNBRO) រួមទៅដោយជំនួយពីអង្គការស្បៀងអាហារពិភពលោក World Food Programme (WFP) អង្គការកាកបាទក្រហមអន្តរជាតិ International Committee of the Red Cross (ICRC) អង្គការជនភៀសខ្លួនអាមេរិក American Refugee Committee (ARC) និងអង្គការមនុស្សធម៌ផ្សេងៗ ជាងដប់ទៀត ដែលមានរួមទៅដោយ ផ្នែកសុខាភិបាល និងសេវាសង្គមកិច្ច អង្គការបេសកម្មសង្គ្រោះព្រំដែន UNBRO ផ្តល់ជម្រក ម្ហូបអាហារ និងទឹក។

រដ្ឋាភិបាលទទួលបន្ទុកសម្រាប់ជនគ្មានទីពឹងទាំងនោះ គឺនៅតែជាតួនាទីរបស់ប្រទេសថៃដដែល ហើយទ័ពយោធាមានអំណាចគ្រប់គ្រងប្រជាជនរស់នៅក្នុងជុំរុំគ្រប់សកម្មភាពទាំងអស់។ ទ័ពយោធាទទួលខុសត្រូវធ្វើជាតម្រួតទាំងខាងក្នុង និងខាងក្រៅជុំរុំបង្កើតវិន័យ និងលក្ខខ័ណ្ឌចាំបាច់សម្រាប់ការពារអធិបតេយ្យភាព និងផលប្រយោជន៍របស់ប្រទេសថៃ។ ជាពិសេសពួកថៃខ្លាចទ័ពយោធាវៀតណាម ដែលបានវាយចូលមកកាន់កាប់ប្រទេសខ្មែរ ក្រោយពីវាបានវាយដេញទ័ពខ្មែរក្រហមចេញ ហើយពេលនេះទ័ពនេះកំពុងបោះទ័ពនៅតាមព្រំដែន ។ ជុំរុំព្រំដែនថៃ-ខ្មែរនីមួយៗ ភ្លាមនោះបានប្រែក្លាយពីជម្រកបណ្តោះអាសន្នរបស់ជនស៊ីវិលទៅជាជុំរុំទ័ពព្រៃខ្មែរជាសម្ងាត់ ដែលជាការឧបត្ថម្ភ ដោយសហគមន៍អន្តរជាតិ ដែលមានសហរដ្ឋអាមេរិក និងថៃ ដើម្បី នឹងបណ្តេញទ័ពវៀតណាមចេញពីប្រទេសខ្មែរ។

ជុំរុំព្រំដែនថៃដែលធំជាងគេហៅថាតំបន់ (សាយធូ Site 2) ជាសហគមន៍ដែលមានមនុស្សជាង ១៥០,០០០នាក់ ហើយមនុស្សម្នាក់ សម្គាល់ខ្លួនដោយប្រើលេខអត្តសញ្ញាណប្រចាំខ្លួន។ ជុំរុំសាយធូមាន បរិវេណពងក្រពើរព័ទ្ធជុំវិញទៅដោយរបងបន្លាលួស។ ក្រុមគ្រួសារដែលមានសមាជិក ចំនួន៦នាក់ រស់នៅក្នុង ពេងឬស្សី មានទទឹងប្រវែង១២ហ្វីត(3.64 ម៉ែត្រ) និងបណ្តោយប្រវែង១៨ហ្វីត(5.45 ម៉ែត្រ)។ គ្រួសារចំនួន ១៦គ្រួសារប្រើប្រាស់បង្គន់សាធារណៈមួយរួមគ្នា។ ជុំរុំពុំមានភ្លើង ឬភ្លើងអគ្គិសនីទេ និងទឹកប្រើប្រាស់ គឺដឹក ជញ្ជូនចូលតាមឡានដឹកទឹកជារៀងរាល់ថ្ងៃ សាយធូពុំមានប្រភពទឹកប្រើប្រាស់ឡើយ។ ជាងមួយទសវត្សប្រជា ជនបានទទួលអាហារដដែលៗ គឺអង្ករ និងត្រីខកំប៉ុងជារៀងរាល់ថ្ងៃ។

មន្ទីរពិនិត្យជម្ងឺក្រុងបូស្តុនបានបង្កើតជាដំបូង ខ្ញុំបានឮអំពីជុំរុំសាយធូជាដដែលៗ ពីក្រុមអ្នកជម្ងឺភៀស ខ្លួនខ្មែរ។ អង្គការសហប្រជាជាតិបានបង្ហាញដល់ពិភពលោកថា ជុំរុំនេះជាជម្រកឋានសួគ៌សម្រាប់ជនភៀសខ្លួន ខ្មែរ។ ប៉ុន្តែ អ្នកជម្ងឺបានរៀបរាប់ភាពពិតផ្សេងទៅវិញៈ ចំពោះជនភៀសខ្លួនជាច្រើនរូបជុំរុំនេះជាទីកន្លែងចាប់ រំលោភផ្លូវភេទ ការកាប់សម្លាប់ និងជាប្រព្រឹត្តិការណ៍យង់ឃ្នងទៅលើមនុស្សជាតិ។

នៅថ្ងៃមួយនោះក្រុមគ្រួសារជនភៀសខ្លួនម្នាក់ បានបង្ហាញរូបខ្ទមស្បូវបងប្អូនរបស់គេដល់យើងនៅក្នុង មន្ទីរពិនិត្យជម្ងឺ ខ្ទមនេះបានឆេះខ្មេចខ្ទីទៅជាផេះដោយសារគ្រាប់រន្ទះបាញ់។ មនុស្សនៅក្នុងខ្ទមទាំងអស់ស្លាប់គ្មាន សល់ម្នាក់ឡើយ។ នៅពេលដែលយើងកំពុងតែសម្លឹងមើលកំទេចផ្សេង អ្នកជម្ងឺសុំអោយយើងទៅជួយបងប្អូន របស់គេដែលនៅរស់រួចផុតពីសេចក្តីស្លាប់។ យើងទៅជាស្រឡាំងកាំងដោយការស្នើសុំនេះ ព្រោះគ្រូពេទ្យអាមេរិក កាំង ពុំធ្លាប់ទៅជុំរុំជនភៀសខ្លួន ឬទ្វីបអាស៊ីអាគ្នេយ៍ឡើយ។ វាជាការស្មានមិនដល់ ដែលអ្នកជម្ងឺស្នើសុំគ្រូពេទ្យ របស់ខ្លួន ហើយយើងក៏សម្រេចចិត្តខិតខំដោយអស់ពីសមត្ថភាពដើម្បីអ្នកទាំងនោះ។

ពីរទៅបីខែក្រោយមក នៅក្នុងខែ តុលា ឆ្នាំ១៩៨៨ ក្រោយពីបានទទួលថវិកាឧបត្ថម្ភមួយចំនួនតូចពីព្រះ វិហារ Episcopal នៅ បូស្តុន ខ្ញុំក៏ធ្វើដំណើរ ទៅប្រទេសថៃ។ អ្នករួមដំណើរជាមួយខ្ញុំ គឺលោក រឺសសែល ជាល់ ប៊ឺត Russell Jalbert ជាអ្នកតាក់តែងច្បាប់ ដែលបានចូលនិវត្តន៍ គាត់ជាអ្នកទទួលខុសត្រូវ ផ្នែករកទីជម្រកអោយ ជនភៀសខ្លួន នៅតំបន់ឆ្នេរសមុទ្រខាងកើត នៃសហរដ្ឋអាមេរិក។ បេសកម្មរបស់យើង គឺធ្វើការប្រមាណមើលទៅ លើមជ្ឈដ្ឋាននៅជុំរុំសាយធូ និងការប៉ះទង្គិចទៅលើសតិអារម្មណ៍ និងសុខុមាលភាពរបស់ជនភៀសខ្លួនដែលរស់ នៅទីនោះ។

នៅក្នុងរយៈពេល ៨ម៉ោងដែលខ្ញុំកំពុងតែជិះតាក់ស៊ីពីទីក្រុងបាងកកទៅកាន់ព្រំដែនប្រទេសថៃ ខ្មែរ ទិដ្ឋ ភាពពិតបានជ្រាបចូលក្នុងដួងចិត្តរបស់ខ្ញុំដោយសន្សឹមៗ។ ទិដ្ឋភាពដីស្រែដែលលាតសន្ធឹងទៅដោយសន្ទូងខៀវ ស្រងាត់បក់រវិចៗ ដាច់កន្ទុយភ្នែក រួម នឹងហ្វូងសត្វក្របី ជាទិដ្ឋភាពដូចទៅ នឹងទិដ្ឋភាពដែលបានបញ្ចាំងនៅលើ កញ្ចក់ទូរទស្សន៍ កាលពីជំនាន់សង្គ្រាមវៀតណាម ធ្វើអោយខ្ញុំបារម្ភថា យើងបានឈានចូលដល់ទីកន្លែងដែល មានគ្រោះថ្នាក់ ដូចគ្នា នឹងទីកន្លែងដែលទាហ៊ាន អាមេរិកកាំងបានស្លាប់បាត់បង់ជីវិតជាច្រើនរូប។

ក្នុងនាមជាវេជ្ជបណ្ឌិតដែលមានបេសកម្មផ្នែកមនុស្សធម៌ ខ្ញុំជឿថាយើងទាំងអស់គ្នា នឹងមានសុវត្ថិភាព រហូតដល់ពេលយើងបាន ឮសម្លេងគ្រាប់ផ្លោងផ្ទុះពីចម្ងាយ នៅពេលដែលយើងបានមកដល់ទីបញ្ជាការនៅក្នុងភូមិមួយក្បែរជុំរុំជនភៀសខ្លួន។ នៅតាមព្រំដែនរវាងប្រទេសថៃ និងប្រទេសខ្មែរ សង្គ្រាមកំពុងតែផ្ទុះឡើងរវាងទ័ពវៀតណាមដែលកំពុងតែកាន់កាប់ប្រទេសខ្មែរ ហើយទ័ពព្រៃខ្មែរកំពុងតែលាក់ខ្លួននៅតាមបណ្តោយព្រំដែន។ ការជឿជាក់របស់យើងកាលពីដំបូងថាយើងមានសុវត្ថិភាពនេះក៏ចាប់ផ្តើមសោយទៅវិញដោយសន្សឹមៗ នៅពេលដែលយើងដឹងថារដ្ឋាភិបាលថៃ បានដាក់ជនជាតិខ្មែរចំនួនជិតកន្លះលាននាក់ នៅក្នុងជុំរុំ ចំនួន ៨រាយនាក់ តាមព្រំដែនដោយយកមនុស្សជាខែល ឬស្រទាប់ការពារដើម្បី ការពារប្រទេសថៃ ខ្ញុំមិនដែលឮសម្លេងគ្រាប់ផ្លោង និងអំបែងគ្រាប់ផ្លោងផ្ទុះជារៀងរាល់ថ្ងៃឡើយ។

នៅថ្ងៃដំបូងអាជ្ញាធរ អង្គការសហប្រជាជាតិបាននាំយើងទៅកាន់ជុំរុំសាយធូ លាតសន្ធឹងនៅចំពោះមុខយើង គឺដីបែកក្រហែងធំធេង ហើយនៅលើដីនោះមានខ្ទមឫស្សីប្រក់ស្បូវរាប់ពាន់ ដែលមានមនុស្សរស់នៅណែនណាន់តាន់តាប់។ ក្រៅពីស្លឹកឈើស៊ីប់ទ្រុឌ និងផ្កាពណ៌ក្រហម និងផ្កាពណ៌ឈូករីកផ្ទិនផ្ទៅនៅក្បែរនោះគ្មានអ្វីផ្សេងទៀត ដែលមានពណ៌បៃតងដុះនៅក្នុងជុំរុំឡើយ សូម្បីតែស្មៅមួយទងក៏គ្មានដែរ។ ជីវិតរស់រវើកដែលគួរអោយកត់សម្គាល់នៅក្នុងជុំរុំសាយធូ គឺមានតែក្មេងៗ ស្រាតននលគក់ ខ្លួនប្រឡាក់ដោយធូលីរត់ទាំងហ្វូងៗតាមខ្ទមឫស្សី។ យើងបានរកមើលសញ្ញាជីវភាពរស់នៅជាធម្មតាក្នុងជីវិតរបស់ជនជាតិខ្មែរ ដូចជាសកម្មភាពដែលរៀបចំឡើង ជាភស្តុតាងបង្ហាញថាប្រជាជនបានបន្តដំណើរជីវិតរបស់គេ តែយើងគ្មានឃើញហាងលក់ឥវ៉ាន់ ទីធ្លាលេងកំសាន្ត ឬវត្តអារាមអ្វីឡើយ។

ទិដ្ឋភាពនៅជុំរុំមានសភាពដូចគ្នា នឹងរូបថតរបស់អ្នកជម្ងឺខ្មែរ គ្រាន់តែខុសគ្នានៅក្នុងពេលនេះ គឺមានឮសម្លេងគ្រាប់ផ្លោង និងអំបែងគ្រាប់កាំភ្លើងធំផ្ទុះនៅក្បែរៗនោះ ដែលធ្វើអោយរូបភាពនោះទៅជាមានចលនារស់រវើក។ ខ្ទមចង្អៀតទាំងនោះមើលទៅហាក់បីដូចជាគុក សង់នៅលើដីដាច់ស្រយាលដែលគេបានបោះបង់ចោល ជាទីដែលមនុស្សពុំអាចស្តាប់វិទ្យុ ឬគ្មានកាសែតសម្រាប់អាន ហើយប្រជាជនដែលរស់នៅក្នុងជុំរុំនោះ បាន ទទួលការហាមឃាត់ មិនអោយសរសេរសំបុត្រ សូម្បីតែ សមាជិកគ្រួសារ ដែលនៅក្នុងជុំរុំជាមួយគ្នា ក៏ដោយ។ ប្រជាជនខ្មែរទទួលការបង្ខាំងដោយគំរាមកំហែងថា នឹងទទួលទារុណកម្មដោយធ្ងន់ធ្ងររហូតដល់អស់ជីវិត បើសិនជាគេហ៊ានលួចរត់ចេញ។ ប្រជាជនរស់នៅក្នុងជុំរុំសាយធូជាច្រើននាក់ត្រូវតម្រួតថៃបាញ់សម្លាប់ នៅពេលដែលគេគ្មានជម្រើសហើយបានចេញទៅរកអូសដុតនៅក្រៅបរិវេណជុំរុំ។ ការចាប់រំលោភផ្លូវភេទ និងការវាយដំ ជនភៀសខ្លួនដោយចោរប្លន់ និងភ្នាក់ងារសន្តិសុខខ្មែរ និងថៃ ជារឿងដែលកើតឡើងជាប្រចាំថ្ងៃក្នុងជីវិតរស់នៅក្នុងជុំរុំ។

ភាពទុរគតដ៏លើសលប់ដែលយើងឃើញនៅក្នុងជុំវិញខ្លួន ធ្វើអោយយើងចាប់ផ្តើម សាកសួរអាជ្ញាធរអង្គការសហប្រជាជាតិ និងអ្នកសង្គ្រោះអន្តរជាតិអំពីលក្ខណៈនៅជុំរុំសាយធូថា តើទីនេះជាទីទាល់ក្រ ជាគុកអន្តោប្រវេសន៍ ឬជាជុំរុំអប់រំកសាង។ យើងពុំអាចផ្តល់យោបល់ដល់អាជ្ញាធរ ទៅលើការធ្វើអោយស្ថានភាពនេះមានភាពប្រសើរឡើងទៅលើផ្នែកផ្លូវចិត្ត និងមនុស្សធម៌បាន លុះត្រាតែយើងរកឃើញពាក្យដែលអាចបរិយាយ អំពី

ជីវិតរបស់ប្រជាជនដែលរស់នៅទីនោះបាន។ តែអាជ្ញាធរអង្គការសហប្រជាជាតិ និងថៃនៅតែពុំប្រាប់យើងថាជនភៀសខ្លួនទាំងនេះជាអ្នកជាប់គុក (ដូចជាយើងបានឃើញនោះ) ហើយដែលគេកំពុងតែ ទទួលទារុណកម្ម (ទោះជាគេពុំមានបំពានច្បាប់ក៏ដោយ) ឬគេកំពុងតែត្រូវការការព្យាបាល ជម្ងឺ នឹងជម្ងឺសតិអារម្មណ៍ ទៅលើបទពិសោធន៍ អំពើប្រល័យពូជសាសន៍ ដែលគេបានទទួល (ការព្យាបាលជម្ងឺមានតិចតួច ហើយការព្យាបាលជម្ងឺសតិអារម្មណ៍គឺគ្មានទាល់តែសោះ)។ ការឈឺចាប់ជាក់ស្តែង នៅក្នុងជុំរុំ គឺជាទីកន្លែងឃុំឃាំងដ៏សាហាវដែលពុំសមស្របទៅតាមទ្រឹស្តីរបស់អាជ្ញាធរ ដែលពោលអះអាងថា វាជាទីកន្លែងជំនួយមនុស្សធម៌ដែលមានការ ការពារមានសុវត្ថិភាព។ ការយល់ដឹងរបស់យើងមានភាពផ្ទុយគ្នាអំពីការយល់ដឹងរបស់អាជ្ញាធរជុំរុំបានបង្កើតនូវពិភពចម្លែកមួយដែលមិនអាចស្មានបាន។

ជនភៀសខ្លួនរាប់រយនាក់ ដែលបានទទួលការសម្ភាសន៍ បាននិយាយអោយគេដឹងឮច្បាស់លាស់អំពីសេចក្តីឈឺចាប់របស់ខ្លួន។ "នៅថ្ងៃទី១៧ ខែ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកក្នុងភូមិរបស់ខ្ញុំ ហើយចាប់ផ្តើមសម្លាប់" ជារឿងដែលគេចាប់ផ្តើមនិយាយ។ គេរៀបរាប់អំពីដំណើររឿងព្រាត់ប្រាស និងសេចក្តីទន្ទត់នៅប្រទេសខ្មែរ និងសេចក្តីអស់សង្ឃឹមនៅជុំរុំសាយធូ។ ផ្ទុយទៅវិញទាំងអាជ្ញាធរជុំរុំ និងវេជ្ជបណ្ឌិតបានបដិសេធនូវសេចក្តីឈឺចាប់ និងទុក្ខវេទនារបស់ជនភៀសខ្លួនដែលគេកំពុងតែជួយ។ សូម្បីតែអ្នករួមការងារផ្នែកសុខាភិបាលជាមួយខ្ញុំ ក៏គេហាក់បីដូចជា និយាយភាសាផ្សេងៗទៅវិញ ទោះបីជាគេបានទទួលការសិក្សាផ្នែកវិទ្យាសាស្ត្រដូចគ្នាក៏ដោយ។ គេបានពោលថា "ស្ទើរតែទាំងអស់ អ្នករស់នៅក្នុងជុំរុំសាយធូបានបំភ្លេចចោលអំពើប្រល័យពូជសាសន៍នៅជំនាន់ប៉ុលពត" ភាពតក់ស្លុតអតីតកាលពុំមានរំខានដល់អារម្មណ៍របស់គេទៀតឡើយ។ "គេបានសម្របសម្រួលខ្លួនទៅតាមស្ថានភាពឃោរឃៅ ដែលជនជាតិថៃបានធ្វើឡើងដល់រូបគេនៅក្នុងជុំរុំសាយធូ"។ រូបអ្នកដោយ ឮសូរគ្រាប់ផ្លោងជារៀងរាល់ថ្ងៃ និងពេលខ្លះគ្រាប់ផ្លោងនោះបានធ្លាក់នៅក្នុងជុំរុំសម្លាប់ប្រជាជន។ "ហេតុអ្វីបានជាអ្នកមកទីនេះ? បើខ្មែរគ្មានបញ្ហាផ្លូវចិត្តនោះទេ"។

នៅល្ងាចមួយបន្ទាប់ពី បានធ្វើសម្ភាសន៍ពេញមួយថ្ងៃ ដែលពោរពេញទៅដោយសេចក្តីទន្ទត់ និងខ្សោះកម្លាំង ខ្ញុំក៏សម្រាកលំហែរកាយនៅក្នុងខ្ទមឫស្សីតូចមួយ ដែលលោមព័ទ្ធទៅដោយដើមត្នោត និងដើមចេកដ៏ស្រស់បំព្រង។ នៅពេលដែលខ្ញុំបិទភ្នែកដើម្បីបន្ធូរអារម្មណ៍តានតឹងរបស់ខ្ញុំ រូបភាពនៃរឿងតក់ស្លុតដែលខ្ញុំបានឮនៅក្នុងថ្ងៃនេះបានលេចឡើងជោគជាំពេញក្នុងសតិរបស់ខ្ញុំ។ ខ្ញុំពុំអាចរំដោះខ្លួនចេញពីសម្រែកតប់ប្រមល់ និងអស់សង្ឃឹមដែលរីកធំឡើងៗ នៅពេលដែលជនភៀសខ្លួនបានរៀបរាប់ ពីរឿងរបស់គេអោយខ្ញុំស្តាប់បានឡើយ។ ខ្ញុំគ្មានវិធីអ្វីដែលអាចជួយគេបានឡើយ គេពុំត្រឹមតែរងទុក្ខវេទនានោះ ដោយអំពើព្រៃផ្សៃដែលពុំអាចបរិយាយបាន តែគេនៅតែទទួលរងទុក្ខវេទនានៅទីកន្លែងដែលគេសង្ឃឹមទុកថា ជាទីជម្រកការពារខ្លួន។ នៅពេលដែលខ្ញុំកំពុងតែដេកបិទភ្នែក ខ្ញុំស្រម៉ៃថាខ្លួនខ្ញុំឡើងតាមបង្អួចទៅលើជាងត្នោត ហើយសម្លឹងមើលទៅជុំរុំសាយធូ ខ្ញុំមានអារម្មណ៍ថា ខ្លួនខ្ញុំរអិល ហើយធ្លាក់ពីលើដើមត្នោត ស្លាប់បាត់បង់ជីវិត ពោរពេញទៅដោយសេចក្តីអស់សង្ឃឹម។ ខ្ញុំគិតថាខ្ញុំវង្វេងវង្វាន់ស្មារតីទាំងអស់នេះហើយ ខ្ញុំបានគិតថានៅក្នុងពេលនោះ ក្នុងនាមជាវេជ្ជបណ្ឌិតខ្ញុំពុំអាច

ព្យាបាលសេចក្ដីឈឺចាប់ និងទុក្ខវេទនានោះអោយជាសះស្បើយបានឡើយ។ មានចំនួនមនុស្សជាច្រើនពេក ដែលមានបទពិសោធន៍ដ៏តក់ស្លុត ក្នុងជីវិតបានរស់នៅក្នុងភាពដ៏ក្រីក្រជាទីបំផុតនៅក្នុងទីកន្លែងឃុំឃាំងនេះ។

ហើយខ្ញុំក៏យកចិត្តទុកដាក់ទៅនឹងភ្លេង ដែលខ្ញុំលេង ដើម្បីជួយលំហែអារម្មណ៍របស់ខ្ញុំ វាជាភ្លេងប្រជាប្រិយណេប៉ូលីតង់ ដែលមិត្តរបស់ខ្ញុំបានអោយមកខ្ញុំ។ ចំរៀងដ៏សាមញ្ញ មានរួមទាំងស្នេហា ទាំងម្ហូបអាហារអំពីម្ដាយ និងអំពីមាតុភូមិ បានច្រៀងតាំងពីយុគសម័យថ្មីអ៊ីតាលី ដែលបានជួយជនក្រីក្រាប់ជំនាន់អោយរួមផុតពីភាពកៀបសង្កត់ទុរគត និងភាពឃោរឃៅ ហើយបាននាំរូបខ្ញុំចុះមកផែនដីដោយសុវត្ថិភាព ពីព្រោះគេបានបង្ហាញ នូវប្រវត្តិក្រុមគ្រួសាររបស់ខ្ញុំផ្ទាល់ និងការស្រលាញ់ចូលចិត្តវប្បធម៌។ បទភ្លេងបានធ្វើអោយដួងជីវិតរបស់ខ្ញុំមានភាពរស់រវើកឡើងវិញ ដោយជឿថា ក្នុងនាមជាមនុស្ស និងជាវេជ្ជបណ្ឌិត ខ្ញុំអាចបង្កើតនូវឥទ្ធិពលល្អនៅក្នុងពិភពលោក ហើយជំនាញរបស់ខ្ញុំត្រូវការនៅទីកន្លែងមួយឡែក និងដ៏អស់សង្ឃឹមនេះដូចជាជុំរុំសាយធូ។ អ្វីដែលខ្ញុំពុំអាចមើលឃើញ តែក្នុងពេលឆាប់ៗ ខ្ញុំអាចរកឃើញការបរិច្ចាគរបស់ខ្ញុំដែល នឹងមិនពិបាកពេក ដូចជាខ្ញុំបានគិតទុកនោះឡើយ ដោយសារឥទ្ធិពល នៃការព្យាបាលមានកប់ទុកនៅក្នុងខ្លួនយើងគ្រប់រូប ទោះជាវាហិនហោចអស់ដោយ ក៏អំពើឃោរឃៅក៏ដោយ ក៏វានៅតែអាចរស់រានបាន ។ ឥទ្ធិពលព្យាបាលដដែលបានបង្វែរត្រចៀកខ្ញុំអោយទៅស្ដាប់ភ្លេង និងទាញខ្ញុំចេញពីដើមត្នោត និងផុតពីសេចក្ដីស្លាប់ ដែលបានស្ថិតនៅរួចជាស្រេចនៅក្នុងខ្លួនរបស់ប្រជាជននៅជុំរុំសាយធូ។

## ផ្នែក ១. ភាពព្យាបាលដោយខ្លួនឯង

ឥទ្ធិពល ដែលហៅថាភាពព្យាបាលដោយខ្លួនឯង ជាការឆ្លើយតបពីធម្មជាតិរបស់មនុស្ស ទៅលើជម្ងឺ និងរបួសផ្លូវចិត្ត។ វិធីដែលបរិយាយដោយលម្អិតទៅលើការព្យាបាលដោយខ្លួនឯង បានឃើញយ៉ាងច្បាស់នៅផ្នែកជាសះស្បើយរបួសរាងកាយ។ នៅពេលមួយរំពេចដែលរបួសកើតមានឡើង សរសៃឈាមបំប្រួញដើម្បីទប់ឈាមជាតិគីមី បញ្ជូនសារទៅជាលិកាផ្ដល់ជាសញ្ញាទៅកោសិកាពិសេស ដើម្បីចាប់ផ្ដើមដំណើរការរលាក។

ឈាមសហូរចូលទៅស្នាមរបួសនៅក្នុងកំឡុង២៤ម៉ោង ដើម្បីសម្លាប់មេរោគ ហើយចាប់ផ្ដើមដំណើរការលាង និងជួសជុលព្យាបាលជាលិកា។ ប្រព័ន្ធជាលិកាដែលមានសារជាតិសរសៃរ ខល់ឡាជីន(Collagen)បានតំរៀបគ្នាឡើង ហើយរមៀលសង្កត់ចូលគ្នាតាមមុខរបួសដែលដាច់រយ៉ៃ ដោយជួសជុលមុខរបួសតែវាពុំអាចធ្វើអោយល្អដូចដើមវិញ វាគ្រាន់តែអាចប្រើការបានវិញ។ កម្រិតជាសះស្បើយនៃភាពខូចខាត គឺអាស្រ័យទៅតាមថាតើដំណើរការព្យាបាលនេះជួយដល់ការព្យាបាលកម្រិតណាដែរនោះ។

ការព្យាបាលរបួសមនោសញ្ចេតនា ដែលធ្វើអោយឈឺចាប់នៅក្នុងសតិអារម្មណ៍ និងព្រលឹងដោយភាពឃោរឃៅ គឺជាដំណាក់ការធម្មជាតិ។ សតិអារម្មណ៍ និងរាង្គកាយភ្ជាប់គ្នាដោយឥទ្ធិពលខ្លាំង ចាប់ពីកម្រិតសារធាតុរហូតទៅដល់ការគិត និងចរិតក្នុងសង្គមរបស់មនុស្សម្នាក់ៗ។ សតិអារម្មណ៍ និងរាងកាយទាក់ទងគ្នាទៅវិញទៅមកដោយអំណាចព្យាបាលដោយខ្លួនឯង។ ក្រោយពីភាពឃោរឃៅចាប់ផ្ដើមកើតឡើង ដំណាក់ការព្យាបាល

ដោយខ្លួនឯងបានចាប់ផ្តើមឡើងមួយរំពេច ហើយការផ្លាស់ប្តូរតាមរយៈប្រតិកម្មតបរបស់រាង្គកាយ និងសតិអារម្មណ៍ទៅលើការខូចខាតដែលបានកើតឡើងក្នុងផ្លូវចិត្ត និងសង្គមរបស់អ្នកនោះ។ ឧទាហរណ៍ ការស៊ូទ្រាំរបស់បុគ្គលក្នុងគុកទារុណកម្ម ដូចជា ឈ្លើយសង្គ្រាមវៀតណាម ឬប្រជាជនដែលត្រូវគេឡោមព័ទ្ធបង្ខាំងនៅប្រទេស ស្សារ៉ាយ៉េវ៉ូ បានត្រូវគេដឹងឮយ៉ាងច្បាស់ថាប្រជាជន មួយចំនួនតូច បានជួបប្រទះ នឹងរោគវង្វេងស្មារតី និងចំនួនភាគច្រើនអាចទប់ទល់ នឹងការមិនមានរោគនានា និងមិនមានភាពទន់ខ្សោយ ផ្នែករាង្គកាយ រហូតដល់ដេកដួលដោយខ្វះជីវជាតិអាហារ ខ្វះទីជម្រក ឬរបួសដែលគ្មានការព្យាបាលនោះឡើយ។

វេជ្ជបណ្ឌិតណាកាស Nakas បានតាមសង្កេតមើលបាតុភូតនេះ ចំពោះអ្នកជម្ងឺរបស់គាត់នៅមន្ទីរពេទ្យស្សារ៉ាយ៉េវ៉ូ ថាអ្នកទាំងនោះពុំមានកើតជំងឺបៅក្លាយ ក្រោយពីការវះកាត់ដែលគាត់គិតថាវា នឹងកើតមានឡើងដោយការខ្វះខាតថ្នាំផ្សះ បន្ទាប់ពីការវះកាត់ពុំមានអនាម័យស្អាតនោះឡើយ។ តាមការសង្កេតមើលរបស់គាត់ "ប្រហែលជានៅពេលដែលយើងត្រូវបានទទួលការបង្ខិតបង្ខំ អោយស្ថិតនៅក្នុងស្ថានភាពតស៊ូ ដើម្បីរស់ ការតស៊ូទ្រាំទ្ររបស់យើងបានក្លាយទៅជាមានភាពខុសពីធម្មតាមួយដែលបង្កើតសម្ពាធទៅលើរាង្គកាយ និងចិត្តគំនិតរបស់យើង វាជាប្រតិកម្មតបមួយដែល ផ្នែកវិទ្យាសាស្ត្រពេទ្យ ក្នុងបច្ចុប្បន្នពុំទាន់ទទួលស្គាល់ពេញលេញនៅឡើយ"។

មានភស្តុតាងបង្ហាញនូវការព្យាបាលដោយខ្លួនឯងតាមកម្រិតជីវសាស្ត្រ ឬកម្រិតរាង្គកាយរបស់បុគ្គលក្រោយពីបានទទួលអំពើឃោរឃៅគ្រប់បែបយ៉ាង។ ការសិក្សាស្រាវជ្រាវបានបង្ហាញថា ពុំមានប្រតិកម្មតបជីវសាស្ត្រ ផ្សេងពីគ្នារវាងជនសាមញ្ញ និងជនដែលរួចផុតពីភាពតក់ស្លុតឡើយ។ រាង្គកាយរបស់មនុស្សមានរួមទាំងខួរក្បាល គឺរៀបចំឡើងអោយស្ថិតនៅក្នុងស្ថានភាពធម្មតា ដើម្បីធ្វើប្រតិកម្មតបទៅ នឹងអ្វីដែលគំរាមកំហែងដល់ការរស់រានក្នុងជីវិតរបស់គេ។ ទាំងនេះមានរួមទាំងប្រតិកម្មតបទៅ នឹងភាពតានតឹងអារម្មណ៍ជាធម្មតាហៅថា "វាយតប ឬរត់" ដែលបញ្ចេញសារជាតិអ័រម៉ូនមួយរំពេចដូចជា គ័រទីសុល Corticsol ដែលបញ្ជាអោយរាង្គកាយជងខ្លួនមួយរំពេចចេញពីគ្រោះថ្នាក់។ អ័រម៉ូនគ័រទីសុលជួយរក្សាលំ នឹងកម្លាំង បង្កើនការសំរើបស្មារតី ការចងចាំ និងការសិក្សា។ តែព្រឹត្តិការណ៍តក់ស្លុតខ្លះៗ ដែលមានសភាពធ្ងន់ធ្ងរពេក ប្រតិកម្មទៅ នឹងភាពតានតឹងអារម្មណ៍ពុំអាចបញ្ឈប់បានឡើយ។ ការបញ្ចេញអ័រម៉ូនគ័រទីសុលជាប់រហូត ដែលពេលខ្លះកើតមានខ្ពស់ឡើងនៅក្នុងបុគ្គលតក់ស្លុត បណ្តាលអោយមានរោគប្រព័ន្ធរំលាយអាហារ ដូចជារោគលើសឈាម រោគបេះដូង និងរោគប្រឆាំងសារជាតិអ៊ីនសូលីន។ ការបន្ថយប្រតិកម្មតបទៅ នឹងភាពតានតឹងអារម្មណ៍ ជាករណីសំខាន់ៗ ដើម្បីការពាររោគទាំងនេះ និងរោគរាង្គកាយផ្សេងៗទៀតកុំអោយកើតមានឡើង។

បច្ចុប្បន្ននេះ គេបានរកឃើញ វិធីប្រតិកម្មភាពព្យាបាលដោយខ្លួនឯងមួយផ្សេងៗទៀត ដែលអាចសម្រាលនូវប្រតិកម្មតប ដ៏ខ្ពស់ហួសចំពោះបញ្ហាតានតឹងនៃអារម្មណ៍។ សារជាតិ Dihydroepiandrosterone (DHEA) ជា ស្តេរយ Steroid អ័រម៉ូនមួយផ្សេងទៀត ដែលបានបង្ហាញថាអាចទប់ទល់ នឹងការយាយីអនុភាពរបស់គ័រទីសុល Cortisol ហើយមានអនុភាពល្អទៅលើអារម្មណ៍ នៅពេលដែលគេប្រើទៅលើមនុស្សដែលអាច

ទប់ទល់ទៅ នឹងភាពតានតឹងអារម្មណ៍។ សារជាតិ Betaendrophins មានអនុភាពដូចជា Opiatellike (សារជាតិបំបាត់ការឈឺចាប់) ក៏បញ្ចេញអនុភាពភ្លាមៗ ក្រោយពីមានភាពតក់ស្លុតកើតមានឡើង ដោយបន្ថយសេចក្តីឈឺចាប់ ផ្នែកសតិអារម្មណ៍ និងរាង្គកាយ។ មុខងាររបស់ neurotransmitter សារជាតិនេះ គឺនាំសាររវាងសរសៃប្រសាទ និងសារជាតិអ័រម៉ូន Hormone នៅក្នុងប្រតិកម្មតប និងការព្យាបាល ដោយខ្លួនឯង ដូចជាសារជាតិដែលបញ្ចេញអ័រម៉ូន Corticotropin-releasing hormone (CRH), dopamine, neuropeptide x, Galanin, serotonin, testosterone និង estrogen ដែលទើបតែចាប់ផ្តើមទទួលស្គាល់ថាមានប្រសិទ្ធិភាពពិតប្រាកដ។

វិទ្យាសាស្ត្របានបរិយាយអំពីចរន្ត នៃសរសៃប្រសាទ ដែលជាមូលដ្ឋានបង្កើតសេចក្តីចងចាំ នៃភាពតក់ស្លុត បានរីកចំរើនយ៉ាងឿនលឿន យ៉ាងធំសម្បើម។ អ្នកវិទ្យាសាស្ត្រ ផ្នែកសរសៃប្រសាទបានផ្តល់នូវប្រាជ្ញាភ្លឺថ្លា ទៅលើការចង់ក្រងសេចក្តីចងចាំភាពតក់ស្លុតនៅក្នុងខួរក្បាល ទំនាក់ទំនងរវាងការចងចាំនេះទៅនឹងអារម្មណ៍ ទៅនឹងសុបិន្តតក់ស្លុត និងសុបិន្តអាក្រក់ តួនាទីរបស់ការចងចាំក្នុងការព្យាបាលតាមរយៈការបរិយាយអំពីរឿងតក់ស្លុត និងលទ្ធភាពដែលអាចសម្គាល់រកឃើញការចងចាំ ដែលបំផ្លិចបំផ្លាញរាង្គកាយ និងសតិអារម្មណ៍ វាជាការសំខាន់ដែលត្រូវយល់អំពីរបៀបដែលជាសេចក្តីចងចាំចាប់ផ្តើមកើតឡើង ដោយវាជាករណីចាំបាច់ក្នុងការសិក្សា ការសម្របសម្រួលទៅ នឹងបទពិសោធន៍ក្នុងជីវិត និងការវិវឌ្ឍន៍ ផ្នែកអាកប្បកិរិយា។ ចំណុចសំខាន់ៗរបស់មនុស្សលោក គឺសេចក្តីចងចាំបទពិសោធន៍ដែលបង្កបង្កើតប្រវត្តិជីវិតរបស់គេ ដោយមានរួមទាំងការចងចាំទៅលើហេតុការណ៍តក់ស្លុត និងសោកនាដកម្មក្នុងជីវិត។

ឃើញថាមានកន្លែងពីរផ្នែកនៅក្នុងខួរក្បាលសម្រាប់ផ្ទុកសេចក្តីចងចាំតក់ស្លុត ផ្នែកមួយហៅថាស្រោមជាពាក្យដែលប្រើតាមពាក្យស្រោមខួរក្បាល ជាចំណែកមួយ ផ្នែកនៃខួរក្បាលដែលទាក់ទងទៅ នឹងស្មារតី។ ផ្នែកនេះបង្កើត *សេចក្តីចងចាំថ្លែងប្រាប់* ដែលផ្ទុកកត្តាពិតថ្មី និងហេតុការណ៍ថ្មីទាក់ទង នឹងស្មារតីរលឹកឡើងវិញទៅលើការសិក្សា និងការចងចាំពីពេលមុន។ សេចក្តីចងចាំថ្លែងប្រាប់ថា Hoppocampus (ការចងចាំយូរលង់) កណ្តាលខួរក្បាល។ នៅក្នុងស្ថានភាពកត់ស្លុត និងស្ថានភាពមានគ្រោះថ្នាក់ ជាពិសេសហេតុការណ៍ដែលធ្វើអោយតក់ស្លុត ភាពចងចាំផ្សេងទៀត បានបង្កើតឡើងហៅថា *សេចក្តីចងចាំរំជួលចិត្ត* ការចងចាំបែបនេះមានក្នុង Amygdala ដែលមានរាងដូចជាផ្លែអាល់មន់ Almond ជាប់ នឹង Hippocampus ពាក់កណ្តាលខួរក្បាល។ ការចងចាំរំជួលចិត្តការបកស្រាយអារម្មណ៍ទោរទន់ ដោយគ្មានមនសិការដែលទាក់ទងទៅ នឹងបទពិសោធន៍ប៉ះពាល់ដោយចរិត ដែលធ្វើឡើងដោយសេចក្តីប៉ងប្រាថ្នា។ Amygdala មណ្ឌលបញ្ជាប្រតិកម្មតប និងការភ័យខ្លាចនៅក្នុងខួរក្បាល ហើយវាពុំរង់ចាំគំនិតមនសិការឡើយ វាមាននៅផ្នែក Cortex (ខួរក្បាលខាងមុខ) វាសម្រេចថាតើសេចក្តីគំរាមនោះជាភាពពិត ឬពុំពិត។ Amygdala អាចបញ្ជាប្រតិកម្មតបទៅ នឹងភាពអាសន្ន នៅក្នុងកំឡុងមួយវិនាទី ដោយបញ្ជាអោយប្រព័ន្ធប្រតិកម្មតប នឹងភាពតានតឹងអារម្មណ៍ចាប់ដំណើរការឡើង។

នៅពេលដែលសេចក្តីចងចាំថ្លែងប្រាប់ថាបានផ្ទុកសេចក្តី លម្អិតហេតុការណ៍តក់ស្លុត ទុកជាកត្តាពិតអារម្មណ៍រំភើបចិត្តក្រៃលែង ដែលទាក់ទងទៅ នឹងហេតុការណ៍នេះ បានចាត់ទុកថាហេតុការណ៍នេះ ជាសេចក្តី

ចងចាំរំជួលអារម្មណ៍។ ឧទាហរណ៍ អ្នកជម្ងឺម្នាក់ ដែលខ្ញុំព្យាបាលបានរងរបួសដោយចោរប្លន់ ចោរប្លន់នោះបានមកគោះទ្វារខ្លាំងៗ ហើយចុចកណ្ដឹងទ្វារផ្ទះផ្ទួនៗ ដើម្បីចូលទៅក្នុងបន្ទប់ជួល។ សេចក្ដីចងចាំថ្លែងប្រាប់ថាបានធ្វើអោយគាត់ចងចាំទឹកមុខចោរដែលប្លន់គាត់ កំណត់ពេលដែលបានកើតឡើង និងវត្ថុដែលគេប្លន់យក និងប្រតិកម្មកូនរបស់គាត់ទៅលើហេតុការណ៍នោះ។ សេចក្ដីចងចាំដោយរំជួលអារម្មណ៍របស់គាត់ ធ្វើអោយគាត់ទៅជាតានតឹងអារម្មណ៍ និងភ័យខ្លាចដោយជីពចរដើរញាប់ និងបែកញើស នៅពេលណាដែលមានគេចុចកណ្ដឹងទ្វារ ឬគោះទ្វារ ប្រព័ន្ធទាំងពីរនេះមានជាតុផ្សំទៅដោយកត្តាពិត និងអារម្មណ៍រំភើបចិតដែលបង្កើតស្ថានភាពបណ្ដាលអោយអ្នកជម្ងឺក្លាយទៅជាអ្នកជាប់គុកតក់ស្លុតនៅក្នុងបន្ទប់ជួលរបស់ខ្លួន។

គួរអោយសោកស្ដាយណាស់ដោយហេតុការណ៍តក់ស្លុត អាចបង្កើតនូវការចងចាំរំជួលអារម្មណ៍នៅក្នុងផ្នែក Amygdala ដែលរំលឹកឡើងវិញជាញឹកញាប់ហើយពិបាកបំភ្លេចចោល។ មនុស្សហាក់បីដូចជា ពុំអាចទប់ស្កាត់ស្មារតីទៅលើសេចក្ដីចងចាំដោយរំជួលអារម្មណ៍។ ហេតុនេះហើយបានជាភាពតក់ស្លុតរំជួលអារម្មណ៍ មានរួមទៅដោយភាពនឹកឃើញមួយភ្លែតៗ និងមជ្ឈដ្ឋានសម្គាល់ប្រភពដើមនៃភាពតក់ស្លុត អាចមានអានុភាពទៅលើអ្នករស់រួចផុតពីសេចក្ដីស្លាប់។ មធ្យោបាយព្យាបាលត្រឹមត្រូវទៅលើសេចក្ដីចងចាំរំជួលអារម្មណ៍ គឺជៀសវាងកុំធ្វើអោយភាពរំជួលចិត្តនៅក្នុងផ្នែក Amygdala កើតមានឡើង និងធ្វើអោយផ្នែក Cortex បញ្ចូលស្មារតីទប់ស្កាត់ការរំលឹកហេតុការណ៍តក់ស្លុតឡើងវិញ។ ការអធិប្បាយរឿងតក់ស្លុតត្រឹមត្រូវអាចធ្វើអោយសេចក្ដីចងចាំថ្លែងប្រាប់កើតមានឡើង ដោយធ្វើអោយបញ្ចេញសេចក្ដីគិតសមហេតុផល អំពីស្ថានភាពតក់ស្លុតព្រមគ្នានោះវាក៏ទប់អារម្មណ៍ទោរទន់ខ្លាំងនោះចោលមួយរយៈសិន។ មធ្យោបាយនេះអាចបណ្ដាលអោយបន្ថយ ឬបំបាត់ការចងចាំដែលដក់ជាប់ក្រៅអត្ថន័យសម្របសម្រួល។

ការព្យាបាលដោយខ្លួនឯងក៏កើតមានឡើងនៅកម្រិតចិត្តសាស្ត្រ នៅពេលដែលគំនិត អាចបង្កើតអត្ថន័យថ្មី ចេញពីភាពឃោរឃៅ នៅចំណុចនោះអាកប្បកិរិយាក៏លេចចេញឡើង ដើម្បីជួយបុគ្គល តក់ស្លុតលៃលកដោះស្រាយអារម្មណ៍អាម៉ាស់មុខកំហឹង និងសេចក្ដីអស់សង្ឃឹមរបស់ខ្លួន។ អារម្មណ៍ និងសកម្មភាពពុំកើតឡើងដោយស្វ័យប្រវត្តិចេញពីខ្លួនយើងនោះទេ តែវាបញ្ចេញឡើងដោយ យោងទៅតាមជំនឿដែលគេបានរៀនសូត្រ និងអត្ថន័យដែលផ្គុំគ្នាជាប្រព័ន្ធតែមួយដូចជាកញ្ចុំផ្កាយ។ គំនិតរបស់ទស្សនវិទូ "ពិភពជីវិត" បរិយាយអំពីធម្មជាតិរបស់មនុស្ស និងសុភនិច្ឆ័យនៃពិភពលោកដែលមានរួមដោយបទពិសោធន៍គ្រប់យ៉ាងដែលបានកើតឡើងចំពោះរូបគេ។ ទោះជាបុគ្គលនោះមកពីវប្បធម៌ ឬមុខវិជ្ជាជីវៈខុសៗគ្នា ដូចជាកសិករ និងតន្ត្រីករ ដែលនឹងប្រកបវិជ្ជាជីវៈខុសគ្នានៅក្នុងជីវិតរបស់គេ ក៏ជីវិតរបស់ពួកគេមានភាពប្រហាក់ប្រហែលគ្នាបើសិនជាពួកគេជឿជាក់ទៅលើភាពស្មើគ្នា ភាពសុច្ចរិត និងភាពសមហេតុផលនៅក្នុងជីវិត។ ហើយនៅពេលដែលអំពើឃោរឃៅកើតមានឡើង ពិភពលោកនេះត្រូវប្រានចូលទៅក្នុងភាពតក់ស្លុត ដោយអ្វីៗ ដែលបានកើតឡើងនោះមានភាពហួសពីការស្មានរបស់គេ។ គេគិតថា "ហេតុអ្វីក៏រឿងអាក្រក់នេះកើតមានឡើងដល់រូបខ្ញុំ!" ជនល្មើស គឺរង់ចាំនូវប្រតិកម្មភាពភ័ន្តនេះដើម្បីធ្វើអំពើអាក្រក់។

គេរង់ចាំភាពអាម៉ាស់មុខខ្លាំងដែលគ្របដណ្តប់លើជីវិតរបស់មនុស្ស និងលុបបំបាត់នូវមនោសញ្ចេតនាទាំងពួង ជាពិសេស សេចក្តីសង្ឃឹម និងសេចក្តីរីករាយ។ នៅករណីខ្លះៗ អំពើឃោរឃៅនេះមានឥទ្ធិពលតិចតួច ហើយអាចជួសជុលដោយងាយស្រួល ករណីខ្លះៗទៀត ជាពិសេស ការឃោរឃៅ គឺហួសកម្រិត នឹងអ្វីៗ ដែលបុគ្គលនោះជឿជាក់ ទៅលើត្រូវបានបំផ្លាញចោល។ ការព្យាបាលខ្លួនឯងខាង ផ្លូវចិត្តបានចាប់ផ្តើមឡើង ដោយស្តារពិភពជីវិតអតីតកាលឡើងវិញ ឬជាទូទៅបានបង្កើតជីវិតពិភពថ្មីមួយទៀត។

ខ្លឹមសារទិដ្ឋភាពចិត្តសាស្ត្រនៃការធ្វើដោយខ្លួនឯង គឺការប្តេជ្ញាដើម្បីរស់ និងភាពជាសះស្បើយឡើងវិញ បុគ្គល អាចធ្វើការសម្រេចចិត្តគ្រប់បែបយ៉ាង ដើម្បី មិនបណ្តោលអោយ អំពើដល់ឃោរឃៅមានជ័យជំនះលើរូបគេបាន។ ខ្ញុំបានឃើញទិដ្ឋភាពនៃការធ្វើអោយខ្លួនឯងភាពជាសះស្បើយទុក្ខនៅសាយធូរបស់ក្មេងប្រុសម្នាក់អាយុ១៦ ឆ្នាំ ឈ្មោះ ជាម រឿន Chiem Rouen ដែលបានបាត់បង់អ្វីទាំងអស់៖ ក្រុមគ្រួសាររបស់គាត់ ផ្ទះសម្បែង មិត្តភក្តិ ទាហ៊ានរបស់គាត់ ថែមទាំងភ្នែករបស់គាត់ទៀត។ នៅពេលដែលខ្ញុំចូលទៅក្នុងបន្ទប់តូចរបស់គាត់នៅក្នុងមន្ទីរពេទ្យ គាត់ដើរដោយកាន់ដៃគិលានុប្បដ្ឋាយិការ។ ភ្នែកខូចរបស់គាត់រុំដោយបង់រុំរបួសធំមួយបន្ទះ ទិដ្ឋភាពដ៏អាណោចអាធ័មនេះ ធ្វើអោយខ្ញុំគិតថា តើវេជ្ជបណ្ឌិតនិយាយជាមួយវាបែបណាទៅ ឬតើមានថ្នាំពេទ្យអ្វីទៅដែលអាចជួយគាត់បាន។ ហើយជាសំណាងល្អនៅពេលនោះគាត់ដើរមករក ហើយវាខ្សឹមប្រាប់ខ្ញុំថា "កុំព្រួយលោកដុកទ័រ ថាខ្ញុំនឹងជាវិញ" ក្រោយពីគាត់បានពន្យល់ប្រាប់ថា ប៉ុលពតបានសម្លាប់ក្រុមគ្រួសាររបស់គាត់ ហើយមេបញ្ជាការទាហ៊ានបានយកគាត់ទៅរស់ នៅជាមួយជាសមាជិកក្រុមគ្រួសារថ្មី ហើយគេបានបណ្តេញគាត់ចេញភ្លាមនៅខណៈដែលគាត់រងរបួស គាត់បានអធិប្បាយ អំពីជីវិតថ្មីដែលគាត់កំពុងតែបង្កើតឡើង។ ដោយសេចក្តីផ្តោតអារម្មណ៍ទៅលើចំណេះវិជ្ជា ដែលគាត់អាចចាប់ផ្តើមឡើងនៅមន្ទីរព្យាបាលនេះ គាត់សង្ឃឹមថា នឹងរស់នៅក្នុងជីវិតប្រកបដោយលទ្ធភាព ទោះបីជាគាត់ខ្វាក់ភ្នែកក៏ដោយ។

សេចក្តីជម្រុញអោយគាត់ព្យាយាមសិក្សាកើតឡើង ដោយការប្រឹងប្រែងរបស់គាត់ ក្នុងការធ្វើអោយជាដោយខ្លួនឯង។ ក្មេងប្រុសនេះឃើញអនាគតដែលអ្នកដទៃទៀត ពុំអាចនឹកស្រម៉ៃឃើញ លុះត្រាតែគេបាន ឮគាត់និយាយប្រាប់ដោយផ្ទាល់មាត់។ ភាពសុទិដ្ឋិនិយម(ភាពសុទ្ធតែល្អ) របស់គាត់ធ្វើអោយបុគ្គលិកទាំងអស់ជួយជ្រោមជ្រែងនៅក្នុងគោលដៅសិក្សារបស់គាត់។

ចំពោះជនតក់ស្លុត ការតស៊ូច្រើនតែកើតឡើងរវាងគំនិតបំផ្លាញ និងអារម្មណ៍រំជួលដែលកើតឡើងដោយអំពើឃោរឃៅ និងការពិចារណា ចាំបាច់ឡើងវិញទៅលើអត្ថន័យ បទពិសោធន៍ នៃអំពើឃោរឃៅ ។ ឧទាហរណ៍ ឈ្មោះ ទ្រឹង Truong អតីតយោធាវៀតណាម ដែលជាប់គុកជាឈ្លើយសង្គ្រាមនៅក្នុងរបបកុម្មុយនីស រដ្ឋាភិបាលវៀតណាមចំនួនជាងដប់ឆ្នាំ បានលាតត្រដាងនូវការប្រយុទ្ធវាយប្រហារដោយបញ្ចេញស្នាមញញឹមទាំងញ័រញាក់ ដែលគាត់ច្រើនតែមាននៅលើទឹកមុខរបស់គាត់។

គាត់ពុំចេះភាសាអង់គ្លេសទេ ហើយគាត់និយាយភាសាវៀតណាម ឮតែខ្សឹបៗ យឺតៗ ប្រកបដោយសេចក្តីគោរព។ គាត់ជាបុរសសុភាពរាបសារម្នាក់ជំនាន់ ឆ្នាំចិតសិប ដែលបានទទួលការ "អប់រំកសាងឡើងវិញ" ដោយ

ពួកកុម្មុយនីស ពេលនេះគាត់រស់នៅឯកោដោយគ្មានសេចក្តីស្រលាញ់ក្នុងខ្លួន ចំនួន១០ឆ្នាំ គាត់បានថ្លែងអះអាងថាគោលដៅ "គ្រូបង្រៀន" របស់ពួកវា គឺប្រើល្បិចដែលគេធ្វើអោយជីវិតរបស់គាត់គ្មានតម្លៃ ហើយគេពិតជាបានសម្រេចជោគជ័យនេះបានយ៉ាងពិតប្រាកដមែន។ ដោយពួកវាយកគាត់យកចេញពីសមាជិកក្រុមគ្រួសារបង្កើតរបស់គាត់យូរពេលពេកបានធ្វើអោយក្រុមគ្រួសាររបស់គាត់បោះបង់រូបគាត់ចោល ។ នៅពេលដែលគេដោះលែងរូបគាត់ ញាតិសន្តានផ្សេងៗទៀត បានយកគាត់មករស់នៅសហរដ្ឋអាមេរិក តែបច្ចុប្បន្ននេះ ទំនាក់ទំនងតែមួយគត់ដែលគាត់មានជាមួយអ្នកដទៃ គឺនៅព្រះវិហារ កាត់តូលិក Catholic គាត់ធ្វើការបេន់ស្រន់ជារៀងរាល់ថ្ងៃនៅផ្ទះ ហើយចូលរួមនៅក្នុងការថ្វាយបង្គំព្រះពីរដងក្នុងមួយអាទិត្យ ។

នៅពេលដែលទ្រង់អធិប្បាយអំពីជីវិតបច្ចុប្បន្នរបស់គាត់ ភាពតានតឹងរវាងអារម្មណ៍អស់សង្ឃឹមរបស់គាត់ និងជំនឿទៅលើព្រះ មានសភាពហាក់បីដូចអាចទទួលអារម្មណ៍យល់ដឹងបាន។ ការបរិយាយរឿងរបស់គាត់ជាទាហ៊ានវៀតណាមវ័យក្មេង ដើរយ៉ាងសង្ហា នៅក្នុងព្យូហយាត្រាទ័ពនៅទីក្រុងព្រៃនគរ ក្នុងនាមជាសមាជិកឃាមល្បាតកាន់ទង់ជ័យ ដើរជួរមុខម្នាក់មានភាពខុសស្រឡះពីរូបភាពដែលគាត់គូរពីការវាយដំដោយឥតត្រាប្រណី និងការធ្វើអោយអាប់យសនៅក្នុងជញ្ជាំងគុកទារុណកម្មរបស់កុម្មុយនីស។ កិត្តិយស និងបុណ្យសក្តិពីមុនត្រូវបាត់បង់អស់រលីង តែគាត់បានរកវាឃើញឡើងវិញនៅពេលដែលគាត់លុតជង្គង់អធិស្ឋាននៅក្នុងព្រះវិហារ។ ទ្រង់កំពុងតែជួបប្រទះ និងភាពកើតទុក្ខ គាត់មានអារម្មណ៍ថា បើសិនជាគាត់បោះបង់ជំនឿរបស់ខ្លួនគាត់ នឹងស្លាប់ សមត្ថភាពនៃតុល្យភាពរបស់គាត់ ទោះជាយ៉ាងណាក៏ដោយ ក៏វាជាករណី បណ្តោះអាសន្ន។

ជម្ងឺធ្លាក់ទឹកចិត្ត(Depression)របស់គាត់ជាមួយនឹងជំនឿដ៏ពិសិដ្ឋរបស់គាត់ "ភាពប្តេជ្ញាបរិសុទ្ធ" បានរាំងគាត់កុំអោយធ្វើអត្តឃាតខ្លួនគាត់ ទោះជាគាត់ទទួលស្គាល់ថាជារៀងរាល់ថ្ងៃគាត់សញ្ជឹងគិតពីរឿងធ្វើអត្តឃាតខ្លួន។ ខណៈពេលដែលវេជ្ជបណ្ឌិតជាច្រើន អាចយល់ថាលក្ខណៈសញ្ញារោគរបស់បុរសនេះ ត្រូវការសេវា ផ្នែកសតិអារម្មណ៍ជាបន្ទាន់ គាត់អាចមានជីវិតរស់រានដោយខ្លួនគាត់តាមបែបបទអធិស្ឋានរបស់គាត់ ក្នុងទម្រង់បែបបទព្យាបាលដោយខ្លួនឯង។ គាត់បានចូលរួមយ៉ាងសកម្ម និងជម្រុញខ្លួនគាត់ជាខ្លាំងអោយប្រឹងប្រែងរស់នៅជាមនុស្ស ដោយបានផ្លាស់ប្តូរអត្តសញ្ញាណរបស់គាត់ពីភាព "ជីវិតគ្មានន័យ" ទៅជាជនម្នាក់ដែលមានន័យក្នុងជីវិតនៅចំពោះចក្ខុរបស់ព្រះ។

ការធ្វើព្យាបាលខ្លួនឯងមានការពាក់ព័ន្ធជាមួយ នឹងកត្តាពិតនៃសង្គម និងកត្តាពិតនៃសតិអារម្មណ៍ មនុស្សលោកជ្រើសរើសយកសកម្មភាពសង្គមគ្រប់បែប ដើម្បីនឹងជួសជុលជីវិតខូចខាតរបស់ខ្លួន ក្រោយពីអំពើឃោរឃៅបានកើតមានឡើង ទោះជាមានសេចក្តីភ័យខ្លាច ភាពចាត់ទុកជាទុរយស និងភាពឯកោដែលធ្វើអោយអ្នករួចផុតពីសេចក្តីស្លាប់ ពិបាកមានការ នឹងចូលរួមនៅក្នុងសកម្មភាពសង្គមផ្សេងៗ។ ឥរិយាបទល្អនៅក្នុងសង្គមដូចជា ការគិតដល់ប្រយោជន៍អ្នកដទៃ (បរត្ថភាព)ការងារ និងការចូលរួមខាងផ្នែកព្រលឹងវិញ្ញាណធ្វើអោយដំណើរការផ្នែកសរសៃប្រសាទមានភាពប្រសើរឡើង ដោយវាជួយធ្វើអោយសុខភាពបានល្អឡើង និងបន្ថយផលវិបាកដែលកើតឡើងដោយភាពតានតឹងអារម្មណ៍។ អាកប្បកិរិយាទាំងនេះ និងអ្វីផ្សេងៗ ទៀត ដូចជា ការ

និយាយកំប្លែងលេងសើច ការគាំទ្រផ្នែកសង្គម និងការហាត់ប្រាណដោយកាយវប្បកម្ម ជួយអោយសតិអារម្មណ៍របស់បុគ្គលបានជាសះស្បើយ។

ផងដែរទោរុណកម្ម និងអំពើឃោរឃៅបែបផ្សេងៗ អាចមានប្រសិទ្ធិភាពអាក្រក់ទៅលើប្រព័ន្ធរបស់សេរីរាង្គ ភាពសំណាងដោយសកម្មភាពសង្គមក៏អាចមានឥទ្ធិពលល្អកម្រិតស្មើគ្នាទៅលើរាង្គកាយ និងសតិអារម្មណ៍ដែរ ។ កត្តាពិតនៃសង្គមទៅលើភាពព្យាបាលដោយខ្លួនឯងបានផុសឡើងយ៉ាងច្បាស់នៅជុំរុំសាយធូ ដែលជាទីកន្លែងដ៏លំបាកវេទនាបំផុតរបស់មនុស្សជាតិ អ្នករស់ក្នុងជុំរុំបានតស៊ូជាខ្លាំងដើម្បីរស់។ ដូចជា ព្រះភិក្ខុព្រះនាម ម៉ូនីចិន្តា Mony Chenda ជាព្រះសង្ឃមានព្រះជន្មក្មេងមួយអង្គដែលរស់នៅក្នុងជុំរុំព្រះអង្គមានព្រះពុទ្ធដីការ ថា "ទោះជាស្ថានភាពនៅសាយធូអាក្រក់យ៉ាងណាក៏ដោយសកម្មភាពប្តូផ្តាច់ទៅលើជីវិតរបស់ជនជាតិខ្មែរជុំរុំសាយធូ គឺជា ជុំរុំនៃសេចក្តីសង្ឃឹម"។

ជនភៀសខ្លួនរស់នៅជុំរុំសាយធូ ស្ទើរតែពេញ មួយទសវត្សរ(១០ឆ្នាំ) គឺជាទីកន្លែងពោរពេញទៅដោយភាពទុរគតសាហាវឃោរឃៅ ជាទីកន្លែងដែលអ្នកជាប់ទោស ត្រូវគេហាមមិនអោយប្រកបការងារ សិក្សារៀនសូត្រ ឬគោរពសាសនា។ នៅក្នុងពេលដែលជីវភាពរស់នៅយ៉ាងបង្ខំក្លាយទៅជាបន្ទុករបស់អ្នកដទៃ ប្រជាជនក្នុងជុំរុំបានទទួលនូវឈ្មោះថ្មី ស្ទើរតែជាសកលពីអាជ្ញាធរ និងបុគ្គលិកសង្គ្រោះថាជាប្រជាជនខ្ជិលច្រអូស គ្មានចេះដឹងគុណគេ និងគ្មានការខ្នះខ្នែងប្រឹងប្រែងឡើយ ។ មន្ត្រីទាំងនោះយល់ថា ជនភៀសខ្លួនបានរួចផុតពីអំពើសម្លាប់រង្គាលរបស់ប៉ុលពត ហើយនៅពេលបច្ចុប្បន្ននេះគ្មានធ្វើអ្វី ដើម្បីជួយខ្លួនឯងសោះ ។ ភាពពិតបានបង្ហាញថាសេចក្តីយល់ឃើញរបស់មន្ត្រីទាំងនេះ គឺខុសទាំងស្រុង នៅពេលដែលយើងចូលទៅក្នុងជុំរុំ យើងបានធ្វើសម្ភាសន៍ប្រជាជន យើងគ្មានឃើញមនុស្សណាម្នាក់នៅផ្ទះឡើយ។ បន្តិចម្តងៗ ជីវិតសម្ងាត់នៃសង្គមចាប់ផុសលេចឡើងដោយការខិតខំខុសច្បាប់ ដែលជាញឹកញាប់ច្រើនកើតមានឡើងនៅក្នុងជុំរុំឃុំឃាំងអ្នកជាប់ទោសដោយសង្គ្រាម។ ប្រជាជននាំគ្នាចាកចេញពីផ្ទះរកវិធីគ្រប់យ៉ាង និងធ្វើអ្វីៗ គ្រប់បែបដើម្បីរស់ អ្នកខ្លះជួញដូរសត្វមាន់ អ្នកខ្លះធ្វើជាស្រីពេស្យា អ្នកខ្លះមើលក្មេង អ្នកខ្លះឱបបុគ្គលិកសង្គ្រោះតាមកង់ចុះឡើងដោយយកកំរៃ ហើយអ្នកខ្លះលួចចេញទៅក្រៅជុំរុំ ដើម្បីរកអូសមកដាំស្ល ។ មានសកម្មភាពជាច្រើនកើតមានឡើង តែអាជ្ញាធរគ្មានចាប់អារម្មណ៍ឡើយ។ ផ្ទុយ នឹងការបន្ទាន់ទៅតាមកាលៈទេសៈ ប្រជាជនចូលធ្វើការ ដោយចូលរួមក្នុងសកម្មភាពបរត្តភាព (គិតឃើញប្រយោជន៍អ្នកដទៃ) និងនូវបន្តទំនៀមទម្លាប់សាសនាដោយសម្ងាត់ សកម្មភាពសង្គមទាំងអស់ដែលមានអត្ថប្រយោជន៍ដល់សុខភាព និងសុខុមាលភាពរបស់គេ។

ប្រជាជនរស់នៅក្នុងផ្ទះដ៏ចង្អៀត តែគេនៅតែទទួល "ចិញ្ចឹម" អ្នកគ្មានផ្ទះសម្បែង និងក្មេងអនាថា កូនក្មេងនៅក្នុងជុំរុំសាយធូជា "កូនរបស់គ្រួសារណាមួយជានិច្ច"។ ការថ្វាយបង្គំព្រះ និងកម្មវិធីព្រះពុទ្ធសាសនា និងពិធីបុណ្យនានា បានប្រារព្ធឡើងដោយសម្ងាត់នៅ ស្ទើរតែគ្រប់ផ្ទះទាំងអស់ ទោះបីជា នៅពេលគេចាប់បានគ្រួសារនោះ នឹងត្រូវគេធ្វើទណ្ឌកម្មដោយវាយដំ និងបន្ថយកំណាត់របបអាហារក៏ដោយ។

សេចក្តីលាតត្រដាងមួយទៀត ទៅលើភាពព្យាបាលដោយខ្លួនឯង កើតមានឡើងនៅពេលដែលគេសួរប្រជាជនរស់នៅសាយធូអំពីការថែទាំខ្លួនប្រកបដោយអនាម័យចំបាច់ ។ គេនាំគ្នាសើចទៅលើសំណួរនេះ ផ្ទុយទៅ នឹងកត្តាពិត ប្រជាជនម្នាក់ៗ បានទទួលសំលៀកបំពាក់ពីរទៅបីបន្លាស់ សាប៊ូតិចតួច និងទឹកមួយធុងរៀងរាល់ពីអាទិត្យ ទោះបីជាពួកគេក្រយ៉ាងណាក៏ដោយ ប្រជាជនគ្រប់រូបបានថែទាំខ្លួនគេ និងកូនចៅរបស់គេ ដោយអនាម័យទៅតាមសេចក្តីត្រូវការ ។ គេកក់សក់ ដុះធ្មេញ ហើយស្ត្រីៗ បានផ្ចិតផ្ចង់ និងប្រយ័ត្នប្រយែងទៅលើអនាម័យស្ត្រីភេទ។ ការព្យាបាលដោយខ្លួនឯង ស្បើយទុក្ខកើតមានឡើងដោយវិធីផ្សេងៗ ជារៀងរាល់ថ្ងៃខ្លះដោយការបញ្ចេញអោយឃើញ ខ្លះទៀតដោយភាពលាក់អាថ៌កំបាំង។

## ១.២ ជំនួយទៅលើការព្យាបាលដោយធម្មជាតិ

កាលពីជំនាន់មុនវិជ្ជាសាស្ត្រពេទ្យសម័យ ការព្យាបាលដោយខ្លួនឯងជាឥទ្ធិពលព្យាបាលសំខាន់ ក្នុងការថែទាំមនុស្សឈឺ។ វេជ្ជបណ្ឌិតបុរាណដឹងអំពីឥទ្ធិពលព្យាបាលដោយធម្មជាតិនេះ ហើយបានត្រូវគេរៀបរាប់ជាភាសាឡាតាំងថា Vis medicatrix natuae ឬឥទ្ធិពលព្យាបាលដោយធម្មជាតិ។ គេដឹងថាតួនាទីរបស់គេ គឺពុំមែនបង្កើនកម្លាំងអ្នកជម្ងឺដោយប្រើថ្នាំពេទ្យ ឬបង្ខំអោយអ្នកជម្ងឺត្រូវតែទទួលព្យាបាលតាមខ្លួនគេឡើយ តែគេត្រូវសហការជាមួយ នឹងអ្នកជម្ងឺដោយប្រើឥទ្ធិពលព្យាបាលដោយធម្មជាតិ ដែលចាប់ផ្តើមឡើងក្រោយពីរោគា ឬរបួស។

គេបានបង្កើតវិធីគាំទ្រ និងពង្រឹងឥទ្ធិពលទាំងនេះដើម្បីព្យាបាលទុកកង្វល់រាង្គកាយ និងសតិអារម្មណ៍ ឬយ៉ាងហោចណាស់ក៏ជួយសម្រួលឥទ្ធិពលភាពពិការ និងពន្យារមរណភាព។ ដោយវេជ្ជបណ្ឌិតបុរាណការយល់ដឹងជាការលាតត្រដាងរោគា គេអាចផ្តល់យោបល់ទៅលើថ្នាំព្យាបាល ចំណីអាហារ និងការផ្លាស់ប្តូរទម្លាប់របៀបរស់នៅដែលគេដឹងថា នឹងពិតជាធ្វើអោយជាសះស្បើយ ឬបន្ថយការឈឺចាប់។ ហើយគេនៅយ៉ាងជាប់លាប់ជាមួយ នឹងអ្នកជម្ងឺ ដោយដំណើរការព្យាបាលធ្វើឡើងជាសាធារណៈស្ទើរទាំងអស់ទៅហើយនោះ វេជ្ជបណ្ឌិតបានទទួលការលើកទឹកចិត្តដ៏អស្ចារ្យក្នុងការបង្កើតលទ្ធផលល្អ ដោយហេតុនេះគេអាចរក្សាកេរ្តិ៍ឈ្មោះល្អរបស់គេ។

ទម្លាប់បែបនេះ នៅមានរហូតមកទល់សព្វថ្ងៃ ចំពោះប្រជាជនដែលពុំទទួល វិជ្ជាសាស្ត្រពេទ្យសម័យ មានរួមទៅដោយសហគមន៍ ដែលគ្មានសិទ្ធិទទួលសេវា ផ្នែកពេទ្យនៅសហរដ្ឋអាមេរិក និងអ៊ឺរ៉ុប។ អ្នកជម្ងឺដែលពុំអាចរកវេជ្ជបណ្ឌិត ឬគ្រឹះស្ថានសម័យបានប្រើគ្រូបុរាណព្យាបាលជម្ងឺរបស់គេ។ ថ្នាំព្យាបាលតាមទំនៀមទម្លាប់មានវិធីដូចគ្នា នឹងរបៀបបុរាណ គេប្រើថ្នាំឬសឈើ ស្មៅ ចំណីអាហារ ជាពិសេសទំនាក់ទំនងយល់ចិត្តរវាងគ្រូបុរាណអ្នកជម្ងឺ និងក្រុមគ្រួសារ។ គួរអោយស្តាយណាស់ ដោយពេលខ្លះ វេជ្ជបណ្ឌិតសម័យធ្វើការទិះទៀនគ្រូបុរាណដោយនិយាយថាគេប្រើសារជាតុគ្មានប្រសិទ្ធិភាព( សារជាតុគ្មានប្រតិកម្ម) ផ្ទុយពីទទួលស្គាល់ឥទ្ធិពលរបស់អ្នកទាំងនោះ ក្នុងការធ្វើអោយការព្យាបាលខ្លួនឯងមានដំណើរការឡើង និងមានប្រសិទ្ធិភាព។ ការទិះទៀន ក៏មិន

បានចាប់អារម្មណ៍ទៅលើប្រវត្តិ និងវិជ្ជាសាស្រ្តដែលបង្កើតប្រសិទ្ធិភាពល្អ ក្នុងទំនាក់ទំនងយល់ចិត្តរវាងអ្នកព្យាបាល និងអ្នកជម្ងឺ។

វាបានប្រើពេលជាង ពីរទសវត្ស ដោយធ្វើការជាមួយ នឹងជនរួចផុតពីសេចក្តីមហាសម្លាប់រង្គាល និងទារុណកម្ម ដើម្បីអោយខ្ញុំរកឃើញដំណើរការព្យាបាលខ្លួនឯងអោយជាសះស្បើយដោយធម្មជាតិ។ បទពិសោធន៍របស់ខ្ញុំនៅសាយធូ ទៅលើចំរៀងដែលបានបង្វែរអារម្មណ៍របស់ខ្ញុំ ចេញពីសេចក្តីអស់សង្ឃឹម បានធ្វើអោយខ្ញុំរកមើលលទ្ធភាពនេះនៅក្នុងអារម្មណ៍របស់អ្នករួចផុតពីសេចក្តីស្លាប់ថាជាករណីដ៏លំបាកបំផុត។ ការសួរជនភៀសខ្លួនដោយផ្ទាល់ថា តើគេសុខទុក្ខយ៉ាងណាដែរ ដោយសង្ឃឹមថា នឹងបានឃើញចម្លើយបន្តិចបន្តួចទៅលើដំណើរការជាសះស្បើយនេះ គឺទទួលបានតែលទ្ធផលមិនច្បាស់លាស់។ តែបើសួរយើងសំណួរពិតប្រាកដថា "តើអ្នកមានអារម្មណ៍ថាអ្នកមានសុខភាពល្អយ៉ាងណាដែរ? ពុំល្អទាល់តែសោះ មធ្យម ល្អ ឬល្អណាស់"? ចម្លើយស្ទើរតែច្បាស់ទាំងអស់។

ជនភៀសខ្លួនជាពិសេសដឹងអំពីសុខភាពរាងកាយ និងសតិអារម្មណ៍របស់ខ្លួន តែមានតែពីរទៅបីនាក់ទេដែលនិយាយត្រង់ៗថា៖ "លោកវេជ្ជបណ្ឌិត នេះគឺជាវិធីដែលខ្ញុំរៀបចំជីវិតរបស់ខ្ញុំឡើងវិញ" ទោះជានៅក្នុងមជ្ឈដ្ឋានប្រកបដោយសន្តិសុខយ៉ាងណាក៏ដោយ ជនតក់ស្លុតជាញឹកញាប់ពុំគិតអំពីសេចក្តីព្យាយាមព្យាបាលខ្លួនគេឡើយ។ ការពង្រឹងសេចក្តីព្យាបាលដោយខ្លួនឯងពុំអាចធ្វើឡើងបាន លុះត្រាតែជនតក់ស្លុតដឹងច្បាស់ពីលទ្ធផលសេចក្តីភាពជាសះស្បើយ។ ខ្ញុំត្រូវប្រើពេលជាច្រើនឆ្នាំ ក្នុងការកែសំណួរដ៏សាមញ្ញពី "តើអ្នកមានអារម្មណ៍ថា អ្នកមានសុខភាពល្អយ៉ាងណាដែរ?" ទៅ "តើយើងអាចធ្វើអ្វីរួមគ្នាដើម្បីធ្វើអោយអ្នកមានសុខភាពល្អឡើយវិញ"? សំណួរនេះទទួលស្គាល់ថាការព្យាបាលខ្លួនឯង ជាដំណើរការពិតដែលត្រូវគាំទ្រដោយសតិសម្បជញ្ញៈ និងដោយសកម្ម។ ដូចគ្នា នឹងថ្នាំបុរាណ មូលដ្ឋាននៃការជម្រុញអោយប្រើដំណើរការព្យាបាលជាធម្មជាតិត្រូវតែរៀបចំឡើងជាមួយនឹងអ្នកជម្ងឺ។

គួរអោយស្តាយណាស់ ដោយមានឧបសគ្គជាច្រើនមករារាំងក្នុងការបង្កើតដំណើរការព្យាបាលដោយខ្លួនឯង។ ភាគច្រើន គឺជាការយល់ដឹងរបស់ជនល្មើស នៃអំពើមហាឧក្រិដ្ឋកម្មដែលកើតមានឡើង ទៅលើដំណើរការព្យាបាលសំខាន់ៗ នៅក្នុងតំបន់របស់ជនរងគ្រោះ ដែលជនល្មើសព្យាយាមព្យាបាទបំផ្លាញ។

ដូច្នេះហើយបានជាគេបំផ្លាញបំបាត់មន្ទីរពេទ្យ គ្រូពេទ្យ គ្រូមើលជម្ងឺតាមបែបបុរាណ (គ្រូខ្មែរ)អាចារ្យ និងចាស់ទុំនៅក្នុងក្រុមគ្រួសារ។

នៅគ្រប់ស្ថានភាពឧក្រិដ្ឋកម្មរាប់ទាំងអ្នកជាប់គុក ដែលទទួលទារុណកម្មនៅគុកប្រទេសវៀតណាម ទៅប្រជាជនដែលទទួលការវាយប្រហារនៅ ប្រទេសបូស្សនា អ្នករួចផុតពីសេចក្តីស្លាប់ នៅទីបញ្ចប់ពឹងផ្អែកទៅលើការព្យាបាលដោយខ្លួនឯងតែមួយគត់ដើម្បីរស់ និងភាពជាសះស្បើយឡើងវិញ។ គួរអោយអស្ចារ្យ ដោយការបំបាត់ទម្រង់ព្យាបាលជាទូទៅ ធ្វើអោយឥទ្ធិពលដ៏មហិមារ នៃការព្យាបាលដោយខ្លួនឯងបានលាតត្រដាងឡើងយ៉ាងច្បាស់។

ឧបសគ្គមួយទៀត នៃការព្យាបាលដោយខ្លួនឯង គឺការមិនយកចិត្តទុកដាក់ របស់សង្គមសម័យទំនើប អារម្មណ៍ឈឺចាប់របស់បុគ្គល ត្រូវបំបាត់ចោលដោយសង្គមនយោបាយ និងផ្នែកផ្សព្វផ្សាយព័ត៌មានដែលមមាញឹកយកចិត្តទុកដាក់ទៅលើហេតុការណ៍មហន្តរាយ។ ជាប្រចាំថ្ងៃ យើងបានទទួលព័ត៌មានរាយការណ៍អំពីឧក្រិដ្ឋកម្មនៅខុងហ្គោ Congo អាយរាក់ Iraq ឬប៉ាឡេស្ទីន Palestine អ៊ីស្រាអែល Israel ដោយថ្លែងពីចំនួនមនុស្សស្លាប់ និងរបួស។

កម្រមានព័ត៌មានរាយការណ៍អំពីចំនួនជនរងរបួសដែលកំពុងតែឈឺចាប់នៅមន្ទីរពេទ្យ ឬនៅផ្ទះ តើគេរស់នៅដូចម្តេចទៅនៅពេលគេគ្មានភ្នែក ឬគ្មានដៃជើង ហើយតើសមាជិកគ្រួសាររបស់ជនដែលស្លាប់នោះក្លាយទៅជាអ្វីទៅ។ សារព័ត៌មានពុំដែលផ្សាយថា "ថ្ងៃនេះជនឈ្មោះ……..រងរបួសដាច់ជើង នៅ……………ហើយគាត់កំពុងតែដោះស្រាយ នឹងបញ្ហានេះដោយ……………"។ ដោយពិភពលោកទាំងមូលចាប់អារម្មណ៍ ទៅលើកត្តាឃោរឃៅ នៃហេតុការណ៍តក់ស្លុត ការព្យាបាលសតិអារម្មណ៍ក្រោយពីព្រឹត្តិការណ៍មហន្តរាយពុំបានទទួលជំនួយឡើយ។

វិជ្ជាជីវៈ ផ្នែកពេទ្យក៏អាចជាឧបសគ្គទៅលើការព្យាបាលដោយខ្លួនឯង នៅខណៈដែលគេស្មានថាគ្រូពេទ្យអាចដឹងពីចិត្ត និងជួយជម្រុញដំណើរការព្យាបាលដោយខ្លួនឯងជាធម្មជាតិរបស់អ្នករស់រួចផុតពីសេចក្តីស្លាប់ ជាញឹកញាប់ ករណីនេះពុំពិតទេ។ វេជ្ជបណ្ឌិតទទួលការរៀនសូត្រអោយស្តាប់អ្នកជម្ងឺគ្រប់រូប ជាពិសេសចំពោះអ្នកដែលឈឺខ្លាំង និងមានទុក្ខព្រួយដោយកត្តាសមហេតុផលតាមបែបបទវិទ្យាសាស្ត្រ និងគំនិតដែលមានគោលដៅច្បាស់លាស់។ វិធីនេះជាចំណែកមួយ ផ្នែកនៃទំនៀមទម្លាប់យូរអង្វែង នៃវិជ្ជាពេទ្យសម័យ នៅក្នុងឆ្នាំ១៩១២ វេជ្ជបណ្ឌិតកាណាដា លោកវិឡិយ៉ឹម អូសឡឺ Williams Osler ថ្លែងដោយច្បាស់ថាវេជ្ជបណ្ឌិតត្រូវតែដកខ្លួនចេញពីអារម្មណ៍ទោរទន់របស់អ្នកជម្ងឺ ហើយត្រូវតែមានអារម្មណ៍ ឆ្លើយតបទៅលើការឈឺចាប់របស់អ្នកជម្ងឺ- ដើម្បី នឹងអាចមើលទៅ "ក្នុង" និង "សិក្សា" ជម្រៅជីវិតពិតរបស់អ្នកជម្ងឺ។

ជាការពិតផ្ទុយពីជួយអោយយល់ដឹងអំពីជម្រៅជីវិតរបស់អ្នកជម្ងឺ ការដកខ្លួននេះបង្កើតនូវភាពងងឹតនៅទីបញ្ចប់វេជ្ជបណ្ឌិតមិនត្រឹមតែមិនឃើញព័ត៌មានសំខាន់ ផ្នែកសុខភាព តែគេក៏គ្មានឱកាសបណ្តុះបណ្តាលដំណើរការព្យាបាលដោយខ្លួនឯងដែរ។

សាលារៀនផ្នែកវិជ្ជាពេទ្យបង្រៀន វេជ្ជបណ្ឌិតក្មេងៗអោយរកមើលរោគា ដោយយកការវិនិច្ឆ័យរោគជាមូលដ្ឋានដើម្បីបង្កើតគំរូព្យាបាល ហើយតាមដានអ្នកជម្ងឺដែលបានទទួលការវិនិច្ឆ័យរោគ ដោយប្រើថ្នាំពេទ្យព្យាបាល ឬព្យាបាលរាងកាយ។ ជាការកម្រមានដែលគ្រូពេទ្យធ្វើការសាកសួរអំពីសមត្ថភាពរបស់អ្នកជម្ងឺទៅលើការព្យាបាលដោយខ្លួនឯង។ វេជ្ជបណ្ឌិតទទួលការហ្វឹកហ្វឺនក្នុងការធ្វើសម្ភាសន៍ជាភៀសខ្លួន និងជនដែលរួចផុតពីសេចក្តីស្លាប់ពីអំពើមហាសាហាវយង់ឃ្នង ជាញឹកញាប់ គឺសួរអំពីភាពតក់ស្លុត ដោយគេពុំចង់បើកនិយាយអំពីរឿងអាក្រក់ឡើយ។ ហើយគេក៏គេចពីសំណួរពិបាកឆ្លើយដែលគេពុំអាចដោះស្រាយបានតាមបែបបទវិជ្ជាពេទ្យ។

អំពើទាំងនេះជាករណីប្រងើយកន្តើយ ទៅលើកត្តាពិតនៃការឆ្លើយតបរបស់អ្នកជម្ងឺក្នុងការព្យាបាលជាធម្មជាតិ ដែលអាចជួយណែនាំវេជ្ជបណ្ឌិតអំពីការព្យាបាលសុខភាព។
វេជ្ជបណ្ឌិតមើលពុំឃើញដំណើរការព្យាបាលជាធម្មជាតិ ដោយគេយកចិត្តទុកដាក់តែលើដំណើរការព្យាបាលតាមបែបបទព្យាបាលវិជ្ជាពេទ្យរបស់គេ។ ការព្យាយាមរបស់អ្នកជម្ងឺក្លាយទៅជាការបញ្ចាំងរចនាសម្ព័ន្ធដ៏មហិមារដែលវេជ្ជបណ្ឌិតសំដែងឡើង។

យោងទៅតាមវិជ្ជាជីវៈផ្នែកពេទ្យ ការទៅជួបវេជ្ជបណ្ឌិតមួយភ្លែតៗ គឺជាជំហ៊ានដ៏សំខាន់ក្នុងដំណើរការព្យាបាលរបស់អ្នកជម្ងឺ។ តែកំណត់ពេលចំនួន២០នាទី រៀងរាល់៦អាទិត្យដែលអ្នកជម្ងឺជួប នឹងវេជ្ជបណ្ឌិតជាកំណត់ពេលដ៏ស្តួចស្តើងណាស់បើប្រៀបធៀបទៅ នឹងកំណត់ពេលដែលអ្នកជម្ងឺចំណាយពេលព្យាបាលខ្លួនឯងនៅផ្ទះ។ ដោយគ្រូពេទ្យកម្រចេញពីការិយាល័យរបស់ខ្លួន ដើម្បីធ្វើអោយខ្លួនគេ ដឹងថាអ្នកជម្ងឺរបស់ខ្លួនបានធ្វើអ្វីខ្លះ ជារៀងរាល់ថ្ងៃនោះ ដំណើរការព្យាបាលនៅក្នុងខ្លួនរបស់អ្នកជម្ងឺជាករណីមិនសំខាន់ ឬមិនយកចិត្តទុកដាក់។

## ១.២ មជ្ឈដ្ឋានសម្រាប់ឆាពជាសះស្បើយ

ទោះបីជាការព្យាបាលដោយខ្លួនឯង មានដំណើរការចេញពីរាងកាយ និងអារម្មណ៍របស់យើងក៏ដោយ ការព្យាបាលដោយខ្លួនឯង នៅតែត្រូវមានវត្តមាននៅក្នុងសង្គម។ នៅករណី ដែលការបង្កើតប្រព័ន្ធព្យាបាលដោយខ្លួនឯងសម្រាប់ជនតក់ស្លុតមានភាពដូចគ្នា និងការបង្កើតជម្រកសម្រាប់ជនទទួលអំពើហឹង្សាក្នុងក្រុមគ្រួសារ វាហាក់បីដូចជា ពុំអាចកើតមានឡើងឡើយ។ មជ្ឈដ្ឋានផ្នែកសុខភាពសម្រាប់ជួយជនតក់ស្លុតត្រូវតែផ្លាស់ប្តូរឡើង ជំហ៊ានដំបូង គឺបង្កើតមជ្ឈដ្ឋានដែលទាក់ទាញអារម្មណ៍សម្រាប់ការព្យាបាលបញ្ហាឧក្រិដ្ឋកម្ម។

អ្នកជម្ងឺសតិអារម្មណ៍បន្តិចបន្តួចនៅក្នុងសហរដ្ឋអាមេរិក និងទីផ្សេងៗ ច្រើនតែទទួលការព្យាបាល នៅមន្ទីរព្យាបាលទ្រុឌទ្រោម ទីតាំងតោកយ៉ាក ទោះបីជាវាឋិតនៅក្នុងស្ថាប័នសិក្សា វរជនក៏ដោយ។ មណ្ឌលទាំងនោះបានបញ្ចេញអោយអ្នកជម្ងឺ និងបុគ្គលិកមានអារម្មណ៍ថាគេពុំសម នឹងទទួលបមជ្ឈដ្ឋាន ដែលគ្រាន់បើជាងនេះទេ ជាមជ្ឈដ្ឋានមិនសមរម្យសម្រាប់ព្យាបាល។ អ្នកជម្ងឺជនភៀសខ្លួនជាទូទៅច្រើនតែជាអ្នកទុរគត និងមានឋានៈទាបនៅក្នុងសង្គម ហើយច្រើនតែទទួលការចាត់តាំងរិតតែទាបជាងភាពទុរគតរបស់គេទៅទៀត បទពិសោធន៍ជីវិតតក់ស្លុត និងការពុំចេះនិយាយភាសាអស់គ្លេសបានទទួលការចាត់តាំងទៅក្នុងចំណោមអ្នកជម្ងឺសតិអារម្មណ៍ដ៏ទាបបំផុត។ សេចក្តីយកចិត្តទុកដាក់ត្រូវតែផ្តល់ឡើងដើម្បីបង្កើតមជ្ឈដ្ឋានដ៏ល្អ ដែលបង្ហាញនូវភាពគោរពដក់អ្នកជម្ងឺតក់ស្លុតដោយពុំយកឋានៈសង្គម និងកម្រិតទុរគតមកប្រើឡើយ។

ភាពកក់ក្តៅ និងភាពទាក់ទាញអារម្មណ៍របស់មន្ទីរពេទ្យព្យាបាលជួយរក្សាឡើងវិញនូវតម្លៃ និងសេចក្តីគោរពរបស់អ្នកជម្ងឺដែលទទួលអារម្មណ៍អាម៉ាស់មុខ និងប្រមាថមើលងាយ។ នៅមន្ទីរព្យាបាលសតិអារម្មណ៍ឥណ្ឌូ-ចិន នៅទីក្រុងបូស្តុន អ្នកជម្ងឺយកផ្ទាំងគំនូរវប្បធម៌របស់គេមកតាំង។ ជាបន្តបន្ទាប់រហូតទាល់តែមន្ទីរព្យាបាលក្លាយទៅជាសារមន្ទីរ តាំងពិពណ៌វប្បធម៌គ្រប់ជញ្ជាំងគ្របដណ្តប់ ដោយផ្ទាំងគំនូរដើម មានរួមទាំងផ្ទាំង

ប៉ាក់ដៃរបស់ជនភៀសខ្លួនភូមា សម្រោលអាយ៉ងប្រទេសខ្មែរ រូបនាគប៉ាក់សូត្រប្រទេសវៀតណាម ផ្ទាំងគំនូរទិដ្ឋភាពក្រុមគ្រួសារ គូរដោយស្នាដៃរបស់ជនជាតិវៀតណាម ដែលជាប់គុកពេលសង្គ្រាម និងផ្ទាំងផ្តៅដ៏ធំធេតឆាយនៃ "ជីវិតរុក្ខជាតិ" ពោរពេញទៅដោយសត្វ និងមនុស្សដែលរចនាឡើងដោយជនជាតិម៉ុង និងជនជាតិឡាវ។ សោភ័ណភាពមន្ទីរព្យាបាលនេះហើយ ជាមូលហេតុចំបងដែលអ្នកជម្ងឺព្រមចូលរួមនៅក្នុងការព្យាបាល ជាពិសេសនៅក្នុងករណីនិយាយអំពីរឿងតក់ស្លុតរបស់គេ។

ដោយគេបានចូលរួមចំណែក បង្កើតមន្ទីរពេទ្យប្រកបដោយសោភ័ណភាពសម្រាប់ខ្លួនគេ មានអ្នកជម្ងឺខ្លះៗ ឈប់មកព្យាបាលទៀត ការឈប់មកព្យាបាលនេះផ្ទុយទៅ នឹងកម្រិតធម្មតា ចំនួន ៥០ភាគរយ នៅក្នុងចំណោមអ្នកជម្ងឺទុគត ដែលឈប់មកព្យាបាលនៅក្នុងស្ថាប័នអាមេរិកកាំង។ ក្រោយពីបានសង់មន្ទីរព្យាបាលជាថ្មីឡើងវិញ នៅទីក្រុងសៀមរាបប្រទេសកម្ពុជា ដែលត្រូវរុះរើ និងដុតបំផ្លាញក្លាយទៅជាផេះដោយខ្មែរក្រហម ក្រុមការងាររបស់យើងបានដាំផ្កានៅខាងក្រៅ ។ អ្នកជម្ងឺ និងក្រុមគ្រួសារ អ្នកខ្លះជាជនក្រីក្រជាងគេ នៅក្នុងខេត្តបាននាំគ្នាទាំងហ្វូង មកមន្ទីរព្យាបាលចូលរួមចំណែកដោយអង្គុយ យ៉ាងស្ងប់ស្ងាត់នៅក្នុងការព្យាបាល-ជាទីកន្លែងដែលមានបរិយាកាសស្ងប់ស្ងាត់ និងគោរពដែលគេពុំបានទទួលជាច្រើនឆ្នាំមកហើយ គេថែមទាំងជួយបុគ្គលិករក្សាវត្តមានស្ងប់ស្ងាត់ទៀតផង។

ដោយការបង្កើតសោភ័ណភាពដល់ចំណែកមួយ ផ្នែកនៃការព្យាបាលដោយខ្លួនឯង សកម្មភាពរចនាសម្ព័ន្ធ ក្លាយទៅជាទិដ្ឋភាពដ៏សំខាន់ នៃកិច្ចការសហគមន៍ និងការព្យាបាលរបស់យើង។ សកម្មភាពសិល្បៈអាចជួយដំណើរការព្យាបាល នៅករណីដែលការព្យាបាលដោយវិធីពិភាក្សា និងថ្នាំពេទ្យទទួលបរាជ័យ អ្នកជម្ងឺសហការជាមួយ នឹងសមជិកសហគមន៍ បានបង្កើតការតាំងពិព័ណ៌រូបថត ដោយយោងទៅតាមប្រវត្តិសាស្ត្រផ្ទាល់មាត់របស់ស្ត្រីខ្មែរ ហើយបានបង្កើតសៀវភៅកំប្លែង សម្រាប់យុវវ័យដែលបានបាត់បង់ឪពុកម្តាយរបស់គេ។

ក្រុមរបស់យើងបានរៀនអំពីអាយ៉ង ដើម្បីនិយាយអំពីការយល់ដឹងសុខភាព និងផ្តល់ឱវាទដល់កុមារនិងជនពេញវ័យ។ អាយ៉ងមានលទ្ធភាពនិយាយអំពីរឿងលីលា និងរឿងល្អអស្ចារ្យ ជាញឹកញាប់ច្រើននិយាយអំពីភាពគ្មានសុជីវធម៌របស់ជនមានអំណាច ទោះជាគេសម្តែងជាចំណែកមួយ ផ្នែកនៃសិល្បៈ ប្រទេស អ៊ីតាលី Commedia I Dell' arte ឬជាការសម្តែងស្រមោលអាយ៉ង ជាទំនៀមទម្លាប់ ប្រទេស ឥណ្ឌូណេស៊ី និងប្រទេសកម្ពុជាក៏ដោយ។ ដោយឥទ្ធិពលសង្គមវាជាទំនៀមទម្លាប់ ដែលអាយ៉ងច្រើននិយាយអំពីគំនិតស្នេហ៍គ្រស្នាញ នៅគ្រាដែលយើងនៅជុំរុំសាយធូ យើងស្នើសុំព្រះភិក្ខុពិន សែម Pin Sem អោយព្រោះអាយ៉ងប្រពៃណីខ្មែរឡើងវិញសម្រាប់ប្រើក្នុងការព្យាបាលរបស់យើង។ អាយ៉ងដ៏អស្ចារ្យនេះ បានផ្សព្វផ្សាយទៅដល់អ្នកដែលរួចផុតពីសេចក្តីស្លាប់ ហើយចូលទៅអារម្មណ៍មនុស្សគ្រប់រូប ដោយនាំមកទឹកមុខញញឹម និងសំណើចក្អាកក្អាយហើយដាស់តឿនអារម្មណ៍ទស្សនិកជន ដោយភាពរស់រវើក និងឥទ្ធិពលរបស់គេ។

ភាពក្រមាច់ក្រមើមរីករាយរបស់អាយ៉ងជួយលើកទឹកចិត្តមនុស្សគ្រប់រូប។ សេចក្តីអស់សង្ឃឹមអាចមានគ្រោះថ្នាក់ដល់ជីវិតទាំងជនដែលរួចផុតពីសេចក្តីស្លាប់ ទាំងអ្នកព្យាបាល អាយ៉ងជួយយ៉ាងអស្ចារ្យដល់ទាំងអ្នករួចផុតពីសេចក្តីស្លាប់ ហើយបានជួយទាំងអ្នកព្យាបាលកុំអោយអស់សង្ឃឹមទៀតផង។
នៅពេលដែល យើងធ្វើអោយអាយ៉ងប្រទេសកម្ពុជាមានភាពដូចដើមវិញ នៅក្នុងរោងកុនបូស្តុន ជនដែលរួចផុតពីសេចក្តីស្លាប់ ពីភាពរន្ធត់ដែលពុំអាចបរិយាយ បានបញ្ចេញស្នាមញញឹមជាលើកដំបូង នៅពេលដែលគេឃើញអាយ៉ងបញ្ចាំងនៅលើផ្ទាំងអេក្រង់។

តួចម្លែក និងតួល្អដូចជាតួសង្សកង្កែប និងមហាក្សត្រីពស់អាចយល់ដឹងអំពីពិភពអាថ៌កំបាំងរបស់អ្នកជម្ងឺដែលបានជួបប្រទះ នឹងទុក្ខសោក និងភាពតក់ស្លុតដ៏ក្រៃលែង។ អាយ៉ងបានបើកផ្លូវអោយជនដែលរួចផុតពីសេចក្តីស្លាប់និយាយបញ្ចេញចំណុចសំខាន់ៗ នៃរឿងតក់ស្លុតរបស់គេ និងពណ៌នាអំពីជីវិតថ្មីដែលគេសង្ឃឹមថាគេនឹងបង្កើតឡើង។

យើងសង្ឃឹមថាដោយយោងតាមការព្យាយាមផ្នែកវិទ្យាសាស្ត្រថ្មី ភាពព្យាបាលដោយខ្លួនឯង នឹងទទួលការដឹងឮថាករណីនេះមានមុខនាទីដ៏សំខាន់ក្នុង ផ្នែកជាសះស្បើយរបស់ជនតក់ស្លុត។ ភស្តុតាងទាំងអស់បង្ហាញថាវេជ្ជបណ្ឌិតបុរាណបានដឹងជាស្រេចថា៖ ជីវសាស្ត្រ អារម្មណ៍សាស្ត្រ និងដំណើរការសង្គម នៃភាពព្យាបាលដោយខ្លួនឯងមានឥទ្ធិពលក្នុងការជាសះស្បើយ ហើយដំណើរការនេះត្រូវតែគាំទ្រដោយស្ថាប័នវិជ្ជាពេទ្យសម័យ និងសង្គម។ វាជាការរំភើបដែលបានដឹងថាក្នុងនាមជាមនុស្សពុំមានវណ្ណៈ ពិសេសសម្រាប់ជនតក់ស្លុតទេ គេគ្រាន់តែជាជនសាមញ្ញអភ័ព្វដែលបានទទួលបទពិសោធន៍រន្ធត់នៅក្នុងឆាកជីវិត។ វាជាការគ្មានលទ្ធផលក្នុងការប្រាប់គ្រឹះស្ថានពេទ្យថា "ជៀសចេញទុកអោយជនតក់ស្លុត និងសហគមន៍របស់គេជួយខ្លួនគេ" បើសិនជាការទទួលការយល់ដឹងអំពីឥទ្ធិពលព្យាបាលដោយខ្លួនឯង នាំមកនូវសេចក្តីបញ្ចប់ដូចនេះ វាជាលទ្ធផលមិនគួរអោយជឿ ដោយការព្យាបាល និងស្ថាប័នសង្គម ជាចំណែកទាំងមូល នៃជីវិតមនុស្ស។ នៅគ្រាដែលជីវិតតក់ស្លុតបានផ្លាស់ប្តូរពីភាពធម្មតា ភាពពិតទូទៅទៅជាភាពថ្មី ជាទិដ្ឋភាពតស៊ូគេត្រូវការទំនាក់ទំនងរឹងមាំពីក្រុមគ្រួសារ មិត្តភក្តិ អ្នកជិតខាង វេជ្ជបណ្ឌិត និងភ្នាក់ងារសង្គមកិច្ច។

ជំហ៊ានដំបូង នៃភាពជាសះស្បើយរបស់ជនតក់ស្លុត ទោះជាក្មេង ឬមនុស្សចាស់ក្តី គឺបំបែកភាពនៅតែឯង ដោយទទួលស្គាល់ថា ជាឥទ្ធិពលព្យាបាលដោយខ្លួនឯង កំពុងតែមានដំណើរការ ហើយវា នឹងបណ្តាលអោយមានលទ្ធផលល្អកើតមានឡើង មានរួមទាំងការត្រឡប់ទៅដំណើរជីវិតធម្មតាវិញ។ ការព្យាបាលដោយខ្លួនឯងធ្វើអោយមនុស្សលោករួចផុតពីរោគា ធ្វើអោយមានសុខភាព និងសុខុមាលភាពល្អវិញ ក្នុងករណីនេះ អ្នកជំនួយមានសារៈសំខាន់ ដោយគេអាចប្រើភាពប៉ិនប្រសប់របស់គេ ផ្នែកយល់ចិត្តមកជួយជម្រុញសុទិដ្ឋិនិយមទៅលើការព្យាបាលរបស់ ជនដែលរួចផុតពីសេចក្តីស្លាប់។

# ជំពូកទី៥ ការនិទានរឿងជាវិធីសាស្ត្រព្យាបាល

នៅក្នុងប្រវត្តិ ខ្សែជីវិតរបស់គាត់ ការរួចផុតពិសេចក្តីស្លាប់ នៅ អ៉រ ស្វីត *Survival In Auschwitz* លោក ព្រីម៉ូ លីវី Primo Levi បានអធិប្បាយអំពីសុបិន្តដដែលៗ ដែលគាត់មាននៅគ្រា ដែលគាត់រស់នៅក្នុងជុំរុំមរណៈ។ ហើយនៅពេលដែលគាត់បានវិលត្រឡប់មកផ្ទះវិញ គាត់បាននិយាយរឿងនោះប្រាប់មិត្ត និងក្រុមគ្រួសាររបស់គាត់ ៖ នៅជាភាពរីករាយខ្លាំងក្រៃលែង គ្រប់សព្វាង្គកាយគាត់ពុំអាចអធិប្បាយបានអំពីភាពបានត្រឡប់មកផ្ទះវិញហើយបានចូលរួមនៅក្នុងចំណោមមនុស្សជាទីរាប់អាន និងអ្វីៗ ជាច្រើនទៀតដែលត្រូវរំលឹកឡើងវិញ ៖ តែខ្ញុំពុំអាចទប់ខ្លួនកុំអោយចាប់អារម្មណ៏ថា មានមនុស្សជាច្រើនពុំយកចិត្តទុកដាក់ស្តាប់ខ្ញុំឡើយ។ ជាការពិតណាស់នោះ ខុសប្លែកពីគ្នាទាំងអស់ ៖ គេនិយាយទាំងវង្វេងវង្វាន់ទៅលើអ្វីៗ នៅក្នុងចំណោមខ្លួនគេ ហាក់ដូចជាខ្ញុំគ្មានវត្តមាននៅទីនោះ បងស្រីខ្ញុំបានសម្លឹងមកខ្ញុំ រួចគាត់ងើបដើរចេញដោយគ្មានចេញវាចារមួយម៉ាត់ឡើយ...... ទុក្ខព្រួយដោយសង្គ្រាមពេលនេះបានកើងឡើងនៅក្នុងខ្លួនខ្ញុំ។

ចំពោះជនតក់ស្លុតដែលចាកចេញពីពិភពលោក ដូចជា លោក Auschwitz សេចក្តីភ័យខ្លាចខ្លាំងបំផុតគឺភាពពុំអាចមានទំនាក់ទំនងជាមួយ នឹងពិភពលោកជាធម្មតាឡើងវិញ គេភ័យខ្លាចថាជនដែលជិតស្និត នឹងរូបគេនឹងដើរចេញពីរូបគេ ដោយបោះបង់ និងមិនយកចិត្តទុកដាក់ នៅពេលដែលគេព្យាយាមរៀបរាប់អំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គេ។ ការពុំយកចិត្តទុកដាក់របស់អ្នកស្តាប់រិតតែធ្វើអាយអារម្មណ៍ឈឺផ្សារបស់អ្នក រួចផុតពីសេចក្តីស្លាប់ពោរពេញ ទៅដោយភាពអយុត្តិធម៌នៃសង្គ្រាម ដែលធ្វើអោយគេមានអារម្មណ៍ថារឿងរ៉ាវរបស់គេគ្មានន័យ។ សុបិន្តរបស់លោក Levi បានធ្វើអោយគាត់ទទួលអារម្មណ៍ដឹងទុកជាមុនថា ការមិនទទួលដឹងឮ របស់ញាតិមិត្តគាត់ ទៅលើសេចក្តីឈឺចាប់របស់គាត់នេះ ជានិម្មិតរូបបរិបត្តិទំនាក់ទំនងសកលរវាងជនតក់ស្លុត និងពិភពលោកទូទៅ។

តែសុបិន្តក៏អាចជួយណែនាំលោក Levi រកដំណោះស្រាយបានដែរ ប្រហែលជានៅត្រឹមកម្រិតខ្លះវាអាចជួយអោយគាត់យល់ដឹង ថាហេតុអ្វីបានជាបងស្រីរបស់គាត់ ពុំអាចទ្រាំទ្រទទួលអារម្មណ៍ឈឺផ្សារ ដែលកើតមានឡើងនៅពេលដែលនាងស្តាប់រឿងរបស់គាត់។ ទោះបីជា អ្នករួចរស់ផុតពីសេចក្តីស្លាប់ ដោយសេចក្តីតក់ស្លុត ត្រូវតែចែកចាយបទពិសោធន៍របស់គេជាមួយ នឹងអ្នកឯទៀតក៏ដោយ ដើម្បីអោយខ្លួនគេភាពជាសះស្បើយ គេក៏ត្រូវតែព្យាយាមធ្វើឡើងតាមបែបបទយល់ដឹងពីចិត្ត ដើម្បីកុំអោយអ្នកស្តាប់បាន ប្រសិនបើការនិយាយនោះធ្វើឡើងត្រឹមត្រូវ។ មុននឹងជនតក់ស្លុតអាចចូលរួម ដោយមានប្រសិទ្ធិភាពក្នុងការនិទានរឿងរបស់ខ្លួនគេត្រូវតែធ្វើការប្រមាណមើលសមត្ថភាពរបស់អ្នកស្តាប់សិន។

វេជ្ជបណ្ឌិតពេទ្យ បុគ្គលិកសង្គមកិច្ច សកម្មជនផ្នែកសហគមន៍ និងអ្នកផ្សេងៗ ជាច្រើននាក់ទៀតដែលមានទំនាក់ទំនងជាមួយ នឹងជនតក់ស្លុតអាចទទួលមុខងារជាអ្នកបង្ហាត់ "ជននិទានរឿង"។ ការយល់ដឹងច្បាស់

ពេញលេញទៅលើសក្តានុភាពវិធីព្យាបាលរឿងតក់ស្លុត គឺត្រូវរួមសហការដោយជោគជ័យ ជាមួយនឹងជនតក់ស្លុតលើជំនាញនិទានរឿងរបស់គេ។ ករណីទាំងនេះ ពុំរាប់បញ្ចូលតែជនដែលបានទទួលបទពិសោធន៍អំពើដ៏ឃោរឃៅនោះទេ ស្ត្រីមេផ្ទះដែលបានទទួលរងគ្រោះ ជនរងគ្រោះដោយអំពើហិង្សាក្នុងក្រុមគ្រួសារ ជនមានជម្ងឺធ្ងន់ធ្ងរ យុវវ័យ និងកុមារដែលមានបញ្ហាទាំងអស់ក៏អាចទទួលផលប្រយោជន៍ដោយការចែកចាយរឿងដ៏មានប្រសិទ្ធិភាពរបស់គេជាមួយ និងអ្នកឯទៀតផងដែរ។ មនុស្សពេញវ័យ និងជនជរាត្រូវការជំនួយពិសេស នៅក្នុងរឿងនេះដោយក្រុមនីមួយៗ បានទទួលអារម្មណ៍ថា រូបគេត្រូវបានទទួលការចាត់ទុកថាជាពលរដ្ឋ គ្មានសិទ្ធជាពលរដ្ឋថ្នាក់ទាប ហើយជឿថាគ្មាននរណាម្នាក់គិតគួរអំពីចំណាប់អារម្មណ៍របស់គេឡើយ។

## ផ្នែក ១. ការនិទានរឿងមិនក្បោះក្បាយ

នៅក្នុងរឿងនិទាន របស់ជនជាតិឆីលីបង្ហាញនូវភាពបរាជ័យរបស់ជនតក់ស្លុត ក្នុងការពុំនិយាយពីបទពិសោធន៍ទារុណកម្មនៅក្រោមរបបពីណូចេ Pinochet ជាបែបអញ្ជើញអ្នកស្តាប់អោយចូលរួម ៖ ខ្ញុំបានទទួលការសួរចម្លើយ ចំនួន ៥ ដង ហើយជារៀងរាល់ពេល ខ្ញុំត្រូវស្រាតនលគក គេបញ្ជាអោយខ្ញុំស្រាតខោអាវចេញទាំងអស់។ ខ្ញុំពិតជាស្រាតននលគកមែន ជារៀងពេលក្នុងការសួរចម្លើយ ទាំងប្រាំដងនេះ ព្វខ្ញុំចាប់ផ្តើមមានរដូវទោះបីជាវាពុំមែនជាពេលដែលខ្ញុំត្រូវមានរដូវក៏ដោយ ប្រហែលជាមកពីសរសៃប្រសាទហើយ។ ទោះបីជាយ៉ាងណាក៏ដោយ លទ្ធផល គឺខ្លួនខ្ញុំប្រឡាក់សុទ្ធតែឈាម ជារៀងរាល់ពេលតែងតែមានអ្នកធ្វើបាបខ្ញុំយ៉ាងហោចណាស់ចំនួនប្រាំនាក់ វាបានបង្ខំអោយខ្ញុំស្រាតខោអាវហើយអោយខ្ញុំសម្លឹងមើលចំភ្នែករបស់វា នៅពេលដែលខ្ញុំកំពុងតែស្រាតខោអាវ។ ហើយវានិយាយបន្ថោកធ្វើអោយខ្ញុំអាម៉ាស់មុខគ្រប់បែបយ៉ាង វានិយាយថាវា នឹងចាប់រំលោភខ្ញុំហើយវាធ្វើបាបពេញរាងកាយខ្ញុំ វាជាការអាម៉ាស់ផ្នែកផ្លូវភេទ... វានៅតែបង្ខំអោយខ្ញុំសម្លឹងមើលចំភ្នែករបស់វាទៀត។ វានាំគ្នាឈរជាជួរហើយវាបង្ខំអោយខ្ញុំដើរកាត់មុខវា ធ្វើហាក់បីដូចជារបៀបបង្ហាញម៉ូដសំលៀកបំពាក់ វានៅតែបង្ខំអោយខ្ញុំសម្លឹងមើលភ្នែករបស់វា រឿងនេះចេះតែធ្វើអោយខ្ញុំនឹកឃើញដល់ភាព ដែលវាបង្ខំអោយខ្ញុំសម្លឹងមើលចំភ្នែករបស់វា ដែលធ្វើអោយខ្ញុំមានអារម្មណ៍ម៉ាស់មុខជាទីបំផុត។

រឿងនេះពុំអនុញ្ញាតអោយយើងគិតអំពីអ្វីផ្សេងៗទៀត ក្រៅពីហេតុការណ៍នោះឡើយ ៖ ការនិយាយបន្ថោកធ្វើអោយអាម៉ាស់មុខ ផ្នែកផ្លូវភេទចំពោះស្ត្រីភេទ ដែលកាន់សាសនាកាតូលិក គឺជាការធ្វើអោយនាងខ្មាស់អៀនយ៉ាងអនេក និងអាប់យស។ នៅពេលដែលយើងនឹកឃើញ នឹងភ្នែកនូវទិដ្ឋភាពទារុណកម្ម នៅក្នុងគំនិតរបស់យើង អារម្មណ៍របស់យើងធ្វើអោយតក់ស្លុត ស្ត្រីជនជាតិឆីលីដែលខ្ញុំហៅឈ្មោះគាត់ថាម៉ារា Maria ត្រូវគេបង្ខំអោយចូលរួម នៅក្នុងការបង្ហាញម៉ូដសំលៀកបំពាក់អាសអាភាសន៍ខុសពីមាគ៌ា ដោយអ្នកធ្វើទារុណកម្មទាំងនោះយកសម្ផស្សស្ត្រីភេទ មកចំអក នឹងបន្ថោកមើលងាយ។ គេបង្ខំអោយគាត់យកបទពិសោធន៍រាងកាយអាថ៌កំបាំងស្ត្រីភេទមកបង្ហាញជាសាធារណៈ យើងចង់អោយឧក្រិដ្ឋជនទទួលទោស តែសាច់រឿងនេះធ្វើអោយយើងស្លុត ហើយយើងពុំអាចឆ្លើយតបទៅតាមការយល់ដឹងរបស់យើងបានឡើយ សេចក្តីក្លាហានរបស់ស្ត្រីនេះបង្ហាញអោយឃើញថា គាត់

មានកម្លាំងតស៊ូតែរឿននេះបានលាតត្រដាងនូវសេចក្តីមានៈ និងភាពប៉ិនប្រសប់ តស៊ូ ដើម្បីរស់ដ៏តិចតួចរបស់គាត់។ រឿងនេះធ្វើអោយយើងដឹងបន្តិចបន្តួចនូវកត្តាពិតអំពីសេចក្តីតស៊ូ នឹងភាពលំបាក ភាពរួចផុតពីសេចក្តីស្លាប់ បើសិនជាស្រ្តីនេះទទួលការលើកទឹកចិត្តអោយគាត់អធិប្បាយរឿងរបស់គាត់តាំងពីដើមដល់ចប់ បទពិសោធន៍ដែលបានកើតឡើងនៅប្រទេសគាត់តាំងពីដើម និងឧទាហរណ៍ សេចក្តីមានៈ និងអ្វីៗ ដែលនឹងកើតឡើងបន្ទាប់ពីភាពតក់ស្លុតនោះ គាត់ពិតជាអាចផ្តល់ការយល់ដឹងដ៏ក្រៃលែងអំពីភាពព្យាបាល ដោយអំពីរំលោភផ្លូវភេទ ដល់អ្នកស្តាប់នៅក្នុងប្រទេសឡាតាំងអាមេរិកកាំងផ្ទុយទៅវិញគាត់បានជ្រើសយកតែសេចក្តីលម្អិតនៃបទពិសោធន៍ព្រៃផ្សៃមកបញ្ជាក់វិញ។

ផ្ទុយ នឹងបុរសវ័យមជ្ឈឹមខ្មែរម្នាក់ ឈ្មោះ តា រា Dara គាត់បានយករឿងរបស់គាត់ មកនិយាយ ដើម្បីអោយអ្នកស្តាប់ស្អប់ខ្ពើម និងមានអារម្មណ៍ឈឺចាប់។ តារាជាជនដែលមករស់នៅទីក្រុងបូស្តុនបានជួប នឹងបុរសម្នាក់នៅក្នុងសហគមន៍ថ្មីរបស់គាត់ដែលគាត់ជឿថាបានសម្លាប់សមាជិកគ្រួសាររបស់គាត់ ដែលមានរួមទៅដោយភរិយាមុន និងកូនរបស់គាត់នៅក្នុងរបបប៉ុលពត។ ទោះជានៅសហរដ្ឋអាមេរិក តារាបានខិតខំបំភ្លេចរឿងអតីតកាល ដោយរៀបការជាថ្មីជាមួយ នឹងស្រ្តីខ្មែរម្នាក់ ហើយមានកូនពីរថែមទៀតក៏ដោយ ការជួប នឹងបុរសនោះតែមួយភ្លែតបានធ្វើអោយគាត់ផ្ទុះកំហឹងពុះកញ្ជ្រោល ដូចជា ឃាតករ។ គាត់មានអារម្មណ៍ថា គាត់កំពុងតែរស់នៅក្នុងស្ថានភាពសម្លាប់រង្គាលជាថ្មីឡើងវិញ ហើយគាត់ពុំអាចទប់ចិត្តបាន គ្មាននរណាម្នាក់អាចជួយរម្ងាប់ចិត្តគាត់បានឡើយ។ នៅទីបំផុតគាត់បានគូររូបនៅលើផ្ទាំងក្រណាត់គំនូរដែលមាន ទំហំ បួន ហ្វីតបួនជ្រុង ដែលបរិយាយរឿងជាទិដ្ឋភាពរូបត្លុក ចំនួនជាង១០ អំពីសមាជិកក្រុមគ្រួសាររបស់គាត់ដែលត្រូវខ្មែរក្រហមកំពុងតែស្រាវពោះវៀនចេញ និងដុតទាំងរស់នៅក្នុងអណ្តាតភ្លើង។ ក្រោយពីគូររូបនេះរួច គាត់បត់រូបគំនូរនេះរួចប្រក់នៅក្នុងស្បោងគំនូរ ហើយគាត់ដាក់តាំងតាមខ្លួនដោយចង់ នឹងខ្សែក្រវ៉ាត់ខោរបស់គាត់ ជារៀងរាល់យប់នៅក្នុងផ្ទះរបស់គាត់ ដែលធ្វើពុំទាន់រួចសព្វគ្រប់នោះគាត់បានយករូបនោះមកតាំងនៅលើក្បាលដំណេករបស់គាត់ទុកអោយភរិយា និងកូនរបស់គាត់មើល នៅទីបំផុតដោយសេចក្តីអស់សង្ឃឹមដ៏ខ្លាំងរបស់គាត់ បានបណ្តាលអោយសហគមន៍ខ្មែរនៅក្នុងតំបន់នាំយកគាត់មកមន្ទីរពេទ្យព្យាបាល។

តារាធ្វើអោយអ្នកព្យាបាលរបស់គាត់ ស្ទើរតែដួលសន្លប់ដោយរូបគំនូរដាក់ស្តែងនេះ រូបគំនូររបស់គាត់មានទិដ្ឋភាពគួរអោយពិបាកមើលណាស់ រូបគំនូរនេះបានបង្ហាញនូវទិដ្ឋភាពដ៏សំខាន់ នៃភាពតក់ស្លុតរបស់គាត់ ហើយបើមើលតែពីរទៅបីវិនាទី អ្នកមើលពិតជាមានអារម្មណ៍ឈឺចង់ក្អួតចង្អោរ។ រូបគំនូរនេះបានលាតត្រដាងនូវដំណើរជីវិតដែលបានជួប នឹងភាពហ្នឹងថ្កល់នៅក្នុងរយៈកាលសម្លាប់រង្គាលដោយគ្មានលទ្ធភាពថា នឹងអាចផ្លាស់ប្តូរបាន ឬធូរស្រាលឡើយ។ កំហឹងពុះកញ្ជ្រោលបានបង្ហាញឡើងនៅចំណុចខ្លាំងបំផុតដែលខ្លួនខ្ញុំមិនដែលបានឃើញនឹងភ្នែក តែយើងពុំអាចចូលរួមទៅក្នុងការឈឺចាប់របស់គាត់បាន ដោយរូបភាពនោះពោរពេញទៅដោយសេចក្តីស្អប់ខ្ពើម ប្រាសចាកសីលធម៌។ សេចក្តីបញ្ជាក់ គឺផ្តោតទៅលើតែកត្តាពិត ដោយពុំរាប់បញ្ចូលកត្តាផ្សេងៗ នៃរឿងតក់ស្លុតឡើយ ដើម្បី នឹងលៃលកដោះស្រាយអារម្មណ៍របស់ខ្លួន តារាបានជ្រើសយកជីវិតអត់ន័យដែលពោរពេញ

ទៅដោយកំហឹងឃាតកម្ម និងទុក្ខព្រួយ។ ការស្តាប់រឿងរបស់គាត់មានន័យថា រូបអ្នកត្រូវតែអនុញ្ញាតអោយអារម្មណ៍របស់អ្នកទទួលភាពព្រៃផ្សៃនោះផងដែរ បន្ទាប់ពីមើលផ្ទាំងគំនូររបស់តាវា តែមួយភ្លែតក្បាលរបស់អ្នកចាប់ផ្តើមឈឺ ហើយអ្នកព្យាយាមលុបបំបាត់រូបភាពនោះចេញពីអារម្មណ៍របស់អ្នក។

ភាពជាសះស្បើយរបស់តាវាចាប់ផ្តើមឡើង ដោយគាត់បានទទួលស្គាល់គោលបំណងរបស់គាត់ទៅលើអនុភាពពិសពុល នៃរូបគំនូរ ដែលមានឥទ្ធិពលទៅលើជនទាំងឡាយដែលបានទទួលការបង្ខិតបង្ខំអោយមើលដោយផ្ទាល់ភ្នែក ជាពិសេសភរិយាថ្មី កូន និងអ្នកព្យាបាលចិត្តសាស្ត្ររបស់គាត់។ ជាទូទៅ ការរចនានៅលើផ្ទាំងគំនូរ ក៏បានបង្ហាញថាក្រុមគ្រួសាររបស់គាត់ទាំងអស់ ត្រូវគេសម្លាប់ចោលព្រៃផ្សៃជាងសត្វជាតុទៅទៀត ហើយគេកប់ចោលនៅក្នុងផ្នូរមរណៈរួមគ្នាដោយគ្មានវិធីបូជាសពសមស្របតាមមាគ៌ាព្រះពុទ្ធសាសនា ហើយវិញ្ញាណក្ខ័ន្ធ អ្នកទាំងនោះ នឹងរងទុក្ខវេទនា រហូតទាល់តែមានវិធីបុណ្យសពសាសនាធ្វើឡើង ទើបវិញ្ញាណក្ខ័ន្ធអ្នកទាំងនោះបានជួប នឹងសេចក្តីសុខ។ តំណាងនៃរូបគំនូរនេះ បានលាតត្រដាងជាបន្ថែមទៀតថា ក្រុមគ្រួសាររបស់គាត់ដែលត្រូវគេសម្លាប់នោះ នឹងនៅតែរស់រវើកដរាបណារូបគំនូរនៅតែមានរូបរាង។ ការចងចាំពុំភ្លេចបានបែបនេះអំពីក្រុមគ្រួសាររបស់គាត់ដែលស្លាប់អស់ទៅហើយ បានបង្ហាញរូបគាត់មិនអោយ
រវីរវល់ នឹងជីវិតថ្មី និងក្រុមគ្រួសារថ្មីរបស់គាត់។

ក្រោយពីដឹង និងពិភាក្សាអំពីបញ្ហាទាំងនេះ តាវាបានសម្រេចជោគជ័យទៅលើពន្លកការព្យាបាលដោយខ្លួនឯង ដោយគាត់ងាកមករកកូនក្រោយរបស់គាត់។ ដោយសន្សឹមៗ អស់រយៈកាលជាច្រើនឆ្នាំ គាត់ក៏បានបំពេញតួនាទីរបស់គាត់ជាឪពុក និងជាស្វាមី។ នៅក្នុងករណី ដែលការផ្លាស់ប្តូរសន្សឹមៗ នេះកើតមានឡើង ឥទ្ធិពលនៃរូបគំនូរក៏រម្ងាប់ទៅវិញ។ នៅទីបំផុតបុគ្គលិកខ្មែរបានប្រាប់គាត់ថា គាត់ត្រូវលាក់រូបគំនូរនោះទៅ។ នៅគ្រាដំបូងតាវាគាត់ផ្ទុះកំហឹងខ្លាំងណាស់ សេចក្តីសោកសៅទៅលើមរណៈភាពរបស់ក្រុមគ្រួសារគាត់បានផ្ទុះចេញមកវិញ តែក្រោយមកគាត់ក៏អាចដាក់រូបគំនូរនោះនៅក្នុងទូរដាក់ខោអាវ។ នៅពេលនេះគាត់អាចបង្វែរភាពបញ្ចាក់ទៅលើកត្តាពិត ដោយយករូបគំនូរជាតំណាងនោះ និងសេចក្តីភ័យខ្លាចរបស់គាត់ថាគាត់ពុំអាចបំពេញនូវតួនាទី បានដូចជា មនុស្សធម្មតា ជាពិសេស ទៅលើភរិយាក្រោយ និងកូនក្រោយរបស់គាត់ នៅគ្រាដែលតាវាដឹងខ្លួនថា គាត់បានធ្វើអោយជីវិតគាត់អន្តរាយ គាត់ក៏ចាប់ផ្តើមភាពជាសះស្បើយឡើងដោយសន្សឹមៗ។

## ១.១ អព្ភូតហេតុធម្មជាតិ

ជាមូលដ្ឋាន នៃការនិទានរឿង គឺជាសមត្ថភាពរបស់មនុស្សលោក នៅក្នុងការស្តាប់ និងយល់ដឹងសេចក្តីឈឺចាប់របស់អ្នកផ្សេងទៀត វាជាសកម្មភាពព្យាបាល អ្នកនិទានរឿង ហើយវាមានអត្ថប្រយោជន៍ ដល់អ្នកស្តាប់។ រឿងមិនត្រឹមតែបង្កើតទំនាក់ទំនងរវាងមនុស្សលោកទេ តែវាអាចបំបាត់ភាពនៅឆ្ងាយពីគេឯងដែលកើតឡើងដោយអំពើឧក្រិដ្ឋកម្ម វាក៏អាចការពារកុំអោយសេចក្តីចងចាំភាពកត់ស្លុត ជាធម្មជាតិរលត់សាបសូន្យ និងភាពធូរ

ស្រាលអារម្មណ៍របស់ជនតក់ស្លុតផ្លាស់ប្តូរដោយឆាប់រហ័ស លទ្ធផលដ៏ល្អនេះផុសចេញពីអព្ភូតហេតុធម្មជាតិនៃការយល់ដឹងអារម្មណ៍ទុក្ខសោក។

ការយល់ដឹងអារម្មណ៍ទុក្ខសោក គឺមានអត្ថន័យដូចជា "អនុភាពការសម្គាល់ខ្លួនដោយប្រើសតិអារម្មណ៍ (និងពោរពេញទៅដោយការយល់ដឹង)ទៅលើបុគ្គលិក ឬគោលដៅដែលគេ នឹងគិតត្រិះរិះមើល"។ នៅក្នុងផ្នែកចិត្តវិទ្យាសម័យទំនើបពាក្យដែលពណ៌នា អំពីដំណើរការដែលអ្នកព្យាបាលដាក់ខ្លួនគាត់ ឬខ្លួននាងដោយពាក់ស្បែកជើងរបស់អ្នកផ្សេងទៀត គឺដើម្បី នឹងទទួលបទពិសោធន៍សព្វយ៉ាង ដែលជននោះមាននៅក្នុងអារម្មណ៍ និងសេចក្តីសង្វេគរបស់គេ។ ប៉ុន្តែ ការបញ្ជាក់ទៅលើសេចក្តីសង្វេគរបស់អ្នករួចផុតពីសេចក្តីស្លាប់ គំនិតសម័យយល់ដឹងអារម្មណ៍ទុក្ខសោកទាំងនេះ អាចទទួលបរាជ័យដោយគេពុំទទួលស្គាល់ តម្លៃពិសេសជាងនេះទៅទៀត គឺទស្សនៈបទពិសោធន៍។

ជាងរាប់រយឆ្នាំកន្លងមក អ្នកចិត្តសាស្ត្រជាជាតិ អាល្លឺម៉ង់ រ៉ូប៊ីត វិសឈ័រ Robert Vischer បានរៀបរៀងពាក្យ Einuhlung ឬ "យល់ដឹងទុក្ខសោក" នៅក្នុងឃ្លាជាសិល្បៈរចនា។ លោក ទីអូឌ័រ លិប Theodor Lipps ជាអ្នកចិត្តសាស្ត្រជនជាតិ អាល្លឺម៉ង់ម្នាក់ទៀត ក្រោយមកគាត់បានយកពាក្យនេះមកប្រើក្នុងផ្នែកចិត្តសាស្ត្រ គាត់បានយកមកប្រើក្នុងការពន្យល់ដំណើរការសិល្បៈរចនា ទុកជាគោលដៅនៃការយល់ដឹងរបស់យើង ដែលបានបង្កើតសេចក្តីសង្វេគនៅក្នុងរូបយើង ហើយប្រាប់យើងអោយឆ្លើយតប ដោយអោយយើងធ្វើការរាវរកអត្ថន័យរបស់វា។

គាត់ និងអ្នកចិត្តសាស្ត្រជំនាន់មុន ដឹងថាសិល្បៈរចនាអាចបង្កើតសេចក្តីសង្វេគ និងគំនិតរបស់យើងដែលបញ្ចាំងអត្ថន័យមានភាពដូចគ្នា នឹងសិល្បៈរចនា ។ មនុស្សលោកអាចចាត់គុណភាពមនុស្សទៅជាវត្ថុគ្មានជីវិតដូចជាផ្ទាំងគំនូរ ដោយហេតុនេះគំនូរអាចបកស្រាយអត្ថន័យតាមរយៈសិល្បៈរចនា ដែលជាការព្យាយាមដ៏ប្រុងប្រយ័ត្នបំផុតរបស់មនុស្ស។ គំនិតនៃពាក្យ Einfühlung បានផ្លាស់ប្តូរដោយសន្សឹមៗ ទៅក្នុងគំនិតបច្ចុប្បន្ននៃការយល់ដឹងទុក្ខសោក ដែលគេយកមកប្រើនៅក្នុងការផ្តល់ឱវាទ និងការទាក់ទងផ្សេងៗ របស់មនុស្សលោក។

បើសិនជាការយល់ដឹងជាអំពើចាប់អារម្មណ៍ដែលចេញពីអាកប្បកិរិយាល្អ ដូច្នេះអ្នកស្តាប់ដែលយល់ដឹងរឿងតក់ស្លុត គឺបញ្ចេញអារម្មណ៍របស់ខ្លួនលើសពីភាពគ្រាន់តែធ្វើអោយអារម្មណ៍របស់ខ្លួនទោរទន់ ទៅតាមអារម្មណ៍រំជើបរំជួលរបស់អ្នករួចពីសេចក្តីស្លាប់ទៅទៀត។ ការយល់ដឹងរបស់អ្នកតាមសង្កេតមើលជាដំបូងត្រូវតែយល់ច្បាស់អំពីទិដ្ឋភាពដែលជិតនៅក្នុងអារម្មណ៍របស់ជន រួចផុតពីសេចក្តីស្លាប់ ទៅលើពិភពតក់ស្លុតដែលបំភ្លឺនៅក្នុងគំនិតរបស់ជនតាមសង្កេតមើល។ តាមរយៈសកម្មភាពយល់ដឹង អ្នកតាមសង្កេតមើលបន្ទាប់មកអាច "មើល" ទិដ្ឋភាពនៅក្នុងអារម្មណ៍ និងទទួលបទពិសោធន៍សេចក្តីរំភើបរាងកាយ អារម្មណ៍ និងគំនិតដែលទាក់ទងទៅ នឹងទិដ្ឋភាពទាំងនោះ។ បើសិនជាអ្នកតាមសង្កេតមើល គិតអំពីទិដ្ឋភាពតក់ស្លុតសតិអារម្មណ៍បែបគំនូរ គេនឹងពិនិត្យមើលទិដ្ឋភាពនោះ យ៉ាងលម្អិតជាធម្មជាតិដោយចាប់អារម្មណ៍ខ្លាំង និងចង់ដឹង។ ការយកចិត្តទុកដាក់ចង់ដឹងអាចទទួលលទ្ធផលប្រកបដោយជម្រៅ និងការយល់ដឹងពោរពេញទៅដោយអត្ថន័យក្នុងពិភពរបស់ជនរួចផុតពីសេចក្តីស្លាប់។ ការពិនិត្យឡើងវិញទៅលើរឿងតក់ស្លុត ជាបែបសិល្បៈគំនូរ ធ្វើអោយមានការឃ្លាតចេញ

បន្តិចបន្តួច តែវាបានផ្តល់នូវការយកចិត្តទុកដាក់ស្តាប់កាន់តែច្រើនឡើងដែលគួរអោយអស្ចារ្យ វាអាចជាការព្យាបាលដល់អ្នកនិទានរឿង និងអាចផ្តល់ព័ត៌មានច្បាស់លាស់ដល់អ្នកស្តាប់។

ការនិទានរឿង ជាដំណើរការមួយដែលមានឥទ្ធិពល ដោយអ្នកស្តាប់អាចបង្កើតជារូបភាពនូវអ្វីៗ ដែលអ្នកនិទានរឿងកំពុងតែរៀបរាប់ឡើង។ ជាច្រើនឆ្នាំខ្ញុំបានប្រមូលផ្តុំទិដ្ឋភាពរស់រវើក និងស្រស់បំព្រងនៃរឿង អ្នកជម្ងឺរបស់ខ្ញុំ តែខ្ញុំពុំបានចាត់ទុករឿងនោះទាក់ទងទៅ នឹងដំណើរការព្យាបាលឡើយ ។ អ្នករួចផុតពីសេចក្តីស្លាប់ខ្មែរម្នាក់ឈ្មោះ សុខាំ Sokham ទទួលបទពិសោធន៍រំជើបរជួលរាង្គកាយ និងមានអារម្មណ៍ភ័យស្លន់ស្លោរថាគាត់លង់ទឹក រៀងរាល់ពេលដែលគាត់លុបមុខ។ គាត់បានរាយការណ៍ថា នៅពេលគាត់ជាប់ទោសនៅក្នុងជុំរុំទោសករពលកម្មក្រោមរបបខ្មែរក្រហម គេប្រើគាត់ដូចសត្វគោ គេអោយគាត់អូសនង្គ័លភ្ជួរដីស្រែទឹកពេញប្រៀប។

ជាញឹកញាប់គាត់រអិលជើងដួលទៅក្នុងដីភក់ដោយនឹមនង្គ័លធ្ងន់ធ្ងរ ឬនឹមនង្គ័លឈើសង្កត់គាត់ ផ្កាប់មុខ គាត់រអិលរិតតែជ្រៅទៅៗ ក្នុងទឹក ហើយគាត់ចាប់ផ្តើមលង់ទឹក នៅពេលដែលខ្ញុំថែទាំសុខាំ ខ្ញុំពិបាកទ្រាំ នឹងទិដ្ឋភាពទាំងនេះណាស់។ វានៅតែដក់ជាប់ក្នុងអារម្មណ៍របស់ខ្ញុំ ជាការពិតពេលខ្លះនៅពេលដែលខ្ញុំកំពុងតែលុបមុខ ខ្ញុំបានទទួលបទពិសោធន៍ថា ទឹកហូរពេញភ្នែក និងមាត់របស់ខ្ញុំ ខ្ញុំភ័យស្លន់ស្លោរ ថាខ្ញុំកំពុងតែលង់ទឹក។ វិញ្ញាណ ដូចគ្នា រវាងបទពិសោធន៍របស់ខ្ញុំទៅលើទឹក និងបទពិសោធន៍ទារុណកម្មរបស់សុខាំ ជាសញ្ញាអោយដឹងថាភាពទទួលអារម្មណ៍បែបនេះ អាចធ្វើអោយសមត្ថភាពយល់ដឹងរបស់ខ្ញុំអោយសាបសូន្យ។

ពេលក្រោយៗមក ខ្ញុំបានធ្វើការយ៉ាងជិតស្និតជាមួយ នឹងអ្នកជម្ងឺរបស់ខ្ញុំ ហើយទិដ្ឋភាពនោះមានរូបរាងកាន់តែច្បាស់ឡើងហើយរិតតែមានឥទ្ធិពលខ្លាំងឡើង វាហាក់បីដូចជា ភាពយន្តដែលបញ្ចាំងឡើងព្រមគ្នានៅក្នុងអារម្មណ៍របស់ខ្ញុំ។ នៅទីបញ្ចប់ ខ្ញុំដឹងហើយបានទទួលស្គាល់ថាអ្នកជម្ងឺបានដាក់ទិដ្ឋភាពទាំងនោះនៅក្នុងខួរក្បាលរបស់ខ្ញុំ ហើយទោះបីជាយើងមានវប្បធម៌ផ្សេងៗគ្នាក៏ដោយ ខ្ញុំពិតជាអាចទទួលបទពិសោធន៍ហេតុការណ៍នោះដោយការមើលឃើញ។ ការយល់ដឹងកើតឡើងនៅពេលដែលម៉ារីណា Marina ដូនជីខ្មែរអោយុ ៦០ឆ្នាំ ម្នាក់បានចូលរួមនៅក្នុងកម្មវិធីប្រវត្តិសាស្ត្រផ្ទាល់មាត់។ អាកប្បកិរិយាខាងក្រៅគ្រប់បែបយ៉ាងរបស់ម៉ារីណា មានសភាពហាក់បីដូចជារីករាយ ហើយពុំមានទទួលបទពិសោធន៍ជូរចត់អ្វីពីខ្មែរក្រហមឡើយគាត់ស្លៀកពាក់ស កោរសក់អស់ មុខគាត់មានរាងមូល ដូចជាផ្លែប៉មភ្លឺរលោង ទឹកមុខញញឹមរបស់គាត់បញ្ចេញនូវភាពរីករាយ។

កាលពីវ័យកុមារម៉ារីណា ទទួលរងទុក្ខដោយភាពទុរគតខ្លាំង នៅក្នុងភូមិដាច់ស្រយាលតូចមួយនៅក្នុងប្រទេសកម្ពុជា។ ដើម្បី នឹងផ្តល់ជីវិតប្រសើរដល់រូបគាត់ ឪពុករបស់គាត់បានចាត់ចែងអោយគាត់រៀបការជាមួយ នឹងបុរសម្នាក់ដែលមានវ័យចាស់ជាងគាត់២៨ឆ្នាំ។ មង្គលការដ៏ជូរចត់នេះធ្វើអោយគាត់រលូតកូនជាច្រើនដង ទីបំផុតគាត់កើតបានកូនប្រុសមួយ ដែលធ្វើអោយគាត់រីករាយខ្លាំណាស់ គាត់ផ្តូរផ្តាច់ខ្លួនគាត់ ដើម្បីកូន។ តែដូចជាជនជាតិខ្មែរគ្រប់រូបបដិវត្តន៍ខ្មែរក្រហមបានសម្លាប់ក្រុមគ្រួសាររបស់គាត់អស់ នៅសល់តែខ្លួនគាត់និងកូនដែលនៅពេលនោះវាមានអាយុ២០ឆ្នាំ អ្នកទាំងពីរបានខិតខំកសាងជីវិតថ្មី តែនៅឆ្នាំ១៩៨០ ទ័ពវៀតណាម បានចូលមកនៅក្នុងភូមិរបស់គាត់ហើយវាចាប់ប្រុសៗ ខ្មែរ ជាពិសេសក្មេងៗ អោយចូលធ្វើជាទ័ពទាហ៊ាន

ប្រយុទ្ធជាមួយ នឹងទ័ពខ្មែរតស៊ូនៅព្រំដែនថៃ-ខ្មែរ។ ម៉ារីណា និងកូនរបស់គាត់បានលាក់ខ្លួននៅក្នុងខ្ទមមួយតែពួកទាហ៊ានបានរកពួកគេឃើញ នៅពេលដែលគាត់ជាម្តាយកំពុងស្រែកសុំអោយគេដោះលែងកូនគាត់ ពួកទាហ៊ានបានយកកាំភ្លើងមកក្ឆូងបង្ខំអោយកូនប្រុសក្មេងរបស់គាត់ចូលធ្វើជាទ័ពទាហ៊ាន។

នៅត្រង់ចំណុចនេះ ក្នុងរឿងរបស់ម៉ារីណា គាត់បានសុំពន្យល់ថាការបាត់បង់កូនរបស់គាត់ ពុំមែនដោយសារទ័ពវៀតណាមទេ តែវាដោយសារគាត់បានលេងសត្វខុសពីបែបបទកាលគាត់នៅវ័យកុមារៈ

ខ្ញុំគិតថាក្នុងអារម្មណ៍របស់ខ្ញុំប្រហែលជាពីជាតិមុន ឬនៅក្នុងជាតិនេះ ខ្ញុំពុំដឹងច្បាស់ទេថាខ្ញុំបានធ្វើបាបកូនសត្វមួយ។ ជនជាតិខ្មែរជឿថាយើង នឹងទទួលផលកម្មវេរា បើយើងធ្វើបាបកូនសត្វ យើងនឹងបែកបាក់ពីជនដែលយើងស្រលាញ់។ យើងមានកម្មបើសិនជាយើងធ្វើអោយសត្វជ្រុះរោម ឬបើសិនជាយើងយកកូនសត្វមកលេង។ ខ្ញុំគិតប្រហែលជាខ្ញុំធ្វើអំពើនេះនៅជាតិមុន ឬជាតិនេះ ហេតុដូច្នេះ ហើយបានជាខ្ញុំព្រាត់ប្រាស់ពីប្តី និងកូនរបស់ខ្ញុំ។ នេះជាសេចក្តីដែលខ្ញុំបារៀបរាប់ប្រាប់មនុស្សទាំងពួង នេះជាមូលហេតុ ដែលខ្ញុំព្យាយាមអស់ពីសមត្ថភាពធ្វើអំពើល្អ ដើម្បីកុំអោយខ្ញុំមានកម្ម ដោយជាតិនេះកាលពីក្មេងខ្ញុំបានលេងជាមួយកូនសត្វជៀរជើរនៅក្នុងសំបុក។

ខ្ញុំដាក់ដៃខ្ញុំចូលទៅក្នុងសំបុក យើងយកកូនសត្វចេញពីសំបុកមកលេង ហើយពេលខ្ញុំលេងរួច ខ្ញុំដាក់វាចូលទៅក្នុងសំបុកវាវិញ។ ខ្ញុំពុំចាំថា ខ្ញុំបានលេងកូនសត្វនេះចំនួនប៉ុន្មានថ្ងៃ ឬប៉ុន្មានខែទេ មុន នឹងពេលខ្ញុំឈប់លេងវានោះ ពេលនោះខ្ញុំនៅក្មេង ខ្ញុំនៅរត់លេងជងខ្លួនទរទេ ស្លៀកតែខោខ្លី គ្មានពាក់អាវទេ ដងខ្លួនខាងលើមានភាពននលគក។ ទិដ្ឋភាពដ៏ល្អសោភារបស់កុមារីតូចមួយកំពុងតែលេងជាមួយ និងកូនសត្វ បំបាត់នូវហេតុការណ៍ពិត បទពិសោធន៍ជីវិតរបស់ ម៉ា រីណាមានភាព ហាក់បីដូចជា គំនូរទេសភាពរស់រវើក។ ជីវភាពទុគតតែប្រកបដោយភាពសុខសាន្តរបស់គាត់កាលពីវ័យកុមារ បានកែប្រែអំពើឃោរឃៅរបស់ជនល្មើស។ ម៉ារីណា បានស្វែងរកមូលហេតុ "អ្វី" អំពីសេចក្តីទុក្ខសោកប្រចាំថ្ងៃរបស់គាត់ដោយគាត់ពុំដឹងពីវាសនារបស់កូនគាត់ ហើយគាត់បានរៀបរាប់នូវសេចក្តីទុក្ខសោក នេះតាមរយៈរឿងសត្វ ពិភពជីវិតរបស់ម៉ារីណា អាចមានភាពពេញលេញឡើងវិញ នៅគ្រាដែល ផ្នែកទាំងឡាយដែលបានបំផ្លាញ ឬខូចខាតនោះបានទទួលការជួសជុលឡើងវិញ និងដាក់ជំនួសវិញ។ ដំណើរការព្យាបាលដោយខ្លួនឯងបង្កើតនូវពិភពធម្មជាតិថ្មី នៅពេលដែលអ្នកស្តាប់អនុញ្ញាតអោយអានុភាពទិដ្ឋភាពពិភពលោកទាំងនេះប្រែទៅជាការមើលឃើញវិញ វាអាចផ្តល់នូវការយល់ដឹង និងគាំទ្រដល់ដំណើរការព្យាបាលរបស់អ្នកនិទានរឿង។

## ១.២ ទំនាក់ទំនង ផ្នែកវប្បធម៌

ការយកចិត្តទុកដាក់ទៅលើរឿងតក់ស្លុត របស់អ្នកនិទានរឿង ជាញឹកញាប់ត្រូវរារាំង ដោយភាពលំអៀងសង្គមនិងវប្បធម៌។ បើសិនជាអ្នកស្តាប់ប្រឆាំង នឹងអ្នកនិទានរឿង ដំណើរការយល់ដឹង នឹងពុំអាចចាប់ផ្តើមបានឡើយ វាជាការប្រសើរបើយើងធ្វើជាគថ្លង់ទៅលើជនដែលយើងពុំចូលចិត្ត គោរព ឬទុកចិត្ត។ ទោះបីជាយ៉ាងណាក៏ដោយ ចំណងទាក់ទងអាចធ្វើឡើង រវាងវប្បធម៌ពីរដើម្បីធ្វើអោយមានការយល់ដឹង និងយកចិត្តទុកដាក់

ទៅលើបទពិសោធន៍តក់ស្លុតក្នុងជីវិតរបស់គ្នាទៅវិញទៅមក ភាពពិតប្រាកដនេះក្លាយទៅជាភាពជាក់ស្តែង នៅក្នុងចំណោមជនរួចផុតពីសេចក្តីស្លាប់ នៅក្នុងករណីរញ្ជួយផែនដី នៅទីក្រុងកូបេ Kobe ប្រទេសជប៉ុន។ នៅវេលាម៉ោង ៥:៤៦ ព្រឹក ថ្ងៃទី១៧ ខែ មករា ឆ្នាំ១៩៩៥ ភាពរញ្ជួយផែនដីបានកើតមានឡើងនៅលើ ភូមិភាគជីគោក ប្រទេសជប៉ុន បណ្តាលអោយមានសោកនាដកម្មដ៏មហិមាទាំងរាង្គកាយ ទាំងផ្លូវចិត្ត ។ ភាពរញ្ជួយផែនដីកើងឡើង ចំនួន ម្ភៃពីរវិនាទី ចំណុចដែលការរញ្ជួយផែនដីកើតមានឡើង មានចម្ងាយ ម្ភៃពីរគីឡូម៉ែត្រ ពីសមុទ្រ ទីក្រុងកូបេ Kobe ប្រជាជនប្រមាណជាង ៥,៥០០ នាក់ ស្លាប់ ៣៤,៥០០នាក់របួស និងជាង ៣២០,០០០នាក់ គ្មានទីជម្រក ។ ផ្ទះសម្បែងជាង ៨០,០០០នាក់ ត្រូវកំទេចចោល ហើយផ្ទះជាង ១០០,០០០នាក់ ត្រូវខូចខាតខ្លះៗ ។ ក្រុមជំនាញ ផ្នែកសតិអារម្មណ៍ នៃមន្ទីរពេទ្យព្យាបាលសតិអារម្មណ៍ឥណ្ឌូចិន និងអ្នកជំនាញមនុស្សសាស្ត្រជប៉ុននាំគ្នាចូលទៅទីក្រុងកូបេ Kobe ដែលទទួលភាពវិនាសខូចខាតនៅកំណត់ ១០ថ្ងៃ បន្ទាប់ពីភាពមហន្តរាយបានកើតឡើង។

គោលដៅដ៏សំខាន់មួយរបស់យើង គឺធ្វើការបញ្ជាក់ទៅលើស្ថានភាពសតិអារម្មណ៍របស់ជនរួចផុតពីសេចក្តីស្លាប់ដោយគ្រោះរញ្ជួយផែនដី ដើម្បីជួយប្រទេសជប៉ុន ក្នុងការព្យាយាមសង្គ្រោះមនុស្ស។ យើងសម្ភាសន៍មនុស្សរាប់រយនាក់ ដែលបាត់បង់ទីជម្រកដោយគ្រោះមហន្តរាយ ទោះបីជាមានការជឿជាក់ដ៏ធំធេងថា ប្រជាជនជប៉ុនពុំនិយាយបញ្ចេញភាពទុក្ខព្រួយរបស់ខ្លួន ជាពិសេសទៅដល់ជនជាតិផ្សេងទៀតនោះ គតិបណ្ឌិតនិយមនេះ ពិតជាពុំត្រឹមត្រូវឡើយ។ អ្នករួចផុតពីសេចក្តីស្លាប់ ដោយគ្រោះរញ្ជួយផែនដីបានចូលរួមចំណែកសន្ទនាដោយភាពកក់ក្តៅ និងស្និទស្នាល គេបាននិយាយពីបទពិសោធន៍តក់ស្លុតរបស់គេដោយលម្អិត និងស្និទស្នាល ហើយបានធ្វើអោយភាពលំបាកដោយភាសា និងវប្បធម៌ខុសគ្នា ទៅជាមានភាពងាយស្រួលវិញ។

ការសម្ភាសន៍របស់យើងជាមួយ នឹងខ្យូកូ Kyoko ស្ត្រីចាស់ជរាម្នាក់ ជាការសម្ភាសន៍ធម្មតា គាត់អង្គុយនៅលើកំរាល ទំហំធំប៉ុនកំរាលព្រំតូចមួយ ហើយនៅជុំវិញគាត់មានរបស់របរសេសសល់ដែលជាកម្មសិទ្ធ ផ្ទាល់ខ្លួនរបស់គាត់ នៅក្នុងសាលារៀនជាទីជម្រកដែលគាត់កំពុងតែស្នាក់នៅ។ កំរាលធ្វើអំពីដើមស្រូវជាផ្ទះរបស់គាត់នៅក្នុងចំណោមកំរាលផ្ទះរាប់ពាន់ ជម្រកនោះត្រជាក់ខ្លាំណាស់ នៅក្នុងពេលធ្វើសម្ភាសន៍គាត់ឃើញថា ខ្ញុំរងារ ទោះបីជាគ្មានម្ហូបអាហារក៏ដោយគាត់បានដាំតែបែតងអោយខ្ញុំ។ ថ្វីបើសន្ទះចិត្តរបស់ខ្ញុំប្រាប់ខ្ញុំថា ខ្ញុំត្រូវបដិសេធដោយគាត់មានការខ្វះខាតខ្លាំងណាស់ តែដោយខ្ញុំយល់ ខ្ញុំក៏ទទួលយកទឹកតែតាមទំនៀមទម្លាប់រាក់ទាក់ទទួលភ្ញៀវរបស់គាត់ទៅ។

ទោះបីជាខ្យូកូ Kyoko បាត់បង់អ្វីៗ ស្ទើរតែទាំងអស់ទៅហើយ នៅពេលដែលខ្ញុំសួរអោយគាត់បរិយាយពីបទពិសោធន៍តក់ស្លុតរបស់គាត់ គាត់និយាយតែពីការខ្វះខាតភាពឯកជន និងភាពអាម៉ាស់មុខដោយរស់នៅក្នុងជម្រកជន្លៀសជាមួយ និងមនុស្សដែលគាត់ពុំធ្លាប់ស្គាល់។ វាធ្វើអោយគាត់មានអារម្មណ៍ខ្វល់ខ្វាយ នៅពេលដែលពុំអោយគាត់ធ្វើអ្វីទាំងអស់ ដើម្បីជួយខ្លួនគាត់ និងអ្នកឯទៀត គាត់បានបរិយាយអំពីការឈរតម្រង់ជួរចាំរាប់ម៉ោង ដើម្បីជួប និងវេជ្ជបណ្ឌិតនៅទីជម្រក។ នៅពេលដល់វេនគាត់ គាត់បានប្រាប់វេជ្ជបណ្ឌិតថាគាត់មានអារម្មណ៍

ខ្វល់ខ្វាយ គាត់សំរាន្តមិនលក់ ហើយគាត់ខ្លាចទីជម្រក វេជ្ជបណ្ឌិតបានស្រែកឡើងយ៉ាងខ្លាំង នៅចំពោះមុខអ្នកជម្ងឺជាច្រើននាក់ ដែលកំពុងតែរង់ចាំ ថាគាត់អាត្មានិយម គិតតែប្រយោជន៍ខ្លួនឯង ហើយទន់ខ្សោយដោយគាត់ធ្វើការស្នើសុំសេចក្តីត្រូវការផ្ទាល់ខ្លួន ដែលគួរអោយអស់សំណើចបែបនេះ។ វេជ្ជបណ្ឌិតនោះបាននិយាយឡើងថា រូបគាត់ធ្វើអោយខាតបង់ពេលវេលារបស់វេជ្ជបណ្ឌិត និងអ្នកជម្ងឺដែលត្រូវការការព្យាបាល។ បន្ទាប់ពីវេជ្ជបណ្ឌិតបន្ទាបកិត្តិយសរបស់គាត់ជាសាធារណៈ វេជ្ជបណ្ឌិតនោះបានដេញគាត់ចេញ ដោយបង្ហាញនូវភាពបរាជ័យទាំងស្រុងទៅលើភាពយល់ចិត្ត។ ព្រមគ្នា នឹងពេលដែលយើងកំពុងតែញុំាទឹកតែ ហើយគាត់បានបញ្ចប់រឿងរបស់គាត់ ទឹកភ្នែកគាត់ហូរត្របាញ់ចេញពីកែវភ្នែកទាំងពីររបស់គាត់។

អារម្មណ៍ទំនាក់ទំនងខ្លាំងរវាងស្ត្រីជប៉ុន ជាពិសេសស្ត្រីចាស់ជរា និងជនជាតិអាមេរិកកាំង នៅក្នុងពេលនោះ បានគិតថាពិតជាមិនអាចសម្រេចបានឡើយ។ កាលពីហាសិបឆ្នាំមុន ថ្ងៃជួបប្រជុំរបស់យើង អាមេរិកកាំងបានទម្លាក់គ្រាប់បែកវាយប្រហារទីក្រុងខូបេ Kobe ហើយបានបំផ្លាញទីក្រុង ធ្វើអោយខ្យូកូ Kyoko គ្មានជម្រកនិងក្រខ្សត់។ គាត់បាននិយាយថាគាត់មិននឹកស្មានសោះថា ហាសិបឆ្នាំ ក្រោយមកគាត់បានអង្គុយញុំាទឹកតែជាមួយ នឹងវេជ្ជបណ្ឌិតអាមេរិកកាំង ដែលបានស្តាប់ប្រវត្តិដំណើររឿងតក់ស្លុតក្នុងជីវិតរបស់គាត់។ ការយល់ចិត្តបានបំពេញចំណងវប្បធម៌ និងភាសារដែលចែករូបយើងទីទៃពីគ្នា អារម្មណ៍ដែលយើងមាននៅពេលនោះ បានបកស្រាយយ៉ាងរណ្តំនៅក្នុងកំណាព្យតាំងកា Tanka ដែលនិពន្ធដោយអ្នករួចផុតពីសេចក្តីស្លាប់ពីភាពរញ្ជួយផែនដី ស៊ូម៉ាកូ ហារាដា Sumako Harada ៖ ទឹកមុខពិតរបស់យើង បានបរិយាយថា នឹងបញ្ចេញភាពពិត ទឹកមុខពិតរបស់គាត់ នៅពេលដែលយើងបាត់បង់សំលៀកបំពាក់ ម្ហូបអាហារ និងផ្ទះសម្បែងជាទីកម្រិតអត្តិភាព (ជីវិត)។

## ១.៣ រឿងតក់ស្លុតជាកម្មបទសិល្បៈ

សមត្ថភាពរបស់មនុស្ស ក្នុងការស្តាប់ដោយយកចិត្តទុកដាក់ ពុំធានាអះអាងថាអ្នកផ្សេង នឹងស្តាប់ដំណើររឿងជីវិតតក់ស្លុតដូចគ្នាឡើយ។ ជាញឹកញាប់អ្នកស្តាប់ត្រូវតាំងចិត្ត ហើយទប់អារម្មណ៍កុំអោយមានប្រតិកម្ម ទៅលើហេតុការណ៍តក់ស្លុតដោយប្រាប់ខ្លួនឯងថា "ខ្ញុំទ្រាំស្តាប់លែងបានទៀតហើយ" ឬ "រឿងនេះធ្វើអោយខ្ញុំខឹងខ្លាំងណាស់ ដូចគ្នា នឹងរឿងផ្សេងៗ ទៀតដែលខ្ញុំបានស្តាប់ឮ" ។ នៅពេលដែលភាពជួបប្រទះកើតមានឡើងជាដដែល រួមនឹងការយល់ចិត្តច្រើនលើសលប់មនុស្សខ្លះបានដកខ្លួនចេញ ហើយបដិសេធមិនស្តាប់តទៅទៀតទេ។ ជាកត្តាពិតការស្តាប់យកចិត្តទុកដាក់ ហាក់បីដូចជា ផ្លែដាវមានមុខពីរដោយអ្នកស្តាប់យកចិត្តប្រកបដោយអារម្មណ៍ ករុណា មេត្តា ពុំត្រឹមតែអាចភ្ជាប់ទំនាក់ទំនងបានយ៉ាងប្រសើរជាមួយ នឹងអ្នកនិទានរឿងតក់ស្លុតនោះទេ គេថែមទាំងទោរទន់អារម្មណ៍ទាំងស្រុងទៅ នឹងសេចក្តីសង្វេគចិត្ត និងទិដ្ឋភាពតក់ស្លុតដែលអ្នកនិទានរឿងបានទទួលបទពិសោធន៍ទៀតផង។ អ្នកនិទានរឿងត្រូវតែដឹងថា "រៀបរាប់តែល្មម" ហើយកុំធ្វើអោយ

អ្នកស្តាប់ទទួលអារម្មណ៍រំភើបហួសពេក អ្នកនិទានរឿងក៏ត្រូវតែដឹងអំពីសមត្ថភាពរបស់អ្នកស្តាប់ដោយយកចិត្ត ហើយប្រើមធ្យោបាយចូលរួមនៅក្នុងការនិទានរឿង។

អ្នកនិទានរឿងគួរតែយល់ដឹងនូវវិធីនិទានរឿងល្អ ឧទាហរណ៍ គេត្រូវតែដឹងថាសញ្ញាសម្រាប់ បង្ហាញរឿងដែលមានតែមួយគត់សម្រាប់បទពិសោធន៍របស់ខ្លួន។ រឿងតក់ស្លុតពោរពេញទៅដោយសញ្ញាបង្ហាញជីវៈប្រវត្តិផ្ទាល់ខ្លួន និងវប្បធម៌។ រូបភាពដែលមានឥទ្ធិពល គឺបានប្រើឡើងជាតំណាងបទពិសោធន៍ជីវិត ប្រតិកម្មអារម្មណ៍ និងអាកប្បកិរិយា វាបកស្រាយនូវអ្វីៗ ដែលគ្មានពាក្យ ឬអាចនិយាយអោយចំៗបាន។ អ្នកកាសែតស្រុករ៉ាន់ដាន Rwandan បាននិយាយអំពីនិមិត្តរូប នៃបទពិសោធន៍របស់គាត់ទៅលើអំពើសម្លាប់រង្គាលនៅក្នុងប្រទេសរបស់គាត់ ដោយរៀបរាប់ថាគាត់បានជួបប្រទះ នឹងបុរសម្នាក់ចំអិនអាហារនៅលើគំនរឆ្អឹងមនុស្ស ជាទិដ្ឋភាពសាមញ្ញតែមានអត្ថន័យស្មុគ្រស្មាញ។ និមិត្តសញ្ញាជាដំណើរការដែលដកស្រង់ផ្នែកផ្សេងៗ ជាច្រើនចេញពីពិភពតក់ស្លុត ហើយយកវាមកផ្គុំគ្នា ដើម្បីធ្វើជាចំណងទាក់ទងដ៏ជិតស្និទតែមួយ នៅពេលដែលអ្នករួចផុតពីសេចក្តីស្លាប់មកមន្ទីរពេទ្យព្យាបាល ហើយចាប់ផ្តើមរៀបរាប់ដំណើររឿងរបស់គេ គេមានការពិបាកក្នុងការនិយាយអោយបានក្បោះក្បាយអំពីភាពខូចខាតដល់កាយសម្បទា និងសតិអារម្មណ៍របស់គេ។

ចំពោះទំនាក់ទំនងរវាងវេជ្ជបណ្ឌិត និងអ្នកជម្ងឺ ថ្នាំពេទ្យអាចយកមកប្រើជានិមិត្តសញ្ញា នៃដំណើរការព្យាបាលដោយខ្លួងឯង។ ត្រាង Tran អ្នកជម្ងឺវ័យមជ្ឈឹមជនជាតិវៀតណាមម្នាក់ ដែលធ្លាប់ជាប់គុកនៅក្នុងសង្គ្រាមបាននិយាយថាគាត់ពិតជាស្លាប់ បើសិនជាគេឈប់ផ្តល់ថ្នាំពេទ្យអោយគាត់ដោយរដ្ឋាភិបាលកាត់បន្ថយថវិកា ទោះបីជាថ្នាំពេទ្យ ពុំសំខាន់សម្រាប់ជីវិតរបស់គាត់ ហើយគាត់គ្មានជម្ងឺអ្វីដែលយាយីដល់ អាយុជីវិតរបស់គាត់ក៏ដោយ។ ចំពោះរូបគាត់ថ្នាំពេទ្យជានិមិត្តរូបដែលមានឥទ្ធិពលក្នុងការផ្តល់កម្លាំងជីវិតនៅក្នុងសង្គមថ្មី បន្ទាប់ពីការទទួលទារុណកម្មជាច្រើនឆ្នាំ នៅប្រទេសវៀតណាម ហើយគាត់បានប្រើថ្នាំនោះយ៉ាងខ្ជាប់ខ្ជួន ដើម្បីទប់ស្កាត់ជម្ងឺប្រចាំកាយ និងបញ្ហាសតិអារម្មណ៍។ អ្នកនិទានរឿងផ្សេងៗទៀត ក៏បាននិយាយអំពីខ្លួនគេដោយប្រៀបធៀបខ្លួនគេនៅ នឹងសត្វស្លាបតូចផ្សេងៗ ជាសត្វដែលគេច្រើនតែធ្វើបាប។

ការបញ្ចេញអារម្មណ៍ជាលក្ខណៈដ៏សំខាន់ នៃការនិទានរឿង តើអ្នកនិទានរឿងធ្វើបែបណាទៅដើម្បីកុំអោយអ្នកអានមានអារម្មណ៍រំជើបរំជួលខ្លាំង? ជនតក់ស្លុតជាច្រើនរូប មានគុណវិបត្តិអាម៉ាស់មុខពីរបែបក្រៀមក្រំ និងអស់សង្ឃឹមជាគុណវិបត្តិមួយ ហើយគុណវិបត្តិមួយទៀត គឺកំហឹង និងគំនុំសងសឹកទៅលើជនឯទៀត។ ជនតក់ស្លុតខ្លះៗ រេទៅរេមករវាងគុណវិបត្តិទាំងពីរនេះ នៅពេលដែលជនផ្សេងៗទៀតផ្តោតអារម្មណ៍ទៅលើតែការស្អប់ខ្ពើម និងការសងសឹក។ ជនខ្លះដែលក្រៀមក្រំដោយការបាត់បង់ ក៏ទទួលអារម្មណ៍សង្ឃឹម រីករាយ និងកំប្លែងលេងសើច។ អារម្មណ៍ទូទៅមួយទៀត គឺភ័យខ្លាច អ្នករួចផុតពីសេចក្តីស្លាប់អាចភ័យមិនហ៊ានចេញពីផ្ទះតែម្នាក់ឯង ដោយគេខ្លាចថាមានរឿងអាក្រក់កើតឡើងដល់រូបខ្លួន និងក្រុមគ្រួសារ។ សេចក្តីភ័យខ្លាចកំណត់នូវអ្វីៗដែលគេចង់ធ្វើ អ្នកដែលគេចង់ជួប នឹងទីកន្លែងដែលគេចង់ទៅ អាចរហូតដល់ក្លាយទៅជាគេដាក់ខ្លួនឯង ព្រោះ

តែសេចក្តីភ័យខ្លាច។ អ្នកនិទានរឿងត្រូវតែដឹងថា អ្នកស្តាប់ដែលមានអារម្មណ៍ទោរទន់ និងទទួលអារម្មណ៍មានថាមពល(កម្លាំង)កម្រិតដូចគ្នា។

នៅពេលដែលយករឿងតក់ស្លុតមកទស្សនាជាបែបសោភ័ណភាព ដូចជាសិល្បៈរចនា វាមានរួចទៅដោយរចនាបថ និងនិមិត្តសញ្ញា និងអត្តចរិករំជួលចិត្ត រចនាបថដែលអ្នករួចផុតពីសេចក្តីស្លាប់បានបង្ហាញអំពីបទពិសោធន៍របស់គេជាសារៈសំខាន់ណាស់។ ទំនាក់ទំនងបែបខ្លះៗ ងាយស្រួលទាក់ទង និងងាយយល់ជាងបែបផ្សេងៗទៀត។ អ្នករួចផុតពីសេចក្តីស្លាប់ខ្លះសោះអង្គើយ ហើយមិនសូវនិយាយស្តី ខណៈដែលអ្នកផ្សេងទៀត ធ្វើអោយព្រឹត្តិការណ៍មានភាព ដូចជាល្ខោនហើយរៀបរាប់បានយ៉ាងច្រើន អ្នះខ្លះពោរពេញទៅដោយសេចក្តីរីករាយ និងគួរអោយស្រលាញ់ ខណៈដែលអ្នកខ្លះធ្វើគួរអោយស្អប់ និងពោរពេញទៅដោយទុក្ខព្រួយ។ អ្នកក្រៅពុំបានរៀបចំខ្លួនទទួល ការនិយាយកំប្លែងលេងសើចអំពីលក្ខណៈបុគ្គលជនជាតិស្បែកខ្មៅដែលនិទានរឿងឡើងយ៉ាងច្រើន ជារឿងព្រេងរបស់ជនជាតិបូស្សនានៅក្នុងសង្គ្រាម។ រឿងកំប្លែងល្បីនៅប្រទេសបូស្សនា Bosnia និយាយអំពីក្មេងប្រុស ម៉ូស្លីម Muslim ម្នាក់ ដែលកំបុតដៃជើងដោយគ្រាប់មីន វាបានគេចវេងចោលអវៈយវៈសិប្បនិមិត្ត(ក្លែងក្លាយ)នោះតាមបង្អួចសាលារៀន ព្រោះវា "រត់គេចជីវិតបំណែករបស់វា" រចនាបថចង្វាក់ដែលអ្នករួចផុតពីសេចក្តីស្លាប់ធ្វើចលនានៅក្នុងពិភពលោក។ រឿងផ្តល់នូវ "ស្នាដៃ" ប្លែកតែមួយគត់របស់វិចិត្រករ នៅក្នុងករណីនេះ គឺអ្នករួចផុតពីសេចក្តីស្លាប់ដោយភាពតក់ស្លុត។

រឿងដែលបានរៀបចំ និងផ្សព្វផ្សាយឡើងដោយល្អ ជួយបណ្តុះបណ្តាលជីវៈប្រវត្តិ សតិអារម្មណ៍ និងដំណើរសង្គមសាស្ត្រ នៃការព្យាបាលដោយខ្លួនឯង។ ជនជួបប្រទះ នឹងភាពតក់ស្លុតអាចទទួលផលដ៏ច្រើនក្នុងការចូលរួមសហប្រតិបត្តិការជាមួយ នឹងអ្នកស្តាប់ បើសិនជាគេនិយាយរឿងតក់ស្លុតរបស់គេបានដោយចប់សព្វគ្រប់។ តែការនិយាយរឿងតក់ស្លុតដោយលម្អិតពិតជាពុំគ្រប់គ្រាន់ឡើយ រឿងត្រូវតែនិយាយឡើងជាបែបបទដែលអ្នកផ្សេងៗទៀត អាចបន្តការស្តាប់បាន ដោយគ្មានភាពរន្ធត់ហួស ឬលែងចង់ស្តាប់តទៅទៀត។ ដោយមានរួមទៅដោយការណែនាំ របស់អ្នកព្យាបាល ញាតិសន្តាន ឬមិត្តភក្តិជួយគាំទ្រដោយជឿជាក់ ទៅលើដំណើរនិទានរឿង អ្នកនិទានរឿង អាចរៀនអំពីវិធីសំណោះសំណាលអំពីបទពិសោធន៍របស់គេ ជាមួយអ្នកដទៃប្រកបដោយជោគជ័យ។

ការណែនាំ អាចជួយអ្នកនិទានរឿងប្តូរអារម្មណ៍តានតឹង ដែលកើតមានឡើយ ដោយបទពិសោធន៍ឃោរឃៅ និងរបៀបដែលគេនិយាយបញ្ចេញ។ អារម្មណ៍ទោរទន់ខ្លាំងត្រូវតែទប់អោយជាប់ ដើម្បីកុំអោយមានអារម្មណ៍នោះបកស្រាយជំនួសអត្ថន័យរឿង នៅក្នុងសង្គមរបស់យើង សកម្មភាពរុញច្រានជាច្រើនទាក់ទងនឹងភាពតក់ស្លុត ការផ្តល់ពត៌មានសង្ខេបសេចក្តីរាយការណ៍ពីអំពើឃោរឃៅ ការបញ្ចាំងហ្វីល និងកម្មវិធីជាសាធារណៈ ដែលបញ្ជាក់ទិដ្ឋភាពសមហេតុផលបំផុត នៃអំពើឃោរឃៅនៅក្នុងសហគមន៍ គឺធ្វើឡើងដោយការធ្វេសប្រហែស ឬដោយចេតនា ដើម្បីផ្សព្វផ្សាយអារម្មណ៍ពិសពុល។ អ្នករួចផុតពីសេចក្តីស្លាប់ ដឹងខ្លួនថាសារៈសំខាន់

នៃការបញ្ចេញអារម្មណ៍ គឺធ្វើឡើងជាបែបមួយ ដែលពុំធ្វើអោយអ្នកស្តាប់ មានអារម្មណ៍ថារំជើបរជួលពន់ពេក ពេលនោះគេអាចរម្ងាប់អារម្មណ៍របស់គេបាន ហើយអាចសំណេះសំណាលជាបែបបទមួយសមស្របមួយវិញ។

សេចក្តីណែនាំ ក៏អាចជួយជម្រុញអោយមានការប្រើ ការស្រម៉ៃ និងការច្នៃប្រឌិត ដើម្បីនិយាយរឿងតក់ស្លុតអោយបានចប់សព្វគ្រប់។ ជនតក់ស្លុតត្រូវគិតថ្លឹងថ្លែងការប្រើសេចក្តីប្រៀបធៀប និងនិមិត្តសញ្ញាអាចជួយអោយគេបញ្ចេញអារម្មណ៍ និងគំនិតរបស់ខ្លួន ហើយរបៀបដែលគេនិយាយរឿងអាចធ្វើអោយសារដំណឹងរបស់គេរិតតែមានខ្លឹមសារឡើងថែមទៀត។ វាជាករណីកម្រមានដោយរឿងខ្វះភាពក្បោះក្បាយមិនគួរអោយចាប់អារម្មណ៍ និងខ្វះការយល់ដឹងជ្រៅជ្រះ តែអ្នកនិទានរឿង អាចត្រូវការសេចក្តីលើកទឹកចិត្ត ដើម្បីរៀបចំរឿងរបស់គេអោយបានល្អ ។ ពេលខ្លះការពិនិត្យរឿងឡើងវិញជាលាយល័ក្ខអក្សរ ឬខ្សែអាត់សម្លេងអាចជួយក្នុងដំណើរការនេះ អ្នកស្តាប់ប្រកបដោយភាពយកចិត្ត ហើយដើរតួជាអ្នកណែនាំអាចជាជំនួយសំខាន់ បើសិនជាដំណើរការនេះធ្វើអោយនឹកឃើញរឿងឈឺចាប់ខ្លាំង ដែលធ្វើឡើងដោយឯកឯង វាក៏ជាសារៈសំខាន់ក្នុងការយល់ដឹងថារឿងតក់ស្លុតអាចនិទានរឿងឡើងដោយសង្ខេបជាផ្នែកនីមួយៗ ជាជាងការនិទានរឿងអោយចប់តែម្តង។ នៅក្នុងមន្ទីរពេទ្យព្យាបាលរបស់យើង យើងមានពាក្យសម្រាប់បរិយាយករណីនេះ ៖ "តិចៗ ក្លាយទៅជាច្រើនក្នុងរយៈពេលយូរលង់"ភាពសម្ងាត់របស់ អ្នកនិទានរឿងក្នុងការ រកអ្នកដទៃអោយជួយ អាចត្រូវការ ការបញ្ជាក់អះអាងឡើងវិញ។

សេចក្តីឈឺចាប់ដែលបណ្តាលអោយឡើងដោយអំពើបំពានរបស់មនុស្សលោក ជាញឹកញាប់ធ្វើអោយសមត្ថភាពច្នៃប្រឌិត និងការសំណេះសំណាលដោយបើកចំហទៅវិញទៅមករបស់បុគ្គលនោះអន់ថយ ដោយគេភ័យខ្លាច និងភាពអាម៉ាស់មុខ និងអំពើឃោរឃៅនៅអនាគតកាល។ ជនតក់ស្លុតគួរតែទទួលជំនួយដែលធ្វើអោយគេដឹងខ្លួនថា ខ្លួនគេមានអ្វីៗ ដែលជនគ្រប់រូប និងសង្គមត្រូវការ និងចង់បាន មនុស្សគ្រប់រូបចង់ដឹងពីរបៀបដោះស្រាយវិបត្តិបាត់បង់ សោកនាដកម្ម ការព្យាបាទ និងសេចក្តីឈឺចាប់ក្រុមគ្រួសារ និងសហគមន៍។ ស្នាដៃអក្សរសិល្បៈ ដែលមានតម្លៃជាយូរអង្វែង គឺយោងទៅតាមចំណង់របស់មនុស្សទៅលើចំណេះដឹងបែបនេះ។ អ្នករួចផុតពីសេចក្តីស្លាប់ ត្រូវគេរុញច្រានអោយឡើងលើឆាកសម្តែងដោយព្រេងវាសនា ហើយត្រូវបានទទួលឱកាសអោយបានបង្រៀនយើងគ្រប់ៗគ្នាអំពីវិធីដោះស្រាយសោកនាដកម្ម និងអំពើឃោរឃៅរបស់មនុស្សលោក។

អ្នករួចផុតពីសេចក្តីស្លាប់ ត្រូវតែធ្វើពើដោយចាត់ខ្លួនថាមានអត្តចរិតល្អជាក់លាក់ តែគេត្រូវតែដឹងថាដំណើរការភាពជាសះស្បើយភាគច្រើន អាចនាំមកនូវការយល់ដឹងជ្រៅជ្រះ សេចក្តីសង្ឃឹម និងថែមទាំងភាពរីករាយ។ ជនតក់ស្លុតភាគច្រើនមានចំណូលចិត្តដោយគិតថារឿងរបស់ខ្លួន នឹងអាចជួយអ្នកឯទៀតបាន។

វិធីប្រសើរបំផុតសម្រាប់ជួយអ្នករួចផុតពីសេចក្តីស្លាប់ ការរៀបរាប់រឿងរបស់ខ្លួន គឺអោយគេបំពេញតួនាទីជាគ្រូបង្រៀន។ មធ្យោបាយនេះបានទទួលស្គាល់ថា ជនគ្រប់រូបត្រូវការការរៀនសូត្រផ្សេងៗ ពីអ្នកទទួលបទពិសោធន៍ឃោរឃៅ ។ ផងដែរវាក៏ជួយបង្វែរដំណើរការព្យាបាលដោយប្រើការនិទានរឿងរបស់ជនតក់ស្លុត ហើយ

ត្រូវបញ្ជាក់ ពីផលប្រយោជន៍ដល់ទូលំទូលាយទៅលើសង្គមជាទូទៅ ។ វិធីនេះ គឺបញ្ជាក់បន្ថែមទៀត ទៅលើលក្ខណៈ ធម្មជាតិនៃការគិតពីប្រយោជន៍អ្នកដទៃរបស់អ្នកនិទានរឿង ដូចជាយើង នឹងឃើញថាបរត្ថភាព (ការគិតពីប្រយោជន៍អ្នកដទៃ) ជាអត្ថន័យដ៏សំខាន់ជាងគេនោះ នៅក្នុងសង្គមក្នុងការបណ្តុះបណ្តាលការព្យាបាលដោយខ្លួនឯង។

## ១.៨ ការនិទានរឿងដោយល្អ

ការរកតុល្យភាព (ថ្លឹងថ្លែង) ល្អត្រឹមត្រូវនៅក្នុងឆ្នាំ១៩៩៩ កម្មវិធីហារវើដ Harvard ផ្នែកភាពតក់ស្លុតរបស់ជនភៀសខ្លួន បានចាប់ផ្តើមមុខវិជ្ជាថ្មីនៅក្នុងសាលាវិជ្ជាពេទ្យ ចំនួនពីរនៅក្នុងចំណោមសាលារៀនវិជ្ជាពេទ្យបីនៅប្រទេសបូស្ស្សនា Bosnia ក្រសួងសង្គមកិច្ចនៅសកលវិទ្យាល័យស្សារ៉ាយ៉េវ៉ូ Sarajevo និងសិក្ខាសាលានៅសលកវិទ្យាល័យហ្វ្រាន់ស៊ីសក្កាន់ Franciscans ជាមូលដ្ឋានរៀបចំគម្រោងថ្មី កម្មវិធីសិក្សាជាផ្លូវការចាត់ជនតក់ស្លុតទៅជា "គ្រូបង្រៀន" ហើយអ្នកវិជ្ជាជីវៈព្យាបាលទៅជា "សិស្ស" ។ មុខវិជ្ជាថ្មីទទួលការស្វាគមន៍ជាអបអរសាទរពីអ្នកជម្ងឺ នៅពេលដែលរូបគេក្លាយទៅជាអ្នកនិទានរឿងដ៏ល្អ ហើយអ្នកវិជ្ជាជីវៈពេទ្យ ក៏ក្លាយទៅជាអ្នកស្តាប់ដ៏ល្អផងដែរ។

នៅក្នុងករណី របស់ម៉ាជដា Majda ស្ត្រីវ័យក្មេងប្រកបដោយចំណេះវិជ្ជាម្នាក់របស់ក្រុមគ្រួសារម៉ូស្លីមនៅប្រទេសបូស្សនាជា "គ្រូបង្រៀន" និងជាវេជ្ជបណ្ឌិតពេទ្យនៅសាកលវិទ្យាល័យពេទ្យស្សារ៉ាយ៉េវ៉ូ Sarajevo និងជា "សិស្សម៉ាជដាបានប្រាប់យើងថា នាងពុំដែលទុកចិត្តមនុស្សប្រុសឡើយ ដោយឪពុកនាងស្រវឹងតែស្រា ហើយអាពាពិពាហ៍បងស្រី របស់នាងក៏បរាជ័យទៀត។ ដោយនាងជាប់ចិញ្ចឹមក្មួយប្រុសនាង នាងពុំចង់ទាក់ទងជាមួយមនុស្សណាម្នាក់ឡើង "ខ្ញុំបដិសេធទំនាក់ទនងណាដែលពុំទទួលស្គាល់ក្មួយប្រុសរបស់ខ្ញុំ។ ខ្ញុំរកតុល្យភាព (ថ្លឹងថ្លែង) ជាក់លាក់ពុំឃើញនៅក្នុងគំនិតថា បើមានជនណាម្នាក់គោរពខ្ញុំ ហើយខ្ញុំត្រូវតែគោរពមនុស្សប្រុស"។ នៅពេលដែលនាងបានជួបហ្វ្រានហូ Franjo "គឺជាសេចក្តីស្នេហាឃើញភ្លាមស្រលាញ់ភ្លែត" ដូចជានាងពន្យល់ប្រាប់ថា "ពេញមួយជីវិតនាងស្រម៉ៃថាបានជួប នឹងបុរសម្នាក់ដូចជា Franjo។ វាជាលើកដំបូងដែលខ្ញុំមានទំនាក់ទំនងហើយពុំចង់កាត់ផ្តាច់វាភ្លាមឡើយ"។ ទោះជា Franjo ជាជនជាតិក្រូអូត Croat និងរ៉ូម៉ង់កាតូលិក Roman Catholic វាពុំមែនជាកត្តាដែលទាក់ទាញអារម្មណ៍នាងឡើយ នាងដឹងភ្លាមថាគាត់ជាមនុស្សពិសេសៈ

☞ ខ្ញុំស្រលាញ់គាត់ ដោយគាត់មានប្រាជ្ញាល្អ ចិត្តល្អ និយាយត្រង់ដោយកំប្លែងលេងសើច រាក់ទាក់ និងសុភាពរាបសារ។ គាត់គោរពខ្ញុំ អ្វីតែមួយគត់ដែលខ្ញុំពុំចូលចិត្ត គឺពេលខ្លះគាត់ផឹកស្រាហើយគាត់និយាយចំៗ អំពីអ្វីផ្សេងៗ ដែលអ្នកឯទៀតពុំហ៊ាននិយាយ។ និយាយដោយខ្លី គឺខ្លួនគាត់នៅក្នុងភាពនិយាយប៉ះទង្គិច ដោយមកពីអ្វីៗ ដែលបានកើតឡើងនៅក្នុងប្រទេសបូស្សនា និងប្រជាជនរបស់គេ។ ថ្ងៃមួយគាត់មកផ្ទះរបស់យើងហើយគាត់ប្រាប់យើងអោយប្រយ័ត្នដោយនិយាយថា "ពួកម៉ូស្លីមកាន់សីល ហើយកំពុងតែបន់ស្លន់ គេពុំឃើញអ្វីៗ ដែលកំពុងរង់ចាំគេឡើយ"។ នៅពេលដែលសង្គ្រាមចាប់ផ្តើមឡើង ម៉ាជដាបានទៅរស់នៅជាមួយ នឹងក្រុមគ្រួសារ

របស់ហ្វ្រានចូ Franjo នៅហ្វូនីកា Fojnica មួយរយៈពេលខ្លី តែដោយនាងបារម្ភអំពីសុវត្ថិភាពក្រុមគ្រួសាររបស់នាង នាងក៏ត្រឡប់មកវិញ។ នៅពេលដែលការវាយប្រហារកើនឡើងកាន់តែខ្លាំងFranjo ត្រូវគេកោះហៅអោយទៅជួយនៅក្នុងសង្គ្រាមទំនាក់ទំនងរបស់គេ ក៏រយោលហើយគេក៏ដាច់ការទាក់ទងពីគ្នាទៅ ម៉ាជដា Majda បារម្ភថាទំនាក់ទំនងរបស់គេ ពុំមានស្ថេរភាពបានយូរអង្វែងឡើយ៖

☞ នៅពេលចូលឆ្នាំថ្មី មិត្តរបស់ខ្ញុំទូរស័ព្ទមកខ្ញុំ ខ្ញុំខំតែសង្ឃឹមថាគេជូនពរខ្ញុំពេលចូលឆ្នាំថ្មី តែនាងបាននិយាយថា "ឯងមានដឹងថា Franjo យ៉ាងម៉េចទេ? គាត់ត្រូវគេសម្លាប់"។ ពាក្យនេះហាក់បីដូចជាពុំជ្រួតជ្រាបចូលខួរក្បាលខ្ញុំឡើយ ខ្ញុំនៅតែនិយាយជាមួយនាងតទៅទៀត ហើយនាងក៏និយាយកាន់ឡើងថា " គាត់ត្រូវគេសម្លាប់ដ៏អាណោចអាធ័មជាទីបំផុត គេសម្លាប់គាត់ដូចសត្វជាតុ " ខ្ញុំចូលទៅបន្ទប់ទឹក ហើយចាប់ផ្តើមទ្រហោយំ ខ្ញុំនៅតែទន្ទេញថារឿននេះមិនពិតទេ មកដល់ពេលនេះវានៅហាក់បីដូចជាសុបិន្ត។
ក្រោយមកនាងបានដឹងថា គាត់ត្រូវជនរួមជាតិដែលជាអច្ឆន្ទិជន(ជនខ្វះសីលធម៌)សម្លាប់ ដោយគាត់ជាធម្មនិដ្ឋ(ប្តេជ្ញា)កាតូលីក គេសម្លាប់គាត់នៅក្នុងថ្ងៃគ្រីស្តស្មាស់ Christmas តែនាងនៅតែរក្សាជំនឿរបស់នាង៖

ខ្ញុំនៅតែជឿជាក់ទៅលើសីលធម៌របស់មនុស្សជាតិ ការទទួលសេចក្តីគោរពនៅប្រទេសបូស្សនា និងអំពើល្អទាំងឡាយដែល Franjo បានព្យាយាមរក្សា គាត់បានបូជាជីវិតប្រឆាំង នឹងអំពើងងឹតងងល់ និងយុគនិយម(ដើមកំណើត)។ គាត់ជានិមិត្តរូប នៃបុរសម្នាក់ដែលប្រកបដោយចំណេះវិជ្ជា ដែលស្នេហាប្រទេសជាតិរបស់ខ្លួន ។ អ្នកខ្លះបានប្រាប់ខ្ញុំថា មរណៈភាពរបស់គាត់ ហាក់បីដូចជា គេសម្លាប់ប្រទេសបូស្សនាទាំងមូល ធ្វើអោយខ្ញុំខ្លោចផ្សារណាស់។ គេបានព្យាយាមសម្លាប់សេចក្តីស្រលាញ់ក្នុងចំណោមមនុស្ស និងសេចក្តីល្អទាំងអស់នេះដែលមាននៅក្នុងទំនាក់ទំនងរវាងមនុស្ស។ យើងពុំដែលស្អប់ខ្ពើមសាសនានៅទីនេះឡើយ។ នៅបូស្សនាយើងអបអរសាទរសាសនាគ្រប់បែប និងវប្បធម៌ស្មើគ្នា នេះជាការព្យាយាមបំផ្លាញសាសនារបស់យើង។ មានតែមនុស្សអសីលធម៌ និងគ្មានយល់តម្លៃមនុស្សទេ ដែលធ្វើអំពើបែបនេះ។ អ្នកទាំងនេះពុំស្រលាញ់មនុស្សណាក្រៅតែពីប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ចំពោះគោលបំណងរបស់នាង៖

ខ្ញុំនៅតែរកមនុស្សផ្សេងទៀត ដែលមានចរិយាសម្បត្តិដូចរូបគាត់ ខ្ញុំដឹងថាចរិយាសម្បត្តិបែបនេះ ពិតជាមានមែន វាគ្រាន់តែពិបាករកនៅក្នុងចំណោមមនុស្ស ខ្ញុំរីករាយណាស់ដោយខ្ញុំបានស្រលាញ់បុរសត្រឹមត្រូវ ខ្ញុំបានដឹងថាមនុស្សភាគតិចណាស់ជាមនុស្សដែលប្រកាន់សាសនាទុកជាខួងព្រលឹង។ ពេលវេលាបានឈានទៅមុខ ហើយខ្ញុំបានទទួលស្គាល់ថាគាត់ទៅបាត់រហូតហើយ ខ្ញុំនឹងរក្សាខ្លួនអោយនៅមានភាពដដែលដូចជាពេលដែលខ្ញុំបានជួបគាត់។

រឿងនេះបង្ហាញអំពីការនិទានរឿងល្អ ខុសពីម៉ារា Maria និងតារា Dara ម៉ាជដា Majda បានទទួលឱកាសបង្រៀនវេជ្ជបណ្ឌិតអំពីដំណើរការព្យាបាលដោយខ្លួនឯង តាមរយៈការនិទានរឿងតក់ស្លុតរបស់នាង។ នាងបានទទួលករណីយកិច្ចជាគ្រូបង្រៀនដោយហ្មត់ចត់បំផុត នាងនិយាយរឿងរបស់នាងដោយផ្ទាល់ ជាពាក្យរបស់នាង ដោយគ្មានការបង្ហាត់ណែនាំត្រួតពិនិត្យ ឬត្រូវបំពេញទៅតាមចិត្តបុគ្គលណាម្នាក់ឡើយ។ នៅគ្រាដែលកត្តា

ពិតបានបរិយាយឡើង នាង Majda ពុំអធិប្បាយរឿងនេះដោយចំៗ ហើយឃោរឃៅឡើយជាចំណែកមួយ ផ្នែកនៃការព្យាបាលដោយខ្លួនឯង នាង Majda ពុំនិយាយបញ្ចេញភាពលម្អិតនៃអំពើសម្លាប់ដូចសត្វ របស់សង្គ្រាម នាងអោយយើងស្តាប់ឡើយ។ តាមរយៈការបរិយាយដោយប្រុងប្រយ័ត្នរបស់នាងទៅលើការស្លាប់របស់ Franjo នាងជៀសវាងធ្វើមិនអោយអ្នកស្តាប់បាត់បង់ការយកចិត្តទុកដាក់ទៅលើរឿងរបស់នាង។ វាជានិមិត្តរូប នៃការប្រឆាំង នឹងភាពអសីលធម៌របស់នាងដែលបានបង្ហាញឡើងយ៉ាងច្បាស់លាស់។ នាងពុំបន្ទន់ខ្លួនទៅតាមការស្អប់ខ្ពើមជាតិសាសន៍ឡើយ ដោយនាងនៅតែបន្តអបអរសាទរទំនៀមទម្លាប់របស់វប្បធម៌ផ្សេងៗ ក៏ដូចជា ការស្រលាញ់បុរសជនជាតិក្រូអេទ្យាន Croatian ដែរ។ នាងនៅតែរក្សាភាពដដែល ហើយបន្តជឿជាក់ទៅលើសេចក្តីល្អរបស់មនុស្ស។

រឿងរបស់នាង Majda បង្ហាញនូវចំណុចសំខាន់ នៃរឿងតក់ស្លុត នាងត្រូវបង្ខំចិត្តអោយមើលហួសធាកជីវិតបន្ទាប់ពីមរណៈភាពរបស់Franjo ហើយរកឃើញតម្លៃពិតដែលមាននៅក្នុងពិភពលោក។ នាងបានដឹងអំពីរំលោភហារសាស្ត្រនយោបាយ ហើយឃើញថាការប្រឆាំងនៅបូស្សនាពុំមែនជាសង្គ្រាមសាសនាទេ វាជាករណីដែលបង្កើតឡើង ដោយមនុស្សជំនាន់ដើមពោរពេញទៅដោយភាពអាត្មានិយម ដែលព្យាយាមបំផ្លាញវប្បធម៌របស់ជនជាតិបូស្សនា និងអារ្យធម៌ តាមរយៈសាសនា និងការតស៊ូជាតិសាសន៍។ អ្នកខ្លះអាចស្មានបានថាពេលបច្ចុប្បន្ននេះ នាងជាកម្លាំង ផ្នែកដោះស្រាយបញ្ហានៅក្នុងក្រុមគ្រួសាររបស់នាង និងសហគមន៍របស់នាង។

ដោយមរណៈភាពរបស់ Franjon និង Majda បានវិនិច្ឆ័យសម្រេចសេចក្តីប្តេជ្ញារបស់នាង ៖ "ខ្ញុំនឹងរក្សាខ្លួនអោយនៅមានភាពដដែល ដូចជាពេលដែលខ្ញុំបានជួបគាត់" នាងពុំបណ្តោយអោយអំពើសម្លាប់ដ៏ព្រៃផ្សៃរបស់ Franjo ធ្វើអោយខូចតម្លៃរបស់នាងឡើយ។ ទោះជានាងបានប្រាប់យើងថា នាងក្រៀមក្រំបន្ទាប់ពីមរណៈភាពរបស់ Franjo តែចំណូលចិត្តទៅលើការងារ ការទទួលខុសត្រូវរបស់នាងទៅលើក្រុមគ្រួសារ ក្មួយប្រុស និងសេចក្តីចងចាំនូវអំពើល្អរបស់ Franjo បានជួយនាងអោយផុតពីការដកខ្លួនចេញពីសង្គម ហើយបានជួយនាងដោះស្រាយបញ្ហាដំណើរជីវិតប្រចាំថ្ងៃ។ និស្សិតវេជ្ជបណ្ឌិតនេះបានរៀបរាប់ប្រាប់រឿងទុក្ខសោក និងអារម្មណ៍ឈឺចាប់របស់នាង ជាមួយយើង តែនាងក៏បានរៀបរាប់ប្រាប់នូវសេចក្តីស្នេហា និងសេចក្តីស្រលាញ់ដែលនាងមានទៅលើ Franjo ផងដែរ។ នាងអាចធ្វើអោយយើងយល់ចិត្ត ដើម្បីអោយយើងចូលរួមនៅក្នុងដំណើរការព្យាបាល អំពើឃោរឃៅនៅក្នុងដំណើរជីវិតរបស់នាង បានធ្វើអោយនាងក្លាយទៅជាកម្លាំងព្យាបាលដែលមានសារៈសំខាន់ ផ្ទុយ នឹងភាពច្របូកច្របល់ក្នុងសង្គម និងសេចក្តីភ័យខ្លាចដែលកើតមានឡើងនៅជុំវិញខ្លួននាង និងក្នុងសង្គមបូស្សនាបច្ចុប្បន្នកាល។

ក្នុងនាមជាគ្រូបង្រៀន Majda មិនដែលដកសេចក្តីយកចិត្តទុកដាក់ចេញពីសិស្សវេជ្ជបណ្ឌិតរបស់នាងឡើយ។ នៅពេលដែលគេសួរនាងថា តើនាងចង់បានទំនាក់ទំនងរបៀបណាពីវេជ្ជបណ្ឌិតប្រចាំខ្លួនរបស់នាង នាងនិយាយឡើងថា "ខ្ញុំចង់បានទំនាក់ទំនងពោរពេញទៅដោយភាពកក់ក្តៅ ទុកចិត្ត និងស្មោះត្រង់។ វាជាករណីសំខាន់ ដែលវេជ្ជបណ្ឌិត និងអ្នកជម្ងឺមានអារម្មណ៍គ្មានលាក់លៀម ទុកចិត្ត និងគោរព" ទាំងនេះជាលក្ខណៈ

សម្បត្តិដែលនាងគោរពនៅក្នុងទំនាក់ទំនងរវាងនាង និង Franjo នៅទីបញ្ចប់នាងបានរកឃើញភាពថ្លឹងថ្លែងត្រឹមត្រូវនៅក្នុងចិត្តរបស់នាង។ នេះជាឧបសគ្គចុងក្រោយ គឺបង្រៀនភាពថ្លឹងថ្លែងនេះទៅសង្គមរបស់នាង ដើម្បីជួយអោយប្រជាជនអាចសម្រេចជោគជ័យល្អតែមួយរួមគ្នា។

## កថាខណ្ឌ ១. ការធ្វើអោយមានស្នាដៃនៅក្នុងពិភពលោក

នៅក្នុងខែ មិថុនា ឆ្នាំ២០០២ សារព័ត៌មានរបស់ស្ថានីយ៍ទូរទស្សន៍ABC បានផ្សាយកម្មវិធីមួយដែលផ្តោតទៅលើកម្មវិធីហាវើដ Harvard ជាកម្មវិធីប្រតិបត្តិការ ទៅលើភាពតក់ស្លុតជនភៀសខ្លួនទូទាំងពិភពលោក។ នៅថ្ងៃបន្ទាប់មកខ្ញុំបានទទួលទូរស័ព្ទពីលីហ្ស Liz និងស្ទីវ អាល់ឌ័រម៉ែន Steve Alderman ដោយកូនរបស់គេឈ្មោះ ភីត ទ័រ Peter បានស្លាប់នៅក្នុងការវាយប្រហារ ថ្ងៃទី១១ ខែ កញ្ញា ហើយគេបាននិយាយថាគេចង់ចូលរួមនៅក្នុងសហប្រតិបត្តិការរបស់យើង។ យើងក៏ចាប់ផ្តើមសហការជាមួយ នឹងក្រុមគ្រួសារ Alderman ភ្លាម ហើយក៏បង្កើតជាថ្នាក់ជំនាញ Peter C. Alderman។

បេសកម្មរបស់កម្មវិធីនេះ គឺផ្តល់ការហ្វឹកហ្វឺនវិទ្យាសាស្ត្រ និងការគាំទ្រដល់អ្នកមានវិជ្ជាជីវៈពេទ្យទូទាំងពិភពលោក ដែលធ្វើការជាមួយនឹងជនរងគ្រោះដោយអំពើមហាឃោរឃៅ។ វេជ្ជបណ្ឌិត អ្នកព្យាបាលចិត្តសាស្ត្រ និងអ្នកប្រកបវិជ្ជាជីវៈផ្នែកសតិអារម្មណ៍ និងអ្នកនយោបាលមកពីប្រទេសនានា ដែលបានទទួលបទពិសោធន៍ដោយសង្គ្រាមមហាឃោរឃៅដូចជា អាប់ហ្គានិស្ថាន Afghanistan, អ៊ីរ៉ាក់ Iraq, កម្ពុជា Cambodia, រ៉ាន់ដាន Rwandan, យូហ្គាន់ដា Yuganda, ភីរ៉ូ Peru, បូស្សនា Bosnia និងឈីលី Chile បានមកជួបជុំគ្នាជាមួយ នឹងប្រទេសអ៊ីតាលី Italy, ប្រទេសអាមេរិក United States និងប្រទេសអង់គ្លេស England។ នៅក្នុងការជួបជុំគ្នាប្រចាំឆ្នាំ ដែលធ្វើឡើងនៅទីក្រុងអូវីតូ អ៊ីតាលី Orvieto Italy អ្នកចូលរួមមានឱកាសរៀនជំនាញព្យាបាលថ្មី និងហ្វឹកហ្វឺន ថែមទាំងរៀនអំពីរបៀបថែទាំខ្លួនទៀតផង។ អ្នកស្រី Liz Alderman និងស្វាមី Steve ជាវេជ្ជបណ្ឌិត គេបានចូលរួមយ៉ាងសកម្ម នៅក្នុងថ្នាក់ជំនាញនីមួយៗ គេចូលរួមចំណែកដោយផ្ទាល់ ជាបែបបទប្រកបដោយអត្ថន័យ ចេញពីបទពិសោធន៍តក់ស្លុតនៅក្នុងដំណើរជីវិតរបស់គេ។ ក៏ដូចជា Majda ដែលបានបង្រៀនសិស្សវេជ្ជបណ្ឌិតដែរ នៅក្នុងថ្នាក់ អ្នកស្រី Liz បានធ្វើអោយខ្លួនគាត់បែរពីភាពជាមេផ្ទះទៅជាគ្រូបង្រៀន និងអ្នកប្រកបការងាររួមគ្នានៅក្នុងក្រុម។

អ្នកស្រីជLiz បង្ហាញនូវលក្ខណៈសម្បត្តិទាំងអស់ របស់អ្នកនិទានរឿងល្អ អ្នកស្រីដោយភាព និយាយស្មោះត្រង់ ហើយព្យាយាមនិយាយដោយស្មោះត្រង់ចេញពីចិត្ត នៅពេលដែលអ្នកស្រីនិយាយបង្ហាញពីបទពិសោធន៍ជីវិតរបស់ខ្លួន ដោយជៀសវាងពីភាពបញ្ចេញទ្រឹស្តី និងពិចារណាញាណ។ ដូចជា Majda ដែរ អ្នកស្រីបាននិយាយាចេញពីក្រអៅបេះដូង និងនិមិត្តរូបដែលជាលក្ខណៈសម្បត្តិ បទពិសោធន៍ដំណើរជីវិតរបស់គាត់ ចាប់តាំងពីថ្ងៃទី១១ ខែ កញ្ញា មក គឺមូលនិធិរបស់ Peter C. Alderman ដែលបានបង្កើតឡើងជាកិត្តិយស ដល់កូនប្រុសរបស់គាត់ ផ្ទុយនឹងការបាត់បង់ដោយសោកនាដកម្មរបស់គាត់ គាត់កម្រខឹងណាស់។ គាត់ពុំដែលច្រឡោត ឬធ្វើ

អោយអ្នកស្តាប់ទោរទន់អារម្មណ៍ខ្លាំងពេកឡើយ តែអារម្មណ៍មហាទុក្ខសោកនៅតែមានជានិច្ច នៅពេលបានឮរឿងរបស់គាត់ អ្នកស្តាប់បានទទួលអារម្មណ៍រិតតែជិតស្និទទៅ នឹងមហាទុក្ខរបស់គាត់។ ដូចគាត់បាននិយាយឡើងថា "ដូច្នេះ សុបិន្តដ៏អាក្រក់របស់អ្នកក្លាយទៅជាភាពពិត" យើងបាត់បង់កូនរបស់យើង ដោយអំពើព្រៃផ្សៃ និងហួសពីការស្មាន ទាំងនេះជាបទពិសោធន៍ដែលខ្ញុំបានរៀនសូត្រ ហើយដែលយើងពុំអាចរំសាយពីទុក្ខនេះបាន"។

កូនប្អូនបង្អស់នៅក្នុងចំណោមកូនទាំងបីនាក់ របស់ក្រុមគ្រួសារ Alderman គឺ ភីតទ័រ Peter អាយុ២៥ឆ្នាំ នៅពេលដែលគាត់ស្លាប់ នៅពេលនោះ Liz កំពុងតែនៅប្រទេសបារាំងជាមួយ នឹងស្វាមីរបស់គាត់ហើយ នឹកគិតថា Peter ប្រហែលចូលរួមប្រជុំនៅទីផ្សារអន្តរជាតិ នៅពេលដែលយន្តហោះបានហោះបុកអគារនោះ ដូចជា Liz បានបរិយាយឡើងនៅថ្ងៃនោះថា៖

> ទូនាប់ខាងក្រោមបានជ្រុះបាត់ ខ្ញុំកំពុងតែនៅពិភពមួយចំហៀងទៀត ហើយពុំដឹងថាកូនប្រុសខ្ញុំនៅទីណាទេ វាជាអារម្មណ៍អស់សង្ឃឹមស្លន់ស្លោរ ខ្ញុំបានដកចានចេញពីម៉ាស៊ីនលាងចាន ហើយយកវាលាងដោយដៃវិញ។

ក្រោយមកទើប លោកស្រីដឹងថា កូនប្រុសរបស់លោកស្រីបានស្លាប់នៅក្នុងអគារនោះ៖ "ខ្ញុំបានដឹងថា Peter ស្លាប់ តែខ្ញុំពុំដឹងច្បាស់ថាសេចក្តីស្លាប់មានអត្ថន័យដូចម្តេចទេ ខ្ញុំពុំដឹងច្បាស់នូវពាក្យ 'ជានិរន្តន៍' នោះទេ ហើយវាប្រើរយៈពេលដ៏យូរទំរាំតែខ្ញុំដឹងយល់អត្ថន័យនោះ" ពេលវេលាបានកន្លងផុតទៅ លោកស្រីត្រូវសម្រេចថា តើលោកស្រីត្រូវបន្តដំណើរជីវិតរបស់ខ្លួនដោយវិធីណា៖

ខ្ញុំមានជម្រើសពីរ នៅពេលដែលកូនខ្ញុំស្លាប់ ខ្ញុំត្រូវសម្លាប់ខ្លួន...មិនមែនបានសេចក្តីថា ខ្ញុំយកកាំភ្លើងមកបាញ់ក្បាលខ្លួនឯងទេ តែវាមានន័យថា ខ្ញុំចូលគេងលើគ្រែហើយពុំក្រោកឡើងវិញ ឬពុំដើរដោយលើកជើងមួយទៅដាក់នៅពីមុខជើងមួយទៀត យើងច្រើនតែមានមហាទុក្ខ និងកាន់ទុក្ខដែលមានភាពដូចគ្នា នឹងការរស់នៅរបស់យើង។

បួនឆ្នាំបន្ទាប់មកក្រោយ ពីលោកស្រីបាត់បង់កូនប្រុសរបស់លោកស្រីទៅ សេចក្តីឈឺចាប់របស់ លោកស្រី Liz នៅតែមានកំរិតស្មើ នឹងពេលដែលអ្នកស្រីដឹងថាកូនរបស់អ្នកស្រីបានស្លាប់។

ខ្ញុំពុំបានដឹងថាខ្លួន ខ្ញុំជានរណាទៀតឡើយ ខ្ញុំតែងមានអារម្មណ៍ថា ខ្ញុំដឹងថា ខ្លួនខ្ញុំជានរណា ហើយខ្ញុំមានភារៈកិច្ចដូចម្តេច។ ម្តាយឪពុកខ្ញុំបានផ្តល់ភាពទំនុកចិត្តលើខ្លួនខ្ញុំដោយរឹងពឹង ហើយខ្ញុំក៏ដើរតាមចង្វាក់ដំណើររបស់ខ្លួនខ្ញុំ ពេលនេះខ្ញុំគ្មានដឹងថាខ្លួនជានរណាទេ ខ្ញុំពុំដឹងថាតើខ្ញុំនឹងមានប្រតិកម្មដូចម្តេចទេ ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយនាទីទៅមួយនាទី... ខ្ញុំពុំអនុញ្ញាតអោយខ្លួនឯងសប្បាយរីករាយ នឹងជីវិត។ មហាទុក្ខដ៏ធំធេងរបស់ខ្ញុំពុំអាចប្រៀបធៀបទៅ នឹងការបាត់បង់ Peter បានឡើយ។ Peter បានបាត់បង់អនាគតរបស់ខ្លួន វាពុំអាចមានឱកាសមានប្រពន្ធកូនដែលទទួលភាពរីករាយដែលកើតមានឡើងក្នុងជីវិតឡើយ...ខ្ញុំពុំអនុញ្ញាតអោយខ្លួនខ្ញុំរីករាយ នឹងអ្វីៗផ្សេងទៀត។ ខ្ញុំធ្លាប់ចូលចិត្តស្តាប់អូប៉េរ៉ា Opera ខ្ញុំពុំអាចស្តាប់វាបានទៀតទេ ដោយភ្លេងនោះធ្វើ

អោយខ្ញុំយំ ខ្ញុំពុំអាចមើលផ្ទៃមេឃដ៏ល្អត្រចង់តទៅទៀតឡើយ ដោយ Peter ពុំអាចមើលឃើញដូចខ្ញុំ។ ខ្ញុំពុំចូលចិត្តថ្ងៃដ៏ល្អត្រចះត្រចង់នេះទៀតទេ ដោយ Peter ពុំអាចទទួលអារម្មណ៍បែបនេះបានទៀត...ខ្ញុំពុំអនុញ្ញាតអោយខ្លួនខ្ញុំត្រឡប់ទៅធ្វើអ្វីៗ ដែលខ្ញុំចូលចិត្តធ្វើនោះឡើយ វាជាភាពដ៏លំបាកសម្រាប់រូបខ្ញុំ ប្រហែលជាមកពីការយល់ឃើញរបស់ខ្ញុំជាម្តាយ។ តើខ្ញុំសប្បាយរីករាយ នឹងជីវិតនៅក្នុងលោកនេះដោយបែបណាទៅ បើ Peter គ្មានទាំងជីវិតផងនោះ? ផ្ទុយនិងសេចក្តីឈឺចាប់របស់ខ្លួន លោកស្រី Liz បានបរិច្ចាគចំណែកមួយដ៏សំខាន់ តាមរយៈមូលនិធិថ្មីដល់ក្រុមគ្រួសាររបស់លោកស្រី។ លោកស្រីនិយាយថា "ប្រហែលជាខ្ញុំស្រែកទ្រហោរយំនៅក្នុងខ្លួន តែខ្ញុំបានដឹងខ្លួន តែបើសិនវាជាការពិតមែននោះ ខ្ញុំធ្វើអ្វីៗ ពុំកើតទេ។ តែខ្ញុំកំពុងតែបំពេញមុខនាទីដ៏សំខាន់" លោកស្រី Liz ស្វាមី និងកូនបានធ្វើអោយសោកនាដកម្មរបស់គេក្លាយទៅជាសេចក្តីព្យាយាមប្រកបដោយអត្តប្រយោជន៍ ដោយបង្កើតសុខភាព និងសុខុមាលភាព នៅក្នុងជីវិតរបស់ប្រជាជន ដែលរងទុក្ខទៅដោយសង្រ្គាម។ មិនតែប៉ុណ្ណោះ មូលដ្ឋានបំណងរបស់លោកស្រី ក្នុងការធ្វើអំពើល្អនៅក្នុងពិភពលោកនេះ បានធ្វើអោយលោកស្រីភ្ញាក់ផ្អើលទៅលើខ្លួនឯងថែមទៀតផង។

ខ្ញុំពុំដែលគិតគូរអំពីការបន្សល់ទុកស្នាដៃនៅក្នុងពិភពលោកឡើយ ស្នាដៃរបស់ខ្ញុំ គឺនៅលើកូនរបស់ខ្ញុំ តែ Peter ស្លាប់នៅវ័យក្មេងពេក ហេតុដូច្នេះហើយការបន្សល់ទុកស្នាដៃ គឺបង្កើតមូលនិធិជំនួសវិញ ខ្ញុំនឹងបង្រៀនអ្នកឯទៀតពីបទពិសោធន៍ដែលខ្ញុំបានរៀនសូត្រ។ សេចក្តីឈឺចាប់ពុំអាចរសាយបាត់ទេ ហើយកម្រិតឈឺចាប់ក្នុងរយៈពេលបួនឆ្នាំក៏ពុំមានកម្រិតតិចជាងនៅពេលដែល Peter ស្លាប់ដែរ។ ខ្ញុំពុំអាចជាសះស្បើយឡើយហើយក៏ពុំអាចរក្សាខ្លួនអោយនៅជាមនុស្សដដែលបានឡើយ តែខ្ញុំត្រូវតែទទួលយកដោយបែបនេះ។ ប៉ុន្តែ Peter តែងតែនៅទីនេះជាដដែល។ ខ្ញុំមានអារម្មណ៍ល្អនៅក្នុងថ្នាក់ជំនាញ ហើយខ្ញុំរីករាយដែលខ្ញុំបានបន្សល់ទុកស្នាដៃនៅក្នុងពិភពលោកទុកក្នុងនាមរបស់ Peter ។ ខ្ញុំបានចាប់បង្កើតមូលនិធិនេះ ប្រៀបដូចជាបើកមុខជំនួញតូចមួយ ខ្ញុំចេះកិច្ចការកុំព្យូទ័របានល្អឡើង ទោះបីជា Peter មិនបានឃើញកិច្ចការទាំងនេះក៏ដោយ ខ្ញុំដឹងថាវាពិតជាសប្បាយរីករាយក្រៃលែងដោយគេឃើញខ្ញុំកំពុងតែធ្វើកិច្ចការទាំងនេះ។ Liz និងស្វាមី Steve បានចាប់ផ្តើមការព្យាយាមគិតប្រយោជន៍អ្នកដទៃ (បរត្ថភាព) ប្រាំបីខែ ក្រោយពីកូនរបស់គេបានស្លាប់ ។ លោកស្រី Liz កំពុងតែរុំភួយរបស់ Peter និងគេងនៅលើគ្រែរបស់ Peter នៅពេលដែលកម្មវិធីផ្សាយពត៌មានលោក ទូរទស្សន៍ Nightline បានផ្សព្វផ្សាយឡើង។ ពេលនោះលោកស្រីបានឃើញក្មេងកំព្រាដោយសង្រ្គាមបីនាក់ នៅប្រទេសអាប់ហ្គានីស្ថាន Afghanistan ពេលនោះលោកស្រីមានអារម្មណ៍ចង់ត្រកងឱបក្មេងទាំងបីនាក់ ដោយយកវាមកនៅផ្ទះជាមួយហើយថែទាំវា ដើម្បីធ្វើអោយជីវិតក្មេងនោះល្អប្រសើរឡើង។ ហើយនៅពេលដែលលោកស្រីបន្តទស្សនាកម្មវិធីនេះ លោកស្រីមានអារម្មណ៍ថា លោកស្រីប្រហែលជាអាចជួយបានច្រើនជាង ភាពជួយយកអសារក្មេងបីនាក់នេះទៅទៀត។ លោកស្រីទទួលអារម្មណ៍ទោរទន់ពន់ពេកថា លោកស្រីត្រូវការធ្វើអ្វីដែលប្រកបទៅដោយសេចក្តីសង្ឃឹមជាក់លាក់។ Liz ខ្លោចផ្សារដោយសេចក្តីស្លាប់ដ៏តក់ស្លុតរបស់កូនប្រុសលោកស្រី លោកស្រីតែងតែក្រៀមក្រំ ទោះជាវាពុំមានបញ្ចេញនៅលើទឹកមុខ ឬអាកប្បកិរិយារបស់អ្នកស្រីក៏ដោយ។ លោកស្រីបានថ្លែងថា "រឿង

របស់ខ្ញុំ ពុំមែនជាកញ្ជ្រែងដែលសម្រាប់ផ្ទុករបស់របរទេ" ហើយ "ខ្ញុំព្យាយាមទាញសេចក្ដីរីករាយមកដាក់ជីវិតរបស់ខ្ញុំវិញ" អ្វីដែលសំខាន់ជាងគេ គឺលោកស្រីមានអារម្មណ៍ថា លោកស្រីបានទទួលជោគជ័យដ៏លើសលប់ ក្នុងការផ្តល់ប្រយោជន៍ដល់អ្នកដទៃ ។ លោកស្រី Liz ប្រាប់យើងថា លោកស្រីជឿជាក់ថាលោកស្រីបានធ្វើអោយអ្នកខ្លះមានអារម្មណ៍មិនស្រួល។ លោកស្រីគិតថាអ្នកខ្លះគេពុំចង់ដឹងពីកិច្ចការមូលនិធិទេដោយគេមិនសូវធ្វើអ្វីដើម្បីជួយអ្នកផ្សេងៗទៀត។ ប៉ុន្តែ លោកស្រីក៏មានអារម្មណ៍ថាគេគេចពីលោកស្រីដោយមកលោកស្រីនិយាយចំៗ ហើយស្មោះត្រង់ លោកស្រីពុំអាចទទួលយកភាពភូតកុហក និងឧបាយកលបានឡើយ។ លោកស្រី Liz បាននិយាយរឿងរន្ធត់ចិត្តនេះនៅក្នុងថ្នាក់ជំនាញ មនុស្សជាច្រើនបានស្តាប់សម្តីរបស់លោកស្រីរៀនសូត្រអំពីសេចក្តីលំបាក នៃសេចក្តីភាពជាសះស្បើយពីភាពបាត់បង់កូន និងទទួលការលើកទឹកចិត្តដោយស្មារតី និងបរត្តភាពរបស់លោកស្រី។ ក៏ដូចគ្នា នឹងរឿងរបស់ Majda ដែរ រឿងរបស់ Liz ធ្វើអោយអ្នកស្តាប់ចូលរួមចំណែក នៅក្នុងសេចក្តីឈឺចាប់របស់លោកស្រីហើយវាក៏ធ្វើអោយគេចូលរួមស្រលាញ់កូនប្រុស Peter របស់លោកស្រីផងដែរ។ លោកស្រីធ្វើអោយសេចក្តីយល់ចិត្តរបស់យើងមានដំណើរការឡើង ដើម្បីអោយយើងជឿ និងចូលរួមនៅក្នុងបំណងរបស់លោកស្រីដើម្បីព្យាបាលទុក្ខសោក និងសេចក្តីឈឺចាប់របស់អ្នកឯទៀត ដែលកើតមានឡើងដោយឧក្រិដ្ឋកម្ម។ លោកស្រី អាចផ្លាស់ប្តូរសេចក្តីឈឺចាប់របស់លោកស្រី អោយក្លាយទៅជាកម្លាំងព្យាបាលសម្រាប់អ្នកឯទៀត សម្រាប់ក្រុមគ្រួសាររបស់លោកស្រី និងសម្រាប់ខ្លួនលោកស្រី។

អារម្មណ៍ទោរទន់ពន់ពេក ពោរពេញទៅដោយអនុស្សាវរីយ៍ តក់ស្លុតដែលដក់ជាប់នៅក្នុងខួរក្បាលរបស់អ្នករួចផុតពីសេចក្តីស្លាប់។ កាតព្វកិច្ចសំខាន់នៅក្នុងអារម្មណ៍ក្រោយពីភាពតក់ស្លុត គឺយកអារម្មណ៍ទោរទន់ពន់ពេក នេះមកធ្វើអោយអារម្មណ៍នេះរសាយម្តងបន្តិចៗ តាមរយៈការនិទានរឿងល្អ អ្នកនិទានរឿងមិនល្អ និយាយរឿងតក់ស្លុតប្រកបដោយពិសពុលធ្វើអោយប៉ះពាល់ដល់អារម្មណ៍ និងរាង្គកាយ ដោយផ្តោតទៅលើកត្តាពិត និងការបញ្ចេញអារម្មណ៍ដោយពេញទំហឹង។ នៅក្នុងសង្គមរបស់យើង ស្ថានភាពដែលបញ្ចេញការនិទានរឿងបែបនេះជាភាពធម្មតារួមទៅដោយសេចក្តីរាយការណ៍ អំពីសោកនាដកម្មដោយស្ទើរតែ ឬដោយអស្ចារ្យ របស់ផ្នែកផ្សព្វផ្សាយព័ត៌មាន និងការសួរយកព័ត៌មានអំពីការព្យាបាល ដោយខ្វះការណែនាំរបស់បុគ្គលិក ផ្នែកសតិអារម្មណ៍ ។ ផ្ទុយទៅវិញ អ្នកនិទានរឿងដ៏ល្អអាចបញ្ចេញអារម្មណ៍តក់ស្លុតដ៏ជំនាញប្រៀបដូច នឹងអ្នកលេងភ្លេងដ៏ប៉ិនប្រសប់ម្នាក់ដែលទាក់ទាញចំណាប់អារម្មណ៍ និងការចូលរួមរបស់អ្នកស្តាប់។ រឿងតក់ស្លុតជាឧបករណ៍ ដ៏សំខាន់បំផុតនៃភាពជាសះស្បើយរបស់អ្នករួចផុតពីសេចក្តីស្លាប់ ជំពោះអ្នកស្តាប់ការនិទានរឿងដ៏ល្អ ជាគុណសម្បត្តិពោរពេញទៅដោយគតិបណ្ឌិតវប្បធម៌ និងការបញ្ចេញអោយដឹងដោយបង្រៀនមេរៀន ដ៏ជ្រាលជ្រៅរបស់អ្នកនិទានរឿង អំពីភាពរួចផុតពីសេចក្តីស្លាប់ និងភាពជាសះស្បើយរបស់មនុស្សលោក។ ការចែកចាយទៅវិញទៅមកដោយអារម្មណ៍រឹងមាំរវាងអ្នកស្តាប់ និងអ្នកនិទានរឿងដែលកើតមានឡើងបានក្លាយទៅជាធនធានដ៏រីក និងថ្លៃប្រឌិតសម្រាប់រូបគេម្នាក់។

# ជំពូកទី៦ សុបិន្តល្អ និងសុបិន្តអាក្រក់

រឿងតក់ស្លុតជាវិធីព្យាបាលដោយខ្លួនឯងតែមួយគត់ ដែលពុំទាន់ទទួលស្គាល់ពេញលេញនៅឡើយទេ វាជាដំណើរការ ផ្តែកសតិអារម្មណ៍មួយដែលគេយកចិត្តទុកដាក់ជាយូរលង់មក ហើយយល់ថាសុបិន្តជាភាពអត់ប្រយោជន៍។ សុបិន្តពេលនេះទើបតែចាប់ផ្តើមទទួលការអោយតម្លៃដោយសន្សឹមៗថា សុបិន្តជាប្រតិកម្មនៃការព្យាបាលដោយខ្លួនឯងដ៏សំខាន់របស់ជនជួបប្រទះ នឹងភាពតក់ស្លុត។

ការចងចាំនាពេលថ្ងៃ និងសុបិន្តនៅពេលយប់បានបង្កើតនូវភាពបន្ត នៃការយល់ដឹងអំពីពិភពលោកដែលយើងកំពុងរស់នៅ គឺជាគំនូរដ៏សំខាន់ នៃជីវប្រវត្តិ និងអត្តចរិតផ្ទាល់របស់យើង។ នៅពេលដែលភ្ញាក់ខ្លួនមនុស្សយើងចាប់ផ្តើមដំណើរនៃការចងចាំ ហើយបានបង្កើតនូវការចងចាំថ្មីទៀត។ នៅពេលលង់លក់ ដំណើរការនេះនៅតែបន្តទៅទៀតដោយពេញលេញ គ្រាន់តែយើងពុំមានដឹងខ្លួន លើកលែងតែយើងភ្ញាក់ដឹងខ្លួនហើយចងចាំសុបិន្តរបស់យើង។ ជនដែលមានភាពតក់ស្លុតហាក់បីដូចជារស់នៅក្នុងពិភពលោកដែលពោរពេញទៅដោយសុបិន្តពុំមានទីបញ្ចប់ សុបិន្តពេលថ្ងៃ និងសុបិន្តពេលយប់មានទំនាក់ទំនង នឹងគ្នាទៅវិញទៅមកដោយគ្មានការរអាក់រអួលឡើយ។ ចំពោះជនរងគ្រោះដោយអំពើហឹង្សាដ៏ឃោរឃៅបំផុត មួយចំនួនទោះសុបិន្ត និងភាពភ័យខ្លាចនៅក្នុងសុបិន្តក៏អាចហៅថាសុបិន្តអាក្រក់ដែរ សុបិន្តនេះអាចជួយផ្តល់ការយល់ដឹងដ៏ជ្រៅជ្រះទៅលើរឿងតក់ស្លុត និងជួយដំណើរការ នៃការជាសះស្បើយ។ ចំពោះជនរងគ្រោះខ្លះៗ សុបិន្ត និងសុបិន្តអាក្រក់ នឹងបន្តអោយមានរយៈពេលយូរអង្វែង។ នៅករណីនេះ យកមកប្រើសម្រាប់ការព្យាបាលសុបិន្តទាំងនោះមាននាទីសំខាន់ក្នុងរឿងតត់ស្លុត។

លោក ស៊ីកម៉ុដ ហ្វ្រ័ត (Sigmud Freud) បានធ្វើអោយសម័យទំនើប មានការចំណាប់អារម្មណ៍ទៅលើសុបិន្ត ដោយការបោះពុម្ពផ្សាយសៀវភៅនៅឆ្នាំ១៩០០ *ការបកស្រាយសុបិន្ត។* គាត់បានស្នើផ្តល់យោបល់ថាសុបិន្ត គឺជាវិថី (Via Regis) ឬ វិធីដ៏មហិមារចំពោះអ្នកដែលពុំដឹងខ្លួន ដោយវាបញ្ចេញនូវសញ្ញាខុសពីការពិតហើយជាញឹកញាប់ច្រើនតែរំខានដល់សេចក្តីប្រាថ្នារបស់ជនសុបិន្ត។ ជាងពាក់កណ្តាលសតវត្សក្រោយមកអ្នកវិទ្យាសាស្ត្រចាប់ផ្តើមចាត់ថាលក្ខណៈសុបិន្តដោយចិត្តសាស្ត្រថា សុបិន្តជាបាតុភូតដែលកើតដោយគ្មានន័យក្នុងខួរក្បាល ឬជាការលាងសំអាតសេចក្តីចងចាំដែលគេពុំចង់បានក្នុងថ្ងៃនោះ។ បទពិសោធន៍របស់ខ្ញុំទៅលើសុបិន្តនិងសុបិន្តអាក្រក់របស់អ្នកដែលរួចផុតពីសេចក្តីស្លាប់ជាងពីរទសវត្សមកពុំមានលក្ខណៈស្របទៅ នឹងគំរូទាំងពីរបែបនេះទេ។

នៅមន្ទីរចិត្តសាស្ត្រឥណ្ឌូចិន អ្នកជម្ងឺជនភៀសខ្លួនអាស៊ីអាគ្នេយ៍ភាគច្រើន មានសុបិន្តអាក្រក់ បាតុភូតនេះពុំមានអ្វីគួរអោយភ្ញាក់ផ្អើលទេ ដោយជនទាំងនោះភាគច្រើនទទួលភាពតក់ស្លុតដ៏ធ្ងន់ធ្ងរ តែសុបិន្ត និងសុបិន្តអាក្រក់របស់គេ មានតួនាទីដ៏សំខាន់នៅក្នុងដំណើរជីវិតបច្ចុប្បន្នរបស់គេ។ ការសន្ទនារបស់ខ្ញុំជាមួយ នឹងក្មេងស្រី

ជំទង់ ស៊ីប៉ូ Sipo ជាយុវនារីខ្មែរគេងនៅមន្ទីរពេទ្យនាងចង់សម្លាប់ខ្លួននៅក្នុងឆ្នាំ១៩៨០ដែលបណ្តាលអោយមានការយល់ដឹងថាសុបិន្ត និងសុបិន្តអាក្រក់របស់ជនទទួលភាពតក់ស្លុត់ អាចបង្ហើបបង្ហាញនូវរឿងតក់ស្លុតរបស់ពួកគេ។ Sipo បានទទួលការព្យាបាល ផ្នែកជម្ងឺធ្ងន់ធ្ងរដោយការបំពុលខ្លួនឯង។ បុគ្គលិកពេទ្យមានការភ័ន្តច្រឡំដោយនាងពុំត្រឹមតែបដិសេធថាគ្មានអ្វីកើតឡើងដល់រូបនាងទេ នាងថែមទាំងបដិសេធថានាងពុំបានចង់សម្លាប់ខ្លួនឡើយ។ នាងឆ្លើយតប នឹងសំនួរ "តើមានអ្វីដែលធ្វើអោយនាងខឹងឬទេ"? ដោយនិយាយជាភាសាអង់គ្លេសថា "ទេ" ជាម្តងទៀតគេសួរថា "តើនាងមានខឹងពីរឿងអ្វីទេ"? "ទេ" "តើអ្នកអាចប្រាប់ខ្ញុំថា តើហេតុអ្វីបានជានាងព្យាយាមសម្លាប់ខ្លួននាង"? នាងឆ្លើយដោយច្បាស់ថា "ខ្ញុំពុំដឹងទេ" តែនៅពេលដែលខ្ញុំសួរនាងថា "តើនាងមានយល់សុបិន្ត ឬយល់សុបិន្តអាក្រក់ទេ"? នាងឆ្លើយថា នាងយល់សុបិន្តអាក្រក់ដដែលៗ ជារៀងរាល់យប់៖ "ខ្ញុំកំពុងតែបីឪពុករបស់ខ្ញុំនៅលើដៃខ្ញុំ គាត់ឈឺខ្លាំងដោយសារការស្រេកឃ្លានដាច់ពោះ។ គាត់មើលមុខខ្ញុំហើយស្រាប់តែគាត់ដាច់ខ្យល់ស្លាប់ទៅ" នាងក៏ចាប់ផ្តើមយំ។

ទោះជានាង Sipo ពុំទាន់ចាត់ថាសុបិន្តដែលកើតឡើងផ្ទួនៗ ដែលទាក់ទងទៅ នឹងស្មារតីរបស់នាង នៅពេលដែលនាងភ្ញាក់ដឹងខ្លួនក៏ដោយ សុបិន្តបានបញ្ជាក់នូវភាពបន្ទោសខ្លួនឯងរបស់នាង។ នាងពុំអាចជួយស្រោចស្រង់ជីវិតឪពុកនាងនៅក្នុងជំរុំអប់រំជំនាន់ប៉ុលពតបាន ហើយនាងមានអារម្មណ៏ថានាងបានចូលរួមនៅក្នុងមរណៈភាពរបស់គាត់ ដោយនាងពុំបានចែករំលែកចំណែកអាហារ រួមចំណែកដ៏តិចតួចរបស់នាងអោយទៅឪពុក។ ការបាត់បង់ឪពុក និងអារម្មណ៏ទទួលខុសត្រូវរបស់នាងទៅលើមរណៈភាព របស់ឪពុកនាងបានបង្ហាញឡើងនៅក្នុងសុបិន្តអាក្រក់របស់នាង ដែលបណ្តាលអោយនាងព្យាយាមសម្លាប់ខ្លួន។

ការសម្ភាសន៍នេះជា *ឱកាសមួយសម្រាប់ខ្ញុំ* ឬការរកឃើញ ផ្នែកវិទ្យាសាស្ត្រពេទ្យ បង្រៀននូវសេចក្តីសំខាន់ៗនៅក្នុងការធ្វើដំណើរដោយរលូន និងភាពសុបិន្តរបស់អ្នកនិទានរឿងតក់ស្លុត បែបបទដែលសុបិន្ត និង សុបិន្តអាក្រក់មានរូបរាង និងមានដំណើរ នៃភាពតក់ស្លុតបានរស់ឡើងវិញ ជាចំណុចមួយដ៏ចាំបាច់ក្នុងភាពជាសះស្បើយដោយខ្លួនឯង និងការរួចផុតពីសេចក្តីស្លាប់របស់មនុស្សលោក។ អារម្មណ៏របស់ជនរងគ្រោះហាក់បីដូចជានៅតែនឹកថា "ខ្ញុំចងចាំការរួចផុតពីសេចក្តីស្លាប់ ហើយខ្ញុំសង្ឃឹមថា នឹងធ្វើអោយអំពើអាក្រក់ដែលបង្កើតឡើងដោយអ្នកដទៃបានភាពជាសះស្បើយ"។

## ផ្នែក ១. តួនាទីវិជ្ជមាន (ល្អ) របស់សុបិន្ត

ការរកឃើញនូវសម័យថ្មីនៅលើជីវសាស្រ្ត នៃការចងចាំ និងសុបិន្តបានបញ្ជាក់ថាវិញ្ញាណយល់ដឹងការចងចាំភាពតក់ស្លុត និងសុបិន្តបានជួយក្នុងភាពជាសះស្បើយ និងភាពរួចផុតពីសេចក្តីស្លាប់។ ផ្នែកចិត្តសាស្រ្តនៃការយល់សុបិន្តបានអធិប្បាយឡើងជាលើកដំបូងនៅឆ្នាំ១៩៥៣ នៅពេលដែលអ្នកស្រាវជ្រាវរកឃើញការទទួលដំណើរពេលយប់ គឺរំខានឡើងនៅអំឡុងពេលសកម្មភាពចរន្តមានដំណើរការនៅក្នុងខួរក្បាល (ហៅថាចរន្តខួរក្បាល ដែលគេវាស់ដោយចរន្តអគ្គិសនី (Electroencephalogram ឬ EEG) វាជាការតាមសង្កេតមើលដូចគ្នា នឹង

ពេលដែលមនុស្សភ្ញាក់ដែរ។ ក្នុងរយៈពេលនេះ មានល្បឿនចលនាភ្នែក ( Rapid Eye Movement ឬREM ) ដេកជារយៈពេលតែមួយគត់ ដែលការយល់សុបិន្តកើតមានឡើង។ ទោះជាគ្មានការបញ្ជាក់ដោយពិតប្រាកដធ្វើឡើងក៏ដោយ អ្នកវិទ្យាសាស្ត្រជឿថាចលនាភ្នែកនៅក្នុងពេលដេកលក់ ហាក់បីដូចជាអនុលោមទៅតាមសកម្មភាពនៅក្នុងសុបិន្តរបស់យើង យើងមើលឃើញសុបិន្តរបស់យើងដោយចំៗនៅពេលដែលសុបិន្តកំពុងតែកើតមានឡើង។

អ្នកវិទ្យាសាស្ត្រផ្នែកការចងចាំលោក ជូណាថាង វិនស៊ុន (Jonathan Winson) បានផ្តល់យោបល់ឡើងថា សុបិន្តកើតចេញពីដំណើរការរបស់សរសៃប្រសាទ ដែលព័ត៌មានត្រូវបានប្រមូលផ្តុំដែលនៅក្នុងកំឡុងពេលថ្ងៃ ចាំបាច់សម្រាប់ការរស់រានមានជីវិតរបស់ពូជពង្ស នៃជំពូកផ្សេងៗ ដែលត្រូវបានយកមកអោយមានដំណើរការឡើងវិញ នៅពេលដេកលង់លក់។

សម្មតិកម្មជាទ្រឹស្តីយោងទៅតាមការសិក្សានៃរកឃើញ នៅក្នុង ឆ្នាំ១៩៥៤ នៃចង្វាក់ខួរក្បាល (Theta rhythms) ធម្មតារបស់សត្វទន្សាយ សត្វកំប្រុក សត្វកំពីងពួយ សត្វកណ្តុរ និងសត្វឆ្មា នៅពេលដែលវាភ្ញាក់ដឹងខ្លួន។ ចង្វាក់ខួរក្បាលសត្វទាំងនេះ និងអាកប្បកិរិយាផ្សេងៗដែលចំបាច់សម្រាប់ការរស់រានមានជីវិតរបស់សត្វដូចជា ការស្វែងរកសាច់ជាអាហារ និងការរុករកអាហារ សកម្មភាពទាំងនេះក៏រកឃើញមាននៅកំណត់ពេលល្បឿនចលនាភ្នែក(REM) នៅពេលដេកលក់របស់សត្វដែរ។ លោក Wilson បានបង្ហាញទំនាក់ទំនងរវាងចង្វាក់ខួរក្បាលសត្វទៅ នឹងការបង្កើតភាពចងចាំដោយធ្វើអោយខួរក្បាលរបស់សត្វកណ្តុរមានរបួស មធ្យោបាយបំបាត់ភាពប្រុងប្រយត្ន័នៅក្នុងចង្វាក់ខួរក្បាលនេះ ដាយថាហេតុបំបាត់ជំនាញរស់នៅរបស់សត្វ។ ទោះជាចង្វាក់ខួរក្បាល (Theta rhythms) ពុំមានរកឃើញនៅក្នុងមនុស្សលោក ឬពួកសត្វស្វា លោក Winson បានសន្និដ្ឋានថាវាផ្តល់គន្លឹះអំពីដើមហេតុនៃការយល់សុបិន្តរបស់មនុស្ស ។ "សុបិន្តអាចឆ្លុះបញ្ចាំងនូវយន្តការបកស្រាយ ការចងចាំពីជំពូកសត្វតូចតាច ដែលជាព័ត៏មានសំខាន់សម្រាប់ការរស់នៅ បានយកមកប្រើឡើងវិញនៅក្នុងល្បឿនចលនាភ្នែក( REM )នៅពេលដេកលក់"។

នៅក្នុងបរិស្ថានដ៏គ្រោះថ្នាក់ របស់បុព្វបុរសនាអតីតកាល វាជាភាពងាយស្រួលក្នុងការ នឹកគិតអំពីមនុស្សលោកជំនាន់ដើម ក្នុងការចែកចាយបទពិសោធន៏ដែលមានការគំរាមកំហែងដល់ជីវិតរស់នៅរបស់ពួកគេ មានរួមទាំងព្រឹត្តិការណ៍ហឹង្សាដែលទាក់ទង នឹងការព្រានប្រមាញ់ ការភ្ជួររាស់ដីសម្រាប់កសិកម្ម ធាតុអាកាស និងករណីសំខាន់ជាងគេ គឺអ្នកសម្រាប់សត្វ និងសម្លាប់មនុស្ស។ សត្វ និងមនុស្សប្រហែលច្រើនតែបន្តនឹកគិតពីឧបហេតុតក់ស្លុតនៅក្នុងសុបិន្តរបស់គេ ដើម្បីរៀនអំពីរបៀបរស់រានមានជីវិត សម្រាប់ទប់ទល់ នឹងគ្រោះថ្នាក់នៅថ្ងៃអនាគត ។ ព័ត៌មាននៅក្នុងខួរក្បាលទាំងអស់ដែលខួរក្បាលរ៉ាប់រងយកមកដោះស្រាយនៅក្នុងពេលលង់លក់ អាចពិតជាចំណុចសំខាន់ៗសម្រាប់ករណីភាពដែលមិនដឹងខ្លួន។ ព័ត៌មានក្នុងសុបិន្ត គឺកើតឡើងពីចំណេះដឹង និងព័ត៌មានទាំងអស់ដែលមាននៅក្នុងខួរក្បាល ហើយកម្រិតមានតិចតួចណាស់ដែលវាដក់ជាប់នៅក្នុងខួរក្បាលនៅពេលមានស្មារតី សុបិន្តជាតំណាង នៃទំនាក់ទំនងព័ត៌មានដែលមានសម្រាប់ជួយយើងនៅក្នុងដំណើរជីវិតប្រចាំថ្ងៃរបស់យើង។

ទស្សនៈជីវសាស្ត្រទៅលើសារៈសំខាន់របស់សុបិន្ត ក្នុងភាពរស់រានមានជីវិត ជួយក្នុងការយល់ដឹងអំពីសុបិន្ត និងសុបិន្តអាក្រក់ដែលបានរាយការណ៍ឡើងដោយជនទទួលភាពតក់ស្លុត។ លោក Winson និងអ្នកផ្សេងៗទៀត បានរាយការណ៍ថាអត្ថន័យសុបិន្ត និងសុបិន្តអាក្រក់របស់ជនទទួលភាពតក់ស្លុតពុំអាចបន្លំដោយការធ្វើអោយប្លែក និងការទប់បង្ក្រាបបានឡើយ តែវាត្រូវមានជាស្រេចសម្រាប់នឹកយកមកវិញ។ ទោះបីជាអ្វីៗដែលមាននៅក្នុងសុបិន្ត ជាញឹកញាប់ច្រើនតែស្រពិចស្រពិល និងការប្រមូលផ្តុំព័ត៌មានដោយខួរក្បាលជាភាពពុំដឹងច្បាស់ក៏ដោយ វាអាចផ្តល់នូវការយល់ដឹងសំខាន់ទៅលើរឿងតក់ស្លុតក្នុង ផ្នែកព្យាបាលជនទទួលភាពតក់ស្លុតអាចត្រូវគេសួរអំពីការយល់ដឹងរបស់គេទៅលើអ្វីៗ និងអត្ថន័យសុបិន្តរបស់គេ។ ចំពោះទស្សនៈ ផ្នែកជីវសាស្ត្រ និងផ្នែកវិវឌ្ឍន៍វិញ សុបិន្តជាអ្នកដោះស្រាយបញ្ហាផ្ទៃក្នុងដ៏សំខាន់ និងជាអ្នកបង្រៀនពីយន្តការនៃការរស់រានមានជីវិត។

សុបិន្តល្អបង្រៀនអំពីវិធីរស់រានមានជីវិត និងផ្តល់នូវភាពជាសះស្បើយដល់រាងកាយ និងសតិអារម្មណ៍ពីក្នុងចិត្ត។ សុបិន្តអាក្រក់បង្កើតអោយមានអារម្មណ៍ជាអវិជ្ជាមានដ៏ខ្លាំង ដែលបណ្តាលអោយការយល់ដឹងមានកម្រិតតិចតួច ហើយនឹងអាចបណ្តាលអោយលក្ខណៈជីវិតរបស់បុគ្គលនោះកាន់តែចុះថយ។ នៅករណីបន្តបន្ទាប់មកដំណើរការជីវសាស្ត្រ នៃសេចក្តីចងចាំ ដែលទាក់ទង នឹងដំណើរការរបស់សុបិន្តបានតម្រូវអោយខួរក្បាលធ្វើការដ៏ខ្លាំងជ្រុលជុនជាបពេក បានត្រឡប់ទៅជាធ្វើអោយអ្នកមានភាពតក់ស្លុត ជាមានភាពឈឺចាប់កាន់តែខ្លាំងឡើង ដូចជាកោសិកា នៃសេរីរាង្គកាយក្លាយទៅជាមេរោគព្យាបាទរាង្គកាយខ្លួនឯង។ ការឆ្លើយតបចិត្តសាស្ត្រដែលទាក់ទង នឹងអ្វីៗមាននៅក្នុងសុបិន្ត ដូចជាប្រតិកម្ម នឹងអារម្មណ៍តានតឹង អាចធ្វើអោយរាង្គកាយមានរបួស។ ការនឹកឃើញសារចុះសារឡើង ទៅលើព្រឹត្តិការណ៍អាក្រក់ នៃរឿងតក់ស្លុតដោយគ្មានដំណោះស្រាយ ឬការសម្រាលទុក្ខអាចធ្វើអោយមានសេចក្តីអស់សង្ឃឹម និងខកចិត្តនៅក្នុងស្ថានភាពភ្ញាក់ដឹងខ្លួន។

ការយកចិត្តទុកដាក់ទៅលើតួនាទីក្នុងការដោះស្រាយបញ្ហាធ្ងន់ធ្ងរនៃសុបិន្ត ធ្វើអោយមានវិធីព្យាបាលថ្មីផ្តើមកើតឡើង។ បាតុភូតនៃការចងចាំទាំងអស់ មានរួមទាំងការចងចាំពេលថ្ងៃ និងសុបិន្ត ជាទ្រង់ទ្រាយសំខាន់នៃដំណើរការព្យាបាលដោយខ្លួនឯងរបស់ជនរួចផុតពីសាចក្តីស្លាប់។ អ្នកព្យាបាលត្រូវតែស្តាប់រឿងតក់ស្លុតនៅក្នុងសុបិន្ត ហើយរៀបចំតាមលំដាប់បើសិនជាអាចធ្វើបាន ថាតើសុបិន្តបង្រៀនពីអ្វីខ្លះ។ អ្នកព្យាបាលដ៏ត្រូវតែយកចិត្តទុកដាក់ ឬមិនត្រូវព្រងើយកន្តើយពីសេចក្តីសុបិន្តរបស់អ្នកជម្ងឺតទៅទៀត ហើយត្រូវចាត់ទុកខ្លួនជាសិស្សមួយរូប ដែលជំពុងរៀនសូត្រពីសុបិន្ត ហើយអនុញ្ញាតអោយសុបិន្តនោះជួយណែនាំដល់រូបគេ។

ដើម្បីបង្កើតឥទ្ធិពលព្យាបាលនៃសុបិន្ត អ្នកត្រូវដឹងពីវប្បធម៌ គឺជាកត្តាដ៏សំខាន់ ផល្លា(Phalla)ជាស្ត្រីវ័យកណ្តាលម្នាក់ គាត់មានប្អូនប្រុសម្នាក់នៅស្រុកខ្មែរដែលបានស្លាប់ថ្មីៗ ក្នុងអាយុ ៣៥ឆ្នាំ។ នាងបានផ្ញើប្រាក់ទៅស្រុកខ្មែរ អោយគេធ្វើបុណ្យសពតាមប្រពៃណីនៅវត្តអារាមជូនប្អូនរបស់នាង តែញាតិមិត្តរបស់នាងបានលួចប្រាក់នោះអស់ទៅ។ ហើយរឿងនេះបានក្លាយជាសាច់រឿងនៃសុបិន្តអាក្រក់ដែលកើតឡើងជារឿយៗ ដោយប្អូនប្រុសរបស់នាងចេះតែបង្ហាញខ្លួនឡើង ដោយមានរូបរាងស្គមស្គាំង។ ផល្លាចេះតែចង់ទៅជាមួយប្អូនប្រុសរបស់

នាង តែមានតាចាស់ម្នាក់ហាមនាងថាកុំអោយទៅជិតប្អូន ព្រោះប្អូននាងបានក្លាយខ្លួនទៅជាខ្មោច ហើយវាអាចចូលសណ្ឋិតក្នុងរាងកាយនាងធ្វើអោយនាងឈឺ។ នាងបដិសាធពុំស្តាប់សេចក្តីហាមឃាត់នេះទេ នាងបានលើកប្អូននាងឡើង ហើយចាប់ផ្តើមអៀវកវាដើរលើស្ពានមួយ ហើយមកដល់ត្រឹមចំនុចនេះនាងបានភ្ញាក់ដឹងខ្លួនឡើង។

នៅពេលដែលគេសួរថា តើព្រលឹងរបស់ប្អូននាងបានទៅកាន់សុគតិភព ដែរឬទេ នាងបានពន្យល់ទាំងទឹកភ្នែកថា នាងជឿថាប្អូននាងពុំបានសុខទេ លើកលែងតែលោកសង្ឃសូត្រមន្តតាមប្រពៃណីអោយវា។ គម្រោងធ្វើបុណ្យនៅវត្តក្នុងតំបន់បានធ្វើឡើងយ៉ាងឆាប់រហ័សអោយអ្នកជម្ងឺ។ នៅពេលផល្លាមកព្យាបាលលើកក្រោយ សុបិន្តអាក្រក់របស់នាងបានបាត់ទៅ ហើយទុក្ខកង្វល់របស់នាងក៏រម្ងាប់បាត់ដែរ វាជាភាពមួយដែលនាងសន្មតថាមកពីនាងបានធ្វើបុណ្យអោយប្អូននាង។

ចំពោះជនរងគ្រោះខ្លះទៀត ការទាក់ទងនៅក្នុងសុបិន្តជាមួយ នឹងក្រុមគ្រួសារដែលបាត់ខ្លួន ឬស្លាប់អាចជាករណីដែលធ្វើអោយមានការជាសះស្បើយដែរ។ នៅក្នុងឆ្នាំ២០០៤ស្ត្រីជរាជនជាតិបូស្សាន(Bosian) នៅស្រេប្រេនីកា(Srebrenica) ឈ្មោះ អឺមីុណា (Ermina) រស់នៅក្នុងផ្ទះមួយព័ទ្ធជុំជិតទៅដោយភាពវិនាសទៅលើរាង្គកាយ និងអនុស្សាវរីយ៍របស់ញាតិមិត្ត ចំនួន ៣គ្រួសារ ដែលត្រូវបានគេសម្លាប់ មានរួមទាំងប្តី និងកូនប្រុសរបស់គាត់។ នៅពេលដែលសួរថា តើគាត់បន្តរស់នៅទីនេះដូចម្តេចទៅ គាត់ឆ្លើយថាពេលខ្លះគាត់មានអារម្មណ៏ថាគាត់អាចបាត់បង់វិញ្ញាណដោយសារទុក្ខសោកនេះ។ តែគាត់និយាយបន្តថា "ប្តីខ្ញុំមករកខ្ញុំជាញឹកញាប់នៅក្នុងសុបិន្តរបស់ខ្ញុំ ហើយប្រាប់ខ្ញុំថាជាការប្រសើរណាស់ ដែលខ្ញុំវិលត្រឡប់មកទាមទារយកដីធ្លីរបស់យើងវិញ"។ ការមកជួបពេលយប់របស់ប្តី និងពេលខ្លះកូនប្រុសរបស់គាត់ជួយជម្រុញទឹកចិត្តគាត់ និងជួយគាត់ អោយរស់នៅជាធម្មតា សតិអារម្មណ៏សុខសាន្តក្នុងជីវិតនៅលើដីមួយជំរៀកតូច ដែលឃាឃីដោយសេចក្តីស្លាប់។

## ១.១ តួនាទីអវិជ្ជមាន (មិនល្អ) នៃសុបិន្ត

អ្នករួចផុតពីសេចក្តីស្លាប់ដោយសារអំពើឃោរឃៅ សមត្ថភាពដោះស្រាយនូវអនុស្សាវរីយ៍ និងសុបិន្តជាធម្មជាតិរបស់គេ មានភាពផ្សេងៗគ្នា។ នៅក្នុងការស្រាវជ្រាវអំពីជនភៀសខ្លួនបូស៊្សីនាន (Bosinian) ដែលមានលក្ខណៈទ្រង់ទ្រាយដ៏ធំ ហើយបានកត់ត្រាទុកជាយូរមកហើយអំពីព្រឹត្តិការណ៏តក់ស្លុតដែលទាក់ទងនឹងសង្គ្រាម និងទារុណកម្មចំនួនជាង ៦០ករណី យើងបានរកឃើញថា ភាពកើតឡើងជាធម្មជាតិចំពោះភាគច្រើននោះ គឺគេឈប់គិតអំពីព្រឹត្តិការណ៏ដែលកើតឡើងចំពោះពួកគេ។ អស់រយៈពេលជិត ៣ឆ្នាំ នៅចន្លោះការសម្ភាសន៍របស់យើង ភាគច្រើនបានរាយការណ៏ ថាកម្រិតព្រឹត្តិការណ៏តក់ស្លុតដែលគេបានទទួលបទពិសោធន៍បានថយចុះតាមរយៈការបំភ្លេចចោលនូវការចងចាំ នៃភាពតក់ស្លុតទាំងនោះ។ រឿងនិទានអំពីការដោះស្រាយបញ្ហាអាចផ្តល់នូវលទ្ធផលល្អទាំងនេះ។

ក្រុមចំនួនពីរ ដែលបានចូលរួមនៅក្នុងការស្រាវជ្រាវនេះ មានភាពខុសប្លែកពីក្រុមផ្សេងៗទៀត ក្នុងកំឡុង ពេលការសម្ភាសន៍លើកទី១ នៃការរៀបរាប់មើលឃើញជាក់ស្តែង ឬក៏មានបទពិសោធន៍ផ្ទាល់ទាក់ទងនឹងការបំពារបំពានផ្លូវភេទ ផ្លូវដែលរួមបញ្ចូលការចាប់រំលោភ។ អំពើឃោរឃៅផ្លូវភេទនៅក្នុងសង្គ្រាមប្រទេសបូស្សនា(Bosnia)ដែលជាសភាពពេញនិយមទាំងបុរស ទាំងស្ត្រី។ ទោះបីជាយ៉ាងណាក៏ដោយ ៣ឆ្នាំក្រោយមក គ្មានជនណាម្នាក់និយាយបញ្ចេញថាគេបានទទួល ឬឃើញជាសាក្សីនូវបទពិសោធន៍ទាំងនោះឡើយ។ លទ្ធផលបង្ហាញនូវឥទ្ធិពលតួនាទី នៃកត្តាវប្បធម៌ ដូចជាភាពអាម៉ាស់មុខទៅលើការរំលឹកឡើងវិញ នៃការចងចាំ។ នៅក្នុងករណីនេះ ភាពអាម៉ាស់មុខដែលទាក់ទងទៅ នឹងការបំពារបំពានផ្លូវភេទ អាចបណ្តាលអោយបុគ្គលដែលទទួលរងគ្រោះបាត់បង់នូវការចងចាំសេចក្តីចងចាំទាំងស្រុង-ជាបាតុភូតដែលអាចជាករណីសំខាន់សម្រាប់ការរស់រានមានជីវិតរបស់ពួកគេក្នុងក្រុមគ្រួសាររបស់គេ និងសហគមន៍។

ក្រុមទី២ ដែលមានសភាពប្លែកនៅក្នុងការស្រាវជ្រាវ មានរួមទៅដោយជនដែលនិយាយថាគេមានការចងចាំដ៏តក់ស្លុតច្រើន ហើយនៅតែមានសុបិន្តអាក្រក់ ៣ឆ្នាំក្រោយមក។ ក្នុងចំណោមជនទាំងនេះ មានជនមួយចំនួនតូច មានជម្ងឺតក់ស្លុត(PTSD) ជាជម្ងឺផ្លូវចិត្តដែលកើតមានឡើងដោយព្រឹត្តិការណ៍តក់ស្លុតដល់ជីវិត ហើយព្រឹត្តិការណ៍នេះបានបង្ហាញឡើងដោយការចងចាំ និងសុបិន្តអាក្រក់ នៃព្រឹត្តិការណ៍នោះជារឿយៗ។ ការគេចចេញពីសេចក្តីពិត ទីកន្លែង ឬជនដែលបង្កអោយមានភាពតក់ស្លុត អារម្មណ៍ឃ្លាតឆ្ងាយ និងពុំចង់ជួបមនុស្សឯទៀត ឆាប់ភ្ញាក់ផ្អើល ឬរំជើបរំជួលសតិអារម្មណ៍។ ជនភៀសខ្លួនទាំងនេះប្រៀបបានទៅ នឹងជនដែលមានបទពិសោធន៏ភាពតក់ស្លុតដូចគ្នា គេមានអារម្មណ៍ប្លែកពីអ្នកទាំងនោះ ដោយគេគិតពីបទពិសោធន៍ឃោរឃៅរបស់គេជាប់ជានិច្ច ហើយវិធីព្យាបាលខ្លួនរបស់គេពុំមានជោគជ័យ។

ចំពោះជនទទួលភាពតក់ស្លុតខ្លះៗ សុបិន្ត និងសុបិន្តអាក្រក់ជាភាពព្យាបាលសម្រាប់ពួកគេ រីឯជនដែលរងទុក្ខព្រួយ ឬឈឺថ្កាត់ធ្ងន់ធ្ងរដោយសុបិន្តទាំងនេះ ជាកត្តាដែលគេពុំអាចដឹងបាន។ ជាលទ្ធផលអ្នកវិជ្ជាជីវៈខាងព្យាបាលផ្លូវចិត្តពុំមានមតិយល់ស្របជារួមថា តើការចងចាំព្រឹត្តិការណ៍តក់ស្លុត និងក្តីសុបិន្តតែលើកទឹកចិត្តអោយមានបែបវិទ្យាសាស្ត្រ ដោយអនុភាពធ្វើអោយខូចប្រយោជន៍អាចកើតមាន ឬក៏ត្រូវបង្កប់ចោល។ សុបិន្តជាពិសេសអាចជាភាពតក់ស្លុត បើសិនជាវាក្លាយជាសុបិន្តអាក្រក់ នៅពេលដែលសុបិន្តអាក្រក់កើតឡើង ជាញឹកញាប់ ការវិនិច្ឆ័យ ផ្នែកសតិអារម្មណ៍ទៅលើជម្ងឺតក់ស្លុតច្រើនតែអនុម័តថាជាទុក្ខព្រួយក្រោយពីព្រឹត្តិការណ៍កើតមានឡើង (PTSD)។ សុបិន្តដែលមានភាពតក់ស្លុត និងសុបិន្តអាក្រក់ គឺជាលក្ខណៈធម្មតាដែលកើតមានឡើងនៅក្នុងចំណោមប្រជាជនដែលទទួលរងនូវភាពតក់ស្លុត ដែលអាចគ្មានការបញ្ជាក់ថាជារោគ ឬជម្ងឺ ប៉ុន្តែ អាចបបង្ហាញឡើងនូវដំណើរការដោះស្រាយបញ្ហា និងភាពជាសះស្បើយដោយខ្លួនឯង។ វាជាភាពដែលអាចកើតមានឡើងនៅក្នុងចំណោមអ្នករួចផុតពីសេចក្តីស្លាប់មួយភាគតិច ដោយដំណើរការភាពជាសះស្បើយដោយខ្លួនឯង នៃសេចក្តីចងចាំនៃភាពតក់ស្លុតបានទទួលបរាជ័យខុសពីគោលបំណងព្យាបាល ដែលបណ្តាលអោយមានលទ្ធផលមិនល្អទៅលើសុខភាព និងសង្គម ការវិនិច្ឆ័យរោគ នៃជម្ងឺតក់ស្លុត (PTSD) គួរតែត្រូវធ្វើការអនុវត្តឡើងដោយប្រុងប្រយ័ត្ន។

បើសិនជាការចងចាំបទពិសោធន៍តក់ស្លុត អាចបំបាត់ដោយគ្រាន់តែជាការផ្សងទុក បញ្ហាចងចាំការតក់ស្លុត និងសុបិន្តអាចរលាយបាត់ទៅ។ តែការទប់ស្កាត់គំនិតពុំងាយស្រួលធ្វើបានឡើយ ដូចបានបង្ហាញឡើងនៅក្នុងការសិក្សាស្រាវជ្រាវដោយលោក ដានីញ៉ែល អិម វែគន័រ( Danniel M.Wegner ) និងសហការីរបស់គាត់។ ក្រុមស្រាវជ្រាវរបស់មហាវិទ្យាល័យ២ បានណែនាំអោយគិតអំពីសត្វខ្លាឃ្មុំសមួយ។ ក្រុមទី១ បានទទួលការស្នើសុំ អោយទប់កាតពគិតទៅលើសត្វខ្លាឃ្មុំ តែក្រុមនេះបានរាយការណ៍ថា គេគិតពីសត្វខ្លាឃ្មុំសច្រើនជាង ក្រុមដែលពុំបានទទួលការស្នើសុំអោយទប់ស្កាត់កុំអោយគិតទៅលើសត្វខ្លាឃ្មុំនោះ។

ការពិសោធន៍ជាច្រើនពេលនេះបានបង្ហាញឡើងដោយគ្មានការប្រែប្រួលថា ការព្យាយាមទប់ស្កាត់ការគិតដែលយើងពុំចង់គិត ផ្ទុយទៅវិញវាធ្វើអោយគំនិតដែលយើងពុំចង់គិតនោះវិលត្រឡប់មកវិញ ជាញឹកញាប់ច្រើនកាន់តែខ្លាំងជាងមុន។ ដោយការព្យាយាមទប់ស្កាត់ការចងចាំជាទូទៅច្រើនតែគ្មានប្រសិទ្ធិភាព អ្នកវិទ្យាសាស្ត្រ ផ្នែកសរសៃប្រសាទបានព្យាយាមបង្កើតថ្នាំពេទ្យដែលអាចលុបបំបាត់សេចក្តីចងចាំតក់ស្លុត មកដល់ពេលនេះ ទោះបីជាយ៉ាងណាក៏ដោយគ្មានថ្នាំពេទ្យណាអាចព្យាបាលបាន ឬទប់ស្កាត់សេចក្តីចងចាំដែលពុំចង់គិតនោះបានឡើយ។

ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាថតរូបភាពសរសៃប្រសាទថ្មីៗ នេះ បានបង្ហាញថាសកម្មភាពដែលកើតឡើងនៅពេលមានស្មារតី នៅចំណុចស្រោមខួរក្បាលអាចទប់ស្កាត់ សេចក្តីចងចាំនៅត្រង់ចំណុចពាក់កណ្តាលខួរក្បាល ដែលគេជឿថាជាចំណុចគ្រប់គ្រង សេចក្តីចងចាំភាពតក់ស្លុត។ ទោះជាការបំបាត់សេចក្តីចងចាំភាពតក់ស្លុតធ្វើឡើងដោយបំណងក៏ដោយ ជាពិសេសខាងផ្លូវអារម្មណ៍មានការលំបាក ដោយការសិក្សារូបភាពសរសៃប្រសាទ បានបង្ហាញថាមានទំនោរជាធម្មជាតិមួយទៅរកការផុសឡើង នៃការចងចាំភាពតក់ស្លុតភ្លាមតែកម្រិតឆ្លើយតបដែលទាក់ទង នឹងអារម្មណ៍ នឹងរសាយបាត់ទៅវិញទៅតាមពេលវេលា។ ស្ថានភាព ពិតប្រាកដដែលបុគ្គលម្នាក់ អាចទប់សាចក្តីចងចាំទៅលើបទពិសោធន៍ អតីតកាលពុំអាចដឹងច្បាស់បានឡើយ។ យុទ្ធសាស្ត្រនៃបញ្ញាយល់ដឹងសព្វគ្រប់ ដែលអ្នករួចផុតពីសេចក្តីស្លាប់យកមកប្រើដើម្បីដោះស្រាយសេចក្តីចងចាំតក់ស្លុត និងសុបិន្ត ជាករណីដែលគេពុំអាចយល់ដឹងច្បាស់បាន។ មធ្យោបាយ ដូចជាការនិទានរឿងតក់ស្លុតល្អ អាចជួយគាំទ្រជម្រុញបង្កើនភាពដោះស្រាយបញ្ហាជាធម្មជាតិ និងបង្កើនឥទ្ធិពលបំភ្លេចសេចក្តីចងចាំ សុបិន្ត និងសុបិន្តអាក្រក់ ករណីទាំងនេះត្រូវតែបង្កើតអោយមានឡើង ដោយយកអនុភាពទាំងនេះមកប្រើដើម្បីបំបាត់សេចក្តីចងចាំជាជាងយកថ្នាំពេទ្យមកប្រើ។

## ១.២ ការចងចាំដែលបរាជ័យ

ជនរងគ្រោះដោយភាពតក់ស្លុតខ្លះៗ បានឆ្លងកាត់ភាពវិលវល់ចុះឡើង នៃការចងចាំ នឹងសុបិន្ត ដោយការព្យាយាមបំភ្លេច ច្រើនតែធ្វើអោយនឹកឃើញកាន់តែខ្លាំងៗ ជាងមុនទៅទៀត មានរួមទៅដោយលទ្ធផលអាក្រក់ ចំពោះជនដែលលាក់ទុកនូវការបំពារបំពានផ្លូវភេទរបស់គេ ជាការសម្ងាត់អនុភាព នៃការព្យាបាល អាច

ទទួលរងការឈឺចាប់ដោយស្ងាត់ៗ ការគិតពីភាពតក់ស្លុតជាប់ជានិច្ចនៅក្នុងចិត្ត។ ចំពោះអ្នកទាំងនេះ ជាធម្មតា ទៅលើសុបិន្ត និងសុបិន្តអាក្រក់បានបាត់បង់ភាពប្រសិទ្ធភាពរបស់អនុភាពនោះ។

បញ្ហា "ការចងចាំភាពដែលបរាជ័យ" ឬសុបិន្តភ័យខ្លាច សុបិន្តអាក្រក់ដែលកើតឡើងដោយផ្ទួនៗ ដែលពុំសោយបាត់ទៅវិញដោយឯកឯងជាយូរមក បានបង្ហាញឡើងដោយ អ្នកដឹកនាំសហគមន៍ប្រកបដោយជោគជ័យ ជនជាតិឡាវម្នាក់ ដែលបានមករស់នៅរដ្ឋកាល លីហ័រញ៉ាជាមួយ នឹងក្រុមគ្រួសារក្រោយពីគាត់បានរត់ភៀសខ្លួនពីប្រទេសឡាវ នៅឆ្នាំ ១៩៧៩។ តាំងពីពេលនោះមក ស៊ូវណ្ណា (Souvanna) ទទួលការឈឺចាប់ដោយសុបិន្តអាក្រក់ដដែលៗ អស់រយះបេលជាង ៣ទសវត្ស ។ គាត់តភ្ជាប់សុបិន្តរបស់គាត់ទៅភាពតក់ស្លុតពីរធំៗ នៅក្នុងជីវិតរបស់គាត់ ដែលគាត់រក្សាជាការសម្ងាត់ ទោះវាមិនមែនជាការលាក់សម្ងាត់ពីក្រុមគ្រួសាររបស់គាត់ ឬពីអ្នករស់រានមានជីវិតជាជនជាតិឡាវ ក៏ដោយហេតុការណ៍ លើកដំបូងបានកើតឡើង នៅពេលគាត់ជាប់គុកកុម្មុយនិស្តឡាវះ

ខ្ញុំបានធ្វើការអោយអាមេរិកកាំង នៅប្រទេសឡាវចាប់តាំងពីខ្ញុំបានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ នៅពេលដែលកុម្មុយនិស្ត បានចូលកាន់កាប់ប្រទេសឡាវ ពួកអាមេរិកកាំងក៏ចេញអស់ទៅ ខ្ញុំបានសម្រេចចិត្តរស់នៅក្នុងប្រទេសរបស់ខ្ញុំ។ នៅថ្ងៃទី១៨ ខែ មេសា ឆ្នាំ១៩៧៧ នៅវេលាម៉ោង៣រសៀល ពួកកុម្មុយនិស្តបានចាប់ខ្លួនខ្ញុំ គេចាប់ខ្ញុំដាក់ខ្នោះ ហើយបញ្ជូនទៅគុកឡាវខាងជើងជាប់ទល់ដែនចិន គុកអប់រំជាទីនរក។ វាដក់រហូតយកអ្វីៗទាំងអស់ចេញពីរូបខ្ញុំ។ នៅរយះពេល ចំនួន៦ខែដំបូង ខ្លួនខ្ញុំទ្រុឌទ្រោមខ្លាំង វាបង្ខំអោយខ្ញុំរស់នៅកន្លែងតូចមួយ ដូចជាទ្រុងជ្រូកជាមួយ នឹងអ្នកជាប់ គុក២២នាក់ទៀត វាហៅឈ្មោះហើយយើងត្រូវតែលុតជង្គង់ចុះ វាធ្វើបាបយើងដោយយើងជាមនុស្សអាក្រក់ ជាសត្រូវរបស់រដ្ឋាភិបាល។

អ្នកជាប់គុកជាមួយខ្ញុំជាច្រើននាក់បានស្លាប់ នៅពេលមានអ្នកលួចរត់ ហើយវាចាប់បាន វាសម្លាប់ចោល ហើយយកសពដែលបានសម្លាប់ដោយអាណោចអាធ័មនោះមកអោយយើងមើលគ្រប់គ្នា ខ្ញុំក្លាយជាមនុស្សដើរដោយគ្មានវិញ្ញាណមានតែរូបរាង។

នៅថ្ងៃមួយនោះ អ្នកជាប់គុក ចំនួន ២១នាក់ លួចរត់ ក្រោយពេលនោះមក វានាំខ្ញុំចេញពីទីនោះ វាបានយកខ្ញុំទៅលើភ្នំ ជាទីដែលវាបោះដែកគោលភ្ជាប់អ្នកជាប់គុកលួចរត់នៅលើឈើឆ្កាង ខ្ញុំបានឃើញអ្នកទាំងនោះ ហើយអ្នកខ្លះនៅរស់មិនទាន់ស្លាប់ទេ មិនដឹងជាមូលហេតុអ្វីទេ ក្រោយពីវាសួរចម្លើយខ្ញុំរួច វាអត់សម្លាប់ខ្ញុំ ឬធ្វើទារុណកម្មខ្ញុំទេ វាយកខ្ញុំចុះមកជុំរុំខាងក្រោមវិញ។ រឿងតក់ស្លុតទីពីរ គឺបានកើតឡើងបន្ទាប់ពី ស៊ូវណ្ណា ត្រូវបានដោះលែងពីគុក នៅឆ្នាំ១៩៧៩ ហើយបានភៀសខ្លួនទៅប្រទេសថៃឆ្លងកាត់ទន្លេមេគង្គ ជាមួយនឹងកូនស្រីម្នាក់ក្នុងចំណោម កូនស្រី ទាំង៣នាក់របស់គាត់។ ពេលបន្តិចក្រោយមកប្រពន្ធគាត់ក៏មកតាមក្រោយជាមួយ នឹងកូន២នាក់ទៀត។ គេភៀសខ្លួនតាមទូកតូចមួយដែលត្រូវលិចបាត់នៅកណ្តាលទន្លេ កូនទាំងពីរ ត្រូវទឹកគួចយកទៅបាត់ ហើយសពអ្នកទាំងពីរបាត់រកមិនឃើញ ក្នុងពេលភៀសខ្លួននោះ ប្រពន្ធរបស់គាត់ត្រូវគេចាប់ហើយ នឹង

ឃាត់ខ្លួន តែគេបានលែងនាង ហើយនាងក៏បានជួបជុំប្តីវិញ គាត់បាននិយាយថាការបាត់កូនស្រីទាំងពីររបស់គាត់ជា "ស្នាមរបួសនៅក្នុងបេះដូងរបស់ខ្ញុំ"។

ការគិតទៅលើហេតុការណ៍ទាំងពីរនេះ ជាពិសេស បទពិសោធន៍នៅក្នុងគុក ធ្វើអោយសុបិន្តអាក្រក់របស់បុរសនេះកើតមានឡើង។ នៅពេលដែលគាត់ភ្ញាក់ដឹងខ្លួន គាត់នឹកគិតត្រិះរិះទៅលើហេតុការណ៍ដែលកើតឡើងពីអតីតកាល ដោយគ្មានភាពច្បាស់លាស់អ្វីមួយឡើយ។ នៅពេលយប់គាត់ទទួលបទពិសោធន៍សំខាន់ ចំនួន២គ្មានឈប់ឈរ។ នៅក្នុងសុបិន្តមួយមានសត្វពស់ សត្វក្របី ឬសត្វដំរីដេញខាំគាត់នៅក្នុងព្រៃ។ សត្វពស់ជាធម្មតាច្រើនជាពស់ថ្លាន់ ឬសត្វពស់វែកធំហើយកាចសាហាវខ្លាំង គាត់ខ្លាចវាណាស់ហើយតែងតែព្យាយាមសម្លាប់វា នៅក្នុងសុបិន្តឯទៀតគាត់ត្រូវពួកកុម្មុយនិស្តដេញបាញ់គាត់ហើយគាត់ចេះរត់គេច។

រឿងតក់ស្លុតដែលជក់ជាប់នៅក្នុងសុបិន្ត អាចនឹកឃើញដោយងាយស្រួល ទាំងនេះពុំមែនជាកត្តាពិតនៃភាពរំជើបរំជួលសរសៃប្រសាទចេញពីខួរក្បាល ដែលហៅថាការសំអាតកាកសំណល់ ជីវិតពោរពេញទៅដោយបញ្ហាសតិអារម្មណ៍នោះឡើយ ។ សុបិន្តអាក្រក់ ក៏ពុំត្រូវការដាក់បញ្ចូលដោយសេរីដែរ ការបកស្រាយសេចក្តីប្រាថ្នាលាក់បាំង ឬការលាក់បំបាត់ចរិយាខ្មាស់អៀន ដើម្បីធ្វើការបញ្ជាក់ច្បាស់ទៅលើអត្ថន័យរបស់វា។ នៅពេលដែលសត្វពស់ជានិមិត្តរូបសំខាន់ក្នុងរឿងព្រេង និងវប្បធម៌របស់ជនជាតិឡាវ វាជាតំណាងថាមពលល្អក្នុងធម្មជាតិ ស៊ូវណ្ណា មានអារម្មណ៍ថា គាត់ពុំត្រូវការបកស្រាយសុបិន្តរបស់គាត់ ជានិមិត្តរូបឡើយ។ អារម្មណ៍ភាពពិតនៃសុបិន្តដែលកើតឡើងមិនឈប់ឈរទាំងនេះ ធ្វើអោយអារម្មណ៍រន្ធត់កាន់តែខ្លាំងឡើង៖ គាត់មានសេចក្តីភ័យខ្លាចជានិច្ចថា មានគេតាមសម្លាប់គាត់ ហើយគាត់បារម្ភថា តាមរយៈសុបិន្តគេ នឹងពិតជាបានសម្រេច។

សេចក្តីចងចាំរបស់ស៊ូវណ្ណា នៅពេលដែលគាត់ភ្ញាក់រួមជាមួយ នឹងសុបិន្តអាក្រក់ ក្លាយជាភាពរន្ធត់ពិតជាប់រហូត តែដូចគ្នា នឹងអ្នករួចផុតពីសេចក្តីស្លាប់ឯទៀត សុបិន្តអាក្រក់របស់គាត់ មិនញឹកញាប់ដូចជា ពេលវេលាចាប់ផ្តើមឡើងកាលពី ២៧ឆ្នាំមុនឡើយ។ នៅគ្រាដំបូងវាកើតឡើងជារៀងរាល់ថ្ងៃ បច្ចុប្បន្ននេះវាកើតឡើងជារៀងរាល់អាទិត្យ ហើយពេលខ្លះអាចកើតឡើងជារៀងរាល់ខែ។

ខ្ញុំសម្គាល់ឃើញថាសេចក្តីចងចាំទាំងនេះ និងសុបិន្តកើតឡើងតិចជាងមុន ខ្ញុំពុំអាចប្រាប់អ្នកថាវាញឹកញាប់យ៉ាងណាទេ ដោយវាកើតឡើងដោយគ្មានកំណត់ពេល វាកើតឡើងនៅពេលណាដែលវាកើតឡើង។ វាកើតឡើងរួមដោយសតិអារម្មណ៍រន្ធត់ខ្លាំង អ្នកពិតធ្វើការប្រាស្រ័យពុំចង់ទាក់ទង៖ អ្នកគ្រាន់តែចង់នៅតែឯកឯងដោយអ្នកមានអារម្មណ៍ក្រៀមក្រំ នៅក្នុងខ្លួនអ្នក ពិតណាស់នៅក្នុងខ្លួនអ្នកអារម្មណ៍ភ័យខ្លាចអាចផុសឡើងដោយងាយៗ ទោះបីអ្នកជាបុរសក្លាហានហើយព្យាយាមដោះស្រាយដោយបិទជិត លាក់ទុកមិនអោយវាលេចចេញក៏ដោយ អ្នកចង់និយាយទៅកាន់អារម្មណ៍ភ័យខ្លាចនេះបំភ្លេចវាចោលទៅ លាហើយ ពិតជាពុំងាយស្រួលទេ។

សុបិន្តមានជីវិតដោយខ្លួនឯង វារស់ដោយឯករាជ្យក្នុងអារម្មណ៍របស់អ្នករួចផុតពីសេចក្តីស្លាប់រូបនេះ ហើយធ្វើអោយគាត់តានតឹងអារម្មណ៍។ គេពុំអាចបង្ក្រាប ទប់ស្កាត់ ឬបំបាត់វាបានឡើយ វាផ្តល់សេចក្តីសង្ឃឹម ដល់

ស៊ូវណ្ណាថា សុបិន្តនេះពុំកើតឡើងញឹកញាប់ជាងមុន ឬតានតឹងដូចមុនឡើយ តែនៅពេលណាដែលវាកើតឡើងវាធ្វើអោយខូចខាតខ្លាំង គាត់ភ័យថាសុបិន្តដែលធ្វើអោយមានអារម្មណ៍តានតឹងដូចនេះ និងពិតជាសម្លាប់រូបគាត់៖ ខ្ញុំមានពេគខ្លាញ់ច្រើនក្នុងឈាម ហើយខ្ញុំភ័យថា បើខ្ញុំមានសុបិន្តបែបនេះ ខ្ញុំ នឹងស្លាប់ នៅពេលដែល ខ្ញុំមានសុបិន្តបែបនេះ ខ្ញុំត្រូវងើបឡើង ដើរចុះឡើង ឬមើលទូរទស្សន៍។ ចំនួន៥ ឬ១០នាទីក្រោយមក ខ្ញុំអាចទៅទទួលទានដំណេកវិញ ប្រពន្ធដឹងថា ខ្ញុំមានសុបិន្តបែបនេះ ហើយពេលខ្លះនាងបានលួងលោមខ្ញុំថា បន្ទាប់ពីសុបិន្តនោះបានកើតឡើង។

នៅពេល ស៊ូវណ្ណា ងើបពីសុបិន្ត បេះដូងរបស់គាត់លោតញាប់ខ្លាំង ហើយគាត់បែកញើសជោគខ្លួន ភាពតានតឹងអារម្មណ៍នេះកើតឡើង ពីសម្ពាធឈាមឡើងខ្ពស់ ចង្វាក់បេះដូងដើរខ្លាំង និងប្រព័ន្ធសរសៃប្រសាទផ្សេងទៀតកើតមានឡើង ជាសញ្ញាការភ័យខ្លាចខ្លាំង ដែលកកើតមានឡើង ជាង៣ទសវត្ស ហើយ ដែលធ្វើអោយខ្លួន និងខួរក្បាលរបស់គាត់នៅក្នុងភាព "ពុះកញ្ជ្រោល" ជាញឹកញាប់។ សុបិន្តអាក្រក់របស់ស៊ូវណ្ណា ពុំមានផ្តល់សុខុមាលភាពដល់រូបគាត់ឡើយ ជាការពិតណាស់ចំពោះជនភៀសខ្លួនជាច្រើនរូប និងសហគមន៍តក់ស្លុតឯទៀត ភាពតានតឹងពុំរ៉ែតក់ស្លុតដោយសុបិន្តអាក្រក់ធ្វើអោយមានពេគលើសឈាម ពេគបេះដូង និងពេគដាច់សរសៃខួរក្បាល។

នៅពេលដែលខ្ញុំព្យាយាមរកសញ្ញាខ្លះៗ ពីស៊ូវណ្ណា នៃការដោះស្រាយបញ្ហា ឬមេរៀនអំពីការរួចផុតពីសេចក្តីស្លាប់ នៃសុបិន្តរបស់គាត់ គ្មានអ្វីបង្ហាញឡើងសោះ ៖ ខ្ញុំគ្មានដឹងទាល់តែសោះថា សុបិន្តបង្រៀនអ្វីខ្លះដល់រូបខ្ញុំទេ ខ្ញុំគិតពុំឃើញថាតើខ្ញុំរៀនសូត្របានអ្វីខ្លះពីសុបិន្តទាំងនេះ ខ្ញុំពុំមានចំលើយទៅលើសំនួររបស់អ្នកទេ ខ្ញុំប្រាថ្នាថាការចងចាំ និងសុបិន្តទាំងនេះ នឹងសាបសូន្យទៅ។ វាធ្វើអោយខ្ញុំភ័យខ្លាចណាស់ ខ្ញុំពុំជឿថាវាជាសុបិន្តកើតឡើងពីជំនឿ ដូចជាចាស់ទុំ នៅស្រុកខ្ញុំជឿនោះឡើយ។ ខ្ញុំបានព្យាយាមសព្វបែបយ៉ាងតែគ្មានបានសម្រេចសោះក្នុងការបំភ្លេចសុបិន្តនេះ ជីវិតរបស់ខ្ញុំ នឹងមានភាពប្រសើរឡើងខ្លាំង បើគ្មានសុបិន្តនេះ។

ដោយគ្មានផ្តល់ផលប្រយោជន៍ភាពជាសះស្បើយដល់កាយ និងចិត្ត សុបិន្តទាំងនេះធ្វើអោយប៉ះពាល់ជីវិតរបស់ស៊ូវណ្ណា និងសុខភាពរបស់គាត់។ អ្នកវិទ្យាសាស្ត្រ ផ្នែកសរសៃប្រសាទពុំអាចឆ្លើយថា ហេតុអ្វីបានជាសុបិន្តទាំងនេះ បានគំរាមកំហែងដល់សតិអារម្មណ៍របស់អ្នកយល់សុបិន្ត។ វាជាករណីពុំច្បាស់លាស់ថា ហេតុអ្វី បានជាជនជាតិឡាវម្នាក់នេះមានសេចក្តីចងចាំដែលបំភ្លេចពុំបាននេះ នៅពេលដែលជនជាតិឡាវឯទៀតមានប្រវត្តិដូចគ្នា តែគេអាចបំភ្លេចទិដ្ឋភាពដ៏តក់ស្លុតនេះចេញពីអារម្មណ៍គេបាន។ ចំពោះរូបគាត់ភាពភ័យខ្លាច នៃអារម្មណ៍ទៅលើភាពតក់ស្លុតពិត និងសុបិន្តអាក្រក់ មានកម្រិតស្មើគ្នា វាបង្កើតនូវភាពភ័យខ្លាចជាទីបំផុត។ អារម្មណ៍របស់ស៊ូវណ្ណា បានបង្កើតសុបិន្តទាំងនេះ ដើម្បីរំលឹកគាត់ថា "គាត់បានទទួលភាពតក់ស្លុតដ៏អស្ចារ្យ ហើយនៅតែមានជីវិតរស់នៅ" តែគួរអោយស្តាយណាស់ ដោយគាត់បារម្ភថាមេរៀនដ៏សំខាន់នេះ នឹងបំផ្លាញសុខភាពរាង្គកាយរបស់គាត់នៅពេលស្របគ្នា។ ស៊ូ វណ្ណាពុំចង់បានសុបិន្តនេះតទៅទៀតទេ គាត់បានការដោះលែងចេញពីសុបិន្តនេះ។ ជាការពិតណាស់ករណីនេះជាសេចក្តីចងចាំពុំអាចបំភ្លេចបាន ហើយត្រូវការបំភ្លេចអោយសាបសូន្យ។

សេចក្តីសង្ឃឹមមានសម្រាប់ស៊ូ វណ្ណា និងអ្នកផ្សេងទៀតដែលរងគ្រោះដោយសុបិន្ត និងសុបិន្តអាក្រក់តក់ស្លុត ករណីសិក្សាស្រាវជ្រាវលើកដំបូងប្រើបច្ចេកទេសរូបភាព នៅក្នុងការព្យាបាលសុបិន្តអាក្រក់ដែលបានធ្វើឡើងតាំងពីឆ្នាំ ១៩៣០ ។ ការស្រាវជ្រាវបែបទស្សនៈវិជ្ជាដ៏ជឿនលឿនដោយប្រើវិធានការជ្រើសរើសដោយចៃដន្យ នៅក្នុងពេលថ្មីៗ នេះបានបង្ហាញថា សុបិន្តអាក្រក់ដែលកើតឡើងជាដដែលៗ ដោយពុំអាចបំភ្លេចបានរបស់ជនរួចផុតពីសេចក្តីស្លាប់នោះ អាចបំបាត់ចេញ ហើយដាក់សុបិន្តដែលល្អ មានប្រយោជន៍ជំនួសវិញ។ មធ្យោបាយព្យាបាលមានរួមទៅដោយ អ្នករងគ្រោះរៀនសូត្រអំពីវិធីគ្រប់គ្រង(Control)សុបិន្តអាក្រក់របស់ខ្លួននៅពេលដែលភ្ញាក់ដឹងខ្លួនឡើង។ ជាលទ្ធផលសុបិន្តអាក្រក់បានទទួលការ "វែកញែកដោយល្អិតល្អន់" ចេញពីអារម្មណ៍របស់អ្នករួចផុតពីសេចក្តីស្លាប់ ហើយត្រូវដាក់សុបិន្តមានប្រយោជន៍ល្អជំនួសវិញ។

នៅក្នុងការសិក្សាស្រាវជ្រាវដែលធ្វើឡើងនៅសកលវិទ្យាល័យ នីវម៉ិចស៊ីកូ (New Mexico) របស់ជនរងគ្រោះរំលោភផ្លូវភេទ ដែលមានសុបិន្តអាក្រក់រ៉ាំរ៉ៃ និងធ្ងន់ធ្ងរចំនួនជិតម្ភៃឆ្នាំ សុបិន្តអាក្រក់បានកាត់បន្ថយចុះដ៏ច្រើន ពីចំនួនប្រហែលជា២ដង ទៅជា៦ដងក្នុង១អាទិត្យ ដែលធ្វើអោយការទទួលទានដំណេកបានប្រសើរជាងមុន។ អ្នកព្យាបាលសម្រេចលទ្ធផលដ៏ស្ញើចសរសើរនេះជាបីផ្នែក គេបង្រៀនអ្នករងគ្រោះថាសុបិន្តអាក្រក់របស់គេក្លាយជាទម្លាប់"អាក្រក់"ធ្វើអោយគេគានតឹងអារម្មណ៍ និងទទួលទានដំណេកពុំបានដែលជាភាពអត់ប្រយោជន៍។ អ្នករួចផុតពីសេចក្តីស្លាប់ទទួលការបង្ហាត់អោយកត់កំណត់ហេតុសុបិន្ត ប្តូរសាច់រឿងដោយដាក់ទិដ្ឋភាពមានប្រយោជន៍ ហ្វឹកហាត់សុបិន្តថ្មីចំនួនដប់ទៅដប់ប្រាំនាទីជារៀងរាល់ថ្ងៃ ហើយតាមសង្កេតមើលការរលាយបាត់ សុបិន្តអាក្រក់របស់គេ នៅពេលក្រោយមក។ ស៊ូ វណ្ណា ជាបេក្ខជនមួយដ៏សមស្របបំផុតសំរាប់មធ្យោបាយនេះ ដោយគាត់ប្រុងប្រៀបជាស្រេចក្នុងការគ្រប់គ្រងទៅលើសុបិន្តរបស់គាត់។

តែគួរអោយសោកស្តាយណាស់ ដោយនៅពេលនេះមធ្យោបាយ ទៅតាមវិធីការស្រាវជ្រាវរបស់នីវម៉ិចស៊ីកូ (New Mexico) ត្រូវអ្នកព្យាបាលថែទាំជនរងគ្រោះដោយអំពើហឹង្សាដ៏មហិមា មួយចំនួនធំ ពុំយកចិត្តទុកដាក់នេះជាលទ្ធផលសេចក្តីដែលបរាជ័យនោះ ពុំបានទទួលការរកឃើញ និងព្យាបាលតាមវិធីសាស្ត្រនេះឡើយ។ សុបិន្តអាក្រក់ជាទូទៅ ច្រើនតែចាត់ចូលទៅក្នុងប្រភេទជម្ងឺតក់ស្លុត(PTSD) ហើយព្យាបាលដោយថ្នាំរម្ងាប់សតិអារម្មណ៍ ដែលភាគច្រើនគ្មានប្រសិទ្ធិភាពទៅលើរូបគេឡើយ។ សុបិន្តអាក្រក់នៅតែមានលក្ខណៈសញ្ញាពេខ្លាំក្លាដែលពុំងាយ នឹងរលត់សាបសូន្យ តាមរយៈមធ្យោបាយព្យាបាសបច្ចុប្បន្ន។

## ១.៣ ការប្រមូលផ្តុំយកសុបិន្តមកបរិយាយចែកចាយ

សុបិន្ត និងសុបិន្តអាក្រក់ មានភាពហួសពីសមត្ថភាពរបស់បុគ្គលម្នាក់ៗ ដែលក្លាយទៅជាបាតុភូតមួយដល់សង្គម។ ការស៊ើបអង្កេតដែលធ្វើឡើងដោយលោក ហរ្គ័ឌន់ ឡ័រ៉ន់( W. Gordon Lawrence) នៃគ្រឹះស្ថានថាវីស្តុក (Tavistock) នៅទីក្រុងឡុង (London)បានរកឃើញថាសុបិន្តជាអារម្មណ៍មួយដែលបានផ្លាស់ប្តូរទៅតាមបែបបទនៃសង្គម និងវប្បធម៌ មានន័យថា សុបិន្តទាំងនេះស្ថិតនៅក្នុងជាការសន្ទនាជាមួយមជ្ឈដ្ឋានសង្គម។

សាច់រឿងក្នុងសុបិន្តជាប់ទាក់ទងជាមួយ និងបទពិសោធន៍ប្រចាំថ្ងៃ ជាលទ្ធផលវាអាចផ្តល់ព័ត៌មានសំខាន់ៗសម្រាប់ការបំពេញការងារ និងទំនាក់ទំនងក្នុងសង្គម។ តែគួរអោយសោកស្តាយណាស់ការដេកយកសុបិន្តចេញពីសង្គមនេះ ជាករណីដែលកម្រកើតមានឡើង សុបិន្តនៅក្នុងសម័យដ៏ជឿនលឿនពុំមានទំនាយទាយទុកជាមុនសូរសម្លេង នៃដួងព្រលឹងវិញ្ញាណចេញពីភពមួយផ្សេងទៀត ដូចមាននៅក្នុងសម័យបុរាណ និងនៅក្នុងជីវិតរបស់មនុស្សលោក កាលពីជំនាន់ដើមឡើយ។ រឿងតក់ស្លុតមានរួមទៅដោយសុបិន្ត និងសុបិន្តអាក្រក់ពុំមានតួនាទីច្បាស់លាស់ចាត់ឡើងដោយសង្គមបានឡើយ។ ក៏ដូចជារឿងតក់ស្លុតដែរ គេគួរតែយកវាមកបរិយាយចែកចាយជូនជាមួយ នឹងសង្គម ដើម្បីផ្តល់ប្រយោជន៍ទៅលើភាពរួចផុតពីសេចក្តីស្លាប់ និងភាពជាសះស្បើយ ដូច្នេះសុបិន្ត និងសុបិន្តអាក្រក់គួរតែទាក់ទាញរឿងតក់ស្លុត។

ការនឹកឃើញនូវប្រវត្តិ ហេតុការណ៍តក់ស្លុតដែលប្រជាជននៅក្នុងសង្គមភាគច្រើនមានការជឿជាក់ទៅលើ និងទទួលស្គាល់ការអនុវត្តន៍ដោយរដ្ឋាភិបាលជាផ្លូវការ ជាញឹកញាប់ច្រើនតែពុំយោងទៅតាមបទពិសោធន៍ច្រើនរបស់ជនដែលបានឆ្លងកាត់ហេតុកាណ៍ពិតនោះទេ។ ការចងចាំបែបនេះជាទូទៅបង្កើតឡើងដោយអ្នកឈ្នះដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវរបស់អ្នកឈ្នះដែលកើតមានឡើង ជនជាតិបូស្សនាន បច្ចុប្បន្ននេះ បានជួប្រទះ និងសង្គ្រាមស៊ីវិល រួមដោយប្រជាជាតិខុសគ្នា ចំនួនបីក្រុម-ក្រ័រអូត(Croats ស៊ើប Serbs) និងបូស្សនាន ម៉ូស្លីម (Bosnian Muslims)ដែលបានសម្លាប់គ្នាទៅវិញទៅមក ដោយបាននិយាយកំប្លែងអាក្រក់អំពីបាតុភូតនេះ ៖

អ្នកចិត្តសាស្រ្តល្បីល្បាញឈ្មោះម្នាក់ បានទៅសួរសុខទុក្ខអ្នកជម្ងឺនៅមន្ទីរពេទ្យវិកលចរិត ជាមួយ នឹងកូនសិស្សរបស់គាត់។ គាត់ជ្រើសរើសយកកូនសិស្សម្នាក់អោយមកសម្ភាសន៍អ្នកជម្ងឺ ហើយអោយអ្នកឯទៀតចាំស្តាប់ការសម្ភាសន៍នោះ សិស្សបានសួរដោយសេចក្តីគោរពថា "ហេតុអ្វីបានជាអ្នកនៅមន្ទីរពេទ្យ"? អ្នកជម្ងឺឆ្លើយដោយស្ងប់ស្ងាត់ថា ព្រោះតែអ្នក។ ហ្នឹងហើយ អ្នកជា អ្នកសំរេចថាខ្ញុំឈឺចាប់សតិអារម្មណ៍ អ្នកនៅក្នុងមតិសម្លេងភាគច្រើន។ នៅខណៈដែលយើងជាអ្នកជម្ងឺក្លាយជាអ្នកមានមតិភាគច្រើនវិញខ្ញុំ នឹងមកមន្ទីរពេទ្យនេះ ដើម្បីសួរសុខទុក្ខអ្នកហើយសួរនូវសំណួរដូចគ្នានេះទៅអ្នកវិញ"។

អំពើឃោរឃៅរបស់ភាគីនីមួយៗ បានបង្អាក់ ឬក្លែងបន្លំសេចក្តីចងចាំដែលធ្វើអោយប៉ះពាល់ដល់កិត្តិយសដែលគេចង់បង្ហាញអំពីរូបគេ និងសង្គមរបស់គេ។ បទពិសោធន៍អាម៉ាស់មុខជាក្រុមក៏អាចជួយជំរុញអោយមានការចងចាំក្នុងសង្គម ដែលធ្វើអោយមានការសេងសឹកសំរាប់អ្នកឈ្នះ និងសេចក្តីសោកស្តាយសំរាប់អ្នកចាញ់។ សេចក្តីចងចាំរបស់ជនរងគ្រោះពុំអាចចាត់យកជាការដោយក្រុមមានអំណាចឡើយ បច្ចុប្បន្ននេះនៅក្នុងប្រទេសជាច្រើន ដូចជាប្រទេសស៊ូដាន(Sudan) និងសាធារណៈស៊ើប (Publice-Serb) រឿងតក់ស្លុត និងសុបិន្តរបស់ប្រជាពលរដ្ឋដែលរងគ្រោះ ពុំមានទទួលការដឹងឮ ឬយកមកអនុវត្តន៍ទុកជាសកម្មភាពដែលមានផលប្រយោជន៍ក្នុងសង្គមឡើយ។

ការបង្កើតសេចក្តីចងចាំទំនាក់ទំនងសង្គម ដែលចែកចាយគ្នាទៅវិញទៅមក ពេលខ្លះគេហៅថាការប្រមូលផ្តុំការចងចាំដែលអាចឃើញភាពជាក់ស្តែង នៅស្រេប្រីនីកា(Srebrenica) ក្នុងថ្ងៃនេះ មួយទសវត្ស

ក្រោយពីអំពីសម្លាប់រង្គាលមនុស្សប្រុស និងក្មេងប្រុសជនជាតិម៉ូស្លីមនៅក្នុង ឆ្នាំ១៩៩៥ ។ ទីក្រុង និងតំបន់ស្រេប្រីនីកា(Srebrenica)នៅក្នុងសាធារណៈរដ្ឋស៊ើប ពីដើមកំណើតមានជនជាតិបូស្សនានម៉ូស្លីម ចំនួន៨០ភាគរយ បច្ចុប្បន្ននេះ ស្ទើរតែ៨០ភាគរយ ជាជនជាតិបូស្សនានស៊ើប។ ជនជាតិបូស្សនានម៉ូស្លីមបានជម្លៀសខ្លួនចេញដើម្បីរស់នៅក្នុងពេលដែលគេបោសសំអាតពូជពង្សនោះ បានវិលត្រឡប់មកភូមិវិញបន្តិចម្តងៗ។ នៅពេលដែលខ្ញុំទៅស្រេប្រនីកាអាជ្ញាធរប្រចាំតំបន់ពុំអាច ឬពុំពិភាក្សាអំពីអំពើកំណាចឃោរឃៅដែលធ្វើឡើងប្រឆាំងទៅលើជនជាតិបូស្សនានម៉ូស្លីមជិតខាងឡើយ។ ពលរដ្ឋស៊ើបក្នុងមូលដ្ឋាន មួយចំនួន បានពិភាក្សាដោយបើកចំហរទៅលើរឿង ដែលគេហៅថា"ឧក្រិដ្ឋកម្ម"។ អ្នកខ្លះបដិសេធការពិតទៅលើអំពើសម្លាប់រង្គាលជនជាតិម៉ូស្លីមដែលបានកើតមានឡើងនៅក្នុងតំបន់ ទោះជាមានភស្តុតាង និងរកឃើញផ្នូរខ្មោចពាសវាលពាសកាលក៏ដោយ។ អ្នកខ្លះថ្កោលទោសប្រជាជនម៉ូស្លីមដែលរស់នៅក្នុងតំបន់ថា គេជាអ្នកបង្កើតភាពកំណាចឃោរឃៅនេះ អ្នកខ្លះអារកាត់សេចក្តីដោយនិយាយចោទថា ប្រជាជនម៉ូស្លីមដែលរស់នៅក្នុងតំបន់នេះបានរៀបគម្រោងការសម្លាប់ប្រជាជនស៊ើបដែលរស់នៅជិតខាង។ តែអំពើសម្លាប់រង្គាលនេះពុំមានកើតដល់ប្រជាជនស៊ើបមួយភាគធំដែលមានមុខងារ ផ្នែករដ្ឋកិបាលទាល់តែសោះ។

ផ្ទុយទៅវិញជនភៀសខ្លួនម៉ូស្លីមដែលបានវិលត្រឡប់មកភូមិជិតខាងរបស់គេវិញ ទៅជានិយាយបែបផ្សេងទៅវិញ។ នៅក្នុងឱកាសមួយ អ្នកភូមិពីរទៅបីនាក់ បានមកចូលរួមជាមួយអ្នករួមការងាររបស់ខ្ញុំជាជនជាតិបូស្សនាន ម៉ូស្លីម វេជ្ជបណ្ឌិត អាយដា កាពីតាណវិច(Aida Kapentanovic) និងរូបខ្ញុំ គឺស្ថិតនៅចំកណ្តាលភូមិ ដែលមានតែថ្មល់អត់ចិញ្ចើម កំទិចសំណង់អគារធ្លាក់ពាសពេញដី ផ្ទះបាក់បែកគ្រប់ទិស-ដើម្បីប្រាប់យើងអំពីការប្រឹងប្រែងដ៏លំបាករបស់គេសព្វថ្ងៃ ក្នុងការព្យាយាមបង្កើតជីវិតរបស់គេឡើងវិញនៅស្រេប្រីនីកា(Srebrenica)។ បន្តិចក្រោយមកប្រជាពលរដ្ឋទាំងប្រុសទាំងស្រី និងកូនក្មេងបានប្រមូលគ្នាមកជួបជុំ ហើយចង់អធិប្បាយអំពីរឿងរបស់ខ្លួន។ នៅចុងបញ្ចប់នៃការពិភាក្សានេះ បុរសវ័យចំណាស់ម្នាក់ចង្អុលទៅស្ត្រីចំណាស់ពីរនាក់ ខ្សឹបប្រាប់យើង ថ្វីបើអ្នកជុំវិញយើងស្តាប់ឮក៏ដោយ គាត់បាននិយាយស្ត្រីទាំងនេះបាត់បង់ប្តី និងកូនប្រុសរបស់គេនៅក្នុងឱកាសសម្លាប់រង្គាល។ គ្មាននរណាម្នាក់ដឹងពិតប្រាកដទៅលើហេតុការណ៍កើតឡើងដល់ពួកប្រុសៗ ដែលនៅក្នុងចំណោមអ្នកបាត់ខ្លួននោះឡើយ ប្រហែលជាអ្នកទាំងនោះកប់នៅក្នុងគំនរផ្នូរសពដែលគេរកមិនទាន់ឃើញ។ អាយដា(Ida) និងរូបខ្ញុំ បានសួរគេដោយប្រុងប្រយ័ត្នបំផុតថា តើគេធ្វើយ៉ាងដូចម្តេចដើម្បីនឹងតស៊ូដោះស្រាយ នឹងការបាត់បង់របស់គេ។ ដោយភាពស្ងប់ស្ងាត់គេបានថ្លែងថាគេរង់ចាំតែថ្ងៃស្លាប់ ដោយគេមានអារម្មណ៍ថាគ្មានអ្វីទៀតនៅសល់សម្រាប់ខ្លួនគេទៀតឡើយ។

ផ្ទុយនឹងការថ្លែងរបស់អាជ្ញាធរស៊ើបៀន(Serbian) ផ្នែកនយោបាយ និងផ្នែករដ្ឋាភិបាលដែលបានអះអាងថា គ្មានអំពើសម្លាប់រង្គាលកើតមានឡើង នៅស្រេប្រីនីកា(Serbrinica) នោះទេ ភាពពិតនៃហេតុការណ៍នេះបានលេចចេញឡើងនៅក្នុងការសម្ភាសន៍របស់យើង។ សុបិន្ត និងសុបិន្តអាក្រក់ចាប់ផ្តើមនិយាយឡើងនៅ

ក្នុងសន្ទនារបស់យើង ដូចបានរាយការណ៍ឡើងដោយអឺមីណា(Ermina)ដែលប្រាប់យើងថាប្តី និងកូនប្រុសរបស់នាងដែលស្លាប់ទៅហើយនោះ បានមកលេងជាមួយនិងនាង។

បទពិសោធន៍របស់យើងនៅ Serbrinica បានបញ្ជាក់ថា សង្គមត្រូវការបង្កើតយន្តការ-តាមរយៈការប្រជុំសាធារណៈការពិភាក្សានៅក្នុងសាលារៀន និងការជួបជុំគ្នាផ្សេងៗទៀត-សម្រាប់អោយប្រជាជននិយាយចែកចាយរឿងតក់ស្លុតដែលទាក់ទងសុបិន្ត និងសុបិន្តអាក្រក់ ។ ប្រជាជនទាំងមូលនៅស្រេប្រីនីកា (Serbrinica) បានគិត និងស្រម៉ៃការរង់ចាំព្រឹត្តិការណ៍ទាំងនេះ ថ្វីបើគេត្រូវបិទមាត់ខ្លួនគេ ឬទទួលការបញ្ជាក់បន្ថែមពីអាជ្ញាធរស៊ើប(Serbs)។ ពេលនេះមានតែបុព្វជិត (ជនប្រកបអាជីវកម្ម ផ្នែកសាសនា)សមាជិកគ្រួសារ និងបុគ្គលិកផ្នែកសិទ្ធិមនុស្សដែលអាចពាំនាំព័ត៌មានសំខាន់ៗ ទាំងនេះចេញចូលបានជាទៀងទាត់។ ផ្នែកផ្សព្វផ្សាយព័ត៌មានគួរបំពេញតួនាទីដ៏សំខាន់ ដោយគាំទ្រការផ្សព្វផ្សាយរវាងស៊ើប(Serbs) និងបូស្សនាន(Bosnian) ដោយចែកចាយការផ្សព្វផ្សាយលម្អិតជាឯកសារតាមរយៈទូរទស្សន៍ និងរឿងតាមកាសែត អំពីប្រវត្តិរឿងតក់ស្លុតរបស់ប្រជាជនគេជាជាងផ្សព្វផ្សាយ ការចោទប្រកាន់ដោយសង្វេគមិនឈប់ឈរ និងការបដិសេធថាព្រឹត្តិការណ៍នេះពុំមានកើតឡើងនោះទេ។

ស្ថានភាពនៅស្រេប្រីនីកា(Serbrinica)មានភាពប្រៀបដូចគ្នា និងរឿងតក់ស្លុតគ្មាននរណាដឹងឮ និងសុបិន្តផ្សេងៗរបស់អ្នករួចផុតពីសេចក្តីស្លាប់ជនជាតិអាមេរិកកាំងជំនាន់ដើម ដែលត្រូវគេជម្រុះបំបាត់ពូជពីទឹកដីកុលសម្ព័ន្ធរបស់គេនៅក្នុងសតវត្សទីដប់ប្រាំបួន។ បានរាយការណ៍ឡើងដោយជនរាតត្បាតមានសេចក្តីដូចនេះ ៖ ប្រជាជនអាមេរិកកាំងដែលទើបតែមកដល់ថ្មីៗ គ្មានអំណត់អត់ធ្មត់ គ្មានរបៀបរៀបរយ និងឈ្លានពាន(ចូលចិត្តបង្ករឿង)ពុំចេះរស់នៅជាមួយ និងជនជាតិអាមេរិកកាំង។ គេនាំគ្នាពពាក់ពពូនឆ្ពោះទៅទិសខាងលិច បំផ្លិចបំផ្លាញព្រះធរណី។ ជត ប៊ែន(George Bent) ជាកូនប្រុសកាត់របស់ពាណិជ្ជករ វិលីយ៉ឹម ប៊ែន (William Bent) បានលើកមកនិយាយអំពីរថភ្លើងដែលមានប្រវែងរាប់ម៉ាយ ទូររថភ្លើងធំៗគ្របដំបូលក្រណាត់ស មានរូបរាងដូចសំពៅនៅលើផ្ទៃសមុទ្រ។ ជនជាតិអាមេរិកកាំង ដែលមើលឃើញរថភ្លើងបើកបរឆ្ពោះចូលមករៀងរាល់រដូវ-កាន់តែច្រើនឡើងៗ-គេអាចមើលឃើញលទ្ធផលទុកជាមុន។ ចំការកប្បាសដែលគេបានបោះជុំរំរស់នៅ រាប់ជំនាន់ជាយូរមកនោះចាប់ផ្តើមវិនាស ស្មៅដុះតាមជ្រលងភ្នំ ត្រូវសត្វពាហនៈស៊ីរាបស្មើដល់គល់។

នៅក្នុងឆ្នាំ១៨៤៩ ជាកំណត់ពេលវេលាសកម្មភាពប្រញាប់ប្រញ៉ាប់រកមាស ជម្ងឺអាសន្នរោគបានកើតមានឡើង។ ជនជាតិស៊ូ(Sioux) និងជនជាតិឆេយេន(Cheyennes) រស់នៅជិតពួកអនិតិជនចេញចូលបានទទួលរងគ្រោះ និងរោគនេះច្រើនជាងគេ ប៉ុន្តែ រោគនេះបានរីករាលដាលទៅទិសពាយ័ព្យ ដល់ជនជាតិប្លែគហ្វុត(Blackfoot)រហូតទៅដល់ទិសនិរតីចូលទៅក្នុងដែនដីរបស់ហ្គីអូវ៉ា(kiowa) និងកូម៉េនជី(Comanche) លោក Bent ទៅទស្សនាភូមិនេះ ឃើញតែទិដ្ឋភាពទទេស្អាតគ្មានមនុស្សរស់នៅឡើយនោះ គាត់បានឃើញតែជម្រករកក្រណាត់មានពាសពេញទៅដោយសពមនុស្ស។

នៅក្នុងរដូវក្តៅ ឆ្នាំ១៨៥៣ ពាណិជ្ជករម្នាក់ ដែលប្រកបមុខរបរជំនួយដោះដូរនេះជាយូរយារមកហើយ និងជាភ្នាក់ងារអេឌៀន ឈ្មោះ Thomas "ដៃ បាក់"(Fitpatrick) បានរួមដំណើរជាមួយ និងជនជាតិ (Cheyennes Arapahos និង Sioux)។ គាត់បានសរសេរថា៖ "គេអស់សង្ឃឹមទៅលើបញ្ហារកស្បៀងអាហារអស់រយៈពេលជាងកន្លះឆ្នាំមកនេះ គេពឹងផ្អែកទៅលើស្បៀងបន្តិចបន្តួច ដែលគេមាន ការបាត់សត្វក្របីកើនឡើងកាន់តែច្រើន ហើយនឹងវិនាសសាបសូន្យក្នុងពេលដ៏ឆាប់ៗ...ស្ត្រីវង់ទុក្ខដោយខ្លួនចង់បានស្បៀងអាហារ រួមទៅដោយសម្រែកទួញយំអត់ឈប់ឈរពីកូនរបស់គេដែលស្រេកឃ្លាន"។

ក្រៅពីសេចក្តីបានជួបប្រទះទាំងនេះ មានឯកសារខ្លះៗដែលនៅសេសសល់ពីភាពតក់ស្លុត ជាបទពិសោធន៍ផ្ទាល់ខ្លួនរបស់ជនជាតិអាមេរិកកាំងខ្លះៗ ដែលរួចផុតពីសេចក្តីស្លាប់។ ជនទាំងអស់ដែលទទួលភាពតក់ស្លុត ជាបន្តបន្ទាប់មក នឹងជួបប្រទះឧបសគ្គដោយខ្វះខាតប្រវត្តិរឿងផ្ទាល់ខ្លួន ការនិយាយចែកចាយរឿងតក់ស្លុត ពុំត្រឹមតែជាថាមពលជីវៈវិទ្យា ដើម្បីអោយរួចផុតពីភាពមហន្តរាយ បច្ចុប្បន្ននេះ តែប៉ុណ្ណោះទេ វាក៏ជាករណីមួយ ដែលយើងផ្តល់ដល់បុព្វបុរសយើង នូវឯកសារអំពីការតស៊ូទ្រាំទ្រ និងជំនះទៅលើអំពើសាហាវយង់ឃ្នងរបស់មនុស្សទៅលើមនុស្ស។ ជនជាតិអាមេរិកកាំង(Native Americans) ជនជាតិអាហ្វ្រិក–(African Americans) បូស្សនាន(Bosnians) ខ្មែរ វ៉ាន់ដា (Rwandans) និងប្រជាជនទទួលភាពតក់ស្លុតឯទៀត ត្រូវការដឹងអំពីប្រវត្តិដែលរួចផុតពីសេចក្តីស្លាប់របស់ជនជាតិខ្លួន។

ផលវិបាកអាក្រក់ នៃការពុំដឹងអំពីប្រវត្តិបានបង្ហាញឡើងនៅក្នុងសោកនាដកម្មសម្លាប់ជីដូន មិត្តរួមថ្នាក់ និងខ្លួនឯងរបស់យុវជនជាតិអាមេរិកកាំងដើម នៅលើទឹកដីរបស់អាមេរិកកាំង បឹងក្រហម (Red Lake) នៅក្នុងរដ្ឋមីនសូតា (Minesota) នៅក្នុងឆ្នាំ២០០៥ ។ ចាស់ៗដែលគាត់ដឹងអំពីពិធីបុណ្យរម្ងាប់អារម្មណ៍ជំនាន់ដើម កំពុងតែអស់សង្ឃឹម ដោយជំនាន់គាត់មានគ្នានៅសល់តែពីរទៅបីនាក់ ដែលអាចដោះស្រាយសោកនាដកម្មនេះបាន ដោយប្រើពិធីបុណ្យសាសនាត្រឹមត្រូវ។ រឿងតក់ស្លុត និងសុបិន្តរបស់ជនជាតិ(Chippewa) រួម និងមេរៀនដ៏សំខាន់បានបាត់បង់នៅក្នុងជំនាន់បច្ចុប្បន្ននេះ នៅពេលដែលអ្នកឈ្នះសង្គ្រាមត្រូវរដ្ឋាភិបាលអាមេរិក បញ្ជូនទៅសាលារៀប្រជាជន ដែលគេហាមឃាត់មិនអោយរៀនភាសារបស់ខ្លួនកេរ្តិ៍មរតកវប្បធម៌ និងប្រវត្តិរួចផុតពីសេចក្តីស្លាប់។ ការយល់ដឹងអំពីការតស៊ូរាប់ជំនាន់របស់ជាតិជីព័រ៉ា(Chippewa) ដែលអាចផ្តល់ជំនួយដ៏លើសលប់ដល់សហគមន៍បច្ចុប្បន្ន ពេលនេះមានកំរិតតិចតួចបំផុត។

សុបិន្តតក់ស្លុត និងសុបិន្តអាក្រក់ ត្រូវចាត់ទុកថាជា ផ្នែកចាំបាច់នៃការនិយាយប្រាប់អំពីបទពិសោធន៍ផ្ទាល់ខ្លួនជួបជុំគ្នា សង្គមត្រូវអោយតម្លៃដល់រឿងរ៉ាវទាំងនេះ និងបង្កើតឱកាស ដើម្បីពិភាក្សាជាសាធារណៈ។ ប្រជាជនភាគច្រើន ប្រុងតែចូលរួមនៅក្នុងបទពិសោធន៍ទាំងនេះ ចាប់តាំងពីការនិយាយរឿងសុបិន្តរួមគ្នាកើតមានឡើង មិនត្រឹមតែមាននៅក្នុងចំណោមមនុស្សពេញវ័យទេ តែវាក៏មាននៅក្នុងចំណោមក្មេងផងដែរ។ លោករ៉ុន បាឡាមុត (Ron Balamuth) អ្នកវិភាគប្រវត្តិសាស្ត្រ បានយកចិត្តទុកដាក់ទៅលើ ការហាត់និយាយរឿងសុបិន្តនៅក្នុងចំណោមក្មេង គាត់បានរកឃើញថាក្មេងថ្នាក់មត្តេយ្យដ្ឋានដែលមានអាយុតិចត្រឹម ៥ឆ្នាំ ចូលចិត្តនិយាយ

រឿងរួមគ្នា ដែលទាក់ទង និងសុបិន្តទៅវិញទៅមក និងចូលចិត្តនិយាយប្រាប់គ្រូបង្រៀនរបស់វា បើសិនជាផ្តល់ឱកាសអោយវានិយាយ។ មនុស្សពេញវ័យគ្រប់វប្បធម៌ និងពូជសាសន៍ទាំងអស់ធាប់ចូលរួមនៅក្នុងក្រុមនិយាយរឿងសុបិន្តជុំគ្នានៅខណៈដែលគេដឹងថាគេឈប់គិតពីសេចក្តីភ័យខ្លាចថាសុបិន្តរបស់គេ នឹងទទួលការចំអក ឬមិនយកចិត្តទុកដាក់នោះ ជនដែលចូលរួមនិយាយចូលរួមនៅក្នុងការនិយាយរឿងជុំគ្នាអំពីសុបិន្ត និងសុបិន្តអាក្រក់ឃើញថាវាជាករណីផ្តោះផ្តង់គ្នាដ៏រំភើប និងរីករាយ។

ភាពខ្វះខាតចំនួលចិត្តជាសាធារណៈ និងការនិទានរឿងតក់ស្លុតផ្ទាល់ខ្លួននៅក្នុងសហគមន៍ អាចជាករណីហួសប្រមាណនៅស្រេប្រីនីកា(Srebrenica) ដែលជាការពិបាកយល់ ថាតើត្រូវចាប់ផ្តើមដោះស្រាយបញ្ហានោះដោយវិធីណា។ ជំហ៊ានមួយដ៏ចាំបាច់ គឺប្រមូល និងចង់ក្រងទុកជាឯកសារ នូវប្រវត្តិផ្ទាល់មាត់ និងសុបិន្ត ទាំងអស់របស់ជនភៀសខ្លួន និងប្រជាជនស៊ីវិលដែលបានទទួលវិបត្តិតក់ស្លុត។ បើមិនដូចនេះទេ ប្រវត្តិរឿងរ៉ាវដ៏មានតម្លៃ នឹងបាត់បង់ ដែលជាសីលធម៌សម្រាប់មនុស្សជំនាន់ថ្មី នាពេលអនាគតកាល។ ឯកសារបទពិសោធន៍របស់មនុស្ស ពុំត្រូវរក្សាទុកសម្រាប់ជាធន្ទះផ្នែកនយោបាយរបស់រដ្ឋាភិបានឡើយ តែត្រូវរក្សាទុកជាអាទិភាពស្វ័យប្រវត្តិរបស់អង្គការសហប្រជាជាតិ ដូចជា ដែលមានអង្គការសហប្រជាជាតិ ផ្នែកវិស័យអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ដែលហៅថាអង្គកាយ៉ូណេស្កូ (UNESCO) ឬនៅសហរដ្ឋអាមេរិក វិទ្យាស្ថាន(Smithsonian)។

ឧទាហរណ៍ ពីរទៅបីថ្ងៃបន្ទាប់ ពីការវិនាសមហន្តរាយនៅនីវអេឡិន(New Orlean) ដោយព្យុះសង្ឃរាកាទ្រីណា(Katrina) នៅខែ សីហា ឆ្នាំ២០០៥ អ្នកវិទ្យាសាស្ត្រប្រចាំតំបន់បានចាប់ផ្តើមប្រមូលរឿងរបស់អ្នករួចផុតពីសេចក្តីស្លាប់ ពីប្រជាជនរាប់រយនាក់ គ្រប់ចំណាត់ថ្នាក់សំរាប់រក្សាទុក ជាឯកសារមួយនៅបណ្ណាល័យសាធារណៈរដ្ឋនានាទូទាំងទីក្រុង។ ប្រជាជននីវអេឡីន(New Orlean) បានទទួលការស្នើសុំអោយផ្តល់ការអធិប្បាយអំពីបទពិសោធន៍តក់ស្លុតរបស់គេ នូវគ្រាដែលទិដ្ឋភាពព្យុះសង្ឃរា នៅជក់ជាប់នៅក្នុងអារម្មណ៍គេថ្មីៗ។ ភាពវិនាសអន្តរាយដែលបណ្តាលអោយកើតឡើងដោយព្យុះសង្ឃរាកាទ្រីយា(Katriya) ជាតំណាងភាពមអន្តរាយដ៏ធំក្រៃលែង ដែលប៉ះពាល់ដល់សហរដ្ឋអាមេរិកដោយពិតប្រាកដ អ្នកចង់ក្រងឯកសារនៅនីវអេកឡីន(New Orlean)ផ្តល់នូវគំរូល្អដល់អ្នកឯទៀត ដើម្បីយកទៅអនុវត្តន៍ នៅផ្នែកនានាក្នុងពិភពលោក ដែលទទួលការឈឺចាប់ដោយអំពើសាហាវយង់ឃ្នង ឬភាពមហន្តរាយធម្មជាតិ។

ការខ្វះខាតចំនួលចិត្តទៅលើរឿងនិទានភាពតក់ស្លុត និងសុបិន្តរបស់អ្នកព្យាបាលសុខភាព និងសតិអារម្មណ៍ បានបណ្តាលអោយបាត់បង់ការយល់ដឹងទៅលើការព្យាបាល និងភាពប៉ិនប្រសប់ដ៏មានតំលៃ។ នៅក្នុងឆ្នាំ២០០៤ ការនិយាយរឿងសុបិន្តរួមគ្នាបានចាប់ផ្តើមនៅក្នុងថ្នាក់រៀនជំនាញរបស់លោក ភីតទ័រអាល់ដ័រម៉េន (Peter Alderman) នៅក្នុងចំណោមអ្នកវិជ្ជាជីវៈ ផ្នែកវេជ្ជសាស្ត្រពីប្រទេសអាប់ហ្គានីស្ថាន(Afghanistan) អ៊ីរ៉ាក់(Iraq) ឆីលី(Chile) កម្ពុជា(Cambodia) យូហ្គានើដា(Uganda) វ៉ាន់ដាន(Rwandan) បូស្សនា(Bosnia) សាធារណៈស្ពាកា(Republic Spaska)ស្ពេន(Spain) អីតាលី(Italy) និងសហរដ្ឋអាមេរិក(Unite state)។ គោលការណ៍ នៃការហាត់ហ្វឹកហ្វឺននេះ ដឹកនាំដោយអ្នកវិភាគចិត្តសាស្ត្រអ៊ីតាលី លោក ហ្វ្រង់កូប៉ាប៉ារូ(Franco

Paparo)ដែលប្រើសុបិន្តរបស់ក្រុមនេះ ដើម្បីបង្កើតបណ្តាញជំនួយបច្ចេកទេស និងសតិអារម្មណ៍អន្តរជាតិ។ រៀងរាល់ថ្ងៃអ្នកចូលរួមនិយាយសារឡើងវិញអំពីរឿងសុបិន្តហើយពិភាក្សាគ្នាអំពីទំនាក់ទំនង និងបេសកម្មនៃថ្នាក់ជំនាញនេះ។

សុបិន្តសំខាន់ដែលលេចចេញឡើងនៅក្នុងចំណោមសមាជិក គឺមានភាពភ័យខ្លាច ថាគ្មានគេគាំទ្រ និងភាពឯកឯង បែកចេញពីអ្នកឯទៀតអ្នករួមការងារ និងអ្នកជម្ងឺរបស់គេ។ អ្នកចិត្តសាស្រ្តមួយរូបមកពីទីក្រុង ម៉ាឌ្រីដ (Madrid) ដែលនៅពេលនោះគាត់បានព្យាបាលអ្នករងរបួស ដោយភាពវៈកម្មផ្ទុះមីននៅលើផ្លូវថភ្លើង នៅក្នុងខែ មេសា ឆ្នាំ២០០៤ នៅទីក្រុង (Madrid) បាននិយាយរឿងសុបិន្តដ៏អស្ចារ្យ។

ទិដ្ឋភាពជីវិតជាលើកដំបូងរបស់ខ្ញុំ គឺនៅពេលដែលខ្ញុំនៅជាមួយ និងមិត្តម្នាក់កាលពីកុមារភាព ដែលខ្ញុំចងចាំហើយស្រលាញ់ចូលចិត្តភាពថ្លៃថ្នូរបស់គេ។ យើងនាំគ្នាដើរនៅលើដងផ្លូវតូចមួយនៅចន្លោះជ្រោះ និងភ្នំដែលមានដើមឈើដុះពាសពេញ។ យើងដើរដោយស្ងៀមស្ងាត់ហើយភាពរីករាយ និងវត្តមានរបស់គ្នាទៅវិញទៅមកយើងលឺសូរគេកាត់ដើមឈើ (យើងមើលគេពុំឃើញទេ) មួយរំពេចនោះស្រាប់តែតួដើមឈើមួយរលំប៉ះចំក្បាលមិត្តខ្ញុំហើយនាងក៏ធ្លាក់ទៅក្នុងជ្រោះបាត់ទៅ។ ទិដ្ឋភាពជីវិតលើកទីពីរ គឺនៅពេលដែលខ្ញុំអង្គុយនៅតុមួយជាមួយ នឹងទូរស័ព្ទ ខ្ញុំកំពុងតែយំដោយខ្ញុំត្រូវនិយាយទៅកាន់ក្រុមគ្រួសារមិត្តខ្ញុំ ដើម្បីប្រាប់គេពីរឿងហេតុដែលបានកើតឡើងតែខ្ញុំនិយាយមិនចេញ។ បន្ទាប់មកខ្ញុំឃើញមីវលីន(Mevlin) និងយ៉ូស្សេវ(Yosef) {វេជ្ជបណ្ឌិតនៅក្នុង ក្រុមនៅប្រទេសបូស្សនា និងមកពីប្រទេសអ៊ីរ៉ាក់ទៅតាមលំដាប់លំដោយ} គេបានមករកខ្ញុំឃើញហើយជំរុញអោយខ្ញុំនិយាយប្រាប់ក្រុមគ្រួសាររបស់មិត្តខ្ញុំ នៅត្រង់ចំនុចនេះខ្ញុំភ្ញាក់ដឹងខ្លួន។

ក្រុមនោះបានទទួលយល់ដឹង នៃអារម្មណ៍ទៅលើបញ្ហាដែលបានបង្ហាញឡើងនៅក្នុងសុបិន្តនេះ ដូចលោក ម៉ារ បាននិយាយថា "នៅពេលដែលជនម្នាក់ឈឺចាប់ដោយអំពើសាហាវយ៉ង់ឃ្នង [មិត្តពីកុមារភាព] វាធ្វើអោយចិត្តរបស់គេខ្ទេចខ្ទាំដែលបង្កើតនូវរបួសគ្មានជម្រៅ។ វាធ្វើអោយជីវិតរបស់គេគ្មានគោលដៅ [ដើមឈើគ្មានឬស] នៅក្នុងឆាកទីពីរនៃសុបិន្ត នៅពេលដែលនាងពុំអាចរៀបរាប់បប្រាប់ក្រុមគ្រួសារមិត្តនាង អំពីការបាត់បង់កូនស្រីរបស់គេ នាងយំដោយនាងគ្មានសមត្ថភាពនិយាយអំពីទុក្ខសោកឥតឧបមាទៅលើការបាត់បង់មិត្តរបស់នាង។ ក្រុមនោះបាននិយាយឡើងថា ទឹកភ្នែកគ្មានដំណក់នេះគេក៏បានចូលរួមសម្រក់ទឹកភ្នែកនេះដែរ នៅពេលដែលគេបាន ឮរឿងតក់ស្លុតអ្នកជំងឺរបស់គេ។ គេមានអារម្មណ៍ថាប្រហែលជារូបគេបំពេញភារកិច្ច រិតតែមានប្រសិទ្ធិភាពឡើងទៀតក្នុងការនិយាយប្រាប់ និងសម្រាលសេចក្តីឈឺចាប់អ្នកជំងឺរបស់គេ បើថ្នាក់រៀនជំនាញផ្តល់ជំនួយដល់គេផងដែរ។

សុបិន្តក៏បញ្ចប់ ដោយសេចក្តីសង្ឃឹមដោយសមាជិក ទាំង២ក្រុមមីវលីន(Mevlin) និងយ៉ូសៀវ(Yosef) បានជួយម៉ារ(Mar) គេបានលួងលោមអារម្មណ៍នាង និងជម្រុញនាងអោយនិយាយជាមួយ និងក្រុមគ្រួសារមិត្តរបស់នាង។ យោងតាម Mar សុបិន្តរបស់នាងបានបរិយាយឡើងថាសុបិន្តរបស់នាងបានបរិយាយឡើងថា ក្រុមនេះ ហើយប្រឈម នឹងឧបសគ្គជាច្រើននៅពេលដែលគេចូលទៅក្នុងជីវិតរបស់អ្នកជម្ងឺដែលត្រូវបានគេបំពារ

បំពាន សមាជិកទាំងនេះត្រូវតែមានចិត្តក្លាហានប្រឈមមុខ និងសេចក្តីការគំរាមកំហែងដែលធ្វើអោយប្រជាជនស្លូតត្រង់ឈឺចាប់។ តែសុបិន្តក៏ជាសេចក្តីសង្ឃឹមដែរ តាមរយៈនិយាយប្រាប់អំពីសេចក្តីភ័យខ្លាច និងបញ្ហាជាក្រុមដែលអាចធ្វើអោយគេបំភ្លេចសេចក្តីគំរាមកំហែងទាំងនេះ។

## កថាខណ្ឌ ១. ការតន្ទាប់ពិតពខាងក្នុង និងខាងក្រៅ

សុបិន្តរបស់ជនទទួលភាពតក់ស្លុតមានសារៈសំខាន់ សំរាប់ផ្នែកជីវសាស្ត្រ ចិត្តសាស្ត្រ និងព្រឹត្តការណ៍សង្គម។ ពុំមានអ្វីគួរអោយភ្ញាក់ផ្អើលទេ នៅពេលដែលមនុស្សលោក បានចំណាយពេលច្រើនទទួលទានដំណេក ហើយបានបង្កើតនូវវិធីដោះស្រាយបញ្ហាអត់ខ្ចោះ រវាងការភ្ញាក់ដឹងខ្លួន និងការលង់លក់ពីដំណេក។ នៅពេលស្ថានភាពគ្រោះថ្នាក់កើតមានឡើង សុបិន្តលេចចេញឡើងជាស្រេច ដើម្បីជួយអោយយើងរួចផុតពីគ្រោះថ្នាក់ ដោយទប់ស្កាត់មិនអោយខូចខាតដល់រាង្គកាយ និងអារម្មណ៍ធ្ងន់ធ្ងរ។ ការយល់ដឹងអំពីតម្លៃការព្យាបាលសុបិន្តមានកម្រិតគ្រប់គ្រាន់នៅឡើយ ដែលគេត្រូវដាក់បញ្ចូល ទៅក្នុងការព្យាបាលបន្ទាប់ពីភាពតក់ស្លុត។ រឿងរ៉ាវ និងអារម្មណ៍ដែលទាក់ទងទាំងនេះពុំត្រូវបដិសេធ ឬបំភ្លេចចោលឡើយ។

ភាពពិតបានបង្ហាញឡើងថាសុបិន្តដែលកើតមានឡើង ដោយរឿងតក់ស្លុត អាចធ្វើអោយមានគ្រោះថ្នាក់បើសិនជាទុកយូរ។ វាដូចជា ការប្រៀបធៀបទៅ និងម៉ាសកំដៅដែលព្យាយាមធ្វើអោយផ្ទះក្តៅ តែដោយម៉ាសនេះខូច ហើយពុំអាចបិទបានយូរៗ ទៅវាលែងប្រើការកើត ។ ដូចគ្នា និងសុបិន្តដែលអាចក្លាយទៅជាសុបិន្តអាក្រក់ ហើយអាចញាំញីជនតក់ស្លុតជាច្រើនឆ្នាំ ដោយធ្វើអោយទទួលទានដំណេកពុំបានជាច្រើនឆ្នាំ ភាពទន់ខ្សោយ និងបញ្ហាសុខភាពរ៉ាំរ៉ៃផ្សេងៗទៀត។ សុបិន្តអាក្រក់ ជាពិសេសសុបិន្តអាក្រក់ផ្ទួនៗ ត្រូវបំបាត់ចោលនៅពេលដែលការព្យាបាលបានបញ្ចប់ ជាសំណាងល្អដោយយើងមានបច្ចេកទេសសាមញ្ញ និងតម្លៃថោកដែលជាវិធីបំបាត់សុបិន្តអាក្រក់ភាពតក់ស្លុត ដែលមានប្រសិទ្ធិភាពដោយពុំបាច់ប្រើថ្នាំពេទ្យឡើយ។ ការយល់ដឹងនិងការហ្វឹកហ្វឺនប្រើបច្ចេកទេសទាំងនេះ ត្រូវផ្សព្វផ្សាយទៅជនជួបប្រទះភាពតក់ស្លុត និងអ្នកដែលជួយគេ។ ជនដែលទទួលបទពិសោធន៍ដោយអំពើហឹង្សាក្នុងគ្រួសារ ឬអំពើរំលោភបំពានផ្លូវភេទ ឬអំពើឧក្រិដ្ឋកម្មណាមួយ គួរទទួលរងគ្រោះដោយសុបិន្តអាក្រក់ ឬសុបិន្តអាក្រក់ផ្ទួនៗឡើយ។

ការរកឃើញទំនាក់ទំនងក្នុងសង្គមរបស់សុបិន្ត និងការចូលរួមចំណែកដែលអាចកើតមានក្នុងសង្គមជាការតភ្ជាប់នៃភាពដែលអាចកើតមានឡើង ដែលអោយមានការផ្តល់ភាពតភ្ជាប់គ្នារវាងសង្គម និងជីវិតផ្ទៃក្នុងរបស់ជនជួបប្រទះភាពតក់ស្លុត និងពិភពនៅក្នុងសង្គមរបស់គេ។ បើសិនជាមនុស្សមួយចំនួនធំ ផ្តល់យោបល់អំពីសុបិន្តរបស់គេ ទៅក្នុងការពិភាក្សាជាសាធារណៈជាក្រុម ដូចជានៅបូស្សនា តំបន់អាស៊ីដែលរងគ្រោះដោយរញ្ជួយទឹកសមុទ្រ (Tsunami) នៅក្នុងឆ្នាំ២០០៤ និងព្យុះមហន្តរាយ នៅតំបន់អាមេរិកខាងត្បូង (South America) ប្រសិទ្ធិភាពល្អក្នុងសង្គមពិត ជាផលប្រយោជន៍ដ៏ប្រសើរ។ ការពិសោធន៍សុបិន្តរួមគ្នាបែបនេះពុំដែលព្យាយាមធ្វើឡើងក្នុងលក្ខណៈទ្រង់ទ្រាយធំនោះទេ ទោះជាវាបានធ្វើឡើងដល់មនុស្សរាប់រយនាក់ នៅអ៊ីតាលី និងអ៊ឺរ៉ុបខាង

លិច ដែលបានស្នើសុំប្រធានបទបង្រួបបង្រួមគ្នានៅអ៊ឺរ៉ុបក៏ដោយ។ សុបិន្តរួមគ្នាក្នុងសង្គមមានទំនាក់ទំនងដ៏សំខាន់ៗសម្រាប់សហគមន៍ ដែលទទួលភាពរងគ្រោះដោយភាពតក់ស្លុតដោយជម្លោះ ផ្នែកជាតិសាសន៍ និងផ្នែកនយោបាយ ក៏ដូចគ្នា នឹងជនដែលរងគ្រោះដោយអំពើឧក្រិដ្ឋកម្ម និងវិបត្តិសេដ្ឋកិច្ចដែរ។ កត្តាពិត នៃចិត្តសាស្ត្រជំនឿ របស់ជនជួបប្រទះភាពតក់ស្លុតដែលរង់ទុក្ខដោយសុបិន្ត បានបង្ហាញយ៉ាងច្បាស់លាស់នូវពិភពផ្ទៃក្នុង នៃការព្យាយាមរកអត្ថន័យរឿងទាំងមូល ភាពធម្មតា និងសុខភាព។ ផលប្រយោជន៍ប្រតិបត្តិការរួមគ្នា ដូចជាសប្បុរសធម៌ ប្រកបការងារ និងចិត្តនិយម ជាករណីពង្រឹងភាពវិវឌ្ឍន៍ទៅលើការយល់សុបិន្តមួយកំរិតថែមទៀតនៃការព្យាបាលដោយខ្លួនឯង ដែលជាការចូលរួមដ៏សកម្មក្នុងសង្គមពិភពលោក។ ការលាត្រដាងពិភពផ្ទៃក្នុង នៃសុបិន្តទៅក្នុងសកម្មភាពសង្គមផ្សេងៗ នៃពិភពខាងក្រៅ មានផលប្រយោជន៍ដល់សតិអារម្មណ៍ និងរាង្គកាយ។ បទពិសោធន៍ផ្ទៃក្នុងរបស់ជនជួបប្រទះភាពតក់ស្លុត និងអាកប្បកិរិយាសង្គមរបស់គេ ទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាមួយ និងបាតុភូតភាពព្យាបាលដោយខ្លួនឯង។

# ជំពូកទី៧ មធ្យោបាយសង្គមនៃការព្យាបាល

ការព្យាបាលចាប់ផ្តើមឡើងដោយជម្រើស អ្នករួចផុតពីសេចក្តីស្លាប់ដោយអំពើមហាសាហាវយង់ឃ្នងត្រូវធ្វើការសម្រេច*ជ្រើសរើសជីវិតណាមួយ ដើម្បីរស់នៅលើជីវិតអតីតកាលដ៏សោកសៅ ឬជាជីវិតថ្មីមួយ*។ ពីមួយថ្ងៃទៅមួយថ្ងៃ មួយម៉ោងទៅមួយម៉ោង អំពើសាហាវយង់ឃ្នង បានធ្វើអោយមនុស្សប្រឈមមុខដោយប្រើបទពិសោធន៍ភាពតក់ស្លុតរបស់ខ្លួន ដើម្បីកសាងជីវិតថ្មី និងផ្តោតអារម្មណ៍ទៅលើបច្ចុប្បន្នកាល ជាជាងអតីតកាល។ លោក ភល់ស៊ីហ្សានី (Paul Cezanne) ជាវិចិត្រករក្រោយសម័យ(Impressionist) ជនជាតិបារាំង បានដកស្រង់ចំនុចសំខាន់ៗអំពីទីនេះ និងបច្ចុប្បន្ន នៅពេលដែលគាត់ផ្តល់ឱវាទដល់វិចិត្រករ ៖

ក្នុងបច្ចុប្បន្ននេះ ឱកាសកំណត់ពេលវេលាកំពុងតែរត់លឿនទៅ! ត្រូវដកស្រង់ភាពពិតនេះតាមបែបគំនូរ! ដើម្បី នឹងសម្រេចកិច្ចការនេះ យើងត្រូវតែដកយកអ្វីៗទាំងអស់ចេញពីអារម្មណ៍របស់យើង។ យើងត្រូវដាក់ខ្លួនយើងទៅជាឱកាសនោះ ដាក់ខ្លួនយើងជាម៉ាស៊ីនថតពោរពេញដោយអារម្មណ៍... ផ្តល់រូបភាពអំពីអ្វីៗដែលយើងពិតជាឃើញ បំភ្លេចចោលនូវអ្វីៗ ដែលបានកើតមានឡើងមុនជំនាន់របស់យើង។

សម្តីដកស្រង់នេះក៏ជាឱវាទត្រឹមត្រូវសម្រាប់ជនរួចផុតពីសេចក្តីស្លាប់ ដោយវិធីព្យាបាល មានរូបរាងជាជំនាញសិល្បៈ។ តាមរយៈបទពិសោធន៍ ជនជួបប្រទះភាពតក់ស្លុតដែលរួចផុតពីសេចក្តីស្លាប់ទាំងនេះ ពិតជាពុំចង់ធ្វើជាងថត " ម៉ាស៊ីនថតពោរពេញដោយអារម្មណ៍ " សោះឡើយ។ ភាពតក់ស្លុតទាំងនោះបានចារជិតជាប់នៅក្នុងអារម្មណ៍របស់គេ ហើយទិដ្ឋភាពទាំងនោះអាចមានកម្រិតលើសលប់ពន់ពេកដល់រូបគេ។ តាមជម្រៅសេចក្តីឈឺចាប់របស់គេ អ្នករួចផុតពីសេចក្តីស្លាប់ ពុំអាចមើលឃើញថា រូបគេនៅមានជម្រើសទៅលើការរស់នៅរបស់ខ្លួន។ គេអាចឃុំខ្លួនគេនៅក្នុងពិភពពោរពេញទៅដោយទិដ្ឋភាពមហាអាក្រក់ដែលពុំអាចទ្រាំទ្របាន ឬគេអាចបង្កើតអ្វីៗ ដែលថ្មីស្រឡាងសម្រាប់ជីវិតរបស់គេ ដែលជាប្រភពកម្លាំង និងសារៈសំខាន់ក្នុងជីវិត។

សេចក្តីសង្កេតមើលរបស់លោក សេហ្សាននេ(Cezanne) ពុំមានការពន្យល់អំពីវិធីដែលវិចិត្រករអាចធ្វើការបំភ្លេចបាន "អ្វីទាំងអស់ដែលកើតមានឡើងមុនជំនាន់យើង"។ ចំពោះអ្នករួចផុតពីសេចក្តីស្លាប់ វិធីនេះចាប់ផ្តើមឡើងដោយសេចក្តីសម្រេចដែលតម្រូវអោយមានសេចក្តីក្លាហ៊ានដ៏លើសលប់។ នៅក្នុងពិភពសម័យរបស់យើង ពាក្យក្លាហ៊ាននាំមកនូវទិដ្ឋភាពខ្លាំងក្លា អំពើបំពានដែលបង្ហាញនូវស្ថានភាពការគំរាមកំហែងដល់ជីវិត។ តែសេចក្តី*ក្លាហ៊ាន* តម្រូវអោយមានជាបន្តទៀត ក្រោយពីរឿងរ៉ាវមហាអាក្រក់បានប្រែប្រួលអស់ទៅៈ វាជាឥរិយាបថសតិអារម្មណ៍ ជាទូទៅអាចមើលឃើញដោយអ្នកផ្សេងទៀត។

មនុស្សដែលទទួលបទពិសោធន៍មហាសាហាវយង់ឃ្នងដោយអំពើរំលោភផ្លូវភេទ ការវាយតបធ្វើបាប ឬការសម្លាប់ឳពុកម្តាយ ឬកូន ជាញឹកញាប់ត្រូវធ្វើការសម្រេច ពុំត្រឹមត្រូវជាជម្រើសយកវិធីរស់នៅទៅតាមបែបណាមួយនោះទេ តែគេត្រូវសម្រេចថាគេត្រូវតែរស់នៅជាបន្តទៀត ឬយ៉ាងណានោះ។ ជីវិតតក់ស្លុតសាមញ្ញ

ទោះបីជាពុំខ្លាំងក្លាក៏ដោយ អាចមានរួមទៅដោយជម្រើសនេះផងដែរ ត្រូវតែមានសេចក្តីក្លាហ៊ានដើម្បីទប់ស្កាត់កុំអោយឈានចូលដល់សេចក្តីអស់សង្ឃឹម។ ផ្ទុយនឹងសេចក្តីអស់សង្ឃឹម គឺសេចក្តីសង្ឃឹម ហើយ ដើម្បីសង្ឃឹម គឺត្រូវតែមានសេចក្តីស្រម៉ៃ និងមានចំណង់ចិត្តជាថ្មីទៅលើអ្វីៗទាំងអស់ក្នុងជីវិតដែលបានស្រលាញ់ទុកក្នុងចិត្ត និងបានបំផ្លាញចោល។

អ្នករួចផុតពីសេចក្តីស្លាប់ និងអ្នកព្យាបាលរបស់គេជាញឹកញាប់ច្រើនតែយល់ថា មូលដ្ឋាននៃសេចក្តីសម្រេចទៅលើការរស់នៅ គឺធ្វើឡើងជារៀងរាល់ថ្ងៃ។ សេចក្តីសម្រេចបន្តដំណើរជីវិតត្រូវតែចាប់ផ្តើមធ្វើឡើង ហើយដំណើរការព្យាបាលត្រូវតែមានជាបន្តបន្ទាប់។ ភាពព្យាបាលដោយខ្លួនឯង ពុំអាចមានដំណើរការឡើង ហើយភាពជាសះស្បើយ ដូចគ្រាដើមវិញក៏ពុំអាចបញ្ចប់បានដែរ លើកលែងតែមានសេចក្តីអះអាងថាជីវិតរស់រវើកនៅតែមានជាបន្តបន្ទាប់។ តែអ្នកវិជ្ជាជីវៈ ផ្នែកសុខភាពពុំហ៊ានបើកចំហនិយាយរឿងនេះជាមួយ នឹងអ្នកដែលរួចផុតពីសេចក្តីស្លាប់ទេ ដោយមនុស្សជាច្រើន ពុំដឹងថាខ្លួនគេត្រូវធ្វើយ៉ាងណា នៅពេលដែលអ្នកជម្ងឺបញ្ចេញអារម្មណ៍អស់សង្ឃឹមហើយចង់ស្លាប់។ អ្នកព្យាបាលត្រូវតែប្រុងប្រយ័ត្ន ក្នុងការលង់ចិត្តទៅលើទុទិដ្ឋិនិយម(អស់សង្ឃឹម)របស់អ្នករួចផុតពីសេចក្តីស្លាប់ ដោយហេតុនេះ អ្នកព្យាបាលទៅជាមានចិត្តមន្ទិលសង្ស័យទៅលើសមត្ថភាពរបស់ខ្លួនគេក្នុងការជួយអ្នកជម្ងឺ។

នៅក្នុងឱកាសភាវនាដែលផ្តល់ឡើងដោយព្រះសង្ឃវៀតណាម ទិត ញាត់ ហាន (Thich Nhat Hanh) យុវជនក្មេងមួយរូប កាលពីបួនទសវត្សមុនបានតស៊ូនៅក្នុងសង្គ្រាមវៀតណាម គម្ពីរព្រះត្រៃបិដករបស់ព្រះពុទ្ធបានថ្លែងឡើងថា៖ បុរសម្នាក់ស្រេកទឹកជិតស្លាប់ កំពុងតែដើរតាមដងផ្លូវ ដែលមានដីហុយៗទ្រលោម ហើយក៏បានដើរមកដល់ផ្លូវបែក។ គួរអោយអស្ចារ្យណាស់ដែលគាត់ឃើញទឹកពីរទៅបីតំណក់ស្រក់ពីសត្វក្របី ដែលទើបតែដើរកាត់មុខគាត់។ ដោយឃើញតំណក់ទឹក គាត់លុតជង្គង់ចុះហើយយកបបូរមាត់គាត់ដាក់ទៅលើដី រួចលិឍស្រូបយកតំណក់ទឹកនោះ។ ក្រោយពីធ្វើសកម្មភាពនេះរួចគាត់ព្យាយាមគិតថា តើសត្វក្របីនេះមកពីខាងណា។ ដោយមិនដឹងអីសោះ គាត់ក៏ជ្រើសរើសផ្លូវមួយនៃផ្លូវបំបែក ដើម្បីធ្វើដំណើរបន្តទៅមុខទៀត។

សូមគិតស្រម៉ៃទៅលើករណីនេះថា បុរសស្រេកទឹកនេះបានលុតជង្គង់ដាក់មាត់ទៅលើដី ដើម្បីលិឍទឹកពីរទៅបីតំណក់។ យើងពុំដឹងថាគាត់ស្លាប់ដោយសារស្រេកទឹក ឬក៏មិនមែនទេ តែនៅខណៈដែលគាត់ឃើញតែទិដ្ឋភាពដែលគាត់ឃើញនោះ គឺជាការពិតច្បាស់ គាត់បានទឹកផឹកហើយដើរតាមសត្វក្របីនោះ គឺជាការពិតដែលគាត់ឃើញយ៉ាងជាក់ច្បាស់។ ជាការពិតណាស់ ទឹកពីរទៅបីតំណក់ពុំអាចបំបាត់ការស្រេកទឹករបស់គាត់បានទេ តែវាជាតំណាង នៃសេចក្តីសង្ឃឹមថាធនធានសម្រាប់ជីវិតមាននៅខាងមុខ។ អ្នកព្យាបាលទាំងអស់មានឱកាសឃើញ នឹងភ្នែកនូវសកម្មភាពអង់អាចក្លាហ៊ានរបស់អ្នកជួបប្រះភាពតក់ស្លុត។

ស្ត្រីជនជាតិ រ៉ាន់ដាន(Rwandan) ម្នាក់បានរួចផុតពីសេចក្តីស្លាប់ពីអំពើសម្លាប់រង្គាលនៅក្នុងប្រទេសរបស់គាត់ ដែលឪពុកម្តាយ ប្តី និងកូនគាត់៦នាក់ ក្នុងចំណោមកូនទាំង៧នាក់របស់គាត់ ត្រូវគេសម្លាប់នៅពេលដែលគាត់កំពុងតែរត់គៀសខ្លួនជាមួយ នឹងកូនប្រុសពៅរបស់គាត់ទៅជុំរុំភៀសខ្លួន គាត់បានជួបប្រទះនឹងក្រុម

ជនពាលប្រុសមួយហ្វូង វាបានសម្លុតទាមទារយកកូនរបស់គាត់។ ដោយភ័យខ្លាចមានគ្រោះថ្នាក់ដល់អាយុជីវិតកូនរបស់គាត់ គាត់ក៏សុខចិត្តអោយកូនគាត់ទៅក្រុមនោះទៅ ហើយក្រុមជនពាលនោះក៏នាំយកកូនគាត់ទៅ។ នៅពេលដែលក្រុមនោះដើរចេញទៅ កូនគាត់បានស្រែកយំហៅគាត់ "ម៉ែ ម៉ែ កុំអោយមនុស្សអាក្រក់នេះយកខ្ញុំទៅជាមួយវាអី"។ បន្ទាប់ពីគាត់បានមកដល់ជំរុំភៀសខ្លួនប្រកបដោយសុវត្ថិភាព គាត់បានស្វែងរកកូនរបស់គាត់គ្រប់ទិសទី តែគាត់រកវាពុំឃើញសោះ។ ពីរទៅបីឆ្នាំកន្លងមក សម្លេងកូនគាត់ស្រែកយំអោយគាត់ជួយ នៅតែដក់ជាប់ក្នុងអារម្មណ៍របស់គាត់ជានិច្ច គាត់ឮសម្លេងផ្អួនៗជារៀងរាល់ថ្ងៃ នៅទីបំផុតគាត់បានសម្លាប់ខ្លួនគាត់ទៅ។

ទោះជាស្ត្រីនេះបានបាត់បង់សមាជិកគ្រួសារជាច្រើននាក់ នៅគ្រាដំបូងដែលអំពើសម្លាប់រង្គាលនៅ វ៉ាន់ដាន (Rwandan) បានកើតមានឡើង គាត់នៅតែមានសេចក្តីសង្ឃឹមថា គាត់អាចស្រោចស្រង់ជីវិតកូនប្រុសពៅរបស់គាត់បាន។ កូននេះជាវត្ថុដ៏មានតម្លៃបំផុតដែលនៅសេសសល់ក្នុងជីវិតរបស់គាត់ នៅពេលដែលគាត់ត្រូវបង្ខំចិត្តអោយកូនទៅគេ វាជាករណី ចុងបញ្ចប់ដែលដួងចិត្ត គាត់ទទួលមហាទុក្ខក្រៀមក្រំ គាត់មានអារម្មណ៍ថាគាត់ជាអ្នកទទួលខុសត្រូវទៅលើអំពើដែលបានបំផ្លាញជីវិតកូនប្រុសរបស់គាត់។

កសិករស្រុកម៉ាសេដូនីញ៉ា (Macedinian) ម្នាក់ក៏ធ្លាក់ក្នុងសភាពអស់សង្ឃឹមជាអចិន្ត្រៃយ៍ ក្រោយពីភូមិរបស់គាត់ត្រូវវាយប្រហារដោយសង្គ្រាមនៅកូសូវ៉ូ (Kosovo) ហើយបានរីករាលដាលទៅដល់ម៉ាសេដូនីញ៉ា (Macedonia)។ កសិកររូបនេះរួម នឹងកូនប្រុសគាត់អាយុ ម្ភៃបួនឆ្នាំ បានពិគ្រោះគ្នាអំពីការនាំក្រុមគ្រួសារទៅរស់នៅ ក្នុងតំបន់សុវត្ថិភាព ដែលការពារដោយកងទ័ពទាហ៊ាន ម៉ា សេដូនីញ៉ា តែកូនប្រុសនោះបាន ជម្រុញអោយឪពុកជួយយកប្រពន្ធខ្លួន ដែលមានផ្ទៃពោះ និងម្តាយនៅទីមានសុវត្ថិភាពវិញ ហើយទុកអោយខ្លួនគេនៅចាំភូមិ ដើម្បីចូលរួមនៅក្នុងកងសេនាជន និងការពារផ្ទះនៅជីស្រែ និងសត្វគោ។ មិនយូរប៉ុន្មាន កងទ័ពអាល់បេនីញ៉ាន (Albanian) បានលុកលុយចូលមកដល់ទីក្រុង ហើយក៏សម្លាប់កូនប្រុសគាត់បាត់ទៅ។ ឪពុក និងក្រុមគ្រួសារដែលរស់នៅដោយសុវត្ថិភាព នៅក្នុងជំរុំជនភៀសខ្លួនបានទទួលទុក្ខសោកជាពន់ពេកនៅពេលដែលគាត់បានដឹងថាកូនរបស់គាត់ស្លាប់។ បុរសនេះក្លាយទៅជាជនដែលលែងចង់ដឹងឮ អំពីអ្វីៗទាំងអស់ ហើយចង់នៅតែឯកឯង គាត់បានបដិសេធពុំចូលរួមនៅក្នុងពិធីប្រសូត្រចៅ ជាបុត្ររបស់កូនប្រុសគាត់ដែលបានស្លាប់ទៅហើយនោះ។ ទោះបីជាគាត់នៅមានភារៈកិច្ចជាមេគ្រួសារក៏ដោយ គាត់លែងចាប់អារម្មណ៍ពីរឿងជីវិតទៀត ដោយគាត់មានអារម្មណ៍ខ្មាស់អៀន និងបន្ទោសខ្លួនឯងថា គាត់គួរតែនៅការពារទ្រព្យសម្បត្តិគ្រួសារ។ គាត់មានអារម្មណ៍ដូចគ្នា នឹងស្ត្រីជនជាតិ វ៉ាន់ដាន ៖ អំពើកំសាករបស់គាត់បណ្តាលអោយកូនគាត់ស្លាប់បាត់បង់ជីវិត។ មាតាបិតាម្នាក់ៗ នេះមានអារម្មណ៍ថា គេពុំបានជ្រើសយកភាពបូជាដ៏មុះមុត ដោយហ៊ានលះបង់ជីវិតរបស់ខ្លួន ដើម្បីស្រោចស្រង់ជីវិតកូនរបស់គេឡើយ អ្នកទាំងពីររូបនេះបានសម្រេចថាគេ នឹងមិនព្យាយាមបំភ្លេចសេចក្តីតក់ស្លុតរបស់គេឡើយ ហើយគេក៏មិនស្វះស្វែងបង្កើតជីវិតថ្មីទៀតដែរ។

ស្ត្រីខ្មែរម្នាក់ បានធ្វើការសម្រេចផ្ទុយ ទាំងស្រុង ដើម្បីអោយរួចផុតពីសេចក្តីស្លាប់អំពីវិបត្តិផ្ទាល់ខ្លួន ដែលកើតមានឡើងដោយខ្មែរក្រហមសម្លាប់ប្តីគាត់ ៖

សេចក្ដីឈឺចាប់របស់ខ្ញុំបានធូរស្រាលនៅពេលដែលខ្ញុំសូត្រធម៌ព្រះ ខ្ញុំសញ្ជឹងគិតតាមមាគ៌ាព្រះពុទ្ធ ដរាបណាមានជីវិត ដរាបនោះ នឹងមានសេចក្ដីស្លាប់ ភាពបែកបាក់គ្នាជាព្រហ្មលិខិត។ នៅពេលដែលខ្ញុំគិតតាមហេតុផលនេះ ខ្ញុំព្យាយាមមិនកើតទុក្ខពេកទេ។ ខ្ញុំធ្វើបែបនេះនៅពេលដែលខ្ញុំកើតទុក្ខហើយទឹកមុខខ្ញុំក្រៀមក្រំខ្លាំង។ បើមានភាពសប្បាយរីករាយក៏មានភាពទុក្ខព្រួយ ហើយបើមានសើចក្អាកក្អាយក៏មានភាពយំសោក។ នៅពេលដែលខ្ញុំគិតអំពីសិក្ខាបទ (ប្រៀនប្រដៅ)នេះខ្ញុំមានអារម្មណ៍ធូរស្រាល ធ្វើបែបនេះខ្ញុំគិតថាអ្នកដែលស្លាប់បានគេចរួចពីទុក្ខព្រួយបណ្ដោះអាសន្ន។ អ្នកដែលនៅមានជីវិតរស់នៅតែងតែមានទុក្ខព្រួយ....ចាស់ទុំបានមកជួបខ្ញុំហើយប្រាប់ខ្ញុំថា កូនឯងគ្មានឪពុករួចទៅហើយ ឯងមិនគួរធ្វើអោយវាកំព្រាជាម្ដងទៀតដោយគ្មានម្ដាយឡើយ។ ខ្ញុំបានថ្លឹងថ្លែងពីហេតុផលនេះជាយូរពេល ហើយមានអារម្មណ៍ធូរស្រាលឡើង តែខ្ញុំនៅតែនឹកគិតពីទុក្ខព្រួយខ្លះៗ។ ទុក្ខព្រួយទាំងនោះពុំរសាយបាត់ទាំងអស់ឡើយ ខ្ញុំគិតពីកូនរបស់ខ្ញុំ ខ្ញុំគិតពីអនាគតរបស់វា។ វាបានកើតឡើងឃើញពន្លឺព្រះអាទិត្យ ខ្ញុំពុំបោះបង់វាទេ។ ឪពុកបានស្លាប់បាត់ទៅហើយ ដូច្នេះ ម្ដាយគួរតែនៅមានជីវិត។

ស្ត្រីរ៉ាន់ដាន (Rwandan) និងបុរសម៉ាហ្សេដូនាន (Macedonian) ពុំអាចប្រមូលផ្ដុំសេចក្ដីក្លាហ៊ានដែលត្រូវការ ដើម្បីស្រូបផឹកតំណក់ទឹក និងរកសត្វក្របីឡើយ។ គេពុំអាចទទួលស្គាល់ជីវិតហើយទទួលយកថារូបគេនៅមានជីវិតរស់នៅ។ រីឯស្ត្រីខ្មែរវិញគាត់អាចធ្វើការសម្រេចថាគាត់ត្រូវតែបន្តការរស់នៅ ពុំមានអ្វីអាច យកមកប្រៀបផ្ទឹមអោយសមស្របទៅលើទំហំឈឺចាប់រវាងការបាត់បង់កូន ទៅនឹងការបាត់បង់ឪពុកម្ដាយ ឬប្ដីប្រពន្ធបានឡើយ។ ពុំមានរូបមន្តណាដែលអាចប៉ាន់ស្មានថា នណារម្នាក់មានចិត្តអង់អាចក្នុងការព្យាយាមធ្វើអោយខ្លួនភាពជាសះស្បើយពីអំពើឃោរឃៅបានឡើយ។

ពេលខ្លះភាពព្យាបាលដោយខ្លួនឯង វាកប់ទុកដ៏ជ្រៅនៅក្នុងភាពអស់សង្ឃឹម និងភាពសោកស្ដាយរបស់ជនរងគ្រោះដោយភាពតក់ស្លុតបានធ្វើអោយគេមានអារម្មណ៍ថា គេលែងចង់រស់នៅទៀត តែក៏គ្មានអ្វីអាចបំបាត់ឥទ្ធិពលព្យាបាលដោយខ្លួនឯងបានដែរ។ ជនផ្សេងទៀត ដូចជាសមាជិកគ្រួសារ មិត្តភក្តិ អ្នកព្យាបាល ឬជនណាដែលជួយយកអាសារ អាចចូលរួមនៅក្នុងភាពរស់រវើកដ៏សំខាន់ក្នុងជីវិតនេះ ហើយជួយណែនាំអោយជននេះភាពជាសះស្បើយ និងឱបក្រសោបជីវិតរបស់ខ្លួនឡើងវិញ។ ស្ត្រីរ៉ាន់ដាន ពុំបានទាក់ទងជាមួយ នឹងជនបែបនេះទេ កសិករម៉ាហ្សេដូនានមានក្រុមគ្រួសារនៅជុំជិត មានរួមទាំងចៅប្រុសថ្មីទៀតផង តែគាត់ពុំអាចធ្វើអោយសេចក្ដីប្រាថ្នាទៅលើជីវិតរបស់គាត់ គឺមានខ្លឹមសារឡើងវិញបាន។ ស្ត្រីខ្មែរបានយល់ព្រមធ្វើតាមការយកចិត្តទុកដាក់ស្រលាញ់រាប់អានរបស់ "ចាស់ទុំ" ដែលផ្ដល់សុភវិនិច្ឆ័យ (គតិបណ្ឌិត) និងវិចារណញ្ញាណ(សេចក្ដីថ្លឹងថ្លែងសមហេតុផល) របស់គេអំពីរបៀបបំបាត់ទុក្ខព្រួយដល់រូបនាង។

## ផ្នែក ១. សហការ និងការរស់នៅជាមួយគ្នា

នៅពេលដែលជនរួចផុតពីសេចក្ដីស្លាប់ មានចិត្តអង់អាច ដើម្បីបន្តជីវិតរស់នៅ ដោយយល់ព្រមរស់មួយថ្ងៃទៀត ដើម្បីចូលរួមធ្វើសកម្មភាពជាមួយ នឹងពិភពលោក គេបានដាក់ខ្លួនគេ ដើម្បីទទួលអានុភាពទំនាក់ទំនង

សង្គម។ សកម្មភាពបញ្ជាក់អះអាងនេះ មានភាព ដូចគ្នានឹងផ្កាភ្លើងដែលឆាបឆេះសន្ធោសន្ធៅនៅក្នុងគំនរអូស ហើយក្លាយទៅជាមហាអគ្គិភ័យ។ ចំពោះជនជួបប្រទះភាពតក់ស្លុតទាំងអស់ ឥទ្ធិពលព្យាបាលដោយខ្លួនឯង មានជាស្រេចនៅក្នុងខ្លួនរបស់គេ ហើយបំរុងតែ នឹងយកមកបង្កើនឡើងនៅពិភពជុំជិត។ ទោះបីជាយ៉ាងណាក៏ដោយសង្គមសម័យ និងវិជ្ជាពេទ្យសម័យ បានប្រើពេលដ៏យូរក្នុងការទទួលស្គាល់ឥទ្ធិពលព្យាបាលបែបបទទំនាក់ទំនងសង្គម។

ជាង១០០ឆ្នាំមកហើយ ដែលគំនិតបច្ចឹមប្រទេស បានផ្តោតអារម្មណ៍ទៅលើទ្រឹស្តីសង្គមជំនាន់ ដ័រវិនស៊ីប (Darwinism) ដោយយោងទៅលើទ្រឹស្តី និងការវិវឌ្ឍន៍របស់ជីវិត ដែលរៀបចំឡើងដោយ លោក ឆាល ដ័រវិន (Charles Darwin) ហើយបកស្រាយជាសង្ខេបដោយ ហេរប៊ើត ស្ពេនស័រ (Herbert Spencer) ថាជា "*ការរស់រានមានជីវិតដោយសម្របទៅតាមធម្មជាតិ* "។ ទ្រឹស្តីនេះបង្ហាញបញ្ជាក់បន្ថែមនៅលើទិន្នាការ(ភាពច្រើនតែ) របស់មនុស្សលោក ដែលចង់តែប្រណាំងប្រជែងគ្នាទៅវិញទៅមក ដើម្បីដណ្តើមអំណាចហើយធ្វើដូច្នេះ ដើម្បីអះអាងទៅលើការសម្របសម្រួលដ៏ធំធេងរបស់មនុស្សលោក ការបង្កើតកូនចៅ និងការរស់នៅរួចផុតពីសេចក្តីស្លាប់។ លោក រ៉េមិន ដត (Raymond Dart) អ្នកសិក្សាកាយវប្បកម្មមនុស្សជាតិ នៅក្នុងឆ្នាំ១៩៥០ បានធ្វើការអធិប្បាយនៃបកស្រាយនេះជាសកម្មភាពឈ្លានពានជាបែបដែលមានរួមទៅដោយការវាយសម្លាប់នៅយូហ្គាន់ដា (Uganda) សំណល់ពីការសម្លាប់រង្គាល នៅរ៉ាន់ដាន(Rwandan) និងការវាយសម្លាប់ដ៏ព្រៃផ្សៃ នៅស្រេប្រីនីកា(Srebrenica)៖ ទិដ្ឋភាពឈាមខ្ចាតពាសវាលពាសកាលអំពើកាប់សម្លាប់ ស្រាវយកពោះវៀន ជាប្រវត្តិមនុស្សដែលទុកនៅឯកសារដ្ឋាន បានចាប់ផ្តើមឡើង តាំងពីជំនាន់អេហ្ស៊ីបដើមបង្អស់(Egyptian) និងសង្គ្រាមសូម៉េរីយ៉ាន (Sumerian) បានកត់ត្រាការកាប់សម្លាប់ថ្មីៗ នៃកិច្ចចរចានៅក្នុងសង្គ្រាមលោកលើកទីII មានការស៊ីសាច់មនុស្ស ជាទូទៅនៅក្នុងជំនាន់ដើម ដោយគេយកសត្វ ឬមនុស្សមកបូជា ដើម្បីបន់ស្រន់តាមទំនៀមទម្លាប់ ឬធ្វើជំនួសពិធីបន់ស្រន់តាមសាសនា ជាផ្លូវការ មានរួមទៅដោយការដើររកកាត់ក្បាលមនុស្ស ការកាប់ចិញ្ច្រាំរាងកាយ សុះសាច់ ការសេពកាម និងសពមនុស្សរបស់បុរស ដើម្បីសម្តែងតណ្ហាស្រេកឃ្លានឈាមដែលធ្វើអោយខ្លួនប្លែកពីគេ នេះជានិមិត្តសញ្ញា ដែលចាត់ទ្រឹស្តីរបស់មនុស្សដោយឡែកពីប្រភេទសត្វ និងចាត់ទុកដោយប្រាកដថា គេជាអ្នកស៊ីសាច់ជាអាហារដ៏សាហាវបំផុត។

លោកម័រម៉ា នីកីលីច (Momir Dikolic) ជាអតីតអគ្គបញ្ជាការស៊ើបព័ត៌មាន បូស្សនានស៊ែបៀន (Bosnian Serbian) បានឆ្លើយតបជាកស្សិណសាក្សី ចំនួនពីរថ្ងៃនៅ (Hague) ឆ្នាំ២០០៣ ក្រោយពីជនជាតិបូស្សនាស៊ែប បានដេញជនជាតិម៉ូស្លីមចេញពីភូមិស្រេប្រីនីកា (Srebrenica) ហើយជនស៊ីវិលដែលត្រូវចាប់ខ្លួននោះភាគច្រើនជាមនុស្សប្រុស ត្រូវឃាត់ខ្លួនដោយទាហ៊ាន មន្ត្រីប៉ូលីស និងអ្នកយាមល្បាតកាន់កាំភ្លើងនៅតាមសាលារៀន ឃ្លាំចាំមើលយន្តហោះ ទីហាត់កីឡា និងត្រូវចាប់ញាត់ដាក់ពេញៗឡានធំ និងឡានទ្រុងដឹកជញ្ជូនពេញទីក្រុង។ តែនៅកំណត់យប់ទីបី អ្នកទោសចំនួនប្រហែលជា៨០ទៅ១០០នាក់ ត្រូវគេនាំចេញពីទីឃុំឃាំង

ហើយបាញ់ចោល។ ការប្រមូលសម្លាប់ដ៏សាហាវនេះ មានជាបន្តរហូតដល់ទៅចំនួនបួនថ្ងៃ ហើយសពទាំងនោះត្រូវបោះចោលទៅក្នុងផ្នូរសម្ងាត់។

យោងទៅតាមទស្សនៈការវិវឌ្ឍន៍ អំពើឃោរឃៅរបស់មនុស្ស បែបនេះពិបាក នឹងទទួលយល់ឃើញថាជាការសម្របសម្រួល ។ ឃ្លាចែងថា "*ការរស់រានមានជីវិតដោយសមស្របទៅតាមធម្មជាតិ*"។ ពេលខ្លះអាចយកមកប្រើ ដើម្បីធ្វើអោយអំពើសាហាវយង់ឃ្នងទៅជាអំពើសនិទានកម្ម(សមហេតុផល) ដោយកាត់ទោសជនរងគ្រោះថាជាជនទន់ខ្សោយជាង ដូច្នេះ ហើយគេមានតម្លៃទាបជាងមនុស្សដ៏ទៃទៀត ដោយជាមួយគ្នា នោះដែរដោយមិនអើពើទៅលើកម្លាំងព្យាបាលរបស់ចលនាសង្គម។ នៅក្នុងឆ្នាំថ្មីៗនេះការវិវឌ្ឍន៍ ផ្នែកជីវសាស្ត្រ បានយកចិត្តទុកដាក់ទៅលើទ្រឹស្តីរបស់ លោក ដ័រវិន ដែលត្រូវបានបំភ្លេចចោលជាយូរមកហើយ ដែលរួមមានការសហការ និងការរស់នៅជាមួយគ្នារវាងជីវិតទាំងអស់។ មានទាំងអតិសុខុមប្រាណ(បាក់តេរី) រហូតដល់ទៅថនិកសត្វ(មនុស្ស សត្វពាហនៈ) បណ្តាញដ៏ស្មុគ្រស្មាញ នៃទំនាក់ទំនងដែលភ្ជាប់អ្វីៗ មានជីវិតរួមគ្នា ដើម្បីបង្កើនភាពរួចផុតពីសេចក្តីស្លាប់ដល់ជីវិតទាំងអស់។ ឧទាហរណ៍ ដ៏ប្រពៃណីទំនាក់ទំនងសហការរវាងសត្វលោកកើតមានឡើងពីហ្វូងសត្វស្រម៉ោចនៅប្រទេសអាមេរិកខាងត្បូង ។ ស្រម៉ោចនេះខាំស្លឹកឈើដែលដុះនៅជិតទីនោះ ហើយវាទំពារស្លឹកឈើនោះអោយទន់ រួចវាយកសរសៃរម៉ដ្ឋនោះទៅធ្វើជាជី ដើម្បីបណ្តុះផ្សិតនៅក្នុងចំការក្រោមដីរបស់វា។ ជាលទ្ធផលផ្សិតនោះបានដុះទៅជា "ផ្លែ" ហៅថាផ្លែ ហ្គង់ហ្គីលីដៀរ (gongylidia) ដែលសត្វស្រម៉ោចម្ចីម្នាចូលចិត្តទំពារលេប។ សត្វស្រម៉ោចរៀបចំការពារផ្សិតរបស់វាជាបែបផ្សេងទៀត ដោយវាបង្កើតសារធាតុសម្លាប់បាក់តេរីនៅក្នុងខ្លួនវា ដើម្បីសម្លាប់ផ្សិតដែលវាពុំចង់បាន ប្រព័ន្ធដ៏ស្មុគ្រស្មាញនៃទំនាក់ទំនងនេះបានផ្តល់ផលប្រយោជន៍ជាអតិបរមាដល់ហ្វូងសត្វស្រម៉ោច។

ការសិក្សាផ្នែកថនិកសត្វ បានបញ្ជាក់នូវសារៈសំខាន់ ក្នុងសង្គមអំពីដំណើរវិវឌ្ឍន៍ ភាពរួចផុតពីសេចក្តី ស្លាប់។ អ្នកសិក្សាផ្នែកថនិកសត្វអាលីសុន ចូលី (Alison Jolly) បានធ្វើការសន្និដ្ឋានថាទំនាក់ទំនងសង្គម ជាភាពជម្រុញការវិវឌ្ឍន៍តែមួយគត់ ដែលធ្វើអោយភាពផ្លាស់ប្តូរផ្នែកជីវសាស្ត្ររឹតតែលឿនឡើងនៅក្នុងចំណោមសត្វលោក។ មនុស្សលោកបង្ហាញនូវសមត្ថភាពអស្ចារ្យ ក្នុងការធ្វើការរួមគ្នាដើម្បី នឹងបង្កើតលទ្ធផល គ្មានជនណាម្នាក់អាចបង្កើតឡើងបានតែម្នាក់ឯងឡើយ។ ការរួមសហការជាមួយ នឹងមិត្តភក្តិរបស់អ្នក សម្ព័ន្ធមិត្ត រូបអ្នក និងខ្សែស្រឡាយរបស់អ្នក នឹងទទួលផលប្រយោជន៍នៅចុងបញ្ចប់។ ចូលីបានថ្លែងទៀតថា សិក្ខាបទដ៏សំខាន់គឺៈ "ដើម្បីមានប្រយោជន៍ដល់ខ្លួនត្រូវគិតពីអ្នកដទៃជាមុនសិន ហើយត្រូវក្បត់នៅពេលដែលគ្មានជម្រើសអ្វីផ្សេងទៀត "។ ការស្រាវជ្រាវដែលយោងទៅតាមការពិសោធន៍ល្បែងលេង ដែលធ្វើអោយរំភើបអារម្មណ៍ទៅតាមស្ថានភាពជីវិតពិត ក៏បង្ហាញនូវអត្ថប្រយោជន៍សហការនៅខណៈមានគ្រោះកាច។ សេចក្តីបង្ខិតបង្ខំរបស់បុគ្គលអាចបង្កើនភាពសម្រេចដោយជោគជ័យ ប៉ុន្តែនៅករណីសាមគ្គីភាពមិនរឹងពឹង និងគម្រោងការណ៍មិនច្បាស់លាស់អាចជាកត្តាចាំបាច់ ដើម្បីសម្រេចលទ្ធផលកម្រិតអតិបរិមា។

ជាភស្តុតាងដែលបានអធិប្បាយច្រើនបំផុតទៅលើឥទ្ធិពលសហការសង្គម គឺបានថ្លែងឡើងដោយជនដែលទទួលបទពិសោធន៍ដោយអំពើមហាឃោរឃៅ។ ទោះបីជាមានភាពបំផ្លាញវត្ថុនៅជុំវិញខ្លួន និងភាពទន់ខ្សោយកាយសម្បទាក្រោយពីអំពើវិនាសរបស់មនុស្សលោក ឬគ្រោះមហន្តរាយធម្មជាតិ អ្នករួចផុតពីសេចក្តីស្លាប់ជាញឹកញាប់ច្រើនតែជួយអ្នកផ្សេងៗទៀត ដូចឃើញជាសាក្សីស្លាប់ នៅក្នុងពេលព្យុះសមុទ្រកើតមានឡើងនៅអាស៊ីទក្សិណនៅក្នុងឆ្នាំ២០០៤ ។ គេពុំមានរង់ចាំជំនួយដោយគ្មានអើពើឡើយ ការយកចិត្តទុកដាក់ និងសហការរបស់មនុស្សដ៏លើសលប់ ធ្វើអោយការខូចខាតដោយគ្រោះដ៏សាហាវមួយនោះ វាចាប់ផ្តើមរលត់បាត់ទៅ។ សកម្មភាពជួយគ្នាក៏បានឃើញក្រោយពីថ្ងៃទី១១ ខែ កញ្ញា។ នៅក្នុងការវាយប្រហារចំគោលដៅរបស់ភេរវករគឺបង្កើតអោយមានមហាចលាចលក្នុងសង្គម តែប្រជាជននៅនីវយក និងប្រជាជនអាមេរិកកាំងគ្រប់ទិសទី បានសាមគ្គីគ្នា ដើម្បីជួយគ្នាទៅវិញទៅមក។ រឿងរបស់បុព្វបុរស និងការលះបង់ផ្ទាល់ខ្លួន បាននិយាយរៀបរាប់ឡើងវិញជាប្រចាំថ្ងៃនៅក្នុងកាសែត និងទូរទស្សន៍ ដែលធ្វើអោយប្រជាជនបានដឹងឮអំពីការចូលរួមរបស់គេ។

## ១.១ ទស្សនៈសង្គមនៃឱាពព្យាបាល

សកម្មភាពសង្គមជា ឧបករណ៍សំខាន់ នៃភាពព្យាបាលដោយខ្លួនឯង ដោយវាផ្តល់វិធី និងឧបករណ៍សម្រាប់ជួយសម្រួលអោយជាសះស្បើយពីភាពតក់ស្លុត។ សកម្មភាពសង្គម គឺគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង ប្រកបការងារ និងជំនឿ (ទំនាក់ទំនងផ្លូវចិត្ត) បានទទួលការបង្ហាញបែបវិទ្យាសាស្ត្រថា ធ្វើអោយជនជួបប្រទះភាពតក់ស្លុតមានភាពដូចដើមវិញ។ វាមានតួនាទីធ្វើអោយមានការផ្លាស់ប្តូរ ដោយបន្ថយលទ្ធផលអាក្រក់ដែលធ្វើអោយប៉ះពាល់ដល់សុខភាព ដោយមកពីការបញ្ចេញអារម្មណ៍តានតឹងពន់ពេក វាធ្វើអោយមានការជួសជុល ផ្នែកជីវសាស្ត្រ ជួយរៀបចំអាកប្បកិរិយាជាក់លាក់ និងជំនឿក្រោយពីភាពតក់ស្លុត និងបង្វែរជនរួចផុតពីសេចក្តីស្លាប់ចេញពីភាពឯកឯង អោយមកចូលរួមធ្វើសកម្មភាពវិញ។ អាកប្បកិរិយាទាំងនេះក៏អាចមានតួនាទីជាឥទ្ធិពលវិវឌ្ឍន៍ដ៏សំខាន់ក្នុងសង្គម ដែលជួយគាំទ្រអោយមនុស្សលោករស់រានមានជីវិត។

## ១.២ ការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង

សិក្ខាបទនៅក្នុងចំណោមទាំងនេះ គឺការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង ជាសកម្មភាពខ្វល់ខ្វាយដែលធ្វើឡើងជារឿយៗ ដោយគ្មានគិតពីខ្លួនឯង ដើម្បីសុខុមាលភាពអ្នកដទៃ ជាញឹកញាប់ច្រើនតែមានរួមទៅដោយគំនិតបរិច្ចាគទាន។ ការគិតពីប្រយោជន៍អ្នកដ៏ទៃជាងខ្លួនឯងជាការរួបរួមគ្នាពិសេស នៅក្នុងទំនាក់ទំនងសង្គម ដោយវាជាសកម្មភាពដែលពុំយោងទៅតាមការឆ្លើយតបរបស់អ្នកទទួល។ ទន្ទឹមនឹងនេះ ជាទូទៅគេសង្ឃឹមថា អ្នកដែលទទួលផលប្រយោជន៍ដោយអំពើ*ការគិតពីប្រយោជន៍អ្នកដ៏ទៃជាងខ្លួនឯង* នឹងពេញចិត្តទៅលើអំពើនោះ ការឆ្លើយតបនេះពុំចាំបាច់ទេ។ *ការគិតពីប្រយោជន៍អ្នកដ៏ទៃជាងខ្លួនឯង* ជាអាកប្បកិរិយា ជួយព្យាបាលជនជួបប្រទះភាពតក់ស្លុតអោយប្រសើរឡើងវិញ ដោយម្នាក់ៗមានអ្នកផ្សេងទៀតដែលត្រូវការរួបគេ

ហើយអាចទទួលបានផលប្រយោជន៍ដោយជំនួយរបស់គេ ទោះជាខ្លួនគេមានភាពលំបាកផ្ទាល់ខ្លួនយ៉ាងណាក៏ដោយ។

*តែការគិតពីប្រយោជន៍អ្នកដ៏ទៃជាងខ្លួនឯង* ជាញឹកញាប់ច្រើនតែយកមកប្រើខុសនៅក្នុងដំណើរការព្យាបាល ដូចជាបុគ្គលិកសង្គ្រោះ ដែលបានបង្ខំផ្តល់ជំនួយរបស់ខ្លួនដល់ជនជួបប្រទះភាពតក់ស្លុត ដោយបង្កើតទំនាក់ទំនងពឹងផ្អែក និងពុំផ្តល់វិធីថែខ្លួនដល់ជនរួចផុតពីសេចក្តីស្លាប់។ សេចក្តីព្យាយាម ផ្នែកអន្តរជាតិមានបំណងល្អ តែវាជាវិធីសើរៗ ជាលទ្ធផលវាបានធ្វើអោយខូចខាតច្រើនជាងផ្តល់ប្រយោជន៍។ ជូស៊ូស (Jusuf) បុរសវ័យក្មេងជនជាតិម៉ូស្លីមម្នាក់ ធ្វើការនៅក្នុងកម្មវិធីផលិតឈីស(Cheese)នៅទីក្រុងស្រេប្រីនីកានៅក្នុងឆ្នាំ ២០០៤ ជាមួយ នឹងក្រុមហ៊ុនអាមេរិកកាំង បានអធិប្បាយអំពីហេតុការណ៍នេះ ៖

ខ្ញុំព្យាយាមណែនាំវិធីផលិតឈីស បែបទំនើបនៅស្រេប្រីនីកា តែជាភាពលំបាកគេពុំចង់លះបង់បច្ចេកទេសធ្វើឈីស ដែលជាទំនៀមទម្លាប់របស់គេឡើយ។ បញ្ហាគឺបរិច្ចាគជន និងអ្នកផ្សេងៗទៀតដែលព្យាយាមជួយអ្នកទាំងនោះពុំមានវត្តមាននៅទីនោះទៀត។ គេមកនៅក្បែរតែមួយរយៈពេលខ្លី គេនាំមកនូវសេចក្តីកោតសរសើរ ផ្ទះសម្បែងដែលមានតម្លៃថោកៗ និងឧបករណ៍ផ្សេងៗ រួចគេចេញទៅវិញបាត់ភ្លាម គេទ្រាំរង់ចាំពេលត្រឡប់ទៅវិញស្ទើរតែពុំបានទៀតផង។

រឿងអ្នកជួយដែលចូលមករាតត្បាត នៅក្នុងសហគមន៍រងគ្រោះ រួចចាកចេញទៅវិញភ្លាមៗ បែបនេះកើតមានឡើងនៅជុំរុំភៀសខ្លួន និងនៅក្នុងចំណោមប្រជាជនជួបប្រទះភាពតក់ស្លុតទូទាំងពិភពលោក។ អ្នកជួយពេលខ្លះរារាំងភាពព្យាបាលដោយខ្លួនឯង ដោយបង្ខំអោយជននោះទទួលការយកចិត្តទុកដាក់របស់ខ្លួន និងជំនួយដែលជាសេចក្តីតម្រូវរបស់អ្នកឯទៀត ជាញឹកញាប់ច្រើនតែផ្តោតទៅលើអត្ថប្រយោជន៍ តែវាជាជំនួយតិចតួចសម្រាប់អ្នកដែលព្យាយាមបង្កើតជីវិតថ្មី ដែលបានចេញពីអតីតពិភពគ្មានអ្វីនៅសេសសល់ក្រៅពីគំនរផេះ។ អ្នកផ្តល់ជំនួយទាំងនេះជាញឹកញាប់ពុំមានការយល់ដឹងគ្រប់គ្រាន់ទៅលើដំណើរការព្យាបាលជាធម្មជាតិ របស់សហគមន៍ប្រចាំតំបន់។ ដោយគេចាត់ទុកខ្លួនគេអោយនៅដាច់ពីអានុភាពចិត្តសាស្ត្រ និងទំនៀមទម្លាប់របស់មនុស្ស គេ "រង់ចាំតែដល់ពេលគេត្រឡប់ទៅវិញ" ស្ទើរតែពុំបាន។ សេចក្តីតស៊ូសង្គ្រោះនៅទីក្រុងនីវយក (NewYork) ក្រោយពីការវាយប្រហារ នៅថ្ងៃទី ១១ ខែ កញ្ញា បានបង្ហាញនូវភាពរាតត្បាតប្រហាក់ប្រហែលគ្នារបស់បុគ្គលិកសង្គ្រោះ ជាពិសេសបុគ្គលិកផ្នែកចិត្តសាស្ត្រ។

ប៉ុន្តែបើការគិតពីប្រយោជន៍អ្នកដ៏ទៃជាងខ្លួនឯងកម្រ នឹងកើតមានឡើងក្នុងទស្សនៈរបស់អ្នកដែលរួចផុតពីសេចក្តីស្លាប់ តែការជួយជនរងគ្រោះ អាចផ្តល់ជំនួយជាច្រើន ដល់ជនរងគ្រោះក្នុងភាពព្យាបាល ដោយខ្លួនឯង។ ទោះបីជានៅក្នុងករណី ដែលមនុស្សមានតែកម្មសិទ្ធិតិចតួចក៏ដោយ ភាគច្រើនគេអាចរកវិធីឃើញ មានរឿងជាច្រើន អំពីឪពុកម្តាយនៅក្នុងជុំរុំអប់រំ ដែលបានចែកចាយចំណីបន្តិចបន្តួចចុងក្រោយ ជាមួយ នឹងសមាជិកគ្រួសារផ្សេងៗទៀត ជាពិសេសជីដូនជីតា និងកូនចៅ។ នៅក្នុងពេលដែលខ្ញុំឈឺ ស្ត្រីខ្មែរម្នាក់ជាបុគ្គលិករួមការងារបាន

ធ្វើពិធីរំដោះគ្រោះអោយខ្ញុំ ស្ត្រីនោះបានយកទឹកអប់ដែលស្វាមីគាត់បានអោយទៅគាត់ មុនគេយកប្តីគាត់ទៅសម្លាប់ចាក់ទៅក្នុងទឹកពីរទៅបីតំណក់ រួចគាត់បានធ្វើការប្រសិទ្ធិពរដល់រូបខ្ញុំ។

នៅក្នុងបរិយាកាសអំពើមហាឃោរឃៅ ដែលឧក្រិដ្ឋជន ប៉ងបំផ្លាញទំនាក់ទំនងភាពរឹងមាំ និងភាពទុកចិត្តក្នុងសង្គម អ្នកដែលរួចផុតពីសេចក្តីស្លាប់ ត្រូវពង្រឹងស្មារតីរបស់ខ្លួន ដើម្បីជួយអ្នកដទៃ។ ជនជួបប្រទះភាពតក់ស្លុតពេលខ្លះៗ បានបាត់បង់សេចក្តីទុកចិត្តទៅលើសមត្ថភាពរបស់ខ្លួនក្នុងការថែទាំកូនចៅ គ្រូបង្រៀនបានបាត់បង់ សេចក្តីទុកចិត្តក្នុងការបង្រៀនសិស្ស វេជ្ជបណ្ឌិត បានបាត់បង់សេចក្តីទុកចិត្តក្នុងការព្យាបាលអ្នកជម្ងឺរបស់ខ្លួន។ ប៉ុន្តែជនរងគ្រោះដោយស្ថានភាពទាំងនេះ នៅមានសេចក្តីសង្ឃឹមខ្លះៗដែលគេផ្តល់ទៅអ្នកផ្សេងទៀត គេជួយអ្នកទាំងនោះដោយគ្មានគិតពីប្រយោជន៍របស់ខ្លួន ជនរួចផុតពីសេចក្តីស្លាប់ចូលរួមនៅក្នុងភាពព្យាបាលដោយខ្លួនឯង។ អាកប្បកិរិយាការគិតពីប្រយោជន៍អ្នកដ៏ទៃជាងខ្លួនឯង ជនជាបែបបទមើលឃើញឆ្លុះ ខ្ញុំឃើញសេចក្តីឈឺចាប់ និងសេចក្តីរីករាយរបស់ខ្ញុំនៅក្នុងខ្លួនអ្នក ហើយអ្នកឃើញសេចក្តីឈឺចាប់ និងសេចក្តីរីករាយរបស់អ្នកនៅក្នុងខ្លួនខ្ញុំ។ នេះជាមូលដ្ឋានការសន្ទនាគ្នាអំពីអារម្មណ៍របស់គេ ពុំត្រឹមតែនិយាយជាមួយគ្នាទៅវិញទៅមក តែគេបាននិយាយទូទាំងសហគមន៍។

ការអនុវត្តន៍*ការគិតពីប្រយោជន៍អ្នកដ៏ទៃជាងខ្លួនឯង* របស់ជនភៀសខ្លួន និងជនជួបប្រទះភាពតក់ស្លុតផ្សេងទៀត អាចបង្កើតជាមូលដ្ឋានក្នុងការកសាងជីវិតថ្មីរបស់គេ។ ជនជួបប្រទះភាពតក់ស្លុតស្ទើរតែគ្រប់រូប មានរឿងការគិតពីប្រយោជន៍អ្នកដ៏ទៃជាងខ្លួនឯង ដែលគេភ្លេច ឬបំភ្លេចទុកនៅក្នុងប្រវត្តិរឿងសោកនាដកម្មរបស់គេ។ ការនឹករកឃើញ និងការនិយាយសំណេះសំណាលរឿងទៅមកជាសាធារណៈ អំពីរឿងនិទានដែលគេបានបំភ្លេចចោល ពេលនោះមេរៀនថ្មីក៏ផុសចេញមក។ ទោះបីជាយ៉ាងណាក៏ដោយ ការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង ពោរពេញទៅដោយភាពប្រថុយការទទួលគ្រោះថ្នាក់ និងភាពប្តេជ្ញាបះបង់ រឿងបែបនេះពោរពេញទៅដោយភាពចេញពីក្នុងចិត្ត និងសេចក្តីភ័យខ្លាច គ្រោះថ្នាក់ និងពេលខ្លះមានលទ្ធផលអាក្រក់ដែលពុំគ្រោងទុកថាអាចកើតមានឡើង។

សូធា(Sothea)ជាជនភៀសខ្លួន អាយុ សាមសិបឆ្នាំ នៅជុំរុំសាយធូ គាត់ធ្វើការជាគ្រូបង្រៀន នៅពេលដែលគាត់ចូលរួមនៅក្នុងការហ្វឹកហ្វឺនសុខភាពសតិអារម្មណ៍របស់យើង នៅក្នុងនិទាឃរះដូវ (រដូវផ្កាយរីក) ឆ្នាំ ១៩៩០។ ឪពុកម្តាយរបស់គាត់ក៏ជាគ្រូបង្រៀនដែរ តែបានស្លាប់នៅជំនាន់ប៉ុលពតអស់ទៅ។ សូធាមានរឿងនិទានការគិតពីប្រយោជន៍អ្នកដ៏ទៃជាងខ្លួនឯង ជាច្រើនដែលគាត់អាចនិយាយប្រាប់ តែមានរឿងមួយបានបង្ហាញអំពីលទ្ធផលដែលទទួលបានដោយការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង៖

ខ្ញុំធ្វើការនៅមន្ទីពេទ្យទាហ៊ានចំនួន មួយឆ្នាំ ជាកំណត់ពេលដែលខ្ញុំឃើញ ស្ថានភាពជាក់ស្តែង ដែលធ្វើអោយខ្ញុំតក់ស្លុត។ ខ្ញុំនិយាយអំពីព្រឹត្តិការណ៍មួយដែលខ្ញុំបានជួបប្រទះ ហើយធ្វើអោយខ្ញុំរន្ធត់ញាប់ញ័រ វាជាពេលដែលគេនាំមនុស្សយកទៅសម្លាប់ចោល។ ខ្ញុំបាននិយាយជាមួយមនុស្សចំនួន ប្រាំនាក់ មុននឹងគេយកអ្នកទាំងនោះទៅសម្លាប់ចោល អ្នកទាំងនោះពុំមាននិយាយអ្វីទាំងអស់ គេគ្រាន់តែគ្រវីក្បាល។ គេមើលទៅហាក់បីដូចជា

បាត់បង់វិញ្ញាណអស់ទៅហើយ មុខគេឡើងខ្មៅ ភ្នែកស្លោរ ហើយគេមើលមកយើងចំៗ ដោយគ្មានព្រិចភ្នែកឡើយ ហាក់បីដូចជាគេចង់និយាយប្រាប់យើងអំពីអ្វីមួយ។ ខ្ញុំពុំអាចបំភ្លេចកាយវិការ និងទឹកមុខរបស់គេបានឡើយ ខ្ញុំនៅតែឃើញតែទិដ្ឋភាពទាំងនោះនៅក្នុងអារម្មណ៍របស់ខ្ញុំ ដែលធ្វើអោយខ្ញុំទទួលទានដំណេកពុំបានឡើយ។

សូជាជួយយកអាសារអ្នកដទៃដោយប្រថុយទទួលគ្រោះថ្នាក់ ទៅលើសុខភាពសតិអារម្មណ៍របស់ខ្លួន ការជួយអ្នកដែលគេបម្រុងយកទៅសម្លាប់នោះ គឺគាត់បានលះបង់សតិអារម្មណ៍ក្លឹថ្លា និងការទទួលដំណេកសុខសាន្តរបស់គាត់ជាអវសាន្ត។ ទោះជាគាត់ពុំអាចជួយស្រោចស្រង់ជីវិតរបស់អ្នកទាំងនោះបានក៏ដោយ តែគាត់បានអនុវត្តន៍ ការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង ជាករណីសាមញ្ញរបស់ជនរួចផុតពីសេចក្តីស្លាប់ អ្នកព្យាបាល និង
បុគ្គលិកសង្គ្រោះ ដែលយកសេចក្តីឈឺចាប់សោកសង្រេងទាំងនោះ ដាក់ទៅក្នុងស្មារតីរបស់ខ្លួនទុកជាវិធីចងចាំ និងគោរពអ្នកទាំងនោះ។

ផ្ទុយនឹងអំពើល្អរបស់គាត់ សូជាបានលើកយកសំណួរដោយប្រាកដប្រជាថា តើការជួយយកអាសារអ្នកដទៃមាននាំមកប្រយោជន៍ជាសម្ភារៈអ្វីដល់រូបគាត់ ឬផ្តល់ផលប្រយោជន៍ល្អអ្វី? គាត់បានប្រាប់យើងថាការបង្រៀនរបស់គាត់ គាត់បានជួយក្មេងរាប់ពាន់ ផ្នែកអក្សរសាស្ត្រ ប៉ុន្តែ "ខ្ញុំបង្រៀនជាច្រើនឆ្នាំ វាដូចជាគ្មានជួយរូបខ្ញុំទេ ដោយគ្រាន់តែកង់ជិះមួយ ក៏ខ្ញុំគ្មានលុយទិញដែរនោះ"។ ការមន្ទិលសង្ស័យ របស់សូជាទៅលើគតិបណ្ឌិតរបស់ខ្លួនក្នុងការជួយក្មេង បានប្រែក្រឡះវិញដោយព្រឹត្តិការណ៍មួយដែលគាត់ បានប្តូរជីវិតរបស់គាត់ ក្នុងការជួយក្មេងតូចបួននាក់ ពីភាពលង់ទឹក"។ ខ្ញុំបានលោតចូលទៅអាងទឹកទាំងស្បែកជើងកវែងដើម្បីស្រោចស្រង់ជីវិតក្មេងទាំងនោះ។ ខ្ញុំស្ទើរតែអស់ជីវិតដោយគ្រោះថ្នាក់នោះ "នៅពេលដែលខ្ញុំស្រង់ក្មេងនោះចេញពីទឹក ក្មេងពីនាក់បានសន្លប់បាត់ស្មារតី តែក្រោយមកក្មេងៗ ទាំងនោះបានជាដូចដើមវិញ។ គាត់យល់ដឹងពីភ័ព្វសំណាងរបស់គាត់ ក្នុងការសង្គ្រោះដ៏មានគ្រោះថ្នាក់នេះ" ខ្ញុំមានភ័ព្វសំណាងណាស់ ដោយខ្ញុំអាចស្រោចស្រង់ជីវិតមនុស្សម្តងបានបួននាក់ ។ យោងតាមធម៌ព្រះពុទ្ធ អំពើនេះជាបុណ្យកុសលច្រើជាងការធ្វើបុណ្យ១០០វត្តទៅទៀត"។

ជីវិតពុំមានអ្វីប្រាកដថា អំពើការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង ពិតជានាំផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍ជាសម្ភារៈឡើយ។ ជាកត្តាពិតរៀងរាល់អំពើការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង មានរួមទៅដោយគ្រោះថ្នាក់ វាអាចបាត់បង់អ្វីមួយរហូតដល់ជីវិតទៀតផង។ ទោះបីជា សូជាសួរអំពីភាពគ្មានផលប្រយោជន៍ជាសម្ភារៈទៅលើការបង្ហាត់បង្រៀនរបស់ខ្លួនក៏ដោយ គាត់ពុំអាចទប់ចិត្តបានពីការអធិប្បាយថាគាត់ហ៊ានស្លាប់ ដើម្បីជួយស្រង់ក្មេងៗ លង់ទឹកដែលធ្វើអោយរូបគាត់ដឹងយល់ថា៖ ផ្ទុយពីប្រាក់កាក់ និងអំណាចអំពើការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង របស់គាត់បានធ្វើអោយរូបគាត់ទទួលផលប្រយោជន៍ជាអារម្មណ៍ប្រពៃ។ នេះជាភាពជាសះស្បើយមួយ ចំណែកទៅលើភាពខូចខាត ដែលបណ្តាលឡើងនៅក្នុងរបបប៉ុលពត។

បាណាបាស(Banabas)ជនភៀសខ្លួន អាយុ សាមសិបពីរ ឆ្នាំ ជាគ្រូបង្រៀនជំនួយនៅជុំរុំសាយធូ បានបញ្ចេញទស្សនៈល្អទៅលើការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង។ ក្រុមគ្រួសារគាត់ជាកសិករ ហើយគាត់មានគំរិះវិជ្ជាត្រឹមមធ្យមសិក្សា(វិទ្យាល័យ) នៅពេលដែលគាត់ព្យាយាមរត់គេចពីខ្មែរក្រហម (Banabas)បានធ្វើដំណើរតាមព្រំដែនចន្លោះប្រទេសថៃ និងប្រទេសខ្មែរ ជាតំបន់គ្មានច្បាប់ហើយកាន់កាប់ដោយចោរព្រៃ និងអ្នករត់ពន្ធគ្រប់ប្រភេទ។ នៅពេលដែលគាត់នៅទីនោះ គាត់បានជួបបុរសម្នាក់ដែលបានទទួលបទពិសោធន៍ចង់សម្លាប់ខ្លួន៖

នៅក្នុងចំណោមអ្នករត់ពន្ធទាំងនោះ មានបុរសម្នាក់បានខ្ចីមាសប្រាក់ពីបងប្អូន ដើម្បីយកមករកស៊ីដូចគេដូចឯង។ ជាភ័ព្វអាក្រក់ គាត់ត្រូវចោរព្រៃប្លន់យកអស់នៅតាមផ្លូវ ក្រោយពីបាត់បង់អស់ដើមរកស៊ី គាត់លែងមាំមួនទៀត គាត់ហាក់បីដូចជាភ្លេចភ្លាំង ហើយពេលខ្លះគាត់នៅហ្នឹងមួយកន្លែងគាត់ភ័យខ្លាចហើយស្លុត។ បើសិនជា គាត់ត្រឡប់ទៅផ្ទះវិញ គាត់គ្មានអ្វីសងបំណុលគេឡើយ ម្យ៉ាងវិញទៀត បើគាត់បន្តដំណើរតាមព្រំដែនគាត់គ្មានដើមទុនអ្វី នឹងធ្វើការជួញដូរ គាត់ទៅជាវវើវាយ គាត់គិតអ្វីពុំចេញឡើយ គាត់មើលឃើញតែភាពងងឹតស្លុងជាឧបសគ្គនៅចំពោះមុខគាត់ (Banabas) បានព្យាយាមនិយាយដោយអារម្មណ៍ទោរទន់ ទៅកាន់បុរសនោះថា៖

> ៚ ដោយខ្ញុំមានការមន្ទិលសង្ស័យខ្លាំងទៅលើបុរសនេះ ខ្ញុំក៏ដើរសំដៅទៅគាត់ហើយសួរគាត់ខ្លះៗ គាត់បាននិយាយរឿងប្រាប់ខ្ញុំ ទាំងអួលដើមករួមដោយទឹកមុខព្រួយបារម្ភ។ នៅទីបញ្ចប់គាត់បានប្រាប់ខ្ញុំថាគាត់ពុំចង់រស់ទៀតទេ ក្រោយពីនិយាយរឿងប្រាប់ខ្ញុំរួចហើយ គាត់បានធ្វើអោយខ្ញុំអាណិតគាត់ ណាស់។ ដោយឃើញគាត់នៅក្នុងស្ថានភាពបែបនោះ ខ្ញុំមានអារម្មណ៍អាណិតអាសូរគាត់ជាខ្លាំង ខ្ញុំសុំអោយគាត់រស់នៅតទៅទៀត ខ្ញុំនិយាយទៅកាន់គាត់ ដូច្នេះដើម្បីអោយគាត់បង្វែរអារម្មណ៍អោយធម្មតា ដូចមុនវិញ។ ខ្ញុំធ្វើឡើងដោយការពន្យល់គាត់ អំពីទុក្ខសោក និងគ្រោះថ្នាក់របស់មនុស្សលោក ម្នាក់ៗ។
>
> ៚ ទោះបីជា វាជាបន្ទុកធ្ងន់ក៏(Banabas)បានហៅបុរសនោះអោយមកជាមួយខ្លួន ចូលទៅប្រទេសថៃគាត់ "រីករាយណាស់ដោយគាត់បានជួយស្រោចស្រង់មនុស្សម្នាក់ពីសេចក្តីស្លាប់"។ ហើយក្រោយមកគេទាំងពីរក៏ក្លាយទៅជាមិត្ត និងគ្នា ។ Banabas មានជំនាញព្យាបាលស្តាប់ យល់ចិត្ត ដែលធ្វើអោយគាត់យល់អំពីការតាំងចិត្តសម្លាប់ខ្លួនរបស់ជនចម្លែកនោះ ទោះបីជាអំពើការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង របស់(Banabas)ហាក់បីដូចជា ងាយស្រួលសំរាប់រូបគាត់ ដោយគាត់មានជំនាញទំនាក់ទំនងទឹកចិត្តជាធម្មជាតិ វាបង្កប់នូវភាពប្រថុយទទួលគ្រោះថ្នាក់ធ្ងន់ធ្ងររបស់គាត់។

នៅក្នុងរឿងនេះ រួមនឹងរាល់ករណី ការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង ទាំងអស់ គ្មានលទ្ធផលល្អអាចកើតមានឡើង លើកលែងតែមាននរណាម្នាក់សុខចិត្តលះបង់ផ្តល់អ្វីៗ សំខាន់ដល់ជនម្នាក់ទៀត។ បទពិសោធន៍ នេះធ្វើអោយអារម្មណ៍អាម៉ាស់មុខ ជាទូទៅដែលកើតឡើងដោយលទ្ធផលអំពើសាហាវទាំងនោះផ្លាស់ប្តូរវិញ។ ជនរួចផុតពីសេចក្តីស្លាប់ដែល "គ្មានអំណាច" និង "គ្មានតម្លៃ" ទោះជាសេចក្តីអាម៉ាស់មុខរបស់គេមានទម្ងន់កម្រិតណា

ក៏ដោយ គេអាចនិយាយចែកចាយបានខ្លះៗ ទោះបីជា វាហាក់ដូចជាតិចតួចក៏ដោយ។ តាមរយៈការចែកចាយនេះ អ្នករួចផុតពីសេចក្ដីស្លាប់មានអំណាច ដោយសេចក្ដីល្អរបស់ខ្លួនបានធ្វើអោយជីវិតរបស់អ្នកផ្សេងៗទៀតប្រែប្រួល។ យោងតាមរឿងនិទានបុរាណ តាមសេចក្ដីរាយការណ៍ដោយផ្ទាល់ថា មានស្ដ្រីវ័យចំណាស់ម្នាក់បានមកវិហារ (St.Paul) ដោយអាចកំពាំងនៅជិតទីភេរវកម្ម តំបន់លេខសូន្យ ហើយគាត់សុខចិត្តអោយឈើច្រត់របស់គាត់ទៅបុគ្គលិកសង្គ្រោះ និងបុគ្គលិកសំណង់ដែលកំពុងតែអស់កម្លាំងល្ហិតល្ហៃ ដែលបានឈប់សម្រាកនៅតាមផ្លូវដើរ។ ដូចគ្នា នឹងរឿងសូជា និង(Banabas) មូលដ្ឋានការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង គឺ៖ ខ្ញុំព្យាបាលអ្នក ដោយខ្ញុំធ្វើបែបនេះ គឺខ្ញុំព្យាបាលខ្លួនខ្ញុំ អ្នកដែលចូលរួមនៅក្នុងការគិតពីប្រយោជន៍អ្នកដទៃជាងខ្លួនឯង ទោះបីជាគេដឹង ឬមិនដឹងខ្លួន គេពិតជានៅក្នុងមាគ៌ាទៅកាន់ភាពព្យាបាលដោយខ្លួនឯង។

ការធ្វើការងារបែបនេះជាបំណងតែមួយ ដែលសំខាន់ជាងគេរបស់ជនជួបប្រទះភាពតក់ស្លុត ទូទាំងពិភពលោក។ ចាប់តាំងពីជំនាន់ដើមមក បុរស និងស្ដ្រីបានបំពេញកិច្ចការធម្មតាដូចគ្នាៗ ជាច្រើន៖ គេបានបង្កើតសហភាព ហើយបានបង្កើតកូន គេឧបត្ថម្ភខ្លួនគេ និងក្រុមគ្រួសារដោយប្រកបកសិកម្ម ជួញដូរ នេសាទត្រី ទិញ លក់ និងបង្កើតវត្ថុមានប្រយោជន៍ និងវត្ថុល្អៗ។ ចាប់តាំងពីជុំរុំជនភៀសខ្លួននៅប្រទេសថៃ ទៅដល់ប្រទេសកេនយ៉ា (Kenya) ទៅមណ្ឌលឃុំឃាំងនៅអូស្ដ្រាលី(Australia) និងអ៊ឺរ៉ុប(Europe) និងពីខ្ទមស្បូវជនជាតិស៊ូដាន (Sudan0 ទៅអាគារជនភៀសខ្លួនរាប់ខ្នង នៅតំបន់ប្រ៊ង់(Bronx)ខាងត្បូង ជាទីដែលជនរួមផុតពីសេចក្ដីស្លាប់ប៉ងប្រាថ្នាធ្វើការ ដើម្បីចិញ្ចឹមជីវិតខ្លួន ជាឥទ្ធិពលព្យាបាលដ៏អស្ចារ្យ។ មួយខែបន្ទាប់ភូមិនេសាទនៅថៃ បានបាត់បង់ប្រជាពលរដ្ឋពាក់កណ្ដាលពីចំនួនប្រជាពលរដ្ឋ ប្រាំពាន់នាក់ ដោយសារតែព្យុះមហាសមុទ្រ អ្នកនេសាទបានចាប់ផ្ដើមត្រឡប់ទៅនេសាទវិញ។

៤ ការអធិប្បាយអំពីការព្យាយាមរបស់គេបង្ហាញនូវនិមិត្តរូបនៃភាពព្យាបាលដោយខ្លួនឯង៖

- ៦ ក្រុមអ្នកនេសាទ បានសាមគ្គីគ្នាបែបនេះ ហាក់ប្រៀបដូចជា ថ្មេររបួសដែលកំពុងតែភាពជាសះស្បើយបន្តិចម្ដងៗ។ សាច់សារលោហិតរបស់គេ ហាក់បីដូចជាមានគេទាញដាច់ពេញមួយទំហឹងដៃចេញពីសហគមន៍របស់គេ។ គេកំពុងតែនាំគ្នាចាក់ស្រេះកសាងសារជាថ្មី ដោយប្រើអ្វីៗ ដែលមាននៅសេសសល់។
- ៦ ការងារជាភាពមានប្រយោជន៍ខ្លាំងសំរាប់បុគ្គលដែលទើបនិងងើបចេញពីបទពិសោធន៍តក់ស្លុត មូលដ្ឋានសំខាន់បំផុត ជាទូទៅវាជាដំណើរជីវិតរស់នៅ វាជួយរក្សាបុគ្គលអោយមានជីវិតពីមួយថ្ងៃទៅមួយថ្ងៃ។ វាក៏ជាពោងនៃជីវិតសម្រាប់សតិអារម្មណ៍ ដែលធានាអះអាងដល់អ្នករួចផុតពីសេចក្ដីស្លាប់ថា គេពុំអស់សង្ឃឹមទាំងស្រុងនោះទេ ហើយក៏ពុំបាត់បង់អស់រលីងដែរ។

នៅពេលដែលឥទ្ធិពលព្យាបាលដោយខ្លួនឯង ឆាប់ឆេះឡើងនៅក្នុងខ្លួនអ្នករួចផុតពីសេចក្ដីស្លាប់ វាធ្វើអោយគេចង់ប្រកបការងារយ៉ាងខ្លាំង។ ជនភៀសខ្លួនអាយរ៉ាក់(Iraq)ម្នាក់ គឺធ្លាប់ធ្វើជាសម្ព័ន្ធមិត្តរបស់អាមេរិកកាំង ហើយបានចូលរួមនៅក្នុងការបះបោរ ដោយឥតខ្លឹមសារប្រឆាំង និងរបបសាសាំហូស្សេន(Sadam Hussein) នៅក្នុងសង្គ្រាមឈូងសមុទ្រលើកដំបូង បានទទួលអនុញ្ញាតអោយចូលមកសហរដ្ឋអាមេរិក ដោយ

ក្រសួងការបរទេស។គាត់បានធ្វើដំណើរគ្មានទីដម្រកពីរដ្ឋមួយទៅរដ្ឋមួយ ដោយគាត់រកការងារធ្វើពុំបានព្រោះតែលក្ខណៈអន្តោប្រវេសន៍របស់គាត់ពុំច្បាស់លាស់ គាត់បានមកដល់រដ្ឋម៉េន (Maine) ហើយត្រូវប៉ូលីសចាប់បញ្ចូលដាក់ចូលទៅពេទ្យសតិអារម្មណ៍ ក្នុងពេលនោះរឿងរបស់គាត់ ស្តាប់ទៅមានអត្ថន័យហាក់បីដូចជារឿងស្រមើលស្រមៃ។ ចំពោះប៉ូលីសរូបគាត់ហាក់បីដូចជាមានជម្ងឺសតិអារម្មណ៍ធ្ងន់ធ្ងរ គេបានហៅថាមន្ត្រីអន្តោប្រវេសន៍រដ្ឋម៉េន អោយមកបញ្ជាក់លក្ខណៈអន្តោប្រវេសន៍របស់គាត់។ នៅពេលដែលបានជួបមន្ត្រីនេះ បុរសនេះបាននិយាយថា "សូមជួយខ្ញុំ ខ្ញុំត្រូវការការងារធ្វើ" នៅពេលដែលប្រវត្តិរឿងតក់ស្លុតនេះបានទទួលការបញ្ជាក់ច្បាស់លាស់គាត់ក៏បានទទួលការងារធ្វើ ហើយសញ្ញារោគសតិអារម្មណ៍របស់គាត់ ក៏លែងមានទៀតទេ។

រឿងមួយទៀតបានបរិយាយអំពីជនជួបប្រទះភាពតក់ស្លុតម្នាក់ ដែលអាចរកភាពទៅពឹងពាក់ខ្លួននៅក្នុងសង្គមបានដោយខ្លួនឯង។ បុរសខ្មែរវ័យមជ្ឈឹមម្នាក់ ក្រុមគ្រួសាររបស់គាត់បានរួចផុតពីសេចក្តីស្លាប់នៅក្នុងរបបប៉ុលពត គាត់បានទទួលប្រាក់ឧបត្ថម្ភចិញ្ចឹមជីវិតពីរដ្ឋ (វែលហ្វែរ) ហើយគាត់រស់នៅក្នុងតំបន់ឧក្រិដ្ឋកម្មទីទាល់ក្រនៅសហរដ្ឋអាមេរិក។ ជារៀងរាល់យប់គាត់ចាក់សោរខ្លួនគាត់នៅក្នុងបន្ទប់ជួលតូចមួយ គាត់រៀនទន្ទេញសៀវភៅជួសជុលរថយន្តពីមួយទំព័រទៅមួយទំព័រទៀត។ បន្ទាប់ពីរៀនសូត្រតាមសៀវភៅនេះអស់ចំនួនមួយឆ្នាំគាត់ចាប់ផ្តើមជួសជុលឡាន អោយមិត្តភក្តិ និងអ្នកជិតខាង ភាគច្រើនជាជនជាតិផ្សេងៗ ពីជនជាតិខ្មែរ។ កេរ្តិ៍ឈ្មោះគាត់ជាជាងជួសជុលរថយន្តដ៏ជំនាញកាន់តែល្បីឡើង ក្មេងជំទង់នៅក្នុងតំបន់ដែលធ្លាប់សម្លុតគាត់ពេលនេះវាមកសុំដំបូន្មាន ពីគាត់អំពីវិធីជួសជុលរថយន្ត។ ក្រោយមកគាត់ក៏មានការងារធ្វើពេញម៉ោងជាជាងជួសជុលរថយន្តនៅហាងប្រេងឥន្ធនៈ(សាំង)ក្នុងតំបន់ ហើយក៏គាត់ឈប់ទទួលប្រាក់ឧបត្ថម្ភចិញ្ចឹមជីវិតពីរដ្ឋនោះទៀតទៅ។

ពាក្យថា *ការងារ* ជាពាក្យដែលសំដៅពុំត្រឹមតែជាបែបបទនិយមទៅលើការងារនោះទេ តែវាជាសកម្មភាពដែលជួយពង្រឹងសុខុមាលភាពរបស់បុគ្គល ក្រុមគ្រួសារ ឬសហគមន៍។ ការនេសាទត្រី ការបាញ់សត្វ និងការថែចំការ រួមនឹងកិច្ចការផ្ទះផ្សេងៗ ជាច្រើនទៀត ដូចជា ការថែទាំកូន ឬចៅ។ ជាប្រភេទការងារទាំងអស់ អានុភាពការងារ គឺទទួលដឹងឮតិចតួចណាស់ ការស្រាវជ្រាវស្ទើរតែគ្មានធ្វើឡើងទាល់តែសោះ នៅក្នុងឆ្នាំ១៩៩០ ការធ្វើសម្ភាសន៍ជាមួយ និងជនភៀសខ្លួនរាប់ពាន់នាក់បានបញ្ជាក់ជាកត្តាពិតថា ជនជួបប្រទះភាពតក់ស្លុតគ្រប់អាយុនិងកម្រិតវប្បធម៌ មានភាពតស៊ូអត់ធន់ នៅពេលដែលរូបគេចូលរួមប្រកបការងារ។ ទោះបីជាការងារបែបណាក៏ដោយ អោយតែសកម្មភាពនោះជួយដល់ការរស់នៅប្រចាំថ្ងៃរបស់គេ វាមានអានុភាពព្យាបាលដ៏ខ្លាំងក្លា។ ចំពោះជនដែលទទួលរងគ្រោះដោយអំពើសាហាវយង់ឃ្នង ការងារក្លាយជាយុថ្កាដែលទប់ខ្លួនគេអោយ នឹងនៅក្នុងពិភពចាស់របស់គេ នៅខណៈដែលពិភពថ្មីកំពុងតែចាប់ផ្តើមឡើង។

នៅក្នុងពេលព្យាបាលបន្ទាប់ពីភាពឃោរឃៅ ការងារជាត្រីវិស័យដែលបង្ហាញជនរួចផុតពីសេចក្តីស្លាប់នូវទិសដៅ ដែលគេអាចគេចផុតពីសតិអារម្មណ៍អស់សង្ឃឹមភាពទាល់ច្រក។ ការងារមិនត្រឹមតែ ផ្តល់អ្នករួចផុតពីសេចក្តីស្លាប់ នូវឱកាសរកប្រាក់ និងមានប្រយោជន៍នោះទេ តែវាក៏បង្កើតកំណត់ពេលវេលាច្បាស់លាស់ និងទី

កន្លែងដែលគេត្រូវតែមានវត្តមាននៅក្នុងចំណោម ក្រុមមិត្តភក្តិដែលធ្លាប់ស្គាល់ មានរួមទាំងសត្វពាហនៈ និងគ្រឿងម៉ាស៊ីនឧស្សាហកម្ម ហើយផ្តល់អត្ថន័យទាំងស្រុងទៅលើគោលដៅ និងតម្លៃការងារ។ ការងារផ្តល់មជ្ឈដ្ឋានសំរាប់មិត្តភាព និងទំនាក់ទំនងស្និទស្នាល។ ហើយវាក៏ផ្តល់ឱកាសអោយអ្នករួចផុតពីសេចក្តីស្លាប់ចាត់សេចក្តីគិតអំពីរឿងតក់ស្លុតរបស់ខ្លួនទុកមួយឡែក យ៉ាងហោចណាស់ជាបណ្តោះអាសន្ន នៅពេលដែលគេកំពុងតែផ្តោតអារម្មណ៍ទៅលើការងាររបស់គេ។ តាមរយៈការងារអ្នករួចផុតពីសេចក្តីស្លាប់ប្រើជំនាញចាស់ ហើយរៀនជំនាញថ្មីៗ និងកំពុងតែជួសជុលជីវិតបែកខ្ញែកបន្តិចម្តងៗ ប្រៀបដូចជា ភាពភ្ជាប់ជុំឥដ្ឋមួយជុំម្តងៗ។

ការងារជាកត្តាមួយ ដ៏ស្មុគស្មាញនៅក្នុងការព្យាបាលសតិអារម្មណ៍អាម៉ាស់មុខ វាពិតជាអាចមានឥទ្ធិពលដូចជា ថ្នាំផ្សះភាពអាម៉ាស់មុខ ដោយការងារអាចបង្កើនសេចក្តីគោរពនៅក្នុងរង្វង់គ្រួសារ និងសហគមន៍ ដល់ជនទាំងអស់ដែលរកប្រាក់មកចិញ្ចឹមជីវិតខ្លួនគេ។ តែភាពអាម៉ាស់មុខ ក៏អាចកើនឡើងក្រោយពីអំពើឃោរឃៅបានបញ្ចប់ ដោយភាពគ្មានការងារធ្វើ និងភាពជម្រុញអោយមានការពឹងផ្អែក។ ឪពុកដែលពុំអាចរកអ្វីមកចិញ្ចឹមក្រុមគ្រួសារ ម្តាយដែលពុំអាចថែទាំកូនបាន គឺមានភាពអាម៉ាស់មុខនៅក្នុងរង្វង់កែវភ្នែកកូនរបស់ខ្លួន អ្នកជិតខាង និងខ្លួនឯង។ ឪពុកអាចមានអារម្មណ៍ក្រេវក្រោធ និងគ្មានសមត្ថភាពដោយហេតុនេះ កូនរបស់គេជាពិសេស ក្មេងយុវវ័យវាលែងគោរពឪពុកទៀត។ ជនភៀសខ្លួនជាច្រើនបាន រាយការណ៍ថា ឪពុកខ្លួនគ្មានបានការ គ្មានតម្លៃអ្វីទេ ស្ត្រីជនភៀសខ្លួនអាចជៀសផុតពីភាពវាយតម្លៃរបស់កូនខ្លួន តែគេអាចមានអារម្មណ៍ដូចកូនដែរ ដោយគេក្តៅក្រហាយទៅលើស្វាមីរបស់ខ្លួនដែលពុំអាចចិញ្ចឹមក្រុមគ្រួសារបាន។

ផ្ទុយនឹងមូលហេតុជាច្រើន ដែលជនរួចផុតពីសេចក្តីស្លាប់ត្រូវប្រកបការងារនោះ ប្រព័ន្ធនយោបាយដែលគេប្រឈមមុខទូទាំងសកល គឺព្យាយាមបង្ខំអោយគេពឹងផ្អែកទៅលើប្រព័ន្ធនោះ ហើយរក្សាភាពអត់ការងារធ្វើ។ វាជាភាពងាយស្រួលហើយចំណាយតិច ដោយទុកមនុស្សអោយនៅស្ងៀម និងគ្មានការងារធ្វើ អ្នករួចផុតពីសេចក្តីស្លាប់ ដឹងអំពីបែបបទនេះហើយគេបានខិតខំអស់ពីសមត្ថភាពធ្វើអោយខ្លួនគេក្លាយជាជនទីពឹងខ្លួន។ ដើម្បីអោយក្លាយទៅជាជនទីពឹងខ្លួន ជាញឹកញាប់គេត្រូវតែធ្វើល្បិចកលបន្លំប្រព័ន្ធដែលធ្វើឡើងសំរាប់ជួយគេទៅវិញ។ បុគ្គលិកសង្គ្រោះជាច្រើន ឧទាហរណ៍ មានការមន្ទិលសង្ស័យនៅពេលដែលមនុស្ស ដែលខ្លួនបានជួយអោយបានលួចខ្លួននោះ ហើយអ្នកទាំងនោះគ្មានបញ្ចេញភាពថ្លែងអំណរគុណ ទៅលើសេចក្តី ព្យាយាមដែលគេបានជួយដល់អ្នកទាំងនោះឡើយ។ នៅពេលដែលអ្នកព្យាបាល ឬអ្នកនយោបាយមិនពេញចិត្តទៅលើភាពអនាធិបតេយ្យរបស់ជនរួចផុតពីសេចក្តីស្លាប់ ជនរួចផុសពីសេចក្តីស្លាប់ទៅជាជឿថាវោហារសាស្ត្រភាព និងសកម្មភាពរបស់អ្នកដែលមកជួយរូបគេនោះជាទុច្ចរិតភាព។ អ្នករួចផុតពីសេចក្តីស្លាប់ក៏សម្របសម្រួលទទួលយកមធ្យោបាយជាសាធារណៈនោះ ដោយដើរតួរជាជនគ្មានទីពឹង ហើយទន្ទឹម និងនេះគេក៏បានបង្កើតប្រយោជន៍សេដ្ឋកិច្ចសំរាប់ខ្លួនគេជាសម្ងាត់។ នៅគ្រា ដែលយើងនៅក្នុងប្រទេសបូស្សនា(Bosnia) យើងបានចូលទៅភូមិតូចមួយ ដែលល្បីថាកំពុងតែជួបប្រទះភាពលំបាកបំផុត។ ក្រុមគ្រួសារស្ទើតែទាំងអស់ បានបាត់បង់សមាជិកដោយសង្គ្រាមថ្មីៗ នេះ។ រោងចក្រគ្មានដំណើរការ គ្មានការងារធ្វើ អ្នកភូមិស្ទើរតែមិនរស់ ដោយពឹងផ្អែកទៅលើតែផលិតផលកសិកម្មដែលផលិ

តឡើងនៅក្នុងតំបន់របស់ខ្លួន ហើយស្ថានភាពអនាគត ផ្នែកឧស្សាហកម្មក៏ពុំមានទិសដៅដែរ។ ឱកាសដ៏សំខាន់ៗ បានខាតបង់ដោយ ផ្នែកវិវឌ្ឍន៍ភាពសហគមន៍អន្តរជាតិ ក្រោយពីកិច្ចព្រមព្រៀងសន្ធិសញ្ញាសន្តិភាព (Dayton Peace Accord) 1995 បានបញ្ចប់។ ប្រជាជនបានខិតខំប្រមូលកម្លាំង ដើម្បីបង្កើតជីវិតថ្មីរបស់គេ តែគេគ្មានឱកាសអនុវត្តន៍គំរោងកាណ៍នោះឡើយ នៅសូម៉ាលីយ៉ា(Somalia) ស៊ូដាន(Sudan) វ៉ាន់ដាន (Rwandan) ទីម័រខាងកើត (East Timor) ប្រទេសដែលរងគ្រោះដោយមហាព្យុះសមុទ្រ និងព្យុះសង្ឃរា ដែលធ្វើអោយមានមហន្តរាយដល់តំបន់អាមេរិកកាំងខាងត្បូង ជនជួបប្រទះភាពតក់ស្លុតទាំងនេះក៏ពុំអាចរង់ចាំប្រាំឆ្នាំ ដើម្បីរកការងារថ្មីធ្វើឡើយ គេត្រូវការធ្វើការនៅក្នុងនេះ។

នៅជុំរុំសាយធូ នៅក្នុងកំឡុងឆ្នាំ១៩៨០ ជនជាតិខ្មែរ ដែលរួចផុតពីសេចក្ដីស្លាប់ ពីរបបប៉ុលពត ត្រូវគេហាមពុំអនុញ្ញាត អោយធ្វើស្រែចំការ ឬប្រកបការងារផ្សេងៗ ជាងមួយទសវត្សតែអង្គការសហប្រជាជាតិ និងសហគមន៍ សង្គ្រោះអន្តរជាតិគាំទ្រច្បាប់នេះ ដោយចែកម្ហូបជាអង្ករ និងត្រីមកពីប្រទេសជប៉ុន ហើយគេបានដកហូតសេរីភាពពិតពីភាពជាសះស្បើយ ដោយពុំអោយមានសាលារៀន ការងារ និងឱកាសសម្រាប់ប្រារព្ធពិធីសាសនា ឬពិធីសង្គមផ្សេងៗ។ ជនជាតិថៃ បានហៅច្បាប់នេះថា ជាច្បាប់កម្រិត ចំនួនជិវិតមនុស្សអោយនៅកម្រិតតិច *ទប់ស្កាត់ចំនួនមនុស្សកុំអោយកើនឡើង* ។ បច្ចុប្បន្ននេះ ជុំរុំជនភៀសខ្លួនជាច្រើននៅប្រទេសអាហ្វ្រិក និងអាស៊ីបានធ្វើតាមសិក្ខាបទនេះ។ ប្រទេសខ្លះៗ ដែលជាប្រទេសស្នាក់អាស្រ័យដំបូង បានផ្ដត់ផ្ដងជនភៀសខ្លួនដោយវិធីកំណាញ់ និងខ្វះសីលធម៌។ ជនដែលរកទីស្នាក់អាស្រ័យនៅប្រទេសអូស្ត្រាលី ភាគច្រើនបានទទួលទារុណកម្មនៅក្នុងមាតុប្រទេសរបស់ខ្លួនរួចទៅហើយ នៅពេលគេមកដល់ប្រទេសអូស្ត្រាលីត្រូវគេចាប់យកឃុំទុកនៅក្នុងជុំរុំគុកដាច់ស្រយ៉ាល ក្នុងស្ថានភាពសាហាវឃោរឃៅ ទោះបីជារូបគេបានទទួលទុក្ខសោកសង្រេង ហើយជាកត្តាពិតគេពុំបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មអ្វីក៏ដោយ គេធ្វើដូច្នេះ គឺដើម្បីហាមអ្នកផ្សេងៗទៀតកុំអោយចូលមកប្រទេសអូស្ត្រាលី។

នៅអឺរ៉ុប គេក៏បានបដិសេធពុំផ្ដល់ការងារ ដល់ជនជួបប្រទះភាពតក់ស្លុត ដែលមកសុំច្បាប់ ស្នាក់អាស្រ័យ។ ប្រទេសស្វីស (Switzerland) ជាប្រទេសដែលមានច្បាប់ស្នាក់អាស្រ័យជឿនលឿនជាងគេនៅក្នុងពិភពលោក ដោយគេផ្ដល់ប្រាក់ជំនួយ និងឧបត្ថម្ភផ្នែកសង្គមកិច្ចច្រើន។ ក្រៅពីផ្ទះសម្បែងដ៏ល្អប្រណិត និងផលប្រយោជន៍សង្គមកិច្ច អ្នកមកសុំទីស្នាក់អាស្រ័យនៅប្រទេសស្វីសពុំអាចប្រកបការងារបាន លុះត្រាតែគេអាចនិយាយភាសាស្វីសបានស្ទាត់ជំនាញ។ នៅករណីដែលគេបានសម្រេចជោគជ័យទៅលើកម្រិតភាសាដែលស្ទើរតែ ពុំអាចធ្វើបាននោះ មានការងារតិចណាស់សម្រាប់ពួកគេ។ កម្រិតចំនួនប្រជាជនរកទីស្នាក់អាស្រ័យនៅប្រទេសស្វីសដែលមានទុក្ខកង្វល់ មានកំរិត ចំនួន៤០ភាគរយ។

នៅក្នុងសហរដ្ឋអាមេរិក ដំណើរការរួមបញ្ចូលសម្រាប់ជនភៀសខ្លួន រាប់លាននាក់ នៅដំណាក់កាលដំបូង គឺមានរួមទៅដោយជំនួយឧបត្ថម្ភ ជាបែបបទលះបង់ ឬអាចហែលឆ្លងក្នុងទីផ្សារការងារ។ ជនភៀសខ្លួនមានសក្ដានុភាព (ដែលអាចកើតមានឡើង) ធំធេងក្នុងការទទួលជោគជ័យទៅលើសេដ្ឋកិច្ច ឬទទួលបរាជ័យដ៏

ធំ។ ប្រព័ន្ធសុខាភិបាល (សុខភាព) និងសុខុមាលភាព (វែលហ្វែរ) ប្រចាំរដ្ឋជាកត្តាដ៏ធំមួយ នៅក្នុងភាពបរាជ័យរបស់ជនភៀសខ្លួនជាច្រើនរូប។ ភាពពិការដោយសុខភាព និងសតិអារម្មណ៍ ដោយមកពីទុក្ខកង្វល់ និងអារម្មណ៍តានតឹង នៃភាពតក់ស្លុតខុសប្រក្រតីរបស់ជនភៀសខ្លួន ត្រូវគេចាត់អោយទទួលប្រាក់វែលហ្វែរ ដែលភាគច្រើពុំមាន ចំនួនគ្រប់គ្រាន់សម្រាប់ការរស់នៅ។ ជនភៀសខ្លួនតិចណាស់ដែលត្រឡប់ទៅធ្វើការវិញ នៅពេលដែលគេទទួលប្រាក់ឧបត្ថម្ភពីរដ្ឋ(អេសអេសអាយSSI) ដោយគេគ្មានទទួលការហ្វឹកហ្វឺន ផ្នែកការងារ ហើយទីផ្សារការងារពុំមានការឧបត្ថម្ភផ្នែកសុខភាព។ ជាកត្តាពិតប្រព័ន្ធសុខុមាលភាពបានជំរុញជនភៀសខ្លួនអោយនៅតែរក្សាភាពពិការរបស់ខ្លួន បើពុំដូច្នេះទេ គេនឹងបាត់បង់ផលប្រយោជន៍របស់គេ។ ដោយសារផ្នែកសង្គមកិច្ចសម្រាប់ជនភៀសខ្លួនអោយនៅ "ធ្វើការធ្វើអ្វី? បើអ្នកអាចនៅទទួលជំនួយឧបត្ថម្ភសម្រាប់ ការរស់នៅកម្រិតទាប ក៏ដោយការទទួលប្រាក់ពិការ វាជាការប្រសើរបំផុត បើនៅឈឺជានិច្ច" ។ នៅ ខណៈ ដែលជនភៀសខ្លួនជាច្រើននាក់ពុំយល់ស្របតាមគំរោងនេះ ចំពោះជនដែលទទួលប្រាក់ពិការភាព ហើយត្រូវផ្លាស់ប្តូរទៅប្រកបការងារវិញ ជាករណីនេះដែល សឹងតែពុំអាចទៅរួច ពីព្រោះគេបានទទួលផលប្រយោជន៍យ៉ាងតិចតួចពីការងារគេត្រឡប់ទៅធ្វើការវិញ។ ទូទាំងពិភពលោក និងនៅក្នុងសហរដ្ឋអាមេរិក ការគិតគំនិតសោះអង្គើយខ្លាំងជាងគេក្នុងការដោះស្រាយអំពើសាហាវយង់ឃ្នង គឺភាពរកការងារជាបន្ទាន់សំរាប់ជនជួបប្រទះភាពតក់ស្លុត។

## ១.៣ ជំនឿ

ភាពបន្ថយសេចក្តីឈឺចាប់របស់មនុស្សលោក ជាចំណុចសំខាន់ៗក្នុងការព្យាបាលសុខភាព និងសតិអារម្មណ៍។ តែគួរអោយស្តាយណាស់ ដោយថ្នាំពេទ្យពុំអាចព្យាបាលភាពខូចខាតផ្លូវចិត្ត និងផ្នែកសង្គមដែលបានកើតមានឡើងដល់ជនរួចផុតពីសេចក្តីស្លាប់ដោយអំពើសាហាវឃោរឃៅ។ ជនរងគ្រោះទាំងនេះ ជាញឹកញាប់ទទួលបទពិសោធន៍ឈឺចាប់ ដែលគេពុំធ្លាប់ទទួលពីមុនមក។ វាអាចកើតឡើងយ៉ាងងាយស្រួលទៅលើជនរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ ដូចគ្នា និងជនរួចផុតពីសេចក្តីស្លាប់។ ខ្លឹមសាររឿងបុព្វបុរសប្រទេសក្រិច (Philoceltetes)បានអធិប្បាយបានថា បុព្វបុសដែលរងរបួស គឺគេបានទទួលការព្យាបាលពីព្រោះ ភាពរស់នៅលើទឹកដីចម្លែកជាទីដែលភាពតក់ស្លុត និងសេចក្តីឈឺចាប់របស់គេ បានប្រែក្លាយទៅជាភាពទូទៅមួយចំណែកនៅក្នុងជីវិតរបស់គេទៅហើយនោះ។ ហេតុដូច្នេះ ជនជួបប្រទះភាពតក់ស្លុតជាញឹកញាប់ច្រើនគោរពអាទិទេពអោយជួយរូបគេ។

ជនរួចផុតពីសេចក្តីស្លាប់គ្រប់ទីកន្លែងនៅក្នុងពិភពលោក ឧទាហរណ៍ បាននិទានរឿងអស្ចារ្យដូចៗ គ្នាអំពីតួនាទី របស់ព្រះអាទិត្យ និងតារា(ផ្កាយ) នៅក្នុងភាពរួចផុតពីសេចក្តីស្លាប់របស់គេ ការសម្លឹងទៅលើឋានសួគ៌ គេបានឃើញអន្តិភាព(គ្មានទីបញ្ចប់) ដែលគ្មានប៉ះពាល់ដោយសកម្មភាពមនុស្សលោកឡើយ។ ផ្កាយជួយរក្សាគេអោយមានជីវិត នៅពេលដែលគេកំពុងតែទទួលទារុណកម្មនៅក្នុងជុំរុំអប់រំ ឬនៅក្នុងគុក។ ជារៀងរាល់ ព្រឹកព្រះអាទិត្យបានបញ្ចេញរស្មីឡើង ហើយបានដាស់តឿនថា រូបគេបានរួចផុតពីសេចក្តីស្លាប់ មួយថ្ងៃទៀតហើយ។

ហ្វូងផ្កាយជាភាពអចិន្ត្រៃយ៍នៃធម្មជាតិ វាជាតំណាងជីវិតអចិន្ត្រៃយ៍ វាជាឥទ្ធិពលដែលពុំអាចបន្ថយចុះដោយអំពើសាហាវយង់ឃ្នងរបស់មនុស្សលោក។ ការយកលំដាប់តាមចលនារបស់ផ្កាយ ទោះបីជាតែមួយភ្លែតក៏ដោយអ្នករួចផុតពីសេចក្តីស្លាប់អាចដកខ្លួនគេចចេញពីភាពឃោរឃៅ នៃជីវិតនៅលើផែនដី។

អ្នករួចផុតពីសេចក្តីស្លាប់មើលទៅក្នុងអារម្មណ៍របស់ខ្លួនគេ ហើយជាញឹកញាប់គេរកឃើញជំនឿ និងតម្លៃដែលគេបានកំណត់ទុករួចទៅហើយ។ គេមានអារម្មណ៍ល្អទៅ និងជំនួយរបស់ព្រះ ទោះបីជាព្រះពុទ្ធ ព្រះអាឡា (ឥស្លាម) ព្រះយ៉ាវេ (ហ៊ីប្រ៊ូ) ឬព្រះយ៉េស៊ូ។ ជំនឿទៅលើអាទិទេពអំពីជីវិតមានរួមទាំង ការបួងសួងដល់ដួងព្រលឹង អាចការពារ និងជួយអ្នករួចផុតពីសេចក្តីស្លាប់នៅក្នុងឱកាសដែលគេត្រូវការបំផុត។ នៅពេលដែលអារម្មណ៍របស់ជនជួបប្រទះភាពតក់ស្លុតបានជួបប្រទះ និងភាពរឹករវដោយអំពើឃោរឃៅ ដួងវិញ្ញាណអាចជួយការពារមនុស្សកុំអោយក្លាយទៅជាជនស្លុតរន្ធត់ទាំងស្រុង។ អ្នករួចផុតពីសេចក្តីស្លាប់ភាគច្រើននៅក្នុងអារម្មណ៍របស់គេ គេបានគិតថាព្រលឹងឪពុកម្តាយរបស់គេជួយគាំទ្ររូបគេ ហើយអ្នកខ្លះព្យាយាមរស់ ដើម្បីកូនរបស់គេ។ អ្នកខ្លះប្រើកម្លាំងទឹកចិត្តទៅតាមជំនឿ នយោបាយរបស់គេ និងសេចក្តីប្តេជ្ញារបស់គេ ដើម្បីយុត្តិធម៌ សង្គម។ គំនិតរបស់គេផ្តល់នូវចំណុចមួយ ដែលគេអាចចេញចូលបានគ្រប់ពេលទៅតាមសេចក្តីប្រាថ្នា ទោះបីជារូបគេជាប់ឃុំឃាំងនៅក្នុងជញ្ជាំងគុក ឬនៅក្នុងជុំរុំជនភៀសខ្លួនក៏ដោយ។

ទស្សនវិទូសម័យបុរាណស្សេណេកា (Seneca) បានសង្កេតឃើញថា អ្នករួចផុតពីសេចក្តីស្លាប់ភាគច្រើនដឹងទុកជាមុនះ

"ភាពពិតនៃសន្តិភាពអាចរកឃើញនៅក្នុងខ្លួនយើង ពុំមែនរកឃើញដោយភាពផ្ទាល់ប្តូរនៅពិភពលោកខាងក្រៅឡើយ" ។

ឥទ្ធិពលព្យាបាលដោយសកម្មភាពអារម្មណ៍ បានឆ្លងកាត់ការពិនិត្យដោយវិទ្យាសាស្ត្រ ការស្រាវជ្រាវដោយជីវសាស្ត្រ និងបទពិសោធន៍ជាក់ស្តែង បានបញ្ជាក់ថាការផ្លាស់ប្តូរអាក្រក់ទៅលើកាយសម្បទា ដែលទាក់ទង និងបទពិសោធន៍ជីវិតមិនល្អ អាចទប់ស្កាត់បានដោយអនុវត្តន៍តាមទំនៀមទម្លាប់របស់មនុស្សលោក ដូចជា ការបន់ស្រន់ ភាវនា វិធីអធិដ្ឋានតាមជំនឿសាសនា និងក្រុមដែលផ្តោតអារម្មណ៍ទៅលើការថែទាំខ្លួន។[11] នៅពេលដែលសីលធម៌ និងតម្លៃរបស់យើងត្រូវបំផ្លាញដោយអំពើឧក្រិដ្ឋកម្ម ជំនឿដ៏មុះមុតអាចទប់ស្កាត់ភាពទន់ខ្សោយរបស់យើងពីភាពស្រងាកចិត្តពន់ពេក ហឹង្សា និងសេចក្តីអស់សង្ឃឹម។ បាតុភូតនេះមានឃើញដោយច្បាស់ នៅក្នុងករណីឈ្លើយសង្គ្រាម POWs អ្នករួចផុតពីសេចក្តីស្លាប់ដោយទារុណកម្ម និងជនភៀសខ្លួន ដែលបានបំព្រួញសង្ខេបដោយ លោកណេលស៊ិន ម៉ិនដែលឡា (Nelson Mandela) ប្រធានាធិបតីជនជាតិស្បែកខ្មៅដំបូងគេនៅប្រទេសអាហ្វ្រិកខាងត្បូង។ ក្រោយពីគេបានដោះលែងគាត់ចេញពីការឃុំឃាំងវាយជំដាង ម្ភៃប្រាំពីរឆ្នាំ នៅក្នុងរបបប្រកាន់ពូជសាសន៍ គាត់បានរិះរកដំណោះស្រាយជាជាងភាពសងសឹក។ នៅក្រោមច្បាប់គ្រប់គ្រងគណៈកម្មាការសច្ចៈសម្រុះសម្រួលប្រទេសអាហ្វ្រិកខាងត្បូវ ជនរងគ្រោះ រាប់ពាន់នាក់បានបញ្ចេញកំរិត

តស៊ូដ៏អស្ចារ្យប្រហាក់ប្រហែលគ្នា ជាលទ្ធផលដែលកើតមានឡើងដោយជំនឿមុះមុត និងបែបបទដឹកនាំ ផ្នែកនយោបាយ។

ជាអកុសលអ្នករួចផុតពីសេចក្តីស្លាប់ ជាញឹកញាប់ពុំបានទទួលរៀនសូត្រអំពីរបៀបដោះស្រាយទៅលើអារម្មណ៍ទោរទន់ទាំងស្រុងនោះទេ ជាលទ្ធផលគេក្លាយទៅជាវង្វេង នៅក្នុងព្យុះសង្ឃរាអារម្មណ៍អាក្រក់។ ឪពុកម្នាក់មានកូនប្រុសម្នាក់ធ្វើទាហ៊ាន កូននោះបានស្លាប់ក្នុងពេលថ្មីៗនេះ នៅប្រទេសអ៊ីរ៉ាក់ (Iraq) គាត់ពុំអាចទ្រាំនិងអារម្មណ៍ខ្លោចផ្សារ និងទុក្ខសោកដែលគាត់ទទួលបទពិសោធន៍នៅពេលដែលគាត់ឃើញរូបថតកូនរបស់គាត់កាលពីកុមារភាព។ ម្តាយម្នាក់ ចំនួន ពីរឆ្នាំក្រោយ ពីភេរវកម្មថ្ងៃទី១១ ខែ កញ្ញា នៅតែយំយែកនៅពេលគាត់ហៅឈ្មោះកូនប្រុស ដែលបានស្លាប់ទៅហើយនោះ។ បុរសខ្មែរម្នាក់ នៅតែអង្គុយសោកស្តាយចំនួន ម្ភៃប្រាំឆ្នាំក្រោយមក នៅពេលដែលគាត់នឹកឃើញថាគាត់ពុំអាចយកថ្នាំទៅអោយកូនរបស់គាត់ដែលឈឺជិតស្លាប់នៅក្នុងជំរុំខ្មែរក្រហមនៅក្បែរនោះបាន។

តែនៅពេលដែលភាពព្យាបាល ដោយខ្លួនឯងបានបង្ហាញចេញតាមរយៈសកម្មភាព និងគំនិតជាបែបបទជំនឿអារម្មណ៍នោះពុំអាចបែកខ្ចាយដោយគ្មានទិសដៅឡើយ។ អារម្មណ៍បានទទួលការទប់ស្កាត់ដោយបែបបទពិធីសាសនា និងទំនៀមទម្លាប់ច្បាស់លាស់ ដែលផ្តល់កំណត់ពេល និងទីកន្លែងពិតដល់អ្នករួចផុតពីសេចក្តីស្លាប់អោយបញ្ចេញអារម្មណ៍ និងការយល់ដឹងរបស់គេ។ ការចូលរួមនៅក្នុងពិធីទំនៀមទម្លាប់សាសនា តម្រូវអោយមានវិន័យ ដើម្បីទប់ស្កាត់អារម្មណ៍ និងសេចក្តីប្តេជ្ញា ដើម្បីធ្វើអោយអ្វីៗទាំងនោះមានខ្លឹមសារឡើងវិញ។

ទំនៀមទម្លាប់សាសនា អាចជាវិធីឯនជនតូចមួយ ផងដែរចរិតអំពើឃោរឃៅរបស់មនុស្សលោកជាករណីហួសវិស័យ ដូចគ្នា និងភាពព្យាបាលអោយជាសះស្បើយដែរ លើកតែយើងបែងចែកវាអោយទៅជាចំណែកតូចៗធ្វើអោយវាមានខ្លឹមសារឡើង។ ដូចមានចែងឡើងនៅក្នុងធម៌ព្រះពុទ្ធអំពើបុរសម្នាក់ដែលស្រែកទឹកខ្លាំង ហើយបានអោនយកមាត់លិទ្ធតំណក់ទឹកនៅលើដី។ វិធីសាសនាតិចតួចជាប្រចាំថ្ងៃ មានរួមទាំងការបន់ស្រន់ ភាវនាការកត់ទុករឿងហេតុ និងការបណ្តុះបណ្តាលភាពរីករាយ ជាទូទៅក្នុងដំណើរជីវិត អាចបង្កើតលទ្ធផលមានប្រសិទ្ធិភាពដល់ភាពព្យាបាលនៅពេលក្រោយមក។

នៅក្នុងឆ្នាំ២០០០ នៅពេលដែលប្រទេសទីម័រខាងកើត (East Timor) បានព្យាយាមទាមទារ ឯករាជ្យពីប្រទេសឥណ្ឌូណេស៊ី (Indonesia) នៅក្នុងពេលដកថយអ្នកកាន់ក្តាប់ប្រទេសឥណ្ឌូណេស៊ី និងអ្នកជំនួយក្នុងតំបន់បានធ្វើអ្វីៗគ្រប់យ៉ាងកំទេចបំផ្លាញអ្វីៗដែលនៅសេសសល់ មានរួមទាំងសាលារៀនពេទ្យផង។ ផ្ទះរបស់អគ្គនាយកសាលាក៏ត្រូវគេកំទេចចោលទ្រុឌទ្រោម។ តែនៅមួយយប់នោះ នៅពេលដែលប្រពន្ធ និងកូនគាត់កំពុងតែយកចិត្តទុកដាក់ គឺជាពេលដែលគាត់ទទួលពិធីជប់លៀងអាហារល្ងាចអ្នករួមការងារជនជាតិអូស្ត្រាលី និងរូបខ្ញុំ។ គាត់ទទួលយើងដោយមានម្ហូបអាហារដ៏ឆ្ងាញ់ពិសារ ប្រហែលជាម្ហូបអាហារបម្រុងទុកសំរាប់តែក្នុងគ្រួសាររបស់គាត់នៅក្នុងអាទិត្យនោះ។ គ្រឿងសង្ហារឹមនៅក្នុងបន្ទប់ទទួលភ្ញៀវក្រៅពី កៅអី មានតែទូរឈើខ្ពស់មួយគត់មានរូបព្រះនាងម៉ែរ៊ី( Virgin Mary) ។ នៅពេលដែលសួរឡើងថាហេតុអ្វីបានជាគេមិនកំទេច ព្រះនាងចោលនៅ

ពេលដែលគាត់បានរត់គេចខ្លួន ប្រជាជន(East Timor) ញញឹមហើយមើលមុខគ្នា កូនស្រីតូចរបស់អគ្គនាយក សើចតិចៗ ព្រមគ្នា និងពេលដែលអគ្គនាយកបានពន្យល់ថា "នៅពេលដែលយើងរត់គេចទៅលើភ្នំ ដើម្បីគេចពីអំពើសម្លាប់រង្គាល គ្នាយើងប្រាំនាក់ សែងទូរនេះ និងព្រះនាងម៉ែរ៉ី(Virgin Mary)ទៅក្នុងព្រៃ។ ព្រះនាង បានរស់នៅជាមួយយើងរហូត ព្រះនាងការពារយើង តើយើងអាចទុកព្រះនាងចោលអោយពួកឈ្លានពានបំផ្លាញភាពបរិសុទ្ធរបស់ព្រះនាងឬ? ព្រះនាងជាមាតារបស់យើង"។ អ្នករួចផុតពីសេចក្តីស្លាប់ទាំងអស់នេះដឹងច្បាស់ថា អាយុជីវិតរបស់គេ គឺពឹងផ្អែកទៅលើការថែរក្សាពិតពជំនឿសាសនារបស់គេ។

អំពើដ៏សាហាវយង់ឃ្នងអាចបង្កើតទំនាក់ទំនងថ្មី រវាងអ្នករួចផុតពីសេចក្តីស្លាប់ និងប្រភពទ្រទ្រង់ជំនឿសាសនា ហើយគ្រឹះស្ថានសាសនាបែបប្រពៃណីនិយម ត្រូវសម្របសម្រួលបត់បែនទៅតាមភាពផ្លាស់ប្តូរនេះ ។ គ្រឹះស្ថានសាសនាសំខាន់ៗ ដែលពេញនិយមនៅបូស្សនា (Bosnia) ប្រទេសកម្ពុជា វ៉ាន់ដាន(Rwandan) និង (East Timor) បានឆ្លងកាត់ភាពផ្លាស់ប្តូរដ៏ធំធេងបន្ទាប់ពីការប្រយុទ្ធប្រឆាំង។ នៅប្រទេសកម្ពុជានៅក្នុងរបបខ្មែរក្រហម ទោះជាគ្រឹះស្ថានសាសនា ត្រូវកំទេចចោលស្ទើរតែទាំងអស់ក៏ដោយ ប្រជាជនបានកសាងវត្តអារាមព្រះពុទ្ធឡើងវិញ មុននឹងគេសាងសង់ផ្ទះសម្បែងរបស់ខ្លួនគេ។ សាសនាឥស្លាម និងសាសនាកាតូលិកបានរីកចំរើនជាលំដាប់លំដោយ ជាពិសេសនៅប្រទេសបូស្សនា ជារដ្ឋអតីតកុម្មុយនិស្ត និងប្រទេសទីម័រខាងកើត។ អ្នកនិយមជំនឿធម្មជាតិ និងផ្នែកព្យាបាលបុរាណនៅវ៉ាន់ដាន និងទីម័រខាងកើតបានកែសម្រួលទំនៀមទម្លាប់ ប្រចាំតំបន់ និងបុរាណរបស់គេ ដើម្បីសម្របទៅតាមអំពើមហាសាហាវយង់ឃ្នង។ នៅវ៉ាន់ដាន ឧទាហរណ៍ ជនជាតិហ្គាកាកា (gacaca) បានយកច្បាប់យុត្តិធម៌កុលសម្ព័ន្ធ ឬច្បាប់យុត្តិធម៌ប្រចាំតំបន់មកប្រើក្នុងការកាត់សេចក្តីដាក់ទណ្ឌកម្ម និងការអោយចូលរួមនៅក្នុងសហគមន៍ប្រចាំតំបន់ ដល់ជនដែលបានរៀបចំការសម្លាប់ និងរំលោភបំពានផ្លូវភេទនៅក្នុងសម័យសម្លាប់រង្គាល។ ខ្លឹមសារទំនៀមទម្លាប់ទៅលើករណីលើកលែងទោស ផ្នែកតុលាការរបស់ហ្គាកាកា បានបញ្ជាក់ចាត់ទុកទណ្ឌកម្ម ជាសេវា សហគមន៍ជាវិធី ដើម្បីបណ្តុះបណ្តាលភាពដោះស្រាយសម្របសម្រួល។

ផ្ទុយទៅវិញ នឹងខ្លឹមសារជំនឿឯកជននៅកម្រិតសហគមន៍ ឥទ្ធិពលព្យាបាល ផ្នែកគ្រឹះស្ថានសាសនាប្រពៃណីយនិយម នៅក្នុងសង្គមមុនសម័យសង្គ្រាមកើតមានឡើងជាករណី មិនច្បាស់លាស់។ នៅប្រទេសខ្លះដូចជា អេលស្សាវ៉ាឌ័រ (El Salvador)វិហារកាតូលិក បានការពារប្រជាជនពីអំពើសាហាវយង់ឃ្នង តែនៅទីផ្សេងៗទៀត ដូចជានៅវ៉ាន់ដានវិហារកាតូលិកចាត់ទុកជាទីសម្លាប់រង្គាល ដោយសហធម្មិក(អាចារ្យ)បានចូលរួមនៅក្នុងអំពើសម្លាប់ព្រៃផ្សៃ។ កេរកម្មរបស់ជនជាតិឥស្លាម បានទទួលការទិតៀនដោយរដ្ឋាភិបាល និងគ្រឹះស្ថានសាសនា ធ្វើអោយមានការរិះគន់យ៉ាងខ្លាំងទៅលើបែបបទអំពើឧក្រិដ្ឋកម្មដែលរៀបចំ ឡើងដោយផ្នែកសាសនា។ មានសាសនាជាច្រើនគ្រប់សណ្ឋានទាំងអស់ បានទទួលស្លាកស្នាមដោយតួនាទីចូលរួមរបស់គេនៅក្នុងអំពើមហាសាហាវយង់ឃ្នង ទោះជាភាពចូលរួមនោះជាប្រភេទសកម្ម ឬជាភាពយល់ព្រមស្ងាត់ៗ ឬជាភាពអាក់ខានពុំបានផ្តល់ជំនួយនៅក្នុងភាពស្តារអោយមានភាពដូចដើមវិញក៏ដោយ។

នៅក្នុងសង្គមជាច្រើន មូលដ្ឋានគ្រឹះស្ថានសាសនាជួប និងភាពលំបាកក្នុងការជួយស្ត្រីដែលជួបប្រទះនិងអំពើរំលោភបំពានផ្លូវភេទ ទាំងកំរិតសាសនាវិទ្យាទៅលើតួនាទីរបស់ស្ត្រី ទាំងទស្សនៈបុរាណទៅលើផ្លូវភេទ និងភាពបរិសុទ្ធរបស់ស្ត្រី។ ជិតពីរទសវត្សមកហើយដែលព្រះសង្ឃខ្មែរ និងមន្ត្រីសង្ឃជាន់ខ្ពស់ បានទទួលការស្នើសុំអោយប្រារព្ធវិធីស្រោចទឹក ជាពិសេសដល់ស្ត្រីដែលបានទទួលអំពើរំលោភផ្លូវភេទ ឬបំពានផ្លូវភេទ តែសេចក្តីស្នើសុំនេះពុំបានបំពេញតាមដោយជោគជ័យឡើយ។ នៅក្នុងធម៌ព្រះសុទ្ធសាសនា ស្ត្រីភេទតាមទំនៀមទម្លាប់ ត្រូវចាត់ទុកថាមិនស្អាតបាត។ គេមិនអនុញ្ញាតអោយស្ត្រីប៉ះពាល់ ព្រះសង្ឃឡើយ។ ទោះជាវិធីបរិសុទ្ធកម្មពិសេសជាភាពស្របតាមមាគ៌ាសាសនាវិទ្យាព្រះពុទ្ធក៏ដោយ។

ជំនឿនេះ ប្រហាក់ប្រហែលគ្នា អំពីភាពស្អាតស្អំរបស់ស្ត្រីភេទ មានកើតឡើងនៅប្រទេសឥស្លាមទោះបីជាយ៉ាងណាក៏ដោយ នៅបូស្សនា លោក (Derives′ Ahmed Muradin) ជាអ្នកបួសជន្មាយុ ៩០ឆ្នាំ លោក បានទទួលសេចក្តីគោរពយ៉ាងខ្ពង់ខ្ពស់ លោកជាចៅក្រមច្បាប់ Shariah ជាច្បាប់ឥស្លាមយោងទៅតាមQur′an និងទំនៀមទម្លាប់អ្នកបង្រៀនសាសនា Muhammad បានចែងកំរិតមួយថា ស្ត្រីបូស្សនាសជនជាតិឥស្លាម ដែលទទួលអំពើបំពានផ្លូវភេទត្រូវតែទទួលឋានៈជាជនហ៊ានបូជាជីវិតជាជាងប្រឆាំង និងច្បាប់សាសនា។ នៅក្នុងមតិរបស់លោក លោកបានប្រកាសថាក្នុងនាមជាមនុស្សលោក និងជាអ្នកប្រាជ្ញ លោកត្រូវចាប់ប្រតិបត្តិការពិត និងបញ្ជូនស្ត្រីទាំងនេះទៅកាន់ទីកន្លែងដែលត្រឹមត្រូវសម្រាប់រូបគេនៅក្នុងសង្គម។

តើមាននរណាម្នាក់ ដែលអាចនិយាយថាស្ត្រីទាំងនេះមិនបរិសុទ្ធ និងមានបាបកម្មដោយសារអ្វីដែលគេបានឆ្លងកាត់ ឬទេ? ដូច្នេះ គេអាចមានកំហុសដោយសារបុព្វហេតុផ្សេងៗទៀត តែចំពោះបុព្វហេតុនេះពិតជាពុំត្រឹមត្រូវឡើយ ដូច្នេះ គ្មាននរណាម្នាក់ត្រូវនិយាយអំពីអ្នកទាំងនេះដោយប្រកាន់ ឫកពារបែបនេះឡើយ។

យើងជាជនជាតិឥស្លាម ជាពិសេសអ្នកដែលមានភាពជិតស្និទជាងគេ ត្រូវទទួលស្គាល់គេដោយចាត់ទុកគេជាបុព្វស្ត្រី ជាជនដែលហ៊ានបូជាជីវិតជាជាងប្រឆាំង និងច្បាប់សាសនា ហើយគាំទ្រសតិអារម្មណ៍ទាំងសម្ភារៈ។ យើងសូមផ្តល់យោបល់ ជាពិសេសចំពោះបុរស ដែលជាស្វាមីរបស់ស្ត្រីដែលបានទទួលបទពិសោធន៍សោកនាដកម្មនេះ អោយមានជំហររឹងមាំឱបក្រសោបភរិយាខ្លួនដោយផ្ទាល់ និងតាមមតិប្រៀបធៀបរបស់ពិភពលោកទូទៅ។ ទោះជាគេបានបង្ហាញថា គេពិតជាអាណិតអាសូរទៅលើភាពឈឺចាប់របស់ភរិយាខ្លួន គេក៏សុខចិត្តជួយសម្រាលសេចក្តីឈឺចាប់នេះ ដើម្បីអោយនាងងាយស្រួលទ្រាំទ្រ។

ភាពព្យាបាលអោយភាពជាសះស្បើយរបស់ស្ត្រីបូស្សនាន បានរកឃើញដោយវោហាររបស់អ្នកបួសចាស់ជរាឈ្លាស់វៃម្នាក់នេះ ។ តែករណីនេះ ពិតជាពុំមែនចេះតែកើតមានឡើងឡើយ ទោះបីជាយ៉ាងណាក៏ដោយជាធម្មតា ជនជួបប្រទះភាពតក់ស្លុត គឺចង់ប្រកួតប្រជែងបង្កើតទំនាក់ទំនងដោយផ្ទាល់ទៅ និងដោយព្រះ ពុំចាំបាច់មានជំនួយពីគ្រឹះស្ថានសាសនា ឬសហធម្មិកឡើយ។

ឥទ្ធិពលព្យាបាលតាមជំនឿជាកម្មវត្ថុដែលគេពុំសូវចង់យកមកពិភាក្សានៅ ផ្នែកវិជ្ជាពេទ្យសម័យ និងផ្នែកព្យាបាលចិត្តសាស្ត្រ ជាទូទៅពួកគេពុំជឿថាឋានសួគ៌ ត្រូវដាក់បញ្ចូលនៅក្នុងដំណើរការព្យាបាលឡើយ។[13]

មធ្យោបាយ ផ្នែកវិជ្ជាពេទ្យ និងផ្នែកចិត្តសាស្ត្រទៅលើឥទ្ធិពលព្យាបាលដោយជំនឿ គឺលំអៀងច្រើនទៅលើភាពមិនជឿជាមតិទូទៅ និងភាពបណ្តែតបណ្តោយធ្វេសប្រហែល។ ទោះបីជា ផ្នែកវិជ្ជាជីវៈពេទ្យប្រឈមមុខ និងសេចក្តីស្លាប់ ជារៀងរាល់ថ្ងៃក៏ដោយ វេជ្ជបណ្ឌិតជាច្រើនហាក់បីដូចជា ពុំអាចដោះស្រាយបញ្ហាជំនឿរបស់អ្នកជម្ងឺបាន ទោះជាមានកំណត់ហេតុ ចំនួនច្បាស់លាស់ពី ផ្នែកវិទ្យាសាស្ត្របានបង្ហាញអំពីប្រសិទ្ធិភាពនៃការបន់ស្រន់ក៏ដោយ វេជ្ជបណ្ឌិតជាទូទៅមានអារម្មណ៍មិនស្រួលទៅលើគំនិតចូលរួមបន់ស្រន់ជាមួយ និងអ្នកជម្ងឺជិតស្លាប់របស់ខ្លួន។ ឬផ្តល់សេចក្តីគាំទ្រតាមបែបបទជំនឿដល់ជនរងគ្រោះដោយអំពើរំលោភបំពាន និងជនរួចផុតពីសេចក្តីស្លាប់ដោយអំពើទារុណកម្ម។ ដោយវិទ្យាសាស្ត្រពេទ្យមានឥទ្ធិពលដ៏មហិមា និងមានប្រសិទ្ធិភាព អ្នកព្យាបាលពេទ្យពុំអនុញ្ញាតអោយមានប្រព័ន្ធព្យាបាលផ្សេងៗទៀតឡើយ ជាពិសេស អ្នកដែលយកព្រេងវាសនាមកប្រើក្នុងជីវិតរបស់គេ។ នៅពេលដែលគេយល់ដឹងថា អ្នកជម្ងឺកំពុងតែប្រឈមមុខ និងសេចក្តីស្លាប់ តែគេអាចចង់ដឹងថាតើវេជ្ជបណ្ឌិតរបស់គេយកទម្រង់សាសនា និងជំនឿមកប្រើជាពង្វាង ឬមួយយ៉ាងណានោះ អ្នកខ្លះបានសួរថា "តើអ្នកជឿ ឬមិនជឿ?" តាមរយៈភាពយល់ចិត្តគ្នាដោយភាពស្ងាត់ស្ងៀមទៅវិញទៅមក វេជ្ជបណ្ឌិត និងអ្នកជម្ងឺបន្តទំនាក់ទំនងរបស់គេ ហើយពុំយកចិត្តទុកដាក់ទៅលើមធ្យោបាយសំខាន់ៗនៃការព្យាបាលឡើយ។

នៅជុំរុំសាយធូ ផ្ទុយទៅវិញជនភៀសខ្លួនខ្មែរដែលទទួលការហ្វឹកហ្វឺន ជាអ្នកព្យាបាលសតិអារម្មណ៍ ជាញឹកញាប់បាននិយាយអំពីព្រលឹងចូលរូបដែលកើតមានឡើង ជាទូទៅនៅក្នុងចំណោមអ្នកជម្ងឺដែលគេជួយ។ នៅក្នុងទំនៀមទម្លាប់នេះព្រលឹងចូលរូបនៅក្នុងខ្លួនមនុស្សមានបីបែប សំខាន់ជាងគេ គឺធ្វើអោយមានលទ្ធផលអាក្រក់ៈ សាច់ញាតិដែលស្លាប់ទៅ តែព្រលឹងរបស់គេនៅតែវិលវល់ ជនល្បីល្បាញ ដូចជាព្រះមហាក្សត្រជ័យវរ្ម័នទី៧ ដែលបានកសាងប្រាសាទអង្គរធំ ហើយបានចាប់ផ្តើមសាសនាព្រះពុទ្ធ នៅប្រទេសកម្ពុជា ឬខ្មោចបីសាច ដែលចង់បំផ្លាញជនគ្រប់រូបដែលគេចូលសន្ធប់ក្នុងរូប។ ព្រលឹងទាំងបីបែបអាចធ្វើអោយមានសញ្ញារោគកើតមានឡើងនៅលើកាយសម្បទា ដូចជាប្រកាច់ វិលមុខ ក្តៅខ្លួន ងងឹតមុខដួល និងទទួលទានដំណេកពុំបានរ៉ាំរ៉ៃ ហើយគេបានបង្ហាញរាង្គកាយរបស់គេទៅព្រលឹងនោះទៅតាមសុបិន្តអាក្រក់របស់គេ។ ព្រលឹងនោះពេលខ្លះនិយាយតាមរយៈសម្លេងជនដែលគេចូលរូប ដោយម្ចាស់ខ្លួនពុំដឹងខ្លួន ឬយល់ដឹងឡើយ។ មានតែអ្នកស្តាប់ទេ ដែលអាចយល់ការនិយាយទាក់ទងរបស់ព្រលឹង។ បើសិនជាព្រលឹងនោះពុំបានដេញចេញ ដោយវិធីសែនព្រេនត្រឹមត្រូវនោះទេ ព្រលឹងនោះអាចធ្វើអោយជននោះឈឺខ្លាំង និងអាចរហូតដល់ស្លាប់ទៀត។ ព្រលឹងដែលវិលវល់អាចធ្វើអោយស្ងប់ស្ងៀមបាន តាមរយៈវិធីបុណ្យសពតាមទំនៀមទម្លាប់ព្រះពុទ្ធ ការសូត្រធម៌ និងថ្នាំបុរាណរបស់គ្រូខ្មែរ អាចបំបាត់ព្រលឹងបុព្វបុរស និងខ្មោចបីសាចបាន។

ជនហ្វឹកហ្វឺនខ្មែរ ដែលមានចំណេះវិជ្ជាខ្ពស់ទាំងអស់គ្នាជឿទៅលើព្រលឹងចូលរូប ហើយគេចង់ដឹងថាជំហររបស់ខ្ញុំទៅលើបញ្ហានេះមានកំរិតត្រឹមណា ទាំងផ្នែកវិជ្ជាជីវៈ ទាំងផ្នែកផ្ទាល់ខ្លួន។ នៅពេលទទួលការសួរបែបនេះដោយផ្ទាល់បើសិនជាខ្ញុំជឿទៅលើព្រលឹងចូលរូបវាបង្កើននូវវិបត្តិដល់ខ្ញុំ។ តើចំណេះដឹងរបស់ខ្ញុំ ផ្នែកវិជ្ជាពេទ្យនៅជុំរុំជនភៀសខ្លួនទាក់ទង និងព្រលឹងចូលរូបនោះ មានភាពសាមញ្ញកំរិតណានៅក្នុងចំណោមអ្នកជម្ងឺ?

ចម្លើយដែលសិស្សខ្មែរ ចង់បានពីវេជ្ជបណ្ឌិតអាមេរិកកាំង គឺថាខ្ញុំពុំជឿទៅលើរឿងព្រលឹងចូលរូបឡើយ តែជាការធម្មតាសំរាប់ពួកគេដោយគេជឿទៅលើជំនឿនេះ អាចជាភាពលាក់បាំងគំនិតប្រឆាំង និងជំនឿផ្លូវចិត្ត។ ដូច្នេះ ខ្ញុំឆ្លើយដោយខ្សោយថា ខ្ញុំជឿដោយខ្ញុំមានបទពិសោធន៍ផ្ទាល់អំពីវត្តមានឋានសួគ៌នៅក្នុងការប្រកបវិជ្ជាជីវៈពេទ្យរបស់ខ្ញុំ។

អ្នកវិជ្ជាជីវៈផ្នែកដើមកំណើតមនុស្សជនជាតិណាវ៉ាហូ (Navajo) ម្នាក់បានពន្យល់ប្រាប់ខ្ញុំនៅពេលម្តងនោះថា នៅក្នុងសង្គមរបស់នាង ក៏ដូចជា នៅក្នុងទំនៀមទម្លាប់សង្គមភាគច្រើនដែរ ព្រលឹងនៅឋានសួគ៌ នឹងធ្វើអន្តរាគមន៍ក្នុងការព្យាបាលដោយបណ្តេញព្រលឹងអាក្រក់ចេញ លើកលែងតែអ្នកព្យាបាលរៀបចំតាមចំណេះដឹងផ្នែកព្រលឹង និងការអនុវត្តន៍។ ខ្ញុំបានទទួលស្គាល់ដោយមានភស្តុតាងទៅលើភាពពិត នៃសេចក្តីអះអាងនេះ។ ជារៀងរាល់អាទិត្យខ្ញុំបានជួបជាមួយ និងអ្នកជម្ងឺនៅបូស្តុន (Boston) ដែលព្រលឹងបានចូលរូបគាត់ ជាព្រលឹងសាច់ញាតិរបស់គាត់ ដែលគេបានសម្លាប់ នៅរបបប៉ុលពត ជននោះអោយគាត់ឃើញមុខ តាមរយៈសុបិន្តអាក្រក់។ សពសាច់ញាតិដែលបានស្លាប់ទៅហើយ នោះត្រូវដាក់ចូលលាយលំគ្នា ខ្ញុំកត់ត្រាយករឿងតក់ស្លុតចប់សព្វគ្រប់ដោយហ្មត់ចត់ ហើយបានសហការជាមួយ និងអ្នកជម្ងឺ ដើម្បីដោះស្រាយតាមតម្រូវការ និងបំណងរបស់ព្រលឹង ជាទូទៅ គឺវិធីបុណ្យសពត្រឹមត្រូវតាមទំនៀមទម្លាប់ព្រះពុទ្ធ។ ក្រោយពីវិធីនោះបានប្រព្រឹត្តធ្វើឡើងព្រលឹងនោះក៏រសាយបាត់ពីសុបិន្ត ការឈឺចាប់កាយសម្បទារបស់អ្នកជម្ងឺទាំងប៉ុន្មានក៏រសាយបាត់ទៅផងដែរ។

អ្នកចិត្តសាស្រ្តវ័យមជ្ឈឹមជនជាតិបូស្សនានម្នាក់ មានតួនាទីដ៏ច្បាប់លាស់ទៅលើការព្យាបាល របស់គាត់តាមបែបបទជំនឿ។ កាលពីគាត់នៅប្រទេសយូហ្គូស្លាវ៉ា(Yugoslavia) ក្នុងយុវវ័យជាជនជាតិឥស្លាម ជាដំបូងគាត់បដិសេធពុំទទួលទំនៀមទម្លាប់តឹងរឹង ផ្នែកសាសនាឥស្លាមពីឪពុកម្តាយរបស់គាត់ ជាពិសេសពីម្តាយរបស់គាត់។ នៅក្នុងរបបកុម្មុយនិស្ត ឪពុកម្តាយរបស់គាត់បានទទួលការចាត់តាំងថា ជាជនជាតិដើមដំបូង ចាស់គំរិលនិងក្រខ្សត់ ឬហៅថាប៉ាប៉ា(Papa) "ក្រចកជើងគោ"។ ក្រោយមកគាត់មាន ឈ្មោះល្បីល្បាញជាអ្នកគំនូរមួយរូបនៅបូស្សនាក្រោយមកទៀតជាវេជ្ជបណ្ឌិត និងអ្នកព្យាបាលចិត្តសាស្រ្ត។ បន្ទាប់ពីឃើញ ព្រះអាឡាប្រឈមមុខប្រឆាំង និងរូបគាត់អំពីជំនឿគ្មានព្រះរបស់គាត់ នៅក្នុងសុបិន្តគាត់បានត្រឡប់មកចូលវិហារវិញ ហើយចាប់ផ្តើមបន់ស្រន់។ បន្ទាប់ពីភាពបញ្ចេញអារម្មណ៍ទោរទន់ខ្សោយ ទាំងកម្លាំងកាយសម្បទា ទាំងកម្លាំងចិត្ត ជាលើកដំបូងគាត់ក៏ចាប់ផ្តើមទ្រហោរយំ ដោយបញ្ចេញសម្លេងដើមកំណើតរបស់គាត់ បកស្រាយសាសនារបស់គាត់។ គាត់បានរៀនភាសាអារ៉ាប់ដើម្បីអានគម្ពីរ (Qur'an) ហើយបង្កើតភាពជិតស្និទ ជាមួយ នឹងឪពុកម្តាយរបស់គាត់និងអ្នកជិតខាងដោយសម្របខ្លួនគាត់ចូលតាមសាសនា នៅក្នុងចំណោមមនុស្សដែលទទួលការចាត់ទុក ដោយពួកកុម្មុយនិស្តកាន់កាប់សង្គមរបស់គាត់ថាជាក្រុមចាស់គំរិលគ្មានភាពរីកចំរើនលូតលាស់។

នៅពេលដែលសង្រ្គាមចាប់ផ្តើមឡើងដោយភាព បែកខ្ញែកនៅយូហ្គូស្លាវ៉ានៅក្នុងឆ្នាំ១៩៩២ គាត់បានទទួលការកោះហៅដោយយោធាអោយទៅការពារប្រជាជនគាត់ ដែលកំពុងតែទទួលរងគ្រោះ ដោយអំពើសាហាវយង់ឃ្នងពីជនជាតិបុស្សនានស៊ើប។ នៅទីលានប្រយុទ្ធក្នុងនាមជាវេជ្ជបណ្ឌិត គាត់គ្មានកាន់អាវុធទេ តែគាត់

ស្ថិតនៅចម្ងាយពុំលើសពី សាមសិបម៉ែត្រពីសមរភូមិមុខ។ នៅក្នុងករណីប្រយុទ្ធដ៏សាហាវមួយ គ្រាប់កាំភ្លើងរបស់ជនជាតិស៊ែប្របាញ់ចំលើខ្លួនគាត់ខាងឆ្វេង។ មុនពេលគាត់សន្លប់បាត់ស្មារតី គាត់អង្គុយចុះនៅក្នុងទីលានប្រយុទ្ធជាបែបបទស្ទឹងស្មាធ បិទភ្នែកហើយគិតថា "ពេលនេះខ្ញុំជាអ្នកបូជាជីវិត ហើយខ្ញុំ នឹងបានឡើងឋានសួគ៌នៅពេលឆាប់ៗនេះ"។គាត់បានឃើញដុំភ្លើងពណ៌លឿង ស គ្មានតែមជុំវិញបានលេបត្របាក់រូបគាត់ ហើយខ្លួនគាត់ក៏ចាប់ផ្តើមអណ្តែតឡើង។ គាត់អាចមើលឃើញថាព្រលឹងគាត់ឃ្លាតចេញពីរាង្គកាយរបស់គាត់ ហើយគាត់មានអារម្មណ៍ធូរស្រាលក្នុងខ្លួនថា សេចក្តីស្លាប់ជាភាពឥតឈឺចាប់។ នៅពេលដែលដំណើរការនេះកំពុងតែឈានចូលជិតដល់ទីបញ្ចប់ ទោះបីជាយ៉ាងណាក៏ដោយ គាត់ដឹងថាគាត់ពុំអាចនិយាយពាក្យឥស្លាមដែល នឹងជួយអោយគាត់ឡើងទៅកាន់ឋានសួគ៌បានឡើយ។ ខ្ញុំបានឃើញជាសាក្សីថាគ្មានព្រះទេ មានតែព្រះអាឡា ហើយ Muhammad ជាទាសករ និងអ្នកនាំសាររបស់ព្រះ"។ គាត់បានភ្ញាក់ដឹងខ្លួនឡើងនៅក្នុងមន្ទីរពេទ្យសមរភូមិយោធា ដៃឆ្វេងគាត់កំរើកពុំរួចដោយខូចសរសៃ។ ក្រោយមកគាត់បានវះកាត់នៅសហរដ្ឋអាមេរិក ហើយក៏ប្រើដៃរបស់គាត់បានឡើងវិញ។

បន្ទាប់ពីសង្គ្រាមចប់នៅក្នុងឆ្នាំ១៩៩៥ តាមរយៈសិទ្ធិសញ្ញាសន្តិភាព គាត់បានក្លាយទៅជាអ្នកចាត់ការថែទាំ អ្នកជម្ងឺសតិអារម្មណ៍ធ្ងន់ធ្ងរ ចំនួន១២០នាក់ ដែលកងទ័ពស៊ែប្រទុកចោលនៅក្នុងមន្ទីរពេទ្យវិកលចរិតក្រោយពីគេបានដកទ័ពថយចេញទៅ។ ជនជាតិរួមឈាមរបស់គេបានចាក់សោរអ្នកទាំងនោះទុកចោលក្នុងស្ថានភាពដ៏អាក្រក់ក្រៃលែង។ គាត់ព្យាបាលអ្នកជម្ងឺស៊ែប្រគ្រប់រូប គាត់បានព្យាយាមធ្វើអោយសុខភាពសតិអារម្មណ៍របស់គេបានគ្រាន់បើឡើងវិញដោយប្រើថ្នាំពេទ្យ និងការពិភាក្សា ដោយថាហេតុ នឹងជួយអោយគេមានសុខភាពល្អឡើងវិញ រួចគាត់បញ្ជូនអ្នកទាំងនោះទៅអោយពួកសត្រូវវិញ។ ក្នុងនាមជាវិជ្ជបណ្ឌិត និងមនុស្សម្នាក់ស្មួយរូប គាត់ពេញចិត្ត និងកិច្ចការរបស់គាត់ណាស់ ហើយនៅទីបញ្ចប់គាត់អាចសម្រុះសម្រួលជំនឿឥស្លាម ជាមួយ និងគ្រីស្តសាសនាដែលអ្នកជម្ងឺរបស់គាត់ជឿ។

នៅពេលបច្ចុប្បន្ននេះ គាត់ធ្វើការនៅធូសទឡា Tuzla ជាអ្នកព្យាបាលចិត្តសាស្ត្រធ្វើការជាមួយអ្នកជម្ងឺគ្រប់សាសន៍ វប្បធម៌ និងជំនឿសាសនា ដែលមានរួមទាំងបូស្សនានស៊ែប្រ និងឥស្លាម។ គាត់បានសួរអ្នកជម្ងឺរបស់គាត់ទាំងអស់ថាគេជឿលើព្រះ ឬអត់ បើគេឆ្លើយថាអត់ គាត់ចាប់ផ្តើមព្យាបាលចិត្តសាស្ត្រតាមទម្លាប់ធម្មតា។ បើសិនជាគេឆ្លើយថាគេជឿព្រះ គាត់ចាប់ផ្តើមនិយាយអំពីជីវិតរបស់អ្នកជម្ងឺតាមជំនឿនោះ គាត់បានចូលរួមក្នុងការបន់ស្រន់ឯកជនជាមួយ និងអ្នកជម្ងឺឥស្លាមនៅក្នុងបន្ទប់ពិនិត្យ ចាប់តាំងពីកំណត់ពេលដែលការបន់ស្រន់នេះ ពុំទាន់បានទទួលស្គាល់ជាបែបបទជាទូទៅដោយ ផ្នែកចិត្តសាស្ត្រនៅបុស្សនា។ គាត់ជាអ្នកប្រឆាំងជាតិនិយម ដោយជឿជាក់ថាអ្នកដែលយកសាសនាមកប្រើក្នុងនយោបាយ ជាអ្នកបោកបញ្ឆោតបង្កើនភាពរំជើបរំជួលវឹកវរ និងទំនាស់នៅក្នុងចំណោមប្រជាជន។ វេជ្ជបណ្ឌិតមួយរូបនេះមានភ័ព្វសំណាងណាស់ ដោយគាត់រកឃើញឥទ្ធិពលព្យាបាលខ្លួនឯងនៅក្នុងជីវិតរបស់គាត់ ដែលគាត់អាចយកមកប្រើជាវិធីត្រឹមត្រូវ និងប្រយ័ត្នប្រយែងនៅក្នុងវិជ្ជាជីវៈពេទ្យរបស់គាត់។

## ១.៨ ការព្យាបាលនៅក្នុងដំណើរជីវិតប្រចាំថ្ងៃ

មធ្យោបាយរបស់សង្គមនិយមនៅក្នុងការព្យាបាលមានភាពសំខាន់ស្មើគ្នា សំរាប់មនុស្សដែលប្រឈមមុខនិងបញ្ហាសុខភាពធ្ងន់ធ្ងរ ដូចជា ជម្ងឺមហារីក។ នៅករណី ដែលព័ត៌មានវិទ្យាសាស្ត្រ លេចឮឡើងអំពី ផ្នែកចិត្តសាស្ត្រ នៃសកម្មភាពសង្គមដែលពន្យាថា និងកាត់បន្ថយអត្រាមរណៈក្នុងចំណោមនោះ អ្នកមានជម្ងឺមហារីកប្រព័ន្ធបង្កើនភាពព្យាបាលដោយខ្លួនឯង ពុំទាន់កើតមានឡើង ជាទូទៅនៅក្នុងការព្យាបាលជម្ងឺបែបនេះឡើយ។ មធ្យោបាយរបស់សង្គមនិយមនៅក្នុងការព្យាបាលនោះ ពិតជាពុំអាចធ្វើឡើងជំនួសការព្យាបាលតាមទម្លាប់បានឡើយ ដូចជាការប្រើថ្នាំគីមីសម្លាប់រោគ និងការប្រើកាំរស្មីដុតសម្លាប់រោគ តែភាពអបអរទៅលើការព្យាបាលដោយខ្លួនឯង អាចដាក់បញ្ចូលទៅក្នុងដំណើរការព្យាបាល។

ជនដែលប្រឈមមុខ នឹងរោគធ្ងន់ធ្ងរ មានបទពិសោធន៍ ដូចជាជនដែលទទួលរងទុក្ខដោយអំពើសាហាវយង់ឃ្នងដែរ។ ជាញឹកញាប់ជម្ងឺប្រចាំកាយនេះចាប់ផ្តើមកើតឡើងភ្លាមៗ ស្ត្រីរស់នៅដោយសុខដុមរម្យនារហូតដល់ពេល ថតសុដន់ត្រូវយកដុំសាច់ទៅពិនិត្យ រួចបានទទួលការវិនិច្ឆ័យរោគថាមានជម្ងឺមហារីកសុដន់។ ថ្ងៃមុននាងអត់មានឈឺអ្វីសោះស្រាប់តែភ្លាមនោះនាងមានជម្ងឺយាយីដល់អាយុជីវិត ពិភពទាំងមូលរបស់ជនបែបនេះធ្វើអោយមានការផ្លាស់ប្តូរទាំងស្រុង។ អារម្មណ៍រំជើបរំជួលខ្លាំង ដូចជាសេចក្តីភ័យខ្លាច និងក្រៀមក្រំគ្របសង្កត់លើខ្លួននាង មានឥទ្ធិពលនៅលើអារម្មណ៍នាង និងមានអានុភាពគ្រប់គ្រងចរិយារបស់នាងទាំងស្រុង។ រោគាក្លាយទៅជាព្រឹត្តិការណ៍តក់ស្លុតក្នុងជីវិត ពេលខ្លះប្រតិកម្ម នៃការព្យាបាលមានភាពតក់ស្លុតជាងជម្ងឺទៅទៀត។ ភាពក្អួតចង្អោរ ទន់ខ្សោយ និងភាពខូចខាតរាង្គកាយដោយការវះកាត់ អាចជាភាពតក់ស្លុតលើកទីពីរ ពេលខ្លះភាពខ្មាស់អៀន និងភាពអាម៉ាស់មុខ កើតឡើងមកជាមួយ និងជម្ងឺ ឬការព្យាបាលជម្ងឺ ដូចជាការជ្រុះសក់ដោយការព្យាបាលប្រើជាតិគីមី។ ទុក្ខសោកខុសគ្នាពិត រវាងជនជួបប្រទះភាពតក់ស្លុតដែលរួចផុតពីសេចក្តីស្លាប់ និងជនមានជម្ងឺធ្ងន់ធ្ងរ គឺនៅករណីចុងបញ្ចប់ អ្នកមានជម្ងឺធ្ងន់ធ្ងរពុំអាចនឹកឃើញវត្តមានរបស់ជនល្មើសឡើយ។

ឥទ្ធិពលការព្យាបាលដោយខ្លួនឯងទាំងអស់ ដែលរកឃើញនៅក្នុងចំណោមជនជួបប្រទះភាពតក់ស្លុត គឺចាប់ផ្តើមមានដំណើរការពីជនដែលមានជម្ងឺធ្ងន់ធ្ងរ។ សេចក្តីឈឺចាប់របស់ជនជួបប្រទះភាពតក់ស្លុតដែលកើតមានឡើងដោយប្រភពសង្គមច្រើនតែជាឧបសគ្គរាំងឥទ្ធិពលការព្យាបាលជីវសាស្ត្រ(ជីវិត) និងចិត្តសាស្ត្រ។ នៅក្នុងចំណោមអ្នកជម្ងឺមហារីក និងអ្នកជម្ងឺធ្ងន់ធ្ងរផ្សេងៗទៀត ជំនឿទៅលើពូជ និងហេតុផលធម្មជាតិផ្សេងៗ ក្នុងជីវិតដែលបណ្តាលអោយកើតមានជម្ងឺ បានរាំងភាពព្យាបាលដោយខ្លួនឯងតាមបែបបទអនុភាពសង្គម។ ភាពអបអរ ផ្នែកវិទ្យាសាស្ត្រទៅលើការភ្ជាប់ជិតស្និទ វវាងឥទ្ធិពលការព្យាបាល កាយសម្បទា ចិត្តសាស្ត្រ និងសង្គម តម្រូវអោយមានសាមគ្គីភាព គម្រោងថែទាំ និងគម្រោងភាពជាសះស្បើយច្បាស់លាស់។

ស្សារ៉ា(Sarah)បច្ចុប្បន្ននេះ គាត់មាន អាយុ ៦០ឆ្នាំ គាត់ជាអ្នកចាត់ការនៅវិទ្យាល័យ គាត់ទើបតែឈានចូលដល់ អាយុ ៥០ឆ្នាំ ជីវិតរបស់គាត់ត្រូវក្រឡាប់ចាក់ នៅពេលដែលគេប្រាប់ថាគាត់មានជម្ងឺមហារីក។ គាត់ទៅ

ពិនិត្យសុខភាពពោរពេញទៅដោយអារម្មណ៍ល្អឥតខ្ចោះ នៅក្នុងពេលពិនិត្យរោគស្ត្រីគាត់ទទួលការឈឺចាប់ខ្លះៗ វេជ្ជបណ្ឌិតរបស់គាត់ក៏ចេញបទបញ្ជាអោយទៅថតជាធម្មតា ពេលទៅថតគេរកឃើញមានសាច់ដុះប៉ុនក្បាលដែកគោលនៅលើមាត់ស្បូនម្ខាង។ ការវិនិច្ឆ័យរោគ បានបញ្ជាក់ថាមានមហារីកពងស្បូន ដែលជាទូទៅច្រើនតែរកឃើញនៅដំណាក់ការយឺតពេលទៅហើយ គួរអោយអស្ចារ្យណាស់ជម្ងឺមហារីក របស់ស្សារ៉ារកឃើញទាន់ពេល។ ក្រោយពីវះកាត់រួច និងការព្យាបាលដោយថ្នាំគីមី វេជ្ជបណ្ឌិតរបស់គាត់បានប្រាប់គាត់ថា គាត់ត្រូវតាមមើលជម្ងឺដោយហ្មត់ចត់ទោះបីជាភាពជាសះស្បើយមានសង្ឃឹមច្រើនក៏ដោយ។

តែស្សារ៉ាតក់ស្លុតយ៉ាងខ្លាំងទៅលើរោគវិនិច្ឆ័យនេះ នាងមានអារម្មណ៍ថាជីវិតរបស់នាង ត្រូវចប់ត្រឹមនេះហើយ។ ផ្ទុយនឹងការឃ្លាំចាំមើលទៅលើលទ្ធផលល្អរបស់វេជ្ជបណ្ឌិត នាងមានអារម្មណ៍ច្បាស់ថា នាងនឹងស្លាប់ដោយសារជម្ងឺមហារីកហើយពុំអាចបំភ្លេច អំពីភាពស្លាប់នៅពេលខ្លីៗ ខាងមុខនេះបានឡើយ។ នាងបានរៀបចំពិធីបុណ្យសព ជ្រើសរើសភ្លេងដោយហ្មត់ចត់ និងអ្នកដែលឡើងថ្លែងប្រវត្តិរូបរបស់នាង។ មួយឆ្នាំក្រោយពីទទួលការវិនិច្ឆយរោគមក ទោះជាគ្មានភស្តុតាងថាជម្ងឺនេះ អាចមានកើតឡើងវិញក៏ដោយ នាងនៅតែមានអារម្មណ៍ធ្វើអ្វីពុំកើតពេកពន់ទៅលើមរណៈរបស់នាង។

កំណត់ពេលដែលធ្វើអោយស្សារ៉ាភ្ញាក់ខ្លួន គឺនៅពេលដែលមិត្តភក្តិរបស់នាងជូននាងទៅចូលរួមប្រជុំនៅក្នុងក្រុមគាំទ្រជម្ងឺមហារីកមាត់ស្បូន។ នៅទីនោះនាងបានជួបជាមួយ និងស្ត្រីឯទៀតដែលកំពុងតែលៃលកដោះស្រាយ និងជម្ងឺ មានរួមទាំងស្ត្រីដែលរោគធ្លាក់ដល់កំរិតចុងក្រោយ ដែលសន្មតថាពិតជា នឹងស្លាប់។ ជាជាង និងធ្វើអោយសេចក្តីខ្វល់ខ្វាយរបស់នាងកាន់តែមានខ្លាំងឡើងៗ អំពីភាពរួចផុតពីសេចក្តីស្លាប់ ការជួបនឹងស្ត្រីទាំងនោះបានទាក់ទាញស្សារ៉ាអោយចាប់ផ្តើមធ្វើសកម្មភាព។ នាងបានចូលរួមនៅក្នុងបណ្តាញអ្នកស្ម័គ្រចិត្តដែលផ្តល់សេចក្តីគាំទ្រកម្លាំងចិត្ត និងជួយជាសម្ភារៈ ដូចជា យានដ្ឋជំនិះ រត់ការចុះឡើង ផ្តល់ម្ហូបអាហារដល់ស្ត្រីដែលមានជម្ងឺមហារីកដែលត្រូវការជំនួយ។ ក្រោយពីបានធ្វើការជាមួយនោងក្រុមនេះបានពីរទៅបីខែ ស្សារ៉ា ដឹងថាការធ្វើអ្វីមិនកើតដោយសារគិតតែ ពីសេចក្តីស្លាប់ទុកជាមុនរបស់នាងក៏បានរសាយបាត់ទៅ។ ហើយវាជំនួសទៅដោយទំនាក់ទំនងរិតតែ ជិតស្និទ្ធឡើងទៅលើជំនឿក្នុងខ្លួន និងភាពអំណរអរគុណដ៏ជ្រាលជ្រៅជារៀងរាល់ថ្ងៃដែលនាងនៅមានជីវិតរស់នៅមួយថ្ងៃទៀតពោរពេញទៅដោយសុខភាពល្អ និងអាចបរិច្ចាគជួយអ្នកផ្សេងទៀត។ ចំនួន ១០ឆ្នាំក្រោយមក នាងពុំមានជម្ងឺមហារីកទៀត តែនាងនៅតែចូលរួមនៅក្នុងកិច្ចការគាំទ្រជម្ងឺមហារីកមាត់ស្បូនដដែល។

មធ្យោបាយសង្គមនិយម នៃការព្យាបាលដោយខ្លួនឯងហាក់បីដូចជា ងាយស្រួលក្នុងការប្រមូលផ្តុំ និងចាត់ចែងរួមទៅដោយឱកាសដ៏មានតម្លៃសំរាប់ធ្វើការ ឥរិយាបទសីលធម៌ និងជំនឿដែលមានជាស្រេច។ តែមានកត្តាពិត ជាច្រើនដែលបង្អាក់ស្ថានភាពដ៏គ្រចះគ្រចង់នេះ អ្នកដែលនៅជុំវិញខ្លួនយើង មានរួមទាំងក្រុមគ្រួសារអ្នកជិតខាង វេជ្ជបណ្ឌិត និងអ្នកព្យាបាលអាចអោយដឹងច្រើនខ្លះៗ អំពីតម្លៃសកម្មភាពសង្គម ដែលជួយអោយជាសះស្បើយ។ សំខាន់ជាងនេះទៅទៀត ដោយគេគ្មានការយល់ដឹងច្បាស់ផ្ទៃក្នុងទៅលើដំណើរការក្នុងខួរក្បាល

របស់យើង ហើយពុំដឹងផ្ទាល់អំពីពិភពតក់ស្លុតរបស់យើង មានតែអារម្មណ៍យល់ចិត្តរបស់សាច់ញាតិ និងអ្នកជិតខាងរបស់យើងទេ ដែលដឹងថាយើងត្រូវការអ្វីខ្លះ ដោយហេតុនេះ គេអាចជួយយើងបាន។ ហើយមនុស្សដដែលនោះជាកត្តាពិតក៏អាចភ័យខ្លាចបារម្ភថា ស្ថានភាពរបស់ជនជួបប្រទះភាពតក់ស្លុតជាភាពអស់សង្ឃឹមហើយគ្មានអ្វីអាចជួយគេបានឡើយ។

ជាភ័ព្វសំណាងល្អ មានតែជនជួបប្រទះភាពតក់ស្លុតពីរទៅបីនាក់ទេ ដែលទទួលអារម្មណ៍អស់សង្ឃឹមជាអណោក ទៅលើស្ថានភាពបាក់ស្បាតរបស់ខ្លួន។ នៅខណៈដែលមនុស្សគ្រប់រូបមានជីវិតរស់នៅ និងប្រកបដំណើរជីវិតនៅក្នុងសង្គមដែលទទួលភាពឈឺចាប់ ព្រៃផ្សៃ និងឃោរឃៅ ពិភពលោកដដែលនេះក៏អាចនាំមកនូវភាពអត់ឃ្លាន រីករាយ និងបីបាច់ថែទាំ។ ជនជួបប្រទះភាពតក់ស្លុតមានចំណេះដឹងក្នុងខ្លួនរបស់គេ ក្នុងការប្រើមជ្ឈដ្ឋានសង្គម ដើម្បីជួសជុលភាពខូចខាត ដែលបណ្តាលឡើងដោយអំពើឃោរឃៅ ទោះបីជាសេចក្តីព្យាយាមនេះអាចមានភាពល្អប្រសើរ តែផលប្រយោជន៍ការព្យាបាលការងារ ភាពគិតប្រយោជន៍អ្នកដទៃ និងជំនឿអាចមានប្រយោជន៍រិតតែធំធេងជាងនេះទៅទៀត។

# ជំពូកទី៨ ចលនាទាមទារដើម្បីថែរក្សាសុខភាព

"ខ្ញុំខ្លាចអ្នកជម្ងឺនេះ" ដែលគំនិតទាំងនេះជាញឹកញាប់បន្តឡើង នៅក្នុងអារម្មណ៍របស់វេជ្ជបណ្ឌិត និងអ្នកព្យាបាលដែលបង្អាក់ឥទ្ធិពលព្យាបាលដោយខ្លួនឯងរបស់ជនជួបប្រទះភាពតក់ស្លុត។ ខ្ញុំបានតាមដាន មើលភាពភ័យខ្លាចនៅក្នុងចំណោមអ្នករួមការងារជាមួយខ្ញុំ ដែលក្រោយពីបានស្តាប់រឿងតក់ស្លុតរបស់អ្នកជម្ងឺ គេបានដើរចេញយ៉ាងលឿនចេញពីបន្ទប់ពិនិត្យ ឬដកខ្លួនចេញដោយភាពរន្ធត់ និងភ័ន្តច្រឡំ។ រូបខ្ញុំក៏មានបទពិសោធន៍នេះផងដែរ សេចក្តីភ័យខ្លាច យោងទៅតាមជំនឿមិនសមហេតុផលថា អ្នកជម្ងឺ នឹងពុំអាចជាសះស្បើយពីទុក្ខសោកឈឺចាប់របស់គេឡើយ។ ដោយប្រឈមមុខ នឹងភាពរន្ធត់បែបនេះ អ្នកវិជ្ជាជីវៈ ផ្នែកសុខភាពពុំអាចកំចាត់ឥទ្ធិពលរបស់ជនល្មើសបាន។ ហើយឥទ្ធិពលនេះអាចធ្វើអោយភ័យខ្លាច វេជ្ជបណ្ឌិតគ្មានអ្វីការពារ និងគ្មានបានរៀបចំខ្លួនទទួលលទ្ធផលរំខានអារម្មណ៍នេះ។

ជំហ៊ានថ្មីៗ នៅក្នុងផ្ទាំងគំនូររបស់លោករ៉ាហ្វែល (Raphael) *ភាពប្រែរូបព្រះយ៉េស៊ូ* ដែលដាក់តាំងនៅជញ្ជាំងនៅទីក្រុង (Vatican Pinacoteca) នៅប្រទេសរ៉ូម (Rome)បានបង្ហាញទេពកោសល្យ នៅលើផ្ទាំងគំនូរអំពីទឹកមុខភ័យខ្លាចរបស់អ្នកព្យាបាលនៅពេលដែលគេប្រឈមមុខ និងជម្ងឺធ្ងន់ធ្ងរ។ ផ្ទាំងគំនូរនេះបានទទួលការតែងតាំងឡើងនៅឆ្នាំ១៥១៧ ដោយ(Cardinal Giulio De´ Medici) មហាព្រះវិហារបារាំងទីក្រុង (Narbonne)។ ផ្ទាំងគំនូរនេះប្រហែលជាផ្តល់ព័ត៌មានសំខាន់ៗ អំពីបទពិសោធន៍ព្យាបាល ដោយលោករ៉ាហ្វែលធ្លាក់ខ្លួនឈឺ ហើយបានទទួលអនិច្ចកម្មនៅពេលដែលគាត់គូរបញ្ចាក់គំនូរនោះ។

លោករ៉ាហ្វែលបានពណ៌នានៅលើផ្ទាំងគំនូរនោះ ដោយទិដ្ឋភាពពីរបែបចេញពី គម្ពីរសាសនា ទិដ្ឋភាពមួយនៅខាងលើផ្ទាំងគំនូរ ព្រះយ៉េស៊ូ ប្រែរូបទៅជាពន្លឺឋានសួគ៌ ដែលព័ទ្ធជុំទៅដោយកូនក្មេងអ្នកមានបុណ្យ អ្នកទស្សទាយ Elijah និងសាវ៉ក (អ្នកជំនឿគ្រីស្តសាសនា)។ នៅផ្ទាំងគំនូរមួយកំណាត់ខាងក្រោមអ្នកជំនឿគ្រីស្តសាសនា ព្យាយាមព្យាបាលក្មេងប្រុសម្នាក់ឈឺដោយខ្មោចចូល។ ក្មេងនោះកំពុងតែប្រកាច់នៅលើដៃរបស់ឪពុកវាទឹកមុខរបស់អ្នកសាវ៉កពោរពេញទៅដោយសេចក្តីបារម្ភ និងអស់សង្ឃឹមដោយការព្យាបាលនោះពុំអាចបញ្ឈប់ភាពប្រកាច់នោះបាន។ អ្នកដែលឈរមើលបានអង្វរសាវ៉កអោយជួយ ហើយថែមទាំងបញ្ចេញភាពខឹងសម្បារទៅលើ ដោយគ្មានប្រសិទ្ធិភាពរបស់អ្នកព្យាបាលទាំងនោះ។ សេចក្តីបកស្រាយទៅលើភាពបរាជ័យរបស់សាវ៉កក្នុងការព្យាបាលនេះ បានបង្ហាញនូវបរិបទសង្គមអនាធិបតេយ្យ ភាពភ័ន្តច្រឡំ និងភាពអស់សង្ឃឹម ជម្ងឺ ខ្មោចបីសាចនៅក្នុងខ្លួនក្មេងប្រុស ពុំអាចធ្វើអោយជាបានទាល់តែសោះ។

ជាដំណោះស្រាយមួយទៅលើសោកនាដកម្មនៃការព្យាបាល ពុំមែនបង្ហាញឡើងដោយផ្ទាំងគំនូរនេះទេ តែដោយការពណ៌នារបស់វា ក្រោយពីពួកសាវ៉កបរាជ័យក្នុងការព្យាបាលក្មេងនេះ ព្រះយ៉េស៊ូ បានដេញខ្មោចបីសាចចេញដោយផ្ទាល់ខ្លួនព្រះអង្គ ហើយព្យាបាលក្មេងនោះអោយជាសះស្បើយទៅ៖

๖ រួចពួកសាវ័កក៏បានមកជួបព្រះយេស៊ូ ដោយសម្ងាត់ ហើយនិយាយឡើងថា " ហេតុអ្វីក៏យើងពុំអាចដេញខ្មោចនោះចេញបាន"? ព្រះយេស៊ូ ក៏ឆ្លើយវិញថា " ដោយអ្នកមានជំនឿតិចពេក ខ្ញុំនិយាយជាការពិតប្រាប់អ្នកថាបើសិនមានអ្នកជំនឿ ដូចជាគ្រាប់ដើមស្ពៃហាង ហើយអ្នក នឹងនិយាយឡើងទៅកាន់ភ្នំនេះថា " ងើបឡើងពីទីនេះទៅទីនោះ វានឹងធ្វើតាមអ្នក ហើយគ្មានអ្វីដែលអ្នក នឹងពុំអាចធ្វើបានឡើយ" គម្ពីម៉ាថាយ (Matthew 17:19-21)។

๖ ត្រង់ចំនុចនេះព្រះយេស៊ូ និយាយទៅកាន់សាវ័ករបស់ព្រះអង្គថា ព្រះអង្គពុំមែនជាធនធានតែមួយគត់សម្រាប់ការព្យាបាលនេះទេ។ មនុស្សលោកក៏មានអានុភាពខ្លាំងក្លា ដូចជាគ្រាប់ដើមស្ពៃហាង បើសិនជាគេជឿជាក់ទៅលើសក្តានុពលរបស់ខ្លួន។ គ្រាប់ដើមស្ពៃហាងទោះបីជា គ្រាប់វាល្អិតមែនពិត តែវាអាចដុះទៅជាដើមធំ បើសិនជាវាដាំនៅលើដីល្អ។ ព្រះយេស៊ូ បានប្រាប់សាវ័ករបស់ព្រះអង្គថា ការដាំគ្រាប់ ឬការព្យាបាល គេពុំត្រូវអារកាត់ទុកជាមុនទៅលើមជ្ឈដ្ឋានដែលត្រូវដាំឡើយ អ្នកជម្ងឺ។ មជ្ឈដ្ឋានដែលត្រូវដាំខ្លះ និងអ្នកជម្ងឺខ្លះអាចមើលទៅឃើញហាក់បីដូចជា ទន់ខ្សោយ និងបោះបង់សក្តានុពលផ្លាស់ប្តូរនិន្នាការ (ភាពលំអៀង) ដោយគ្មានទាំងសាកល្បងទៀតផង។ ប៉ុន្តែវាជាការពិតផងដែរថា កំរិតតិចជាងគេបំផុតដែលដីអាចផលិតដំណាំបានល្អ និងអ្នកជម្ងឺឈឺខ្លាំងជាងគេ ទុរគតជាងគេអាចជាសះស្បើយបាន។

ផ្ទាំងគំនូរ *ភាពប្រែរូបព្រះយេស៊ូ* របស់លោរ៉ាហ្វែលបានទទួលការចាត់ទុកថា ជាឧទាហរណ៍ដ៏អស្ចារ្យ នៅក្នុងចំណោមគំនូរជំហ៊ានថ្មីៗនៃ (Incitements Dovozionale) "សេចក្តីអំពាវនាវប្តេជ្ញា ដោយសារការមានជំនឿ និងករុណាភាព(គោរពជ្រាលជ្រៅ)។ ដោយមានអត្ថន័យបញ្ជាក់ ទៅលើភាព (humanists) ស្នេហាមនុស្សធម៌" ផ្ទាំងគំនូរមួយនេះបានបង្ហាញថា មនុស្សលោក ក៏អាចចម្លងភាពផ្លាស់ប្តូរអាទិទេព (ឋានសួគ៌) តាមរយៈសកម្មភាពព្យាបាល (ឋានមនុស្សលោក)។ ដើម្បីសំរេចជោគជ័យទៅលើការអំពាវនាវសុខភាពទោះបីជាយ៉ាងណាក៏ដោយយើងត្រូវតែពុះពារអោយផុតពីសេចក្តីភ័យខ្លាចរបស់មនុស្សលោកជាមុនសិន។

## ផ្នែក ១. ការប៉ាន់ស្មានល្អលើលក្ខណៈជម្ងឺទៅថ្ងៃមុខ

ចំពោះវេជ្ជបណ្ឌិត និងអ្នកវិជ្ជាជីវៈពេទ្យ ដើម្បីឈានឆ្លងកាត់ពីសេចក្តីភ័យខ្លាចរបស់គេទៅភាពល្អ និងទីសុទិដ្ឋិនិយម(យល់ថាល្អទាំងអស់) គេត្រូវតែដឹងអំពីកាលៈទេសៈ ដែលទប់ស្កាត់មិនអោយគេឃើញអ្នកជម្ងឺរបស់គេនៅក្នុងលក្ខណៈផ្សេងៗ។ ជាភាពកម្រមានដែលអ្នកវិជ្ជាជីវៈព្យាបាល ចំណាយពេលតិចតួចជាមួយ និងអ្នកជម្ងឺរបស់គេហើយបានដកខ្លួនចេញពីសុក្រឹត(ប្រាកដនិយម)សង្គម ត្រូវទទួលស្គាល់អារម្មណ៍ជំទាស់ដែលខ្លួនគេមានទៅលើអ្នកជម្ងឺ។ មានអ្នកព្យាបាលតិចតួចណាស់ ដែលបានចូលរួមនៅក្នុងពិភពសង្គមរបស់អ្នកជម្ងឺ។ ហេតុដូច្នេះ អ្នកព្យាបាលបានការពាររូបគេពីភាពតាមសង្កេតមើលឃើញជាដំបូរអំពីអ្វីៗ ដែលបានកើតឡើងនៅផ្ទះ និងសហគម៍របស់អ្នកជម្ងឺ ភាពពិតច្បាស់លាស់ នៃជីវិតតក់ស្លុតនៅតែមើលពុំឃើញជាដដែល។

បន្ថែមទៀតចំពោះអ្នកវិជ្ជាជីវៈពេទ្យ រឿងតក់ស្លុតជារឿងដែលពុំទាក់ទងគ្នាខ្លាំង ទៅលើដំណើរការព្យាបាល។ វិទ្យាសាស្ត្រផ្នែកពេទ្យ និងផ្នែកសតិអារម្មណ៍ បែងចែករាង្គកាយ និងគំនិតយល់ដឹង បែងចែកជម្ងឺរបស់មនុស្សលោកទៅជាបំណែកវិតតែតូចៗ ទៅជាច្រើនបំណែករហូតទាល់តែនៅត្រឹមកំរិតពូជ និងកំរិតម៉ូលេគុល។ នៅក្នុងទម្រង់ព្រាងការយល់ដឹងអំពីរឿងតក់ស្លុតរបស់អ្នកជម្ងឺ និងការឆ្លើយតបទៅ និងពិភពធម្មជាតិគ្មានតម្លៃ ហើយសេចក្តីភ័យខ្លាចអ្វីមួយដែលអ្នកជម្ងឺមានក៏ពុំត្រូវការយកមកដោះស្រាយដែរ។ នៅខណៈដែលឥទ្ធិពលគំរូវិទ្យាសាស្ត្រ នេះពុំអាចធ្វើការបដិសេធបាន វាហាក់បីដូចជាពុំមានសមត្ថភាពអ្វីអាចជួយរំលែកសេចក្តីឈឺចាប់ និងរបួសដែលបណ្តាលឡើងដោយមនុស្សទៅលើមនុស្សម្នាក់ទៀតឡើយ។ ដូចគ្នា នឹង *ភាពប្រៀបព្រះយេស៊ូ* ដែលបង្ហាញនូវសេចក្តីឈឺចាប់ជាចំណែកសហគមន៍មួយ ផ្នែករបស់អ្នកជម្ងឺ មានរួមទាំងក្រុមគ្រួសារ អ្នកជិតខាង និងអ្នកព្យាបាលទៀតផង។

អ្នកព្យាបាលក្រិច (Creek) និង រ៉ូមែន (Roman)បុរាណអាចមានវិធីមានប្រយោជន៍ច្រើនទៅលើកិច្ចការរបស់គេ។ គេយល់ថាមនុស្សលោកជាចំណែកមួយ ផ្នែកនៃធម្មជាតិ ហើយជម្ងឺ និងការព្យាបាលរបស់គេជាចំណែកមួយផ្នែក នៃពិភពជុំវិញរូបគេ។ និមិត្តសញ្ញាការព្យាបាលរបស់ព្រះពីបុរាណកាល មានជារូបបុគ្គលិករុំព័ទ្ធដោយសត្វពស់។ បុគ្គលិកជានិមិត្តសញ្ញាឈើច្រត់របស់វេជ្ជបណ្ឌិត ដែលដើរពីផ្ទះមួយទៅផ្ទះមួយ និងពីភូមិមួយទៅភូមិមួយព្យាបាលអ្នកជម្ងឺរបស់គេ។ សត្វពស់គោរពចាត់ទុកជាឥទ្ធិពលព្យាបាល សត្វពស់ជាសត្វដែលរស់នៅក្នុងព្រៃ វាដឹងគុណភាពការព្យាបាលរបស់រុក្ខជាតិ និងថ្នាំបុរាណ ហើយរូងដែលវារស់នៅជាច្រកចូលទៅពិភពក្រោមដី ព្រះក្រោមដី។ នៅករណីដែលសត្វពស់សកស្រការ វាជាការអនុម័តថ្មី អំពីភាពកំចាត់រោគា ដើម្បី នឹងចាប់កំណើតជាជីវិតថ្មីពោរពេញទៅដោយសុខភាព។

វេជ្ជបណ្ឌិតបុរាណ ជាអ្នកវិជ្ជាសាស្ត្រពេទ្យល្អ និងជាសិល្បៈករចំណាន ដែលផ្តោតអារម្មណ៍ទៅលើការយល់ដឹងប្រវត្តិជីវិតជម្ងឺ ចាប់តាំងពីពេលវាកកើតឡើង និងសភាពបច្ចុប្បន្ន រហូតដល់គ្រាអនាគត។ តាមរយៈបទពិសោធន៍ ដោយផ្ទាល់ដៃជាមួយ និងអ្នកជម្ងឺ វេជ្ជបណ្ឌិតក្រិចជំនាន់ដើម គឺរស់នៅជាមួយនិងរោគ ដូច្នេះហើយបានជាគេយល់ដឹងអំពីភាពដែលអាចកើតមានឡើងនៅក្នុងរាង្គកាយ និងអារម្មណ៍របស់អ្នកជម្ងឺ បើសិនជាគ្មានការព្យាបាល។ ការបញ្ចេញប្រតិកម្មនៅ នឹងសេចក្តីយល់ដឹងនេះ គេបានគាំទ្រយ៉ាងសកម្មហើយជួយជម្រុញលើកទឹកចិត្តទៅលើដំណើរការព្យាបាលនេះ។

វេជ្ជបណ្ឌិតបុរាណក៏មានទស្សនៈផ្សេងៗគ្នា ទៅលើការប៉ាន់ស្មានលក្ខណៈរោគអនាគតកាល ខុសពីភាពដែលយើងមាននៅក្នុងបច្ចុប្បន្នកាលនេះ។ តួនាទីសម័យកាល ទៅលើការប៉ាន់ស្មានលក្ខណៈ រោគអនាគតកាល គឺ ដើម្បីវាស់ស្ទង់មើលលទ្ធភាពដែលវាអាចកើតមានឡើង។ ដែលមានភាពផ្ទុយគ្នា និងការប៉ានស្មានលក្ខណៈរោគ ដែលបានប្រើឡើងនៅក្នុងជំនាន់បុរាណ ដើម្បីជាការអះអាងថាលទ្ធផលប្រាកដណាមួយនឹងពិតជាកើតមានឡើង។ វេជ្ជបណ្ឌិតដឹងយ៉ាងច្បាស់នូវដំណើររោគា ហើយអាចប្រាប់អ្នកជម្ងឺ និងក្រុមគ្រួសារអំពីលទ្ធផលនោះ ហេតុដូច្នេះ វាអាចជួយសម្រាលភាពខ្វល់ខ្វាយ និងសេចក្តីភ័យខ្លាច ជាពិសេសបើលទ្ធផលដែលស្មានទុនជាមុន

នោះត្រូវទៅតាមការប៉ាន់ស្មាន។ សារៈសំខាន់ នៃការប៉ាន់ស្មានលក្ខណៈរោគទៅថ្ងៃមុខ គឺជាជំនួយការលើការព្យាបាលសតិអារម្មណ៍។ ចំពោះជនដែលពុំអាចព្យាបាលអោយជាបាន ហើយពិតជាស្លាប់ ត្រូវបញ្ជូនទៅវត្ត ឬទៅជួបអាចារ្យ ដើម្បីទទួលការព្យាបាលតាមសាសនា និងជំនឿ។ ទំនាក់ទំនងរវាងឥទ្ធិពលព្យាបាលជាធម្មជាតិ និងដោយប្រើថ្នាំ គឺបានបញ្ជាក់ឡើងនៅក្នុងអត្ថបទក្រិចទៅលើការព្យាបាលពេទ្យ៖

⁕ ការដេរ និងវះកាត់ដំបៅរលួយនៅក្នុងខ្លួនមនុស្ស គឺជាការព្យាបាលរបស់វេជ្ជបណ្ឌិត នេះក៏ជាការរចនាមួយចំណែករបស់វេជ្ជបណ្ឌិតក្នុងការបំបាត់អ្វីៗ ដែលធ្វើអោយមានការឈឺចាប់ ហើយការបំបាត់មូលហេតុ នៃការឈឺចាប់នេះអ្វីអោយមនុស្សមានសុខភាពល្អ។ ពិភពធម្មជាតិដឹងអំពីរបៀបទាំងនេះ នៅពេលដែលមនុស្សលោកអង្គុយចុះ វាជាពលកម្មក្នុងការក្រោកឈរឡើង ហើយនៅពេលដែលមនុស្សលោកកំពុងតែធ្វើចលនាវាជាលក្ខណៈពលកម្មក្នុងការត្រឡប់ទៅឈប់សំរាកវិញ។

⁕ ម្យ៉ាងវិញទៀតធម្មជាតិមានគុណភាពដូចគ្នា និងវិធីសាស្ត្រពេទ្យ វេជ្ជបណ្ឌិតបុរាណព្យាយាមអស់ពីសមត្ថភាពរបស់គេ ដោយប្រើដំណើរការព្យាបាលធម្មជាតិនៅកម្រិតអតិបរិមា និងបន្ថយភាពសាហាវរោគាទៅលើកាយសម្បទា និងសតិអារម្មណ៍របស់អ្នកជម្ងឺ គេប្រាប់អ្នកជម្ងឺថា៖ "ខ្ញុំដឹងពីរោគារបស់អ្នកហើយ នឹងជួយព្យាបាលអោយជា ឬយ៉ាងហោចណាស់ជួយសម្រាលសេចក្តីឈឺចាប់របស់អ្នក។

"អ្នកអាចមានជម្ងឺមហារីក ដំបៅរលួយ ឬមេរោគពុំធ្ងន់ធ្ងរ ឬជម្ងឺប្រហារជីវិត យោងទៅតាមរោគវិនិច្ឆ័យ អ្នកអាចមានសំណាងល្អ ហើយទទួលលទ្ធផលល្អ"។ ការប៉ាន់ស្មានលក្ខណៈរោគទៅថ្ងៃមុខ ទោះបីជាយ៉ាងណាក៏ដោយអាចយកមកប្រើដោយវេជ្ជបណ្ឌិតសម័យ ទុកជាជំហ៊ានទីមួយ ក្នុងការបង្កើតសេចក្តីទុកចិត្ត ទៅលើសហការព្យាបាលរួមគ្នាដែលគាំទ្រសមត្ថភាពព្យាបាលរបស់អ្នកជម្ងឺដោយខ្លួនឯង។ នៅពេលនេះគេបានដឹងគ្រប់គ្រាន់ទៅលើវិធីព្យាបាលរបស់ជនតក់ស្លុត ហើយអ្នកដែលជួយក្នុងដំណើរការព្យាបាលនេះ មានសុទិដ្ឋិនិយមដ៏លើសលប់។

សេចក្តីនៃការភ័យខ្លាចទៅលើលទ្ធផលមិនល្អ ឬភាពមិនល្អទៅលើការប៉ាន់ស្មានលក្ខណៈរោគទៅថ្ងៃមុខ វាគ្រាន់តែជាសេចក្តីភ័យខ្លាចមួយ ដែលពុំមែនយោងដោយជាក់លាក់ ទៅតាមមូលដ្ឋានពិត នៃវិទ្យាសាស្ត្រហើយបច្ចុប្បន្ននេះ អាចដោះស្រាយបានត្រឹមត្រូវដោយអ្នកព្យាបាល។ ក្នុងការរៀបចំឡើងវិញទៅលើការប្រើភាពប៉ាន់ស្មានលក្ខណៈរោគទៅថ្ងៃមុខ វេជ្ជបណ្ឌិតក៏ត្រូវតែចាប់ផ្តើមមានចម្ងល់សួរ និងទៅលើការយល់ដឹង ជាទូទៅសុខភាព។ ការរៀបចំមូលដ្ឋានសាធារណៈសុខាភិបាល បច្ចុប្បន្នកាល ជាអត្ថន័យដែលបានបង្កើតឡើងដោយអង្គការសុខាភិបាលពិភពលោក ( World Health Organization ហៅកាត់ WHO ): សុខភាពជាស្ថានភាពកាយសម្បទាសតិអារម្មណ៍ និងសុខុមាលភាពសង្គមទាំងមូល ហើយពុំមែនជាស្ថានភាពគ្មានរោគា ឬគុណវិបត្តិឡើយ។"[4] នេះជា អត្ថន័យតម្រាបុរាណដែលប្រមូលផ្តុំឡើងដោយអង្គកាសហប្រជាជាតិ យូអិន UN បន្ទាប់ពីសង្គ្រាមលោកលើកទីII ដែលចាត់ទុកថាជាអ្នកឈានមុខក្នុង (របៀបថ្មី)។ ចាប់តាំងពីកំណត់ពេលដែលអត្ថន័យនេះចាប់បដិ

សន្និទ្បើង ដោយមកពីភាពខ្វះខាតសេចក្តីយកចិត្តទុកដាក់ទៅលើរោគា និងសេចក្តីបារម្ភ ដែលទាក់ទង នឹងសុខុមាលភាពកាយសម្បទា និងសតិអារម្មណ៍។

តែអត្ថន័យនេះក៏បានរៀបចំក្រិតក្រមអត្ថន័យ សុខភាពដោយគ្មានការប្រឆាំងជំទាស់ ការផ្លាស់ប្តូរ ទូទាំងសាកលទៅលើការយល់ដឹងអំពីសុខភាព នៅពេលនេះកំពុងមានដំណើរការ ជាពិសេសចលនាប្រឆាំងរបស់ស្ត្រីទៅ និងគំនិតថា គេចាត់ទុកមនុស្សថាមានសុខភាពល្អ ដោយគេគ្មានរោគា ផ្ទុយ នឹងកត្តាពិតដែលគេបានទទួលសេចក្តីគាបសង្កត់ មានឱកាសតិចតួចសំរាប់សិក្សា និងប្រកបការងារ ឬប្រឈមមុខ និងអំពើ ហឹង្សា ឬអំពើបំពានផ្លូវភេទ ។ ស្ត្រីឥណ្ឌាបច្ចុប្បន្ននេះ សរសេរពត៌មាន និងអត្ថន័យសុខភាពដែលអាចយកមកប្រើនៅក្នុងសង្គមតក់ស្លុតទាំងអស់៖

- សុខភាពជាសភាពលំ នឹងរាង្គកាយ សង្គម និងសុខុមាលភាព ដែលមនុស្សមានអារម្មណ៏រឹងមាំសកម្ម ឈ្លាសវៃ និងមានតម្លៃ វាជាទីដែលគេអោយតម្លៃទៅលើសមត្ថភាពទីទៃគ្នា និងចលនា ជាទីដែលគេសំរេចជ្រើសយកមក បញ្ចេញអារម្មណ៍របស់គេ និងធ្វើចលនាតាមចំណង់ចិត្ត។
- អត្ថន័យនេះបង្ហាញឡើងថាសុខភាពជាថាមពលដំណើការសកម្ម ស្របតាមគំរូព្យាបាលដោយខ្លួនឯង។ យោងតាមអត្ថន័យថ្មីនេះ ជនរងគ្រោះដោយអំពើបំពាន គាបសង្កត់ ហើយនៅតែទទួលបានបែបនេះ ជាបន្តទៀតពុំអាចចាត់ទុកថា មានសុខភាពល្អនៅឡើយទេ។ អំពើសាហាវឃោរឃៅត្រូវតែបំបាត់ចោល ហើយជនទាំងនេះត្រូវតែទទួលយកឱកាសកំរិតអតិបរិមា ដើម្បីសុខុមាលភាពរបស់គេ និងសក្តានុភាព(ភាពដែលគេអាច)គេអាចព្យាបាលឲ្យជាសះស្បើយ។

## ១.១ ជំហ៊ានសំរាប់ព្យាបាលខ្លួនឯង

នៅក្នុងឆ្នាំ២០០០ មន្ទីរសុខភាពរបស់ខ្ញុំ ចាប់ផ្តើមធ្វើការពិសោធន៍ ដើម្បីគាំទ្រសុខភាព ដោយយោងទៅតាមទស្សនៈថ្មីៗ នៃភាពព្យាបាលដោយខ្លួលឯង និងភាពពង្រីកអត្ថន័យសុខភាព ផ្នែកសង្គមវិជ្ជា និងចិត្តវិជ្ជាសំរាប់ជនជួបប្រទះភាពតក់ស្លុត។ ការទទួលយកទស្សនៈរបស់លោក ឌឹកគ្លាស់ បើនណិត Douglas Bennett "ការព្យាបាលជម្ងឺសរសៃប្រសាទ ក្រឡាប់ចាក់" ផ្តល់សុខភាពដ៏ប្រសើរបំផុតដល់ជនក្រីក្រជាងគេបំផុត និងប្រជាជនជួបប្រទះភាពតក់ស្លុតខ្លាំងបំផុតយើងបានចាប់ផ្តើមធ្វើបទពិសោធន៍នេះ នៅទីក្រុងឡូវេស រដ្ឋម៉ាស្សាឈូហ្សែក Lovell, Massachusetts ជាទីក្រុងឧស្សាហកម្មដែលជាទីលំនៅរបស់ជនភៀសខ្លួនខ្មែរចំនួន ជិត៤ម៉ឺននាក់ និងជាសហគមន៍ខ្មែរធំជាងគេកំរិតលេខ២ នៅសហរដ្ឋអាមេរិក។ ក្រុមការងារហាវើដ Harvard បានដឹងឮ តាមស្ថិតិក្រសួងសាធារណៈសុខាភិបាលថា នៅក្នុងចំណោមជនជាតិខ្មែរវ័យមជ្ឈឹម និងវ័យចំណាស់ គេមានរោគទឹកនោមផ្អែម និងជម្ងឺផ្សេងៗ ដែលទាក់ទង និងភាពធុញថប់អារម្មណ៍។ អ្នកដឹកនាំសហគមន៍គាំទ្រយ៉ាងខ្លាំងទៅលើ

គម្រោងការណ៍នេះ គេបានប្រមូលរូចផុតពីសេចក្តីស្លាប់ដោយអំពើសម្លាប់រង្គាលជនជាតិខ្មែរ អោយចូលរួមនៅក្នុងថ្នាក់រៀន ដើម្បីបង្កើនឥទ្ធិពលការព្យាបាលដោយខ្លួនឯងទាំង ផ្នែកចិត្តសាស្ត្រទាំងផ្នែកសង្គម។

កំណត់ពេលជាងបីឆ្នាំ សមាជិកសហគមន៍ ចំនួន មួយរយនាក់ បានស្ម័គ្រចិត្តចូលរួមថ្នាក់រៀនសុខភាព ភាគច្រើនជាបុរស ស្ត្រីវ័យមជ្ឈឹម និងវ័យជរា។ គ្រប់គ្នាគេបានរស់នៅក្នុងរបបសម្លាប់រង្គាលប៉ុលពតប្រហែល ចំនួន មួយភាគបី មានទុក្ខព្រួយយ៉ាងធ្ងន់ធ្ងរហើយភាគច្រើនពុំមានទទួលការព្យាបាលឡើយ។[6] ថ្នាក់នីមួយៗ មានអ្នកចូលរួម ចំនួនម្ភៃប្រាំនាក់ គេជួបគ្នារៀងរាល់អាទិត្យ ចំនួនពីរម៉ោង ក្នុងរយៈពេលចំនួនបីខែ ហើយគេមានធ្វើពិធីអបអរបញ្ចប់ការសិក្សានៅកំណត់ពេលបញ្ចប់កម្មវិធី។ ថ្នាក់រៀនដឹកនាំដោយអ្នកស្រីស្វាង តោ Svang Tor និងរូបខ្ញុំដោយផ្តោតអារម្មណ៍ទៅលើវិធីដោះស្រាយបញ្ហាសុខភាពខ្លាំង ដែលកើតមានឡើងនៅលើកាយសម្បទា និងសតិអារម្មណ៍ដែលទាក់ទង និងអំពើសាហាវយង់ឃ្នង។ ការចូលរួមនៅក្នុងថ្នាក់រៀនតម្រូវអោយមានការប្តេជ្ញាចូលរួម និងគាំទ្រទៅលើប្រធានបទភាពព្យាបាលដោយខ្លួនឯងៈ សេចក្តីសង្ឃឹមថាសុខភាព នឹងបានប្រសើរឡើង ដោយពុំគិតពីលក្ខណៈសុខភាពបច្ចុប្បន្ន និងភាពទទួលស្គាល់មតួនាទីជាសិស្សរបស់យើង ពុំមែនជាអ្នកជម្ងឺរបស់យើង គេនឹងទទួលការបង្ហាត់បង្រៀនជំនាញសំរាប់បង្កើនភាពព្យាបាលដោយខ្លួនឯងរបស់គេ។

វាជាភាពងាយស្រួលអស្ចារ្យក្នុងការយកប្រជាជនខ្មែរមកចូលរួម ប្រជាជនខ្មែរភាគច្រើនបានទទួលការប្រមូលដោយចូលរួមពី ផ្នែកកម្មវិធីសង្គមកិច្ច ពីផ្នែកមណ្ឌលសហគមន៍ខ្មែរប្រចាំតំបន់ មានអ្នកខ្លះក៏អាក់ខានពីរទៅបីដង ទោះបីជាយ៉ាងណាក៏ដោយភាគច្រើនបានចាប់ផ្តើមដោយភាពសង្ឃឹមច្រើនថា ថ្នាក់រៀន នឹងជួយដល់រូបគេ។ គ្មាននរណាម្នាក់បានទទួលការបង្ហាត់បង្រៀនអំពីប្រធានបទចាំបាច់ នៃទម្លាប់ដំណើរជីវិតប្រកបដោយសុខភាពល្អ នៅប្រទេសខ្មែរ ហើយគេក៏គ្មានគំនិតអ្វីមួយដឹងថា បទពិសោធន៍សាហាវឃោរឃៅប៉ះពាល់ដល់សុខុមាលភាព កាយសម្បទា និងសតិអារម្មណ៍របស់គេកំរិតណាដែរ។ ទោះយ៉ាងណាក៏ដោយ សូម្បីតែ ជនជរាដែលគ្មានចំណេះវិជ្ជាអ្វីសោះ អាចទទួលស្គាល់ប្រធានបទនេះនៅពេលដែលគេបានទទួលការណែនាំ។

## ១.២ ចំណីអាហារ និងការហាត់ប្រាណ

ផ្នែកស្រាវជ្រាវសម័យថ្មី បានពង្រឹងតួនាទីដ៏សំខាន់ នៃចំណីអាហារ និងការហាត់ប្រាណ ដើម្បីរក្សា និងបណ្តុះបណ្តាលសុខុមាលភាព។ ចំណីអាហារល្អ និងការហាត់ប្រាណប្រចាំថ្ងៃ ជាកត្តាសក្តានុភាពពិតក្នុងការបន្ថយភាពតក់ស្លុតដែលទាក់ទង និងបញ្ហារការំរកូសចិត្ត និងសុខភាព។ ការហាត់ប្រាណ ឧទាហរណ៍បានបង្ហាញថាមានប្រសិទ្ធិភាពក្នុងការព្យាបាលអារម្មណ៍ក្រៀមក្រំគ្រប់វ័យទាំងអស់។ ការហាត់ប្រាណពុំត្រឹមតែសម្រាលភាពតានតឹងអារម្មណ៍នោះទេ តែវាជួយបង្កើនកម្លាំងសាច់ដុំ និងបង្កើនសុខភាពផ្នែកបេះដូង។ ជាចំណែកមួយផ្នែកនៅក្នុងថ្នាក់រៀន យើងផ្តល់ពត៌មានដោយផ្ទាល់អំពីការហាត់ប្រាណ និងចំពីអាហារ ហើយផ្តល់យោបល់ទៅលើសកម្មភាពសាមញ្ញនេះ សូម្បីតែជនដែលរួចផុតពីសេចក្តីស្លាប់មានវ័យជរាជាងគេក៏ទទួលយោបល់ដូចគ្នាដែរ។ នៅពេលដែលសិស្សបានទទួលការប្រាប់អោយដឹងថា មានតែជនមួយជំពូកទេដែលគ្មាន

ទទួលផលប្រយោជន៍ល្អពីចំណីអាហារល្អ និងការហាត់ប្រាណ គឺសាកសព គេទាំងអស់នាំគ្នាសើចដោយអស់សំណើច។ អ្នករួចផុតពីសេចក្តីស្លាប់រីករាយដោយបានរៀនអំពីវិធីសាមញ្ញ ដើម្បីធ្វើអោយជីវិត និងសុខុមាលភាពរបស់គេ មានភាពរីកចំរើនឡើង ដែលមិននាំមក ឬធ្វើអោយរូបគេមានអារម្មណ៍ទោរទន់ខ្លាំង។

នៅលើកដំបូងសិស្សនាំគ្នាយកតែនំដូរណាត់ និងទឹកក្រូចមកញុាំលេងនៅក្នុងថ្នាក់រៀន វាក្លាយទៅជាភាពឃើញថា គេភ្លេចគិតពីម្ហូបខ្មែរដែលមានគ្រឿងផ្សំដោយជីវជាតិ និងឆ្ងាញ់ពិសារ ហើយគេទទួលទានច្រើនជាងគេ គឺសាច់ត្រី ផ្លែឈើ និងបន្លែស្រស់។ អ្នកខ្លះនៅចាំក្លិនឈ្ងុយឈ្ងប់ និងរសជាតិដ៏ឆ្ងាញ់ពិសារនៃម្ហូបខ្មែរសាមញ្ញ ដែលពុំមានគ្រឿងផ្សំល្បីល្បាញជាប្រវត្តិសាស្ត្រ និងប្រពៃណីឡើយ។ ចំពោះជនជាច្រើនរូបចំណីអាហាររបស់អាមេរិកកាំងគ្រាន់បើជាងម្ហូបអាហារខ្មែរ ដោយអន្លើថាវាទាន់សម័យ ស្រស់ស្អាត និងងាយស្រួល តែជាទូទៅ គឺវាជារបស់អាមេរិកកាំង។ គេចង់សម្របសម្រួលខ្លួលគេទៅប្រទេសថ្មីរបស់គេ ទោះបីវាជាបែបបទសើរៗ តែសំបកក្រៅក៏ដោយ ដូចជាការទទួលទានម្ហូបអាហារអាមេរិកជាដើម។ ក្រោយពីពិភាក្សាអំពីម្ហូបចំណីល្អ សិស្សចាប់ផ្តើមយកផ្លែចេក ផ្លែទំពាំងបាយជូរ ក្រូចពោធិ៍សាត់ និងទឹកដោយពុំចាំបាច់ប្រាប់អោយយកឡើយ ។ ការផ្តល់អត្ថន័យពិសេស ទៅលើភាពពេញចិត្ត ទៅលើម្ហូបអាហារជាទំនៀមទម្លាប់ និងប្រវត្តិសាស្ត្ររបស់គេ ពុំត្រឹមតែធ្វើអោយគេមានអាម្មណ៍ល្អទៅលើសុខុមាលភាព តែវាជាមោទនភាពអត្តសញ្ញាណសញ្ជាតិរបស់ខ្លួនគេ។

លំហាត់មួយហៅថា "ភ្លក់រសជាតិផ្លែចេក" អ្នកចូលរួមបានទទួលការប្រាប់ថាអោយកាច់ចេកជាកំណាត់ៗ ដាក់ចូលក្នុងមាត់ ហើយភ្លក់រសជាតិ និងសាច់ចេកមួយមាត់ៗ បន្តិចម្តងៗ។ វាជាភាពរីករាយក្រៃលែង! ផ្លែចេកមានរស់ជាតិឆ្ងាញ់ពិសារ។ គេចាំពុំបានថាកំណត់ពេលចុងក្រោយដែលគេពិតជាភ្លក់រស់ជាតិផ្លែចេក ឬម្ហូបអាហារដើមកំណើតរបស់គេជាកំណត់នៅពេលណាឡើយ។ គេបានទទួលការស្នើសុំអោយសប្បាយរីករាយ និងការរៀបចំម្ហូបអាហារគ្រប់បែបនៅលើកក្រោយ ដោយចាប់ផ្តើមទាំងពីការរៀបចំ ចំអិនអាហាររបស់គេ រហូតដល់ទៅការទទួលទានដោយយឺតៗ ហើយចាប់អារម្មណ៍ដោយលំអិតទៅលើមុខម្ហូបដែលគេចំអិន រួមទាំងក្លិន និងរស់ជាតិ។ លទ្ធផលនៃការចាត់តាំងតែងតែជាភាពរំភើប នៅខណៈដែលជនជួបប្រទះភាពតក់ស្លុតរាយការណ៍អំពីភាពរីករាយទាំងស្រុងទៅលើម្ហូបអាហាររបស់គេជាលើដំបូង ដែលគេពុំបានធ្វើយូរមកហើយនោះ។ នៅក្នុងស្ថានភាពមហាសាហាវយង់ឃ្នង អ្នកខ្លះបានជួបប្រទះ និងភាពអត់ឃ្លាន ឬត្រូវបង្ខំអោយទទួលទានម្ហូបអាហារស្អុយរលួយ និងម្ហូបអាហារខូច។ ដោយមកពីមានប្រវត្តិសាស្ត្របែបនេះ ម្ហូបអាហារបែបនេះបានបាត់បង់តម្លៃនៅក្នុងវិធីវប្បធម៌ និងសង្គមផ្សេងៗ។ វាមានផលប្រយោជន៍ដ៏ល្អទៅលើសុខភាព ក្នុងការស្តារចំណាប់អារម្មណ៍របស់អ្នកទាំងនោះទៅលើម្ហូបអាហារដែលជាទំនៀមទម្លាប់របស់គេ។

គោលដៅមួយនៃថ្នាក់រៀននេះ គឺជួយសិស្សអោយដឹងអំពីស្ថានភាពកាយសម្បទារបស់ខ្លួន តែជាដំបូងគេត្រូវតែទទួលស្គាល់ភាពពិតអំពីអ្វីៗ ដែលគេបានទទួលបទពិសោធន៍ទៅលើរាង្គកាយរបស់ខ្លួនគេ។ ភាពសាហាវយង់ឃ្នង និងទារុណកម្មបន្សល់ទុកនូវស្លាកស្នាមមានរូបរាង និងគ្មានរូបរាងនៅលើរាង្គកាយបានផ្តិតជាប់នូវប្រវត្តិអំពើសាហាវឃោរឃៅ នៅលើរាងកាយមួយផ្នែកៗ និងប្រព័ន្ធសេរីរាង្គទទួលរងគ្រោះដោយអត់ធន់ និងអំពើ

សាហាវយង់ឃ្នងដែលបានកើតមានឡើងដល់រូបគេ។ អំពើរំលោភផ្លូវភេទ ឧទាហរណ៍ គឺធ្វើអោយជនរងគ្រោះនឹកឃើញអំពើទាំងនោះដោយស្លាកស្នាមនៅលើសុដន់ (ដោះ) ឬប្រដាប់ភេទ ព្រមទាំងរោគរលាកស្បូនរ៉ាំរ៉ៃ រោគថ្លើមប្រភេទ រោគមហារីកស្បូន និងរោគអេចអាយវី HIV/AID។ សិស្សខ្មែរបានទទួលការបង្រៀនថាភាពតក់ស្លុត និងទារុណកម្មគ្រប់បែបយ៉ាង ផ្តល់ផលវិបាកដល់រាង្គកាយជាយូរអង្វែង ហើយទុក្ខកង្វល់រ៉ាំរ៉ៃអាចបង្កើតភាពតានតឹងដល់កាយសម្បទា ដែលធ្វើអោយរាង្គកាយខ្សោយកម្លាំង និងបន្ថយលទ្ធភាពចលនានៅពេលក្រោយៗមកទៀត។ ជាពិសេសស្ត្រីៗ គាត់ពេញចិត្ត និងថ្នាក់រៀននេះ ដោយស្ត្រីខ្មែរបានទទួលការបង្ហាត់បង្រៀនអោយចាត់ទុកកាយសម្បទានៅដោយឡែកពីខ្លួនគេ។ គេនៅតែយកសំលៀកបំពាក់ វប្បធម៌របស់ខ្លួនមករុំរាង្គកាយជិតគេពីក្បាលទៅចុងជើង លាក់បាំងរាង្គកាយ និងភេទរបស់ខ្លួន។

ថ្នាក់រៀនជម្រុញអោយស្ត្រីដែលរងរបួស ជាពិសេសដោយអំពើបំពានរំលោភផ្លូវភេទ ប្រាប់វេជ្ជបណ្ឌិតរបស់គេអោយជួយដោះស្រាយស្នាមរបួសទាំងនោះ។ លំហាត់សំខាន់បានចាត់តាំងឡើងនៅក្នុងថ្នាក់រៀននេះគឺការដើរជារៀងរាល់ថ្ងៃ ចំនួន ២០ នាទី។ ការចាត់តាំងនេះបានទទួលការអនុវត្តន៍តាមយ៉ាងឆាប់រហ័ស ដោយសិស្សរួមថ្នាក់ណាត់ជួបគ្នារួចដើរជាក្រុម។ គ្មានទិដ្ឋភាពណាមួយដែលមើលទៅឃើញរំភើបរីករាយជាង ការឃើញជនជាតិខ្មែរផ្លាស់ប្តូរដោយដើរជាក្រុមនៅជុំវិញទីក្រុងឡូវែល និងអគារជំនាន់ដើម ប្រកបដោយទឹកមុខរីករាយទទួលខ្យល់ឱកាសបរិសុទ្ធ និងការហាត់ប្រាណកាយសម្បទា។ ចំពោះស្ត្រីភាគច្រើននៅក្នុងថ្នាក់រៀន វាជាបទពិសោធន៍ផ្លាស់ប្តូរមូលដ្ឋានដោយគេមានអារម្មណ៍ថា រាង្គកាយរបស់គេធ្វើចលនា។ ដោយមានបន្ទុកកិច្ចការផ្ទះ និងសេចក្តីទទួលខុសត្រូវជាច្រើននៅក្នុងផ្ទះ តម្រូវអោយវេជ្ជបណ្ឌិតចេញវេជ្ជបញ្ជា ដើម្បី អោយក្រុមគ្រួសារ និងសហគមន៍ អនុញ្ញាតអោយស្ត្រីទាំងនោះឈប់សំរាកពីការងារ ហើយយកពេលដែលគេត្រូវការទៅធ្វើការហាត់ប្រាណ ដោយគ្មានការទិតៀន ឬអ៊ូរទាំពីក្រុមគ្រួសារ ឬសហគមន៍ អ្នកទាំងអស់គ្នារីករាយក្នុងការហាត់ប្រាណ ហើយបានបង្កើតចំណងមិត្តភាពជាមួយ និងអ្នកដើរហាត់ប្រាណឯទៀត។

## ១.៣ ភាពកាត់បន្ថយកំហឹង

នៅខណៈពេល ដែលជនជាតិខ្មែរមកជួបជុំគ្នាក្នុងថ្នាក់រៀនសុខភាព ទឹកមុខរបស់គេបង្ហាញនូវភាពតក់ស្លុតអតីតកាល បច្ចុប្បន្នកាល និងភាពតស៊ូក្នុងការបំបាត់ទុក្ខព្រួយដែលគេមាននៅក្នុងខ្លួនរបស់គេ។ គេបានឆ្លងកាត់ស្ថានភាពដំណើរជីវិតដែលយើងរាល់គ្នាពុំអាចនឹកស្មានគិតថា យើងអាចរស់រានមានជីវិតបាន។ នៅដើមឆ្នាំ១៩៩០ នៅពេលដែលក្រុមរបស់យើងប្រមូល(ទិន្នន័យ) ជាលើដំបូងអំពីបទពិសោធន៍ជីវិតតក់ស្លុតរបស់ជនភៀសខ្លួននៅជុំរុំសាយធូ លទ្ធផលគ្រាដំបូងធ្វើអោយយើងភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ជនអាយុលើសពី១៨ឆ្នាំឡើងទៅ ចំនួន មួយពាន់បួន(១,០០៤)នាក់ បានជួបប្រទះ និងព្រឹត្តិការណ៍តក់ស្លុតធំៗ សរុបទាំងអស់ ចំនួន ១៦,០០០នាក់ ។[8] ដោយយើងសួរតែអំពីព្រឹត្តិការណ៍ដែលកើតឡើង ហើយពុំមានសួរអំពីកំរិតចំនួនដែលកើតមានឡើង ចំនួននេះពិតជាតិចជាងចំនួនប៉ាន់ស្មាន ដោយជនភៀសខ្លួនម្នាក់ៗ បានទទួលបទពិសោធន៍លើសពី

ចំនួនមួយដង។ ចំនួនដ៏ច្រើននេះធ្វើអោយយើងមន្ទិលសង្ស័យថា តើអានុភាពកំរិតណាអាចកើតមានឡើងដល់សុខភាពរបស់អ្នកដែលរួចផុតពីសេចក្តីស្លាប់ នៅពេលក្រោយមកដោយសារព្រឹត្តិការណ៍ទាំងនេះ ជាលទ្ធផលបទពិសោធន៍ទាំងនេះក្លាយទៅជាស្មារតី ដែលផុតកំដៅអារម្មណ៍របស់គេអោយនៅពុះកញ្ជ្រោលជានិច្ច។

ជនជាតិខ្មែរដែលរួចផុតពីសេចក្តីស្លាប់ បានរាយការណ៍ឡើងនៅទីក្រុងឡូវែល ថាចំនួន ម្ភៃពីរឆ្នាំក្រោយមកពីរបបប៉ុលពត អ្វីៗដែលមានឡើងដល់រាងកាយ និងខួរក្បាលរបស់គេនៅតែពុះកញ្ជ្រោលដោយអារម្មណ៍ទោរទន់ជារៀងរាល់ថ្ងៃ ទៅលើសេចក្តីឈឺចាប់ដែលទាក់ទង នឹងភាពតក់ស្លុតរបស់គេ។ គេទាំងអស់គ្នាទទួលយល់ព្រមថាគេពុំទាន់រកឃើញវិធីណាមួយ ដែលអាចបន្ថយកំហឹងពុះកញ្ជ្រោលនេះបានឡើយ។ គ្មានជនជាតិខ្មែរណាម្នាក់យល់ដឹងពីទុក្ខព្រួយដែលខ្លួនគេមាន និងនៅតែមានជាបន្ត ដែលកើតឡើងដោយបទពិសោធន៍ជីវិតហើយបានធ្វើអោយមានផលវិបាកដល់សុខភាព និងសុខុមាលភាពរបស់គេឡើយ។ ជនរួចផុតពីសេចក្តីស្លាប់រន្ធត់ចិត្តនៅពេលដែលគេដឹងថារឿងតក់ស្លុតបណ្តាលអោយមានទុក្ខព្រួយ ដែលធ្វើ អោយមានពោគលើសឈាម ជម្ងឺបេះដូង ថែមទាំងជម្ងឺមហារីក ជាជម្ងឺទាំងអស់ដែលកើតឡើងច្រើនក្នុង ពាក់បណ្តាលប្រជាជនរួចផុតពីសេចក្តីស្លាប់ ជាងពាក់បណ្តាលប្រជាជន ដែលគ្មានទទួលភាពតក់ស្លុត ។[9] ប៉ុន្តែ វាជាភាពគ្មានអ្វីលំបាកសំរាប់យើង ក្នុងការបង្រៀនជនជាតិខ្មែរថាទុក្ខព្រួយបណ្តាលអោយជម្ងឺនេះកើតមានឡើង ដោយនៅក្នុងពេលនេះគេអាចមើលឃើញ ហើយដឹងស្គាល់ជម្ងឺទាំងនោះនៅក្នុងខ្លួន និងជីវិតរបស់គេ។

នៅក្នុងដើមឆ្នាំ១៩៥០ លោកថម៉ាស ហម(Thomas Holmes) និងរេចឆឺដ រ៉ាហេ (Richard Rahe) អ្នកវិទ្យាសាស្ត្រជំនាញដើងចាស់បានធ្វើការស្រាវជ្រាវ ទៅលើផលវិបាកព្រឹត្តិការណ៍ដំណើរជីវិតកើតមានឡើងទៅលើសុខភាព និងជម្ងឺ ។ នៅក្នុងឆ្នាំ១៩៦៧ គេបានបោះពុម្ពផ្សាយមាត្រាដ្ឋានសំរាប់កត់សំគាល់ព្រឹត្តិការណ៍ទុក្ខព្រួយក្នុងជីវិត ចំណុចដែលមានឥទ្ធិពលជាងគេគឺ៖

| ព្រឹត្តិការណ៍ | កំរិតរបស់ឥទ្ធិពល |
|---|---|
| មរណៈភាពរបស់ស្វាមីភរិយា | ១០០ |
| ការលែងលះគ្នា | ៧៣ |
| ការបែកបាក់គ្នារវាងប្តីប្រពន្ធ | ៦៥ |
| ការជាប់ឃុំឃាំង | ៦៣ |
| មរណៈភាពរបស់សមាជិកក្រុមគ្រួសារជិតដិត | ៦៣ |

មរណៈភាពរបស់ស្វាមី និងភរិយាមានកំរិតច ចំនួន១០០ នៅត្រង់នេះចាត់ទុកជាព្រឹត្តិការណ៍ទុក្ខព្រួយខ្លាំងជាងគេនៅក្នុងជីវិត។ តាមកំរិតមាត្រាដ្ឋាននេះ លោក Holmes និង លោក Rahe អាចបូកបញ្ចូលកំរិតពិន្ទុ

នៃបទពិសោធន៍ទុក្ខព្រួយទាំងអស់របស់ជនណាម្នាក់ ដើម្បីរកកម្រិតពិន្ទុសរុបដែលគេអាចយកមកធ្វើការប៉ាន់ស្មាន ថាតើជននេះ នឹងអាចក្លាយទៅជាឈឺ។ ឧទាហរណ៍ ចំនួនពិន្ទុសរុបនៅចន្លោះពី១៥០ និង១៩៩ នៅក្នុងរយៈពេលជាង១ឆ្នាំ ភាពអាចទៅជាឈឺមានកម្រិត ចំនួន ៣៧ ភាគរយ នៅមួយឆ្នាំក្រោយទៀត ចំនួនពិន្ទុសរុបនៅចន្លោះពី ២០០ និង ២៩៩ មានកម្រិត ៥១ ភាគរយ ចំនួនពិន្ទុសរុបលើសពី ៣០០ មានកម្រិត ៧៤ ភាគរយ។ ជនជាតិខ្មែរដូចគ្នា នឹងជនជាតិជាច្រើនទៀត ដែលទទួលបទពិសោធន៍ មហាសាហាវយង់ឃ្នង មានកម្រិតពិន្ទុច្រើនហួសពីកម្រិតមាត្រដ្ឋាន អាចធ្វើអោយមានបញ្ហាគំរាមកំហែង ដល់សុខភាពរបស់គេ។

សិស្សបានទទួលការបង្រៀនថា ជារៀងរាល់ថ្ងៃ ព្រឹត្តិការណ៍មហាសាហាវយង់ឃ្នង ចាប់ផ្តើមមានប្រតិកម្មជាបែបទូទៅ វាយតប ឬរត់គេច។ ផងដែរមានប្រតិកម្មសរិរៈវិទ្យា (ដំណើរការសេរីរាង្គ) ជាច្រើនដែលជួយតម្រង់អោយមនុស្សរួចផុតពីសេចក្តីស្លាប់ មានរួមទាំងសារជាតិអ័រម៉ូន ដែលបង្កើនថាមពល សំរាប់បញ្ចេញសារជាតិ អ៊ិនដ័រហ្វីន Endorphin ជាសារជាតិបំបាត់ការឈឺចាប់ជាធម្មជាតិរបស់រាង្គកាយ។ នៅករណីដែលគ្មានជំនួយទៅលើភាពតក់ស្លុតនោះទេ ការឆ្លើយតប នឹងទុក្ខព្រួយរបស់មនុស្សម្នាក់ៗ អាចមានប្រតិកម្មច្រើនហួស ធ្វើអោយប្រព័ន្ធនោះខូចខាត។ អ្នករួចផុតពីសេចក្តីស្លាប់ដែលពុំអាចគេចពីភាពវិលវល់នេះ បានក្លាយទៅជាទន់ខ្សោយរាង្គកាយ និងអស់សង្ឃឹម រហូតទាល់តែកាយសម្បទា និងសតិអារម្មណ៍ជាយថាហេតុទទួលភាពលើសលប់ក្រៃលែង។

សិស្សទាំងអស់របស់យើង បានទទួលការបង្ហាញពីដំណើរការ ដែលប៉ះពាល់ជីវិតរបស់គេ គេក៏បានដឹងថា សូម្បីតែគិតអំពីអំពើសាហាវយង់ឃ្នងដែលបានកើតឡើងជាយូរឆ្នាំមកហើយ ធ្វើអោយការឆ្លើយតបទៅនឹងទុក្ខព្រួយមានសកម្មភាពរស់រវើកឡើងវិញ ហាក់បីដូចជា ព្រឹត្តិការណ៍នោះកើតមានឡើងជាម្តងទៀត ។ ភាពគិតអំពីសេចក្តីតក់ស្លុតនីមួយៗ និងទុក្ខព្រួយនីមួយៗ នាំមកនូវកំហឹងពុះកញ្ជ្រោល ដូចជា ទឹកពុះនៅក្នុងឆ្នាំង ជាយថាហេតុបណ្តាលអោយកើតមានជម្ងឺ។ យើងក៏ផ្តោតអារម្មណ៍បង្រៀនអ្នកទាំងនោះ ពីបច្ចេកទេសបំបាត់កំហឹង ដោយយកក្រុមគ្រួសារ អ្នកចាស់ទុំក្នុងសហគមន៍មកជួយដោះស្រាយបញ្ហា ហើយប្រើបច្ចេកទេសបន្ធូរអារម្មណ៍ ដូចជាការបន់ស្រន់ និងភាវនា។

## ១.៨ ការក្បត់ និងការរួបរួមក្នុងក្រុមគ្រួសារ

ភាពសាហាវយង់ឃ្នងប៉ះពាល់ដល់ក្រុមគ្រួសារ ពុំត្រឹមតែតាមរយៈអំពើកាប់សម្លាប់ចោល ភាពបាត់ខ្លួន និងភាពបាត់បង់ផ្ទះសម្បែងនោះទេ តែវាក៏ប៉ះពាល់ដល់អារម្មណ៍ ដោយបង្កើតទំនាស់នៅក្នុងក្រុមគ្រួសារ ដែលហាក់បីដូចជា មិនអាចដោះស្រាយបាន។ ជនជួបប្រទះភាពតក់ស្លុក ជាទូទៅមានជំនឿ ហើយជាញឹកញាប់ទុកបញ្ហានោះជាភាពសម្ងាត់ និងពុំនិយាយបញ្ចេញអោយគេដឹងថា បុគ្គលជិតស្និទនៅក្នុងក្រុមគ្រួសាររបស់ខ្លួន ឬមិត្តសម្លាញ់សំខាន់របស់ខ្លួនបានក្បត់ខ្លួន។ អារម្មណ៍ឈឺចាប់ទៅលើការក្បត់ ជាទីបញ្ចប់បានជ្រាបដល់អ្វីៗ ទាំងអស់នៅក្នុងដំណើរជីវិត និងទំនាក់ទំនងផ្ទាល់ខ្លួន របស់ជនរួចផុតពីសេចក្តីស្លាប់។ ពាក្យថា *ក្បត់* ដើមកំណើត

ចេញពីពាក្យឡាតាំង មានន័យដោយលំអិតថា "ធ្វើអោយក្រឡាប់ចាក់ ការធ្វើបែបនេះ គឺធ្វើអោយមនុស្សនោះងាយទទួលរងគ្រោះ" ការវិនិច្ឆ័យបច្ចុប្បន្ន គឺ "ចុះចាញ់ ឬផ្តល់អំណាច អោយសត្រូវ ដោយអំពើក្បត់ ឬទុច្ចរិត" សត្រូវពុំអាចក្បត់ជនរងគ្រោះបានឡើយ មានតែជនស្និទស្នាលដែលមានទំនាក់ទំនងទុកចិត្ត ហើយជាជនដែលយល់ដឹងពីមនុស្សទាំងនោះទេដែលគេអាចធ្វើបាបដល់ជននោះដោយងាយស្រួល។ សិស្សបានទទួលការបញ្ជាក់សេចក្តីសំខាន់ៗទៅលើការក្បត់នៅក្នុងជីវិតរបស់ខ្លួន។

តាមបទពិសោធន៍សាកល្បងជាងពីរទសវត្សមក ខ្ញុំដឹងថាស្ថានភាពជាច្រើនមានរួមទៅដោយសេចក្តីមិនយកទុកចិត្តទុកដាក់តិចតួច ឬការមិនស្មោះត្រង់ដែលអាចរាលដាលទៅជាធំ វាអាចក្លាយទៅជាការក្បត់មានគ្រោះថ្នាក់ដល់ជីវិតនៅករណី ដែលកាលៈទេសៈប្រវត្តិសាស្ត្រប្រែប្រួលភ្លាមៗ។ សេចក្តី "ក្បត់តូចតាចlittle " អាចក្លាយទៅជាសេចក្តី "big ក្បត់ធំដុំ" ជនជាតិខ្មែរទាំងអស់ដែលនៅក្នុងថ្នាក់រៀនមានបញ្ហាររវាង សេចក្តី "ក្បត់តូចតាច" ដែលក្លាយទៅជាសេចក្តី "ក្បត់ធំដុំ" ស្ត្រីម្នាក់បាននិយាយអំពីរឿងប្តីរបស់គាត់ មុនជំនាន់ខ្មែរក្រហម ដែលមានចំណងស្នេហាលួចលាក់ជាមួយ និងសង្សាម្នាក់ដែលប្តីនាងបានចិញ្ចឹមនៅក្នុងភូមិមួយទៀត។ ប្រពន្ធបានដឹងពីស្ថានភាពនេះតែបានអត់ទ្រាំយ៉ាងស្ងៀមស្ងាត់ ដោយចាត់ទុកជាសេចក្តី "ក្បត់តូចតាច"។ នៅពេលដែលខ្មែរក្រហម វាយយកភូមិនោះបាន ប្តីរបស់គាត់ និងសង្សារក៏នាំគ្នារត់ចេញពីភូមិបាត់ទៅ នៅពេលដែលក្រុមគ្រួសាររបស់គាត់ ត្រូវគេប្រមូលដាក់ទៅក្នុងជុំរុំអប់រំ ប្រពន្ធពុំបានដឹងដំណឹងពីព្រេងវាសនារបស់ប្តីឡើយ ក្រោយពីសង្គ្រាមបានចប់ទៅ ប្តីគាត់បានវិលមកជួបជុំប្រពន្ធ និងកូនវិញ នៅពេលនោះហើយទើបគាត់ដឹងថា ប្តីគាត់បានរួចផុតពីសេចក្តីស្លាប់ហើយបាន រស់នៅដោយសុខសាន្តជាមួយ និងសង្សារនៅប្រទេសថៃ នៅរយៈពេលដែលក្រុមគ្រួសាររបស់គាត់បានទទួលរងការឈឺចាប់ដោយភាពអត់ឃ្លាន កាប់សម្លាប់ ហើយញាតិមិត្តជាច្រើនរូបត្រូវបានបាត់បង់ជីវិត។ ប្រពន្ធរបស់គាត់បានបៀមកំហឹងដោយស្ងៀមស្ងាត់ទៅការក្បត់របស់ប្តី ដោយគ្មានបញ្ចេញនូវសេចក្តីស្រលាញ់ ឬការគាំទ្រធ្វើឡើយ។ ស្នេហាលួចលាក់របស់ប្តីក្លាយទៅជារឿងដែលពុំអាចអត់ទោសឲ្យបាន "ក្បត់ធំដុំ" ហើយកំហឹងរបស់ប្រពន្ធបានបណ្តាលឲ្យនាងជ្រើសយកសេចក្តីសម្រេចច្បាស់លាស់ ដែលធ្វើអោយប៉ះទង្គិចដល់សេចក្តីសុខរបស់ក្រុមគ្រួសារទាំងមូល។

អារម្មណ៍ក្បត់ដែលពុំមានការថ្លឹងថ្លែងច្បាស់លាស់អាចបំផ្លាញក្រុមគ្រួសារ នៅខណៈដែលកំពុងតែរស់នៅក្នុងជុំរុំខ្មែរក្រហម កូនរបស់សិស្សម្នាក់បានប្រឈមមុខ និងសេចក្តីស្លាប់ដោយសារជម្ងឺ ហើយរូបគាត់ជាគ្រូពេទ្យ ពុំអាចព្យាបាលកូនបានដោយគ្មានថ្នាំត្រឹមត្រូវ ពីព្រោះ ខ្មែរក្រហមបានអោយថ្នាំដែលគ្មានប្រយោជន៍ ដើម្បីព្យាបាលកូនគាត់។ ប្រពន្ធគាត់បានអង្វរគាត់អោយទៅរកថ្នាំដែលព្យាបាលត្រូវនោះ នៅតាមមន្ទីរពេទ្យប្រចាំតំបន់ ដែលគេបោះបង់ចោលតែប្តី បានប្រកែកដោយដឹងថា បើខ្មែរក្រហម ដឹងអត្តសញ្ញាណពិតប្រាកដរបស់គាត់វានឹងសម្លាប់គាត់ចោល។ កូនប្រុសតូចរបស់គាត់ក៏បានស្លាប់ទៅ ក្រោយបន្តិចមកគូរស្រករទាំងពីរនាំគ្នាភៀសខ្លួនទៅព្រំដែនថៃ អ្នកទាំងពីរកើតទុក្ខក្រៀមក្រំដ៏លើលលប់ពេកក្រៃទៅលើការបាត់បង់កូនប្រុសរបស់គេ។ នៅតាមព្រំដែនប្រពន្ធបដិសេធពុំឆ្លងកាត់ព្រំដែនទៅជាមួយប្តីទេ គាត់បានត្រឡប់ទៅជួយម្តាយនៅក្នុងជុំរុំខ្មែរក្រហម

វិញ ប្តីបានទទួលអារម្មណ៍ថាគេបោះបង់ខ្លួនចោល។ ក្រោយមកគាត់បានមកដល់សហរដ្ឋអាមេរិកជាជនភៀសខ្លួន ដោយជឿជាក់ ថាប្រពន្ធគាត់បានស្លាប់នៅប្រទេសកម្ពុជាទៅហើយ។ ចំនួន ពីរឆ្នាំក្រោយមកនៅពេលដែលប្រពន្ធគាត់ និងម្តាយបានមកដល់សហរដ្ឋអាមេរិកដោយសុវត្ថិភាព គេទាំងពីរក៏ចាប់ផ្តើមចំណងអាពាពិពាហ៍របស់គេបន្តទៅទៀត តែបន្តិចក្រោយមកលែងលះគ្នាទៅ ដោយសន្ទុះកំហឹង ដែលមានទៅលើការក្បត់របស់គេម្នាក់ៗ។

សិស្សបានឃើញថាបញ្ជីរាយអំពីការក្បត់ជាបញ្ជីគ្មានកំណត់ ដែលប៉ះទង្គិចដល់ក្រុមគ្រួសារស្ទើរតែទាំងអស់ដែលបានទទួលបទពិសោធន៍ទទួលភាពសាហាវឃោរឃៅដ៏ខ្ពស់បំផុត។ ស្ត្រីដែលបានទទួលអំពើរំលោភផ្លូវភេទ ជាញឹកញាប់ច្រើនតែត្រូវគេបន្ទោស "ក្បត់" ប្តីរបស់ខ្លួន ការក្បត់ផ្សេងៗទៀត អាចកើតមានឡើងនៅក្នុងជីវិតរបស់អ្នករួចផុតពីសេចក្តីស្លាប់ គឺការលាក់ម្ហូបអាហារពីញាតិមិត្ត ដែលកំពុងតែជិតស្លាប់ដោយសេចក្តីអត់ឃ្លាន ភាពចោទប្រកាន់ខុស ថាជនម្នាក់នោះបានបញ្ចេញអាកប្បកិរិយាប្រឆាំង និងជនល្មើស ហើយយកខ្លួនអ្នកនោះប្រគល់ទៅអោយសត្រូវ។ ដូចជាជង្គូវដែលលាក់ខ្លួននៅក្នុងផ្លែប៉ោម អារម្មណ៍នៃការក្បត់ ធម្មតាជាភាពសម្ងាត់ ដែលនៅទីបញ្ចប់វាបំផ្លាញទំនាក់ទំនងផ្ទាល់ខ្លួន ព្រមទាំងសុខភាព និងសុខុមាលភាពរបស់ជនទាំងនោះទៀតផង។

អារម្មណ៍អាក្រក់ដែលទាក់ទង នឹងភាពសាហាវយង់ឃ្នងរួម នឹងសេចក្តីគិតថា សមាជិកគ្រួសារ និងមិត្តភក្តិក្បត់ ផ្តល់នូវមូលដ្ឋានគ្មានលំ នឹងក្នុងការបង្កើតអត្តសញ្ញាណផ្ទាល់ខ្លួន និងវប្បធម៌ចំពោះក្នុងចំណោមក្មេងៗ និងមនុស្សពេញវ័យ។ សិស្សទាំងអស់ធ្វើការពិនិត្យ នៅក្នុងថ្នាក់រៀនទៅលើភាពគ្មាន មោទនភាព របស់កូនគេ និងយុវវ័យ ទៅលើសហគមន៍ដែលត្រូវបានបំផ្លេចបំផ្លាញអស់ ជិះជាន់ ឬធ្វើបន្ទាបបន្ថោក។ ការរស់នៅជាជនជាប់ឃុំ ក្នុងការរងគ្រោះ សិស្សបានរកឃើញថាជាការងារបំផុតដែលអារម្មណ៍របស់គេនៅតែផ្តោត ទៅលើអំពើអាក្រក់ ទាំងឡាយដែលកើតមានឡើង នៅក្នុងសង្គមរបស់គេ ដោយពុំគិតអំពីភាព តស៊ូរឹងមាំរបស់គេ ដែលបកស្រាយដោយប្រវត្តិសាស្ត្រវប្បធម៌ និងបទពិសោធន៍របស់ខ្លួនឡើយ។ គេឃើញថាកូនរបស់គេមានការពិបាក នឹងទទួលបានមោទនភាព ជាជនរងគ្រោះដោយអំពើសម្លាប់រង្គាល ដែលបណ្តាលអោយយុវវ័យមានការយល់ខុសផ្ទុយស្រឡះ អំពីកេរ្តិ៍តែករបស់ខ្លួន។

បញ្ហាទាំងនេះ បានយកមកដោះស្រាយដោយបើកចំហ នៅក្នុងថ្នាក់រៀនមានរួមទាំងអ្វីៗ ចាំបាច់ទាំងអស់សំរាប់ដោះស្រាយចំណុចសំខាន់ផ្សេងៗ រវាងទំនាក់ទំនងផ្ទាល់ខ្លួន និងសង្គម ដែលបានខូចខាតដោយការក្បត់។ កំហឹងដែលជក់ជាប់ជាយូរអង្វែងទៅលើញាតិសន្តាន និងមិត្តភក្តិ បានត្រូវជំនួសដោយភាពខន្តីអភ័យទោសវិញ។ មេរៀនរបស់ជនជាតិអាហ្វ្រិកាំង អាមេរិកកាំង ដែលបានកសាងមោទនភាព ពីទាសភាពអតីតកាល ភាពប្រកានពូជសាសន៍ និងភាពជិះជាន់ បានយកមកប្រើនៅក្នុងការបង្រៀនអ្នករួចផុតពី សេចក្តីស្លាប់អំពីវិធីស្តារភាព ការគោរពវប្បធម៌របស់បុព្វបុរសខ្លួន ដែលបានទទួលបទពិសោធន៍ក្នុងសម័យ។ ចំណុចល្អនៃបទពិសោធន៍របស់ជនជាតិខ្មែរ បានទទួលការកត់សម្គាល់ដោយថ្នាក់រៀន ហើយបានផ្តល់នូវភាពសំខាន់ៗ ទៅលើ

ព្រឹត្តិការណ៍តក់ស្លុត ដែលបានកើតឡើងដោយរបបប៉ុលពត។ សិស្សបានទទួលការលើកទឹកចិត្តអោយចែកចាយសេចក្ដីគោរពថ្មី ដែលគេនឹងរកឃើញអំពីអត្តសញ្ញាណខ្មែររបស់ខ្លួនគេ ទៅដល់យុវវ័យដែលនៅជុំជិតខ្លួនគេ។

## ១.៥ សេចក្ដីចងចាំដែលមិនអាចគ្រប់គ្រងបាន

ពិសិដ្ឋភាពនៃសេចក្ដីចងចាំ ជាបញ្ហាដ៏ពិបាកក្នុងការចាប់យកមក និយាយពិភាក្សាគ្នា ដោយវាជាករណីដ៏ឈឺចាប់មួយ ជាពិសេសបើជនជាទីស្រលាញ់ ដែលស្លាប់ដោយអំពើសាហាវយង់ឃ្នង តែវាអាចជួយរក្សាភាពជិតស្និទ្ធ និងនិរន្តរ៍ភាពជាមួយ នឹងជនដែលបានទទួលអានិច្ចកម្មទៅហើយ ។ នៅពេលដែលយើងសួរសិស្សថាតើគេមានចងចាំភាពតក់ស្លុតពីអតីតកាល ឬទេ? ភាគច្រើនឆ្លើយថា "មានជារៀងរាល់ថ្ងៃ"។ គេក៏បញ្ចេញថាសេចក្ដីចងចាំទាំងនេះ ជាញឹកញាប់មានជាប់ជាមួយ និងសុបិន្តអាក្រក់ទាំងសេចក្ដីចងចាំទាំងសុបិន្តអាក្រក់ធ្វើអោយរាងកាយ និងអារម្មណ៍របស់គេមានភាពមិនស្រួលតែវាក៏ជួយរក្សារូបគេអោយនៅជិតមនុស្សជាទីស្រលាញ់របស់គេដោយចាត់ទុកអ្នកទាំងនោះ នៅក្នុងបេះដូង និងអារម្មណ៍របស់ខ្លួន។

នៅពេលដែលគេសួរអោយជនជាតិខ្មែរ នឹកគិតឡើងវិញនូវសេចក្ដីចងចាំ ដែលធ្វើអោយគេមិនស្រួលក្នុងចិត្តយ៉ាងហោចណាស់មួយអាទិត្យម្ដង អ្នកទាំងនោះបាននឹកឃើញថា យ៉ាងហោចណាស់ក៏មានម្ដងដែរ ភាគច្រើន។ មានច្រើនជាងម្ដងទៅទៀត បុរសម្នាក់ដែលមានអាយុទើបតែចំនួន ៦០ឆ្នាំ បានបរិយាយអំពីសេចក្ដីចងចាំនៅពេលដែលកូនប្រុសរបស់គាត់ម្នាក់ កំពុងតែជិតស្លាប់នៅក្នុងជុំរុំអប់រំខ្មែរក្រហម។ គាត់មានថ្នាំដែលគាត់ជឿជាក់ថា អាចជួយស្រោចស្រង់ជីវិតរបស់កូនគាត់បាន តែទាហ៊ានខ្មែរក្រហមពុំអនុញ្ញាតអោយគាត់ចេញពីភូមិ ទៅជួបកូនរបស់គាត់ឡើយ។ បើគាត់ហ៊ានលួចរត់ទៅ គាត់ដឹងថាគេ នឹងចាប់គាត់បានហើយសម្លាប់គាត់ចោល។ មួយអាទិត្យក្រោយមក គេបានប្រាប់គាត់ថាកូនរបស់គាត់បានស្លាប់ទៅហើយ គាត់ពុំបានស្រាកស្រាន្តពីភាពបាត់បង់កូននេះឡើយ ហើយគាត់គិតតែអំពីកូននេះជារៀងរាល់ថ្ងៃ។ សេចក្ដីចងចាំនេះពាំនាំនូវភាពសោកសៅ និងភាពស្ដាយក្រោយយ៉ាងក្រៃលែង។

ជនជាតិខ្មែរដែលរួចផុតពីសេចក្ដីស្លាប់ បំរុងខ្លួន នឹងចែកចាយសេចក្ដីចងចាំទាំងនោះ ជាមួយគ្នាទៅវិញទៅមក ហើយគេបានទទួលស្គាល់ថាការចែកចាយ នេះធ្វើអោយរូបគេមានអារម្មណ៍ពុំស្រួលចិត្តឡើយ។ គេពុំដឹងថាទោះបីជាយ៉ាងណាក៏ដោយ សេចក្ដីចងចាំដែលមិនអាចគ្រប់គ្រងបាននេះ អាចសម្លាប់រូបគេបាន បើសិនជាគេមិនរៀនវិធីគ្រប់គ្រងការចងចាំនេះអោយបាន។ នៅពេលដែលគេយលដឹងច្បាស់ថា រូបគេជាអ្នកចាត់ចែងគ្រប់គ្រងលើសេចក្ដីចងចាំតក់ស្លុត គេអាចយកវាដាក់ទៅមួយកន្លែង ហើយបង្កើតជាទម្លាប់មួយដែលរូបគេអាចរំលឹកមកវិញតាមពិធីសាសនា នៅកន្លែងដឹងពេលវេលាដ៏សមរម្យប្រាកដណាមួយ។ នៅពេលដែលគេយកវិធីនេះមកដើម្បីទាក់ទងការចងចាំនេះទុកមួយកន្លែង ពេលនេះ គេអាចយកការចងចាំ នោះមកបញ្ចេញឡើងដោយសុវត្ថិភាព ដោយសេរី និងអាចប្រារព្ធធ្វើឡើងតាមរយៈវិធីសាសនា ឬក្នុងពេលជញ្ជឹងគិតដល់អ្នកជាទីស្រលាញ់ដោយឯកជនម្នាក់ឯង។ ឪពុកដែលតែងតែគិតអំពីកូនប្រុសរបស់គាត់ បានចាត់ទុកសេចក្ដីនឹកឃើញនេះ ដោយ

ដោគជ័យតាមរយៈ ការបញ្ចេញអារម្មណ៍ ក្នុងកំឡុងពេលបន់ស្រន់ នៅចុងសប្តាហ៍ក្នុងវត្តអារ៉ាម។ ការកត់ត្រាសេចក្តីចងចាំ ហ្នឹងសុបិន្តអាក្រក់ និងព្រឹត្តិការណ៍មហាទោរទន់អារម្មណ៍ នៅក្នុងសៀវភៅកំណត់ហេតុ និងកំណត់ហេតុប្រចាំថ្ងៃ ជួយអ្នករួចផុតពីសេចក្តីស្លាប់អោយបំបាត់ ឬបន្ថយការគិតពីសេចក្តីឈឺចាប់របស់ខ្លួន។

ការរម្ងាប់សេចក្តីចងចាំមិនអាចគ្រប់គ្រងបាន និងសុបិន្តអាក្រក់ អាចបង្កើតអោយមានវិធីនៃការព្យាបាលផ្សេងៗ ទៀតអំពីការរៀនរម្ងាប់អារម្មណ៍។ ពេលនេះសិស្សបានទទួលបទពិសោធន៍ដោយផ្ទាល់ ទៅលើការដឹងថាអារម្មណ៍អាចខ្ចប់ទុកមួយកន្លែង ហើយថែមទាំងអាចបំបាត់ចោលបាន បើសិនជាចាប់ធ្វើឡើងតាមវិធីអប់រំត្រឹមត្រូវ។ គេរៀនដាក់កម្រិតអារម្មណ៍ បើសិនជាអារម្មណ៍របស់គេឡើងហួសកម្រិត គេអាចប្រើមធ្យោបាយបង្វែរហើយបញ្ឈប់វាវិញបាន ។ ជាយថាហេតុ សិស្សអាចនិយាយថា "នៅពេលដែលខ្ញុំគិតអំពីរឿងនេះ ខ្ញុំខឹងខ្លាំងណាស់។ តែនៅក្នុងពេលនេះនៅពេលដែលខ្ញុំចាប់ផ្តើមគិតបែបនេះ ខ្ញុំបញ្ឈប់វាភ្លាម"។ គេរៀនអំពីរបៀបជៀសពីទីកន្លែង ការគិត និងអាកប្បកិរិយាដែលបង្កើតអារម្មណ៍ទោរទន់ខ្លាំង នៅពេលក្រោយមកអាចបណ្តាលអោយមានជម្ងឺ និងធ្វើអោយប៉ះពាល់ដល់សុខុមាលភាពទូទៅ។ ការដោះស្រាយ និងសេចក្តីចងចាំដែលមិនអាចគ្រប់គ្រងបាន ពិតជាអាចជួយបង្កើនទំនាក់ទំនងរបស់គេអោយប្រសើរឡើង ជាមួយនិងសមាជិកគ្រួសារ និងមិត្តភក្តិដែលបានបាត់បង់ទៅ ហើយគេអាចគ្រប់គ្រងអារម្មណ៍របស់គេ គេអាចបញ្ចេញសេចក្តីត្រេកអរ ដល់អ្នកដែលបានទទួលអនិច្ចកម្មទៅ ដោយគ្មានបែកស្មារតីដោយសេចក្តីឈឺចាប់របស់គេឡើយ។

## ផ្នែក ២. ឥទ្ធិពលព្យាបាលដោយនាពសើចសប្បាយ

ក្រោយពីខ្ញុំបានប្រកបការងារនៅមន្ទីរសុខភាព ចំនួន ១៨ ខែ ជាមួយ និងស្ត្រីខ្មែរចំណាត់ម្នាក់ ដែលបានទទួលរងទណ្ឌកម្មដ៏ធ្ងន់ធ្ងរ ហើយពុំដែលចាប់អារម្មណ៍ទៅលើអាការៈខាងក្រៅរបស់ខ្លួនគាត់ឡើយ តែក្រោយមកគាត់មកចូលរួមប្រជុំ ដោយកាត់សក់ដ៏គួរអោយចាប់អារម្មណ៍ គាត់ពិតជាបានកាត់សក់នោះនៅហាងកែសម្ផស្សមួយ។ ខ្ញុំបានសរសើរគាត់ថា សក់គាត់ស្អាតណាស់ហើយគាត់ញញឹមឡើង រួចខ្ញុំក៏និយាយលេងថា ពេលគាត់ដើរចេញពីហាងកែសម្ផស្សបុរសខ្មែរចំណាស់ៗ ពិតជាដេញតាមគាត់ហើយ។ អ្នកជម្ងឺសើចដោយរីករាយ ហើយបានចែកចាយសេចក្តីរីករាយរបស់គាត់ អំពីចំណាប់អារម្មណ៍របស់អ្នកឯទៀត ទៅលើ សម្ផស្សរបស់គាត់។ នៅខណៈនោះ គាត់នឹកគិតដល់ការយកចិត្តទុកដាក់របស់គាត់ ទៅលើរូបសម្បត្តិ ខាងក្រៅរបស់គាត់ បានយកចិត្តទុកដាក់ដោយសង្ឃឹមទៅលើស្ថានភាពរបស់គាត់។

ខ្ញុំបានរៀនសូត្រពីបទពិសោធន៍នៅមន្ទីរសុខភាព ថាការចាប់ផ្តើម និយាយរឿងកំប្លែងលេងសើចជាមួយនឹងអ្នករួចផុតពីសេចក្តីស្លាប់ជាបទពិសោធន៍ រំលែកទុក្ខសម្រាប់ជនគ្រប់រូប។ ដូច្នេះ ខ្ញុំបានព្យាយាមនិយាយកំប្លែងលេងសើចនៅក្នុងថ្នាក់រៀនសុខភាព។ ដើម្បីបង្ហាញដល់ជនជាតិខ្មែរ ពីភាពលំបាកបែបណាដែលវេជ្ជបណ្ឌិតស្តាប់ពីបញ្ហារបស់អ្នក ជម្ងឺតាមរយៈអ្នកបកប្រែភាសារ ខ្ញុំប្រើល្បែងលេងរបស់ក្មេងអំពីការនិយាយតៗ គ្នាតាមទូរស័ព្ទ។ នៅក្នុងថ្នាក់មួយ ខ្ញុំបានខ្សិបដាក់ត្រចៀកស្ត្រីខ្មែរម្នាក់មុនគេថា "សត្វឆ្កែចូលចិត្តស្គរគ្រាប់!" ស្ត្រី

នោះសើច ឮក្អាកក្អាយ នៅពេលដែលគាត់ខ្សិបដាក់ត្រចៀកស្ត្រីម្នាក់ទៀត ដែលអង្គុយជិតគាត់ "សត្វឆ្កែចូលចិត្ត ស្ករគ្រាប់!" គាត់គិតយល់ថា សត្វឆ្កែស៊ីស្ករគ្រាប់ជាគំនិតលីលើ។ ម្នាក់ៗខ្សិបប្រាប់គ្នា ហើយញញឹមសើចទាំងអស់គ្នា។ សូម្បីតែបុរសខ្មែរដែលម៉ឺងម៉ាត់ក៏សើចដែរនៅក្នុងពេលនោះ ការខ្សិបនេះបានបន្តឡើងពេញបន្ទប់ ហើយនៅទីបញ្ចប់ពាក្យខ្សិបនេះ នៅដដែលគ្មានផ្លាស់ប្តូរឡើយ៖ "សត្វឆ្កែចូលចិត្តស្ករគ្រាប់!" លទ្ធផលនេះ ប្រហែលជាកើតឡើង ដោយមកពីគេយកចិត្តទុកដាក់ទៅលើលំហាត់នេះ។ ស្ត្រីចំណាស់ម្នាក់ដែលទើប នឹងចេញពីពេទ្យ ដោយរោគស្លាប់ដៃជើង បាននិយាយឡើងថា សេចក្តីសើចនេះបានធ្វើអោយគាត់មាន អាយុវែង ចំនួន ១០ ឆ្នាំទៀត ដោយពន្យល់ថា "សំណើចអាចព្យាបាលរោគដោយភាពរីករាយ អាចដកយកភាពទុក្ខព្រួយចេញពីអារម្មណ៍របស់ជនម្នាក់បាន"សមាជិកនៅក្នុងថ្នាក់រៀនទទួលយកព្រមតាមគាត់។

ដូចបានបង្ហាញអោយឃើញឡើង តាមរយៈការស្រាវជ្រាវដ៏ទូលំទូលាយ សំណើច និងកំប្លែងជាការព្យាបាល នៅខណៈដែលកត្តាពិតបានរកឃើញថា វិធីព្យាបាលបែបនេះបានយកមកប្រើនៅក្នុងចំណោមមន្ទីរពេទ្យព្យាបាលរោគមហារីក និងយកមកព្យាបាលរោគាធ្ងន់ធ្ងរផ្សេងៗទៀត វិធីនេះពុំទាន់ឈានដល់ផ្នែកចិត្តសាស្ត្រសម័យឡើយ។ អ្នកព្យាបាលរោគសតិអារម្មណ៍ហាក់បីដូចជាខ្លាចថា ការនិយាយកំប្លែងលេងសើច អាចមើលឃើញថាជា ភាពមិនយល់ចិត្តចំពោះជនដែលកំពុងតែឈឺចាប់។ តែបើគ្មានការនិយាយកំប្លែងលេងសើច និងភាពរីករាយដែលកើតឡើងនោះទេ ជំនួយព្យាបាលអោយគ្រាន់បើឡើងពិតជាបាត់បង់។ វាជាអំនួតពន់ពេកដែលអ្នកចិត្តសាស្ត្រគិតថារូប គេមានប្រាជ្ញាឈ្លាសវៃ "យល់ដឹង" បញ្ហាជីវិតគ្រប់បែបដោយគ្មានជំនួយពីសិល្បៈកំប្លែង មានរួមទាំងអាយ៉ង ការនិយាយគ្រាប់តាម ការនិយាយរឿងកំប្លែង និងអ្នកកំប្លែង។

ចំណុចពិតនៃសំណើចក្នុងភាពជាសះស្បើយជាលំហាត់សាមញ្ញ ដូចជាការដើរជាប្រចាំថ្ងៃ លោក ន័រម៉ិន ខូស៊ិន Norman Cousins អ្នកកែសម្រួល និងតែងតែនិយាយថា សំណើច "ជាការរត់លេងខាងក្នុង អ្នកស្រាវជ្រាវ រ៉ូប័ត ប្រ៉ូឌី Robert Brody បានថ្លែងថា៖

នៅពេលដែលអ្នករៀបចំបម្រុង នឹងសើចឡើង សរសៃនៅលើមុខ ដែលបញ្ហាភាពបញ្ចេញទឹកមុខចាប់ផ្តើមរមូលជ្រួញឡើង។ សរសៃពេញរាងកាយរបស់អ្នកកន្ត្រាក់ ដូចជាកណ្តាប់ដៃ សរសៃបំពង់ករបស់អ្នកសម្រាប់បន្លឺសម្លេងពុំអាចសម្របសម្រួលបាន។ រន្ធខ្យល់ និងបំពង់សម្លេងរបស់អ្នកបើកបន្ទរ ហើយរង់ចាំដោយញាប់ញ័រ។ សន្ទះដង្ហើមរបស់អ្នកឡើងតឹង រង់ចាំភាពផ្ទុះដង្ហើម ខ្យល់នៅក្នុងរាង្គកាយរបស់អ្នកចាស់ឡើងពេញខ្លួន រហូតទាល់តែអ្នកទទួលអារម្មណ៍ថា ខ្យល់នោះបានចូលពេញសួតរបស់អ្នក...នៅពេលអ្នកសើចពេញទំហឹងភាពដកដង្ហើមរបស់អ្នកត្រូវផ្អាក់មួយរយៈ។ ថ្គាមក្រោមរបស់អ្នកញ័រ សន្ទះខ្យល់ត្របាញ់ចូលបំពង់ខ្យល់ ស្លេះស្អិតជាប់ទៅ នឹងបំពង់ខ្យល់របស់អ្នក ភាពឡូឡាទ្រហឹងអ៊ឹងកងផ្ទុះឡើង! សំណើចរបស់អ្នកបន្លឺសម្លេងឡើង នៅករណី ខ្លះគេចុចល្បឿនមើលឃើញថា មានល្បឿន ចំនួន ១៧០ម៉ាយក្នុងមួយម៉ោង។

ជាបន្ថែមទៀត ដើម្បីបន្ធូរភាពតានតឹងអារម្មណ៍ និងភាពអន្ទះអន្ទែង អ្នកវិទ្យាសាស្ត្របានបង្ហាញឡើងថា សំណើចធ្វើអោយមានការឆ្លើយតបល្អដល់ ផ្នែកចិត្តសាស្ត្រ និងភាពប្រឆាំងរោគ ដែលជួយនៅក្នុងការព្យាបាល

រាង្គកាយ និងសតិអារម្មណ៍មិនប្រក្រតី។ ដោយសំណើចជាភាពឆ្លងរាលដាល វាក៏នាំនូវភាពរីករាយដល់ជនឯទៀតផងដែរ។

ជនជាតិខ្មែរដែលរួចផុតពីសេចក្តីស្លាប់ បានទទួលការរំឭកជាប់រហូតថាគេ ត្រូវការភាពរីករាយ និងសើចសប្បាយក្នុងជីវិតរបស់គេ ដើម្បីអោយសុខភាពរបស់ពួកគេបានល្អ ។ នៅពេលមួយនោះខ្ញុំបានចេញបទបញ្ញាពេទ្យអោយសិស្សគ្រប់រូបនៅក្នុងថ្នាក់រៀនៈ "សូមរីករាយ នឹងខ្លួននាក់សូមធ្វើអ្វីៗ អោយសប្បាយនៅអាទិត្យក្រោយ"។ ហើយគេទាំងអស់គ្នាបានធ្វើតាមជាលើកដំបូងបំផុតក្នុងកំណត់ពេលជាច្រើន ទសវត្សមក។

## ២.១ ឧបករណ៍របស់សង្គមសំរាប់ការព្យាបាល

ជនជួបប្រទះភាពតក់ស្លុត កម្រធ្វើការទាក់ទងរវាងសកម្មភាពសង្គម និងភាពព្យាបាលទៅលើអំពើសាហាវយង់ឃ្នងផ្ទុយពីកត្តាពិតដែលបញ្ជាក់ថា ការដាក់ខ្លួននៅឯកោអាចគំរាមកំហែង ដល់កាយសម្បទា និងសុខុមាលភាពសតិអារម្មណ៍។ សិស្សរបស់យើងជាច្រើននាក់ ជាពិសេសជនជារាដែលច្រើននៅតែឯកឯងនៅពេលថ្ងៃ។ ស្ថានភាពនេះបានកែរតម្រូវដោយការរៀបចំសហគមន៍តូចមួយ ដែលបង្កើតឡើងដោយថ្នាក់រៀន និងដោយការចូលរួមពីជនទាំងឡាយនៅមណ្ឌលខ្មែរប្រចាំតំបន់។ ជនជាតិខ្មែរក៏ដូចជាសហគមន៍រួចផុតពីសេចក្តីស្លាប់ឯទៀតដែរ គេទទួលការបង្ហាត់បង្រៀនជាទំនៀមទម្លាប់ក្នុងការជួយអ្នកឯទៀត ជាពិសេសសមាជិកក្រុមគ្រួសារ និងអ្នកជិតខាងដែលផ្តល់ជំនួយក្នុងការព្យាបាល។ ទោះជាយ៉ាងណាក៏ដោយ ជនទាំងនេះភាគច្រើនមានឧបករណ៍ និងធនធានថវិកាស្តួចស្តើងសំរាប់យកមកចែកចាយគ្នា។ អ្នកខ្លះ សូម្បីតែទឹកតែសម្រាប់ទទួលមិត្តភក្តិនិងអ្នកជិតខាងក៏ពុំមានលទ្ធភាពបានដែរ អ្នកខ្លះទន់ខ្សោយទាំងកាយទាំងចិត្ត ហើយមិនអាចផ្តល់ប្រយោជន៍អ្វីបានឡើយ ។ អំពើសាហាវយង់ឃ្នង ជាពិសេសបើជាករណីរ៉ាំរ៉ៃហើយនៅមានពុំឈប់ឈរ វាបណ្តាលអោយពុំត្រឹមតែការទន់ខ្សោយកាយសម្បទានោះទេ វាថែមទាំងធ្វើអោយសតិអារម្មណ៍អន់ថយ។ មានតែជនជាតិខ្មែរពីរទៅបីនាក់ទេ ដែលយល់ថាភាពអត់កម្លាំងកើតឡើងដោយសេចក្តីអស់សង្ឃឹម ដែលបណ្តាលឡើងរួមទាំងភាពធ្វើអោយអាម៉ាស់មុខ អំពើរំលោភបំពាននៅក្នុងរបបខ្មែរក្រហម និងដោយការតស៊ូសម្របសម្រួលទៅ នឹងបែបបទជីវិតរស់នៅអាមេរិកកាំង។ ការជួយសិស្សអោយទាក់ទងគ្នាថ្វីបើគេមានអារម្មណ៍អស់សង្ឃឹមក៏ដោយ ជាជំហ៊ានទីមួយ ក្នុងការកសាងភាពរស់រវើកឡើងវិញរបស់គេ ដើម្បីអោយគេអាចចូលរួមនៅក្នុងសង្គមជាបែបបទព្យាបាល។

ដោយមានឧបស័គ្គជាច្រើនទាំង ផ្នែកច្បាប់ ទាំងផ្នែកសេដ្ឋកិច្ចការយល់ដឹងអំពីអ្វីៗ ដែលត្រូវការដើម្បីរកអត្ថន័យថ្មី សម្រាប់ជួយដល់ភាពព្យាបាលដោយខ្លួនឯងរបស់ជនដែលរួចផុតពីសេចក្តីស្លាប់ទាំងនេះជាករណីលំបាក ។ ការងារផ្តល់ស្តេរភាពទៅលើអត្តសញ្ញាណ ផលិតផល និងប្រាក់ចំណូល តែកិច្ចការជាផ្លូវការទៀងទាត់ពុំមែនជាជម្រើសឡើយ ដោយមានការជម្រុញអោយធ្វើសកម្មភាពការងារបែបផ្សេងៗ ដូចជាធ្វើចំការ ឬធ្វើស្រែលក់ដូរបន្តិចបន្តួច រកស៊ី និងការរកប្រាក់សុទ្ធបែបផ្សេងៗ ទៀត ។ កម្រនិងនិយាយបើកចំហអំពីទីផ្សារងងឹត បើ

សិនជាគេចាប់បានគេ នឹងជាប់គុក ឬត្រូវបង់ពិន័យ ។ សកម្មភាពបែបនេះ មានរួមទៅដោយឈ្នួលបំរើការងារផ្ទះ ឬកម្មករសំណង់ ឬធ្វើការខុសច្បាប់ក្នុងការងារដែលមានគ្រោះថ្នាក់ ដូចជាការងារ ផ្នែកគ្រឿងគីមីពុលជាដើម។

យើងក៏ជម្រុញអោយសិស្សចូលរួមនៅក្នុងសកម្មភាពសាសនាដែរ ទោះបីជា មានវត្តព្រះពុទ្ធប្រចាំតាមតំបន់ក៏ដោយជនជាតិខ្មែរខ្លះៗ ពុំចង់ចូលរួម។ ស្ត្រីខ្លះខ្លាចមានភាពកេរ្តិ៍ឈ្មោះទុរយស ដោយគេបានទទួលអំពើរំលោភបំពានផ្លូវភេទ។ សិស្សផ្សេងៗទៀត ពុំមានជំនឿលើសមត្ថភាពរបស់សាសនា និងការបន់ស្រន់ថា អាចជួយដោះស្រាយបញ្ហាគេបានឡើយ។ ឧបសគ្គជាទូទៅជាងគេក្នុង ផ្នែកសាសនា គឺអារម្មណ៍ជ្រួលច្របល់របស់អ្នក រស់បានរួចអំពីអំពើឃោរឃៅដោយបង្អាក់សមត្ថភាពរបស់គេ ក្នុងការប្រមូលអារម្មណ៍ទៅលើការបន់ស្រន់ភាវនា ឬកម្មវិធីសាសនាផ្សេងៗ ទៀត ។ នៅពេលណាដែលគេចូលដល់ទីតាំងចំរើន ភាវនាស្ងាត់ ខួរក្បាលរបស់គេមានពោរពេញទៅដោយភាពនឹកឃើញហើយមើលឃើញទិដ្ឋភាព អំពើសាហាវយង់ឃ្នងទាំងឡាយដែលគេបានជួបប្រទះ។

ទោះបីជាអ្នកឈឺចាប់ដោយភាពតក់ស្លុត ត្រូវការផលប្រយោជន៍ពី ផ្នែកសាសនា អ្នកខ្លះខ្វល់ខ្វាយដោយគេពុំអាចប្រើវិធីនេះជួយក្នុងភាពព្យាបាលដោយខ្លួនឯងបាន។ ឧបសគ្គទាំងនេះមានរួមទៅដោយ ផ្នែកសាសនាបានសម្គាល់អោយឃើញឡើងនៅក្នុងថ្នាក់រៀន ហើយបានដោះស្រាយឡើងតាមរយៈការពិភាក្សាជាក្រុម និងសកម្មភាពដែលជួយធ្វើអោយខួរក្បាលគេបានស្រឡះ ដោយប្រើវិធីសូត្រធម៌ និងភាវនាធម៌ ប្រកបដោយជោគជ័យ។

## ២.២ ដំណើរការពីស្ថានភាពដ៏ហួសកម្រិតទៅស្ថានភាពសាមញ្ញ

ការប្រៀបធៀបលក្ខណៈអារម្មណ៍រវាងសិស្ស ចំនួនមួយរយនាក់ មុន និងក្រោយពេលហ្វឹកហ្វឺន សុខភាពបានបង្ហាញថាមពល និងអារម្មណ៍ល្អបានកើនឡើង ហើយអារម្មណ៍អស់សង្ឃឹម អារម្មណ៍ខកចិត្ត និងទុក្ខព្រួយបានថយចុះយ៉ាងច្បាស់លាស់។ បន្ទាប់ពីបញ្ចប់ការសិក្សា សិស្សបន្តការហាត់ប្រាណ កាយសម្បទា និងអារម្មណ៍ដោយខ្លួនឯង ចំនួនប្រាំមួយខែ ទៅមួយឆ្នាំ។ កម្មវិធីបានជួយធ្វើអោយភាពព្យាបាលដោយខ្លួនឯងរបស់គេបានប្រសើរឡើង។

មានមនុស្សតិចណាស់ដែលរងគ្រោះដោយអំពើសាហាវយង់ឃ្នង ហើយបានទទួលបទពិសោធន៍ ដូចគ្នានឹងអ្វីៗ ដែលជនជាតិខ្មែរបានទទួលរងកម្មនៅក្នុងជុំរុំអប់រំខ្មែរក្រហម តែចំណុចសំខាន់ៗ ទូទៅនៃភាពជាសះស្បើយមានទំនាក់ទំនង ដូចគ្នា សំរាប់ជនដែលរួចផុតពីសេចក្តីស្លាប់ទាំងអស់។ មធ្យោបាយការព្យាបាលដោយខ្លួនឯង គឺមានទំនាក់ទំនងដូចគ្នា សម្រាប់ជនដែលបានរួចផុតពីសេចក្តីស្លាប់ទាំងអស់។ មធ្យោបាយការព្យាបាលដោយខ្លួនឯង គឺមានសម្រាប់ជនទាំងអស់ដែលទទួលរងទុក្ខ ដោយរបួសរាង្គកាយ និងសតិអារម្មណ៍ ទោះបីជាការបែកបាក់ និងការលែងលះគ្នារវាងប្តីប្រពន្ធ អំពើហឹង្សាក្នុងក្រុមគ្រួសារ អំពើរំលោភបំពានផ្លូវភេទ ការបាត់បង់កូនប្តីប្រពន្ធ ឬមិត្តភក្តិដោយអំពើផ្សេងៗ ក្រៅពីធម្មជាតិ ឬជាបែបតក់ស្លុតទូទៅ។ ការព្យាបាលដោយខ្លួនឯងមាន

ឥទ្ធិពលរួមគ្នា ដូចនិងបញ្ហាបំពានដែលប្រព្រឹត្តឡើងដោយមនុស្សលោកផងដែរ។ ប្រជាជនខ្មែរបានបង្ហាញនូវភាពមានៈតស៊ូដែលអាចជួសជុលឡើងវិញបាន តាមរយៈប្រព័ន្ធ និងមធ្យោបាយច្បាស់លាស់។

បន្ទាប់ពីបទពិសោធន៍ជាក្រុម នៃថ្នាក់រៀនសុខភាពយើងចានកែតម្រូវ និងសម្របសម្រួលប្រធានបទតាមស្ថានភាពសាមញ្ញ។ ដោយធ្វើបែបនេះយើងបានជ្រើសយកសកម្មភាពដែលយើងបានយកចិត្តទុកដាក់ ធ្វើដូច្នេះ ដើម្បីអោយសកម្មភាពនេះមានប្រសិទ្ធិភាព ហើយបានទទួលយកតាមវប្បធម៌ ឬជាន់ថ្នាក់សង្គម។ ជម្រើសការហាត់ប្រាណអាចជ្រើសយកតាមប្រភេទ ឧទាហរណ៍ ស្ត្រីចូលចិត្តការហាត់ប្រាណប្រភេទពិតប្រាកដដូចជា យ៉ូហ្គា Yoga នៅខណៈដែលបុរសចូលចិត្តសកម្មភាពស្វាហាប់។ ជាសំណាងល្អជនស្ទើរតែគ្រប់រូបចូលចិត្តការដើរស្វាហាប់។ ចំណីអាហារមានកំរិតប្លែកគ្នាខ្លាំង ដោយការជ្រើសយកម្ហូបអាហារល្អ គឺយោងទៅតាមជំនឿទំនៀមទម្លាប់ ការចំណាប់អារម្មណ៍ទៅលើមុខម្ហូប និងរស់ជាតិ ហើយវាក៏ជាករណី សំខាន់ៗ ដែលយើងត្រូវដឹងអំពីបែបបទពិតប្រាកដណាមួយ និងកំរិតតានតឹងអារម្មណ៍ដែលកើតមានឡើងនៅក្នុងស្ថានភាពសាហាវយង់ឃ្នង ដែលចាត់ទុកតាមប្រភេទព្រឹត្តិការណ៍តក់ស្លុត។ នៅខណៈដែលស្ថានភាពអំពើហឹង្សាក្នុងក្រុមគ្រួសារមានភាពខុសគ្នាយ៉ាងខ្លាំង ពីអំពើយាយីផ្លូវភេទខ្លាំងនៅទីកន្លែងធ្វើការ ភាពតានតឹងអារម្មណ៍ដែលកើតមានឡើង និងអានុភាពដែលកើតមានឡើងទៅលើសុខភាព និងសតិអារម្មណ៍មានកំរិតដូចគ្នា។

រឿងរបស់អាន់តូនី (Anthony) ពាណិជ្ជករម្នាក់ បានបង្ហាញអំពីមធ្យោបាយសុខភាព ដែលប្រើនៅក្នុងថ្នាក់រៀនខ្មែរ អាចយកមកអនុវត្តជាវិធីព្យាបាលទូទៅ តាមបែបផ្សេងៗ ស្ថានភាពរបស់អាន់តូនីមានភាពប្លែកពីសិស្សខ្មែររបស់យើង។ គាត់ពុំមានទទួលផលប្រយោជន៍ពីភាពគាំទ្រជាក្រុម នៅពេលដែលដោះស្រាយ និងស្ថានភាពតក់ស្លុតរបស់គាត់។ ទោះបីជាយ៉ាងណាក៏ដោយ ព្រោះគាត់ធ្វើការបានប្រាក់ខែច្រើន គាត់អាចចូលរួមនៅក្នុងក្លឹបកីឡា គាត់អាចហាត់ប្រាណ មានម្ហូបអាហារល្អ និងមានការងារធ្វើ។ ក្នុងនាមជាជនជាតិអាមេរិកកាំងគាត់ពុំទទួលភាពតានតឹងអារម្មណ៍ ដោយពុំចាំបាច់សម្របសម្រួលតាមសង្គមថ្មីបានឡើយ។ ជីវិតគាត់មានលំនឹង ជាជនវ័យមជ្ឈឹម គ្មានបារម្ភ មានមិត្តភក្តិជាច្រើន និងមានទំនាក់ទំនងសង្គមល្អ តែគាត់បានឆ្លងកាត់ភាពតក់ស្លុត ហើយត្រូវការភាពព្យាបាលដោយខ្លួនឯង។

អាន់តូនី និងប្រពន្ធបានលែងលះគ្នា នៅពេលដែលកូនស្រីរបស់គាត់មានអាយុ ចំនួន១០ឆ្នាំ ប្រពន្ធគាត់បានរៀបការជាថ្មី ហើយបានប្តូរទីលំនៅទៅឆ្ងាយ ជាមួយប្តីថ្មី និងកូនស្រីរបស់អាន់តូនី។ ភ្លាមក្រោយពីប្តូរទីលំនៅ ឪពុកចុងចាប់ផ្តើមធ្វើបាបកូនស្រីជារៀងរាល់ពេលដែលគាត់ស្រវឹងស្រា ហើយបានកើតឡើងជាញឹកញាប់។ នៅក្នុងករណីមួយនោះ គាត់បានធ្វើអោយកូនស្រីវ័យជំទង់នេះរងរបួសយ៉ាងធ្ងន់ធ្ងរ ដោយគ្រោះថ្នាក់ចរាចរណ៍ ព្រោះតែការបើកបរពេលស្រវឹងស្រារបស់គាត់។ ក្រោយពីកូនស្រីចេញពីផ្ទះទៅរៀននៅមហាវិទ្យាល័យ កូនស្រីគាត់បានប្រាប់ពីប្រវត្តិការធ្វើបាបរាងកាយ ចំនួនជាង ប្រាំបីឆ្នាំ របស់នាងដល់រូបគាត់។ កូនស្រីបានប្តឹងយកឪពុកចុងឡើងតុលាការ ដោយចោទប្រកាន់ជាបទឧក្រិដ្ឋធ្វើបាបរាងកាយ និងបណ្តាលអោយរបួសតែឪពុកចុងបានទទួលតែការស្តីបន្ទោសពីចៅក្រម មួយឆ្នាំក្រោយមកកូនស្រីគាត់បានធ្វើអត្តឃាតខ្លួននាង។

អាន់តូនីពោរពេញទៅដោយកំហឹងដ៏លើសលប់ ទៅលើចៅក្រម ឪពុកចុង និងប្រពន្ធដើម ដោយគាត់មានអារម្មណ៍ថា អ្នកទាំងនោះបានសម្លាប់កូនស្រីគាត់។ គាត់ចង់សងសឹកអ្នកទាំងនោះ គាត់បានទទួលការព្យាបាលអស់រយៈពេល ជាង ចំនួនប្រាំឆ្នាំ ជាមួយ និងអ្នកចិត្តសាស្ត្រផ្សេងៗទៀត គេបានប្រាប់អោយគាត់បំបាត់ចោលអារម្មណ៍កំហឹងពេលរាល និងទឹកចិត្តផ្តន្ទាទោសរបស់គាត់។ ផ្ទុយទៅវិញ នៅពេលគាត់បានមកជួបខ្ញុំ ខ្ញុំទទួលស្គាល់អារម្មណ៍ឈឺចាប់របស់គាត់។ ឪពុកចុងបានប្រព្រឹត្តអំពើយ៉ាងអាក្រក់ទៅលើកូនស្រីរបស់គាត់ ហើយជននោះត្រូវតែទទួលទោស។ ការធ្វើបាបលើរាង្គកាយកូនក្មេងជាយូរឆ្នាំ ជាភាពពិតដែលប្រពន្ធគាត់បដិសេធពុំព្រមទទួល ប្រពន្ធគាត់ពិតជាធ្វើឡើងដោយចេតនាទៅលើកូនស្រីរបស់ខ្លួន។ ហើយចៅក្រម បានកាត់សេចក្តីដោយគ្មានត្រឹមត្រូវ និងអយុត្តិធម៌ ករណីនេះប្រហែលជា មូលហេតុដែលបណ្តាលអោយកូនស្រីគាត់ធ្វើអត្តឃាតខ្លួននាង។

ការទទួលស្គាល់ជម្រៅអារម្មណ៍របស់អាន់តូនី ទៅលើភាពក្បត់ និងភាពសងសឹក ហើយខ្ញុំក៏បានសួរគាត់ថាតើគាត់ចង់ធ្វើសកម្មភាពនេះដោយវិធីណា? ការទទួលស្គាល់អារម្មណ៍របស់គាត់បណ្តាលអោយគាត់បញ្ចេញអរម្មណ៍វេទនាជាពន់ពេក រហូតដល់ចំណុចដែលគាត់គិតរិតតែជ្រៅទៅទៀត ថារូបគាត់ក៏ក្បត់ នឹងកូនគាត់ដែរ។ ក្នុងនាមជាពាណិជ្ជករគាត់ប្តូរទីលំនៅជាប់រហូត ហើយបានចំណាយពេលតិចតួចបំផុតជាមួយកូនស្រីរបស់គាត់កាលពីនាងនៅវ័យក្មេង។ គាត់មានអារម្មណ៍ថា គាត់អាចដឹងពីការធ្វើបាបនេះ បើសិនជាគាត់បានចំណាយពេលច្រើនជាមួយនាង។ ភាពក្បត់បែប "ក្បត់តូចតាច little " ដោយការចំណាយពេលរបស់គាត់ទាំងអស់ទៅលើការងារ បណ្តាលអោយមានភាព "ក្បត់ធំ" ដោយមើលមិនឃើញថា ជនល្មើសរស់នៅក្នុងផ្ទះជាមួយកូនស្រីរបស់គាត់។ នៅត្រង់ចំណុចនេះការព្យាបាលរបស់គាត់ គឺអាន់តូនី ត្រូវចាប់ផ្តើមធ្វើការប្រមាណមើលពីស្ថានភាពសោកនាដកម្មរបស់គាត់ដោយសមហេតុសមផល ហើយសំរេចទទួលយកសេចក្តីទុក្ខសោក និងកំហុសរបស់ខ្លួនគាត់។

ការព្យាបាល គឺធ្វើឡើងតាមវិធីដែលយើងបង្កើតឡើងនៅក្នុងថ្នាក់រៀនខ្មែរ អារម្មណ៍របស់អាន់តូនី មានសភាពដូចគ្នា នឹងជនជាតិខ្មែរដែលមានឋានៈស្មើគ្នា គឺអារម្មណ៍របស់គេពោរពេញទៅដោយសុបិន្តអាក្រក់ផ្ទួនៗអំពីការឈឺចាប់ដែលកូនស្រីគាត់ទទួល និងភាពគ្មានសមត្ថភាពរបស់គាត់ ក្នុងការបញ្ឈប់ទារុណកម្មនោះ។ គាត់ទទួលស្គាល់សេចក្តីត្រូវការកាត់បន្ថយសុបិន្តអាក្រក់ និងការចងចាំដែលមិនអាចគ្រប់គ្រងបានទៅលើអត្តឃាតរបស់កូនស្រីគាត់។ អាន់តូនីអាចដោះស្រាយបញ្ហាសុបិន្តអាក្រក់របស់គាត់បាន ហើយជាយថាហេតុ បានបំភ្លេចវាចោលដោយគាត់ទទួលស្គាល់ថាសុបិន្តរបស់គាត់ ពុំអាចធ្វើអោយកូនស្រីគាត់មានជីវិតរស់ឡើងវិញបាន ឬអាចដោះស្រាយទុក្ខសោក និងកំហុសដែលគាត់មានសព្វថ្ងៃបានឡើយ។

ការបំបាត់សេចក្តីឈឺចាប់ ពុំមែនជាវិធីសព្វគ្រប់នៅក្នុងករណី តក់ស្លុតណាមួយឡើយ គោលដៅ គឺត្រូវបង្កើតភាពពេញចិត្ត និងសប្បាយរីករាយក្នុងជីវិតសារជាថ្មី ជាសេចក្តីសង្ឃឹមដ៏សែនលំបាក។ អាន់តូនីមិចចង់លះបង់ សេចក្តីឈឺចាប់របស់គាត់ ហើយយកទិដ្ឋភាពល្អនាពេលអនាគតមកដាក់ជំនួសវិញ។ តាមរយៈសេចក្តី

ឈឺចាប់របស់គាត់ គាត់បានរក្សាព្រលឹងកូនស្រីគាត់អោយនៅមានភាពរស់រវើក ភាពផ្ទុះកំហឹងរបស់អាន់តូនី ជារឿងរាល់ថ្ងៃទៅលើប្រពន្ធគាត់ ប្តីរបស់ប្រពន្ធគាត់ និងចៅក្រមធ្វើអោយគាត់មានអារម្មណ៍ថា គាត់បានធ្វើអ្វីជាសេចក្តីសងសឹកអោយកូនគាត់។ អារម្មណ៍ទាំងនេះរាំងសមត្ថភាពរបស់គាត់ មិនអោយសប្បាយរីករាយ សូម្បីតែអ្វីៗ ជាភាពសាមញ្ញក្នុងជីវិតក៏គ្មានដែរ។ ដោយថាហេតុគាត់អាចទប់ស្កាត់អារម្មណ៍ឈឺចាប់នេះបាន ដោយពុំបណ្តោលអោយវាឆាបឆេះឡើងគ្រប់ពេលថ្ងៃ ឬយប់ឡើយ។ គាត់អាចស្រលាញ់អនុស្សាវរីយកូនស្រីគាត់ថែមឡើងទៀត ដោយបោះចោលភាពជ្រួលច្របល់ដែលពំផ្លាញជីវិតរបស់គាត់ វិធីនេះអាចមានភាពងាយស្រួលឡើងនៅស្ថានភាពជាក្រុម ដោយអ្នកឯទៀតអាចបញ្ជាក់ នូវសេចក្តីត្រូវការរបស់ជនដែលរួចផុតពីសេចក្តីស្លាប់ ដើម្បីនាំមកនូវភាពចុះសម្រុងសុខដុមរម្យនា និងភាពសប្បាយរីករាយ។

បរត្ថភាព (គិតប្រយោជន៍អ្នកដទៃ) ការងារ និងសាសនា ផ្នែកសំខាន់ៗ នៃកម្មវិធីជាសះស្បើយ ពីភាពតក់ស្លុត ក៏អាចយកមកព្យាបាលជាមួយ និងជនម្នាក់ៗបានដែរ។ ចំណោះអាន់តូនី ការចូលរួមនៅក្នុង វិស័យសង្គមមួយ ផ្នែកមានភាពរិតតែងាយស្រួលឡើងៗ។ គាត់ជាបុរសដែលខិតខំធ្វើការងារ ហើយការផ្តោតអារម្មណ៍ទៅលើការងារនេះ ហើយដែលអាចរក្សាគាត់អោយមានជីវិតរស់នៅ បន្ទាប់ពីកូនស្រីគាត់បានស្លាប់ទៅ ។ គាត់មានសេចក្តីប្រាថ្នាដ៏ខ្លាំងក្នុងការជួយក្មេងៗ ដែលមានបញ្ហា ដោយថាហេតុ ដូចគាត់បានធ្វើឡើងនៅក្នុងពេលព្យាបាល។ សំខាន់ជាងនេះទៅទៀត អាន់តូនីជាជនកាន់សាសនារ៉ូមាំងកាតូលិក ហើយនៅក្នុងពេលសារភាពកំហុស គាត់បានសុំសេចក្តីខន្តីអភ័យទោស ពីភាពមិនយកចិត្តទុកដាក់របស់គាត់ទៅលើកូនស្រីរបស់គាត់។ គាត់បានរៀនអំពីវិធីដកយកអនុស្សាវរីយកូនស្រីរបស់គាត់ចេញពីសុបិន្តអាក្រក់ ហើយយកការបន់ស្រន់នៅព្រះវិហារមកជំនួសវិញ គាត់បានបន់ស្រន់ជារៀងរាល់អាទិត្យ ជាវិធីអោយពរជ័យដល់ដួងព្រលឹងរបស់នាង ហើយគាត់បន់ព្រះអោយជួយគាត់លើកលែងទោសអោយរូបគាត់ និងប្រពន្ធដើមគាត់ ទៅលើភាពបរាជ័យក្នុងការការពារកូនរបស់គាត់។ នៅខណៈដែលគាត់អាចព្យាបាលខ្លួនគាត់ ពីអនុស្សាវរីយតក់ស្លុត នៅទីបញ្ចប់នៃការព្យាបាលនេះ សេចក្តីប្រាថ្នារបស់អាន់តូនី ក្នុងការផ្តល់ទោសដល់ឪពុកចុងនៅតែមានភាពខ្លាំងក្លាជាដដែលៗ គាត់នៅតែគិតថាច្បាប់បរាជ័យក្នុងការជួយកូនស្រីរបស់គាត់។

## ២.៣ យុត្តិធម៌សង្គម

លទ្ធផលមួយដែលពិបាកសម្រាប់ ជនជួបប្រទះភាពតក់ស្លុតសំរេចជោគជ័យតែឯកឯង ឬរួមគ្នានោះគឺយុត្តិធម៌សង្គម។ ជនជួបប្រទះភាពតក់ស្លុតប្រកាន់ទុកជារឿងផ្ទាល់ខ្លួន មានកម្រិតស្មើគ្នា នឹងអត្ថន័យយុត្តិធម៌សង្គម។ ចំពោះរូបគេការចាត់ទុកដោយយុត្តិធម៌ ទៅលើស្ថានភាពរបស់ជនម្នាក់ អាចខុសគ្នាឆ្ងាយគ្មានទីកំណត់។ នៅក្នុងសង្គមជាច្រើនទោះបីជាយ៉ាងណាក៏ដោយ សេចក្តីត្រូវការរបស់ជនជួបប្រទះភាពតក់ស្លុត ជាភាពលំបាក នឹងបំពេញតាម។ យុត្តិធម៌ជាករណី នយោបាយពុំមែនជាករណី ផ្ទាល់ខ្លួនឡើយ។ កម្រមានណាស់ដែលយុត្តិធម៌យកចិត្តទុកដាក់ទៅលើសេចក្តីឈឺចាប់ និងទុក្ខសោកផ្ទាល់ខ្លួនរបស់ជនរួចផុតពីសេចក្តីស្លាប់ ដែលជា

ភាពព្រងើយកន្តើយទៅលើសេចក្តីត្រូវការ ផ្នែកព្យាបាលរបស់គេ។ ការកាត់ទោសឧក្រិដ្ឋ ការប្រត្តិបត្តិដាក់ស្តែង ការកាត់ទោសសិទ្ធិមនុស្ស និងតុលាការប្រចាំតំបន់ពុំបានរៀបចំបញ្ចេញភាពយកចិត្តទុកដាក់ទៅលើភាពជាសះស្បើយរបស់ជនរងគ្រោះឡើយ។ ជនរួចផុតពីសេចក្តីស្លាប់ និងអ្នកព្យាបាលរបស់គេជាញឹកញាប់ជួបប្រទះ និងការពិតថា សេចក្តីព្យាបាល គឺជាភាពដែលគេមិនចាប់អារម្មណ៍ ឬទទួលការគាំទ្រដោយតិចតួច គោលដៅទីបញ្ចប់សំរាប់សង្គម គឺរកវិធីដាក់ទោសជនដែលបានប្រព្រឹត្តិបទឧក្រិដ្ឋ។ ក្នុងប្រទេសដែលអំពើសាហាវយង់ឃ្នងទទួលការជម្រុញឡើងដោយផ្នែកនយោបាយ ហើយនៅតែមានជាបន្តយ៉ាងខ្លាំងពីសេចក្តីចាប់អារម្មណ៍ទាំង ផ្នែកយុត្តិធម៌សង្គម ទាំងផ្នែកព្យាបាលផ្ទាល់ខ្លួនពុំមានវត្តមាន ហើយត្រូវបានប្រឆាំងយ៉ាងសកម្ម។

វេជ្ជបណ្ឌិតភ័យខ្លាចថាជនជួបប្រទះភាពតក់ស្លុត អាចរកវីធីដោះស្រាយបាន ដោយយល់ដឹងពីកំណប់ធនធានភាពជាសះស្បើយ ដែលអ្នកជម្ងឺអាចប្រមែប្រមូលឡើងបាន។ ជោគជ័យដែលគួរអោយកត់សម្គាល់របស់ជនភៀសខ្លួនខ្មែរ និងជនដែលរួចផុតពីសេចក្តីស្លាប់ផ្សេងទៀត ដូចជាអាន់តូនីបានបង្ហាញឡើងថា ប្រព័ន្ធមធ្យោបាយជាសះស្បើយ យោងទៅតាមវិន័យព្យាយាមប្រចាំថ្ងៃ មានប្រសិទ្ធិភាពជាងភាពលាយលំ ទៅដោយភាពគ្មានយកចិត្តទុកដាក់របស់វេជ្ជបណ្ឌិត និងជនជួបប្រទះភាពតក់ស្លុត។ វិធីព្យាបាលដោយខ្លួនឯង និងបច្ចេកទេសបែបនេះ អាចយកមកអនុវត្តន៍ យ៉ាងទូលំទូលាយ នៅក្នុងស្ថានភាពឧក្រិដ្ឋកម្មមហាឃោរឃៅ និងសាមញ្ញ។ បើសិនជាសង្គមចាត់អ្នកព្យាបាលអោយបំបាត់ភាពភ័យខ្លាចរបស់គេ ដោយយកលំនាំ តាមគំនិតដាំគ្រាប់ស្ពៃហាង មកប្រើជាវិធីព្យាបាលសុខភាពនៅក្នុងបណ្តាលអោយ អ្នកជម្ងឺទាំងអស់ ទទួលយកលទ្ធផលដ៏គួរអោយស្ងើចសរសើរ នឹងកើតមានឡើង។

# ជំពូកទី៩ សង្គមជាអ្នកព្យាយាម

មន្ទីរចិត្តសាស្ត្រឥណ្ឌូចិន The Indochinese Psychiatry Clinic (IPC) នៅទីក្រុងប្រាយតុន រដ្ឋម៉ាស្សាឈូសែត្ស Brighton, Massachusetts បានកើតឡើងថ្មីៗ ទើបតែបានប្រាំបីឆ្នាំ ហើយទើបតែចាប់ផ្តើមរីកចំរើនឡើង។ មន្ទីរពេទ្យ នេះមានបុគ្គលិក ចំនួនដប់ប្រាំមួយ នាក់ វេជ្ជបណ្ឌិត បុគ្គលិកសង្គមកិច្ច អ្នកចិត្តសាស្ត្រ និងអ្នកវិជ្ជាជីវៈឥណ្ឌូចិនផ្សេងៗ ដែលផ្តល់កិច្ចការងារ បំរើដោយជោគជ័យដល់ជនមានអារម្មណ៍តក់ស្លុតខ្លាំងជាងគេប្រចាំតំបន់នៅ ក្នុងសហគមន៍ជនភៀសខ្លួនទើប នឹងមកដល់ថ្មីៗ។ មន្ទីរពេទ្យព្យាបាលមានអ្នកជម្ងឺជាង ១៦០នាក់។ រដ្ឋម៉ាស្សាឈូសែត្សបានគាំទ្រជាសាធារណៈយ៉ាងពេញលេញ។ តែនៅមួយថ្ងៃនោះ ទូរស័ព្ទក៏បានរោទិ៍ឡើងដោយមានសារជាបន្ទាន់ពីសមាជិកគណៈកម្មាធិការ រដ្ឋផ្នែកសុខភាពសតិអារម្មណ៍បានផ្តល់ដំណឹងដល់យើងថា ដោយការកាត់បន្ថយថវិកា មន្ទីរសុខភាព នឹងត្រូវបិទទ្វារនៅក្នុងរយៈពេលពីរអាទិត្យទៀត។ អ្នកជម្ងឺទាំងអស់ នឹងត្រូវអោយចេញ ផ្ទុយពីការពិតថាគ្មានសេវាសុខភាពផ្សេងៗណាទៀត សម្រាប់អ្នកទាំងនេះឡើយ។ បុគ្គលិកទាំងអស់នឹងត្រូវបញ្ឈប់លែងអោយធ្វើការ។

បុគ្គលិករបស់ខ្ញុំបានទទួលអារម្មណ៍ថាតក់ស្លុតអស្ចារ្យទៅលើបទបញ្ជានេះ វាមានអារម្មណ៍ហាក់បីដូចជាគេសុំអោយយើងកាត់ផ្តាច់អ្នកជម្ងឺរបស់យើងពីការថែទាំសុខភាព និងសតិអារម្មណ៍ ប្រៀបដូចជា នឹងការសុំអោយដកអ្នកជម្ងឺពី ផ្នែកលាងឈាមដូច្នេះដែរ។ ខ្ញុំពុំអាចនឹកគិតស្មានថា រដ្ឋាភិបាលរបស់យើងសុំអោយយើងបោះបង់ការថែទាំអ្នកជម្ងឺរបស់យើងឡើយ។ មន្ទីរពេទ្យព្យាបាលចំនួនម្ភៃ ដែលផ្តល់សេវាដល់ជនក្រីក្រជាងគេនៅក្នុងរដ្ឋប្រឈមមុខ នឹងការកាត់បន្ថយនេះ។ ដោយធ្លាប់ជួបប្រទះ នឹងវិបត្តិកាត់បន្ថយបែបនេះជាច្រើនពីមុនមក វាជាប្រវត្តិសង្ខេបៗ របស់មន្ទីរពេទ្យព្យាបាលផងដែរ ខ្ញុំក៏ទទួលភាពរំសាយអារម្មណ៍ប្លែកថា ពេលនេះជាពេលដែលខ្ញុំត្រូវលះបង់ការងាររបស់ខ្ញុំក្នុងការគ្រប់គ្រងមន្ទីរសុខភាពនេះ។ វានឹងពិតជាងាយស្រួលជាង ហើយបានទទួលថវិកាចំណេញច្រើនជាង បើសិនជាផ្តល់សេវាសតិអារម្មណ៍នៅក្នុងចំណោមប្រជាជនដែលពុំជួបប្រទះ នឹងឧបសគ្គសង្គមបែបនេះ។

ដោយភាពស្មុគស្មាញនេះ ខ្ញុំបានទូរស័ព្ទទៅប្រាប់គ្រូរបស់ខ្ញុំ និងអតីតគ្រូបង្រៀននៅសកលវិទ្យាល័យយ៉េល Yale សាស្ត្រាចារ្យ ប៊័រីសអាស្ត្រាចាន Boris Astrachan ដើម្បីសុំដំបូន្មាន។ ខ្ញុំបានពន្យល់គាត់ថា ដោយវិបត្តិថវិការដ្ឋ ខ្ញុំគ្មានវិធីណាដោះស្រាយ ដើម្បីស្រោចស្រង់មន្ទីរសុខភាពនេះតទៅបានឡើយ ខ្ញុំលែងតស៊ូទៀតហើយ។ ក្រោយពីខ្ញុំនិយាយចប់មានភាពស្ងាត់ដ៏យូរ រហូតទាល់តែសាស្ត្រាចារ្យ Astrachan បន្លឺសម្លេងខ្លាំងថា "ផ្តេសផ្តាស! ឯងមិនត្រូវជឿថា ការសម្រេចនយោបាយវាគ្រាន់តែជារឿងប្រាក់កាស។ ជានិច្ចជាកាល គឺគេយកចិត្តទុកដាក់ទៅលើករណីតម្លៃ និងគោលការណ៍។ ឯងត្រូវត្រលប់ទៅរកអ្នកគាំទ្រសហគមន៍ ឬមន្ទីរសុខភាព និងអ្នកជម្ងឺអោយគេជួយតវ៉ាទៅលើសេចក្តីសំរេចចិត្តនេះ ដោយវាជាភាពអយុត្តធម៌ និងប្រាស់ចាកសីលធម៌។ រដ្ឋត្រូវ

តែទទួលខុសត្រូវក្នុងការថែទាំប្រជាជនដែលឈឺថ្កាត់ វាជាភាពប្រាសចាកសីលធម៌ដែលបោះបង់ចោលជនដែលកំពុងតែទទួលការព្យាបាល”។

ពាក្យសម្តីរបស់គាត់ធ្វើអោយរូបខ្ញុំ និងបុគ្គលិករបស់ខ្ញុំមានកម្លាំងឡើង ដូច្នេះយើងក៏ទៅរកអ្នកជម្ងឺរបស់យើង ហើយស្នើសុំអោយគេជួយយើងស្រោចស្រង់មន្ទីរពេទ្យព្យាបាល។ សេចក្តីឆ្លើយតប និងប្រតិកម្មសហគមន៍ឥណ្ឌូចិនប្រចាំតំបន់ ទៅលើសេចក្តីស្នើសុំរបស់យើងមានភាពលើសលប់ក្រៃលែង។ ប្រជាជនរាប់ពាន់នាក់បានទូរស័ព្ទទៅថៅហ្វ៊ាយខេត្ត និងគណៈកម្មាធិការការិយាល័យ ផ្នែកសុខភាពសតិអារម្មណ៍ បញ្ចេញមតិសង្ខេបៗរបស់គេជាពាក្យថា “ទុក IPC” ដោយភាគច្រើនគេពុំចេះនិយាយភាសាអង់គ្លេស។

ពីរបីថ្ងៃមុនពេលមន្ទីរសុខភាពបិទទ្វារ ផ្នែកប្រជាជនអាល់ស្តុនប្រាយតុន Allston Brighton Citizenបានបោះពុម្ពផ្សាយវិចារណកថាមានចំណងជើងថា “មណ្ឌលឥណ្ឌូចិនត្រូវតែនៅបើកទ្វារ” ៖

- ការកាត់បន្ថយភ្លាមៗ នៃជំនួយរដ្ឋទៅលើមន្ទីរសុខភាពសតិអារម្មណ៍ប្រាយតុនពុំអាចដាក់ជំនួសដោយភាពឥតក្តីមេត្តានេះឡើយ។
- មណ្ឌលទទួលស្គាល់ទូទាំងប្រទេស ប្រឈមមុខ នឹងភាពបំរុងតែរលំបិទទ្វារទៅហើយ ក្រោយពីសេចក្តីប្រកាសថ្មីៗ ថាថវិកាឧបត្ថម្ភទាំងអស់របស់រដ្ឋ ប្រហែលជាចំនួន $290,000 នឹងត្រូវដកចេញពីមណ្ឌល។
- មន្ទីរសុខភាពបានរកវិធីថ្មីៗ ជួយស្រោចស្រង់ជីវិតជនភៀសខ្លួនខ្មែរ ជនជាតិឡាវ និងវៀតណាម នៅក្នុងសហគមន៍របស់យើង។ ស្នាដៃដែលគួរអោយកត់សម្គាល់ជាងគេ គឺបានផ្តល់ឱកាសព្យាបាលសំខាន់ៗសម្រាប់ប្រជាជនឥណ្ឌូចិន ដែលរងទុក្ខទារុណកម្មដោយស្នាដៃ ឆ្គួតលីលានយោបាយនៅក្នុងប្រទេសកំណើតរបស់គេ។

តាមរយៈកិច្ចការរបស់បុគ្គលិកមណ្ឌលសុខភាព និងអ្នកផ្តល់ឱវាទហ្វឹកហ្វឺនឥណ្ឌូចិន ប្រជាជនបែបនេះរាប់រយនាក់ បានទទួលជំនួយក្នុងការបង្កើតជីវិតថ្មី ចេញពីជីវិតប្រេះឆារបស់គេ ហើយក្លាយទៅជាប្រជាជនមានប្រយោជន៍នៅក្នុងសហគមន៍នេះ។ ការដកហូតថវិកាជំនួយសំរាប់បន្តដំណើរការនេះចេញពីមណ្ឌល ជាភាពព្រៃផ្សៃមួយបែបទៀតហើយ។

លោកសមាជិកសភា ម៉ាយហ្គ័ល បារ៉េត Michael Barrett និងលោកតំណាងរាស្ត្រ ខេវិន ហូណាន Kevin Honan បានសន្យាតវ៉ាប្រឆាំងទាមទារអោយមណ្ឌលនៅមានវត្តមាន។ ប្រជាជននៅ Brighton គួរតែសហការជាមួយ នឹងតំណាងរាស្ត្ររបស់គេធ្វើបាតុកម្មដោយស្វាហាប់ ទៅលើការបិទទ្វារកំណប់ទ្រព្យសកម្មប្រកបដោយសីលធម៌ និងមានតម្លៃនៅក្នុងសហគមន៍នេះ។

មន្ត្រីផ្លូវការក្រសួងសុខភាពសតិអារម្មណ៍គួរគប្បីដឹងថា យើងនឹងធ្វើការតវ៉ាទាមទារ អោយខ្លួនយើងនៅក្នុងតំបន់ Allston-Brighton ។ វាពុំមានអ្វីខុសគ្នាឡើយ ទោះជាជនទាំងនោះជាប្រជាជនរស់នៅយូរអង្វែង ឬជាប្រជាជនដែលទើប នឹងមកដល់ថ្មីដែលគ្មានអំណាចក្តី។

អ្នកដឹកនាំរដ្ឋបានទទួលមតិលំអៀងយ៉ាងពិតប្រាកដ ដោយសេចក្តីគាំទ្រដ៏លើសលប់ពីអ្នកគាំទ្រមន្ទីរសុខភាពរបស់យើង។ នៅកំណត់ថ្ងៃដែលមន្ទីរសុខភាពបម្រុង នឹងបិទទ្វារ មានមន្ទីរសុខភាពយុវវ័យ ចំនួនប្រាំបីត្រូវបានបិទទ្វារ និងមិនបើកទ្វារឡើងវិញឡើយ មានតែមន្ទីរសុខភាពរបស់យើង និងមន្ទីរសុខភាពសតិអារម្មណ៍ និងផ្នែកពិការទេដែលនៅបើកទ្វារ។ ទោះជាក្រោយពីការសំរេចនេះក៏ដោយ ទូរស័ព្ទនៅតែមានធ្វើឡើងគាំទ្រជាបន្តដោយភាពខ្លាំងក្លាដដែល។ ពីរបីថ្ងៃក្រោយមកការិយាល័យចៅហ្វាយខេត្ត បានទូរស័ព្ទមកខ្ញុំអោយបញ្ឈប់ទូរស័ព្ទ ដោយវាធ្វើអោយរំខានដល់ការងាររបស់គេ។

ការព្រមានដាស់តឿនរបស់លោក Astrachan ពិតជាត្រឹមត្រូវ សេចក្តីសម្រេចរបស់អ្នកនយោបាយ និងអ្នកបង្កើតច្បាប់ ទៅលើការប្រើធនធានមានកំរិតជាការវិនិច្ឆ័យដ៏មានតម្លៃ។ ជាវាសនាអាក្រក់ដែលសុខភាព និងសុខភាពសតិអារម្មណ៍របស់ជនជួបប្រទះភាពតក់ស្លុត ជាទូទៅច្រើនតែចាត់ទុកដោយសង្គមថាជាភាពសំខាន់តិចតួច។ ការព្យាបាលផ្ទាល់ខ្លួន នៃភាពតក់ស្លុតដែលទាក់ទង នឹងរោគា ទោះជាវាកើតឡើងដោយទារុណកម្ម ឬដោយអំពើហិង្សាក្នុងក្រុមគ្រួសារក៏ដោយ ត្រូវចាត់ទុកថាជារឿងផ្ទាល់ខ្លួន ដែលត្រូវដោះស្រាយជាឯកជនដោយជនរងគ្រោះ។ ជាភាពកម្រមានដែលសង្គមប្រជាធិបតេយ្យ ភ្លឺថ្លាយល់ថាការព្យាបាលភាពតក់ស្លុតនេះ ចាត់ទុកថាជាសេចក្តីទទួលខុសត្រូវរបស់សង្គម និងផ្នែកនយោបាយ។ នៅក្នុងករណី ខុសធម្មតា ប្រជាជនដែលទទួលភាពវិនាសមហន្តរាយដោយសង្គ្រាម ភាពប្រឆាំងគ្នាក្រោយសង្គ្រាមរវាងរដ្ឋាភិបាល និងអង្គការជំនួយអន្តរជាតិ គឺគេយកចិត្តទុកដាក់យ៉ាងសំខាន់ៗ ទៅលើការជួសជុលផ្លូវ អាគារ និងរចនាសម្ព័ន្ធហិរញ្ញវត្ថុ ជនដែលទទួលគ្រោះថ្នាក់ ជាពិសេសផ្នែកសតិអារម្មណ៍ គឺត្រូវទុកអោយថែទាំដោយខ្លួនគេផ្ទាល់។

គំនិតដែលយល់ថាភាពព្យាបាលដោយខ្លួនឯង និងភាពជាសះស្បើយពីសង្គម គ្មានទំនាក់ទំនងអ្វីនោះជារឿងប្រឌិតសុទ្ធសាធ។ នៅឡើយភាពដែលកើតមានឡើងជាប់រហូត បានបណ្តោយអោយអំពើឧក្រិដ្ឋកម្មទាក់ទង នឹងភាពក្រីក្រកើតមានឡើងជារៀងរាល់ថ្ងៃ ទោះបីជាដោយក្រុមហ្គែង ឬថ្នាំញៀនពេស្យា ឬអំពើរំលោភបំពានផ្លូវភេទកូនក្មេង និងស្រ្តី ហើយត្រូវគេបំភ្លេចចោលដោយយោងតាមកំរិតសំខាន់ៗក្នុងសង្គម។ វាជាភាពអំណរសាទរ ដែលឥរិយាបទបំភ្លេចចោលនេះបានរលត់បាត់ទៅដោយសន្សឹមៗ។ ភាពទទួលស្គាល់បញ្ជាក់ដោយវិទ្យាសាស្រ្តទៅលើឥទ្ធិពលព្យាបាលដោយខ្លួនឯងរបស់ជនជួបប្រទះភាពតក់ស្លុតកំពុងតែកកើតឡើងដោយភាពផ្លាស់ប្តូរទាំងស្រុង ផ្នែកថែទាំសុខភាព។ សេចក្តីទទួលស្គាល់ភាពព្យាបាលដោយខ្លួនឯងជាភាពជីវវិទ្យា ចិត្តវិទ្យា និងការឆ្លើយតបរបស់សង្គមទៅលើឧក្រិដ្ឋកម្មជាភាពកាច់បំបាក់ឥរិយាបទអាក្រក់របស់សង្គម ដែលចាត់ទុកជនជួបប្រទះភាពតក់ស្លុតជាករណីបន្ទាប់បន្សំ។ សង្គមគ្រប់គ្រងទាំងនោះ ពេលនេះត្រូវភ្ជាប់គ្រឹះស្ថានសង្គម ជាមួយនឹងគ្រឹះស្ថានសុខភាពដែលជួយជំរុញភាពព្យាបាលដោយខ្លួនឯង។ វាជាករណីមួយដែលពុំអាចធ្វើអោយការវិវឌ្ឍន៍កើតមានឡើងបាន នៅក្នុងសង្គមដែលកាន់កាប់ដោយអាជ្ញាធរផ្តាច់ការ វាជាភាពគាបសង្កត់ដោយ ផ្នែកនយោបាយ សេដ្ឋកិច្ច និងអំពើឧក្រិដ្ឋកម្មក្នុងសង្គម ដែលបានរាលដាលពាសពេញ ហើយពុំមានឱកាសផ្តល់ការកែទំរង់ឡើងវិញបាន។ សង្គមប្រជាធិបតេយ្យផ្តល់ភាពអាចផ្លាស់ប្តូរបានដ៏ប្រពៃបំផុត។

## ផ្នែក ១. កាតព្វកិច្ចទាញប្រឈមមុខ នឹងភាពផ្តេកផ្តួល (ពឹងផ្អែក)

ភាសាជាករណី ដល់សកម្មដែលទប់ស្កាត់ទំនាក់ទំនងរបស់សង្គម ប្រឆាំង នឹងជនជួបប្រទះភាពតក់ស្លុត ព្រឹត្តិការណ៍រញ្ជួយផែនដីនៅក្នុងឆ្នាំ ១៩៩៥ នៅទីក្រុងកូបេ ប្រទេសជប៉ុន Kobe Japanបានបង្ហាញយ៉ាងច្បាស់ពីភាពពិតនេះ។ ជនជាតិជប៉ុនបានបង្កើតភាសាដ៏ល្អ ក្នុងការពិភាក្សាទំនាក់ទំនងផ្ទាល់ខ្លួនរបស់គេ។ ក្នុងការវិភាគវិទ្យា នៃភាពផ្តេកផ្តួលពឹងផ្អែក អ្នកវិភាគចិត្តវិទ្យាជប៉ុន លោកតាកែវ ឌយ Takeo Doi បានបរិយាយឡើងអំពីចំនុចសំខាន់ៗនៃ *Amae* (អាកប្បកិរិយាប្រើលួងលោមអាដ្ឋាធរ) ឬការផ្តេកផ្តួលពឹងផ្អែកផ្ទាល់ខ្លួនរបស់ជនជាតិជប៉ុន។ *Amae* អាចមានអត្ថន័យឡើងថា ជាសេចក្តីប្រាថ្នាចង់បានសេចក្តីស្រលាញ់ជាបែបបទកូនង៉ែតដែលទទួលការស្រលាញ់បីបាច់ពីម្តាយ។ វាជាភាពទូទៅហើយបានទទួលយកដោយជន ពេញ វ័យក្នុងការធ្វើ *Amaeru* ដោយប្រើឥរិយាបថលួងលោមនេះ ឬប្រកាន់ឥរិយាបថបំពេញសេចក្តីប្រាថ្នារបស់ខ្លួន ក្នុងការរកសេចក្តីស្រលាញ់ជាភាពម្តាយ និងកូន ពីជនដែលគេមានអារម្មណ៍ថា គេមានទំនាក់ទំនងជាពិសេស។ ភាសាជប៉ុនមានពាក្យពេចន៍ ជាច្រើនសម្រាប់ពណ៌នាអំពីកាលៈទេសៈ ចិត្តសាស្ត្រនៃភាពបរាជ័យឥរិយាបថលួងលោមនេះ ដូចជា *Suneru* (អារម្មណ៍មិនសប្បាយចិត្ត) *Higama* (មានអារម្មណ៍ថាខ្លួនគេបានទទួលភាពអយុត្តិធម៌) *hinekureru* (មានអារម្មណ៍ប្លែកពីអ្នកផ្សេង ផ្ទុយពីការបង្ហាញភាពពិត *Amae*) និង *Uramu* (បង្ហាញកំហឹងស្អប់ខ្ពើម ឬកំហឹងល្ងីងល្ងរចត់ដោយភាពបដិសេធ)។ ទោះបីជា វាជាភាពបង្ហាញឃើញដោយច្បាស់ ឬអត់ច្បាស់ក៏ដោយ ជនជាតិជប៉ុនតែងតែបារម្ភអំពីប្រតិកម្មរបស់អ្នកដទៃទៀត ទៅលើស្ថានភាព Amae។

ទំនាក់ទំនងរវាងបុគ្គលនៅប្រទេសជប៉ុន ពុំត្រឹមតែចាត់ចែងឡើងដោយសេចក្តី ត្រូវការភាពថៃទាំដោយក្តីស្រលាញ់ពីអ្នកផ្សេងនោះទេ ផងដែរ វាក៏យោងទៅលើ ឬតាមកាតព្វកិច្ច។ កាតព្វកិច្ចសាមញ្ញមួយបែបគឺ *giri* ឬជាកាតព្វកិច្ច ដែលត្រូវធ្វើតបឡើងវិញអោយ ដូចជាបែប និងកំណត់ពេលពិតប្រាកដណាមួយ។ *ភាពយោងតាម* បញ្ជាក់ពីបន្ទុកចិត្តសាស្ត្រដែលមានជាមួយ នឹងការជួយបំពេញតាមសេចក្តីស្នើសុំ នៅខណៈដែល *giri* បញ្ជាក់ពីភាពពឹងពាក់គ្នាទៅវិញទៅមកដែលកើតឡើងដោយកាតព្វកិច្ច។

ជនជាតិជប៉ុនធាប់ទទួលអារម្មណ៍កង្វល់ ហើយតាមមើលដោយប្រុងប្រយ័ត្នទៅលើភាពប៉ះទង្គិចដោយសកម្មភាពរបស់ខ្លួនទៅលើអ្នកដទៃទៀត។ នៅខណៈដែលព្រឹត្តិការណ៍សោកនាដកម្មបង្កើនសេចក្តីត្រូវការភាពស្រលាញ់គាំទ្រ ជនជាតិជប៉ុន ភាគច្រើនដែលរួចផុតពីសេចក្តីស្លាប់ ពីភាពរញ្ជួយផែនដី មានអារម្មណ៍ថាគេពុំអាចយកសេចក្តីត្រូវការ ផ្នែកកាយសម្បទា និងអារម្មណ៍ទោរទន់ដ៏ធំធេងរបស់ខ្លួន ទៅដាក់បន្ទុកលើគ្រួសាររបស់គេបានឡើយ ដោយគេពុំអាចគោរព តបស្នងគុណតាមបែប *giri* ដែលមានកំរិត ចំនួនស្មើគ្នាបាន។ សេចក្តីសុំអោយជនចម្លែកជួយ ជាភាពដែលពុំអាចធ្វើឡើងបាន។ កាលៈទេសៈបង្កើតវិបត្តិទៅលើការទាក់ទងរវាងបុគ្គលជាសាមញ្ញនៅប្រទេសជប៉ុន។ ភាពផ្តេកផ្តួលពឹងផ្អែកដែលល្អត្រូវបានជម្រុញ *amaze* ពុំអាចចែកចាយ

ដោយសមរម្យ ដល់ប្រជាជនរាប់ពាន់នាក់ ដែលបានបាត់បង់ផ្ទះសម្បែង និងជនជាទីស្រលាញ់របស់គេនៅទីក្រុងកូបេ ដោយជនដែលរួចផុតពីសេចក្តីស្លាប់ទាំងនោះត្រូវការជំនួយច្រើនពេក។

ភាពសម្រាប់កាតព្វកិច្ចតាមរយៈការទទួលស្គាល់ជាសាធារណៈ និងការពិភាក្សាអំពីបញ្ហានេះ អាចជួយជនរងគ្រោះដោយភាពរញ្ជួយផែនដីជៀសវាងពីភាពអាម៉ាស់មុខ និងខ្មាសអៀនដោយភាពកំណាញ់ ដូចផ្តល់អត្ថន័យ ឡើងជាគំរូបែបបទទំនៀមទម្លាប់។ មានតែកែសម្រួល អត្ថន័យ *giri* ឡើងវិញ ទើបជនរងគ្រោះ និងជនទទួលទុក្ខសោកអាចទទួលជំនួយច្រើនឡើងពីក្រុមគ្រួសារ និងសហគមន៍។ ទោះជាភាពផ្លាស់ប្តូរតិចតួចបំផុតដែលកើតមានឡើងនៅក្នុងទំនាក់ទំនងសង្គមក៏ដោយ សេចក្តីត្រូវការជាពិសេសរបស់ជនរួចផុតពីសេចក្តីស្លាប់ដោយភាពរញ្ជួយផែនដី និងបំណុលដែលកើតមានឡើងដោយលទ្ធផលនេះ អាចចាត់ចែងឡើងបានដោយរដ្ឋាភិបាលតែមួយប៉ុណ្ណោះ។ រដ្ឋាភិបាលជប៉ុន នៅទីក្រុងកូបេ ទទួលយកកាតព្វកិច្ចនេះ ហើយនៅខណៈដែលគេកំពុងតែបំពេញកិច្ចការនេះ គេក៏យកចិត្តទុកដាក់ទៅលើបញ្ហាចិត្តសាស្ត្ររបស់ជន រួចផុតពីសេចក្តីស្លាប់ដោយរញ្ជួយផែនដី គេបានផ្តល់ជំនួយសុខភាពសតិអារម្មណ៍ដល់ប្រជាជនទាំងនេះ។

ទីក្រុងកូបេ ជាទីជំរាលប្រវត្តិសាស្ត្រសង្គមជប៉ុន នៅខណៈដែលប្រជាជនទូទាំងប្រទេសមើលឃើញជាលើកដំបូងអំពីភាពចាំបាច់ ដែលត្រូវជួយជនកំពុងត្រូវការជំនួយ ដោយគ្មានបន្ទោស និងរិះគន់ថាគេខ្វះភាពអត់ធ្មត់ជាវប្បធម៌របស់ជនជាតិជប៉ុន។ ប្រជាជនទូទៅរាប់ពាន់នាក់ នាំគ្នាពពាក់ពពួនចូលទៅទីមហន្តរាយរញ្ជួយផែនដី ផ្តល់ជំនួយដោយស្ម័គ្រចិត្តរបស់គេ ។ ភាពបដិវត្តក្នុងការជួយយកអាសាជនជួបប្រទះ ភាពតក់ស្លុត ដែលចាប់ផ្តើមឡើងនៅ ទីក្រុងកូបេចំរើនលូតលាស់ជាបន្តនៅប្រទេសជប៉ុន។ បច្ចុប្បន្ននេះ ក្រោយពីភាពមហន្តរាយនៅប្រទេសជប៉ុន អ្នកនឹងមិនឃើញផ្លាកបិទស្អិត ជារូបមុខញញឹម ដែលអាផ្សាធរតំបន់បិទផ្សាយនៅលើបង្គោលទូរស័ព្ទ និងអគារពេញ ទីក្រុងកូបេ ជាស់តឿនអោយជនរួចផុតពីសេចក្តីស្លាប់ ទទួលយកព្រេងវាសនារបស់ខ្លួនដោយគ្មានប្រកែក និងពុំបញ្ចេញអារម្មណ៍អវិជ្ជមាន។

មេរៀននៅទីក្រុងកូបេ អាចបន្តពង្រីកមកដល់សហរដ្ឋអាមេរិក ជនជាតិអាមេរិករស់នៅក្នុងសង្គមដែលមានវប្បធម៌ចម្រុះ មូលដ្ឋានរបស់គេ គឺភាពពឹងពាក់ខ្លួន និងភាពតស៊ូដ៏ខ្លាំងក្លា ដែលផ្ទុយ នឹងជនជាតិជប៉ុនដែលបញ្ជាក់ទៅលើភាពផ្តេកផ្តួលពឹងផ្អែក។ នៅទីក្រុងនីវយក បន្ទាប់ពីអំពើវាយប្រហារ ថ្ងៃទី១១ ខែ កញ្ញា ភ្លាម ទីក្រុងឃើញ នឹងភ្នែកជាសាក្សីនូវភាពរឹងមាំទូទាំងវប្បធម៌ និងក្រុមជាតិសាសន៍។ ប្រជាជននីវយកអាចសុំជំនួយពីប្រជាជននីវយកផ្សេងៗទៀតគេ នឹងជួយដោយគ្មានប្រកែកភ្លាម។ តែភាពរឹងមាំនេះរលាយបាត់ទៅនៅពេលក្រោយមក ប្រហែលជាដោយមកពីមានកំណត់កំរិតថ្មី ដែលតម្រូវអោយមានការពឹងផ្អែក នឹងជំនួយមានភាពងាយស្រួលជាងពីមុន ក្រោយពីថ្ងៃ១១ ខែ កញ្ញា មិនត្រូវបានទទួលស្គាល់ នឹងកំណត់ជាផ្លូវការ ។ អ្នកនយោបាយពុំត្រេកអរនឹងសក្តានុពលផ្លាស់ប្តូរនៅក្នុងទំនាក់ទំនងសង្គមឡើយ។ គេបានធ្វើខុសយ៉ាងខ្លាំងនៅពេលដែលគេបរាជ័យពុំគាំទ្រសហការព្យាបាល ផ្ទុយទៅវិញគេបានប្រាប់ប្រជាជន *កុំអោយ* លះបង់ ហើយប្រកបការងារហាក់បីដូចជាគ្មានអ្វីកើតមានឡើង។

កំហុសនេះនៅក្នុងសេចក្តីវិនិច្ឆ័យនយោបាយ គឺយោងទៅតាមភាពល្ងង់ខ្លៅទៅលើ ឥទ្ធិពលព្យាបាលដោយខ្លួនឯង ក្នុងការបង្កើតឥទ្ធិពលខ្លាំងក្លាពិតក្នុងសង្គមថ្មី ។ ភាពពុំស្រួលអារម្មណ៍ក្នុងសង្គម និងភាពតានតឹងអារម្មណ៍កើតមានឡើងនៅខណៈដែលជនជាតិអាហ្វ្រិកកាំង អាមេរិកកាំងចាប់ផ្តើមបញ្ចេញប្រតិកម្មរបស់គេជាសាធារណៈ មានរួមទាំងអ្នកដែលទទួលបទពិសោធន៍ភេរវកម្ម ដែលមានភាពប្រហែលគ្នា និងអារម្មណ៍គ្មានឥទ្ធិពលក្នុងការដោះស្រាយ និងអំពើបំពានជាតិសាសន៍ដែលកើតមានឡើងជាពុំរ៉ៃ ។ មួយរំពេចនោះស្រាប់តែជនជាតិស្បែកស ជាលើកដំបូងបំផុតទទួលសេចក្តីយកចិត្តទុកដាក់ទៅលើអំពើបំពាន ដូចគ្នា ដែលជនជាតិអាហ្វ្រិកកាំងនិង អាមេរិកកាំងបានទទួលអត់ធន់ជាយូរឆ្នាំមកហើយ ។ ជនជាតិអាហ្វ្រិកកាំង និងអាមេរិកកាំង ពុំមានផ្តល់ឱកាសអោយបង្រៀនសាធារណៈ អំពីមេរៀនដែលគេបានរៀនសូត្រ និងបានធ្វើអោយគេចេះដោះស្រាយភាពប្រកាន់ពូជសាសន៍។

សង្គមជាញឹកញាប់ពុំចង់ទទួលស្គាល់របួសទាំងកាយសម្បទា ទាំងសតិអារម្មណ៍ដែលបណ្តាលឡើងដោយអំពើមហាសាហាវយង់ឃ្នង ដោយគេត្រូវតែទទួលស្គាល់ថាអំពើយង់ឃ្នងនេះជាពិតដែលមានកើតឡើងមុនស្ថានភាពមហន្តរាយកើតមានឡើងទៅទៀត។ ការជៀសវាងបែបនេះ គឺទប់ស្កាត់កុំអោយបើកចំហទៅលើភាពប្រុងប្រយ័ត្ន អំពើឃោរឃៅពុំរ៉ៃ និងមូលហេតុដែលបណ្តាលអោយកើតឡើង។ ការវាយប្រហារភេរវកម្មនៅទីក្រុងនីវយក បានបញ្ចេញនូវសេចក្តីភ័យខ្លាច ទៅលើការជួបប្រទះដោយផ្ទាល់ទៅលើកំរិតអំពើយង់ឃ្នង ដែលមានកើតឡើងមុនថ្ងៃទី១១ ខែ កញ្ញា ។ អំពើយង់ឃ្នងលាក់បាំងនោះបានផុសចេញឡើងដោយគ្មានគ្រោងទុក នៅក្នុងការសិក្សាដែលធ្វើឡើង ដល់ចំណោមសិស្ស ប្រាំបីពាន់នាក់ នៅសាលារៀនសាធារណៈ ទីក្រុងនីវយក ពីកំរិតថ្នាក់ទី៤ រហូតដល់ថ្នាក់ទី១២ បានធ្វើឡើងនៅក្នុងពេល ប្រាំមួយខែ បន្ទាប់ពីអំពើវាយប្រហារ។ ការវិភាគតាមពូជសាសន៍នៅក្នុងចំណោមសិស្ស មានប្រហែលជា មួយភាគបី ជាជនជាតិហ៊ីស្ពេនីស (ស្ពេនីស) និង មួយភាគបួនជាអាហ្វ្រិកាំង និងអាមេរិកាំង ហើយជនជាតិស្បែកស និងអាស៊ីជនជាតិភាគតិច ដែលមានចំនួនប្រហែលជា ១៣ ភាគរយ ក្នុងពូជសាសន៍នីមួយៗ។ ប្រហែលជា មួយភាគបួន ក្នុងចំណោមសិស្សទាំងនេះ យ៉ាងតិចបំផុតមានសិស្សម្នាក់ ដែលមានបញ្ហាសតិអារម្មណ៍ខ្លាំង មួយភាគដប់ មានលក្ខណៈ សញ្ញារោគ សមស្របតាមភាពមិនប្រក្រតី នៃភាពតក់ស្លុត(បាក់ស្បាត) ដោយភាពតក់ស្លុត ហើយចំនួន ៥ភាគរយ នៃជនពេញវ័យបានប្រើសុរាដែលបណ្តាលអោយប៉ះពាល់ ដល់មុខងារប្រចាំថ្ងៃរបស់គេ។

កម្រិតទុក្ខព្រួយសតិអារម្មណ៍ខ្លាំងនេះ ពុំអាចសន្មតថា ជាលទ្ធផលទាំងស្រុងកើតមានឡើងដោយអំពើវាយប្រហារនេះឡើយ ដោយកូនក្មេងមួយចំនួន ស្ទើរតែ ពីរភាគទៅបីភាគ បានជួបប្រទះ នឹងព្រឹត្តិការណ៍តក់ស្លុតមុនថ្ងៃទី១១ ខែ កញ្ញា ។ សិស្សពីរនាក់ក្នុងចំណោមសិស្ស ប្រាំនាក់ ឧទាហរណ៍ សិស្សបានឃើញមនុស្សត្រូវគេសម្លាប់ ឬធ្វើបាបអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ។ ក្មេងម្នាក់ក្នុងចំណោមក្មេង បួននាក់ បានរាយការណ៍ប្រាប់អំពីអំពើឃោរឃៅ ឬស្លាប់ដោយគ្រោះថ្នាក់របស់មិត្តភក្តិជិតស្និទ្ធ ។ ក្មេងម្នាក់ក្នុងចំណោមក្មេងបួននាក់ បាយរាយ

ការណ៍ប្រាប់អំពីអំពើឃោរឃៅ ឬស្លាប់ដោយគ្រោះថ្នាក់របស់សមាជិកគ្រួសារ។ ហើយក្មេងម្នាក់ក្នុងចំណោមក្មេងប្រាំពីរនាក់ បានទទួលរងទុក្ខខ្លាំង នៅក្នុងស្ថានភាពអំពើឃោរឃៅ ឬគ្រោះថ្នាក់។

កំរិតជួបប្រទះ និងភាពឃោរឃៅបែបនេះពុំមានទាក់ទង នឹងការវាយប្រហារភេរវកម្មឡើយ កូនសិស្សសាលារៀនសាធារណៈ នៅទីក្រុងនីវយក ជាការពិតបានប្រឈមមុខ នឹងអំពើឃោរឃៅ ស្ទើរតែរៀងរាល់ថ្ងៃ ដែលជាកត្តាធ្វើអោយមានបញ្ហាសតិអារម្មណ៍ខ្លាំង។

អំពើវាយប្រហារអគារភ្លោះ គ្របដណ្តប់បិទបាំងអំពើឃោរឃៅពុំរ៉ែ ដែលប៉ះទង្គិច ដល់សង្គមអាមេរិកកាំង។ អំពើឃោរឃៅរាលដាលបែបនេះ អាចទាក់ទងទៅនឹងពូជសាសន៍ ភេទ ភាពទុរគត និងភាពកេងប្រវ័ញ្ចសេដ្ឋកិច្ច ។ អ្នកដឹកនាំជាច្រើនភ័យខ្លាចក្នុងការដោះស្រាយបញ្ហានេះ ជាពិសេសនៅពេលដែលគេប្រឈមមុខនឹងស្ថានភាពមហន្តរាយបែបនេះ។ អំពើឃោរឃៅនៅក្នុងចំណោមប្រជាជនសាលារៀនសាធារណៈ ទីក្រុង នីវយកជាប្រអប់បីសាច ហើយគ្មានជនមានអំណាចណាម្នាក់ចង់បើកវាឡើយ ។ ដូច្នេះ ជនរងគ្រោះនៅតែមានភាពជាជនរងគ្រោះដដែល នៅខណៈដែលសេចក្តីភ័យខ្លាចភេរវកម្មអន្តរជាតិ បានសង្កត់បន្ថែមទៅលើជីវិតដែលពោរពេញទៅដោយអំពើឃោរឃៅរួចទៅហើយនោះ ។ សោកនាដកម្មដ៏ខ្លាំងនៅថ្ងៃទី ១១ ខែ កញ្ញា ជាឱកាស បញ្ចេញភាពព្រងើយកន្តើយក្នុងការប្រឈមមុខ នឹងអំពើឃោរឃៅបន្តិច បន្តួចដែលប៉ះពាល់ដល់សង្គមអាមេរិកកាំង។ ភាពពិតនៃអំពើឃោរឃៅនៅក្នុងសង្គមជិតខាង អាចជាភាពផ្លាស់ប្តូរយ៉ាងធាប់ហ័ស ដោយទំនាក់ទំនងអំពើវាយប្រឆាំង នឹងភេរវកម្មរបស់ប្រទេសយើង ទៅនឹងអំពើវាយប្រឆាំងលើសេដ្ឋកិច្ច និងអំពើឧក្រិដ្ឋកម្ម។

## ១.១ អំនួតក្រអឺតក្រទមផ្នែកពេទ្យ

អ្នកព្យាបាលសុខភាព និងសតិអារម្មណ៍ ព្រមទាំងគ្រឹះស្ថានសម័យថ្មី ពុំមានសមត្ថភាពបង្ហាញសេចក្តីដឹកនាំរបស់គេក្នុងការចាត់ទុកភាពព្យាបាលដោយខ្លួនឯង ជាផ្នែកមួយដ៏សំខាន់បំផុតនៅក្នុងការសំរាលសេចក្តីឈឺចាប់។ អ្នកវិជ្ជាជីវៈពេទ្យ ផ្តោតសេចក្តីយកចិត្តទុកដាក់ដ៏ចង្អៀតចង្អល់របស់គេ ទៅលើតែជីវសាស្ត្រ បង្កើត ជម្ងឺ និងភាពជំទាស់ និងចំណាប់អារម្មណ៍ ដោយយោងទៅតាមកំរិតចំណេញដែលគេអាចប្រមូលយកពីផ្នែកឧស្សាហកម្មថ្នាំពេទ្យ ហើយមិនយកចិត្តទុកដាក់ទៅលើមធ្យោបាយព្យាបាលចំណេញតិច ជាបែបបទព្យាបាលទាំងមូល (កាយសម្បទា សតិអារម្មណ៍ និងស្ថានភាពសង្គម) ។ ទោះជាអ្នកព្យាបាលសុខភាពភាគច្រើន មានបំណង និងគោលដៅដ៏ប្រសើរថ្លៃថ្លាក៏ដោយ ឧបសគ្គទៅលើភាពទទួលស្គាល់ និងជំនួយទៅលើភាពព្យាបាលដោយខ្លួនឯងនៅតែមានជានិច្ច។

អ្នកព្យាបាលរារាំង និងតាមសង្កេតមើលជាបែបបទ ដូចជារូបគេឈររាំងពីមុខទ្វារ តាមសង្កេតមើលវិធីប្រើថ្នាំបុរាណ ហើយទប់ស្កាត់ជនជួបប្រទះភាពតក់ស្លុត មិនអោយទទួលប្រសិទ្ធិភាពព្យាបាលថ្នាំពេទ្យ និងផ្នែកព្យាបាលសតិអារម្មណ៍ ដោយគេភ័យខ្លាចថាភាពប៉ិនប្រសប់ ចំនេះរបស់គេ និងវិទ្យាស្ថានពុំមានសមត្ថភាព គ្រប់គ្រាន់ដើម្បីទប់សេចក្តីឈឺចាប់ និងទុក្ខព្រួយដែលបញ្ចេញឡើងដោយអំពើឃោរឃៅបានឡើយ។ សេចក្តីឈឺចាប់

ហាក់បីដូចជា ជំងឺដងខ្លាំង គ្មានទីកំណត់ ខុសពីជម្ងឺធ្ងន់ធ្ងរផ្សេងៗទៀត ដូច្នេះ គេទុកអោយអ្នករួចផុតពីសេចក្តីស្លាប់ដោះស្រាយដោយខ្លួនឯង។ ដោយទ្រឹស្តីរបស់វេជ្ជបណ្ឌិតពោរពេញទៅដោយអំនួត និងទម្រង់សម្បើមហួសគេពុំអាចទទួលស្គាល់កាលៈទេសៈ ឬអាចបង្កើតសហការពេញលេញជាមួយ នឹងជនរងទុក្ខដោយភាពតក់ស្លុតបានឡើយ។ តាមបទពិសោធន៍របស់ខ្ញុំ ផ្នែកព្យាបាល វាជាភាពទូទៅដែលវេជ្ជបណ្ឌិតពេទ្យគេចពុំចង់ដឹងប្រវត្តិរឿងតក់ស្លុត អ្នកជម្ងឺរបស់គេទោះបីជាគេបានមើលថែអ្នកជម្ងឺនេះជាយូរឆ្នាំមកហើយ ក៏ ដោយ ។ វេជ្ជបណ្ឌិតមានអារម្មណ៍ថា គេត្រូវមានអំណាចត្រួតត្រាទៅលើទំនាក់ទំនង ដូច្នេះ គេពុំអាចប្រើឥទ្ធិពល ការព្យាបាលដោយខ្លួនឯងបានឡើយ។ ការឆ្លើយទទួលស្គាល់ថាធនធានរបស់អ្នក អ្នកជម្ងឺជាមធ្យោបាយដ៏សំខាន់ក្នុងភាពព្យាបាលពិតជានាំមកនូវភាពអាម៉ាស់មុខដល់រូបគេ។

ផ្ទុយទៅវិញអ្នកព្យាបាល ផ្នែកសតិអារម្មណ៍បានបញ្ជាក់អត្ថន័យជាពិសេសទៅលើរឿងតក់ស្លុត នៅគ្រាដែលគេព្យាបាលជនរួចផុតពីសេចក្តីស្លាប់ ដោយអំពើឃោរឃៅ ។ តែគេកម្រ នឹងសួររក ហើយប្រើរូបមន្តទាំងបួនបែប នៃរឿងតក់ស្លុត (កត្តាពិត អត្ថន័យវប្បធម៌ភាពតក់ស្លុត ភាពមើលហួសពីឆាកជីវិត និងទំនាក់ទំនងរបស់អ្នកស្តាប់ និងអ្នកនិទានរឿង)។ សេចក្តីផ្តោតអារម្មណ៍ដ៏ចង្អៀតចង្អល់ ទៅលើភាពគាំទ្រព្យាបាលបែបនេះ ពេលខ្លះអាចក្លាយទៅជាភាពស្មុគស្មាញ។ កត្តាពិតអំពីភាពឃោរឃៅក្នុងរឿងតក់ស្លុត អាចទទួលសេចក្តីយកចិត្តទុកដាក់ហួសហេតុ ឬការយកចិត្តទុកដាក់ខ្លាំងទៅលើអ្វីតែមួយ ហាក់បីដូចជា សេចក្តីអធិប្បាយអំពីបទពិសោធន៍មានឥទ្ធិពលវេទមន្ត ដែលធ្វើអោយទុក្ខសោករបស់អ្នកជម្ងឺបានភាពជាសះស្បើយ។ អ្នកព្យាបាលលើកទឹកចិត្តអោយអ្នកជម្ងឺនិយាយរឿងឡើងវិញម្តង ហើយម្តងទៀតដោយសង្ឃឹមថាការនិយាយបញ្ចេញរឿងទាក់ទងទាំងអស់នេះចេញ នឹងបំបាត់សញ្ញារោគបាន។ ថ្នាំព្យាបាលសតិអារម្មណ៍ជាធម្មតា ក៏អាចជួយសម្រាលសញ្ញារោគបានដែរ ។ តែភាពពិតប្រាកដ នៃដំនើរជីវិតប្រចាំថ្ងៃរបស់អ្នកជម្ងឺ និងការប្រើជំនួយផ្សេងៗនៅក្នុងសង្គម ទៅលើការព្យាបាល ជាទូទៅច្រើនតែគេមិនអើពើ។ ការសិក្សាស្រាវជ្រាវមួយទៅលើមធ្យោបាយព្យាបាលរបស់អ្នកព្យាបាលវិជ្ជាជីវៈ មានរួមទាំងអ្នកព្យាបាលសុខភាពសតិអារម្មណ៍ នៅប្រទេសកម្ពុជា និងបូស្សនា គេរកឃើញថាវាមានភាពដូចគ្នា ខ្លាំងនៅក្នុងប្រទេសទាំងពីរ ។ នៅខណៈដែលអ្នកព្យាបាលទាំងនេះ ប្រើមធ្យោបាយទៅលើអ្នកជម្ងឺតាមគម្រោងទ្រឹស្តីយោងរបស់គេ គេជឿជាក់ជាសកលថា បញ្ហាធំដែលអ្នកជម្ងឺរបស់គេជួបប្រទះ គឺអំពើឃោរឃៅ និងភាពទុរគត ។ ប៉ុន្តែ ដោយគេគ្មានការហ្វឹកហ្វឺន ភាពប៉ិនប្រសប់ ឬធនធាន សំរាប់ដោះស្រាយភាពទុរគត និងអំពើឃោរឃៅនេះ គេក៏មិនយកចិត្តទុកដាក់ ទៅលើរឿងទាំងនេះទៅ ដោយបែបនេះភាពព្យាបាលនៅដាច់ដោយឡែកពីពិភពសង្គមរបស់អ្នកជម្ងឺតក់ស្លុត។

ប៉ុន្តែ មានអ្នកវិជ្ជាជីវៈពេទ្យខ្លះៗ បានចាប់ផ្តើមប្រើវិធីកែប្រែថ្មី ដែលទទួលស្គាល់សារៈសំខាន់ៗ នៃភាពព្យាបាលដោយខ្លួនឯង។ អ្នកព្យាបាលនៅក្នុងថ្នាក់ស្ទាត់ជំនាញ លោកភីតទ័រ ស៊ី អាឌ័រមែន Peter C. Alderman បានគាំទ្រយ៉ាងសកម្មទៅលើភាពឆាប់ឈប់កើតទុក្ខ នៅក្នុងចំណោមអ្នកជម្ងឺរបស់គេ ។ គេក៏ផ្តោតអារម្មណ៍ទៅលើសេចក្តីត្រូវការរបស់គេសម្រាប់លើកទឹកចិត្ត និងថែទាំខ្លួន នៅពេលដែលគេកំពុងតែប្រឈមមុខព្យាបាលអ្នក

ជម្ងឺ ដែលទទួលបទពិសោធន៍ឃោរឃៅដ៏អស្ចារ្យ ។ អ្នកព្យាបាលក្លាហ៊ានទាំងនេះបានរកឃើញថាឧបសគ្គ ដ៏ធំជាងគេទៅលើការងាររបស់គេ គឺសក្តានុពលនៃភាពគ្រោះថ្នាក់ទៅលើសុខុមាលភាពរបស់គេ ដោយគេមានអារម្មណ៍អាណិតអាសូរ និងមេត្តាលើសលប់ទៅលើអ្នកជម្ងឺរបស់គេ។ ផ្ទុយនឹងចាត់ដាក់អ្នកជម្ងឺអោយនៅឆ្ងាយ គេបានអនុវត្តន៍កម្មវិធីថែទាំខ្លួន ដែលគាំទ្រដោយថ្នាក់រៀនផ្នែកចាត់ចែង។ កម្មវិធីនេះទទួលស្គាល់សេចក្តីគោរពវិទ្យាសាស្ត្ររបស់អ្នកព្យាបាល ទៅលើទំនាក់ទំនងអាណិតអាសូរ ដែលផ្ទេរបទពិសោធន៍ឈឺចាប់របស់អ្នកជម្ងឺ ទៅក្នុងអារម្មណ៍ និងកាយសម្បទារបស់អ្នកព្យាបាល។ បញ្ហាកើតមានឡើងនៅពេលដែលសេចក្តីឈឺចាប់របស់អ្នកព្យាបាល បណ្តាលអោយមានលទ្ធផលមិនល្អដោយមានរួមទៅដោយការឈឺចាប់កាយសម្បទា ហេវហត់ និងទុក្ខកង្វល់។ ដើម្បីរារាំងភាពទាំងនេះ អ្នកចូលរួមនៅក្នុងថ្នាក់រៀនផ្នែកចាត់ចែង បានផ្តោតអារម្មណ៍ទៅលើការនិយាយចែកចាយអំពីករណីលំបាក នៅក្នុងកិច្ចប្រជុំ នៅប្រទេសអ៊ីតាលី រួចនិយាយក្រៅផ្លូវការជាមួយអ្នករួមការងារនៅផ្ទះ ។ កម្មវិធីនេះបានធ្វើអោយសុខភាព និងសុខុមាលភាពរបស់អ្នកព្យាបាល មានភាពប្រសើរឡើង និងទំនុកបំរុងទំនាក់ទំនងល្អរវាងវេជ្ជបណ្ឌិត និងអ្នកជម្ងឺ ។ បើសិនជាវេជ្ជបណ្ឌិតមិនយកចិត្តទុកដាក់ទៅលើអានុភាពព្យាបាលដោយខ្លួនឯង នៅក្នុងខ្លួនគេនោះទេ គេក៏ នឹងមិនយកចិត្តទុកដាក់ទៅលើអ្នកជម្ងឺរបស់គេដែរ ហើយគេទាំងពីរនាក់ នឹងវង្វេងវង្វាន់ ដោយកង្វល់នៅក្នុងទំនាក់ទំនងរបស់គេទាំងពីរ អាចមានភាពលើសលប់ក្រៃលែង ។ គួរអោយស្តាយដោយអ្នកព្យាបាលសុខភាព និងសតិអារម្មណ៍ រស់នៅក្នុងរង្វង់ពិភពវិជ្ជាជីវៈពោរពេញទៅដោយអំនួតក្លាហ៊ាន ដែលមិនអោយគេ ទទួលស្គាល់ភាពទន់ខ្សោយរបស់ខ្លួនគេ និងសេចក្តីត្រូវការថែទាំខ្លួនគេ។

## ១.២ បំណងល្អបណ្តាលអោយមានលទ្ធផលអាក្រក់

មនុស្ស និងវិទ្យាស្ថានល្អពេលខ្លះអាចប្រព្រឹត្តិអំពើអាក្រក់ ករណីនេះ ពិតជាចាត់តាំងលក្ខណៈរបស់អង្គការសង្គ្រោះអន្តរជាតិជាច្រើន ដែលព្យាយាមជួយជនជួបប្រទះភាពតក់ស្លុត ជាពិសេសជនភៀសខ្លួន និងជនរួចផុតពីសេចក្តីស្លាប់ដោយសង្គ្រាមសាហាវយង់ឃ្នង ។ ខ្ញុំបានដឹងអំពីភាពមិនចុះសម្រុងគ្នារវាងបំណងល្អ និងលទ្ធផលអាក្រក់ នៅគ្រាដំបូងនៅក្នុងកិច្ចការរបស់ខ្ញុំ ផ្នែកជនភៀសខ្លួន ។ នៅក្នុងឆ្នាំ ១៩៩០ ខ្ញុំបានទទួលលិខិតសម្ងាត់មួយច្បាប់ ពីជនភៀសខ្លួនខ្មែរម្នាក់ដែលរស់នៅក្នុងជុំរុំសាយធូ ជាអ្នកថែទាំប្រជាជនខូចសតិអារម្មណ៍ខ្លាំងជាងគេនៅក្នុងជុំរុំ ដាច់ឡែកពីអាជ្ញាធរជុំរុំ ។ លិខិតនោះសរសេរជាអក្សរខ្មែរ ហើយបានលួចបញ្ជូនចេញពីជុំរុំដោយបុគ្គលិកសង្គ្រោះ ហើយធ្វើរជាសម្ងាត់តាមទូរសារ (ហ្វាក់ Fax) ទៅមន្ទីរពេទ្យព្យាបាលរបស់ខ្ញុំនៅបូស្តុន ។ ក្នុងការសរសេរលិខិតនេះ មិត្តខ្មែរម្នាក់របស់ខ្ញុំ បានហ៊ានដាក់ជីវិតរបស់ខ្លួននៅក្នុងភាពគ្រោះថ្នាក់ ទោះជាគេបានទទួលការហាមឃាត់ពីអាជ្ញាធរថៃថា បើជនណាប្រាប់នរណាម្នាក់ ជាពិសេសជនក្រៅជុំរុំអំពីស្ថានភាពក្នុងជុំរុំ ជននោះ នឹងទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ លិខិតនោះចាប់ផ្តើមដូចខាងក្រោមនេះ៖

৬ *ថ្ងៃទី៥ ខែ មករា ឆ្នាំ១៩៩០ ម៉ោង២ល្ងាច* ជនជាតិខ្មែរស្ទើរតែគ្រប់រូប ដែលរស់នៅជុំរុំសាយធូ មានរោគសតិអារម្មណ៍។ អ្នកខ្លះមានរោគធ្ងន់ធ្ងរ អ្នកខ្លះអត់មាន រោគសតិអារម្មណ៍ទាំងនេះបណ្តាលមកពីការរស់នៅក្នុងជុំរុំយូរ

ពេក និងដោយសារអំពើជិះជាន់ពុករលួយរបស់ជនមានអំណាចនៅក្នុងជុំរុំ ។ *ដូចជា មេសូត្រនៅកំរិតថ្នាក់រៀនទី៣បានថ្លែងថា "គោព្រៃ:តូចទទួលទានតិច ធំទទួលទានច្រើន" ។*

៦ ផ្ទុយពីសេចក្តីរាយការណ៍ទាំងប៉ុន្មានរបស់អង្គការសហប្រជាជាតិ និងអាជ្ញាធរជុំរុំថៃ ដែលបានរាយការណ៍ជូនពិភពលោកជាផ្លូវការ ភាពឃុំឃាំងយូរពេល និងអំពើពុករលួយទាំងនេះ បានបង្កើតអោយមានរោគសតិអារម្មណ៍នៅក្នុងចំណោមប្រជាជនខ្មែរ។ គួរអោយភ្ញាក់ផ្អើលដោយលិខិតនេះពុំមាននិយាយអំពីអំពើសម្លាប់រង្គាលនៅក្នុងរបបប៉ុលពត ពីឆ្នាំ១៩៧៥ ទៅឆ្នាំ១៩៧៩ ។

ឃើញថាភាពឃុំឃាំង និងអំពើពុករលួយបានបិទបាំងអំពើសាហាវយង់ឃ្នងដែលជាភាពតក់ស្លុតជាចំបង នៅរយៈកាលរបបប៉ុលពតលិខិតបានបន្តទៀតថា ៖

*៧ អ្នកដឹកនាំទាំងនេះឈ្លោះគ្នាទៅវិញទៅមក ដោយដណ្តើមគ្នាថា នរណាមានអំណាច ជាង អំណាចទាំងនេះ បណ្តាលអោយអ្នកដឹកនាំទាំងនេះពុករលួយ ដោយគេគិតថានៅខណៈ ដែលគេមានអំណាច គេមានប្រាក់ ។ តើគេបានប្រាក់មកពីណា? គេបានប្រាក់មកពីអង្គការសង្គ្រោះ គេយកមនុស្សធ្វើជាឈ្នាន់ ដើម្បីទទួលប្រាក់ ។ គេបានប្រាប់អង្គការទាំងនេះថាទ គេត្រូវការនេះ សំរាប់ប្រជាជនរបស់គេ ។ អង្គការទាំងនេះយល់ព្រមផ្តល់ជំនួយដោយពុំដឹងថាអ្នកដឹកនាំក្នុងជុំរុំប្រើឈ្មោះប្រជាជនមកបិទបាំង ដើម្បីយកប្រាក់សំរាប់ខ្លួនឯង ។ តែប្រជាជននៅតែវេទុក្ខ ហើយគេដកហូតយកអ្វីៗ ដែលប្រជាជនត្រូវការជាចាំបាច់ ។ អ្នកមានអារម្មណ៍ថា អ្នកមិនអាចធ្វើអ្វីកើត មានតែទ្រាំមើលអំពើពុករលួយដែលកំពុងតែកើតមានឡើង ។ អ្នកមានតែទទួលអារម្មណ៍ឈឺចាប់ដោយអំពើក្បត់ទាំងនេះ អ្នកដឹកនាំឈ្លាសវៃលើតែ ផ្នែកកេងប្រវ័ញ្ចយកចំណេញ។ សិទ្ធិ និងអំណាច គឺនៅលើអ្នកទាំងនេះ ។ ការធ្វើអ្វីមួយដោយគ្មានការអនុញ្ញាតពីអ្នកទាំងនេះជាអំពើខុស នៅទីនេះគេនិយាយថា យើងមានលិទ្ធិប្រជាធិបតេយ្យ តែគេបានអនុវត្តលិទ្ធិផ្តាច់ការ។ សូមមើលមកនាយកជុំរុំ នាយកអង្គការស្ត្រីខ្មែរ នាយក្រុមនាយកសាលារៀន អគ្គមេបញ្ជាការប៉ូលីស នាយកមន្ទីរពេទ្យ មុខងារទាំងនេះគ្មានផ្លាស់ប្តូរជាង១០ឆ្នាំមកហើយ។ ទោះបីជាប្រជាជនមិនចូលចិត្តអ្នកទាំងនេះក៏ដោយ ក៏ប្រជាជនគ្មានធ្វើអ្វីកើតឡើយ ករណីទាំងនេះជាមូលហេតុបណ្តាលអោយមានរោគសតិអារម្មណ៍។*

ក្រោយពីភាពអាប់កេរ្តិ៍ឈ្មោះនៅក្រោមរបបខ្មែរក្រហម ជនភៀសខ្លួននៅតែជាប់គុក ដោយភាពកេងប្រវ័ញ្ចយកចំណេញលើ និងភាពក្បត់ដោយលិទ្ធិ "ប្រជាធិបតេយ្យ" ដែលបានទទួលឧបត្ថម្ភជាថវិកា ដោយអង្គការអន្តរជាតិ ជាបែបបទរបបខ្មែរនៅក្នុងជុំរុំ ។ ទោះបីជាគ្មានលិខិតនេះក៏សហគមន៍ជំនួយអន្តរជាតិ មិនគប្បីអះអាងថាគេមិនបានដឹងឮអំពីស្ថានភាពនេះទេ។ ការយល់ព្រមធ្វើការក្រោមច្បាប់ "ទប់ស្កាត់ភាពអមនុស្សធម៌" ដែលតម្រូវឡើងដោយរដ្ឋាភិបាលថៃ ដែលផ្តល់ធនធានដល់ប្រជាជនគ្រប់ល្មមសំរាប់រស់តែប៉ុណ្ណោះ អង្គការសហប្រជាជាតិ និងអង្គការសង្គ្រោះឯទៀត បានធ្វើការសម្របសម្រួលដោយគ្រោះថ្នាក់។ ជាសំណាងអាក្រក់ដោយបែបបទ និងកំណត់កិច្ចសម្របសម្រួលនេះពុំអាចដឹងលឮបានឡើយ ដោយឯកសារប្រតិបត្តិនៅក្នុងជុំរុំផ្នែកសង្គ្រោះសហប្រជាជាតិបានត្រូវគេបំផ្លាញចោលអស់។

ការបដិសេធរបស់បុគ្គលិកអង្គការសហប្រជាជាតិអំពីភាពឃោរឃៅ អំពើឃុំឃាំងដោយអមនុស្សធម៌ជាភាពពិបាកយល់ តែលិខិតបានផ្តល់ដំណឹងផ្ទៃក្នុងខ្លះៗ ៖

*☚ ជនបរទេសភាគច្រើនជឿជាក់ថា ប្រជាជនខ្មែរពុំចង់ទៅទីណាឡើយ គេស្រលាញ់ប្រទេសរបស់ខ្លួន ដោយគេមានជីវិតរស់នៅដ៏ល្អនៅក្នុងជុំរុំ។ ជនជាតិខ្មែរជួយគ្នាទៅវិញទៅមកដោយល្អ ជនជាតិខ្មែរស្រលាញ់គ្នា វាជាការពិតដោយជនបរទេសជួយតែជនមានអំណាច ជនជាតិខ្មែរខ្លាចមិនហ៊ាននិយាយ។*

*☚ ជនជាតិខ្មែរពិតជាខ្លាចមិនទុកចិត្តអ្នកថែទាំរបស់គេ អំពីរឿងតក់ស្លុតរបស់ខ្លួនគេ ជាទូទៅនៅ ខណៈដែលបុគ្គលិកសង្គ្រោះមនុស្សធម៌ និងអង្គការសហប្រជាជាតិជួយជាសម្ភារៈផ្សេងៗ ដល់ជនជាតិខ្មែរជាច្រើនរូប ដើម្បីរស់រានមានជីវិត គេពុំមានចូលរួមនៅក្នុងទំនាក់ទំនងស្តាប់ពេញលេញនៅក្នុងការនិយាយរឿងឡើយ។ ទោះជាបុគ្គលិកសង្គ្រោះខ្លះៗ បានយកចិត្តទុកដាក់ទៅលើបញ្ហាសតិអារម្មណ៍របស់ជនជាតិខ្មែរ ជនទាំងនេះមានអំណាចតិចតួចទៅលើច្បាប់ទប់ស្កាត់ភាពអមនុស្សធម៌ នៅក្នុងជុំរុំ ដែលជាករណី បង្កើតភាពតានតឹងអារម្មណ៍ច្រើន។ វាជាឱកាសដ៏ប្រសើរសម្រាប់ភាពជាសះស្បើយ ដោយវាបិទបាំងសេចក្តីឈឺចាប់ពីអំពើសម្លាប់រង្គាលនៅក្នុងរបបប៉ុលពត។*

លិខិតបានបញ្ចប់រួមដោយទំនាយទៅលើភាពមហន្តរាយៈ

*☞ ចំពោះគំនិតខ្ញុំ បើសិនជាអ្វីៗ ទាំងអស់នៅតែមានភាពបែបនេះ ចំនួនប្រាំឆ្នាំទៀត ជាជាតិខ្មែរគ្រប់រូបនឹងក្លាយទៅជាឆ្កួតអស់ហើយ ។ ជនជាតិខ្មែរត្រូវការការព្យាបាល ពុំដូច្នោះទេ ជនជាតិខ្មែរស្ទើរតែគ្រប់រូប នឹងស្លាប់ដោយទុក្ខកង្វល់ធ្ងន់ធ្ងរ និងដោយមានអារម្មណ៍ថា ជីវិតរបស់គេពោរពេញទៅដោយភាពអស់សង្ឃឹម។*

*☞ ក្រោយមកជុំរុំសាយធូក៏បានបិទ នៅក្នុងដើមឆ្នាំ ១៩៩០ ប្រជាជនដែលស្នាក់នៅក្នុងជុំរុំ ក៏វិលត្រលប់ទៅប្រទេសកម្ពុជាវិញ បច្ចុប្បន្ននេះ ភាពពិតនៃដំនើរការនេះបានអនុវត្តន៍ឡើង ដូចគ្នានៅប្រទេសអាស៊ី អាហ្វ្រិក បណ្តាប្រទេសមជ្ឈឹមបូព៌ា និងប្រទេសឡាតាំងអាមេរិកកាំង។*

មានប្រជាជន ចំនួនប្រាំពីរលាននាក់ ទូទាំងសកលលោក ហើយជនភៀសខ្លួនជិត ដប់ពីរលាននាក់ ត្រូវទុកនៅក្នុងជុំរុំជនភៀសខ្លួនជាង មួយទសវត្ស ។ ជុំរុំជនភៀសខ្លួន និងការរៀបចំជីវិតរស់នៅឡើងវិញជាសញ្ញាចាត់សន្មតថា ស្ទើរតែទូទាំងពិភពលោក គេមិនយកចិត្តទុកដាក់ទៅលើសក្តានុពលព្យាបាលរបស់ជនជួបប្រទះភាពតក់ស្លុតឡើយ ។ នៅក្នុងគំរោងប៉ងប្រាថ្នាការពារ និងថែទាំជនភៀសខ្លួនរបស់អង្គការអន្តរជាតិ គេបានបង្កើតបរិដ្ឋានកំរិតអតិបរមា ស្ទើរតែគ្រប់កត្តាអាក្រក់នៅក្នុងសង្គម ដោយបណ្តុះបណ្តាលអ្នកជម្ងឺ ដូចជាភាព អត់ការងារធ្វើពុំរ៉ៃ និងអំពើឃោរឃៅគ្មានស្រាកស្រាន្ត។ ភាពប្រឆាំងដូចគ្នានេះ អាចឃើញមាននៅកំរិតសហគមន៍ដោយភាពសម្រុះសម្រួល ផ្នែកនយោបាយបានទទួលស្គាល់ថា ភាពធ្វើអោយប៉ះពាល់ដល់តម្លៃទូទៅនៅក្នុងសង្គម។ នៅក្នុងករណី ជំនួយជនភៀសខ្លួន អង្គការសង្គ្រោះមនុស្សធម៌ ត្រូវប្រកាន់ឆន្ទៈយ៉ាងរឹងមាំប្រឆាំង នឹងស្ថានភាពដែលឃើញថាខុសយ៉ាងពិតប្រាកដ។

## ១.៣ សិទ្ធិមនុស្សប្រឈមនឹងការព្យាបាល

បច្ចុប្បន្ននេះ ភាពប្រឆាំងដ៏ខ្លាំងក្លា គឺរវាងភាពផ្តោតអារម្មណ៍ទៅលើសិទ្ធិមនុស្ស និងសេចក្តីត្រូវការថែទាំជនជួបប្រទះភាពតក់ស្លុត ។ បន្ទាប់ពីអំពើឃោរឃៅបានបញ្ចប់ទៅ ជនរួចផុតពីសេចក្តីស្លាប់ទូទាំងពិភពលោកចង់បានយុត្តិធម៌សង្គម ។ ការដោះស្រាយយុត្តិធម៌ជាសាធារណៈ អាចនឹងជួយបង្កើនភាពជាសះស្បើយរបស់ជនរួចផុតពីសេចក្តីស្លាប់ ដោយគេអាចបង្ហាញសេចក្តីព្យាយាមការព្យាបាលរបស់គេ ។ សកម្មភាពនីតិក្រម និងការកាត់ទោសឧក្រិដ្ឋជនសង្គ្រាម ជាចលនាឈានទៅមុខ នៅក្នុងច្បាប់សិទ្ធិមនុស្ស។ សេចក្តីពិត និងសេចក្តីចរចារបស់គណៈកម្មាការ ប្រទេសអាហ្វ្រិកខាងត្បូង ទៅលើការកាត់ទោសទាក់ទងទៅ នឹងអតីតប្រទេសយ៉ូហ្គូស្លាវ៉ា (Yogoslavia) នៅទីក្រុងហេច Hague ប្រទេសណេទ័រឡែន (Neitherland) ជាបទពិសោធន៍ដ៏ទំនើបដើម្បីបង្កើតភាពយុត្តិធម៌ នៅក្នុងសង្គមដែលប្រឆាំងគ្នាបន្ទាប់ពីសង្គ្រាម អាចជាភាពព្យាបាលដ៏មានតម្លៃសំរាប់ប្រជាជននៅក្នុងស្រុក។ ទោះបីជាយ៉ាងណាក៏ដោយ ផលប្រយោជន៍នៃភាពព្យាបាលបែបនេះ ពុំទាន់មានបង្ហាញឡើងដោយច្បាស់លាស់នៅឡើយទេ។

ភាពទទួលស្គាល់របស់សង្គមទៅលើការថ្លែងជាកសិណសាក្សីជាសាធារណៈ នៅក្នុងប្រទេសខ្លះៗ អាចប្រើពេល រាប់ទសវត្ស ដូចជាបានកើតឡើងនៅប្រទេសឆីលី Chile ទាក់ទងទៅ នឹងរបបពីណូចេ (Pinochet)។ ដំនើរការពន្យាពេលក្នុងការយកឧក្រិដ្ឋជនមករកយុត្តិធម៌ បណ្តាលអោយជនរងគ្រោះអាក់ខានពុំអាចបញ្ចប់រឿងតក់ស្លុតរបស់គេបាន។ សេចក្តីសង្ឃឹមទុកជាមុនដ៏យូរលង់មកហើយទៅលើ ការស្លាប់របស់ ប៉ុលពតនៅក្នុងឆ្នាំ ១៩៩៨ ហាក់បីដូចជា ផ្តល់អារម្មណ៍ធូរស្រាលតិចតួចដល់ចំណោមជនជាតិខ្មែរដែលរស់នៅប្រទេសអាមេរិក។ អ្នកកាសែតបស្ចិមប្រទេសពីរទៅបីនាក់ បានធ្វើជាសាក្សីនៅក្នុងកិច្ចកាត់ទោសប៉ុលពតដែលធ្វើឡើងដោយក្រុមដឹកនាំយោធានៅសេសសល់ពីរបបខ្មែរក្រហម ។ ក្រោយពីដំណើរការកាត់ក្តី នេះចាប់ផ្តើមឡើង បន្តិចក្រោយមកប៉ុលពតក៏បានស្លាប់ទៅ គាត់ស្លាប់ជាបុរសមានរោគា និងទន់ខ្សោយ គួរអោយចម្លែកគេបានបូជាគាត់ នៅក្នុងគំនរភ្នក់ភ្លើងកង់ឡានដែលគេបោះបង់ចោល ហើយកៅអីដែលគាត់ចូលចិត្តអង្គុយនោះ គេបានយកមកដាក់នៅពីលើគំនរភ្លើង។ សេចក្តីកាត់ទោសដែលបានស្នើសុំឡើងដោយអ្នកដឹកនាំខ្មែរមានអំណាចហ៊ុនសែន ទៅលើអ្នកដឹកនាំខ្មែរក្រហមជាៗ ដែលនៅសេសសល់ទាំងប៉ុន្មាន ជាភាពគំរាមកំហែងបើកកកាយឡើងវិញនូវទុក្ខកង្វល់ និងសេចក្តីឈឺចាប់របស់សាធារណៈជន។ ដោយកំរិតលទ្ធផលអាក្រក់ទៅលើភាពព្យាបាលអាចកើតមានឡើងដោយសារការកាត់ទោសនេះមានកំរិតខ្លាំង គណៈកម្មាការអន្តរជាតិ ត្រូវតែធានាអះអាងទៅលើជំនួយចិត្តសាស្ត្រដល់ប្រជាជនដែលបានឡើងថ្លែងជាកសិណសាក្សី។

ជាកម្រិតមធ្យមកំរៃសំណងពិត គឺត្រូវផ្តល់ជំនួយចិត្តសាស្ត្រមានរួមទាំងការផ្តល់ឱវាទដល់ជនរួចផុតពីសេចក្តីស្លាប់រាប់ពាន់នាក់ ដែលបានរៀបរាប់រឿងតក់ស្លុតរបស់គេជាបរិបទនយោបាយ និងនីតិក្រម ។ វាជាករណីបារម្ភដោយជំនួយចិត្តសាស្ត្រសំរាប់ជនរងគ្រោះមានកំរិតតិចតួច ជាញឹកញាប់ច្រើនតែគ្មានទៀតផង។

វាក៏ជាករណីទុក្ខកង្វល់ផងដែរ នៅពេលដែលគេទាមទាររកយុត្តិធម៌ បុគ្គលិកសិទ្ធិមនុស្សយកចិត្តទុកដាក់ទៅលើតែភាពបញ្ជាក់ជាក់ស្តែងថា អំពើបំពានច្បាប់សិទ្ធិមនុស្ស បានកើតឡើងយ៉ាងពិតប្រាកដ ដោយពុំគិតអំពីលទ្ធផល អំពើឃោរឃៅកើតមានឡើងដល់សុខភាព និងសុខុមាលភាពរបស់ជនដែលរួចផុតពីសេចក្តីស្លាប់ ។ សេចក្តីយកចិត្តទុកដាក់ទៅលើភាពជាសះស្បើយអំពើឃោរឃៅ ជាករណីដែលកម្រឃើញមាននៅក្នុងប្រព័ន្ធច្បាប់។

សង្គមបានធ្វើខុសយ៉ាងធ្ងន់ធ្ងរ នៅពេលដែលគេយកចិត្តទុកដាក់ទៅលើការយកព័ត៌មានលំអិត ទៅលើអំពើសម្លាប់ និងឧក្រិដ្ឋកម្មផ្សេងៗទៀត ជាបេសកម្មព្យាបាលដោយខ្លួនឯង។ សមាគមសិទ្ធិមនុស្សអន្តរជាតិនៅស្រេប្រីនីកា ( Srebrenica ) ឧទាហរណ៍ បានបង្កើតសារមន្ទីរវន្ទត់តក់ស្លុត ដោយមានបូជនីយដ្ឋាន និងផ្នូរសព។ គ្រប់ទីកន្លែងនានា នៅតាមខេត្ត អ្នកបានឃើញ នឹងភ្នែកនូវភស្តុតាងអំពើសម្លាប់រង្គាលជនស៊ីវិលនៅក្នុងតំបន់។ ជាការពិតណាស់រាង្គកាយរបស់ជនបាត់ខ្លួនត្រូវគេយកមកធ្វើការសម្គាល់អត្តសញ្ញាណ រួចគេបញ្ជូនទៅអោយក្រុមគ្រួសារវិញការប្រគល់អោយវិញ សូម្បីតែឆ្អឹងតូចមួយសំរាប់ក្រុមគ្រួសារ ក៏ជាករណីដ៏សំខាន់បំផុតក្នុងការជួយជំរុញដំណើរការបញ្ចេញទុក្ខសោកហើយបន្ទាប់មកវាអាចក្លាយទៅជាភាពស្បើយទុក្ខ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រជាជនក្នុងភូមិមានអារម្មណ៍ថា កម្លាំងដែលចំណាយទៅលើការបង្កើតសេចក្តីលំអិតទៅលើសេចក្តីស្លាប់ទាំងនេះមានកំរិតច្រើនជាងការជួយបុគ្គលម្នាក់ៗ នៅក្នុងដំណើរការព្យាបាលដោយខ្លួនឯងរបស់គេ។ ភាពខ្វះខាតសេវាសុខភាព និងសតិអារម្មណ៍ច្បាស់លាស់ នៅតាមខេត្តបានបង្ហាញយ៉ាងច្បាស់លាស់អំពីករណីនេះ។

នៅដើមឆ្នាំ១៩៨០ ការប្រឆាំងរវាងក្រុមទាក់ទិននៅក្នុង ផ្នែកសិទ្ធិមនុស្ស និងសុខភាពសតិអារម្មណ៍ពេលខ្លះមានកំរិតខ្លាំងឥតឧបមា។ ស្ត្រីម្នាក់នៅខណៈដែលគាត់កំពុងតែរត់គេចចូលជុំរុំសាយធូ ពីប្រទេសខ្មែរត្រូវពួកទ័ពឈ្លប មិនស្គាល់មុខរំលោភបំពានយ៉ាងឃោរឃៅ។ ប្តីរបស់គាត់ត្រូវគេសម្លាប់ចោល វារំលោភផ្លូវភេទគាត់ ហើយវាកាត់ដៃទាំងពីររបស់គាត់។ ក្រោយពីក្រុមសុខភាពនៅមន្ទីរព្យាបាល បានរៀបចំគំរោងនីតិសម្បទាផ្នែកសតិអារម្មណ៍ និងមធ្យោបាយផ្តល់ឱវាទសំរាប់រូបគាត់ គេបានយករូបថតរបស់គាត់ ទៅភ្នាក់ងារសិទ្ធិមនុស្សសុំជំនួយ ដើម្បីព្យាបាលគាត់។ ភ្នាក់ងារនោះបានឆ្លើយតបថា ដោយរឿងហេតុនេះពុំមែនជាអំពើឃោរឃៅសិទ្ធិមនុស្ស តែជាឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយចោរព្រៃ គេពុំអាចជួយបានឡើយ។ ទស្សនៈរបស់ខ្ញុំ ផ្នែកវិជ្ជាពេទ្យគឺ សេចក្តីសំរេចថាមានការបំពាននីតិក្រម ឬអត់មាននោះ មិនទាក់ទងគ្នាក្នុងការជួយជនណាម្នាក់អោយភាពជាសះស្បើយពីបញ្ហាសុខភាព និងសតិអារម្មណ៍ឡើយ។

កម្រងរឿងទាក់ទងទៅ នឹងអំពើរំលោភបំពានផ្លូវភេទ ពុំមានកើតឡើងនៅក្នុងបច្ចុប្បន្នកាលនេះ ទៀតទេ។ ទស្សនៈនេះបានបង្កើតឡើងនៅក្នុងឆ្នាំ១៩០៧ ពាក្យមួយឃ្លាថា *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* បានទុកចោលដោយគ្មានបកស្រាយច្បាស់លាស់រហូតទាល់តែសង្គ្រាមសកលលោកលើកទីII នៅខណៈដែលសេចក្តីកាត់ទោសឃោជាអន្តរជាតិសម្រាប់ប្រទេសអាឡឺម៉ង់ និងជប៉ុន បានបកស្រាយឧក្រិដ្ឋកម្មថាជា "ឃាតកម្មប្រល័យវាលកាលទាសករនិរទេស ឬសកម្មភាពអមនុស្សធម៌ផ្សេងៗទៀត ដែលប្រព្រឹត្តឡើងប្រឆាំង នឹងជនស៊ី

វិល"។ អំពើរំលោភបំពានផ្លូវភេទភាគច្រើន គេមិនយកចិត្តទុកដាក់រហូតទាល់តែដល់ ឆ្នាំ១៩៩០ ជាកំណត់ពេលដែលអំពើរំលោភផ្លូវភេទបានកើតឡើងយ៉ាងខ្លាំងនៅក្នុងកំឡុងសង្គ្រាមប្រឆាំងគ្នា នៅក្នុងប្រទេសរ៉្វាន់ដា (Rowanda) និងប្រទេសអតីតយូហ្គូស្លាវ៉ា (Yogoslavia) ពេលនោះហើយដែលគេទទួលយកចិត្តទុកដាក់ជាសាធារណៈ។

បែបបទប្រល័យបំបាត់ពូជសាសន៍ដ៏ខ្លាំងក្លានេះ ដោយមានរួមទាំងអំពើរំលោភផ្លូវភេទច្រើនក្រៃ និងអំពើបំពានផ្លូវភេទនៅក្នុងប្រទេសអតីតយូហ្គូស្លាវ៉ា និងប្រទេសរ៉្វាន់ដា នៅដើមឆ្នាំ១៩៩០ បានបណ្តាលអោយមានភាពពង្រីកប្រព័ន្ធការពារប្រឆាំងអំពើរំលោភផ្លូវភេទដោយសង្គ្រាមក្រោមច្បាប់អន្តរជាតិ។

សេចក្តីការពារនៅពេលបច្ចុប្បន្ននេះ មានរួមទាំងការផ្តល់សេវាថែទាំសុខភាព និងសតិអារម្មណ៍ដល់ជនដែលទទួលអំពើរំលោភបំពានផ្លូវភេទ។

ផងដែរច្បាប់សិទ្ធិមនុស្សបានអនុវត្តន៍ឡើង នៅក្នុងករណីរំលោភបំពានផ្លូវភេទ ពេលនេះត្រូវតែបង្វែរសេចក្តីយកចិត្តទុកដាក់របស់គេចេញពីអត្ថន័យច្បាប់តឹងតែង ហើយពង្រីកសេចក្តីប្តេជ្ញារបស់គេ ទៅលើការផ្តល់សេវាថែទាំសុខភាព និងសតិអារម្មណ៍ជាសកលដល់ជនរងគ្រោះ ដោយអំពើឃោរឃៅទាំងអស់គ្នា។ ការរៀបចំ និងការប្រតិបត្តិឆ្លើយតបទៅលើភាពព្យាបាល បច្ចុប្បន្ននេះ មាននៅក្នុងគំនិតភ្លាមៗ របស់រដ្ឋាភិបាល ភ្នាក់ងារវិវឌ្ឍនភាពអន្តរជាតិ និងអង្គការសហប្រជាជាតិដែលត្រូវតែរៀបចំប្រព័ន្ធថវិកាជំនួយជាបែបបទតម្រូវឡើងតាមច្បាប់។ អ្នកសកម្មនិយមសិទ្ធិមនុស្ស និងអ្នករួមការងារជំនួយមនុស្សធម៌ ត្រូវតែភ្ជាប់កិច្ចការរបស់គេទៅនឹងដំណើរការព្យាបាល។ គេត្រូវតែសួរថា : "តើកម្មវិធីរបស់ខ្ញុំ និងក្រិតក្រមប៉ះពាល់ដល់សុខភាព និងសុខុមាលភាពរបស់ជនរួចផុតពីសេចក្តីស្លាប់បែបណា? តើកម្មវិធីទាំងនេះ ជួយជម្រុញអោយមានភាពព្យាបាលដោយខ្លួនឯងដល់សហគមន៍ និងជនដែលកំពុងតែទទួលសេវា ដែរ ឬទេ? " លើកលែងតែសេចក្តីយកចិត្តទុកដាក់ទៅលើចិត្តសាស្ត្រ និងសុខុមាលភាពសង្គមរបស់ក្រុមរួចផុតពីសេចក្តីស្លាប់ ផ្តល់ជាដំណឹងទៅផ្នែកសិទ្ធិមនុស្ស ពុំដូច្នេះទេមជ្ឈដ្ឋានជំនួយមនុស្សធម៌សន្ទឹកសន្ទាប់ នៅតែមានរួមទៅដោយកម្មវិធីព្យាបាលមិនគ្រប់គ្រាន់ និងបរាជ័យ។

## ១.៤ ថែទាំសង្គមដែលមានជម្ងឺ

នៅនិទាឃរដូវ ឆ្នាំ២០០៤ បុរសម៉ូស្លីមក្មេងម្នាក់ ឈ្មោះយូស៊ឺវ (Jusuf)បានចូលវាយប្រយុទ្ធកាលពីកុមារភាពនៅក្នុងទ័ពឃោជាម៉ូស្លីម នៅប្រទេសបូស្សនា គាត់ធ្វើការនៅក្នុងកម្មវិធីវិវឌ្ឍនភាព នៅខេត្តស្រេប្រេនីកា។ គាត់បានព្យាយាមបង្រៀនកសិករជនជាតិស៊ើប និងម៉ូស្លីមអំពីរបៀបធ្វើឈីស(Cheese)ក្នុងស្រុក ដើម្បីយកទៅលក់ដោយជោគជ័យនៅទីផ្សារបូស្សនា។ បុរសក្មេងម្នាក់នេះ ពោរពេញទៅដោយឧត្តមគតិនិយម ហើយបានធ្វើការជាច្រើនម៉ោង ដើម្បីសម្រេចបេសកម្មរបស់ខ្លួន តែសោកនាដកម្មនៅស្រេប្រេនី កាធ្វើអោយវានៅតែនឹកមមៃឃើញនៅក្នុងអារម្មណ៍របស់វា។ វាទទួលអារម្មណ៍ថាភាពស្អប់ខ្ពើមដែលពុំបញ្ចេញអោយឃើញកំពុងតែកើត

មានឡើងនៅក្នុងសហគមន៍ ទោះបីជា មានការបដិសេធពីប្រជាជនស្បើបក្នុងតំបន់ និងអាជ្ញាធរជាតិថា គ្មានអំពើឃោរឃៅបែបនេះកើតមានឡើងក៏ដោយ។

យូស្សឺវបានរាយការណ៍ថា សុខុមាលភាពចិត្តសាស្ត្ររបស់ប្រជាជនក្នុងតំបន់ដែលវារកឃើញ គឺការធ្វើដំណើរជាលើកដំបូងរបស់ខ្ញុំ ទៅតំបន់ផូឌ្រីនជេ (Podrinje) ជាបទពិសោធន៍ពោរពេញដោយមនោសញ្ចេតនាសម្រាប់រូបខ្ញុំ ។ ខ្ញុំមានអារម្មណ៍អស់សង្ឃឹមនៅក្នុងពិភពលោកថ្មីនេះ ហើយវាហាក់បីដូចជាខ្ញុំក្លាយខ្លួនទៅជាជនសាសនាទូត(អ្នកផ្សាយសាសនា)។ នៅខណៈដែលខ្ញុំណែនាំកម្មវិធីឈើស ដល់អាជ្ញាធរស្បើបប្រចាំតំបន់ គេធ្វើហាក់បីដូចជាគេ ពុំឮឈ្មោះម៉ូស្លីមរបស់ខ្ញុំឡើយ។ គេព្រងើយកន្តើយ នឹងរូបខ្ញុំ ទោះបីជាការព្យាយាមយកកម្មវិធីសេដ្ឋកិច្ចមានប្រយោជន៍ ដែលគ្មានបញ្ហាវិវាទប្រដែងសិទ្ធិមនុស្ស ទៅក្នុងតំបន់ក៏ដោយ គាត់មានអារម្មណ៍ថាគាត់ជាជនសាសនាទូតមកពីពិភពក្រៅ ។ ផ្ទុយនឹងភាពព្រងើយកន្តើយ ដោយអាជ្ញាធរស្បើប យូស្សឺវ បញ្ចេញភាពគ្មានលាក់បាំងទៅលើភាពសម្របសម្រួល ៖

ការងាររបស់ខ្ញុំនៅក្នុងកម្មវិធីនេះ គឺផ្តល់ទីផ្សារដល់អ្នកផលិតឈើសនៅក្នុងតំបន់ ខ្ញុំខ្លាចប៉ុន្តែខ្ញុំក៏មានអារម្មណ៍ថាកិច្ចការរបស់ខ្ញុំ សំខាន់ៗសំរាប់ប្រជាជនទាំងនេះ។ នៅក្នុងចំណោមប្រជាជនស្បើបនៅក្នុងតំបន់ ខ្ញុំបានទទួលអារម្មណ៍ប្រឆាំង នឹងភាពមិនរាក់ទាក់របស់គេ។ តែខ្ញុំសំរេចទទួលយកជាកិត្តិយសពីជនគ្រប់រូបដោយពុំគិតពីពូជសាសន៍ឡើយ ខ្ញុំសំរេចបើកចំហចិត្តរបស់ខ្ញុំ ចំពោះជនគ្រប់រូប ហើយចាប់ផ្តើមប្រតិបត្តិកិច្ចការរបស់ខ្ញុំ។

នៅផ្នែកម្ខាងទៀតប្រជាជនរបស់យូស្សឺវ ម៉ូស្លីមបានទាមទារអោយគាត់ទទួលស្គាល់នូវអំពើឃោរឃៅដែលគេបានទទួលបទពិសោធន៍ ៖

- ប្រជាជនទទួលអារម្មណ៍អំពីភាពបើកចំហ និងសេចក្តីប្តេជ្ញារបស់ខ្ញុំ ទៅលើការងាររបស់ខ្ញុំ ។ ខ្ញុំបានយល់ថា ប្រជាជនទាំងនេះជាប្រជាជនសាមញ្ញ ឆ្លាត និងរឹងមាំ។ ខ្ញុំក៏យល់ថាជនជាតិបូស្សនាម៉ូស្លីមសម្គាល់ខ្លួនគេតាមតួនាទីជនរងគ្រោះ។ នៅគ្រាណា ដែលខ្ញុំចាប់ផ្តើមប្រកាន់ឥរិយាបថធម្មតាជាក់គេ គេរំឮកខ្ញុំអោយភ្ញាក់ស្មារតីឡើងថា គេជាជនរួចផុតពីអំពើសម្លាប់រង្គាល។

យូស្សឺវទទួលអារម្មណ៍ថា សតិអារម្មណ៍របស់ជនរងគ្រោះ ទាំងនេះបានបណ្តុះបណ្តាលឡើងដោយសមាគមសង្គ្រោះអន្តរជាតិ៖

- ប្រជាជននៅស្រែប្រីនីកាទាំងពីរជាតិសាសន៍មានការមន្ទិលសង្ស័យយ៉ាងខ្លាំង គេនឹងស្តាប់អ្នកដោយយកចិត្តទុកដាក់ហើយបន្ទាប់ពីអ្នកគិតថាគេទទួលគំនិតនោះ គេស្នើសុំវិភាគទានភ្លាម។ គេបានធ្វើការស្នើសុំជាច្រើនដង។ ខ្ញុំគិតថាប្រជាជនទាំងនេះ ជាពិសេសប្រជាជនបូស្សនាម៉ូស្លីម គេពឹងផ្អែកទៅលើជំនួយមនុស្សធម៌យ៉ាងខ្លាំង។ គេតែងតែសង្ឃឹមទៅលើវិភាគទាន។

នៅពេលដែលជនរួចផុតពីសេចក្តីស្លាប់ស្លាប់ស្នើសុំវិភាគទាន ចំនួន ប្រាំបួនឆ្នាំ បន្ទាប់ពីឥទ្ធិពលព្រឹត្តិការណ៍តក់ស្លុត វាជាសញ្ញាបំរាមថាដំណើរការព្យាបាលដោយខ្លួនឯងដែលទាក់ទង នឹងការងារ និងឥរិយាបថ បរទត្តភាព

(អោយប្រយោជន៍អ្នកដទៃជាងខ្លួន) អាចទន់ខ្សោយខ្លាំង។ សេចក្តីបដិសេធជាផ្លូវការ ទៅលើអំពើឃោរឃៅដែលបណ្តាលឡើងដោយផ្ទាល់ទៅលើស្ថានភាពនេះ ទុកបន្សល់នូវទីកន្លែងដែលកាន់ក្តាប់ ទៅដោយសេចក្តីភ័យខ្លាច ដល់ប្រជាជនទាំងអស់នៅស្រេប្រីនីកា ៖

ស្រេប្រីនីកាបានជួបប្រទះ និងភាពមហន្តរាយយ៉ាងខ្លាំងក្លា ផ្លូវបាក់បែកខ្លាំង ហើយនៅរដូវត្រជាក់ផ្លូវនោះត្រូវបិទលែងអោយប្រើទាំងអស់។ នៅក្នុងភូមិគ្មានទឹកអនាម័យប្រើប្រាស់នៅក្នុងរដូវក្តៅ ភូមិនេះបានទទួលភាពព្រងើយកន្តើយខ្លាំង តែខ្ញុំមានអារម្មណ៍ថាអ្វីៗ ដែលភូមិនេះត្រូវការ គឺមនុស្ស។ ភូមិនេះគ្មានវេជ្ជបណ្ឌិត វិស្វករ គ្រូបង្រៀន និង បញ្ញវ័ន្ត។ មុនសង្គ្រាមស្រេប្រីនីកាជាភូមិពោពេញដោយវិវឌ្ឍភាព ប្រជាជនមានចំនេះដឹង។ បច្ចុប្បន្ននេះ អ្នកមានចំនេះដឹងទាំងនោះ ពុំត្រឡប់មកវិញឡើយ។ គេខ្លាចសន្តិភាពមិនរឹងមាំ ហើយគេត្រូវរត់ភាសខ្លួនឆ្លងកាត់ទួលទាំងនោះជាថ្មីម្តងទៀត ។ ខ្ញុំគិតថាជនមានចំនេះវិជ្ជាទាំងនោះ ភ័យខ្លាចអំពីអាយុជីវិតរបស់គេ និងអនាគតកូនចៅរបស់គេ គេពុំចង់ត្រឡប់មកវិញទេ ។ គេបាននិយាយឡើងថាប្រាក់បៀវត្ស នៅស្រេប្រីនីកាមានកំរិតតិចពេក នេះជាកត្តាពិតតែបើតាមយោបល់របស់ខ្ញុំ សេចក្តីភ័យខ្លាចជាឧបសគ្គចំបងគេ ដែលរារាំងជនមានចំនេះវិជ្ជាទាំងនោះមិនអោយត្រឡប់មកវិញ។

សូម្បីតែសព្វថ្ងៃនេះ សេចក្តីភ័យខ្លាចនៅស្រេប្រីនីកាជាភាពពិតប្រាកដ ដែលពង្រីកកាន់តែច្បាស់ឡើងដោយសារមន្ទីរ និងផ្នូរសព។ អារម្មណ៍បន្សល់ទុកអោយនៅតែនឹកឃើញ ជាអចិន្ត្រៃយ៍ទៅលើអំពើសម្លាប់រង្គាលប្រល័យពូជ ។ ប្រជាជនស៊ែប្ប និងម៉ូស្លីមដែលនៅសេសសល់ភ័យខ្លាច នឹងការប្តេជ្ញាទៅលើអនាគតរវាងគ្នាឯងទៅវិញទៅមក។ ជាលទ្ធផល គឺគេគ្មានអនាគតសំរាប់កូនចៅរបស់គេឡើយ ផ្ទុយទៅវិញជីវិតនៅស្រេប្រីនីកានៅតែរក្សាភាពគ្មានរីករាយ និងប្រឆាំងភាគី គ្មានហាងលក់កាហ្វេ ហាងទំនិញឧទ្យាន និងទីធ្លាកំសាន្ត ដែលពោរពេញទៅដោយមនុស្សចាស់ និងក្មេងដែលជាទិដ្ឋភាពក្នុងភូមិផ្សេងៗទៀតនៅបូស្សនា។ ដូចជាយូស៊ីបានធ្វើការសង្ខេបឡើងទៅលើស្ថានភាពនោះថា "ខ្ញុំមានអារម្មណ៍ថា សង្គមស្រេប្រីនីកានៅតែមានជម្ងឺជាប្រចាំ " ។

## ១.៨ ការព្យាបាលក្នុងសតវត្សទីម្ភៃមួយ

សូមនឹកគិតទៅលើកម្រងរឿង សមត្ថភាពព្យាបាលដោយខ្លួនឯង របស់បុគ្គលម្នាក់ដែលបានដាក់ជាថាមពលទៅលើឥទ្ធិពលសំខាន់ៗនៅក្នុងសង្គម។ ការចូលរួមចំណែកជាមួយគ្នារបស់ប្រជាជនតក់ស្លុតអាចជាភាពអស្ចារ្យ ។ សហការរួមគ្នាថ្មីអាចបង្កើតឡើងរវាងជនទទួលសេចក្តីឈឺចាប់ដោយភាពតក់ស្លុត និងសង្គមសេចក្តីសង្ឃឹមសំរាប់ជនដែលនៅសេសសល់ផុតពីសេចក្តីស្លាប់ថាគេ អាចទទួលយកសេចក្តីស្វាគមន៍ ដូចគ្នានឹង (Philoctetes) ជាបុគ្គលម្នាក់ដែលជនជាតិក្រិចបានជួយសង្គ្រោះពីភាពបោះបង់ចោលនៅកោះ លីមណូស (Lemnos) ហើយបានត្រឡប់មកជួយនៅក្នុងសង្គ្រាមត្រូជាន (Trojan)។

នៅពេលដែលអំពើមហាសាហាវយង់ឃ្នងកើតឡើង ភាពខូចខាតកើតមានដល់មិនត្រឹមតែបុគ្គលម្នាក់វាកើតឡើងដល់សង្គមទាំងស្រុង ពិតប្រាកដជាមានដល់ទូទាំងពិភពលោក។ ជនរងគ្រោះនៅថ្ងៃទី១១ ខែ កញ្ញា

ក្រុមគ្រួសារ និងមិត្តភក្តិរបស់គេទទួលសេចក្តីឈឺចាប់ភាពបាត់បង់ដ៏រន្ធត់ សូម្បីតែយើងគ្រប់គ្នាដែលមើលការបញ្ចាំងរូបភាពថតទៅតាមកញ្ចក់ទូរទស្សន៍ក៏ទទួលការឈឺចាប់ផងដែរ យើងក៏ទទួលបានបទពិសោធន៍ទុក្ខកង្វល់ ថប់អារម្មណ៍បាត់បង់ជំនឿទៅលើ ផ្នែកមនុស្សធម៌ ភាពយល់ចិត្តលើសលប់ ឬភាពដកអារម្មណ៍លែងខ្វល់ទៀត។ ជាលទ្ធផលសេចក្តីព្យាបាលត្រូវតែកើតមានឡើងមិនត្រឹមតែសំរាប់បុគ្គលម្នាក់ទេ តែសំរាប់សង្គមទាំងមូល ដោយចាត់ទុកសង្គមជាភ្នាក់ងារព្យាបាល។ ជនរងទុក្ខដោយភាពតក់ស្លុតត្រូវការជំនួយពីសង្គមនៅក្នុងដំណើរការព្យាបាលដោយខ្លួនឯង ហើយជាសេចក្តីតបស្នង គេនឹងជួយសង្គមអោយភាពជាសះស្បើយដោយគេចែកចាយរឿង បទពិសោធន៍ និងគតិបណ្ឌិតរបស់ខ្លួនគេទៅដល់សង្គមវិញ។ ភាពព្យាបាលផ្ទាល់ខ្លួន និងសង្គមជាសាមគ្គីភាពទៅវិញទៅមក និងជាទំនាក់ទនងដែលមានសារៈប្រយោជន៍ទាំងសងខាង ។ តាមរយៈដំណើរការព្យាបាលដោយខ្លួនឯងដែលជនម្នាក់ៗធ្វើឡើង ដែលរួចផុតពីសេចក្តីស្លាប់អាចបង្រៀនយើងទាំងអស់គ្នាអំពីវិធីភាពជាសះស្បើយដោយរបួសនៅក្នុងពិភពឃោរឃៅ។

ភាពផ្លាស់ប្តូរទម្រង់មូលដ្ឋាន នៅក្នុងទស្សនៈសង្គមទៅលើជនជួបប្រទះភាពតក់ស្លុត ត្រូវតែចាប់ផ្តើមឡើងដោយជនរួចផុតពីសេចក្តីស្លាប់ផ្ទាល់ តាមរយៈការនិយាយចែកចាយរឿងរបស់គេ ។ ទន្ទឹម នឹងនេះការបញ្ចេញរឿងតក់ស្លុតទាំងអស់ ពុំត្រឹមតែភាពពិតនៃអំពើយង់ឃ្នង តែវាត្រូវការសេចក្តីក្លាហ៊ានមួយចំណែករបស់ជនរួចផុតពីសេចក្តីស្លាប់ ជាពិសេសនៅក្នុងសង្គម និងសហគមន៍ដែលអំពើសាហាវយង់ឃ្នងកើតមានឡើងជាទូទៅ។ ភាពអាម៉ាស់មុខ និងភាពខ្មាស់អៀនដែលមិនអាចជៀសផុត រួមផ្សំទៅដោយរបួសកាយសម្បទា និងសតិអារម្មណ៍។ ចំណង់របស់ជនរួចផុតពីសេចក្តីស្លាប់ក្នុងការនិយាយអោយគេដឹង គឺយោងទៅតាមជំនឿរបស់គេថាគេអាចផ្លាស់ប្តូរអារម្មណ៍អាក្រក់ដែលបានដាក់បណ្តុះបណ្តាលនៅក្នុងស្មារតីរបស់គេ ដោយអំពើសាហាវយង់ឃ្នង។ ដើម្បី នឹងធ្វើអោយដំណើរការព្យាបាលដោយខ្លួនឯងមានភាពធម្មតា ជនជួបប្រទះភាពតក់ស្លុតត្រូវនិយាយចែកចាយរឿងរបស់គេជាក្រុម ឬជាមួយ នឹងជនដែលមានឋានៈស្មើគ្នាក្នុងមជ្ឈដ្ឋានដែលមានភាពសន្តិសុខ យ៉ាងពេញលេញ ហើយនៅក្នុងស្ថានភាព ផ្នែកនយោបាយជាលក្ខណៈមានគ្រោះថ្នាក់ជាទីបំផុត ។ ភាពផ្លាស់ប្តូរគំនិតសម្ងាត់ផ្ទាល់ខ្លួនទៅជាការនិយាយថ្លែងជាសាធារណៈ ត្រូវអោយមានសេចក្តីបំភ្លឺគំនិត សេចក្តីគាំទ្រជាក្រុម និងវិធីដោះស្រាយបញ្ហាដោយប្រសិទ្ធិភាព។ ការនិយាយអោយគេដឹងទៅលើអនុភាពអំពើឃោរឃៅនៅក្នុងសង្គម និងសហគមន៍ផ្សេងៗទៀត អាចមានភាពងាយស្រួលជាងការនិយាយនៅក្នុងសង្គម និងសហគមន៍របស់ខ្លួន ដោយវាជាភាពលំបាកក្នុងការពិភាក្សាអំពើរំលោភបំពានប្រឆាំងនៅក្នុងតំបន់។ នេះជាភាពជាក់ស្តែងនៅក្នុងភាពញញើតញញើមរបស់អាមេរិកកាំង ទាំងអតីតកាលទាំងបច្ចុប្បន្នកាល ក្នុងការដោះស្រាយផលវិបាកចិត្តសាស្ត្រទៅលើព្រឹត្តិការណ៍ ចំនួនពីរសំខាន់ៗបំផុត ទៅក្នុងប្រវត្តិសាស្ត្រប្រទេសយើង ៖ ភាពបោសសំអាតបំបាត់ពូជសាសន៍ជនជាតិដើមអាមេរិកកាំង និងភាពបង្កើតទាសភាព (ខ្ញុំកញ្ជះ)។

ជនរួចផុតពីសេចក្តីស្លាប់ ដោយភាពតក់ស្លុតអាចផ្លាស់ប្តូរសង្គម និងឧបសគ្គវប្បធម៌ ទៅកាន់ភាពព្យាបាលដោយខ្លួនឯង ដោយធ្វើវាអោយទៅជាគំនិតពោរពេញដោយអត្ថន័យនៅក្នុង ពាក្យរបស់យើង។ នាយទា

ហ៊ានដើងចាស់ដែលប្រយុទ្ធក្នុងសង្គ្រាមប្រទេសវៀតណាមបានបើកបង្ហាញផ្លូវនៅក្នុងថ្ងៃនេះ ដោយបង្រៀនពិភពលោក អំពីភាពតានតឹងអារម្មណ៍បន្ទាប់ពីភាពស្លុតបាក់ស្បាត (PTSD) ដែលបានក្លាយទៅជាការយល់ដឹងទាំងសកលលោកថា ជាការប្រមាណមើលពិតទៅលើភាពខូចខាតចិត្តសាស្ត្រ ដែលកើតមានឡើងដល់ទាហ៊ានដែលចូលរួមប្រយុទ្ធនៅក្នុងសង្គ្រាមលះបង់ជីវិត។ ការប្រើពាក្យនេះ នៅបច្ចុប្បន្នកាល ក្លាយទៅជាវិធីអនុវត្តន៍ការពារ និងព្យាបាលលក្ខណៈរោគនេះ។ នៅក្នុងសង្គ្រាមលោកលើកទីI ពាក្យថ្មី *រន្ធត់ដល់សំបកខាងក្រៅ* បាននាំមកនូវភាពអាណិតអាសូរទៅលើទ័ពទាហ៊ាន ដែលទទួលភាពទោរទន់អារម្មណ៍ នៅពេលដែលគេកំពុងតែវាយប្រយុទ្ធ។ មានភាពដូចគ្នា នឹងស្ត្រីភេទដែលបានបរិយាយថា គេជាជនរងគ្រោះដោយអំពើហឹង្សាដែរ មនុស្សអាចជួយគ្នាទៅវិញទៅមកបានច្រើន ដោយគ្មានបរិយាយជាបែបបទមើលងាយ។ ពាក្យព្យាបាលដោយខ្លួនឯងដែលទាក់ទងទៅ នឹងអំពើសាហាវឃោរឃៅត្រូវតែដាក់ចូលទៅក្នុងការសន្ទនាជាសាធារណៈ។

ការសិក្សាស្រាវជ្រាវក៏ត្រូវតែបំពេញតួនាទីដ៏សំខាន់ៗនៅក្នុងគម្រោងសម័យណាមួយ ដើម្បីផ្សព្វផ្សាយភាពព្យាបាលដោយខ្លួនឯង បន្ទាប់ពីព្រឹត្តិការណ៍តក់ស្លុតក្នុងជីវិត ។ ផ្នែកស៊ើបអង្កេតវិទ្យាសាស្ត្រពេលនេះ គេបានយកចិត្តទុកដាក់ទៅលើរោគា និងភាពលំអិតទៅលើផលវិបាកព្រឹត្តិការណ៍តក់ស្លុត។ នៅខណៈដែលព្រឹត្តិការណ៍តក់ស្លុតកើតមានឡើង អ្នកវិទ្យាសាស្ត្រ ចង់ដឹងអំពីអានុភាពរោគសាស្ត្រដែលកើតមាន ជាបន្ទាប់មកនៅកម្រិតជីវសាស្ត្រ និងសង្គមសាស្ត្រ ។ សេចក្តីណែនាំដ៏សំខាន់ៗ ត្រូវតែធ្វើឡើង ដូចគ្នាទៅ នឹងការអនុវត្តន៍ នៅក្នុងឆ្នាំ ១៩៥០ ទៅលើវិជ្ជាវិកលចរឹតក្រឡាប់ចាក់អោយបោះបង់ចោលមធ្យោបាយដាក់ទណ្ឌកម្មដល់ជនមានរោគវិកលចរឹត ។ ជាកត្តាពិតជនជួបប្រទះភាពតក់ស្លុតពិតជាមិនងាយទ្រុឌទ្រោមក្រៃលែង ហើយគេអាចរកវិធីដោះស្រាយជាញឹកញាប់ទៅ នឹងស្ថានភាពដែលពុំអាចយល់បាន ។ ផ្ទុយនឹងសេចក្តីយកចិត្តទុកដាក់ទៅលើរោគសាស្ត្រ និងរោគារបស់ជនរួចផុតពីសេចក្តីស្លាប់ យើងគួរគប្បីពិនិត្យទៅលើមធ្យោបាយរួចផុតពីសេចក្តីស្លាប់ និងមធ្យោបាយព្យាបាលដោយខ្លួនឯងរបស់អ្នកទាំងនោះ ។ ករណីនេះត្រូវពឹងផ្អែកទៅលើសេចក្តី តស៊ូផ្នែកវិទ្យាសាស្ត្រ និងសុខុមាលភាព ។

អ្នកវិជ្ជាជីវៈ និងអ្នកស្ម័គ្រចិត្តដែលយកចិត្តទុកដាក់ទៅលើជនជួបប្រទះភាពតក់ស្លុត ក៏ត្រូវតែធ្វើការប្រមាណមើលថា សេចក្តីព្យាយាមរបស់គេពិតជាជួយប្រាកដមែន ។ បន្ទាប់ពីភាពមហន្តរាយថ្មីរាល់លើក ជនដែលមានចិត្តមេត្តាធម៌ និងបំណងល្អរកវិធីជួយអ្នកឯទៀតយ៉ាងសកម្ម ។ ប៉ុន្តែវាជាភាពកម្រមានដែលផលវិបាក នៃសេចក្តីព្យាយាមមនុស្សធម៌នេះ បានទទួលការប្រមាណមើល។ វាជាការប៉ាន់ស្មានថា អន្តរាគមន៍ ផ្នែកចិត្តសាស្ត្រ និងសង្គមសាស្ត្រអាចយ៉ាងច្រើនជួយបានខ្លះ និងយ៉ាងអន់បំផុតមិនផ្តល់នូវផលវិបាកអ្វីមួយ ឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ភាពសាកល្បងណែនាំខុសបែបបទជំនួយចិត្តសាស្ត្រ អាចក្លាយទៅជាភាពមហន្តរាយ ដែលបង្អាក់ដំណើរភាពព្យាបាលដោយខ្លួនឯងហើយបង្កើតជម្ងឺ និងរោគាពិត។ វាជាការចាំបាច់ដែលជំនួយទាំងអស់ត្រូវតែធ្វើការប្រមាណមើលទៅលើអានុភាពខ្លាំងក្លា ឬភាពប៉ះទង្គិចដែលធ្វើអោយខូចខាតដល់បុគ្គល និងសហគមន៍ ។ គ្មានជនគ្រប់រូបទាំងអស់ដែលទទួលរងរបួសដោយអំពើឃោរឃៅ ចង់បានជំនួយជាបែបបទ

គ្មានចាប់អារម្មន៍ទៅលើវប្បធម៌ ឬការបង្អាក់សមត្ថភាពព្យាបាលខ្លួនឯងជាធម្មជាតិរបស់គេឡើយ។ ឧទាហរណ៍ ជនជួបប្រទះភាពតក់ស្លុតសម្តែងសេចក្តីឈឺចាប់ក្នុងចិត្តទៅលើការប៉ាន់ស្មាន ជាស្វ័យប្រវត្តិថា ប្រវត្តិរឿងឃោរឃៅរបស់គេ តម្រូវអោយគេទទួលការព្យាបាលដើម្បីអោយរូបគេក្លាយទៅជាធម្មតាវិញ។

ការដាក់អោយជនជួបប្រទះភាពតក់ស្លុត ចូលរួមនៅក្នុងភាពជាសះស្បើយ ត្រូវចាត់ទុកជាអានុភាពគតិបណ្ឌិត ដែលត្រូវគ្រង់គ្រាប់តាមសំរាប់ភាពជាសះស្បើយក្នុងសង្គម ។ នៅក្នុងឆ្នាំ ២០០៣ ខ្ញុំបានទៅទស្សនាមន្ទីរពេទ្យព្យាបាលនៅជាយក្រុងលីម៉ា (Lima) ប្រទេសភីរ៉ូ (Peru) ដើម្បីការហ្វឹកហ្វឺន អ្នកវិជ្ជាជីវៈពេទ្យ ក្នុងតំបន់អំពីសុខភាពសតិអារម្មណ៍របស់អ្នកជម្ងឺ ដែលបានទទួលទារុណកម្មពីទ័ពឈ្លបបិទមុខ ។ មន្ទីរពេទ្យព្យាបាល ស្ថិតនៅទីក្រុង ឈ្មោះស្សានធី (Shanty Town) ដែលមានប្រជាជន ចំនួន ១៨0,000 នាក់ ភាគច្រើនជាជនជាតិឥណ្ឌា ដែលបានរត់គៀសខ្លួនចេញពីអំពើសាហាវយង់ឃ្នង អែនឌី( Andes) និងបានមករកការងារធ្វើនៅលីម៉ា។ ទីក្រុងនេះមានទិដ្ឋភាពដែលធ្វើអោយនឹកឃើញដល់ជុំរុំសាយធូ នៅទីនោះខ្ទមឈើរាប់ពាន់បានសាងសង់ឡើងនៅលើទេសភាពដែលមើលទៅហាក់បីដូចជា មុខព្រះច័ន្ទផុសឡើង ដោយមានមាត់ភ្នំភ្លើងនិងទួលរលីងគ្មានព្រៃទាល់តែសោះ ។ គ្មានឧទ្យាន រុក្ខជាតិ អគ្គីសនី ឬទឹកម៉ាស៊ីនឡើយ ។ លូទឹកស្អុយហូរចាក់ទៅលើផ្លូវលំ ។ មនុស្សពេញវ័យ គ្មានយកចិត្តទុកដាក់ទៅលើដីភក់នោះឡើយ ខ្ញុំបានសួរវេជ្ជបណ្ឌិត នៅមន្ទីរពេទ្យព្យាបាលថា ហេតុអ្វីបានជាគេមិនប្រមូលនាំយុវវ័យខ្ជិលច្រអូសទាំងនេះទៅកសាងលូទឹកស្អុយ ដើម្បីធ្វើអោយស្ថានភាពសង្គមបានប្រសើរឡើង? គ្មាននណារម្នាក់មានចម្លើយឡើយ។

ប្រហែលគ្នាដែរ នៅពិតពម្ខាងទៀតក្នុងខេត្តអាសេហ Aceh ប្រទេសឥណ្ឌូណេស៊ី ចំនួន១២ សប្តាហ៍ក្រោយពីមហាព្យុះសមុទ្រ ដែលបានសម្លាប់មនុស្សរាប់ រយពាន់ នាក់ ហើយបានបំផ្លាញផ្លូវ ផ្ទះ និងស្ពាន មនុស្សពេញវ័យ និងក្មេងជំទង់បានទុកនៅចោលដោយគ្មានអ្វីធ្វើ។ ថ្វីបើជំនួយអន្តរជាតិ និងទឹកប្រាក់ច្រើនមហិមាបានផ្តល់ឡើង គេពុំយកយុវវ័យជួបប្រទះភាពតក់ស្លុតទាំងនេះ អោយមកបំរើសេវាសហគមន៍ ដែលមានសារៈសំខាន់។ ភាពខ្វះសមត្ថភាពដាក់មនុស្សទាំងនេះអោយចូលរួមនៅក្នុងការកសាងអនាគតថ្មីរបស់គេឡើងវិញ ជាភាពគ្មានមនសិការ ។

ភាពសម្រួលបែបបទរឿងតក់ស្លុតពេញលេញ ទ្រង់ទ្រាយមួយដែលគួរអោយរំភើបជាងគេ នៅក្នុងភាពព្យាបាលដោយខ្លួនឯង នៅក្នុងការសន្ទនាជាបែបបទសង្គម ជាគោលដៅសំខាន់មួយទៀត សម្រាប់ភាពជាសះស្បើយ តែវាអាចជាការប្រកួតប្រឆាំងដ៏អស្ចារ្យ។ នៅក្នុងសង្គមសម័យ កម្រមានឱកាសសម្រាប់អោយមនុស្សដែលបានទទួលបទពិសោធន៍អំពើឃោរឃៅ និយាយរៀបរាប់រឿងរបស់គេ ដូចជាឪពុករបស់ខ្ញុំបានធ្វើឡើង គាត់អង្គុយនៅចំកណ្តាលក្នុងចំណោមក្រុមគ្រួសារដែលមកជួបជុំគ្នា នៅក្នុងសហគមន៍អ៊ីតាលីតូចមួយ គាត់បង្រៀនក្មេងៗ ជំនាន់ក្រោយតាមរយៈ ការនិយាយប្រវត្តិសាស្ត្រផ្ទាល់មាត់អំពីបទពិសោធន៍ដំណើរជីវិតពិត។ ល្បែងវីឌីអូ និងរឿងភាពយន្តហាក់បីដូចជាមានភាពរំភើបច្រើនជាងការនិទានរឿងដោយយឺតៗ នេះ ។

ទន្ទឹមនឹងនេះដែរ រឿងតក់ស្លុតនៅតែមានជារចនាសម្ព័ន្ធ ប្រកបដោយសោភ័ណភាពដ៏អស្ចារ្យដែលបង្កប់នៅក្នុងវប្បធម៌ចម្រុះ និងមជ្ឈដ្ឋានសង្គមរបស់យើង។ ទោះបីជាមានការបកស្រាយខុស និងការយកចំណេញជាអាជីវកម្ម ដោយផ្នែកសារព័ត៌មាន និងផ្នែកផ្សេងៗទៀត អំពីបទពិសោធន៍ជីវិតតក់ស្លុត រឿងផ្ទាល់ខ្លួនរបស់មិត្តភក្តិយើង និងក្រុមគ្រួសារយើងនៅតែមានអានុភាពជានិច្ច។ សារព័ត៌មាន និងផ្នែកកំសាន្តអារម្មណ៍ ជាពិសេសនៅប្រទេសអាមេរិកដែលរួមទៅដោយមហាអំណាច និងភាពបញ្ចុះបញ្ចូល ត្រូវការចូលរួមទៅក្នុងផ្នែកវិភាគខ្លួនថាតើហេតុអ្វីបានជាខ្លួនបរាជ័យក្នុងបង្ហាញរូបភាពពិត នៃអំពើឃោរឃៅ ក៏ដូចជាការផ្សាយជាសាធារណៈអំពីបទពិសោធន៍ព្យាបាលរបស់ជនជួបប្រទះភាពតក់ស្លុត និងអ្នកជំនួយវិជ្ជាជីវៈ ។ ទស្សនៈដែលផ្សព្វផ្សាយដោយជោគជ័យថា រឿងភាពព្យាបាល និងភាពជាសះស្បើយ នឹងមិននាំមកនូវ សេចក្តីយកចិត្តទុកដាក់គ្រប់គ្រាន់ដល់ទូទាំងប្រទេសជាតិឡើយ ហេតុដូច្នេះហើយ វាជាភាពគ្មានចំណេញ ទស្សនៈនេះអាចជាគំនិតពុំត្រឹមត្រូវ ហើយគ្មានទិន្នន័យ ដើម្បីគាំទ្រអំពីការព្យាបាលដោយខ្លួនទៅតាមការនិទានរឿង។

នៅពេលខ្លះស្មារតីដែលជាប់កង្វល់ ទៅលើវប្បធម៌ រួមទៅដោយរូបភាពអំពើឃោរឃៅដែលបង្ហាញយ៉ាងក្រឡែតទៅជាបែបបទនិពន្ធចិត្តសាស្ត្រ ។ ដូចជា អ្នករាយការណ៍ម្នាក់បានបរិយាយជាសារព័ត៌មាន នៅក្នុងទូរទស្សន៍ថា ″ ទីណាមានឈាមហូរ ទីនោះមានរឿងដែលត្រូវរាយការណ៍ ‶ទន្ទឹមនឹងនេះ សង្គមបានបញ្ឆោតខ្លួនឯង ដោយយករូបភាពថោកទាបដែលជាសេចក្តីឈឺចាប់របស់ប្រជាជនមកផ្សព្វផ្សាយ ។ ផ្នែកសារព័ត៌មាន ត្រូវតែជម្រុញអោយបង្ហាញរឿងតក់ស្លុតពេញលេញ ពុំត្រឹមតែភេរវកម្ម តែប៉ុណ្ណោះទេ ។ ឱកាសសំរាប់ផលិតរឿងច្នៃប្រឌិតសំរាប់បញ្ចាំងក្នុងទូរទស្សន៍ និងផ្សាយតាមវិទ្យុ ដែលបង្ហាញអំពីភាពស្មុគស្មាញទៅលើភាពផ្លាស់ប្តូរពិតពរបស់ជនជួបប្រទះភាពតក់ស្លុតជាភាពគ្មានកំនត់ ។ នៅប្រទេសភីរ៉ូ មនុស្សចំនួន ជាងហុកសិបពាន់នាក់ ត្រូវទ័ពឈ្លបសម្លាប់ចោល នៅក្នុងករណីខ្លះអំពើសម្លាប់ទាំងនេះបានធ្វើឡើងដោយភ្នាក់ងារ អតីត រដ្ឋាភិបាល ។ ទូរទស្សន៍សាធារណៈ ក្រោយមកបានបញ្ចាំងរឿងការបរិយាយឡើងដោយបុគ្គលម្នាក់ និងក្រុមគ្រួសារដែលបានធ្លើយជាកសិណសាក្សី ទៅចំពោះមុខគណៈកម្មការ សច្ចៈ និងសម្របសម្រួល ដែលពុំត្រឹមតែបង្ហាញកម្រិតមហាព្រៃផ្សៃ ដែលបានប្រព្រឹត្តឡើងនោះទេតែអ្វីៗ ដែលសំខាន់ជាងនេះទៅទៀត សេចក្តីជោគជ័យ ក្នុងការផ្តល់ពន្លឺផ្ទៃក្នុងទៅលើស្ថានភាពជាសាធារណៈ អំពីភាពផ្លាស់ប្តូរជីវិតដែលបានខូចខាតដោយអំពើសាហាវយង់ឃ្នង ។

ទូរទស្សន៍សំរាប់សហគមន៍ វិទ្យុ និងប្រព័ន្ធអ៊ីនធ័រណេតអាចបង្កើតមជ្ឈដ្ឋានរុងរឿងសំរាប់ការនិទានរឿង និងការសន្ទនា។ រឿងចម្រុះអាចចែកចាយនៅក្នុងសហគមន៍ចម្រុះ ភាពច្នៃប្រឌិតជាច្រើនបែប និងឯកសារមូលដ្ឋានជាតិ ប្រវត្តិផ្ទាល់មាត់ អាចប្រមូលរឿងនិទានតក់ស្លុតរបស់ជនរួចផុតពីសេចក្តីស្លាប់ អំពីភាពវិនាសមហន្តរាយ ដូចជា ព្រឹត្តិការណ៍ថ្ងៃទី១១ ខែ កញ្ញា ប្រទេសទីម័រប៉ូព៌ា ស្រេប្រីនីកា និងរ៉្វាន់ដា។ ប្រទេសនានាអាចបញ្ជូនអ្នកជំនាញ ផ្នែកមនុស្សវិទ្យា និងអ្នកជំនាញ ផ្នែកជាតិពណ៌នាអោយចុះទៅដល់ទីកន្លែងកើតហេតុ ដើម្បីប្រមូលការនិទានរឿងរបស់ជនជួបប្រទះភាពតក់ស្លុត និងសហគមន៍ ។អ្នកជំនាញផ្នែកភ្លេង និងអ្នកថតរូប អាចថតកត់ត្រាប្រវត្តិសាស្ត្រសង្គម និងសម្ភារៈ ។ តូបថតឯកសារ ដូចជាមាននៅទីក្រុងនីវយកអាចដាក់ទៅកន្លែងសំខាន់ៗ

ជាសាធារណៈ  ដើម្បីដកស្រង់អត្ថន័យ  ដោយគ្មានគ្រោងទុកអំពីប្រវត្តិដំណើរជីវិតរបស់ប្រជាជន  ទៅខណៈដែលគេកំពុងតែពុះពារធ្វើអោយជីវិតគេមានភាពធម្មតាឡើងវិញ។

សិល្បៈគំនូរជានិមិត្តសញ្ញាដែលមានទិដ្ឋភាពពិតជាងគេ  ក្នុងការបង្ហាញសោកនាដកម្ម  របស់មនុស្សលោក ដោយបែបបទបញ្ចេញអាការៈមានភាពដូចគ្នា និងរូបភាពដែលកើតឡើងនៅក្នុងដំណើរការនិទាន  រឿង ។ ខ្សែភាពយន្តសម័យ ការសម្តែង ផ្ទាំងគំនូរ និងរូបចម្លាក់អាចជួយបុគ្គល និងសង្គមក្នុងការពុះពារភាពប៉ះទង្គិចអាក្រក់ដោយហឹង្សារបស់មនុស្ស ។ និមិត្តរូបផ្ទាំងគំនូរ *Guernica* (ទិដ្ឋភាពទំលាក់គ្រាប់បែកនៅ Guernica) របស់ពីកាសូ( Picasso) នៅក្នុងសង្គ្រាមស៊ីវិលជនជាតិស្ពេនីស បានពិពណ៌នាអានុភាពអំពើមហាសាហាវ នៅក្រោមការដឹកនាំរបស់ ឧត្តមសេនីយអគ្គបញ្ជាការហ្វ្រាន់ស៊ីស្កូ ហ្វ្រង់កូ(Francisco Franco)ផ្ទាំងគំនូរនេះបានដាក់តាំងនៅសារមន្ទីរសិល្បៈបច្ចុប្បន្នសម័យ  នៅទីក្រុងនីវយក  រហូតទាល់តែដល់ឆ្នាំ១៩៨១  ហើយគេក៏បានបញ្ជូនទៅប្រទេសស្ពេន (Spain) ដែលបណ្តុះគំនិតព្យាយាមដល់មនុស្សជំនាន់ទាំងអស់អោយធ្វើការទប់ស្កាត់អំពើបំផ្លាញនុយក្លេអ៊ែ (Nuclear) នៅក្នុងសង្គ្រាមគ្មានមេត្តាធម៌នេះ ទន្ទឹមនឹងនេះប្រជាជនពុំត្រូវការសារមន្ទីរដ៏អស្ចារ្យ  ដើម្បីរកឃើញភាពព្យាបាលដែលជាទំនៀមទម្លាប់របស់គេនោះឡើយ  សមាគមន៍នីមួយៗ  មានគំនូរសិល្បៈប្រចាំតំបន់ដែលអាចបញ្ជាក់ច្បាស់លាស់ ទៅលើទស្សនៈវិស័យអំពើសាហាវយង់ឃ្នង។

មូលនិធិរបស់លោក ភីតទ័រ អាល់ឌ័រម៉ិន(Peter c. Alderman) បានបង្កើតដោយមាតាបិតាដែលកូនប្រុសរបស់គេបានស្លាប់នៅក្នុងភេរវកម្មវាយប្រហារអគារភ្លោះ  ដោយគេប៉ងស្ថាបនាទុកជាឯកសារផ្តោតទៅលើភាពជាសះស្បើយនៅជិតទីលានអោយសាបសូន្យ ។ ស្ថាប័ននេះជាចំនែកមួយផ្នែកនៃទស្សនៈរបស់យើង ដែលនឹងប្រមូលផ្តុំហើយដាក់ជាសាធារណៈ ជាការតាំងពិពណ៌រឿងនិទានអំពីភាពព្យាបាលដោយខ្លួនឯង និងភាពរួចផុតពីសេចក្តីស្លាប់របស់ជនជួបប្រទះភាពតក់ស្លុត អ្នកវិជ្ជាជីវៈពេទ្យ និងគ្រូបុរាណទូទាំងសកលលោក។

គណៈកម្មការសាធារណៈ ផ្នែកសិល្បៈគំនូរអាចផ្តល់ពន្លឺប្រាជ្ញារឹតតែច្បាស់ជាងនេះ ទៅលើវប្បធម៌ និងសង្គមអ៊ីតាលីកំពុងតែរចនា "ទីឈប់ទស្សនាសិល្បៈរចនា" Art Stop នៅប្រទេសរ៉ូមដែរ នឹងមានរួមទៅដោយ  រ៉ូម៉ងជំនាន់ដើម ប្រវត្តិសាស្រ្តអ៊ឺរ៉ុបសតវត្សទី១៤ ដល់១៦ និងសិល្បៈគំនូរបច្ចុប្បន្នសម័យ ដែលនឹងបកស្រាយប្រាប់យើងអំពីការឆ្លើយតបរបស់មនុស្សទៅលើអំពើហឹង្សា។ "ទីឈប់ទស្សនាសិល្បៈរចនា" ជារមណីយដ្ឋានដើរកំសាន្តដោយខ្លួនឯង មានដូចជាស្ពានកីឡា និងសិល្បៈអរិយធម៌ជំនាន់ដើម នៃអំពើធ្វើទារុណកម្ម និងភាពព្រៃផ្សៃ ភាពប្តូរទ្រង់ទ្រាយរបស់ Raphel គំនូររូបភាពបែបបទអ៊ីតាលីរបស់លោក Tomba Francoi ដែលដាក់តាំង (និងហាមជំទាស់) ភាពអន្តរាយទាំងសងខាងនៅក្នុងទីក្រុង និងស្រុកក្នុងអរិយធម៌អ៊ីតាលីជំនាន់ដើម។ នៅទីឈប់ទស្សនានីមួយៗ មានចំណារជាលាយល័ក្ខអក្សរអំពីប្រវត្តិសាស្រ្ត និងប្រហែលជាមានកាសែតអាត់សម្លេងបញ្ជាក់អំពីសិល្បៈដែលទាក់ទង នឹងភាពរួចផុតពីសេចក្តីស្លាប់ និងភាពព្យាបាលដោយខ្លួនឯង នៃអំពើសាហាវយង់ឃ្នងនៅក្នុងពិភពបច្ចុប្បន្នកាល។ សហគមន៍ផ្សេងៗទៀត អាចបង្កើតទីកន្លែងដូចគ្នានេះ អំពីការ សញ្ជឹងគិត

ជាបែបវិចិត្រសិល្បៈ ដែលនាំមកនូវការសន្ទនារវាងសាធារណៈ និងឯកជនទៅលើភាពជាសះស្បើយដោយអំពើឃោរឃៅ។

ដូចគ្នាផងដែរ សិល្បៈប្រចាំតំបន់អាចបញ្ចូលទៅទីកន្លែងព្យាបាល នៅទីក្រុងសៀមរាប ប្រទេសកម្ពុជា យើងអាចទៅរកសិល្បៈករប្រចាំតំបន់ អោយគេរចនាបង្ហាញបេសកកម្មមន្ទីរពេទ្យព្យាបាលរបស់យើងជាទីព្យាបាលឥទ្ធិពលអំពើឃោរឃៅ។ សិល្បៈរចនានេះ ពុំបានដឹងឮពីមុនមកដោយបុគ្គលិកខ្មែរនៅមន្ទីរពេទ្យព្យាបាលឡើយ។ អ្នកណែនាំទេសចរណ៍នៅជិតប្រាសាទអង្គរវត្តបានចង្អុលបង្ហាញប្រាប់យើងនូវចម្លាក់គំនូរទាំងឡាយអំពីទិដ្ឋភាពការព្យាបាល ជាពិសេសនៅលើប្រាសាទបាយន្តនៅចុង សតវត្សទីដប់ពីរ និងដប់បី។ នៅលើចម្លាក់ថ្មមានអ្នកជម្ងឺម្នាក់ជាក្រុមគ្រួសារអភិជន (ថ្លៃថ្នូរ) ម្នាក់កំពុងតែសំរាកនៅលើខ្នើយធំមួយ នៅខណៈដែលគេបានទទួលវិធីសម្រាលភាពឈឺចាប់ ដោយអ្នកព្យាបាលម្នាក់ដែលបានដាក់ដៃគាត់នៅលើក្បាលអ្នកជម្ងឺនោះ។ រូបភាព និងទីកន្លែងរូបចម្លាក់នេះ នៅក្នុងពេលបច្ចុប្បន្ននេះ បានចែកចាយក្នុងចំណោមអ្នកជម្ងឺ និងបុគ្គលិកហើយបានក្លាយទៅជាវត្ថុដ៏គួរអោយចាប់អារម្មណ៍ ដែលជាមរតកសិល្បៈរបស់មន្ទីរសុខភាព ដែលបង្ហាញនូវសេចក្ដីយកចិត្តទុកដាក់ព្យាបាលរបស់បុព្វបុរស ខ្មែរសម័យបុរាណកាល ទៅលើការព្យាបាលអំពើឃោរឃៅ។

អំពើឃោរឃៅអាចបណ្ដាលអោយមានដំណើរការ គ្មានការគ្រោងទុកមុន កើតមានឡើងនៅលើទឹកដីចម្លែក ដូចគ្នា និង Philocteters យើងពុំមានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មទេ តែបានទទួលការបោះបង់ចោល និងបណ្ដេញចេញដោយសង្គមសូម្បីតែជនព្យាបាលជាវិជ្ជាជីវៈ អាចធ្វើអំពើយកចំណេញ និងបំពានមកលើរូបយើង។

ប៉ុន្តែពេលនេះ យើងដឹងនៅក្នុងរង្វង់កាយសម្បទា និងអារម្មណ៍របស់យើង យើងដឹងថាយើងមានឥទ្ធិពលដ៏ខ្លាំងក្លាដែលផុសចេញឡើង ដើម្បីរកភាពបញ្ចេញបង្ហាញ ដែលមានសមត្ថភាពព្យាបាលរបួសគ្រប់បែប។ របួសគ្មានស្នាមនៃអំពើឃោរឃៅ ពុំមែនជាភាពមានតែស្រមោលទៀតឡើយ ហើយដំណើរការព្យាបាលដែលមានតែជាស្រមោល ពេលនេះមានជាភស្តុតាងពិត។ នៅខណៈដែលការរកឃើញ ផ្នែកវិទ្យាសាស្ត្រថ្មីបានធ្វើឡើង គេនឹងបង្ហាញមហាឥទ្ធិពលព្យាបាល ដែលបានផ្ដើមធ្វើឡើងនៅក្នុងចំណោមមនុស្សលោក ជាយូរពេលមកហើយនោះ។ បើសិនជាសង្គមរៀនប្រើចំណេះដឹង ផ្នែកពិសោធន៍និយម ដោយពុំពឹង ផ្អែកទៅលើភាពប្រ ឌិតក្នុងសង្គម ហើយសារពត៌មានចំនួនពាក់កណ្ដាល សម័យទំនើបអាចក្លាយទៅជាសម័យដ៏រំភើបចិត្តមួយ ដោយសេចក្ដីភ័យខ្លាចទៅលើឥទ្ធិពលអំពើឃោរឃៅពុំមានទៀតឡើយ ហើយយើងអាចស្វាគមន៍បុគ្គលដែលស្នាក់អាស្រ័យបណ្ដោះអាសន្ននៅលើទឹកដីអំពើឃោរឃៅអោយត្រឡប់ចូលមកសហគមន៍របស់យើងវិញ។

# អវសានបទ (សេចក្ដីបញ្ចប់)

នៅឆ្នាំ១៩៩០ អព្ភូតហេតុមួយបានកើតឡើងនៅប្រទេសថៃ មេបញ្ជាការយោធាជាន់ខ្ពស់ រៀបចំ នឹងសម្រេចបញ្ជូនប្រជាជន ចំនួន១៦០,០០០នាក់ ចេញពីសាយធូ បុរស ស្ត្រី និងកុមារគ្រប់រូបចេញពីព្រំដែនកម្ពុជាថៃ ទៅទីផ្សេងៗទៀត ដែលមានសុវត្ថិភាពជាងនេះ ឆ្ងាយពីការបាញ់គ្រាប់ផ្លោងរបស់ទ័ពវៀតណាម ទៅលើទ័ពឈ្លបកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ មានប្រផ្នូលមួយកើតមានឡើងទៅលើគម្រោងការណ៍នេះ។ វាលស្រែដែលគេបំរុងបញ្ជូនជនភៀសខ្លួន ទៅស្នាក់អាស្រ័យនោះលិចទឹកត្រឹមកជើង។ ពាក្យចរចាមអារាមបាននិយាយតៗ គ្នាពេញជុំរុំ បណ្ដាលអោយមានភាពតក់ស្លុតស្រឡាំងកាំងនៅក្នុងចំណោមប្រជាជន និងបុគ្គលិកសង្គ្រោះ។

ខ្ញុំបានឮពាក្យចរចាមអារាមនៅពេលដែល ខ្ញុំទៅបំពេញបេសកម្ម សុខភាពសតិអារម្មណ៍នៅក្នុងជុំរុំ ហើយបានផ្ញើរសារជាបន្ទាន់ទៅឧត្តមសេនីយថៃ ដែលជាអ្នកទទួលបន្ទុកចាត់ការ ឧត្តមសេនីយនេះ ជាបុគ្គលល្បីឈ្មោះថាកាចសាហាវ និងបំភ័យមនុស្ស ។ យើងបានពន្យល់គាត់អំពីសេចក្ដីបញ្ជាអោយប្ដូរកន្លែងនេះថា បើសិនជាអនុវត្តន៍ឡើង នឹងធ្វើអោយមានគ្រោះថ្នាក់ ដល់ប្រជាជនដែលរស់នៅក្នុងជុំរុំ ដោយការសង់ខ្ទមឬស្សីនៅលើដីភក់វាលស្រែរាតត្បាតដោយរោគគ្រុនចាញ់ ពិតជាធ្វើអោយមានផលវិបាក ដល់សុខភាពប្រជាជន។

បន្ទាប់ពីយើងបានបញ្ចេញសេចក្ដីទទូចអង្វរនេះ ឧត្តមសេនីយបានឆ្លើយតបដោយបង្ខំ និងកំហឹងខ្លះៗ មកយើងថា "ខ្ញុំដឹងថា អ្នកនឹងតវ៉ាទៅលើសេចក្ដីបញ្ជារបស់យើង ដោយចោទប្រកាន់រដ្ឋាភិបាលថៃថា បានប្រព្រឹត្តិឧក្រិដ្ឋកម្មរំលោភសិទ្ធិជនភៀសខ្លួនខ្មែរ។ ខ្ញុំជាឧត្តមសេនីយអគ្គបញ្ជាការទទួលខុសត្រូវ ផ្នែកសុវត្ថិភាពជាតិរបស់ប្រទេសថៃ ។ ពុំមែនជារូបអ្នកទេ ហើយខ្ញុំមិនខ្វល់អំពីអ្វីៗ ដែលអ្នកបាននិយាយឡើងទៅលើកម្មវត្ថុទាក់ទង នឹងអារម្មណ៍នេះទេ។ ហើយបើសិនជាអ្នកយករឿងនេះមកនិយាយជាមួយខ្ញុំជាបែបបទបញ្ញានយោបាយ ខ្ញុំនឹងចាប់អ្នកដាក់គុក និងដេញអ្នកចេញពីប្រទេសថៃភ្លាម ហើយមិនអនុញ្ញាតអោយអ្នកចូលមកវិញជាដាច់ខាត"។

យើងក៏បានដឹងថា សេចក្ដីឆ្លើយតបរបស់ប្រទេសថៃ ទៅនឹងសេចក្ដីតវ៉ាដែលធ្វើឡើងដោយ ផ្អែកលើកលែងទោសជាសាធារណៈ គឺប្រទេសថៃ បានបញ្ជូនអង្គការទាំងនោះចេញពីប្រទេសគេដោយបង្ខំ ហើយមិនអនុញ្ញាត អោយអង្គការទាំងនោះត្រឡប់ចូលមកវិញឡើយ។ ឧត្តមសេនីយនេះក៏បន្តទៀតថា "នៅក្នុងពេលនេះយ៉ាងណាមិញ ដោយអ្នកបានយករឿងសុខភាពមកតវ៉ាប្រឆាំង នឹងបទបញ្ជារបស់ខ្ញុំ ខ្ញុំនឹងគោរពតាមហើយលប់ចោលបទបញ្ជារបស់ខ្ញុំវិញ។ រូបអ្នកជាគ្រូពេទ្យ ហើយអ្នកដឹងនូវអ្វីៗ ជាភាពល្អសម្រាប់សុខភាពរបស់ប្រជាជននៅក្នុងជុំរុំ ខ្ញុំជានាយយោធាពុំមែនជាវេជ្ជបណ្ឌិតទេ។ ខ្ញុំដឹងតែអ្វីៗ ជាភាពប្រសើរបំផុតសម្រាប់សុវត្ថិភាព និងការពារប្រទេសថៃ និងប្រជាជនរបស់ថៃ"។

នៅក្នុងថ្ងៃនោះករណីនេះ បានស្រោចស្រង់ជីវិតប្រជាជនរាប់ពាន់នាក់ ជាច្រើនឆ្នាំក្រោយមកទៀត ខ្ញុំក៏បានជួប នឹងជនមានមុខតំណែង ផ្នែកនយោបាយជាន់ខ្ពស់ជាច្រើនរូបទៀត ជាអ្នកធ្វើការសម្រេចទៅលើកិច្ចការ

ដែលប៉ះទង្គិចខ្លាំងទៅលើសតិអារម្មណ៍របស់ជនជួបប្រទះភាពតក់ស្លុត។ អ្នកសម្រេចច្បាប់ទាំងនេះ ច្រើនតែធ្វើការសម្រេចដោយរូបខ្លួនគេ ឬក្រុមគ្រួសាររបស់ខ្លួនគេបានទទួលរងទុក្ខចិត្តសាស្ត្រដោយលទ្ធផលអំពើឃោរឃៅ។ គេដឹងអំពីភាពស្មុគ្រស្មាញរឿងតក់ស្លុតដោយផ្ទាល់ខ្លួន ហើយបានទទួលការជម្រុញចិត្តអោយយកចិត្តទុកដាក់ ទៅលើសារ បណ្តាំទាំងនេះ។

ប៉ុន្តែ ជនជួបប្រទះភាពតក់ស្លុត ពុំអាចពឹងផ្អែកទៅលើអព្ភូតហេតុនយោបាយ ដើម្បីសម្រាលសេចក្តីឈឺចាប់របស់គេបានឡើយ ដូចជា ប្រទេសជាតិយើងទាំងមូលបានឃើញដោយផ្ទាល់ភ្នែក នៅគ្រាដែលមនុស្សស្លាប់ដោយគ្រោះខ្យល់កំបុតត្បូង លិចផ្លូវ នៅទីក្រុងនូវអ័កលីន New Orlean ។ ភាពកែទម្រង់សង្គម ពុំត្រឹមតែត្រូវការសេចក្តី អនុវត្តន៍ច្បាស់លាស់របស់អ្នកដឹកនាំ តែប៉ុណ្ណោះឡើយ តែក៏ត្រូវការភាពផ្លាស់ប្តូរជាទូទៅ ទាំងឥរិយាបទ និងទម្លាប់។ ដោយអ្នកដឹកនាំឃ្លាតឆ្ងាយពីជីវិតរស់នៅពិតរបស់ប្រជាជន អ្នកប្រលូកក្នុងនយោបាយនៅតែពុំយកចិត្តដាក់ទៅលើឫសគ្មានស្នាមនៃអំពើឃោរឃៅ ហើយបដិសេធផលប្រយោជន៍សង្គម ដែលអាចកើនឡើងដោយគតិបណ្ឌិតរបស់ជនរួចផុតពីសេចក្តីស្លាប់។ ជនជួបប្រទះភាពតក់ស្លុតជាច្រើននាក់ រួមទាំងញាតិសន្តានមិត្តភក្តិ និងអ្នកជំនួយរបស់គេ បានបោះបង់សេចក្តីសង្ឃឹមក្នុងការចាត់ទុកសង្គមជាឥទ្ធិពលព្យាបាលដោយអ្នកដឹកនាំ នៅតែសោះអង្គើយ និងរិះគន់ទៅលើរូបគេ។ នៅឡើយភាពទុទិដ្ឋិនិយម(ឃើញតែផលវិបាក)បែបនេះត្រូវតែរកវិធីដោះស្រាយ ហើយភាពផ្លាស់ប្តូរសង្គមត្រូវតែអនុវត្តន៍ឡើង ដោអំពើឃោរឃៅកើតមានឡើងសកលលោកបានសេចក្តីថា សហគមន៍ទាំងអស់ត្រូវដោះស្រាយទៅលើពិភពសាហាវ ដែលផ្តល់ឱកាសតិចតួចសម្រាប់សុវត្ថិភាព។

នៅកម្រិតការព្យាបាលដែលធ្វើឡើង រវាងជនរួចផុតពីសេចក្តីស្លាប់ និងអ្នកព្យាបាល វាជាភាពកែទម្រង់ដែលមានភាពរីកចំរើនល្អ។ ជនរងគ្រោះដោយអំពើឃោរឃៅបានបង្ហាញអោយឃើញថា គេអាចគាន់បើឡើងក្រោយពីរូបគេទទួលការឈឺចាប់ ហើយលទ្ធផលល្អ នៃការព្យាបាលនេះ បានទទួលការបញ្ជាក់ត្រឹមត្រូវ ដោយអ្នកវិទ្យាសាស្ត្រ។ សម័យកាលបុព្វបុរសបាញ់ព្រួញប្រទេសក្រិច Philoctetes ត្រូវនិរទេសខ្លួនទៅកោះLemnos គឺដោយសេចក្តីឈឺចាប់របស់គាត់ពុំអាចផ្លាស់ប្តូរបាន ហើយឈានដល់ទីបញ្ចប់។ សម័យកាលថ្មី ចាប់ផ្តើមផុសចេញឡើង ដោយទម្លាប់ប្រព័ន្ធ វិជ្ជាពេទ្យបុរាណ ភ្ជាប់បន្តសហការជាមួយភាពព្យាបាលដោយខ្លួនឯងរបស់ជនជួបប្រទះភាពតក់ស្លុត។

មានសំណួរសាមញ្ញ ចំនួនបួនដែលសង្ខេបភាពកែទម្រង់ព្យាបាលនេះ ដោយផ្តល់សេចក្តីណែនាំ ក្នុងការប្រមាណមើលកម្រិត នៃការព្យាបាលដោយខ្លួនឯងនៅក្នុងបុគ្គលម្នាក់។ សមាជិកគ្រួសារជួយបងប្អូនដែលទទួលរងគ្រោះដោយអំពើរំលោភបំពានផ្លូវភេទ ឪពុកម្តាយថែទាំកូនដែលមានបញ្ហា ជនរត់រកទីជម្រកដោយបញ្ហានយោបាយ ជួយប្តីប្រពន្ធដែលរងទារុណកម្ម វេជ្ជបណ្ឌិតពិនិត្យអ្នកជម្ងឺតក់ស្លុត អាចសួរសំណួរសាមញ្ញទាំងនេះ។ ចម្លើយបង្ហាញនូវអ្វីៗ ដែលបានធ្វើឡើង និងអ្វីៗ ដែលនៅតែត្រូវការធ្វើឡើងនៅក្នុងដំណើរការភាពជាសះស្បើយ សំណួរគឺ ៖

១. តើព្រឹត្តិការណ៍តក់ស្លុតអ្វីខ្លះបានកើតឡើង?

២. តើកាយសម្បទា និងសតិអារម្មណ៍របស់អ្នកព្យាបាលរបួសដែលបណ្តាលឡើងដោយព្រឹត្តិការណ៍នោះ បែបណាដែរ?

៣. តើអ្នកបានធ្វើអ្វីខ្លះក្នុងជីវិតជារៀងរាល់ថ្ងៃ ដើម្បីជួយខ្លួនឯងអោយជាសះស្បើយ?

៤. តើយុត្តិធម៌បែបណាដែលអ្នកត្រូវការពីសង្គម ដើម្បីជួយគាំទ្រភាពព្យាបាលផ្ទាល់ខ្លួនរបស់អ្នក?

ខ្ញុំបានបង្រៀនអ្នកវិជ្ជាជីវៈសុខភាពសតិអារម្មណ៍ និងអ្នកផ្តល់ឱវាទប្រធានបទអំពីរបៀបប្រើសំណួរទាំងនេះ នៅក្នុងការសម្ភាសន៍។ ដំណើរការនេះបានជួយគេសម្រេចផលប្រយោជន៍ឥទ្ធិពលព្យាបាលដោយខ្លួនឯង នៅក្នុងកិច្ចការរបស់គេ។ ជនជួបប្រទះភាពតក់ស្លុត ក៏អាចទទួលផលប្រយោជន៍នៅក្នុងការព្យាយាមភាពជាសះស្បើយរបស់ខ្លួន ដោយឆ្លើយតប ទៅនឹងសេចក្តីស្នើសុំទាំងនេះគ្មានលំអៀង សរសេរចម្លើយ អានសេចក្តីឆ្លើយតបឡើងវិញ និងរៀបចំរូបមន្ត គម្រោងភាពជាសះស្បើយសម្រាប់ខ្លួនឯង។ ខ្ញុំបានឃើញភាពសញ្ជឹងគិតអំពីខ្លួន កើតទៅជាភាពភាវនាជាប្រចាំថ្ងៃ ដែលធ្វើអោយសុខភាពគ្រាន់បើឡើង បន្ថយភាពអស់សង្ឃឹម និងស្តារអោយមានអារម្មណ៍ថា ខ្លួនអាចគ្រប់គ្រងអនុស្សាវរីយតក់ស្លុត និងអារម្មណ៍ទោរទន់បាន។

សេចក្តីភ័យខ្លាចរបស់អ្នកព្យាបាល ដូចបានបង្ហាញឡើងថាមានឥទ្ធិពលខ្លាំងនៅក្នុងភាព *ផ្លាស់ប្តូររាង្គកាយ*របស់លោក Raphael ដែលបញ្ជាក់ថានៅតែត្រូវការវិធីដោះស្រាយ និងបំបាត់ទុក្ខ។ ផ្ទុយនឹងភស្តុតាងច្បាស់លាស់ផ្នែកជីវសាស្ត្រ និងផ្នែកវិទ្យាសាស្ត្រ ដូចបញ្ជាក់បន្ថែមទៅលើឥទ្ធិពលព្យាបាលដោយខ្លួនឯង ដែលផ្តល់ភាពមានៈផ្ទាល់ខ្លួន ឯករាជ្យភាព និងលទ្ធផលដែលវេជ្ជបណ្ឌិតជាច្រើនរូបនៅតែបន្តមានអារម្មណ៍ថា អ្នករួចផុតពីសេចក្តីស្លាប់ពុំអាចជួយអោយគ្រាន់បើឡើងវិញឡើយ។ សេចក្តីភ័យខ្លាចទៅលើអំពើឃោរឃៅនៅតែមានភាពខ្លាំងក្លាដដែល ភាពបំភ្លេចសេចក្តីភ័យខ្លាចនេះ និងភាពបន្តដំណើរទៅមុខ គឺយោងទៅតាមសមត្ថភាពយល់ចិត្តរបស់មនុស្សលោកជាសកល។ សមត្ថភាពភ្ជាប់ទាក់ទង នឹងបណ្តាញនេះ អនុញ្ញាតអោយយើងជួយអ្នកផ្សេងៗទៀត នៅខណៈដែលគេឈានទៅកាន់ពិភពថ្មី ដែលសង្ឃឹមថាមានភាពប្រសើរឡើង។ ភាពយល់ចិត្តផ្តល់ឱកាសអោយយើងឃើញថា ជនតក់ស្លុតខ្លះៗ អាចត្រូវការការនិយាយ អ្នកខ្លះបានធ្វើការបដិសេធ ហើយនៅមានអ្នកខ្លះត្រូវការថ្នាំ ដើម្បីជួយសម្រួលចិត្ត។ ពិភពតក់ស្លុតពុំមែនជាភាពគ្មានប្រែប្រួលនោះឡើយ ហើយបានចារទុកជាអចិន្ត្រៃយ៍នៅក្នុងពិភពលំបាកវេទនាអតីតកាលនោះឡើយ វាកំពុងតែផ្លាស់ប្តូរ និងវិវឌ្ឍន៍យ៉ាងខ្លាំងក្លា។ គំនិតព្យាបាលបច្ចុប្បន្ន គឺព្យាយាមធ្វើអោយជីវិតដែល *ធ្លាប់តែ* មានភាពជាសះស្បើយឡើងវិញ ត្រូវតែផ្តោតអារម្មណ៍ទៅលើឥទ្ធិពលរបស់ខ្លួនទៅលើជីវិតដែលនឹងប្រែប្រួលប្រសើរឡើង។

សង្គម និងអ្នកព្យាបាលវិជ្ជាជីវៈ អាចចូលរួមចំណែក នៅក្នុងភាពផ្លាស់ប្តូរដ៏រំភើបមួយនេះ លោក ស្លូសូបានSlosoban វេជ្ជបណ្ឌិតពេទ្យជនជាតិស៊ែបៀន Serbian នៅស្រេប្រីនីកា Srebrenica ចាត់ទុកនិមិត្តរូប នៃចំណងចូលរួមនៅក្នុងដំណើរការភាពជាសះស្បើយនេះ តាមរយៈកិច្ចការរបស់គាត់ជាមួយ នឹងអ្នកជម៉ឺម៉ូស្លីម។ ជាច្រើនឆ្នាំបន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅហើយ នៅក្នុងឆ្នាំ១៩៩៥ មានតែអ្នកជម៉ឺម៉ូស្លីមប្រុសៗទេ ដែលមក

ព្យាបាលនៅមន្ទីរពេទ្យព្យាបាលស្រេប្រីនីកា Srebrenica ដែលតែងតែអមដំណើរដោយប៉ូលីសប្រដាប់អាវុធ។ ជាទូទៅនៅក្នុងសហគមន៍ម៉ូស្លីមគេភ័យខ្លាចថា រូបគេ នឹងទទួលការធ្វើបាប ឬបដិសេធដោយវេជ្ជបណ្ឌិតមន្ទីរពេទ្យព្យាបាល និងគិលានុបដ្ឋាកយិកាទាំងអស់ជាជនជាតិស៊ែប្រ Serb គ្រឹះស្ថសាសនា។ ចំពោះអ្នកភូមិជនជាតិស៊ែប្រ Serb គេចាត់ទុកថាជនជាតិស៊ែប្រ Serb នេះទទួលភាពពង្វក់ស្មារតីដោយអំពើសម្លាប់រង្គាលថ្មីៗនេះ ទោះជាគេពុំបានចូលរួមនៅក្នុងបុព្វហេតុ នោះក៏ដោយ។ ដើម្បីធ្វើអោយមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកភូមិម៉ូស្លីម លោក Slosoban បានដោះអាវពេទ្យចេញ ហើយអង្គុយនៅក្រោមន្ទីរពេទ្យព្យាបាល ពិសារកាហ្វេតាមសម្រួល។ ជាដំបូងប្រជាជនជាតិស៊ែប្រ Serbនៅក្នុងភូមិប្រមូលគ្នីគ្នាមកអង្គុយទទួលទានកាហ្វេជាមួយគាត់ ហើយចាប់ផ្តើមនិយាយគ្នា ជាទូទៅ គឺនិយាយត្អូញត្អែរអំពីបញ្ហាសុខភាព។ តែនៅថ្ងៃមួយនោះ លោកបានទទួលជោគជ័យដោយស្ត្រីចំណាស់ម៉ូស្លីមម្នាក់បានមកជួប លោកនិយាយត្អូញត្អែរអំពីបញ្ហាសុខភាពរាង្គកាយរបស់គាត់។ អ្នកស្គាល់គ្នាជិតដិតជាជនជាតិស៊ែប្រ Serb បានតវ៉ាថា លោកពុំគួរជួយស្ត្រីនេះឡើយ ដោយស្ត្រីនេះជា "សត្រូវ" លោកក៏ឆ្លើយថា "ហេតុអ្វីបានជាអ្នកខ្លាចស្ត្រីចំណាស់បែបនេះ"? លោក Slosoban ក៏ជូនស្ត្រីនេះចូលមន្ទីរពេទ្យដើម្បីព្យាបាល។ ក្នុងករណីនេះវាជាភាពប្រែក្រឡាស់ទៅលើទំនាក់ទំនងរវាងមន្ទីរពេទ្យព្យាបាល និងសហគមន៍ម៉ូស្លីម។

គំនិតព្យាបាលដោយខ្លួនឯង តម្រូវអោយមានភាពបង្វែរចេញពីសេចក្តីយកចិត្តទុកដាក់ទៅលើរោគា និងភាពខូចខាតហើយបែរទៅរកភាពយល់ដឹង អំពីដំណើរការព្យាបាលធម្មជាតិវិញ។ អ្នកព្យាបាលសម័យទំនើប ក៏ដូចជា អ្នកព្យាបាលសម័យបុរាណកាល ប្រទេសក្រិចដែរ ត្រូវតែទទួលស្គាល់ថា មុខងាររបស់គេ គឺជួយជំរុញអានុភាពផ្ទៃក្នុងរបស់មនុស្សលោកអោយជាសះស្បើយពីរបួសកាយសម្បទា និងសតិអារម្មណ៍ ដែលបណ្តាលឡើងដោយសកម្មភាពឃោរឃៅ។ គោលសំខាន់នៃភាពព្យាបាលដោយខ្លួនឯង គឺសំអាងទៅលើភាពរឹងមាំ និងសុខុមាលភាព ជាកត្តាពិតប្រាកដ ដោយព្រោះតែមានការឆ្លើយតបទៅលើដំណើរការព្យាបាលដោយខ្លួនឯងនេះហើយ បានជាមានមនុស្សចំនួនតិចតួចកើតមានរោគសាស្ត្រ និងរោគរ៉ាំរ៉ៃ ដែលហៅថា រោគបាក់ស្បាតធ្ងន់ធ្ងរក្រោយពីបទពិសោធន៍ឃោរឃៅ។ នៅខណៈដែលផ្នែកឱសថសាស្ត្រ បានទទួលផលប្រយោជន៍ពីការសិក្សាយ៉ាងល្អិតល្អន់នៃដំណើរការសះស្បើយ ជាទូទៅរបួសរាង្គកាយ ដូច្នេះ វាក៏អាចទទួលផលប្រយោជន៍ប្រហាក់ប្រហែលគ្នាទៅលើដំណើរការជាសះស្បើយ ទូទៅជាមូលដ្ឋានភាពជាសះស្បើយរបួសគ្មានស្នាម។

ការយល់ដឹងអំពីដំណើរការនេះ តម្រូវអោយមានការយល់ដឹងទាំងស្រុងផ្សេងៗទៀត អំពីតយនាទីរបស់សង្គមទៅលើរឿងតក់ស្លុត។ ពិសពុលនៃរឿងតក់ស្លុត ដែលកើតឡើងដោយកត្តារន្ធត់ និងញាប់ញ័រអារម្មណ៍ ជាភាពចាប់អារម្មណ៍ខុសបែបបទរបស់អ្នកព្យាបាល ផ្នែកព័ត៌មាន និងចំណាប់អារម្មណ៍ជាសាធារណៈ។ ការនិយាយរឿងឃោរឃៅដោយបែបនេះជាភាពប្រថុយទទួលគ្រោះថ្នាក់ ពុំត្រឹមតែទៅលើជនរួចផុតពីសេចក្តីស្លាប់នោះទេ តែទៅលើសង្គមទាំងមូល។ សេចក្តីយកចិត្តទុកដាក់ខុសប្លែកពីធម្មតាអាចធ្វើអោយអ្នករួចផុតសេចក្តីស្លាប់ឈឺ និងបណ្តាល អោយភាពចងចាំព្រឹត្តិការណ៍តក់ស្លុតប្រែប្រួលពីលក្ខណៈធម្មតា ដូចជាបានបង្ហាញឡើង

ដោយទង្វើនឹកឃើញជានិច្ចរបស់សហគមន៍សិទ្ធិមនុស្សអន្តរជាតិទៅលើមហាផ្នូរសពនៅស្រេប្រីនីកា Sebrenica ជាជាងសេចក្តីចាប់អារម្មណ៍ទៅលើភាពផ្សះផ្សារ រវាងអ្នកជិតខាងបូស្សនាន Bosnian និងម៉ូស្លីម Muslim ផងដែរ ។ រូបភាព នៅលើកញ្ចក់ទូរទស្សន៍អំពីភាពមហន្តរាយអត់ទីជម្រករបស់ប្រជាជន រាប់ពាន់នាក់ នៅរដ្ឋលូអ៊ីហ្សាណា Louisiana ក្រោយពីព្យុះកំបុត្រត្បូងកាទ្រីណា Katrina នឹងសាបសូន្យបាត់ទៅ បន្ទាប់ពីពីរទៅបីខែក្រោយមក ដោយបន្សល់ទុកនៅតែរឿងដែលគេមិនបានដឹងអំពីប្រជាជន រាប់ពាន់នាក់ នៅទីក្រុងនីយអ័កលីន New Orleans បានតស៊ូកសាងទីលំនៅ និងការងារ ។ ជនរួចផុតពីសេចក្តីស្លាប់ទទួលអារម្មណ៍ថា រូបខ្លួនត្រូវគេកេងប្រវ័ញ្ច និងធ្វើអោយខូចចិត្តនៅពេលដែល សេចក្តីយកចិត្តទុកដាក់របស់សាធារណៈបានបង្វែរចេញ នៅគ្រាដែលសេចក្តីបារម្ភ ដែលបានបង្ហាញឡើងភ្លាមៗនោះ បានរសាយបាត់ទៅវិញបន្ទាប់ពីលទ្ធផលភាពមហន្តរាយរលត់បាត់ទៅ។

នៅករណី មានសេចក្តីឈឺចាប់របស់មនុស្សលោកកើតមានឡើង សេចក្តីបដិសេធរបស់សាធារណៈក៏មានភាពធំធេងក្រៃលែងដែរ។ ជាលទ្ធផលក្នុងនាមជាប្រជាជនទទួលខុសត្រូវក្នុងសង្គម យើងត្រូវតែសិក្សាអោយដឹងរឿងតក់ស្លុតច្បាស់លាស់ដែលអាចបង្រៀនយើងអំពីភាពរួចផុតពីសេចក្តីស្លាប់ និងភាពជាសះស្បើយ។ ការស្តាប់តម្រូវអោយមានភាពអប់រំ ភាពអត់ធ្មត់ ដើម្បីអោយយល់ដឹងលម្អិតអំពីព្រឹត្តិការណ៍សាហាវយង់ឃ្នង ទៅលើកម្រិតទំនាក់ទំនងក្នុងសាច់រឿងកាន់តែជ្រៅថែមទៀត។ ត្រូវមានភាពជំរុញទឹកចិត្ត ដើម្បីអោយមានចំណូលចិត្តគ្រប់គ្រាន់ក្នុងការចូលរួមទាក់ទងជាមួយ នឹងបុគ្គលដែលបានទទួលអំពើសាហាវយង់ឃ្នងនេះ ហើយទទួលយកជាតម្លៃថារឿងតក់ស្លុត និងជនរួចផុតពីសេចក្តីស្លាប់ជាគ្រូបង្រៀនដំបូង។ ខ្ញុំបានឃើញទូរទស្សន៍ជសាធារណៈនៅប្រទេសភេរ៉ូ Peru បង្រៀនអំពីភាពជាសះស្បើយ នៃអំពើឃោរឃៅទៅលើប្រជាជន រាប់រយពាន់នាក់ បានផ្សាយព្រឹត្តិការណ៍ដែលយោងទៅតាមសេចក្តីថ្លែងជាកស្សិណសាក្សីហេតុពិត នៃការប្រតិបត្តិឡើង។ ខ្ញុំបានឃើញការិយាល័យវេជ្ជបណ្ឌិត និងក្រសួងសង្គមនៅទីក្រុង Boston ប្តូរទៅជាថ្នាក់រៀនដោយមានអ្នករួចផុតទីសេចក្តីស្លាប់ធ្វើជាគ្រូបង្រៀន។ នៅពេលដែលអ្នកវិជ្ជាជីវៈសួរថា "តើអ្នកអាចប្រាប់ខ្ញុំថាអ្នកបានរៀនសូត្រអ្វីខ្លះ ពីបទពិសោធន៍របស់អ្នក? តើអ្នកផ្សេងទៀតដែលនៅក្នុងក្រុមគ្រួសាររបស់អ្នក និងសហគមន៍អាចរៀនសូត្រពីការយល់ដឹងផ្ទៃក្នុង និងការយល់ដឹងរបស់អ្នកបែបណាដែរ? ព័ត៌មានដ៏មានប្រយោជន៍បានបញ្ចេញយ៉ាងសន្ធឹកសន្ធាប់ពីអ្នករួចផុតពីសេចក្តីស្លាប់។ អ្នកទាំងនេះ បានធ្វើអោយសេចក្តីភ័យខ្លាចរបស់យើងដែលយល់ថា សេចក្តីឈឺចាប់រឿងតក់ស្លុត នឹងគ្មានទីបញ្ចប់ ហើយពុំអាចជួយបាននោះស្ងប់ស្ងាត់ទៅវិញ។

ការវិវឌ្ឍន៍បានបង្កើតជីវសាស្ត្រ ចាំបាច់ដល់សមាជិកទាំងអស់សម្រាប់បទពិសោធន៍ដំណើរជីវិត រួមទាំងភាពរួចផុតពីសេចក្តីស្លាប់រួមគ្នា និងសុខុមាលភាព។ វាជាភារកិច្ចសាធារណៈក្នុងការរៀនសូត្រអំពីអ្វីៗ ដែលជនជួបប្រទះភាពតក់ស្លុត អាចបង្ហាត់បង្រៀនដល់យើង ក៏ដូចជាសេចក្តីទទួលខុសត្រូវរបស់ជន ជួបប្រទះភាពតក់ស្លុត ទទូចសុំ ផ្តល់ការបង្រៀនដែរ។ ជនរួចផុតពីសេចក្តីស្លាប់ ទាមទាររកសេចក្តីទុកចិត្ត អ្នកដឹកនាំមានវិន័យ ភាពព្យាយាម សង្គ្រោះបន្ទាន់ប្រកបដោយប្រសិទ្ធិភាព និងជនមានអំណាចប្រកបដោយសេចក្តីទទួលខុស

ត្រូវ ដូចជា វេជ្ជបណ្ឌិត ដែលអាចផ្តល់សេចក្តីការពារ និងគាំទ្រ។ ករណីទាំងនេះរួមទាំងមេរៀនផ្សេងៗទៀត ដែលយើងអាចរៀនសូត្រពីជនសោកសង្រេង ជាករណីមួយដែលមិនអាចកាត់ថ្លៃបានឡើយ។

ជនជួបប្រទះភាពតក់ស្លុត ដែលរួចផុតពីសេចក្តីស្លាប់រំលឹកដល់យើងគ្រប់រូបអំពីភាពទន់ខ្សោយរបស់យើងទៅលើសោកនាដកម្ម និងសក្តានុពលដែលសង្គម អាចបំបោះបង់រូបយើងឡើយ យើងដឹងថាភាពមិនយកចិត្តទុកដាក់របស់សង្គមអាចធ្វើអោយប៉ះពាល់យ៉ាងខ្លាំង ដល់វាសនាជនជួបប្រទះភាពតក់ស្លុត ដែលរួបផុតពីសេចក្តីស្លាប់ មានកម្រិតច្រើនជាងរបួសដែលកើតឡើងដោយអំពើឃោរឃៅទៅទៀត។ ប៉ុន្តែ មានវិធីមួយទៀតដែលអាចធ្វើឡើងបាន នៅខណៈដែលរឿងរបស់ជនរងគ្រោះ ក្លាយទៅជារឿងលើកទឹកចិត្ត ហើយរឿងខូចខាតក្លាយទៅជារឿងជាសះស្បើយ។

នៅក្នុងសៀវភៅនេះ ខ្ញុំបានអបអរសាទរសមត្ថភាពមនុស្សលោក ដែលអាចពុះពារ និងព្រឹត្តិការណ៍ជីវិតដ៏មហាអស្ចារ្យក្នុងដំណើរជីវិត រួមទាំងបទពិសោធន៍តក់ស្លុត ជាទូទៅនៅក្នុងដំណើរជីវិតប្រចាំថ្ងៃ។ ភាពព្យាបាលដោយខ្លួនឯងបានរកឃើញ ពុំត្រឹមតែនៅក្នុងចំណោមជនរួចផុតបីសេចក្តីស្លាប់ដែលបានទទួលទារុណកម្ម ក្រុមគ្រួសារដែលបាត់ខ្លួន ជនភៀសខ្លួន ជនរងគ្រោះដោយភាពរញ្ជួយផែនដី និងអ្នកផ្សេងៗទៀត ដែលបានទទួលបទពិសោធន៍អំពើឃោរឃៅដ៏មហាអស្ចារ្យនោះទេ តែវាមាននៅក្នុងចំណោមយើងគ្រប់ៗរូប។ មនុស្សលោក នៅក្នុងវ័យដូចយើង ក៏ដូចជានៅក្នុងជំនាន់រាប់សតវត្ស បានបង្ហាញអានុភាពរបស់គេ ក្នុងការពុះពារទៅលើអំពើរំលោភបំពានមនុស្សលោក និងគ្រោះមហន្តរាយក្នុងជីវិត។ នៅឡើយសេចក្តីបង្ហាញភាពមានៈនេះ ក៏ធ្វើអោយរូបគេទទួលអំពើរំលោភបំពានគ្រប់បែបយ៉ាង ជាបែបបទទារុណកម្មសង្គម ដែលអនុវត្តន៍ឡើងដោយអំណាចជិះជាន់។ ឧក្រិដ្ឋជន នឹងបន្តវាយប្រហារអ្នកដែលប្រឆាំង នឹងគោលដៅរបស់គេ តែយើងត្រូវតែពុះពារព្យាយាមតទៅទៀត។

ខ្ញុំមានសុទិដ្ឋិនិយមភាពព្យាបាលដោយខ្លួនឯង របស់ជនជួបប្រទះភាពតក់ស្លុត បានកែរប្រែជាអចិន្ត្រៃយ៍ ហើយនឹងមិនកែត្រឡប់ទៅជាបែបបទអស់សង្ឃឹម ដែលបានអនុវត្តន៍ជារឿយៗថា ជាបែបបទការខូចខាតដែលផ្សព្វផ្សាយឡើងដោយជំនាន់មុនឡើយ។ ប៉ុន្តែ ពិភពសង្គមនៅក្នុងមជ្ឈដ្ឋានច្រើនឯទៀត នៅតែមានអំពើបំពាន ឬ នៅតែបង្កភាពប្រទូសរ៉ាយបន្ថែមទៀត ទៅលើគំនិតថ្មីទាំងនេះ ។ ដោយឪពុករបស់ខ្ញុំ គាត់ដឹងអំពីភាពពិតនេះ ទស្សនៈវិច្ឆ័យរបស់គាត់ ទៅលើភាពព្យាបាលដោយខ្លួនឯង បានបកស្រាយជាខ្លឹមសារនេះ ៖ " មើលភាពពិតអោយច្បាស់ តែកុំបោះបង់សេចក្តីស្រម៉ៃរបស់អ្នកអោយសោះ " ។



**Richard F. Mollica,** MD, MAR is a Professor of Psychiatry at Harvard Medical School and Director of the Harvard Program in Refugee Trauma (HPRT) at Massachusetts General Hospital. Since 1981, Dr. Mollica and HPRT have pioneered the medical and mental health care of survivors of mass violence and torture in the U.S. and abroad. Under Dr. Mollica's direction, HPRT conducts clinical, training, policy, and research activities for populations affected by mass violence around the world. Dr. Mollica is currently active in clinical work, research, and the development of a Global Health curriculum, focusing on trauma and recovery. The *Global Mental Health: Trauma and Recovery* certificate program is the first of its kind in global mental health and post-conflict/disaster. Dr. Mollica has published over 160 scientific manuscripts and has recently published his first book, "Healing Invisible Wounds: Paths to Hope and Recovery in a Violent World."

លោកវេជ្ជបណ្ឌិត និងអនុបណ្ឌិតផ្នែកសាសនា រិចឆឺដ អេហ្វ ម៉ូលីកា ជាសាស្រ្តាចារ្យផ្នែកចិត្តសាស្រ្តនៅសាកលវិទ្យាល័យវេជ្ជវិទ្យាហារ៉ឺដ(Harvard)និងជានាយកនៃកម្មវិធីហារ៉ឺដផ្នែកភាពតក់ស្លុតនៃជនភៀសខ្លួន (HPRT) នាមន្ទីរពេទ្យទូទៅនៃរដ្ឋម៉ាស្សាឈូសែ្សត(Massachusetts )។ ចាប់តាំងពីឆ្នាំ ១៩៨១ លោកវេជ្ជបណ្ឌិត ម៉ូលីកា (Mollica) និង HPRT
បានត្រួសត្រាយបើកផ្លូវបង្កើតកម្មវិធីថែទាំសុខភាពនិងសុខភាពផ្លូវចិត្តរបស់ជនរងគ្រោះដែលបានរស់រានមានជីវិតអំពីអំពើហឹង្សាមហិមានិងអំពីការទទួលរងទារុណកម្មនៅក្នុងសហរដ្ឋអាមេរិកនិងនៅបរទេស។
ក្រោមការដឹកនាំរបស់លោកវេជ្ជបណ្ឌិតម៉ូលីកា HPRTបានធ្វើសកម្មភាពជាច្រើនដូចជាព្យាបាលអ្នកជម្ងឺផ្ទាល់នៅក្នុងគ្លីនិក--បង្ហាត់បណ្ដុះ
បណ្ដាលនិស្សិតផ្នែកវេជ្ជវិទ្យា
រៀបចំគោលការនយោបាយនិងសិក្សាស្រាវជ្រាវរកវិធីសម្រាប់ជួយប្រជាជនដែលរងគ្រោះដោយអំពើហិង្សាមហិមានៅជុំវិញពិភពលោក។ បច្ចុប្បន្ននេះលោកវេជ្ជបណ្ឌិត ម៉ូលីកា(Mollica) បានធ្វើការយ៉ាងសកម្មក្នុងការព្យាបាលអ្នកជម្ងឺផ្ទាល់នៅក្នុងគ្លីនិក--បន្តធ្វើការស្រាវជ្រាវនិងធ្វើការអភិវឌ្ឍន៍កម្មវិធីសុខភាពផ្លូវចិត្តពិភពលោកដោយផ្តោតទៅលើភាពតក់ស្លុតនិងភាពសះស្បើយឡើងវិញ ។
កម្មវិធីសុខភាពផ្លូវចិត្តពិភពលោកដែលមានឈ្មោះថា:"កម្មវិធីវិញ្ញាប័នប័ត្រនៃភាពតក់ស្លុតនិងការសះស្បើយឡើងវិញ" គឺជាកម្មវិធីមួយដំបូងគេបំផុតខាងផ្នែកនេះក្នុងកម្មវិធីសុខភាពផ្លូវចិត្តពិភពលោកនិងភាពក្រោយមានការប៉ះទង្គិចឬក្រោយមានគ្រោះមហន្តរាយ។ លោកវេជ្ជបណ្ឌិត ម៉ូលីកា(Mollica) បានបោះពុម្ពផ្សាយ
សាត្រាវិទ្យាសាស្រ្តចំនួន១៦០ច្បាប់និងថ្មីៗនេះលោកបានបោះពុម្ពនូវសៀវភៅដំបូងបង្អស់មួយដែលមានចំណងជើងថា "ការព្យាបាលរបួសគ្មានស្នាម: ដំហ៊ានទៅកាន់សេចក្តីសង្ឃឹមនិងភាពសះស្បើយឡើងវិញនៅក្នុងពិភពលោកដ៏ឃោរឃៅ៉។



**Chanhum En-Hopson** was a high school teacher at Preah Yukunthor in Phnom Penh, Cambodia before the Cambodian Genocide began. She survived the work camps and subsequently came to America where she vowed to help as many Khmer children, women and families as possible.Her commitment to the Khmer community is clearly demonstrated through her efforts to address education gaps amongst Khmer high school youth and to connect Khmer families to health education resources in Long Beach, the largest Cambodian community outside Cambodia. She co-founded the Khmer Parent Association (KPA) with her husband, Mark Hopson, in 1995 and worked tirelessly with underachieving, at-risk youth. Her work as a champion of education earned her the State of California 2016 Woman of the Year Award from Assembly member Patrick O'Donnell, 70th District.

លោកស្សីឥន្ទ-ហប់សុន៑ ចន្៑ទហុ៑ំជាសាស្រ្សា៣ ចារ្យលៅវទ្យិ ៣ល័យព្រះយុគន្ទ្រ
រាជធាន៑ីភុ៑ំនលរញ ព្យលទ្សេកម្ុពជា
ម្ុន្លរលការ្សល័យរូជសាសន៑៍ខ្មែរ្សាន្ទាប់ល្៑ើ៣ម្។ លោកស្សីបាន្រ៉ូរាន្នាន្ទីវតិ លចញ្ជួ្វជំរ៉ូ លកម្ពែ ៍ធូន៑់ធូរ៑
លហើយបាន្លភ៑ៀសមលន្ទដល់ព្យលទ្សអាលម្រ៉ិ ជាទ្សឹកដីខ្ពលលោកស្សីបាន្សន៑៣ថាន៑ឹងជួយបណា ះបណ្ដា លអប់រ៑ំ ូុ
កុមារាកុមារ្ី ិងព្ពួសាស្សែ្រមាន្ទីវតិ ចំលរ្ើ្រ លរ៑ឿងល ើងវញ្ញិ លៅតាមល្ទ្សធភារខ្ពលអាចលធ្៑ើវបាន៑។
ការ្លបាជា៣ ចិតាដ៏ម្ុះម្ុតលដើម្បជឺ ួយដល់សហគម្ន៑៍ខ្មែរ្លន៑ះបាន្សង្ហា ញឱ្យល ើញយ៉ា ងជាក់ចាស់
តាម្រ្យៈការ្ពិតម៉ំព្យឹងខ្សួងតស្ូ៊វអស់ពីដួងចិតាចំល ះការ្ល ះស្សាយបញ្ហា គមាល តនន្តុណភារខាងវសិ ័យ អប់រ៉ំ
ុនងចំលណ្ដមសិស្សវទ្យិ ៣ល័យខ្មែរ៑។លហើយន៑ិងភា៣ ប់ព្ពួសារ្សែរ្លៅន៑ឹងផ្ខាន្ខាងវសិ ័យអប់រ៉ំ ុមភារលៅ ទ្សីព្ពុង
ុងបិចខ្ពលមាន្សជាជន្ទែរ្សលៅលព្ងេន្ទាងលគប់ុតលព្៑ៅព្យលទ្សេកម្ុពជា។លោកស្សីបាន្សលងើកតសមា គម្មាតាបិតាខ្មែរ៑ (KPA)ជាម្ួយសារ ម្ីនាម្ហា៉៣ រ៉ុ-ហប់សន្ទុនងឆ្ន ំ១៩៩៥។លោកស្សីមិតម៉ំលធ្៑ើវការ៉ុងនងងទ់ងយប់
លយម្ិន្ទាលចការ្លន៑ឿយហត់លដើម្បជឺួយយុវជន្ទែរ្សលមាន្ទំលណៈទបជាងគប៉ិនន្ទានក់រ្សស់ម្ួលន្សលរ៑ៀន្សាន្ទ្រ ខ្ពល ើងវញ្ញិ
។កុនងការ្សរ្សស់លោកស្សីខ្ពលជាអនកលងើងឯកខាងវសិ ័យអប់រ៉ំ ន៑ះបាន្សណ្ដា លឱ្យលោកសមាជិក សភាបា៉៣ ព្យិក
អូដូណល់នន្ទំបន៑់ទ្សី៧០ជូន្ទ្ូវ ន្ទ្រ្ូវ ន៑់ដ៏មពាស់ដល់លោកស្សីថាជាស្រ្សីងា ៍ល្៑ើនម្សួចាំឆ្ន ំ២០១៦កុនង តំបន៑់ទ្សី៧០
រ្ដូបកាលីហ៊ូ ន៑ីញ៉ា ។



**Sambo Ly** is a Refugee/Genocide Survivor. She has worked as a Medical Interpreter from 1979-1981 in a Refugee Camp in Thailand and the Philippines. She resettled to the U.S. in 1981 and earned her BA in Computer Science. She has led various trainings in the following areas: medical interpreter, health care interpreter, community interpreter, and done many train the trainer. She is currently a CCHI National Interpreter, and, in addition to her work at AHS, she is a Qualified Bilingual Staff Faculty member at Kaiser. She served as a Consultant and freelance interpreter/translator with the U.S. District Attorney Office, Alameda County Social Services, and other companies, providing translation and transcription services of legal documentation from Khmer/English. She has years of experiences in voice talent, translation and transcription. She has worked at Alameda Health System since 1987 and served as a Medical Interpreter from 1987-1990, was promoted to Manager of the Refugee Health Program and since 2005 has been the Manager for Interpreter Service/ Refugee Health Program. She has also written an autobiography titled, All I Heard Was My Sorrow, published in 2014.

អ្នកនាង លីសំបូរ ជនភៀសខ្លួន បានរស់រានមានជីវិតពីរបបវាលពិឃាតប៉ុលពត។
អ្នកនាងបានប្រកបការងារជាអ្នកបកប្រែភាសាអង់គ្លេសខ្មែរ នៅជំរំជនភៀសខ្លួនប្រទេសថៃ និងប្រទេសហ្វីលីពីន ក្នុងឆ្នាំ១៩៧៩ ទៅដល់ឆ្នាំ១៩៨១។ អ្នកនាងបានមករស់នៅសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៨១ ហើយបានទទួលបរិញ្ញាប័ត្រផ្នែកកុំព្យូទ័រ។ អ្នកនាងបង្រៀនកម្មវិធីហ្វឹកហ្វឺន បកប្រែភាសាផ្នែកសុខាភិបាល សហគមន៍ និងបង្វឹកគ្រូបង្ហាត់ជាច្រើននាក់ទៀត។ អ្នកនាងជាអ្នកបកប្រែភាសាជាតិផ្នែកសុខភាព ភាសាអង់គ្លេស ខ្មែរ។ អ្នកនាងជាសមាជិកបង្ហាត់ប្រព័ន្ធបណ្ដាយសុខភាពខៃហ្ស៊ែរ ផ្នែកបង្វឹកបុគ្គលិកទ្វេរភាសា។ អ្នកនាងបំពេញតួរនាទីជាទីប្រឹក្សា និងអ្នកបកប្រែភាសាផ្ទាល់មាត់/លាយល័ក្ខអក្សរ/ខ្សែអាត់/និតិច្បាប់ ប្រចាំក្រសួងសង្គមកិច្ច ក្រសួងអគ្គមេធាវីសហរដ្ឋអាមេរិក និងក្រុមហ៊ុននានា។ អ្នកនាងមានបទពិសោធជាច្រើនឆ្នាំផ្នែកបកប្រែភាសា និងសេវាសង្គមផ្សេងៗ។
អ្នកនាងចូលប្រកបការងារជាអ្នកបកប្រែភាសាក្រសួងសុខាភិបាលស្រុកអាឡាមីដា រដ្ឋកាលីហ្វ័នីញ៉ា ក្នុងឆ្នាំ១៩៨៧-១៩៩០។ នៅក្នុងឆ្នាំ២០០០អ្នកនាងបានទទួលមុខងារជានាយកចាត់ការផ្នែកក្រសួងសុខភាពជនកម្មវិធីភៀសខ្លួន។ នៅក្នុងឆ្នាំ២០០៦ បានទទួលការចាត់តាំងមុខងារបន្ថែមជានាយកចាត់ការក្រសួងបកប្រែភាសា។
បច្ចុប្បន្ននេះអ្នកនាងជានាយកចាត់ការក្រសួងសុខភាពកម្មវិធីជនភៀសខ្លួន និងក្រសួងបកប្រែភាសា
អ្នកនាងបានសរសេរសៀវភៅជីវប្រវត្តិផ្ទាល់ **របត់ជីវិតសោកា** All I Heard Was My Sorrow បោះពុម្ពជាផ្លូវការក្នុងឆ្នាំ២០១៤។



**Chamroeun Heng** was born and raised in Phnom Penh, Cambodia. He received his Bachelor of Arts degree in Molecular and Cell Biology at the University of California, Berkeley. He subsequently went on to work in research at the US Department of Agriculture in Albany, Ca. With a strong interest in Medicine, he decided to attend medical school at St George's University in Grenada where he received his Doctor of Medicine degree in 2014 and finished his Internal Medicine residency training at St Mary Medical Center in Long Beach in 2017. Currently, he practices hospital medicine at the Kaiser Foundation Hospital in Central Valley, California. He always takes a strong interest in education and community service. Dr. Chamroeun Heng has been involved in various local community programs that help struggling immigrant families and students of disadvantaged backgrounds. He is also a board member of the Khmer Parent Association (KPA) and of Cambodian Health Professionals Association of America (CHPAA).

លោកចំរើន ហេងកើតនិងធំឡើងនៅរាជធានីភ្នំពេញប្រទេសកម្ពុជា។
លោកបានទទួលសញ្ញាប័ត្របរិញ្ញាបត្រផ្នែកជីវវិទ្យាម៉ូលេគុលនិងជីវវិទ្យាកោសិកាពីសាកលវិទ្យាល័យកាលីហ្វ័រនីញ៉ាប៊ើឃេលី `រដ្ឋកាលីហ្វ័រនីញ៉ា។ដោយសារការផ្ដោតចិត្តដ៏ខ្លាំងទៅលើផ្នែកវេជ្ជសាស្ត្រ
លោកបានសម្រេចចិត្តបន្តការសិក្សារបស់លោកនៅសាលាវេជ្ជសាស្ត្រឯសាកលវិទ្យាល័យ St. George'sប្រទេសហ្គ្រេណែដា ហើយបានទទួលសញ្ញា
ប័ត្រជាវេជ្ជបណ្ឌិតនៅក្នុងឆ្នាំ២០១៤។ បន្ទមកទៀតលោកបានបញ្ចប់ការហាត់បណ្ដុះបណ្ដាលផ្នែកវេជ្ជសាស្ត្រ នៅមជ្ឈមណ្ឌលវេជ្ជសាស្ត្រសាំងម៉ារីនៅទីក្រុងឡុងប៊ិចក្នុង២០១៧។ នាពេលបច្ចុប្បន្ននេះ
លោកបានបំពេញមុខងារជាវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យ Kaiser Foundation នៅទីក្រុង Central Valley, រដ្ឋកាលីហ្វ័រនីញ៉ា។
វេជ្ជបណ្ឌិតហេង ចំរើនតែងតែយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអប់រំនិងសេវាកម្មសហគមន៍។
លោកបានចូលរួមក្នុងកម្មវិធីសហគមន៍ក្នុងស្រុកជាច្រើនជួយដល់គ្រួសារជនអន្តោប្រវេសន៍ដែលមានការជួបប្រទះនូវការលំបាកនិងសិស្សដែលមានប្រវត្តិខ្វះខាត។ លោកក៏ជាសមាជិកក្រុមប្រឹក្សាភិបាលនៃសមាគមមាតាបិតាខ្មែរ (KPA)និងនៃសមាគមសុខាភិបាលខ្មែរនៅអាមេរិក(CHPAA)ផងដែរ។



**Vattana Peong** is Executive Director of The Cambodian Family (TCF), a multiethnic human services agency, providing services to low-income children and families in Orange County. He has over 10 years of experience working with underserved communities both in the United States and abroad and is a strong advocate for health equity. He is bilingual in English and Khmer. Vattana has a B.A. in English for Translation and Interpretation from the Royal University of Phnom Penh and a Master Degree in Public Health from California State University, Fullerton.

វឌ្ឍនាពឹងជានាយកប្រតិបត្តិនៃមជ្ឈមណ្ឌលគ្រួសារខ្មែរដែលជាអង្គការផ្តល់សេវាកម្មដល់ពហុជាតិភាគតិចនិង
ផ្តល់សេវាកម្មដល់កុមារនិងគ្រួសារដែលមានប្រាក់ចំណូលទាបនៅទីប្រជុំសាន់តាអាណាតំបន់អូរិនសោនទី។
លោកមានបទពិសោធន៍ជាង១០ឆ្នាំសហការជាមួយសហគមន៍ដែលមិនទទួលបាននូវការឧបត្ថម្ភគ្រប់គ្រាន់
ទាំងនៅសហរដ្ឋអាមេរិកនិងនៅក្រៅប្រទេស ហើយជាអ្នកគាំទ្រយ៉ាងមាំមួនលើ
យុត្តិធម៌ផ្នែកសុខភាព។លោកមានចំណេះពីរភាសាគឺភាសាអង់គ្លេសនិងភាសាខ្មែរ។
លោកមានបញ្ញាប័ត្របរិញ្ញាបត្រផ្នែកភាសាអង់គ្លេសមានជំនាញការបកប្រែភាសាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិង
មានបញ្ញាប័ត្រអនុបណ្ឌិតផ្នែកសុខភាពសាធារណៈពីសាកលវិទ្យាល័យរដ្ឋកាលីហ្វ័រនីញ៉ាហ្វូលឺតុន(CSUF)។



**Cyrus K. Motakef,** is studying economics and chemistry at Colgate University and is a summer intern of Harvard Program in Refugee Trauma (HPRT) at Massachusetts General Hospital. Previously to working at HPRT, Cyrus worked at Newton-Wellesley Hospital in patient care of the Adult GI unit and competed in Club National Rowing. Since the summer of 2017, Cyrus has published a website with the accounts of Cambodian women during the Khmer Rouge and synthesized material for *Healing Invisible Wounds in Khmer*. During his time at St. Mark's School, Cyrus was an editor, writer and a managing director at the independent student run newspaper: The Parkman Post. He wrote mostly about geopolitical events and analyzed certain catalysts in the global economy.

លោកសៃរ៉ុស ខេ. ម៉ូតាខេហ្វ(Cyrus K.Motakef )
កំពុងសិក្សាផ្នែកសេដ្ឋកិច្ចនិងគីមីវិទ្យានៅសាកលវិទ្យាល័យ ខុលហ្គេត(Colgate )
និងជាអន្តេវាសិកនារដូវក្តៅក្នុងកម្មវិធីហាវើដ
(Harvard)ផ្នែកភាពតក់ស្លុតនៃជនភៀសខ្លួន(HPRT) នាមន្ទីរពេទ្យទូទៅនៃរដ្ឋម៉ាសាឈូសិត(Massachusetts)។
ពេលមុនមកធ្វើការនៅ HPRT, លោកសៃរ៉ុស(Cyrus )បានធ្វើការនៅមន្ទីរពេទ្យ
ញូវតុន-វែល្លិស្លី(Newton-Wellesley Hospital) ដើម្បីថែទាំអ្នកជម្ងឺពេញវ័យដែលកំពុងទទួល
ការព្យាបាលនៅក្នុងអង្គភាពជម្ងឺក្រពះពោះវៀន និងបានចូលប្រកួតប្រជែងនៅក្នុងក្លិបអុំទូកប្រណាំងថ្នាក់ជាតិ។
ចាប់តាំងពីរដូវក្តៅឆ្នាំ ២០១៧មក លោកសៃរ៉ុស(Cyrus)
បានចេញផ្សាយវេបសាយមួយជាមួយនឹងកំណត់ត្រារឿងរ៉ាវរបស់ស្ត្រីខ្មែរនាសម័យខ្មែរក្រហមនិងសំយោគឯកសារសម្រាប់សៀវភៅ
"ព្យាបាលរបួសគ្មានស្នាម" ជាភាសាខ្មែរ។ ក្នុងអំឡុងពេលលោកសិក្សានៅសាលាសាំងម៉ារក៍(St. Mark) លោកសៃរ៉ុស(Cyrus)
មានមុខងារជាអ្នកត្រួតពិនិត្យ អត្ថបទនានានិងជាអ្នកនិពន្ធ
ជានាយកគ្រប់គ្រងកាសែតឯករាជ្យមួយដែលមានដំណើរការដោយនិសិត្សឈ្មោះ"ដឺ ផារកម៉ាន់ប៉ុស្ត"(The Parkman Post )។
ភាគច្រើន
លោកសរសេរអំពីព្រឹត្តិការណ៍ភូមិសាស្ត្រនយោបាយនិងបានធ្វើការវិភាគទៅលើកាតាលីករមួយចំនួននៅក្នុងសេដ្ឋកិច្ចពិភពលោក។